# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**កម្រងឯកសារ**

**ថ្នាក់តំបន់ និង ថ្នាក់ជាតិ**

**ស្តីពី**

# ការរៀបចំផែនការយុទ្ធសាស្រ្តបែងចែកការប្រើប្រាស់តំបន់ឆ្នេរសមុទ្រ ដើម្បីគ្រប់គ្រងគ្រោះមហន្តរាយបរិស្ថានកំពុងកើតឡើង


ក្រសួងបរិស្ថាន

ខែកុម្ភៈ ឆ្នាំ២០១៣

UNEP

COBSEA
COORDINATING BODY ON THE SEAS OF EAST ASIA

Sida

# អារម្ភកថា

ព្រះរាជាណាចក្រកម្ពុជាមានផ្ទៃដីសរុបចំនួន ១៨១.០៣៥គ.ម[២] ដែលមានប្រជាជនជាង១៤លាននាក់ (គិតត្រឹមឆ្នាំ២០១២) និងមានតំបន់ឆ្នេរសមុទ្រលាតសន្ធឹងប្រវែង៤៣៥ គ.ម កាត់តាមខេត្តចំនួន៤គឺ **កំពត កែប ព្រះសីហនុ និង កោះកុង**។ តំបន់ឆ្នេរសមុទ្រកម្ពុជាសំបូរទៅដោយជីវចម្រុះ និងធនធានក្នុងទឹកជាច្រើនរួមមាន ដើមកោងកាង ផ្កាថ្មស្មៅសមុទ្រ មច្ឆា ក្តាម បង្គា និងប្រព័ន្ធអេកូស៊ីស្ទែមផ្សេងៗទៀតដែលផ្តល់នូវផលប្រយោជន៍ដ៏សំខាន់សម្រាប់ **ការពារច្រាំងសមុទ្រ ការពារជីវចម្រុះ ជាផ្លូវដឹកជញ្ជូនតាមវ៉ានា តំបន់លំហែកំសាន្ត និងទេសចរណ៍**។ល។ ក្រៅពីនេះ តំបន់ឆ្នេរសមុទ្រកម្ពុជាជាប្រភពធនធានរ៉ែដ៏សំខាន់សម្រាប់អភិវឌ្ឍន៏សេដ្ឋកិច្ចជាតិរួមមាន ប្រេងឥន្ធនៈ ហ្គាស អំបិល សម្ភារៈសំណង់ និងឱសថធម្មជាតិ។ល។ ព្រមទាំងជាតំបន់កំពង់ផែអន្តរជាតិដ៏សំខាន់ និងសកម្មសម្រាប់តភ្ជាប់បណ្តាញពាណិជ្ជកម្មជាមួយពិភពលោក និងជាប្រភពចំណូលសេដ្ឋកិច្ចជាតិ។ ជាងនេះទៅទៀត ឆ្នេរសមុទ្រកម្ពុជាជាកន្លែងទេសចរណ៍ដ៏ប្រណិត មានឆ្នេរខ្សាច់ពណ៌ស ខ្យល់អាកាសបរិសុទ្ធ និងបរិស្ថានដ៏ស្រស់បំព្រង ដោយហេតុនេះហើយទើបកាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១១ **ឆ្នេរសមុទ្រកម្ពុជាបានចូលជាក្លឹបឆ្នេរស្អាតជាងគេបំផុតលើសកលលោក**។

ទន្ទឹមនឹងនោះដែរនៅតំបន់ឆ្នេរសមុទ្រប្រទេសកម្ពុជាមានការអភិវឌ្ឍសេដ្ឋកិច្ចចេះតែកើនឡើង និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដូចជា ស្ពាន ផ្លូវ កំពង់ផែ ការដឹកជញ្ជូនតាមសមុទ្រ រោងចក្រកាត់ដេរ ផលិតផលអនុស្សាវរីយ៍ រោងចក្រថាមពលឥន្ធនៈ ផលិតកម្មកែច្នៃ និង ឧស្សាហកម្មខ្នាតតូច មជ្ឈមណ្ឌលទេសចរណ៍ និងសណ្ឋាគារ។ ជាការពិតណាស់រាល់ការអភិវឌ្ឍ និង សកម្មភាពវិនិយោគតែងតែគំរាមកំហែងដល់ធនធានធម្មជាតិ និងបរិស្ថានជាមិនខានប៉ុន្តែដើម្បីរក្សាកិត្តិស័ព្ទរបស់ខ្លួនថាជាឆ្នេរស្អាតបំផុតលើសកលលោកនោះ ប្រទេសកម្ពុជាបានខិតខំយ៉ាងសកម្ម និងមានការប្តេជ្ញាចិត្តខ្ពស់ដើម្បីប្រើប្រាស់ និងគ្រប់គ្រងធនធានទាំងនោះឱ្យមានចីរភាព និងភាពស្រស់បំព្រង។

ទោះបីជាយ៉ាងណាក៏ដោយ ប្រទេសកម្ពុជាក៏ដូចជាពិភពលោកផងដែរបាននិងកំពុងទទួលរងនូវផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយនានាមកលើជីវិតមនុស្ស សត្វ បរិស្ថាន សង្គម និងសេដ្ឋកិច្ចមិនត្រឹមតែមនុស្សជំនាន់បច្ចុប្បន្នប៉ុណ្ណោះទេថែមទាំងជំនាន់ក្រោយៗទៀតដែលទាមទារឱ្យធ្វើផែនការបន្សាំឱ្យបានទាន់ពេលវេលា។ ជាក់ស្តែងតំបន់ឆ្នេរសមុទ្រកម្ពុជាបានទទួលរងផលប៉ះពាល់នេះពីការប្រែប្រួលអាកាសធាតុដូចជា ការកើនឡើងកម្ពស់ទឹកសមុទ្រ និងកំដៅទឹកព្រមទាំងមានការកើនឡើងជាតិអាស៊ីត។ តាមការសិក្សាបង្ហាញថាប្រសិនបើកម្ពស់ទឹកសមុទ្រកើនឡើង១ម នោះផ្ទៃដីប្រហែលជាង២៥ពាន់ហិចតានៃតំបន់ឆ្នេរសមុទ្រខេត្តកោះកុងនឹងជន់លិច និងអាចឈានដល់៣៨ពាន់ហិចតាបើកម្ពស់ទឹកសមុទ្រកើនឡើង២ម (ពង្រាងរបាយការណ៍ SNC, ឆ្នាំ២០១០)។ ជាងនេះទៅទៀតការចាប់យកដី និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រដោយពុំមានផែនការច្បាស់លាស់ជាកត្តាមួយទៀតជម្រុញឱ្យប្រព័ន្ធអេកូស៊ីស្ទែមទាំងនោះកាន់តែទទួលរងនូវការសឹករេចរឹល និងឈានទៅរកការវិនាសហិនហោចយ៉ាងឆាប់រហ័ស។

ដោយមើលឃើញនូវគ្រោះមហន្តរាយទាំងនេះចេះតែកើនឡើងនៅតំបន់ឆ្នេរសមុទ្រ មិនថាតែប្រទេសកម្ពុជានោះទេ ប្រទេសមួយចំនួននៅក្នុងតំបន់អាស៊ីបូព៌ាក៏ទទួលរងនូវផលប៉ះពាល់អវិជ្ជមានដូចគ្នា ដូច្នេះហើយទើបគម្រោង "***ការធ្វើផែនការបែងចែកការប្រើប្រាស់តំបន់ឆ្នេរ-ការការពារ និងគ្រប់គ្រងគ្រោះមហន្តរាយ និងការអភិវឌ្ឍប្រកបដោយចីរភាព***" ត្រូវបានបង្កើតឡើងដោយលេខាធិការដ្ឋានអង្គភាពសម្របសម្រួលតំបន់សមុទ្រអាស៊ីបូព៌ា (COBSEA) និងបានផ្តល់ជំនួយថវិកាដោយទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសស៊ុយអែត(SIDA) អនុវត្តដោយកម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP) និងអង្គភាព COBSEA មានរយៈពេល៣ឆ្នាំចាប់ពីឆ្នាំ២០១០-២០១២ ដោយអនុវត្តន៍ក្នុងប្រទេសសមាជិក ចំនួន៦រួមមានៈ ***កម្ពុជា ចិន ឥណ្ឌូនេស៊ី ហ្វីលីពីន ថៃ និងវៀតណាម*** និងចែកចេញជា៣ដំណាក់កាលគឺៈ

១. **ដំណាក់កាលទី១:**ការបង្កើតនូវឯកសារគោលការណ៍ណែនាំនិងធនធានតំបន់( អនុវត្តន៍ដោយលេខាធិការ-ដ្ឋានអង្គភាពសម្របសម្រួលតំបន់សមុទ្រអាស៊ីបូព៌ា )

២. **ដំណាក់កាលទី២:** ការពិគ្រោះយោបល់ជាមួយប្រទេសសមាជិកអំពីតម្រូវការ និងអាទិភាពក្នុងការកសាងសមត្ថភាព និង ពីរបៀបថាតើត្រូវបញ្ជ្រាបឯកសារគោលការណ៍ណែនាំទៅក្នុងការអនុវត្តថ្នាក់ជាតិដោយរបៀបណា ( អនុវត្តន៍ដោយលេខាធិការដ្ឋាន "COBSEA" )និង

៣. **ដំណាក់កាលទី៣:** ការកសាងសមត្ថភាពបន្ទាំ និងការអនុវត្តគម្រោងសាកល្បងថ្នាក់ជាតិ ( អនុវត្តន៍ដោយប្រទេសជាសមាជិករបស់អង្គភាព "COBSEA" )

***កម្រងឯកសារនេះរៀបចំឡើងដើម្បីផ្តល់ឱ្យអ្នកសិក្សាស្រាវជ្រាវ និងអ្នកធ្វើសេចក្តីសម្រេចចិត្តយល់ដឹងនូវវិធីសាស្ត្រ និង ទស្សនទានថ្មីៗទាក់ទងនឹងការបែងចែកការប្រើប្រាស់តំបន់ឆ្នេរដើម្បីដោះស្រាយនឹងបញ្ហាដែលកំពុងកើតឡើងនៅតំបន់ឆ្នេរសមុទ្រកម្ពុជាដោយធានានូវកំណើនសេដ្ឋកិច្ច សុវត្ថិភាពសង្គម និងនិរន្តរភាពបរិស្ថាន។ ជាងនេះទៅទៀត កម្រងឯកសារនេះគឺជាការប្រមូលផ្តុំនូវឯកសារបរិធានច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ និងគោលការណ៍ណែនាំថ្នាក់តំបន់ និងថ្នាក់ជាតិទាក់ទងនឹងការរៀបចំផែនការបែងចែកការប្រើប្រាស់ដីតំបន់ឆ្នេរសមុទ្រ ការគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ។*** កម្រងឯកសារនេះចែកចេញជាពីរផ្នែករួមមានៈ

១. **ផ្នែកទី១** គឺការបកប្រែនូវកម្រងឯកសារថ្នាក់តំបន់ជាខេមរភាសាដែលមាន៥ជំពូកដូចខាងក្រោមៈ

***ជំពូកទី១*** គឺជាការណែនាំនូវគោលបំណង តើនរណាគួរប្រើប្រាស់វា, សមិទ្ធផលចុងក្រោយនៃដំណើរការកសាងផែនការប្រើប្រាស់តំបន់ឆ្នេរ ទស្សនទាន និងវិធីសាស្ត្រនានា

***ជំពូកទី២*** ដោះស្រាយនូវក្របខណ្ឌផែនការដែលមានស្រាប់ក្នុងតំបន់សមុទ្រអាស៊ីបូព៌ា

***ជំពូកទី៣*** ផ្តល់ការណែនាំនិងពិភាក្សាអំពីបញ្ហាដែលកំពុងកើតមានឡើង និងវិធីសាស្ត្រគ្រប់គ្រងថ្មីៗសំខាន់ៗមួយចំនួនដូចជា ការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែម ការគ្រប់គ្រងគ្រោះថ្នាក់ និងហានិភ័យ, ការប្រែប្រួលអាកាសធាតុ និងការកសាងផែនការប្រើប្រាស់ដីគោក និងសមុទ្រ។

***ជំពូកទី៤*** ផ្តល់ការណែនាំអំពីបែបបទកសាងផែនការថ្មីៗប្រៀបធៀបនឹងវិធីសាស្ត្រ" **ចាស់" (វិធីសាស្ត្រដែលបានអនុវត្តកន្លងមក)** និង

***ជំពូកទី៥***ផ្តល់នូវចក្ខុវិស័យមួយចំនួនក្នុងដំណើរការកសាងផែនការតំបន់ឆ្នេរសមុទ្រដើម្បីឱ្យអ្នកអានបានយល់ដឹងនូវវិធីសាស្ត្រមួយជំហានម្តងៗប្រកបដោយគតិបណ្ឌិត ការរៀបចំនូវផែនការប្រើប្រាស់តំបន់ឆ្នេរ ការវាយតម្លៃស្ថានភាពបច្ចុប្បន្ន ការធ្វើពង្រាងផែនការប្រើប្រាស់តំបន់ឆ្នេរ ដំណើរការចរចា និងការអនុវត្តផ្សេងៗ។ ផ្នែកនីមួយៗពិភាក្សាលើការអនុវត្តនូវវិធីសាស្ត្រផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែម ការបញ្ចូលគ្នានូវផែនការសម្រាប់ការប្រើដី និងសមុទ្រ ព្រមទាំងការកាត់បន្ថយហានិភ័យ និងដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។

**២. ផ្នែកទី២** គឺជាការប្រមូលផ្តុំ និងចងក្រងនូវឯកសារបរិធានច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រជាតិ ផែនការសកម្មភាពជាតិ និងគោលការណ៍ណែនាំដែលមានស្រាប់ទាក់ទងនឹងផែនការបែងចែកការប្រើប្រាស់តំបន់ឆ្នេរសមុទ្រ ការគ្រប់គ្រងគ្រោះមហន្តរាយធម្មជាតិ ការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងគ្រោះមហន្តរាយនានាបង្កឡើងដោយមនុស្ស និងកម្រងឯកសារបណ្តុះបណ្តាលថ្នាក់ជាតិ។ ផ្នែកនេះមាន៦ជំពូកសំខាន់ៗដូចខាងក្រោមៈ

***ជំពូកទី១*** ស្ថានភាពទូទៅនៃតំបន់ឆ្នេរសមុទ្រ ស្ថានភាពប្រជាជន មុខរបរ ស្ថានភាពសេដ្ឋកិច្ច និងសីតុណ្ហភាព

***ជំពូកទី២*** គោលនយោបាយ យុទ្ធសាស្ត្រ និងក្របខណ្ឌគតិយុត្តទាក់ទងនឹងការប្រើប្រាស់ និងការគ្រប់គ្រងតំបន់ឆ្នេរសមុទ្រដើម្បីដោះស្រាយគ្រោះមហន្តរាយបរិស្ថានកំពុងកើតឡើងតាមរយៈការផ្តល់ការណែនាំអំពីស្ថានភាព គោលនយោបាយ យុទ្ធសាស្ត្រ និងក្របខណ្ឌគតិយុត្តពាក់ព័ន្ធថ្នាក់ជាតិ និងអន្តរជាតិដើម្បីគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រប្រកបដោយនិរន្តរភាព។ ជាមួយគ្នានោះដែរ ជំពូកនេះបាននិយាយពីស្ថានភាពគម្រោងមួយចំនួនដែលបាន និងកំពុងអនុវត្តនៅតំបន់ឆ្នេរសមុទ្រ និងស្ថាប័នពាក់ព័ន្ធ និងណែនាំពីផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ វិធានការមួយចំនួនបានលើកឡើងដើម្បីដោះស្រាយទៅនឹងបាតុភូតទាំងនេះដូចជា ការរៀបចំយុទ្ធសាស្ត្រ និងគោលនយោបាយទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីគោលនយោបាយ និង ផែនការអភិវឌ្ឍន៍ជាតិ ការអនុវត្តផែនការសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការអនុវត្តគម្រោងនានា។ ជាមួយគ្នានោះដែរ ក៏បានលើកឡើងនូវវិធានការមួយចំនួនពាក់ព័ន្ធនឹងផែនការរៀបចំដែនដីដើម្បីគ្រប់គ្រង និងអភិវឌ្ឍដែនដីប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាព។ ក្នុងផ្នែកនេះក៏បានបញ្ចូលនូវបញ្ហាគ្រោះមហន្តរាយកំពុងកើតឡើង និងវិធានការដោះស្រាយនានានៅក្នុងប្រទេសកម្ពុជាដូចជា យុទ្ធសាស្ត្រ និងបរិធានច្បាប់មួយចំនួនព្រមទាំងវិធានការដោះស្រាយគ្រោះមហន្តរាយបណ្តាលមកពីការកំពប់ប្រេង។

***ជំពូកទី៣*** ករណីសិក្សាអំពីការបែងចែកចំណាត់ថ្នាក់តាមមុខងារនៃការប្រើប្រាស់តំបន់ឆ្នេរសមុទ្រនៅខេត្តព្រះសីហនុ ដោយបានលើកឡើងពីការបែងចែកតំបន់ប្រើប្រាស់ចំនួន១២តំបន់ ហើយតំបន់នីមួយៗមានគោលការណ៍ និងសកម្មភាពប្រើប្រាស់ពិសេសៗរៀងៗខ្លួន។ ករណីសិក្សានេះជាមូលដ្ឋានសម្រាប់ការធ្វើផែនការបែងចែកតំបន់ប្រើប្រាស់នៅទូទាំងតំបន់ឆ្នេរសមុទ្រប្រទេសកម្ពុជា។

***ជំពូកទី៤*** បច្ចេកស័ព្ទទាក់ទងនឹងគ្រោះមហន្តរាយតំបន់ឆ្នេរ និងសមុទ្រ និងផែនការប្រើប្រាស់សមុទ្រដោយលើកយកពាក្យបច្ចេកទេសសំខាន់ៗ និងទ្រឹស្តីមួយចំនួនដើម្បីឱ្យអ្នកអានងាយយល់ និងយកទៅប្រើប្រាស់បានត្រឹមត្រូវ ។

***ជំពូកទី៥*** កម្រងឯកសារបណ្តុះបណ្តាលថ្នាក់ជាតិ ស្តីពីការរៀបចំផែនការបែងចែកការប្រើប្រាស់តំបន់ឆ្នេរសមុទ្រដើម្បីដោះស្រាយទៅនឹងគ្រោះមហន្តរាយកំពុងកើតឡើង និងការប្រែប្រួលអាកាសធាតុ ។ និង

***ជំពូកទី៦*** លទ្ធផល និងបទពិសោធន៍ទទួលបានពីការអនុវត្តគម្រោង ។

ក្នុងនាមជាជនបង្គោលនៃអង្គភាពសម្របសម្រួលតំបន់សមុទ្រអាស៊ីបូព៌ា និងជាអគ្គនាយករងបច្ចេកទេស ក្រសួងបរិស្ថាន ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសស៊ុយអែត (SIDA) ដែលបានផ្តល់ថវិកាតាមរយៈកម្មវិធីបរិស្ថានសហប្រជាជាតិ(UNEP)និងអង្គភាពសម្របសម្រួលតំបន់សមុទ្រអាស៊ីបូព៌ា (COBSEA) ។ ជាពិសេសនោះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**ដែលបានណែនាំផ្តល់អនុសាសន៍ និងគាំទ្រក្នុងការរៀបចំកម្រងឯកសារដ៏មានសារៈសំខាន់នេះឡើងដោយឯកឧត្តមបណ្ឌិតបានផ្តល់នូវមាគ៌ាដឹកនាំដ៏ឈ្លាសវៃនិងប្រកបដោយភាពប៉ិនប្រសព្វក្នុងការគ្រប់គ្រងបរិស្ថាន និងអភិរក្សធនធានធម្ម-ជាតិ ជាពិសេសតំបន់ឆ្នេរសមុទ្ររហូតដល់ឆ្នេរសមុទ្រកម្ពុជាជាប់ឈ្មោះជា **ក្លឹបឆ្នេរស្អាតបំផុតលើសកលលោកនិងជាសាធារណៈនៅនិសនិរតី** ។

ជាមួយគ្នានេះដែរ ខ្ញុំសូមថ្លែងអំណរគុណដល់លោកបណ្ឌិត **ELLIK ADLER** អ្នកសម្របសម្រួលអង្គភាព **COBSEA** និងសហការីទាំងអស់ដែលបានជួយជ្រោមជ្រែង គាំទ្រ និងសហការយ៉ាងសកម្មក្នុងការរៀបចំកម្រងឯកសារនេះ ។ ខ្ញុំសូមអរគុណចំពោះឯកឧត្តមបណ្ឌិត **ម៉េង ប៊ុណ្ណារិទ្ធ** អគ្គលេខាធិការរងគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រប្រទេសកម្ពុជា និងជាប្រធាននាយកដ្ឋានគ្រប់គ្រងដែនដីនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ លោក **ស៊ុយ ឆា** ប្រធានមន្ទីរបរិស្ថានខេត្តកំពត លោក **ច្រាក់ វិសាល** នាយករងសាលាខេត្តព្រះសីហនុ លោក **ឈុន សីហា** អនុប្រធានការិយាល័យវាយតម្លៃភាពងាយរងគ្រោះ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុ ក្រសួងបរិស្ថាន និងលោក **លី រតនា** សាស្ត្រាចារ្យសាកលវិទ្យាល័យស្វាយរៀងដែលបានចូលរួមចំណែកក្នុងការរៀបចំកម្រងឯកសារនេះឡើង ។ ជាមួយគ្នានេះដែរ ខ្ញុំសូមថ្លែងអំណរគុណជាពិសេសដល់លោក **មារាក់ ម៉ៅ** អ្នកជំនាញការជាតិតំបន់ឆ្នេរសមុទ្រ និងជាប្រធានការិយាល័យវាយតម្លៃភាពងាយរងគ្រោះ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុ ក្រសួងបរិស្ថាន និងក្រុមការងារក្នុងការដឹកនាំ និងសម្របសម្រួលដើម្បីរៀបចំកម្រងឯកសារតំបន់ឆ្នេរសមុទ្រនេះឡើង ។

ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមការងារអន្តរក្រសួងនិងអ្នកពាក់ព័ន្ធទាំងអស់ដែលបានចូលរួមសហការគាំទ្រទាំងផ្នែកស្មារតីនិងបច្ចេកទេសក្នុងការរៀបចំកម្រងឯកសារដ៏មានសារៈសំខាន់នេះរហូតទទួលបានជោគជ័យ ។

ភ្នំពេញ ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៣ ។

**ភុច សុវាន**

ជនបង្គោលនៃអង្គភាពសម្របសម្រួលតំបន់សមុទ្រអាស៊ីបូព៌ា

និងជាអគ្គនាយករងបច្ចេកទេសនៃក្រសួងបរិស្ថាន

# មាតិកា

អារម្ភកថា........................................................................................................................................... I

ផ្នែកទី១: កម្រងឯកសារថ្នាក់តំបន់ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្របែងចែកការប្រើប្រាស់ឆ្នេរសមុទ្រតំបន់អាស៊ីបូព៌ាដើម្បីគ្រប់គ្រងគ្រោះមហន្តរាយបរិស្ថានកំពុងកើតឡើង .................................. 1

សេចក្តីថ្លែងអំណរគុណ........................................................................................................................... 2

សេចក្តីសង្ខេប....................................................................................................................................... 4

គោលបំណងនៃកម្រងឯកសារធនធាន ..................................................................................................... 6

អ្នកប្រើប្រាស់ឯកសារធនធាន ................................................................................................................ 7

លទ្ធផលទទួលបានពីដំណើរការរៀបចំផែនការប្រើប្រាស់តំបន់ឆ្នេរសមុទ្រ.................................................. 7

របៀបប្រើប្រាស់ឯកសារធនធានៈ ............................................................................................................ 9

ទំនាក់ទំនងរវាងផែនការនិងពេលវេលា.................................................................................................. 10

ជំពូកទី២: ក្របខណ្ឌ និង វិធីសាស្ត្រធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរក្នុងតំបន់សមុទ្រអាស៊ីបូពា .......... 11

ជំពូកទី៣ –បញ្ហាកំពុងកើតឡើង និងវិធីសាស្ត្រគ្រប់គ្រងថ្មីៗ............................................................ 17

ការគ្រប់គ្រងហានិភ័យ និង មុខព្បាគ្រោះថ្នាក់ និងការរៀបចំផែនការបែងចែកការប្រើប្រាស់តំបន់ឆ្នេរ24

ការប្រែប្រួលអាកាសធាតុៈ បញ្ហា និងការគំរាមកំហែងកំពុងកើតឡើង.................................................... 31

ការរៀបចំផែនការបែងចែកការប្រើប្រាស់ដី និងសមុទ្រ ........................................................................ 40

ការកសាងលំនៅដ្ឋានតាមតំបន់ឆ្នេរ (CSD)........................................................................................ 41

ការអភិវឌ្ឍឧស្សាហកម្មតំបន់ឆ្នេរទាក់ទងនឹងការអភិវឌ្ឍ កំពង់ផែនិង ការដឹកជញ្ជូនតាមកប៉ាល់ ....... 41

ភាពចាំបាច់ត្រូវធ្វើសមាហរណកម្មផែនការប្រើប្រាស់ដី និងសមុទ្រ .................................................... 42

ជំពូកទី៤ — គំរូរៀបចំផែនការថ្មី ........ 43

ជំពូកទី៥—ការអនុវត្តនូវទស្សនៈទានកំពុងតែលេចឡើងក្នុងដំណើរការរៀបចំផែនការប្រើប្រាស់តំបន់ឆ្នេរ (CSP) ........ 54

ដំហានទី១ — ការរៀបចំផែនការប្រើប្រាស់តំបន់ឆ្នេរ (CSP) ........ 54

បញ្ហាពាក់ព័ន្ធមួយចំនួននៅពេលអនុវត្តន៍វិធីសាស្ត្រផ្អែកលើប្រពន្ធអេកូស៊ីស្ទែម (EBA) ........ 58

ការរួមបញ្ចូលគ្នានូវការកាត់បន្ថយហានិភ័យ និងការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ ........ 60

បញ្ហាពាក់ព័ន្ធនឹងផែនការសមុទ្រ និងដីគោកចម្រុះ ........ 66

បញ្ហាពាក់ព័ន្ធនឹងការរួមបញ្ចូលនូវការកាត់បន្ថយហានិភ័យ និងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ........ 67

បញ្ហាពាក់ព័ន្ធមួយចំនួននៃការអនុវត្តវិធីសាស្ត្រផ្អែកលើអេកូស៊ីស្ទែម (EBA) ........ 72

បញ្ហាពាក់ព័ន្ធមួយចំនួននៃការកសាងផែនការសមុទ្រ និងដីគោកចម្រុះ ........ 73

បញ្ហាពាក់ព័ន្ធមួយចំនួននៃការកាត់បន្ថយគ្រោះមហន្តរាយ និការប្រែប្រួលអាកាសធាតុ ........ 74

បញ្ហាពាក់ព័ន្ធនៃការណែនាំគំរូការកសាងផែនការថ្មី ........ 79

បញ្ហាពាក់ព័ន្ធនៃការណែនាំនូវគំរូកសាងផែនការថ្មី ........ 82

ដំហានទី ២: ការវាយតម្លៃស្ថានភាពបច្ចុប្បន្ន ........ 85

ភាពខុសគ្នារវាងគំរូរៀបចំផែនការចាស់ និងថ្មី ........ 85

ទស្សនទានស្តីពីការវិភាគស្ថានភាពបច្ចុប្បន្ន ........ 86

បញ្ហាពាក់ព័ន្ធលើការអនុវត្តវិធីសាស្ត្រផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមដោយអនុវត្តន៍នូវផែនការសមុទ្រ និង ដីគោកចម្រុះ និងការបញ្ជ្រាបនូវការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុនៅក្នុងដំណាក់កាលទី២ ........ 102

ជំហានទី៣ ពង្រាងផែនការបែងចែកតំបន់ប្រើប្រាស់ ..... 107

បញ្ហាពាក់ព័ន្ធមួយចំនួនក្នុងការប្រើប្រាស់វិធីសាស្ត្រផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមដោយធ្វើផែនការរៀបចំដែនដីគោក និងសមុទ្រចម្រុះ និងការបញ្ជ្រាបការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុនៅក្នុងដំណាក់កាលទី៣ ..... 123

ជំហានទី ៤: ការចរចា ..... 126

បញ្ហាពាក់ព័ន្ធក្នុងការប្រើប្រាស់វិធីសាស្ត្រផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមដោយធ្វើផែនការរៀបចំដែនដីគោក និងសមុទ្រចម្រុះនិងការបញ្ជ្រាបការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុ ..... 132

ជំហានទី ៥: កម្មវិធីអនុវត្តន៍ ..... 133

គន្ថនិទ្ទេស និងប្រភព ..... 148

ឧបសម្ព័ន្ធទី ១: ឧបករណ៍សម្រាប់វាយតម្លៃមុខសញ្ញាគ្រោះថ្នាក់ និងហានិភ័យ ..... 156

ឧបសម័ន្ធទី ២: ការរួមបញ្ចូលការប្រើប្រាស់ដី និងសមុទ្រនៅក្នុងផែនការមួយ ..... 163

ឧបសម័ន្ធទី ៣: ការធ្វើការជាមួយភាគីពាក់ព័ន្ធ ..... 165

ឧបសម្ព័ន្ធទី ៤: ការផ្តល់នូវអនុសាសន៍មួយចំនួនសំរាប់រៀបចំឯកសារ ..... 167

ឧបសម្ព័ន្ធទី ៥ ..... 169

ឧបសម្ព័ន្ធទី ៧: ការវិភាគដំណើរការរៀបចំតំបន់ឆ្នេរ ការបែងចែកតំបន់ឆ្នេរទៅជា ' ក្រុមតូចៗ' ..... 180

ឧបសម្ព័ន្ធទី ៨: ការវាយតម្លៃសេវាកម្មប្រព័ន្ធអេកូស៊ីស្ទែម ..... 183

ឧបសម្ព័ន្ធទី ៩: គំរូមាតិកាសម្រាប់ផែនការបែងចែកតំបន់ប្រើប្រាស់ដី និងកម្មវិធីអនុវត្តន៍ ..... 194

ឧបសម្ព័ន្ធទី ១០: ការណែនាំដោយសង្ខេបនូវវិធីសាស្ត្រ បច្ចេកទេស និងជំនួយ ..... 197

ឧបសម្ព័ន្ធទី ១១: ការជ្រើសរើសយុទ្ធសាស្ត្រជាក់លាក់សំរាប់ច្រាំងសមុទ្រ ..... 201

ផ្នែកទី ២-កម្រងឯកសារជាតិស្តីពីការរៀបចំផែនការយុទ្ធសាស្ត្របែងចែកការប្រើប្រាស់តំបន់ឆ្នេរសមុទ្រ ដើម្បីគ្រប់គ្រងគ្រោះមហន្តរាយបរិស្ថានកំពុងកើតឡើង ........ 207

ជំពូកទី ១ៈ ស្ថានភាពទូទៅនៃតំបន់ឆ្នេរសមុទ្រប្រទេសកម្ពុជា ........ 208

ជំពូកទី ២ៈ គោលនយោបាយ យុទ្ធសាស្ត្រ និងក្របខណ្ឌគតិយុត្តិទាក់ទងនឹងការប្រើប្រាស់ និង គ្រប់គ្រង តំបន់ឆ្នេរសមុទ្រដើម្បីដោះស្រាយនឹងគ្រោះមហន្តរាយកំពុងកើតឡើង ........ 209

ទាក់ទងនឹងវិស័យបរិស្ថាន ........ 209

ទាក់ទងនឹងការងារប្រែប្រួលអាកាសធាតុ ........ 231

ទាក់ទងនឹងការងាររៀបចំដែនដី ........ 237

ទាក់ទងនឹងគ្រោះមហន្តរាយ ........ 247

ទាក់ទងនឹងកិច្ចការជំនួញសមុទ្រ និងការគ្រប់គ្រងឧបទ្ទវហេតុកំពប់ប្រេង ........ 257

ជំពូកទី ៣ៈ ករណីសិក្សាអំពីការបែងចែកចំណាត់ថ្នាក់តាមលក្ខណៈមុខងារនៃការប្រើប្រាស់តំបន់ឆ្នេរ នៅខេត្តព្រះសីហនុៈ ........ 263

ជំពូកទី ៤ៈ បច្ចេកសព្ទទាក់ទងនឹងគ្រោះមហន្តរាយ សមុទ្រ និងផែនការប្រើប្រាស់តំបន់ឆ្នេរសមុទ្រ 277

ឧបសម្ព័ន្ធទី ១ៈ តារាងសង្ខេបអំពីគោលនយោបាយ យុទ្ធសាស្ត្រ និងបទដ្ឋានគតិយុត្តទាក់ទងនឹង ការប្រើប្រាស់និងគ្រប់គ្រងតំបន់ឆ្នេរសមុទ្រប្រទេសកម្ពុជា ........ 296

ជំពូកទី ៥ៈ ឯកសារបណ្តុះបណ្តាលថ្នាក់ជាតិ ........ 311

ជំពូកទី ៦ លទ្ធផល និងបទពិសោធន៍ទទួលបានពីការអនុវត្តគម្រោង ........ 340

# ផ្នែកទី១

# កម្រងឯកសារថ្នាក់តំបន់ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្របែងចែកការប្រើប្រាស់ឆ្នេរសមុទ្រតំបន់អាស៊ីបូព៌ាដើម្បីគ្រប់គ្រងគ្រោះមហន្តរាយបរិស្ថានកំពុងកើតឡើង

# សេចក្តីថ្លែងអំណរគុណ

ការធ្វើផែនការបែងចែកតំបន់ប្រើប្រាស់គឺជាបទអន្តរាគមន៍ចម្រុះនិងមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទដើម្បីផ្តល់ឱ្យនូវតំបន់ដី និង សមុទ្រដែលមានតិចតួចសម្រាប់ការប្រើប្រាស់ក្នុងគោលបំណងផ្សេងៗដោយគិតគូរទៅលើតម្រូវការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងការការពារបរិស្ថាន។ គម្រោងផែនការបែងចែកតំបន់ប្រើប្រាស់នេះគឺជាវិធីសាស្ត្រមួយក្នុងចំណោមវិធីសាស្ត្រសំខាន់ៗសម្រាប់ការគ្រប់គងតំបន់ឆ្នេរ។

គម្រោង "***ការធ្វើផែនការបែងចែកការប្រើប្រាស់តំបន់ឆ្នេរ-ការការពារគ្រោះមហន្តរាយ និងការអភិវឌ្ឍប្រកបដោយចីរភាព***" បានបង្កើតដោយលេខាធិការដ្ឋានអង្គភាពសម្របសម្រួលតំបន់សមុទ្រអាស៊ីបូព៌ា (COBSEA) ជាគម្រោងមួយបង្កើតឡើងអំឡុងឆ្នាំ២០០៦ បន្ទាប់ពីទទួលរងផលប៉ះពាល់ដោយសាររលកយក្សស៊ូណាមិ និងដាក់ស្នើសុំឱ្យភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសស៊ុយអែត (SIDA) ពិនិត្យនិងសម្រេច។ នៅដើមឆ្នាំ២០០៩ គម្រោងត្រូវបានអនុម័តផ្តល់ជំនួយដោយអង្គការ SIDA អនុវត្តដោយកម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP) និង អង្គភាពសម្របសម្រួលតំបន់សមុទ្រអាស៊ីបូព៌ា (COBSEA) ចាប់ពីឆ្នាំ២០១០-២០១៣។

គោលបំណងរួមរបស់គម្រោងគឺដើម្បីកាត់បន្ថយ និងការពារផលប៉ះពាល់ពីគ្រោះមហន្តរាយធម្មជាតិ ការប្រែប្រួលអាកាសធាតុ និងការកើនឡើងកម្ពស់ទឹកសមុទ្រ និងដើម្បីជម្រុញការអភិវឌ្ឍតំបន់ឆ្នេរប្រកបដោយចីរភាពនៅក្នុងបណ្តាប្រទេសសមាជិករបស់អង្គភាព COBSEA តាមរយៈការអនុវត្តការកសាងផែនការបែងចែកតំបន់ប្រើប្រាស់សម្រាប់ការអនុវត្តការគ្រប់គ្រងតំបន់ឆ្នេរចម្រុះ (ICZM) និងការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែម (EBM)។ ដើម្បីសម្រេចបានគោលដៅនេះយើងត្រូវអនុវត្តនូវសកម្មភាពជាក់ស្តែងមួយចំនួនរួមមាន:

១. ការរៀបចំឯកសារគោលការណ៍ណែនាំ និងធនធានគោលនយោបាយតំបន់ស្តីពី "***ការរៀបចំផែនការបែងចែកការប្រើប្រាស់តំបន់ឆ្នេរនៅអាស៊ីបូព៌ា: ការបញ្ជ្រាបបញ្ហាកំពុងកើតឡើងនិងវិធីសាស្ត្រគ្រប់គ្រងថ្មីៗ*** "។

២. ការពង្រឹងសមត្ថភាពជាតិក្នុងការធ្វើផែនការតំបន់ឆ្នេរប្រកបដោយចីរភាពតាមរយៈការបញ្ជ្រាបឯកសារនេះទៅតាមតម្រូវការ និងសមត្ថភាពជាតិនៃប្រទេសសមាជិករបស់អង្គភាព COBSEA លើការធ្វើផែនការបែងចែកតំបន់ប្រើប្រាស់ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

៣. ការពង្រឹងសមត្ថភាពប្រទេសជាសមាជិកដើម្បីបញ្ជ្រាបគំនិតថ្មីៗដូចជាការប្រែប្រួលអាកាសធាតុការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែម ការកាត់បន្ថយគ្រោះមហន្តរាយ និងការធ្វើផែនការរៀបចំដី-សមុទ្រចម្រុះទៅក្នុងប្រព័ន្ធ និង នីតិវិធីរៀបចំផែនការបែងចែកតំបន់ជាតិដែលមានស្រាប់របស់ប្រទេសនីមួយៗ។ គម្រោងនេះមាន៣ដំណាក់កាលគឺ:

**ក. ដំណាក់កាលទី ១:** ការបង្កើតនូវឯកសារគោលការណ៍ណែនាំ និងធនធានតំបន់

**ខ. ដំណាក់កាលទី ២:** ការពិគ្រោះយោបល់ជាមួយប្រទេសចូលរួមអំពីតម្រូវការនិងអាទិភាព របស់ពួកគេក្នុងការកសាងសមត្ថភាព និង ការបញ្ជ្រាបឯកសារគោលការណ៍ណែនាំទៅក្នុង ការអនុវត្តថ្នាក់ជាតិ និង

**គ. ដំណាក់កាលទី ៣:** ការកសាងសមត្ថភាពបន្ទាំ និងការអនុវត្តគម្រោងសាកល្បងថ្នាក់ជាតិ

ឯកសារធនធានតំបន់ស្តីពី ***ការរៀបចំផែនការបែងចែកការប្រើប្រាស់តំបន់ឆ្នេរសមុទ្រអាស៊ីបូព៌ា: ការបញ្ជ្រាបបញ្ហាកំពុងកើតឡើងនិងវិធីសាស្ត្រគ្រប់គ្រងថ្មីៗ*** គឺជាសមិទ្ធិផលសំខាន់មួយក្នុងដំណាក់ទី១នៃគម្រោង។ ឯកសារនេះបានលើកឡើងនូវរបៀបដែលវិធីសាស្ត្រ និងទស្សនៈទានថ្មីៗអាចបញ្ចូលទៅក្នុងប្រព័ន្ធផែនការដែលមានស្រាប់។ ឯកសារនេះរៀបចំតាមរបៀបមួយដែលអ្នកប្រើប្រាស់អាចដំណើរការយ៉ាងលឿនតាមរយៈជំហានបន្តបន្ទាប់ និងប្រើប្រាស់នូវផ្នែកដែលទាក់ទងទៅនឹងតម្រូវការពិសេសៗរបស់ពួកគេ។ ការបោះពុម្ពបណ្តោះអាសន្ននៃឯកសារធនធាននេះនឹងប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការពិគ្រោះយោបល់របស់ប្រទេសនីមួយៗទាក់ទងនឹងតម្រូវការ និង អាទិភាពជាតិដើម្បីកសាងសមត្ថភាពក្នុងការរៀបចំផែនការបែងចែកតំបន់ប្រើប្រាស់ដែលជាផ្នែកមួយនៅក្នុងការអនុវត្តសេណារីយោនិងរៀបចំផែនទីស្តីពីភាពងាយរងគ្រោះការវិភាគហានិភ័យ និងការអនុវត្តធ្វើផែនការ វីប្រហែលជាការយល់ដឹងជាមូលដ្ឋានបន្ថែមទៀតនូវរបៀបថាតើត្រូវបញ្ជ្រាបការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្តែមទៅក្នុងរបៀបធ្វើផែនការបែងចែកតំបន់ប្រើប្រាស់ជាតិយ៉ាងដូចម្តេច។ ការពិគ្រោះយោបល់ថ្នាក់ជាតិនេះរួមជាមួយសកម្មភាពបន្ទាំនិងការកសាងសមត្ថភាពដែលបានកំណត់នោះនឹងជាសមិទ្ធិផលដ៏សំខាន់នៃដំណាក់កាលទី២ និង ទី៣នៃគម្រោង។

លេខាធិការដ្ឋានអង្គភាពសម្របសម្រួលតំបន់សមុទ្រអាស៊ីបូព៌ា (COBSEA) សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អង្គការ **SIDA** ដែលបានឧបត្ថម្ភគាំទ្រគម្រោងនេះ និង **បណ្ឌិត** Larry Hilderbrand, ទីប្រឹក្សាមកពីប្រទេសកាណាដាក្នុងការចូលរួមចំណែករៀបចំឯកសារនេះឡើង។

**លោក បណ្ឌិត ELLIK ADLER**

**អ្នកសម្របសម្រួលរបស់ COBSEA, UNEP**

# សេចក្តីសង្ខេប

ការរៀបចំផែនការប្រើប្រាស់តំបន់ឆ្នេរ គឺមានតាំងពីយូរយាណាស់មកហើយនៅក្នុងបណ្តាប្រទេសជាសមាជិកតំបន់អាស៊ីបូព៌ា។ ប្រព័ន្ធផែនការមួយចំនួនសម្រាប់ការប្រើប្រាស់ដី និង ប្រព័ន្ធផ្សេងទៀតសម្រាប់ការប្រើប្រាស់សមុទ្របានដើរតួជាមូលដ្ឋានគ្រឹះដ៏សំខាន់មួយសម្រាប់ការពារធនធានធម្មជាតិតំបន់ឆ្នេរសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច សហគមន៍ និងវប្បធម៌។ ទន្ទឹមនឹងនេះ ភាពខ្វះចន្លោះនៅក្នុងប្រព័ន្ធទាំងនេះអាចកំណត់អត្តសញ្ញាណបានដោយខ្លឹមសារសំខាន់នៃឯកសារនេះគឺថាប្រព័ន្ធផែនការទាំងនេះកំពុងទទួលរងនូវសម្ពាធ និងបញ្ហាប្រឈមហើយប្រហែលជាលើសពីដែនកំណត់បច្ចុប្បន្នរបស់គេដោយបញ្ហាដែលកំពុងកើតឡើងសំខាន់ៗមួយចំនួនដូចជា ការប្រែប្រួលអាកាសធាតុ និងក្តីរំពឹងទុកជាច្រើនសម្រាប់ការរួមបញ្ចូលនូវអ្វីដែលយើងអាចឱ្យឈ្មោះថាវិធីសាស្ត្រគ្រប់គ្រងថ្មីៗ។

ទស្សនទានគ្រប់គ្រងតំបន់ឆ្នេរសមុទ្របានអនុវត្តនៅតំបន់សមុទ្រអាស៊ីបូព៌ាជាច្រើនឆ្នាំមកហើយ ប៉ុន្តែចាំបាច់ត្រូវខិតខំបន្ថែមទៀតដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាព។ រលកយក្សស៊ូណាមិកាលពីឆ្នាំ២០០៤ និងសេណារីយោបច្ចុប្បន្នស្តីពីផលប៉ះពាល់ដ៏មានសក្តានុពលបង្កឱ្យមានការប្រែប្រួលអាកាសធាតុ និងកំណើននីវ៉ូទឹកសមុទ្របានបញ្ជាក់ពីសារៈសំខាន់នៃការកសាងផែនការ និងការអភិវឌ្ឍតំបន់ឆ្នេរប្រកបដោយប្រសិទ្ធភាព។ ឧបករណ៍មួយដែលប្រើសម្រាប់ការគ្រប់គ្រងតំបន់ឆ្នេរគឺការរៀបចំផែនការប្រើប្រាស់តំបន់ឆ្នេរ។

ការកសាងផែនការប្រើប្រាស់តំបន់ឆ្នេរត្រូវបានឱ្យនិយមន័យថាជា "បទអន្តរាគមន៍ចម្រុះនិងជាប់ទាក់ទងគ្នាក្នុងការបែងចែកដែនដីនិងដែនសមុទ្រសម្រាប់ការប្រើប្រាស់តាមរូបភាពជាច្រើន ដោយពិចារណាតាមតម្រូវការសម្រាប់ការពារបរិស្ថាន និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម"។ ឯកសារធនធានតំបន់ឆ្នេរនេះបង្ហាញពីមធ្យោបាយដែលវិធីសាស្ត្រនិងទស្សនទានថ្មីៗត្រូវដាក់បញ្ចូលទៅក្នុងប្រព័ន្ធកសាងផែនការប្រើប្រាស់តំបន់ឆ្នេរដែលមានស្រាប់។

របាយការណ៍នេះបានរៀបចំឡើងតាមធ្យោបាយមួយ ដែលអ្នកប្រើប្រាស់អាចអនុវត្តបានតាមរយៈជំហានបន្តបន្ទាប់គ្នាតាមរូបភាពច្រើនប្រភេទ ឬ ប្រើប្រាស់ផ្នែកផ្សេងៗដែលជាប់ពាក់ព័ន្ធទៅនឹងតម្រូវការពិសេសរបស់គេ។

**ជំពូកទីមួយ** គឺជាការណែនាំនូវគោលបំណង តើនរណាគួរប្រើប្រាស់វា, សមិទ្ធិផលចុងក្រោយនៃដំណើរការរៀបចំផែនការប្រើប្រាស់តំបន់ឆ្នេរថាតើត្រូវប្រើប្រាស់ឯកសារនេះរបៀបណា ទំនាក់ទំនងរវាងផែនការ និងពេលវេលា ទស្សនទានគោលការណ៍ និងវិធីសាស្ត្រ។

**ជំពូកទីពីរ** និយាយពីក្របខណ្ឌផែនការដែលមានស្រាប់ក្នុងតំបន់សមុទ្រអាស៊ីបូព៌ា

**ជំពូកទីបី** ផ្តល់ការណែនាំនិងពិភាក្សាអំពីបញ្ហាដែលកំពុងកើតមានឡើង និងវិធីសាស្ត្រគ្រប់គ្រងថ្មីៗសំខាន់ៗមួយចំនួនដូចជា ការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែម ការគ្រប់គ្រងគ្រោះថ្នាក់ និងហានិភ័យ, ការប្រែប្រួលអាកាសធាតុ ការរៀបចំផែនការប្រើប្រាស់ដីគោក និងដែនសមុទ្រ។

**ជំពូកទីបួន** ផ្តល់ការណែនាំអំពីបែបបទកសាងផែនការថ្មីៗប្រៀបធៀបនឹងវិធីសាស្ត្រ **បែបបុរាណ**

**ជំពូកទីប្រាំ** និយាយពីការអនុវត្តទស្សនទានកំពុងកើតឡើងនៅក្នុងដំណើរការកសាងផែនការតំបន់ឆ្នេរ។ វាបានផ្តល់ឱ្យអ្នកអាននូវវិធីសាស្ត្រមួយជំហានម្តងៗប្រកបដោយគតិបណ្ឌិត–ការរៀបចំនូវផែនការប្រើប្រាស់តំបន់ឆ្នេរការវាយតម្លៃស្ថានភាពបច្ចុប្បន្ន ការធ្វើពង្រាងផែនការប្រើប្រាស់តំបន់ឆ្នេរ ដំណើរការចរចា និង ការអនុវត្ត។ ផ្នែកនីមួយៗពិភាក្សាលើការអនុវត្តនូវវិធីសាស្ត្រផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែម ការរួមបញ្ចូលគ្នានូវផែនការសម្រាប់ការប្រើដី និងសមុទ្រ ព្រមទាំងការកាត់បន្ថយហានិភ័យ និងដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។

## ជំពូកទី ១: សេចក្តីផ្តើម

ប្រទេសនៅតំបន់សមុទ្រអាស៊ីបូព៌ាមានឯកសារគោលនយោបាយនិងបទដ្ឋានគតិយុត្តិស្តីពីដំណើរការរៀបចំផែនការនិងឯកសារស្តីពីផែនការរូបវន្តឬការប្រើប្រាស់តំបន់ឆ្នេរសមុទ្រ។ ការអនុវត្តជាក់ស្តែងមានការផ្លាស់ប្តូរនិងអភិវឌ្ឍន៍បន្តបន្ទាប់នៅពេលដែលតម្រូវការថ្មី និងក្តីរំពឹងទុកកំពុងប្រឈមនឹងភាពមិនជាក់លាក់នាពេលបច្ចុប្បន្ន និងអនាគត។ គោលបំណងនៃឯកសារនេះគឺ :

- ផ្តល់នូវវិធីសាស្ត្រថ្មីសម្រាប់ការកសាងផែនការថ្មីត្រូវបានអនុម័តហើយថាតើរបៀបថ្មីនេះខុសប្លែកពីវិធីសាស្ត្របុរាណដូចម្តេច
- ដើម្បីបញ្ចូលគោលការណ៍គ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមទៅក្នុងដំណើរការកសាងផែនការ
- ដើម្បីបញ្ចូលបញ្ហានៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការកសាងផែនការ និង
- ដើម្បីធ្វើសមាហរណកម្មផែនការប្រើប្រាស់ដី និងសមុទ្រ។

***ផែនការប្រើប្រាស់តំបន់ឆ្នេរមិនមែនជាផែនការអភិវឌ្ឍន៍ ផែនការគ្រប់គ្រង ឬផែនការបរិស្ថានទេ ប៉ុន្តែផែនការនេះជាវិធីសាស្ត្រគ្រប់គ្រងមួយដែលត្រូវប្រើជាមួយវិធីសាស្ត្រផ្សេងៗទៀត***

កន្លងមកការចង់បានផែនការប្រើប្រាស់តំបន់ឆ្នេរមាននៅលើផែនទី (ការប្រើប្រាស់ឧបករណ៍ GIS) ជាទីកន្លែងដែលសកម្មភាពនានា និងការប្រើប្រាស់ដីត្រូវបានអនុវត្ត ឬជម្រុញឱ្យប្រើនិងជាទីកន្លែងដែលរបៀបគ្រប់គ្រងធនធានជាក់លាក់ត្រូវបានអនុវត្ត។ នៅពេលដែលការរៀបរាប់តាមប្រភេទដំណើរការកសាងផែនការប្រើប្រាស់តំបន់ឆ្នេរ និងការគិតគូរថ្មីៗត្រូវតែបញ្ចូលគ្នានោះកម្រងឯកសារនេះនឹងត្រូវរៀបចំឱ្យស្របតាមស្ថានភាពជាតិ ស្ថានភាពថ្នាក់ក្រោមជាតិនិងស្ថានភាពមូលដ្ឋានសមស្រប។ ការធ្វើបែបនេះជាប្រការមួយល្អបំផុតដែលអនុវត្តនៅក្នុងប្រទេសជាក់លាក់មួយចំនួននិងនៅថ្នាក់រដ្ឋបាល។

### គោលបំណងនៃកម្រងឯកសារធនធាន

គោលបំណងនៃកម្រងឯកសារនេះគឺដើម្បីជួយដល់ប្រទេសចូលរួមក្នុងការកាត់បន្ថយផលប៉ះពាល់ដោយសារគ្រោះមហន្តរាយធម្មជាតិ ការប្រែប្រួលអាកាសធាតុ និងកំណើននីវ៉ូទឹកសមុទ្រ និងជម្រុញការអភិវឌ្ឍប្រកបដោយចីរភាពនៅតំបន់ឆ្នេរតាមរយៈការអនុវត្តនូវអ្វីដែលបានហៅថាជា (វិធីសាស្ត្រគ្រប់គ្រងថ្មីៗ)។

ឯកសារនេះគូសបញ្ជាក់ពីដំណើរការកសាងផែនការបែងចែកការប្រើប្រាស់ទូទៅដែលអាចអនុវត្តបាននៅកម្រិតខុសៗគ្នាថ្នាក់រដ្ឋបាល និងកម្រិតនៃវិស្សមភាព។ សូមភ្ជាប់មកជាមួយនូវឯកសារយោងអំពីវិធីសាស្ត្រ ឧបករណ៍ និងប្រភពជាច្រើនទៀតដើម្បីស្រាវជ្រាវរកព័ត៌មានបន្ថែម។

គោលបំណងនៃផែនការនេះគឺបង្ហាញឱ្យឃើញជាពិសេសតាមរយៈផែនទី និងការប្រើប្រាស់ឧបករណ៍ GIS ជាកន្លែងដែលមានសកម្មភាពច្រើន និងការប្រើប្រាស់ដី ឬសមុទ្រត្រូវបានអនុញ្ញាត ឬជម្រុញឱ្យប្រើនិងជាទីកន្លែងដែលអនុវត្តនូវការគ្រប់គ្រងធនធានជាក់លាក់។ ផែនការប្រើប្រាស់តំបន់ឆ្នេរនេះគឺជាឧបករណ៍គ្រប់គ្រងមួយដែលត្រូវប្រើជាមួយឧបករណ៍គ្រប់គ្រងផ្សេងៗទៀតដោយផ្តោតការយកចិត្តទុកដាក់លើតំបន់ឆ្នេរ ដី និងសមុទ្រ។ ដូចមាននៅក្នុងដំណើរការទូទៅដែរ វិធីសាស្ត្រដែលបានរៀបរៀងនឹងត្រូវការកែសម្រួលឱ្យស្របតាមស្ថានភាពជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាន។ វិធីសាស្ត្រនេះបានអនុវត្តដ៏ល្អបំផុតនៅក្នុងប្រទេសជាក់លាក់មួយចំនួននិងថ្នាក់គ្រប់គ្រងរដ្ឋបាល។

## តើនរណាជាអ្នកប្រើប្រាស់សៀវភៅនេះ?

គោលការណ៍ណែនាំនេះមានគោលបំណងផ្តល់នូវការទទួលខុសត្រូវតាមបែបវិជ្ជាជីវៈក្នុងការកសាងផែនការ និងការគ្រប់គ្រងតំបន់ឆ្នេរ និងសមុទ្រ និងធនធានរបស់វា។ គោលការណ៍ណែនាំនេះសំដៅជាពិសេសលើស្ថានភាពដែលពេលវេលា ហិរញ្ញវត្ថុ ព័ត៌មាន និងធនធានផ្សេងទៀតមានតិចតួច។ បញ្ហាប្រឈមដែលប្រទេសនៅតំបន់សមុទ្រអាស៊ីបូព៌ាកំពុងជួបប្រទះទាក់ទងនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ កំណើននីវ៉ូទឹកសមុទ្រ និង គ្រោះមហន្តរាយធម្មជាតិផ្សេងៗទៀតកាន់តែបង្ហាញឱ្យឃើញជាក់ស្តែងថែមទៀត។ តំបន់ឆ្នេរសមុទ្រអាស៊ីបូព៌ាងាយរងគ្រោះធ្ងន់ធ្ងរបំផុតពីការគំរាមកំហែងទាំងអស់នេះ ហើយយើងចាំបាច់ត្រូវឆ្លើយតបចំពោះការប្រឈមទាំងនេះ និងព្យាយាមកាត់បន្ថយភាពងាយរងគ្រោះចំពោះប្រព័ន្ធអេកូស៊ីស្តែម និងសហគមន៍។

## លទ្ធផលទទួលបានពីដំណើរការរៀបចំផែនការប្រើប្រាស់តំបន់ឆ្នេរសមុទ្រ

លទ្ធផលទទួលបានចុងក្រោយនៃដំណើរការរៀបចំផែនការប្រើប្រាស់តំបន់ឆ្នេររួមមាន:

- ផែនទីមួយចំនួនដោយរួមមានផែនទីបែងចែកតំបន់ដែលពិពណ៌នាតំបន់មួយចំនួនដែលក្នុងនោះលក្ខខណ្ឌការអភិវឌ្ឍជាក់លាក់ត្រូវបានអនុវត្ត។ ផែនទីបែងចែកតំបន់តំណាងឱ្យវិសាលភាពនៃចក្ខុវិស័យរួមរយៈពេល (20ឆ្នាំ) និងផ្តល់នូវស្ថេរភាពសម្រាប់ម្ចាស់ដី និងក្រុមហ៊ុនអភិវឌ្ឍន៍សម្រាប់រយៈពេលវែង
- ផែនទីផ្សេងៗទៀតដែលត្រូវបានប្រើប្រាស់ជាធាតុចូលដែលបញ្ចូលក្នុងផែនទីបែងចែកតំបន់ប្រហែលជាអាចបញ្ចូលផែនការប្រើប្រាស់ដីធ្លីនាពេលបច្ចុប្បន្ន លក្ខណៈរូបសាស្ត្រ លក្ខខណ្ឌ និងការប្រឈម ទីជំរក និង តំបន់ងាយរងផលប៉ះពាល់ដោយកត្តាបរិស្ថាន និងម្ចាស់កម្មសិទ្ធិដីធ្លី

- អត្ថបទមួយដែលពិពណ៌នាអំពីពីប្រវត្តិ និងដំណើរការដែលតាមរយៈនោះផែនទីបែងចែកតំបន់ត្រូវបានកំណត់ និងការរៀបរាប់តំបន់មួយម្តងៗនូវការប្រើប្រាស់ដែលអនុញ្ញាតនិងដែលហាមឃាត់។ **ប្រហែលជាមានផែនទី និងឯកសារជាច្រើនទៀតបានផលិតតាមរយៈដំណើរការនេះ។**
- ឯកសារការងារផ្សេងៗគ្របដណ្តប់ប្រធានបទមួយចំនួន
- របាយការណ៍ស្ថានភាពបច្ចុប្បន្នអាចហៅបានថារបាយការណ៍ "***ស្ថានភាពបរិស្ថានតំបន់ឆ្នេរ***"
- របាយការណ៍សិក្សាពិសេស
- របាយការណ៍ប្រជុំ និងសិក្ខាសាលាពិគ្រោះយោបល់ (តម្រូវការឱ្យមានប៉ារ៉ាម៉ែត្រការចូលរួមជាសាធារណៈនូវគោលនយោបាយ និង បទដ្ឋានគតិយុត្តពាក់ព័ន្ធ)។

ឯកសារនេះផ្តល់ការណែនាំដល់អ្នកធ្វើសេចក្តីសម្រេចចិត្ត ដែលរៀបចំផែនការលំអិតសម្រាប់តំបន់តូចៗ និង ដើម្បីឆ្លើយតបទៅនឹងការអនុវត្តដល់សិទ្ធិអនុញ្ញាតឱ្យអភិវឌ្ឍឬប្រើប្រាស់ដីក្នុងតំបន់នោះ។ ប្រការនេះមានសារៈសំខាន់ជាពិសេសសម្រាប់ប្រទេសនៅតំបន់អាស៊ីបូព៌ានៅពេល ដែលអភិក្រមអភិបាលកិច្ចភាគច្រើនត្រូវបានធ្វើវិមជ្ឈការហើយផែនការប្រើប្រាស់តំបន់ឆ្នេរភាគច្រើនកើតឡើងនៅតាមមូលដ្ឋានដោយអាស្រ័យលើការណែនាំ និងជំនួយពីថ្នាក់ដឹកនាំរាជរដ្ឋាភិបាលជាន់ខ្ពស់។ គំរូផែនការថ្មីមួយ(គំរូ)បានពិពណ៌នាក្នុងឯកសារធនធាននេះហើយគំរូឯកសារនេះមានមុខងារជាការកំណត់ផែនទីបែងចែកតំបន់ និងអត្ថបទដែលបានបំពេញបន្ថែមដោយផែនការអនុវត្តសំដៅលើសកម្មភាព និងការផ្សព្វផ្សាយ។ ឯកសារនេះបង្កើតឡើងដោយសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរ និង អ្នកពាក់ព័ន្ធផ្សេងៗទៀត និង ផ្សារភ្ជាប់ទៅនឹងដំណើរការថវិកា និងផែនការអភិវឌ្ឍដែលមានស្រាប់។ ឯកសារនេះផ្តោតលើរយៈពេលខ្លី និងក្រៅពីនោះផ្តល់នូវភាពសមហេតុផលមួយសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តដោយចង្អុលបង្ហាញថាតើភ្នាក់ងារឬអ្នកពាក់ព័ន្ធណាខ្លះដែលទទួលខុសត្រូវក្នុងការអនុវត្តសកម្មភាពជាក់លាក់និងថាតើនៅពេលណា។ មាតិកានៃរបាយការណ៍ចុងក្រោយ និងផែនការអនុវត្តមានដូចខាងក្រោមៈ ឯកសារនេះមានលក្ខណៈចង្អុលបង្ហាញនិងតាមបែបធម្មជាតិ។ ដំណើរការនីមួយៗមានលក្ខណៈពិសេសដូចនេះគេរំពឹងថានឹងមានកម្រិតលំអៀងចំពោះដំណើរការនេះ។

| មាតិកាសម្រាប់ការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរ<br>(ព័ត៌មានពិស្តារមានក្នុងឧបសម្ព័ន្ធទី៩) |
| --- |
| **សេចក្តីសង្ខេប**<br>**ផ្នែកទី១: ប្រវត្តិសង្ខេប និង ផែនទីបែងចែកតំបន់រយៈពេលវែង**<br>១. សេចក្តីផ្តើម និងប្រវត្តិសង្ខេប<br>២. ការពិពណ៌នាអំពីដំណើរការ<br>៣. ការពិពណ៌នាអំពីតំបន់<br>៤. ផលប្រយោជន៍ ថ្នាក់ជាតិ តំបន់និងមូលដ្ឋាន<br>**ផ្នែកទី២: កម្មវិធីអនុវត្តន៍**<br>៥. សេចក្តីផ្តើម និងយោងតាមផ្នែកទី១ជាពិសេសជំពូកទី៥ និង៦ (សេចក្តីផ្តើមនេះត្រូវបានផ្តល់ឱ្យដើម្បីឱ្យផ្នែកទី២អាចនៅដាច់ដោយឡែកពីគេបាន។ ទោះជាយ៉ាងណាក៏ដោយមិនត្រូវនិយាយឡើងវិញនូវអ្វី ដែលបាននិយាយរួចហើយនៅផ្នែកទី១នោះទេ<br>៦. ទស្សនៈរួមនៃកម្មវិធីអនុវត្តន៍<br>៧. តម្រូវការស្រាវជ្រាវ និងការអភិវឌ្ឍរយៈពេលវែង<br>៨. សម្របសម្រួលលើកិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាពស្ថាប័នស្តីពីការអនុវត្តកម្មវិធី<br>៩. គម្រោង និងកម្មវិធីអនុវត្តតាមវិស័យ (ចំពោះវិស័យនីមួយៗ/ស្ថាប័នតាមផ្នែកផ្តល់នូវការពិពណ៌នា ***ដោយសង្ខេប*** "thumbnail" ចំពោះសកម្មភាពឬគម្រោងនីមួយៗ ទីតាំង និងតំបន់ប៉ះពាល់របស់វា ការរួមចំណែករបស់វាដើម្បីសម្រេចបានគោលបំណងនិងចក្ខុវិស័យថវិកាដែលបានប៉ាន់ប្រមាណក្របខណ្ឌពេលវេលាដែលបានប៉ាន់ប្រមាណ និងអង្គភាពទទួលខុសត្រូវ)។ |

## តើត្រូវប្រើប្រាស់ឯកសារនេះដោយរបៀបណា?:

រាល់ការអនុវត្តធ្វើផែនការគឺមានលក្ខណៈពិសេសរបស់វា ដូចនេះវាមិនអាចទៅរួចទេក្នុងការយកតាមលំនាំរូបមន្តកសាងផែនការតែមួយដោយកំណត់ជាក់លាក់ចាប់ពីចំណុចចាប់ផ្តើមរហូតដល់ទីបញ្ចប់នោះ។ ភាពខុសគ្នានៃដំណើរការធ្វើផែនការផ្អែកលើ:

- **ថ្នាក់ ឬ កម្រិតនៃផែនការ មានទាំងថ្នាក់ជាតិ តំបន់ ស្រុក រាជធានី ឬផែនការមេ:** ប្រទេសនៅតំបន់អាស៊ីបូព៌ាភាគច្រើនរៀបចំផែនការតំបន់ឆ្នេរនៅគ្រប់ថ្នាក់ទាំងអស់ ឬ ស្ទើរគ្រប់កម្រិតទាំងអស់ និងយល់ដឹងអំពីតម្រូវការរៀបចំវិធីសាស្ត្រធ្វើផែនការ

- **ជំនាញរបស់សមាជិកក្រុមរៀបចំផែនការ:** ប្រទេសនៅតំបន់អាស៊ីប៉ូពាបានកំណត់នូវដែនសមត្ថភាពធ្វើផែនការនិងបានអំពាវនាវរកការគាំទ្រផ្នែកបណ្តុះបណ្តាលសមត្ថភាពហើយប្រការនេះនឹងត្រូវដោះស្រាយនៅដំណាក់កាលទី២
- **ថវិកា និងធនធានដែលមានផ្សេងទៀតសម្រាប់សកម្មភាពរៀបចំផែនការ:** ប្រការនេះផ្អែកលើធនធានថវិការបស់ប្រទេសទាំងនោះហើយសារៈសំខាន់របស់វាស្ថិតលើការវិនិយោគផ្នែកធ្វើផែនការ
- **ពេលវេលា និងកម្រិតនៃការដាក់សម្ពាធ ឬដោយអាជ្ញាធរៈ** សម្ពាធចេះតែកើនឡើងនៅតំបន់សមុទ្ររបស់ប្រទេសតំបន់អាស៊ីប៉ូពាចេញពីការអភិវឌ្ឍ និងនគូបណីយកកម្មដ៏ឆាប់រហ័សព្រមទាំងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុចេះតែកើនឡើង និងការប្តេជ្ញានៃប្រទេសតំបន់អាស៊ីប៉ូពាដើម្បីបង្កើតវិធីសាស្រ្តចម្រុះស្របតាមអនុសញ្ញានិងកិច្ចព្រមព្រៀងអន្តរជាតិនោះធ្វើឱ្យមានតម្រូវការវិធីសាស្រ្តនេះកាន់តែបន្ទាន់
- **ស្ថានភាពផ្លូវច្បាប់មួយចំនួនទៀត**ដែលត្រូវបានលើកឡើងទាក់ទងនឹងមាតិកានិងវិសាលភាព ឬក៏តម្រូវការចូលរួមជាសាធារណៈ ។ ល ។
- **ភាពស្មុគស្មាញនៃប្រព័ន្ធអេកូស៊ីស្ទែម និងការរៀបចំសេដ្ឋកិច្ចសង្គមៈ** បណ្តាប្រទេសតំបន់អាស៊ីប៉ូពាគឺស្ថិតក្នុងចំណោមតំបន់ដែលស្មុគស្មាញ លំបាក មានតម្លៃ និងទទួលរងការគំរាមកំហែងបំផុតក្នុងពិភពលោក
- **ផែនការដែលមានស្រាប់** រួមមានទាំងស្ថានភាពផ្លូវច្បាប់ និងព័ត៌មានផ្សេងៗ និងចំណេះដឹង និង
- **ឆន្ទៈរបស់អាជ្ញាធរពាក់ព័ន្ធ និងក្រុមអ្នកព័ន្ធក្នុងការចូលរួម** និង រួមចំណែកក្នុងន័យស្ថាបនាដល់ការអនុវត្តនេះក្នុងកម្រិតមួយដែលទាំងពេលវេលា និងធនធាននៅមានកម្រិត ។

ជំហានទីមួយៗក្នុងដំណើរការនេះត្រួតពិនិត្យតាមរយៈការប្រៀបធៀបរវាងគំរូផែនការ **ចាស់** និង **ថ្មី** និង ដោយការរួមបញ្ចូលនូវបញ្ហាថ្មីៗ ។

## ទំនាក់ទំនងរវាងផែនការនិងពេលវេលា

ការរៀបចំផែនការគឺជាដំណើរការបន្តមួយដែលមានជំហានដដែលច្រើនសារក្នុងវដ្តរបស់វាតាមរយៈពេលវេលា ។ ក្នុងកម្រងឯកសារនេះទំនាក់ទំនងរវាងចក្ខុវិស័យរយៈពេលវែង និងគោលបំណងនៅផ្នែកមួយចំហៀង ហើយទំនាក់ទំនងគោលបំណងរយៈពេលខ្លីដែលជាចំណុចផ្តោតនៃការអនុវត្តផែនការជាពិសេសត្រូវបញ្ជាក់ច្បាស់ដោយការកសាងមូលដ្ឋានគ្រឹះរៀបចំផែនការរយៈពេលវែងមានសារៈសំខាន់ណាស់ ។ ដោយសារតែការរៀបចំផែនការគឺជាវដ្តមួយម្លោះហើយដំណើរការនេះនិយាយច្រំដែលៗនូវការប្រមូលទិន្នន័យ និងការវិភាគជាច្រើន ។ អ្នករៀបចំផែនការ និងអ្នកឯកទេសលើបញ្ហានេះមិនសូវពេញចិត្តនឹងព័ត៌មានដែលមាននោះទេ ប៉ុន្តែផែនការនេះមិនបានដាក់បញ្ចូលសកម្មភាពតាមរយៈពេលធ្វើផែនការដែលនឹងបំពេញនូវចន្លោះប្រហោង និង កសាងនូវមូលដ្ឋានចំណេះដឹង ។ ជារើយៗមាននៅក្នុងតម្រូវការស្រាវជ្រាវរយៈពេលវែងដែលលទ្ធផលមានតែសម្រាប់វដ្តផែនការនាពេលអនាគត ។ ព្រោះហេតុដូចនេះ អ្នកធ្វើផែនការមានការលើកទឹកចិត្តឱ្យទទួលយក

នូវទស្សនៈនៃតម្រូវការព័ត៌មានរយៈពេលវែង និងកន្លែងណាដែលអាចធ្វើទៅបានចូរស្វែងរកមធ្យោបាយធានាឱ្យបានឆ្លើយតបទៅនឹងតម្រូវការទាំងនោះ។

មានមធ្យោបាយមួយដែលអាចធ្វើទៅបានគឺត្រូវព្រមព្រៀងជាមួយសាកលវិទ្យាល័យ និងវិទ្យាស្ថានស្រាវជ្រាវនៅតាមមូលដ្ឋានដែលតាមរយៈនោះការបង្រៀនត្រូវបានបញ្ចូលជាមួយការស្រាវជ្រាវ ដែលបានអនុវត្តដើម្បីបំពេញតម្រូវការអប់រំក្នុងពេលដំណាលគ្នានឹងការកសាងផែនការអនាគត។ ការបង្កើតនូវឃ្លាំងទិន្នន័យ GIS រយៈពេលវែងគឺជាឧបករណ៍ដ៏សំខាន់មួយទៀតដែលនឹងត្រូវប៉ះប៉ូវការចំណាយតាមរយៈពេលវេលាវិញ។ ឃ្លាំងផ្ទុកទិន្នន័យភូមិសាស្ត្របែបនេះគួរតែរក្សាទុកដើម្បីធានានូវបច្ចុប្បន្នភាពគ្រប់ពេលហើយការធ្វើបែបនេះនឹងអាចកាត់បន្ថយការចំណាយលើការអនុវត្តគម្រោងផែនការអនាគតបានយ៉ាងច្រើន។

វិធីសាស្ត្រធ្វើផែនការតាមបែបបុរាណបានចាប់ផ្តើមពីការកំណត់បញ្ហា ក្រោយមកទៀតកំណត់គោលបំណងដើម្បីដោះស្រាយបញ្ហាទាំងនេះ។ វិធីសាស្ត្រនេះគាំទ្រដល់កម្រងឯកសារនេះហើយបញ្ហាផ្ទុយពីនេះគឺជារឿងដែលត្រូវពិចារណា។ ចក្ខុវិស័យរួមនៃស្ថានភាពអនាគតដែលចង់បានផ្តល់នូវមូលដ្ឋានសំរាប់គោលបំណងរយៈពេលវែង។ បញ្ហាទាំងនេះបើគិតពីការប្រឈម ការរារាំង និងឧបសគ្គវិញគឺជាកត្តារារាំងឬបន្ថយល្បឿនដើម្បីសម្រេចបានគោលបំណងរយៈពេលវែង។ បញ្ហាដែលបានកំណត់មានទំនាក់ទំនងទៅនឹងគោលបំណងហើយប្រការនេះជម្រុញឱ្យមានទស្សនៈមួយ ដែលរក្សាទុកនូវគំនិតរយៈពេលវែងនៅពេលដែលដោះស្រាយជាមួយបញ្ហាអាទិភាពមួយចំនួននៅពេលអនាគតដ៏ខ្លី។ គោលបំណងសំខាន់គឺថាការដោះស្រាយបញ្ហាមួយនៅថ្ងៃនេះនឹងមិនបង្កឱ្យមានបញ្ហាមួយទៀតនៅថ្ងៃស្អែកនោះទេ។

## ជំពូកទី២: ក្របខណ្ឌ និង វិធីសាស្ត្រធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរក្នុងតំបន់សមុទ្រអាស៊ីបូព៌ា

ការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរគឺជាទស្សនៈទានមួយពុំមែនថ្មីនៅតំបន់អាស៊ីបូព៌ានោះទេ។ តាមពិត គេបានប្រើវាជាច្រើនទស្សវត្សរ៍កន្លងមកហើយនៅប្រទេសជាច្រើន និងបានផ្តល់មូលដ្ឋានគ្រឹះសម្រាប់ការបង្កើតនូវការសម្រេចចិត្តច្រើនបំផុតអំពីការបែងចែកតំបន់ប្រើប្រាស់ជាច្រើនតាមរយៈការគិតទុក និងការប្រើប្រាស់របស់មនុស្សជាច្រើនដែលមានការប្រកួតប្រជែង។ វិធីសាស្ត្រទាំងនេះ ច្រើននាំមុខដោយផែនការអភិវឌ្ឍន៍រយៈពេលវែង និងមធ្យម ដែលជាផែនទីចង្អុលផ្លូវសម្រាប់




ការអភិវឌ្ឍក្នុងប្រទេស។ ផែនការប្រើប្រាស់តំបន់ឆ្នេរសមុទ្រត្រូវបានប្រើប្រាស់មានទាំងការលើកកម្ពស់នូវការប្រើប្រាស់ដី និងធនធាន និងកំណត់នូវសកម្មភាពរបស់មនុស្សដើម្បីកាត់បន្ថយនូវផលប៉ះពាល់អវិជ្ជមានដល់ បរិស្ថាន និងសង្គម។ ការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរ

នឹងត្រូវធ្វើឡើងនៅថ្នាក់រដ្ឋបាលក្នុងប្រទេសមួយចំនួននៅតំបន់នេះប៉ុន្តែគ្រាន់តែមានភាពខុសៗ គ្នាប៉ុណ្ណោះ ។[1]

នៅពេលដែលចំណុចខ្វះចន្លោះក្នុងប្រព័ន្ធនេះបានកំណត់នោះចំណុចសំខាន់នៃឯកសារនេះ គឺថាប្រព័ន្ធធ្វើផែនការទាំងនេះកំពុងតែមានសំពាធ និងបញ្ហាប្រឈមហើយប្រហែលជាលើសពីដែនកំណត់នាពេលបច្ចុប្បន្នរបស់គេដោយតាមរយៈបញ្ហាកំពុងកើតមានឡើងមួយចំនួន ដូចជា ការប្រែប្រួលអាកាសធាតុ និងកំណើននីវ៉ូទឹកសមុទ្រ និងការរំពឹងទុកទទួលបានពីបទពិសោធន៍អន្តរជាតិស្តីពីអ្វីដែលយើងឱ្យឈ្មោះថាវិធីសាស្ត្រគ្រប់គ្រងថ្មីៗដូចជាការគ្រប់គ្រងផ្អែកតាមប្រព័ន្ធអេកូស៊ីស្ទែម ។

ការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរត្រូវគេចាត់ទុកថាជាឧបករណ៍មួយដ៏សំខាន់សម្រាប់ដំណើការអភិបាលកិច្ចល្អ ជាពិសេសនៅពេលដែលវិធីសាស្ត្រនេះធ្វើសមាហរណកម្មជាមួយកត្តាបរិស្ថាន សេដ្ឋកិច្ច និងសង្គម ។ វាអាចត្រូវបានគេបង្ខិតចូលជិតតាមរយៈវិស័យផ្សេងៗដែលជារឿយៗមានផលប្រយោជន៍ពិសេសក្នុងការជម្រុញនូវវិធីសាស្ត្រមួយ និង វិធីសាស្ត្រផ្សេងទៀត ឬពួកគេអាចតឹងតែងក្នុងការចាប់យកវិធានការឱ្យទូលាយជាងនេះទៀតនោះ ។ ជាក់ស្តែង ផែនការគ្រប់គ្រងព្រៃឈើដែលជាទូទៅផ្តោតការយកចិត្តទុកដាក់ទៅលើតំបន់សំបូរព្រៃឈើ និង បញ្ហាព្រៃឈើ ។ ផែនការផ្អែកលើទីជម្រាលដែលគាំទ្រដោយជលវិទូ និងបរិស្ថានវិទូ ឬក៏ការរៀបចំផែនការប្រើប្រាស់ដីដែលធម្មតាមិនអើពើ (មិនអើពើទាល់តែសោះ) នឹងតំបន់សមុទ្រ ។

មានការទទួលស្គាល់នូវតម្រូវការដើម្បីគាំទ្រវិធីសាស្ត្រ (ridge-to-reef) កាន់តែច្រើនឡើងៗចំពោះការធ្វើផែនការតំបន់ឆ្នេរពោលគឺជាទស្សនៈទានសំខាន់មួយក្នុងវិធីសាស្ត្រប្រព័ន្ធអេកូស៊ីស្ទែម ឬ ការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែម (ដែលនឹងមានការរៀបរាប់ និងពិភាក្សាពិស្តារនៅផ្នែកបន្តបន្ទាប់ក្នុងរបាយការណ៍នេះ) ។ ប្រការនេះមានន័យថា ទាំងតំបន់សមុទ្រ និង ដីគោកគួរតែរួមបញ្ចូលគ្នាក្នុងផែនការប្រើប្រាស់តំបន់ឆ្នេរ ហើយតាមដែលអាចធ្វើទៅបានអេកូហ្សូនទាំងមូលគួរត្រូវបញ្ចូលគ្នា ។

មានច្បាប់និងបទបញ្ញត្តិជាច្រើនកំពុងបង្កើតឡើងនៅតំបន់អាស៊ីបូព៌ា ដែលផ្តល់នូវក្របខណ្ឌគតិយុត្តសម្រាប់រៀបចំផែនការ ។ ក្នុងករណីខ្លះ មានផែនការជាក់លាក់ទាក់ទងនឹងផែនការប្រើប្រាស់ដី(ឧ. ហ្វីលីពីន) និងក្នុងផែនការផ្សេងពួកគេអាចធ្វើឱ្យមានការគ្រប់គ្រងតំបន់ឆ្នេរចម្រុះកាន់តែទូលាយ (ឧ. ច្បាប់គ្រប់គ្រងកោះ និង តំបន់ឆ្នេររបស់ប្រទេសឥណ្ឌូនេស៊ី និង ការផ្សព្វផ្សាយពង្រាងច្បាប់របស់ប្រទេសថៃស្តីពីការគ្រប់គ្រងធនធានតំបន់ឆ្នេរ និងសមុទ្រ) ។ នៅក្នុងប្រទេសផ្សេងៗទៀត (ឧ. កម្ពុជា) វិធីសាស្ត្រគ្រប់គ្រងឆ្នេរកាន់តែច្បាស់លាស់ថែមទៀតត្រូវបានប្រើសម្រាប់ការគាំទ្រនូវផែនការអភិវឌ្ឍន៍ប្រកបដោយចីរភាពដោយមានផែនការជាមុន តាមតំបន់ឆ្នេរតាមរយៈគោលការណ៍ណែនាំអភិវឌ្ឍន៍ និងបែងចែកតាមតំបន់សមស្រប ។ ក្នុងករណីជាច្រើនគោលបំណងនៃការកសាងផែនការប្រើប្រាស់តំបន់ឆ្នេរគឺត្រូវកំណត់ដោយច្បាប់ពិសេសដោយមានការហាមឃាត់ និង ការដាក់ទណ្ឌកម្មដែលអាចយល់យ៉ាងច្បាស់ ដោយសារការអនុវត្ត និង ពង្រឹងភ្នាក់ងារនិងតុលាការ

[1] Information for this section of the report is drawn primarily from two sets of presentations made by national authorities at COBSEA workshops on spatial planning (November, 2010) and coastal erosion (April, 2011) respectively. While the information at hand is not comprehensive or necessarily completely up-to-date, it does provide a good context for what currently exists, how well it works and identified shortcomings.

ឱ្យអនុវត្ត។ ផែនការប្រើប្រាស់តំបន់ឆ្នេរមានបំណងផងដែរដើម្បីគាំទ្រវិធីសាស្ត្រគ្រប់គ្រងប្រកបដោយការចូលរួមសមាហ-រណកម្មនៅថ្នាក់មូលដ្ឋាន ថ្នាក់ខេត្ត និងថ្នាក់ជាតិ។ នៅពាសពេញតំបន់អាស៊ីអាគ្នេយ៍មានរបាយការណ៍ថា ច្បាប់ដែលមានស្រាប់មិនត្រូវបានអនុវត្ត និងប្រើប្រាស់ឱ្យបានត្រឹមត្រូវនោះទេ។

ភាគច្រើននៃច្បាប់ទាំងនេះក្នុងតំបន់អាស៊ីបូព៌ារួមបញ្ចូលទាំងលក្ខខណ្ឌ ដែលតម្រូវឱ្យមានផែនការយុទ្ធសាស្ត្រតំបន់ឆ្នេរផែនការបែងចែកតំបន់ផែនការគ្រប់គ្រងនិងផែនការសកម្មភាពសម្រាប់តំបន់ឆ្នេរ ហើយភាគច្រើនរួមបញ្ចូលទាំងការវាយតម្លៃគ្រោះថ្នាក់ សេណារីយោភាពងាយរងគ្រោះ ការវាយតម្លៃហានិភ័យ និងយុទ្ធសាស្ត្រការបន្សុាំ។

នៅមានគោលនយោបាយ គាំទ្រ និង ពង្រឹងសមត្ថភាពនៅក្នុងក្របខណ្ឌច្បាប់ទាំងនេះផងដែរ។ ឧទាហរណ៍ ប្រទេសកម្ពុជា មានគោលនយោបាយថ្នាក់ជាតិសម្រាប់ការប្រើប្រាស់ដី និងនគរូបនីយកម្មនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមតំបន់ដែលផ្តល់នូវចក្ខុវិស័យច្បាស់លាស់សម្រាប់គោលនយោបាយកសាងផែនការប្រើប្រាស់តំបន់ឆ្នេរ: *"ដែលផែនការទាំងមូលត្រូវបានប្រើប្រាស់រៀបចំ អភិវឌ្ឍ និង ការពារដោយការកសាងផែនការចម្រុះ និងបែបយុទ្ធសាស្ត្រ និងការធ្វើឱ្យសុខដុមនីយកម្មនូវវិធានការ និងឧបករណ៍សំខាន់ៗជាច្រើនតាមតំបន់"។* ប្រទេសហ្វីលីពីនមានក្របខណ្ឌជាតិសម្រាប់ការកសាងផែនការរូបវន្តដែលរួមបញ្ចូលតំបន់ការពារ តំបន់ផលិតកម្ម តំបន់សង់ទីលំនៅ និងហេដ្ឋារចនាសម្ព័ន្ធ។ នៅប្រទេសថៃមានគោលនយោបាយ យុទ្ធសាស្ត្រ គម្រោងកម្មវិធី និងផែនការនៃសកម្មភាពនៅនឹងកន្លែង ឬក្នុងការអភិវឌ្ឍដើម្បីធ្វើឱ្យប្រសើរឡើង និង រក្សានូវចីរភាពនៃប្រភពធនធានសមុទ្រ និងឆ្នេរ។ ដោយមានការគាំទ្របច្ចេកទេសពីគម្រោងភាពជាដៃគូសម្រាប់គ្រប់គ្រងបរិស្ថាននៅតំបន់សមុទ្រអាស៊ីបូព៌ា (PEMSEA) និង រដ្ឋបាលបរិយាកាស និងមហាសមុទ្រជាតិ (NOAA) នោះប្រទេសវៀតណាមបានរៀបចំគម្រោងមេ ស្តីពីការកសាងផែនការប្រើប្រាស់ដីតំបន់ឆ្នេរដោយរាប់បញ្ចូលទាំងការគាំទ្រគោលនយោបាយ និងច្បាប់ និងការបង្កើតឡើងដោយផ្អែកទៅលើប្រព័ន្ធ និង និតិវិធីកសាងផែនការប្រើប្រាស់តំបន់ឆ្នេរដែលមានស្រាប់។

ផែនការប្រើប្រាស់តំបន់ឆ្នេរចម្រុះតម្រូវឱ្យមានការចូលរួមនូវគ្រប់វិស័យទាំងអស់ និងមានការសម្របសម្រួលខ្ពស់។ ជាញឹកញាប់ការលើកកម្ពស់ការយល់ដឹងនៅមានកម្រិតរវាង និងក្នុងចំណោមភ្នាក់ងារ គោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និង ច្បាប់ជាច្រើនប្រភេទដែលបានអនុវត្តនៅតាមវិស័យជាច្រើន, ការសម្របសម្រួល និង សហការនៅមានកម្រិត និង កិច្ចខិតខំប្រឹងប្រែងជាន់គ្នា។ ដើម្បីដោះស្រាយនូវការប្រឈមទាំងនេះចាំបាច់ត្រូវមានការតែងតាំងពីភ្នាក់ងារដឹកនាំសម្រាប់ការកសាងផែនការ សកម្មភាពបទបញ្ញត្តិ និង ច្បាប់សម្រាប់ការអភិវឌ្ឍការប្រើប្រាស់ដី អចលនៈទ្រព្យ និង ការសង់ផ្ទះសម្បែង (ឧ. គណៈកម្មាធិការប្រើប្រាស់ដីធ្លីថ្នាក់ជាតិ អន្តរភ្នាក់ងាររបស់ប្រទេសហ្វីលីពីន, ក្រុមប្រឹក្សានាយកសម្រាប់ការសង់លំនៅដ្ឋាន បទបញ្ញត្តិប្រើប្រាស់ដីដែលទទួលខុសត្រូវលើមុខងារសម្របសម្រួល។ ក្រសួងធនធានធម្មជាតិ និងបរិស្ថានរបស់ប្រទេសថៃដែលដើរតួសំខាន់ក្នុងការរៀបចំផែនការ និងការគ្រប់គ្រងតំបន់ឆ្នេរ និងក្រុមប្រឹក្សានាយកសម្របសម្រួលការធ្វើផែនការបែងចែកតាមតំបន់របស់ប្រទេសឥណ្ឌូនេស៊ី)។ តាមធម្មតាមានឋានុក្រមមួយនៃផែនការរូបវន្តទាក់

ទងនឹងគោលនយោបាយសហវិមជ្ឈការថ្នាក់ជាតិ។ ឧទាហរណ៍ ប្រទេសវៀតណាមមានផែនការជាច្រើនចាប់ពីយុទ្ធសាស្រ្ត អភិវឌ្ឍន៍ជាតិ ផែនការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមថ្នាក់តំបន់/ខេត្ត ផែនការប្រើប្រាស់ដីនៅថ្នាក់ឃុំ ស្រុក ខេត្ត តំបន់ និងថ្នាក់ជាតិថែមទាំងការកសាងផែនការសម្រាប់ការសាងសង់ទៀតផង។ប្រទេសហ្វីលីពីនមានក្របខណ្ឌជាតិមួយសម្រាប់ការកសាងផែនការរូបវន្ត ក្របខណ្ឌតំបន់ ខេត្ត និង ផែនការប្រើប្រាស់ដីធ្លីដ៏ទូលំទូលាយ។ នៅទីនោះអង្គភាព រដ្ឋបាលមូលដ្ឋានកំពុងផ្តល់នូវជំនួយបច្ចេកទេសក្នុងការរៀបចំបទបញ្ជាការប្រើប្រាស់ដី និងកំណត់តំបន់ដ៏ស៊ីជម្រៅមួយ។ សៀវភៅមគ្គុទេសន៍ការរៀបចំផែនការប្រើប្រាស់ដីតំបន់ឆ្នេរត្រូវបានរៀបចំ ដែលផ្តល់នូវនិតិវិធីក្នុងការរៀបចំបទបញ្ជាការបែងចែកតំបន់ប្រើប្រាស់ដី និង ការគ្រប់គ្រងទិន្នន័យប្រើប្រាស់ដីទូលំទូលាយ។ ក្រៅពីនេះនៅមានការអនុវត្តផែនការប្រតិបត្តិសម្រាប់តំបន់ឆ្នេរជាក់លាក់នៅថ្នាក់ខេត្ត (ឧ. ផែនការបែងចែកតំបន់ដីប្រើប្រាស់សមុទ្រ និងដីតាមតំបន់ឆ្នេរសម្រាប់ខេត្តបាតាន) និងតំបន់មូលដ្ឋាន (ឧ.យុទ្ធសាស្រ្តតំបន់ឆ្នេរទីក្រុងម៉ានីល) ដែលរាប់បញ្ចូលទាំងសមាសភាគសម្រាប់ការវាយតម្លៃហានិភ័យ ផែនការយថាផលសម្រាប់ការកំពុបប្រេង និង ផែនការបែងចែកតំបន់ប្រើប្រាស់សមុទ្រ និងដីឆ្នេរ។

រលកយក្សស៊ូណាមិ នៅអាស៊ីឆ្នាំ២០០៤ បង្កឱ្យមានភាពងាយរងគ្រោះដល់សហគមន៍តំបន់ឆ្នេរជាច្រើនដោយសារគ្រោះមហន្តរាយធម្មជាតិ និងផលប៉ះពាល់របស់វា។ ឧបករណ៍រៀបចំផែនការបែងចែកតំបន់ទាំងនេះ កំពុងពិចារណាពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ និងការគំរាមកំហែងដែលកំពុងតែកើតមានឡើង។ ទោះជាយ៉ាងណាក៏ដោយគ្រោះធម្មជាតិដែលកើតមានការប្រែប្រួលរយៈពេលយូរ និងរយៈពេលមធ្យម (ដូចជាការប្រែប្រួលអាកាសធាតុ), ប្រឈមនឹងប្រព័ន្ធដែលមានស្រាប់ និងតម្រូវឱ្យមានការណែនាំពីរបៀបថាតើត្រូវបញ្ជ្រាបការប្រឈមថ្មីៗនេះទៅក្នុងប្រព័ន្ធរៀបចំផែនការដែលមានស្រាប់ដោយរបៀបណា។ យើងកំពុងមើលឃើញនូវសមាហរណកម្មចេះតែកើនឡើងនូវការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និង ការបន្សាំនឹងការប្រែប្រួលអាកាសធាតុទៅក្នុងសៀវភៅមគ្គុទេសន៍ប្រើប្រាស់ដីតំបន់ឆ្នេរដោយមានការជួយឧបត្ថម្ភពីភ្នាក់ងារម្ចាស់ជំនួយ (ឧ. កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងជំនួយ AusAid សម្រាប់ប្រទេសហ្វីលីពីន)។ ប្រទេសវៀតណាមមានគោលនយោបាយថ្នាក់ជាតិសម្រាប់ការលើកកម្ពស់ការការពារបរិស្ថាន និង សមាហរណកម្ម ការបន្សាំនឹងប្រែប្រួលអាកាសធាតុ ប៉ុន្តែបានរាយការណ៍ពីការខ្វះចន្លោះនូវបទពិសោធន៍ក្នុងការវាយតម្លៃផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ។ កម្ពុជាមានក្របខណ្ឌច្បាប់ គោលនយោបាយ និងការរៀបចំស្ថាប័នដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រងគ្រោះមហន្តរាយដូចជាផែនការសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAPA) ដែលកំពុងអភិវឌ្ឍនូវកម្មវិធីសកម្មភាពដឹកនាំដោយប្រទេស និងដែលអាចសម្រេចបានជាក់ស្តែង និង កំណត់នូវសកម្មភាពអាទិភាពដោះស្រាយនូវសេចក្តីត្រូវការសម្រាប់ការបន្សាំនឹងផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ។ គម្រោង NAPAរបស់កម្ពុជាបានកំណត់គម្រោងបន្សាំដោយគ្មានការស្ទាយក្រោយចំនួន 39 ដែលផ្តោតការយកចិត្តទុកដាក់លើវិធានការដែលមានផលប៉ះពាល់ដោយផ្ទាល់ទៅលើការរស់នៅរបស់ប្រជាជនមូលដ្ឋានជាពិសេសអ្នកក្រីក្របំផុត។




ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីដោះស្រាយទៅនឹងបញ្ហាជាក់លាក់ ដូចជា ការហូរច្រោះតំបន់ឆ្នេរ (ប្រធានបទនៃការផ្សព្វផ្សាយរបស់គម្រោង COBSEA) ប្រព័ន្ធ និងនិតិវិធីការរៀបចំផែនការប្រើប្រាស់តំបន់ឆ្នេរដែលមានស្រាប់មិនមានវិធីសាស្ត្រជាលក្ខណៈប្រព័ន្ធ និងគ្មានគោលនយោបាយថ្នាក់ជាតិ រឺ តំបន់ដែលមានគោលបំណងដោះស្រាយបញ្ហានេះទេ។ រដ្ឋាភិបាលមូលដ្ឋាន និងម្ចាស់ទ្រព្យសម្បត្តិធ្វើការសម្រេចចិត្តផ្ទាល់ខ្លួនពីរបៀបដោះស្រាយបញ្ហា។ គួរឱ្យចាប់អារម្មណ៍ផងដែរ អង្គភាពរដ្ឋបាលមូលដ្ឋានក្នុងប្រទេសហ្វីលីពីនបានជម្រុញឱ្យប្រកាសថាដីធ្លីសាធារណៈដែលប្រគល់ឱ្យថ្មីៗបានកំណត់ថាជាខ្សែក្រវាត់បៃតងក្រុង។

យើងចាំបាច់ត្រូវតែចងចាំថាការគ្រប់គ្រងធនធាន និងផែនការប្រើប្រាស់ដីធ្លីត្រូវតែបែងចែកតាមសមត្ថភាព ពោលគឺទាក់ទងនឹងធនធានមនុស្ស និងហិរញ្ញវត្ថុ–របស់សហគមន៍ដើម្បីអនុវត្ត និងជម្រុញការអនុវត្តការងារទាំងអស់នេះ។ ទោះជាយ៉ាងណាក៏ដោយបញ្ហាថ្មីៗអនុវត្តដោយប្រទេសថៃគឺថាផែនការប្រើប្រាស់តំបន់ឆ្នេរជាញឹកញាប់ត្រូវបានគេមិនអើពើឬនិយាយដោយងាយថាផែនការនេះមិនអាចដោះស្រាយផលប៉ះពាល់តាមដែលចង់បាននោះទេ។ ប្រការនេះម្យ៉ាង ដោយសារ

ការគ្រប់គ្រង ឬ ផែនការប្រើប្រាស់ដីមិនបានអនុវត្តតាមការរៀបចំទុកមានន័យថាពួកគេមិនពិចារណាលើសមាសភាពហិរញ្ញវត្ថុ និងមនុស្សដែលតម្រូវឱ្យអនុវត្តផែនការទាំងនេះប្រកបដោយប្រសិទ្ធភាព ហើយប្រការនេះជាក់ស្តែងលើការអនុវត្តច្បាប់តែម្តង។ ទោះជាយ៉ាងណាក៏ដោយនៅតែមាននិន្នាការមួយដែលពឹងផ្អែកទាំងស្រុងលើម្ចាស់ជំនួយជាជាងការកៀរគរធនធានខាងក្នុង ហើយមានសកម្មភាពជាច្រើនបានអនុវត្តដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុក្នុងតំបន់ឆ្នេរមានរយៈពេលខ្លីមែនទែន។

ការប្រឈមនឹងសមត្ថភាពនិងការអនុវត្តអមជាមួយនឹងការរួមបញ្ចូលនូវបញ្ហាកំពុងកើតឡើងនិងវិធីសាស្ត្រគ្រប់គ្រងថ្មីៗនិយាយដោយផ្ទាល់ចំពោះសេចក្តីត្រូវការសម្រាប់ការណែនាំបន្ថែម។ ឯកសារធនធាននេះមានបំណងផ្តល់នូវការងារនេះ។

## ជំពូកទី៣ –បញ្ហាកំពុងកើតឡើង និងវិធីសាស្ត្រគ្រប់គ្រងថ្មីៗ

ជំពូកនេះរៀបរាប់ និងពិភាក្សានូវចំនួនបញ្ហាដែលកំពុងកើតឡើង និងចាត់ជាវិធីសាស្ត្រគ្រប់គ្រងថ្មីៗដែលមានឥទ្ធិពលកើនឡើង និងធំធេងលើការកសាងផែនការប្រើប្រាស់តំបន់ឆ្នេរទាំងនេះ រួមមាន:

- ការរៀបចំផែនការផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមក្នុងបរិបទតំបន់ឆ្នេរ
- ការធ្វើសមាហរណកម្មការរៀបចំផែនការតំបន់សមុទ្រ និងដែនដី
- ការនាំមកនូវការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងបញ្ហាប្រែប្រួលអាកាសធាតុ, ភាពងាយរងគ្រោះ និងការកសាងភាពធន់ក្នុងដំណើរការរៀបចំផែនការបែងចែកតំបន់ និង
- គំរូរៀបចំផែនការថ្មីមួយ ។

## ការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមនៅក្នុងបរិស្ថានសមុទ្រ និងតំបន់ឆ្នេរ

ការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមគឺជាវិធីសាស្ត្រមួយដែលមិនមែនពិនិត្យលើបញ្ហាទោល,ពពួកសត្វ ឬមុខងារអេកូស៊ីស្ទែមនៅដាច់ដោយឡែក ។ ការទទួលស្គាល់ប្រព័ន្ធអេកូស៊ីស្ទែមសម្រាប់អ្វីដែលពួកគេមានៈ សារធាតុចម្រុះជាច្រើនដែលមានអន្តរកម្មជាមួយគ្នាទៅវិញទៅមកតាមមធ្យោបាយសំខាន់ៗ ។ ជាពិសេសវាមានសារៈសំខាន់សម្រាប់តំបន់ឆ្នេរ និងមហាសមុទ្រ និង ជាពិសេសតំបន់អាស៊ីបូព៌ា ។ ដើម្បីពិពណ៌នាអំពីបញ្ហានេះពាក្យថាការគ្រប់គ្រងផ្អែកលើអេកូស៊ីស្ទែម និងវិធីសាស្ត្រអេកូស៊ីស្ទែមជាទូទៅត្រូវបានប្រើឆ្លាស់គ្នាប៉ុន្តែជាទូទៅមានអត្ថន័យដូចតែគ្នា ។

ការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមទទួលស្គាល់ថាសុខុមាលភាពរបស់យើង និង សុខភាពនៃបរិស្ថានគឺមានទំនាក់ទំនងគ្នា ។ ម្យ៉ាងវិញទៀត ប្រព័ន្ធតំបន់ឆ្នេរ និង សមុទ្រផ្តល់នូវសេវាធម្មជាតិដ៏មានតម្លៃ ឬ "**សេវាអេកូស៊ីស្ទែម**" សម្រាប់សហគមន៍មនុស្សដូចជាការនេសាទបែបកំសាន្ត និងពាណិជ្ជកម្ម ថាមពលកកើតឡើងពីខ្យល់ ឬរលក ការការពារតំបន់ឆ្នេរ និងការកំសាន្ត ។ អាស្រ័យហេតុនេះដើម្បីការពារសុខុមាលភាពរយៈពេលយូរ យើងត្រូវការធានាថាមុខងារ និងផលិតភាពអេកូស៊ីស្ទែមតំបន់ឆ្នេរ និងសមុទ្រត្រូវគ្រប់គ្រងប្រកបដោយចីរភាព ។ ប្រការនេះមានន័យថាជាការគ្រប់គ្រងតាមរបៀបមួយដែលទទួលស្គាល់នូវភាពស្មុគស្មាញនៃអេកូស៊ីស្ទែមសមុទ្រ និងឆ្នេរ ការតភ្ជាប់ក្នុងចំណោមពួកគេការតភ្ជាប់រវាង ដីគោក និងទឹកសាប និងថាតើមនុស្សមានអន្តរកម្មជាមួយគ្នារបៀបណា ។ លើសពីនេះ ការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមផ្តល់នូវដំណោះស្រាយដ៏មានតម្លៃដើម្បីការពារអេកូស៊ីស្ទែមតំបន់ឆ្នេរ និងសមុទ្រក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយដ៏មានសក្តានុពលផ្សេងទៀត ។

គោលការណ៍ និងវិធីសាស្ត្រគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមគឺមានឈ្មោះល្បី និងបានយល់ដឹងនាពេលបច្ចុប្បន្ន ។ ប៉ុន្តែថាតើត្រូវអនុវត្តរបៀបណានៅក្នុងការកំណត់សេដ្ឋកិច្ច សង្គមនិង ជាតិនោះនៅតែជាបញ្ហាប្រឈមសម្រាប់អ្នកធ្វើគោល




នយោបាយ និងអ្នកអនុវត្តជាច្រើន។ នៅចុងបញ្ចប់ ការចេញផ្សាយថ្មីមួយរបស់កម្មវិធីបរិស្ថានសហប្រជាជាតិ(UNEP) គឺ **ចាត់វិធានការឆ្ពោះទៅរកការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមសមុទ្រ និង តំបន់ឆ្នេរស្តីពី–ការណែនាំដំបូង** (មិថុនា 2011), ត្រូវបានចេញផ្សាយដើម្បីជួយប្រទេស និងសហគមន៍ ដោយរួមទាំងអ្នកធ្វើផែនការ និងអ្នកសម្រេចចិត្តនៅគ្រប់កម្រិត និងនៅគ្រប់វិស័យ- ឈានទៅរកការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមនៃតំបន់ឆ្នេរ និងមហាសមុទ្រ។ បទពិសោធន៍ និងមេរៀនដែលបានរៀនពីជុំវិញពិភពលោកដោយរួមទាំងតំបន់អាស៊ីបូព៌ា–ការណែនាំនេះក្លាយជាការណែនាំចំពោះគោល ការណ៍និងការអនុវត្តការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែម និងផ្តល់នូវទស្សនះរួម។ ជាមួយនឹង ការណែនាំនេះ UNEP ស្វែងរកជំនួយពីប្រទេសនិងសហគមន៍ជាច្រើនដើម្បីធ្វើការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែម នៃ តំបន់ឆ្នេរនិងសមុទ្រ។

ប្រទេសជាច្រើនបានជម្រុញឱ្យធ្វើការពិគ្រោះយោបល់លើរបាយការណ៍នេះដោយសារតែពួកគេកំពុងបន្តអនុវត្តនូវវិធីសាស្ត្រគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមជាច្រើនថែមទៀតក្នុងការគ្រប់គ្រងតំបន់ឆ្នេរ និង មហាសមុទ្ររបស់គេ។ ទោះបីជាពាក្យថាការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមបានកំណត់និយមន័យជាច្រើនរបៀបក៏ដោយក៏ខ្លឹមសារសំខាន់ៗរបស់វាផ្តោតលើ:

- ការទទួលស្គាល់ការភ្ជាប់ទំនាក់ទំនងរវាងសមុទ្រ ឆ្នេរ និងប្រព័ន្ធដែនដី ព្រមទាំងរវាងប្រព័ន្ធអេកូស៊ីស្ទែម និងសង្គមមនុស្ស
- ការប្រើប្រាស់ទស្សនះសេវាកម្មអេកូស៊ីស្ទែមដែលតាមតម្លៃ មិនត្រឹមតែសម្រាប់ទំនិញ មូលដ្ឋានដែលគេបង្កើតដូចជាស្បៀងអាហារ ឬ វត្ថុធាតុដើម ប៉ុន្តែសម្រាប់សេវាកម្មសំខាន់ៗដែលគេផ្តល់ឱ្យផងដែរ ព្រមទាំងទឹកស្អាតនិងការការពារពីធាតុអាកាសអាក្រក់ៗ
- ការដោះស្រាយនូវផលប៉ះពាល់ នៃសកម្មភាពផ្សេងៗដែលមានផលប៉ះពាល់លើអេកូស៊ីស្ទែម
- ការគ្រប់គ្រងនិងផ្តល់តុល្យភាពគោលបំណងពហុភាគនិងជួនកាលភាពមានទំនាស់ជាមួយគោលបំណងដែលមានទំនាក់ទំនងជាមួយផលប្រយោជន៍ និងសេវាកម្មអេកូស៊ីស្ទែមផ្សេងៗ
- ការទទួលយកការផ្លាស់ប្តូរបទពិសោធន៍ និងសម្របតាមគោលនយោបាយ និងដំណើរការគ្រប់គ្រង។

ដោយការប្រមូលផ្តុំគ្នា ទស្សនះទានសំខាន់ទាំងនេះបែងចែកជាការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែម ពីការគ្រប់គ្រងបែបប្រពៃណី។ ទាំងនេះជាការពិចារណាដ៏សំខាន់ៗនៅពេលដែលអ្នកអនុវត្តចាប់ផ្តើមអនុវត្តការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែម។ យើងចាំបាច់ត្រូវកត់សម្គាល់ថា ទោះជាយ៉ាងណាក៏ដោយធាតុផ្សំទាំងនេះមានសារៈសំខាន់ណាស់ហើយអាចនឹងត្រូវដោះស្រាយបានមួយជំហានម្តងៗដំណើរការបន្សាំ, ដំណើរការសម្របសម្រួល និងការបំពេញបន្ថែម, ផ្តល់ឱ្យនូវស្ថានភាពធនធាន និងកម្មវិធីមានស្រាប់តំបន់ពិសេស។ ការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមនឹងមើលទៅខុសគ្នាក្នុងទីតាំងខុសៗ

គ្នាដោយគិតទៅលើភាពចម្រុះនៃទំនាក់ទំនងនយោបាយ សង្គម និង អេកូស៊ីស្ទែមពិសេសក្នុងតំបន់ភូមិសាស្ត្រជាក់ស្តែងណាមួយ ។

***គោលបំណងនៃការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមគឺធ្វើឱ្យការគ្រប់គ្រងតំបន់ឆ្នេរ និង សមុទ្រកាន់តែមានប្រសិទ្ធភាព និងចំណាយតិចជាងការគ្រប់គ្រងតាមវិស័យ ដែលមិនមានការសម្របសម្រួល***

ទិដ្ឋភាពមួយក្នុងចំណោមទិដ្ឋភាពសំខាន់ៗបំផុតនៃការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមគឺជាវិធីសាស្ត្រផ្អែកលើទីតាំងជាមូលដ្ឋានជាកន្លែងដែលអេកូស៊ីស្ទែមមួយតំណាងឱ្យកន្លែងមួយ ។ ការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមមានបំណងគ្រប់គ្រងការប្រើប្រាស់របស់មនុស្សនៅកម្រិតមួយដែលគ្របដណ្តប់លើឥទ្ធិផលរបស់វាទៅលើមុខងារអេកូស៊ីស្ទែមឆ្នេរ និង ទឹកសមុទ្រមិនមែនទំហំដែលកំណត់ដោយព្រំដែនយុត្តាធិការនោះទេ ។ ការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមគិតគូរទាំងតំបន់សមុទ្រ និងដីគោកដោយភ្ជាប់គ្នារវាង ដីគោក សមុទ្រ និងឆ្នេរ ។

ការចេញផ្សាយស្តីពីវិធីសាស្ត្របែបអេកូស៊ីស្ទែម និងការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមបានសង្កត់ធ្ងន់លើតម្រូវការអភិបាលកិច្ចតំបន់ កន្លែងដែលទំហំនៃការគ្រប់គ្រងសម្របសម្រួលឬសហការលាតសន្ធឹងពេញតំបន់ដែលមានអន្តរទំនាក់ទំនងនិងប្រព័ន្ធសង្គមមនុស្ស ។ទាំងនេះបានបង្ហាញយ៉ាងល្អក្នុងតំបន់សមុទ្រអាស៊ីបូព៌ាតាមរយៈក្របខណ្ឌតំបន់ប្រកបដោយកិច្ចសហការផ្តល់ដោយគម្រោង COBSEA ។ ជំហានជោគជ័យក្នុងដំណើការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមមានទាំងការងារដែលអ្នកគ្រប់គ្រងឆ្នេរ និងសមុទ្រកំពុងតែបានធ្វើរួចហើយដូចជាការវាយតម្លៃធនធាន ឬស្តុកទុក ការវាយតម្លៃបរិស្ថាន ការត្រួតពិនិត្យ ការបំពុលការគ្រប់គ្រងជលផល និងនៅមានរឿងជាច្រើនផ្សេងទៀត ។

អ្វីដែលបានបែងចែកការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមឱ្យនៅដោយឡែកគឺវិធីសាស្ត្រសមាហរណកម្ម និងគ្រប់ជ្រុងជ្រោយ ។ វាបានតភ្ជាប់ទំនាក់ទំនងការគ្រប់គ្រងតាមវិស័យមុនៗ ដូចជាវិស័យព្រៃឈើ និង ជលផល និង ពិចារណានូវការប្រើប្រាស់ជាច្រើនដែលជះឥទ្ធិពលលើប្រព័ន្ធអេកូស៊ីស្ទែមមួយ ឬ ប្រព័ន្ធអេកូស៊ីស្ទែមច្រើន ។ កត្តានេះតម្រូវឱ្យធ្វើការងារប្រកបដោយចេតនាដើម្បីកសាងកិច្ចសហការនិងការសម្របសម្រួលនូវវិស័យផ្សេងៗគ្នាដែលអាចនៅដាច់ពីគ្នា ឬរហូតដល់មានជម្លោះជាមួយគ្នាទៀតផង ។ ខ្លឹមសារដែលបានបង្កប់នៅក្នុងការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមគឺជាទស្សនៈទាននៃការកសាងភាពធន់ និងការថែរក្សានូវមុខងារប្រព័ន្ធអេកូស៊ីស្ទែម ។ ការកសាងភាពធន់គឺជាការវិលត្រឡប់ទៅរកសភាពដើមវិញក្រោយពីមានការរំខាន –ថាតើការរំខាននោះកើតឡើងដោយធម្មជាតិដូចជា ព្រឹត្តិការណ៍ព្យុះសង្ឃរាមួយ ឬរលកយក្សស៊ូណាមិ ឬថាតើកើតឡើងដោយមនុស្ស ដូចជា ការបំផ្លិចបំផ្លាញរូបវន្តនៃថ្មប៉ប្រះទឹកដោយប្រើគ្រាប់បែកក្នុងការនេសាទត្រី ឬគ្រោះមហន្តរាយដោយសារការធ្លាយកំពុបប្រេង ។ ការធ្វើវិនិយោគ ពេលវេលា និង ថាមពលដើម្បីបង្កើតប្រព័ន្ធអេកូស៊ីស្ទែមឱ្យមានសុខភាព និងផលិតភាពតាមដែលអាចធ្វើទៅបានដើម្បី រក្សានូវភាពធន់របស់ពួកគេ ។

ទាក់ទងនឹងការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរ និងគិតគូរអំពីការគម្រាមកំហែងដែលចេះតែកើនឡើងនោះការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមផ្តល់ផលប្រយោជន៍តាមរយៈការកំណត់ការបន្សាំផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែម (EBA) ។

ការបន្សាំផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមទាក់ទងនឹងការគ្រប់គ្រងនៃជីវចម្រុះ និង ធនធានធម្មជាតិតាមរបៀបដែលនឹងជួយសហគមន៍ងាយរងគ្រោះ ដោះស្រាយនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងបាតុភូតផ្សេងៗទៀត។ យុទ្ធសាស្ត្រនៃការបន្សាំផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមអាចរាប់បញ្ចូលទាំង ការគ្រប់គ្រងជំរកតំបន់សមុទ្រ (ឧ. ព្រៃកោងកាង ទំនប់ខ្សាច់ និង ស្រែអំបិល) ដើម្បីការពារសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធទប់ទល់នឹងខ្យល់ព្យុះ។ ឧទាហរណ៍ជាក់ស្តែងគឺអាងកំពុងបាយនៃប្រទេសកម្ពុជា ជាកន្លែងដែលមានការសិក្សាមួយអំពីភាពងាយរងគ្រោះពីអាកាសធាតុដែលធ្វើឱ្យអ្នកធ្វើផែនការវិភាគលើនូវការព្យាករណ៍ការប្រែប្រួលអាកាសធាតុ និង ការឆ្លើយតបពីការគ្រប់គ្រងដែលមានការពាក់ព័ន្ធខុសៗគ្នា។ ជាថ្នូរមកវិញប្រការនេះអនុញ្ញាតឱ្យអ្នកគ្រប់គ្រងធ្វើការវាយតម្លៃការប៉ះប៉ូវក្នុងចំណោមវិធានការគ្រប់គ្រងជាក់លាក់។ដោយការប្រើប្រាស់នូវការកសាងភាពធន់នៃប្រព័ន្ធអេកូស៊ីស្ទែមដើម្បីបន្សាំនឹងការប្រែប្រួលអាកាសធាតុនោះការបន្សាំផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមជាការអនុវត្តផ្ទាល់នូវការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែម។

នៅពេលដែលអនុវត្តដំណើរការការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមតម្រូវឱ្យមានការផ្លាស់ប្តូរមួយចំនួន ចំពោះក្របខណ្ឌគ្រប់គ្រងដែលមានស្រាប់ វាគប្បីទាញយកផលប្រយោជន៍ដោយមិនធ្វើអ្វីឱ្យអន្តរាយដល់ ឬ ព្រងើយកន្តើយចំពោះសមត្ថភាព កម្លាំងជំរុញ ឬវឌ្ឍនៈភាពដែលមានស្រាប់។ ដំណើរការ EBM ល្អមួយចាប់ផ្តើមដោយការវាយតម្លៃដ៏ម៉ត់ចត់នូវគោលនយោបាយ និងការអនុវត្តបច្ចុប្បន្នដែលមានរួចស្រេច និងថាតើពួកវាមានប្រសិទ្ធភាពរបៀបណាមួយវិស័យម្តងមួយវិស័យម្តង។ បន្ទាប់មកកំណត់ឱកាសដើម្បីចាប់ផ្តើមកសាងប្រព័ន្ធ អេកូស៊ីស្ទែមមួយផ្តោតលើក្របខណ្ឌគ្រប់គ្រងទាំងនោះនឹងចំពោះទស្សនៈទាន និងផ្តោតលើផ្នត់គំនិត និងការយល់ដឹងរបស់អ្នកពាក់ព័ន្ធ។

ការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមផ្តោតលើវិធីសាស្ត្រគ្រប់គ្រងដែលមានស្រាប់ និង ដែលមានសារៈសំខាន់ផ្សេងទៀតដោយមិនព្យាយាមឆ្នៃប្រឌិតឡើយ។ ក្នុងន័យនេះ វិសាលភាពភូមិសាស្ត្រនៃការគ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមអាចគ្របដណ្តប់ជារួមនូវយុទ្ធសាស្ត្រគ្រប់គ្រងចំនួន៥ដែលកំពុងអនុវត្តក្នុងតំបន់សមុទ្រអាស៊ីបូព៌ាៈ (១) ដីឆ្នេរសមុទ្រ និងបរិស្ថានជាប់នឹងច្រាំងសមុទ្រដោយប្រើប្រាស់វិធានការគ្រប់គ្រងតំបន់ឆ្នេរចម្រុះ (ICZM) (២) បរិស្ថានសមុទ្រដោយការរៀបចំផែនការប្រើប្រាស់សមុទ្រ (MSP) (៣) ទន្លេ និងអាងប្រព័ន្ធបង្ហូរទឹកនៅតាមទីជម្រាលដែលបង្ហូរទឹកចូលទៅសមុទ្រ (៤) ដែនទឹកគាំទ្រដល់អាងស្តុកត្រីដែលធ្វើអាជីកម្ម និង (៥) បរិស្ថានសមុទ្រ និងឆ្នេរឡោមព័ទ្ធដោយតំបន់ការពារសមុទ្រ (MPA)។

ប្រទេសមួយចំនួនដែលការគ្រប់គ្រងតំបន់ឆ្នេរចម្រុះមានភាពជឿនលឿនយល់ឃើញថាពួកគេបានកំពុងអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែម។ ការគ្រប់គ្រងតំបន់ឆ្នេរចម្រុះនៅក្នុងប្រទេសទាំងនេះអាចត្រូវបានចំរាញ់ឱ្យទៅជាការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែម ដោយផ្លាស់ប្តូរពីព្រំដែននយោបាយទៅកាន់ព្រំដែនអេកូស៊ីស្ទែម–ផ្សារភ្ជាប់សកម្មភាពការប្រើប្រាស់ដីក្នុងតំបន់ឆ្នេរ និងទឹកក្បែរច្រាំងសមុទ្រ និង ដោះស្រាយទៅនឹងសេវាកម្មប្រព័ន្ធអេកូស៊ីស្ទែមការប្រកបរបរចិញ្ចឹមជីវិត និងបញ្ហាសមភាព។ ចំពោះហេតុផលនេះ វាអាចសមហេតុផលក្នុងការចាប់ផ្តើមជាមួយនឹង

ការកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំដែលគោលនយោបាយ ការគ្រប់គ្រងតំបន់ឆ្នេរចម្រុះអាចផ្តល់ឱ្យនិងផ្លាស់ទីទៅកាន់ការវាយតម្លៃប្រព័ន្ធអេកូស៊ីស្ទែមថាជាជំហានដំបូងក្នុងទិសដៅនៃការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមឱ្យកាន់តែពេញលេញ។

ការរៀបចំផែនការប្រើប្រាស់តំបន់សមុទ្រអាចត្រូវបានគិតថាជាការនឹកគិតក្នុងចិត្ត និងការគិតគូរអំពីការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែម។ ការរៀបចំផែនការប្រើប្រាស់តំបន់សមុទ្រគឺជាមធ្យោបាយមួយដើម្បីបង្កើតរូបភាពធំមើលឃើញថាតើការប្រើប្រាស់ធនធានសមុទ្រ និងលំហរអ្វីកំពុងកើតឡើងនៅទីណា និង កំណត់ថាតើអ្វីគួរកើតឡើងដោយមានផលប៉ះពាល់តិចតួច និងមានជម្លោះអ្នកប្រើប្រាស់កាន់តែតិចតួច។ វិធានការគ្រប់គ្រងដែលបញ្ជាក់ច្បាស់តាមផ្អែក និងខ្នាតតូច ដូចជាការបែងចែកតំបន់ប្រើប្រាស់ច្រើនយ៉ាងការកំណត់បណ្តាញតំបន់ការពារសមុទ្រ ឬ តំបន់ការពាររៀងៗខ្លួនអាច–ប៉ុន្តែមិនមែនជានិច្ច– មានលំហូរចេញពី MSP។ ផលប្រយោជន៍នៃ MSP គឺថាវាអាចឱ្យអ្នកធ្វើផែនការ និងអ្នកគ្រប់គ្រងធ្វើសមាហរណកម្មព័ត៌មានអំពីលក្ខណៈប្រព័ន្ធអេកូស៊ីស្ទែមនិងថាតើមនុស្សមានឥទ្ធិពលលើពួកវារបៀបណា (និង ត្រឡប់វិញ) និងថាតើពួកវាភ្ជាប់ទំនាក់ទំនងជាមួយប្រព័ន្ធអេកូស៊ីស្ទែមរបៀបណា (ឬមានផលប៉ះពាល់ដល់អ្នកផ្សេងទៀត)។ ព័ត៌មាននេះអាចត្រូវបានគូសបញ្ជាក់ដើម្បីបង្កើតមូលដ្ឋាននៃ **(ក)** បទបញ្ញត្តិតាមវិស័យផ្អែកលើទីតាំងទាក់ទងនឹងការប្រើប្រាស់ជាក់លាក់ **(ខ)** ផែនការសម្រាប់ការស្រាវជ្រាវអនាគត ការត្រួតពិនិត្យតាមដាន និងវាយតម្លៃដើម្បីបំពេញព័ត៌មានខ្វះចន្លោះ និង/ឬ **(គ)** ផែនការបែងចែកតំបន់មហាសមុទ្រដ៏ស៊ីជម្រៅមួយ។ នៅពេលដែលអ្នកគ្រប់គ្រងឆ្នេរ និងសមុទ្រមិនអាចមានឥទ្ធិពលលើអ្វីដែលកើតឡើងនៅខ្សែទឹកខាងលើពីតំបន់របស់ពួកគេ ហើយពួកគេអាចធ្វើឱ្យខូចខាតធ្ងន់ធ្ងរក្នុងការបញ្ឈប់ការសឹករេចរិលពីការធ្លាក់ចុះនូវគុណភាព បរិមាណ និង ថេរៈវេលានៃទឹកសាបហូរ និង កករហូរមកចាក់តាមដៃទន្លេ និងសមុទ្រ។ ការគ្រប់គ្រងជម្រាលគឺស្ថិតក្នុងចំណោមយុទ្ធសាស្ត្រចាស់ៗបំផុតសម្រាប់ការគ្រប់គ្រងបរិស្ថានដែលនៅមានដោយកើតឡើងជាការឆ្លើយតបមួយទៅនឹងគ្រោះថ្នាក់ ឬជម្លោះលើវត្តមានទឹកសម្រាប់ការទទួលទាន និង/ឬសម្រាប់ការស្រោចស្រព។ ចំពោះហេតុផលនេះភ្នាក់ងារគ្រប់គ្រងសមុទ្រ និងឆ្នេរគួររៀបចំកិច្ចប្រជុំដើម្បីរៀបចំផែនការសកម្មភាព និងការអភិវឌ្ឍគោលនយោបាយដែលជះឥទ្ធិពលលើតំបន់ជម្រាលឆ្នេរ។

តំបន់ការពារសមុទ្រ(តំបន់ការពារសមុទ្រ) អាចជាឧបករណ៍ដ៏មានប្រយោជន៍ក្នុងការអនុវត្តការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមដោយកំណត់នូវការប្រើប្រាស់ខុសៗគ្នាតាមតំបន់។ និយាយជារួមតំបន់ការពារសមុទ្រត្រូវបានប្រើសម្រាប់ការការពារជម្រក ឬពពួកសត្វពិសេស ថែរក្សាការរកស៊ីចិញ្ចឹមជីវិត សម្របសម្រួលការស្តារឡើងវិញ ឬ គ្រប់គ្រងការប្រើប្រាស់តំបន់សំខាន់ៗសម្រាប់កំសាន្ត វប្បធម៌ និងប្រវត្តិសាស្ត្រ។ តំបន់ការពារអាចឱ្យអ្នកគ្រប់គ្រង ការពារតំបន់សំខាន់បំផុតសម្រាប់មុខងារអេកូស៊ីស្ទែម និង ការផ្តល់សេវាកម្មអេកូស៊ីស្ទែម។ ការខ្វះចន្លោះអាចជៀសវាងបានដោយការបញ្ចូលការរៀបចំផែនការតំបន់ការពារសមុទ្រទៅក្នុង MSP ឱ្យកាន់តែទូលាយនិងកិច្ចខិតខំប្រឹងប្រែងបែងចែកតំបន់មហាសមុទ្រ។ ការបែងចែកឱ្យនៅដាច់ពីគេនៃតំបន់ការពារអាចឱ្យមានទំនាក់ទំនងជាមួយ សមាហរណកម្ម និងវិធីសាស្ត្រការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែម–និងជាញឹកញាប់តំណាងឱ្យកន្លែងដែលជំហានដំបូងស្របតាមការអនុវត្ត ការគ្រប់គ្រងផ្អែកលើប្រព័ន្ធ

អេកូស៊ីស្ទែមត្រូវបានធ្វើឡើង។ ប្រសិនបើតំបន់មួយ ជាបណ្តាញនៃតំបន់ការពារសមុទ្រត្រូវបានបង្កើតឡើងយ៉ាងល្អនោះការអនុម័តនូវទស្សនៈ ការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមប្រហែលជាអាចចាប់ផ្តើមដោយបន្ថែមនូវការអនុវត្តការគ្រប់គ្រងដែលភ្ជាប់ការអភិរក្សដី និងសមុទ្រ ឬការពិនិត្យឡើងវិញថាតើតំបន់ការពារសមុទ្របន្ទុំទៅនឹងទ្រព្យសម្បត្តិដ៏សំខាន់សម្រាប់ការកសាងភាពធននិងការធ្វើសមាហរណកម្មអេកូស៊ីស្ទែមរបៀបណា។

នៅពេលដែលការគ្រប់គ្រងតំបន់ឆ្នេរ និង សមុទ្រ រីកសាយភាយ និងមានភាពចាស់ទុំនោះបរិបទដើម្បីបោះជំហានទៅរកការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមគឺកាន់តែមានការចូលចិត្តខ្លាំងឡើង។ កាបង្កើតនូវការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមប្រកបដោយប្រសិទ្ធភាពក្នុងទីកន្លែង ពិសេសមួយនឹងមានតម្រូវការយល់ដឹងពីក្របខណ្ឌច្បាប់ កិច្ចព្រមព្រៀងអន្តរជាតិ និងវិវត្តភាពការយល់ដឹងលើការដោះស្រាយនឹងភាពមិនប្រាកដប្រជាដែលមានក្នុងតំបន់។

## ឯកសារសម្រាប់អានបន្ថែម:

Agardy, T. 2010. **Ocean Zoning, Making Marine Management More Effective.** Earthscan Publications. London.

Christensen, Norman L., Ann M. Bartuska, James H. Brown, Stephen Carpenter, Carla D'Antonio, Rober Francis, Jerry F. Franklin, James A. MacMahon, Reed F. Noss, David J. Parsons, Charles H. Peterson, Monica G. Turner, and Robert G. Woodmansee. 1996. **The Report of the Ecological Society of America Committee on the Scientific Basis for Ecosystem Management.** Ecological Applications 6:665–691.

Clarke P and S. Jupiter. 2010**. Principles and Practice of Ecosystem-Based Management: A Guide for Conservation Practitioners in the Tropical Western Pacific**. Wildlife Conservation Society. Suva, Fiji. Available at: www.wcs.org/files/pdfs/EBMguide0510_low.pdf

Coast Information Team. 2004. **Ecosystem-based Management Framework.** British Columbia, Canada. Available at: http://www.citbc.org/ebm.html

Coast Information Team. 2004. **Ecosystem-based Management Planning Handbook.** British Columbia, Canada. Available at: http://www.citbc.org/ebm.html

Communication Partnership for Science and the Sea. 2005. **Consensus Statement on Marine Ecosystem-Based Management**. Available at: http://compassonline.org/pdf_files/EBM_Consensus_Statement_v12.pdf

Communication Partnership for Science and the Sea. 2005. **Implementing Marine Ecosystem-Based Management: Integrating Perspectives From Science and Management**. Monterey. Available at: http://compassonline.org/pdf_files/EBM_12_05_Synthesis_5pg.pdf

Conservation Law Foundation – USA, WWF-Canada. 2006. **Marine Ecosystem Conservation for New England and Maritime Canada: a Science-Based Approach to Identifying Priority Arភូមិភាគសមុទ្រអាស៊ីអាគ្នេយ៍ for Conservation.** CLF, Boston, and WWF-Canada, Halifax.

Karen McLeod and Heather Leslie (eds). 2009. **Ecosystem-based management for the oceans**. Island Press. Washington.

UNEP. 2011. Taking Steps Toward Marine and Coastal Ecosystem-based Management – An Introductory Guide. UNEP Regional SEAS Reports and Studies No. 189.

Walker, B., C. S. Holling, S. R. Carpenter, and A. Kinzig. 2004. Resilience, adaptability and transformability in social–ecological systems. Ecology and Society 9(2): 5. [online] URL: http://www.ecologyandsociety.org/vol9/iss2/art5/

Walters, C. 1997. Challenges in adaptive management of riparian and coastal ecosystems. Conservation Ecology [online]1(2):1. Available at: http://www.consecol.org/vol1/iss2/art1/

**Some relevant websites:**
http://compassonline.org

http://www.marineplanning.org/ focus is primarily North America, but much can be learned and applied elsewhere.

http://www.resalliance.org/

http://www.seaweb.org and especially http://www.seaweb.org/resources/ebm.php

**Tools of various kinds can be found at:**
http://www.ebmtools.org/

http://wiki.resalliance.org/index.php/Main_Page Resilience assessment.

http://www.smartgrowthtools.org and especially: http://www.smartgrowthtools.org/ebmtools/index.php A large number of tools listed here with links. Many of specific to parts of the USA.

## ការគ្រប់គ្រងហានិភ័យ និង មុខសញ្ញាគ្រោះថ្នាក់ និងការរៀបចំផែនការបែងចែកការប្រើប្រាស់តំបន់ឆ្នេរ

ចំណុចសំខាន់នៃផ្នែកនេះគឺការគូសបញ្ជាក់នូវផ្លូវបំបែករវាងការគ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់ និង ហានិភ័យ និង ការកសាងផែនការគ្រប់គ្រងការបែងចែកតំបន់។ ប្រទេសនៅតំបន់សមុទ្រអាស៊ីបូព៌ាស្ថិតនៅតំបន់ភូមិសាស្ត្រមួយដែលជាពិសេសងាយរងគ្រោះចំពោះមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ ដូចជាការរញ្ជួយដី បន្ទុះភ្នំភ្លើង ខ្យល់ព្យុះ និងព្យុះសង្ឃរា និង គ្រោះមហន្តរាយបន្តបន្ទាប់ដូចជា ការរអិលបាក់ដី ទឹកជំនន់ ព្យុះ សន្ទុះខ្យល់ព្យុះ និង ស៊ូណាមិ។ល។ ប្រទេសភាគច្រើនមានបង្កើតប្រព័ន្ធសម្រាប់ដោះស្រាយគ្រោះមហន្តរាយទាំងនេះតាមរយៈផែនការត្រៀម ឬ ការកាត់បន្ថយហានិភ័យ។ តាមបែបប្រពៃណីរដ្ឋាភិបាលក្នុងតំបន់សមុទ្រអាស៊ីបូព៌ាមានប្រតិកម្មចំពោះគ្រោះមហន្តរាយហានិភ័យបន្ទាប់ពីបានកើតឡើងជាជាងការផ្តោតលើវិធានការបង្ការដើម្បីកាត់បន្ថយភាពងាយរងគ្រោះ និង ផលប៉ះពាល់ក្នុងកន្លែង។ វិធានការឆ្លើយតបក្រោយមានគ្រោះមហន្តរាយនាំមកនូវការចំណាយ និង បង្ហាញនូវការអភិវឌ្ឍជោគជ័យលើហានិភ័យដែលមិនចាំបាច់ និង មើលឃើញមិនឆ្ងាយ។ ថ្មីៗនេះ ទោះជាយ៉ាងណាក៏ដោយតំបន់នេះបានចាប់ផ្តើមធ្វើឱ្យមានការរីកចម្រើនក្នុងការពង្រឹងសមត្ថភាពគ្រោះមហន្តរាយ។

នៅតែមានគ្រោះមន្តរាយបន្តបន្ទាប់ធ្វើឱ្យខូចខាតដល់ការអភិវឌ្ឍដែលបានកើតឡើងនៅតំបន់អាស៊ីបូព៌ា និង តំបន់អាស៊ីប៉ាស៊ីហ្វិកដែលខាតបង់សេដ្ឋកិច្ចសកលប្រមាណ៤២% និង៨៥%ស្លាប់ដោយសារទទួលរងផលប៉ះពាល់ពីមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ។ ធនាគារអភិវឌ្ឍន៍អាស៊ី(ADB)បានរៀបចំ និងដោះស្រាយនូវគ្រោះមហន្តរាយទាំងនេះតាមរយៈការលើកកម្ពស់វិធានការសមាហរណកម្មការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ (DRM) ដែលរួមទាំងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការផ្តល់ហិរញ្ញវត្ថុលើហានិភ័យគ្រោះមហន្តរាយ។

ក្នុងឆ្នាំ២០០៤ ធនាគារអភិវឌ្ឍន៍អាស៊ីអនុម័តគោលនយោបាយផ្តល់ជំនួយសង្គ្រោះបន្ទាន់ និងគ្រោះមហន្តរាយរបស់ខ្លួនដែលលើកស្ទួយគំរូគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយចម្រុះដែលដោះស្រាយការខ្វះចន្លោះដែលមានបីផ្នែកគឺគោលនយោ-បាយហិរញ្ញប្បទាន និងសមត្ថភាព។ គំរូនេះរួមមានការកាត់បន្ថយហានិភ័យគ្រោះមន្តរាយ និង ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ វិធីសាស្ត្រនេះអាចធ្វើឱ្យមានសហផលជាអតិប្បរិមាសម្រាប់ការវិនិយោគក្នុងវិធានការកសាងភាពធន់ការពារប្រឆាំងនឹងមុខសញ្ញាគ្រោះថ្នាក់ចម្រុះ។ ដើម្បីអនុវត្តគំរូហានិភ័យគ្រោះមហន្តរាយចម្រុះ ធនាគារអភិវឌ្ឍន៍អាស៊ីបង្កើតនូវដំណោះស្រាយជាច្រើនអាចអនុវត្តបានក្នុងពហុលក្ខខណ្ឌ:

- គម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយhttp://www.drrprojects.net/drrp/drrpp/home ដើម្បីពង្រឹងបណ្តាញតំបន់លើការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ និង ផ្តល់ព័ត៌មានលើដំណើរការក្នុងការអនុវត្តគម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងតំបន់ និងកំណត់នូវការខ្វះចន្លោះ និងវិស័យសហប្រតិបត្តិការក្នុងចំណោមដៃគូអភិវឌ្ឍន៍។
- ការទទួលបាននូវហិរញ្ញប្បទានដែលមានភាពបត់បែនគឺជាកូនសោរសំខាន់សម្រាប់តំបន់នេះ។ ដោយមានកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ជាច្រើន ធនាគារអភិវឌ្ឍន៍អាស៊ីកំពុងធ្វើការបង្កើតមូលនិធិពហុម្ចាស់ជំនួយសម្រាប់ការគ្រប់គ្រង

ហានិភ័យគ្រោះមហន្តរាយចម្រុះ។ ជំនួយឥតសំណងពីមូលនិធិទាយទានគួរផ្តល់នូវយន្តការមួយសម្រាប់ផ្តល់មូលនិធិប្រកបដោយគំនិតនវានុវត្តន៍ ថែមទាំងសម្រាប់ការឆ្លើយតបចំពោះសមាជិកប្រទេសស្នើសុំជំនួយធនាគារអភិវឌ្ឍន៍អាស៊ីខ្នាតតូច សម្រាប់ការវាយតម្លៃហានិភ័យ ការអភិវឌ្ឍសមត្ថភាព និង សិក្សាវិសាលភាពការងារ។

នាយកដ្ឋានអភិវឌ្ឍន៍ប្រកបដោយចីរភាពនិងតាមតំបន់ក្នុងធនាគារអភិវឌ្ឍន៍អាស៊ីគឺកំពុងផ្តួចផ្តើមគម្រោងផ្តល់ជំនួយតំបន់ថ្មីចំនួនពីរក្នុងឆ្នាំ២០១១ដែលនឹងបង្កើតដំណោះស្រាយហិរញ្ញវត្ថុហានិភ័យគ្រោះមហន្តរាយសម្រាប់ទីក្រុងនៅឥណ្ឌូនេស៊ី ហ្វីលីពីន និង វៀតណាម http://www.adb.org/projects/project.asp?id=43553 គម្រោងនឹងមានការគាំទ្រការងារជាមួយប្រទេសទាំងនេះដើម្បីបង្កើតប្រវត្តិហានិភ័យ បង្កើតគំរូហានិភ័យសម្រាប់មុខសញ្ញាគ្រោះថ្នាក់អាទិភាព និង ស្វែងរកនូវលទ្ធភាពដោះស្រាយផ្ទេរហានិភ័យជាច្រើន។ ក្នុងរយៈពេល៣ឆ្នាំ ធនាគារអភិវឌ្ឍន៍អាស៊ីសង្ឃឹមថាប្រការនេះនឹងផ្តល់នូវឈុតគំរូហិរញ្ញប្បទានសម្រាប់ហានិភ័យគ្រោះមហន្តរាយដែលអាចអនុវត្តនៅផ្នែកខ្លះទៀតនៅតំបន់អាស៊ី។

ការរីកចម្រើនដ៏អស្ចារ្យនៃតំបន់ទីក្រុងនៅតំបន់អាស៊ីបូព៌ាមានន័យថាទីក្រុងទាំងឡាយមានការកើនឡើងនូវការសាងសង់ និងពង្រីកតំបន់ងាយមានហានិភ័យដោយប្រើនូវការកសាងបច្ចេកទេសដែលមិនត្រូវបានអភិវឌ្ឍដើម្បីដោះស្រាយនូវការទទួលរងហានិភ័យនៃតំបន់ទីក្រុង និង បន្តការពង្រីកក្រុងដោយមិនមានយន្តការអភិបាលកិច្ចគ្រប់គ្រាន់ដើម្បីដោះស្រាយតម្រូវការអ្នកតាំងទីលំនៅនិងអ្នកក្រ។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ ការកាត់បន្ថយនូវហានិភ័យទីក្រុងឥឡូវមានតួលេខលេចធ្លោក្នុងផែនការប្រតិបត្តិការទីក្រុងរបស់ធនាគារអភិវឌ្ឍន៍អាស៊ីថ្មីៗដែលកំពុងតែបញ្ចប់។ លើសពីនោះធនាគារអភិវឌ្ឍន៍អាស៊ីកំពុងប្រើគម្រោងជំនួយសហប្រតិបត្តិការហិរញ្ញវត្ថុ បច្ចេកទេសដើម្បីបង្កើតសៀវភៅមគ្គុទេសពីការកសាងផែនការប្រើប្រាស់ដីឆ្លើយតបនឹងហានិភ័យ ឧបករណ៍កាត់បន្ថយហានិភ័យនៅទីក្រុងសម្រាប់អាជ្ញាធរមូលដ្ឋាន និងគំរូពីការផ្តល់ហិរញ្ញប្បទានសម្រាប់ហានិភ័យគ្រោះមហន្តរាយទីក្រុង។ ធនាគារអភិវឌ្ឍន៍អាស៊ីកំពុងស្រាវជ្រាវរកគំនិតផ្តួចផ្តើមថ្មីប្រកបដោយសក្តានុពលលើការគ្រប់គ្រងហានិភ័យ និង អភិបាលកិច្ចបរិស្ថានដើម្បីលើកស្ទួយ និងគ្រប់គ្រងឱ្យកាន់តែប្រសើរលើការអន្តរាគមន៍ប្រព័ន្ធនយោបាយ សេដ្ឋកិច្ច និងសង្គមជាមួយនឹងបរិស្ថានធម្មជាតិក្នុងបរិបទហានិភ័យគ្រោះមហន្តរាយ និងហានិភ័យអាកាសធាតុ។

សកម្មភាពមនុស្សមិនសមស្របអាចធ្វើឱ្យផលប៉ះពាល់នៃមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិកាន់តែអាក្រក់ទៅៗ។ បច្ចុប្បន្ននេះ គេមិនមានលទ្ធភាពអាចគ្រប់គ្រងខ្យល់ព្យុះបានទេ ប៉ុន្តែគេអាចប្រើប្រាស់នូវការសម្រេចចិត្តគ្រប់គ្រងជាច្រើនដើម្បីកាត់បន្ថយផលប៉ះពាល់ខ្យល់ព្យុះនោះលើមនុស្ស ហើយការកសាងផែនការបែងតំបន់ប្រើប្រាស់ដែលរួមបញ្ចូលជាមួយនឹងលក្ខខណ្ឌបែងចែកតំបន់គឺជាឧបករណ៍មួយដែលអ្នកគ្រប់គ្រងអាចប្រើប្រាស់ដើម្បីកាត់បន្ថយឥទ្ធិពលទាំងនេះបាន។ មានផែនការបង្ការជាច្រើនទៀតត្រូវបានដកស្រង់ពីព្រឹត្តិការណ៍ ឬ គ្រោះអាសន្នថាតើទាំងនេះគឺសម្រាប់ខ្យល់ព្យុះ ឬ ឧប្បទ្ទវហេតុក្នុងរោងចក្រ ឬនៅលើផ្លូវ។ ទោះជាយ៉ាងណាក៏ដោយការយកចិត្តទុកដាក់កំពុងផ្តោតសំខាន់លើ **ហានិភ័យកំពុងកើតឡើង *(Emerging Risks)*** –មុខសញ្ញាគ្រោះថ្នាក់ដែលមានចំណុចចាប់ផ្តើមយឺតៗ ហើយការប្រែប្រួលអាកាសធាតុ

គឺជាកត្តាមួយក្នុងចំណោមមុខសញ្ញាគ្រោះថ្នាក់ទាំងនោះ។ ផលប៉ះពាល់កាន់តែច្រើនដោយសារសកម្មភាពតូចៗរបស់មនុស្ស ដែលគ្មានសកម្មភាពណាមួយគេគិតថាមានគ្រោះថ្នាក់នោះអាចបណ្តាលឱ្យប៉ះពាលដល់បរិស្ថាននិងបង្កការខូចខាតធ្ងន់ធ្ងរដល់សេវាកម្មប្រព័ន្ធអេកូស៊ីស្តែម និង សង្គមមនុស្សក្នុងតំបន់។

ផលប៉ះពាល់នៃព្រឹត្តិការណ៍មុខសញ្ញាគ្រោះថ្នាក់អាចត្រូវបានបែងចែកទាក់ទងនឹងរបាយនៃការបែងចែកតំបន់ ភាពធ្ងន់ធ្ងរ និង ថេរៈវេលា។ ផលប៉ះពាល់ក៏ទាក់ទិននឹងភាពងាយរងគ្រោះ និងការកសាងភាពធន់ផងដែរ។ ភាពងាយរងគ្រោះប្រើសម្រាប់វាស់ស្ទង់ការប្រឈមនឹងមុខសញ្ញាគ្រោះថ្នាក់។ ពាក្យថាភាពធន់នៅទីនេះសំដៅលើលទ្ធភាពរបស់បុគ្គលគ្រួសារ សហគមន៍ ស្ថាប័ន ឬសូម្បីតែប្រព័ន្ធអេកូស៊ីស្តែមដើម្បីងើបរើឡើងវិញពីព្រឹត្តិការណ៍គ្រោះថ្នាក់ហើយពាក្យថា **ភាពធន់** *(Resilience)* គឺផ្ទុយគ្នាស្រឡះនឹងពាក្យថា **ភាពងាយរងគ្រោះ** *(Vulnerability)* ។

ជាទូទៅ មុខសញ្ញាគ្រោះថ្នាក់គឺត្រូវបានកំណត់និយមន័យបែបហ្នឹងនៅពេលដែលមានផលប៉ះពាល់លើមនុស្ស និងសកម្មភាពមនុស្ស។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលមានការយល់ដឹងកាន់តែទូលំទូលាយនូវការពឹងផ្អែករបស់សង្គមលើប្រព័ន្ធអេកូស៊ីស្តែម អ្នកគ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់ក៏នឹងរួមបញ្ចូលនូវលក្ខណៈបរិស្ថានសំខាន់ៗផងដែរដែលអាចមានផលប៉ះពាល់អវិជ្ជមានដោយសារព្រឹត្តិការណ៍ទាំងនេះថាតើវាកើតឡើងឆាប់ ឬក៏យូរ។

***ប្រភេទនៃសំនួរដែលអ្នកកសាងផែនការនឹងសួរនៅពេលដែលស្វែងរកការបញ្ចូលការកាត់បន្ថយហានិភ័យ និងការគ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់ក្នុងដំណើរការកសាងផែនការ រួមមានៈ***

១. អ្វីជាមុខសញ្ញាគ្រោះថ្នាក់ដោយសារកត្តាធម្មជាតិ និងមនុស្សទាក់ទិននឹងវិស័យកសាងផែនការ? តើអ្វីជាលក្ខណៈពិសេសរបស់ពួកគេជាពិសេសទាក់ទងនឹងតំបន់ភូមិសាស្ត្រ ភាពធ្ងន់ធ្ងរ និង រយៈពេលនៃផលប៉ះពាល់?

២. តើមានអ្វីខ្លះ-ប្រសិនបើមាន-ជាមុខសញ្ញាគ្រោះថ្នាក់ទី២ឬផលវិបាកបន្ទាប់ពីមានគ្រោះថ្នាក់លើកដំបូង? (ឧ. អគ្គីភ័យក្រោយពីមានរញ្ជួយដីនៅតំបន់ទីក្រុង) តើវាទំនងជាកើតមានឡើងនៅម្តុំណាទៀត?

៣. តើមានអ្វីខ្លះកំពុងប្រឈមមុខនឹងហានិភ័យ ហើយក្រុមប្រជាជនណាខ្លះ កំពុងទទួលរងនូវហានិភ័យនេះ (ប្រឈមជាមួយមុខសញ្ញាគ្រោះថ្នាក់) ហើយតើពួកគេនៅកន្លែងណា?

៤. តើពួកគេមានភាពរឹងមាំប៉ុណ្ណាក្នុងការប្រឈមជាមួយមុខសញ្ញាគ្រោះថ្នាក់ពិសេសៗនោះ? ភាពរឹងមាំសំដៅលើលទ្ធភាពបន្តបំពេញមុខងារ និងសេវាកម្មអំឡុងពេលមានព្រឹត្តិការណ៍កើតឡើង។ ប្រព័ន្ធអេកូស៊ីស្តែមមានសុខភាពហាក់ដូចមានភាពកាន់តែរឹងមាំនៅពេលប្រឈមនឹងគ្រោះមហន្តរាយធម្មជាតិជាងប្រព័ន្ធសឹករេចរិល។ ប្រសិនបើមុខសញ្ញាគ្រោះថ្នាក់ដោយសារធម្មជាតិកើតមានជាទូទៅក្នុងតំបន់នោះ ប្រព័ន្ធអេកូស៊ីស្តែមប្រហែលមានការវិវត្តដើម្បីសង្គ្រោះពួកគេឱ្យមានជីវិតវិញបាន។

៥. តើពួកគេទទួលរងគ្រោះ ឬអាចធន់បានយ៉ាងដូចម្តេចចំពោះមុខសញ្ញាគ្រោះថ្នាក់ជាក់លាក់នោះ? ថាតើពួកគេរំពឹងថានឹងអាចស្តារឡើងវិញបានកម្រិតណាតើអាចទទួលផល មុខងារឬ ទម្រង់បានស្រដៀងគ្នាទេបន្ទាប់ពីព្រឹត្តិការណ៍មួយកើតឡើង?

តើអ្វីជាបុព្វហេតុនៃភាពងាយរងគ្រោះឬភាពធន់របស់គេ? ចំពោះអ្នកធ្វើផែនការ សំនួរនេះអាចបង្ហើបឱ្យដឹងថាការអនុវត្តការធ្វើផែនការបែងចែកតំបន់ប្រើប្រាស់ជាកន្លែងដែលភាពងាយរងគ្រោះមានទំនាក់ទំនងផ្ទាល់ជាមួយទីតាំងដង់ស៊ីតេ ឬ កម្រិតនៃការប្រើប្រាស់ដី កង្វះខាតនៃលទ្ធភាពទៅដល់ និងមកពីតំបន់ទាំងនោះ ។ល។ កត្តាទាំងនេះអាចអនុវត្តដោយផ្ទាល់នៅក្នុងផែនការបែងចែកតំបន់ប្រើប្រាស់ ។

៦. តើអ្វី និង នៅកន្លែងណាដែលមានសមាសភាពឆ្លើយតបសង្គ្រោះបន្ទាន់ ដូចជា កន្លែងឱសថការី ប៉ុស្ដិ៍នគរបាល ការផ្គត់ផ្គង់សម្រាប់ការសង្គ្រោះបន្ទាន់ ផ្លូវជម្លៀសចេញការបម្រុងនូវការផ្គត់ផ្គង់អគ្គិសនី ទីជម្រកជនភៀសខ្លួន? តើកត្តាទាំងនេះស្ថិតនៅក្នុងទីតាំងមានសុវត្ថិភាព និងធម្មជាតិរឹងមាំមួយរឺនៅ?

សំនួរទាំងនេះមានភាពស្រដៀងគ្នាទៅនឹងសំនួរដែលអ្នកកសាងផែនការយថាភាព ឬសេវាកម្មជួយសង្គ្រោះនឹងចោទសួរ ។ ក្រុមទាំងនេះនឹងផ្តោតទៅលើបញ្ហាប្រតិបត្តិការ – ទិដ្ឋភាពស្ថាប័ន និង អង្គការនៃការត្រៀមរៀបចំការឆ្លើយតប និង ការសង្គ្រោះ – ចំណែកឯអ្នកកសាងផែនការបែងចែកតំបន់វិញនឹងផ្តោតលើទិដ្ឋភាពទីតាំងក្នុងគោលបំណងដើម្បី:

- ការកាត់បន្ថយនូវការប្រឈមចំពោះមុខសញ្ញាគ្រោះថ្នាក់តាមរយៈការជៀសវាងពីកន្លែងដែលគ្មានសុវត្ថិភាពហាមឃាត់មិនឱ្យមានការអភិវឌ្ឍក្នុងតំបន់អាចមានទឹកជំនន់ជន់លិច ទីជម្រាលចោទ និងគ្មានស្ថេរភាពដោយប្រើប្រាស់វិធានការ **Set Backs** តាមបណ្តោយឆ្នេរដែលប្រឈមនឹងខ្យល់ព្យុះ និង រលកយក្សស៊ូណាមិ ។
- ធ្វើឱ្យមានសុទិដ្ឋិនិយមរឹងមាំតាមរយៈការផ្តល់ការអភិវឌ្ឍ និងកសាងលំនឹងភ្ជាប់ទៅនឹងលក្ខខណ្ឌការបែងចែកតំបន់ដែលធ្វើឱ្យកាន់តែប្រសើរឡើងនូវសមត្ថភាពទប់ទល់នៃសំណង់អាគារចំពោះមុខសញ្ញាគ្រោះថ្នាក់ឧទាហរណ៍តម្រូវការសាងសង់អាគារដោយប្រើប្រាស់វិធីសាស្ត្រធន់នឹងការរញ្ជួយដីធានាថាប្រព័ន្ធអេកូស៊ីស្ទែមព្រៃកោងកាងគឺធំល្មម និងមានសុខ-មាលភាពល្អអាចទប់ទល់នឹងខ្យល់ព្យុះ ។
- ការធានានូវលទ្ធភាពអាចទៅដល់ និងមកពីតំបន់នោះបានគ្រប់គ្រាន់ ដើម្បីផ្តល់សេវាកម្មសង្គ្រោះ និងជម្លៀសចេញ ។

ការវាយតម្លៃភាពងាយរងគ្រោះគឺមិនអាចជៀសវាងបានទេក្នុងបរិបទនេះ ។ មានទិដ្ឋភាពជាច្រើនទាក់ទិននឹងភាពងាយរងគ្រោះមួយចំនួនអាចដោះស្រាយបានដោយផ្ទាល់តាមរយៈអ្នកកសាងផែនការបែងចែកតំបន់ ។ អ្នកកសាងផែនការបែងចែកតំបន់អាចដោះស្រាយនូវលក្ខខណ្ឌមិនមានសុវត្ថិភាពមួយចំនួនដោយផ្ទាល់ ។ តាមរយៈដំណើរការកសាងផែនការភាគច្រើននៃមូលហេតុចំបងៗ និង សំពាធឌីណាមិកផ្សេងៗទៀតនោះអាចគូសបញ្ជាក់ និង ដោះស្រាយបានតាមរយៈផែនការអភិវឌ្ឍន៏ចម្រុះហើយសមាសភាពមួយក្នុងចំណោមសមាសភាពទាំងនោះគឺផែនការបែងចែកតំបន់ឆ្នេរសមុទ្រ ។

**កត្តាងាយរងគ្រោះ**

***កត្តារូបវន្ត:***

- ភាពងាយរងគ្រោះនៃបរិស្ថានតំបន់ & ដែលបង្កើតឡើង
- ទីតាំង ការរៀបចំប្លង់/បច្ចេកទេស & សម្ភារៈប្រើប្រាស់សម្រាប់ការសាងសង់លំនៅដ្ឋាន & ហេដ្ឋារចនាសម្ព័ន្ធ
- តំបន់ដាច់ស្រយាល
- កម្រិតដង់ស៊ីតេប្រជាជន

***កត្តាសង្គម:***

- កម្រិតនៃសុខមាលភាពបុគ្គល សហគមន៍ និងសង្គម
- សមភាពសង្គម ប្រភេទវណ្ណៈ បញ្ហាយេនឌ័រ
- កម្រិតអនក្ខរភាព និងការអប់រំ
- សុខមាលភាពរាងកាយ ខួរក្បាល និងផ្លូវចិត្ត
- ទឹក និង អនាម័យមូលដ្ឋាន និង ការថែទាំសុខភាព
- ប្រព័ន្ធចំណេះដឹងតាមប្រពៃណី
- ប្រព័ន្ធអង្គការចាត់តាំងសមូហភាព

***កត្តាសេដ្ឋកិច្ច:***

- ស្ថានភាពសេដ្ឋកិច្ច និងភាពក្រីក្រ
- កម្រិតនៃការបម្រុងទុក ការប្រើប្រាស់ និង ការផ្គត់ផ្គង់ ប្រព័ន្ធដឹកជញ្ជូន ជាលក្ខណៈបុគ្គល សហគមន៍ និង សេដ្ឋកិច្ចជាតិ

***កត្តាបរិស្ថាន:***

- ការបាត់បង់ធនធានធម្មជាតិ
- ស្ថានភាពនៃការសឹករេចរិលធនធាន
- ការបំពុល

***ប្រភព:*** Abramovitz, 2001. UN-ISDR, 2004, Chua, 2006

សំនួរដ៏សំខាន់ដែលត្រូវការឆ្លើយនៅកម្រិតអភិក្រមគោលនយោបាយនិងយុទ្ធសាស្ត្រគឺ « ***កម្រិតនៃហានិភ័យអ្វីខ្លះដែលយើង (ក្នុងនាមជាសង្គមមួយ) ត្រៀមទទួលយក?*** » នេះជាទូទៅមានទំនាក់ទំនងជាមួយការយកចិត្ត ទុកដាក់នឹងសេដ្ឋកិច្ចតាំងពីការត្រៀមតម្រូវឱ្យមានធនធានហិរញ្ញវត្ថុ។ នៅក្នុងបរិបទនេះប្រព័ន្ធអេកូស៊ីស្ថែមតំបន់ឆ្នេរអាចទទួលបាននូវសារៈសំខាន់ ពិសេសក្នុងន័យកាត់បន្ថយផលប៉ះពាល់នៃប្រភេទមុខសញ្ញាគ្រោះថ្នាក់ជាក់លាក់ (ឧ. ព្រៃកោងកាងការពារប្រឆាំង នឹងកំសួលព្យុះ ព្យុះ រលកយក្សស៊ូណាមិ) ឬ តំបន់ដីសើមស្រូបទាញយកនូវទឹកជំនន់ភ្លាម១ និងកាត់បន្ថយការខូចខាតចំពោះការតាំងទីលំនៅក្នុងក្រុង។ ក្នុងប្រព័ន្ធបែបនេះមានប្រយោជន៏ជាច្រើនលើការការពារសំណង់វិស្វកម្មរឹងមាំក្នុងនោះពួកគេមានផលិតភាពក្នុងខ្លួនគេ និងជាទូទៅមានស្វ័យចីរភាពផ្ទាល់ខ្លួន និងស្វ័យបង្កើត។ សូមអ្នកអានតាមដានទៅឧបសម្ព័ន្ធ 1 សម្រាប់ការពិភាក្សាពិស្តារនៃឧបករណ៏និយមប្រើបំផុតសម្រាប់វាយតម្លៃមុខសញ្ញាគ្រោះថ្នាក់ និងហានិភ័យ។

## ឯកសារសម្រាប់អានបន្ថែម:


Harris and Bahadur. 2011. **Harnessing Synergies: Mainstreaming Climate Change Adaptation in Disaster Risk Reduction Programmes and Policies**.

Inter-Agency Task Force on Climate Change and Disaster Risk Reduction. **Disaster Risk Reduction Tools and Methods for Climate Change Adaptation.**

Intersections, July 2011 – **Disaster Risk Management**.
Online Version - http://www.adb.org/documents/periodicals/intersections/2011/issue05-jul2011.asp

Abarquez, I. and Z. Murshed, 2004. **Community-Based Disaster Risk Management: Field practictioners' handbook**, Bangkok: Asian Disaster Preparedness Center. Available at: http://www.adpc.net/pdr-sea/publications/12Handbk.pdf

ECLAC, 2003. **Handbook for Estimating the Socio-Economic and Environmental Effects of Disasters,** Santiago, Chile: Economic Commission for Latin America and the Caribbean. Available at: www.proventionconsortium.org/toolkit.htm

EMA, 2000. **The Good Practice Guide: Community awareness and education in emergency management,** Canberra: Emergency Management Australia. Available at: http://www.crid.or.cr/digitalizacion/pdf/eng/doc12728/doc12728.htm

IFRC, 2005. **Guidelines for Emergency Assessment**. Geneva: International Federation of the Red Cross and Red Crescent Societies. Available at: http://www.proventionconsortium.org/files/tools_CRA/IFRC-guidelinesassessments-LR.pdf

Wisner. B., P. Blaikie,T. Cannon and I. Davis, 2003. **At Risk: natural hazards, people's vulnerability and disasters**. Second edition. UNDP. Available at: http://www.unisdr.org/eng/library/Literature/7235.pdf


**Web sites of interest**

http://www.adpc.net Asian Disaster Preparedness Center, Bangkok.

http://www.unisdr.org International Strategy for Disaster Reduction, a United Nations initiative.

http://www.preventionweb.net/english/hyogo/gar/2011/en/home/index.html 2011 Global Assessment Report on Disaster Risk Reduction

## ការប្រែប្រួលអាកាសធាតុៈ បញ្ហា និងការគំរាមកំហែងកំពុងកើតឡើង

ស្ថានភាពនៃរបាយការណ៍បរិស្ថានសមុទ្រអាស៊ីបូព៌ា (UNEP/COBSEA,២០០៩) បានសរសេរច្បាស់លាស់ថាយើងគួរចាត់វិធានការខ្លាំងក្លា និង បន្ទាន់ក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុឱ្យកាន់តែឆាប់តាមដែលអាចធ្វើទៅបាន។ វិធានការនេះត្រូវតែធ្វើឱ្យរួចជាស្រេចដើម្បីជៀសវាងការកើនឡើងយ៉ាងឆាប់រហ័សនូវការចំណាយដើមទុននាពេលអនាគតទាក់ទងនឹងការបាត់បង់អាយុជីវិត ទ្រព្យសម្បត្តិ និងមុខរបរចិញ្ចឹមជីវិត។ ចំណែកឯផលប្រយោជន៍សេដ្ឋកិច្ចនៃវិធានការបន្ទាន់និងឆាប់រហ័សលើការប្រែប្រួលអាកាសធាតុនឹងមានតម្លៃច្រើនជាងពីការចំណាយធម្មតា ហើយវាមានសារៈសំខាន់ណាស់ដែលថាការចំណាយលើការបន្សាំនឹងការប្រែប្រួលអាកាសធាតុមិនធ្វើឱ្យអន្តរាយដល់ការផ្តល់មូលនិធិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និង ដាក់សំពាធហួសហេតុលើថវិកានៃប្រទេសកំពង់អភិវឌ្ឍន៍ជាច្រើនក្នុងតំបន់នោះទេ។

***ការបញ្ជ្រាបការបន្សាំនឹងការប្រែប្រួលអាកាសធាតុទៅក្នុងការកសាងផែនការជាតិ គឺមានសារៈសំខាន់ណាស់ក្នុងតំបន់សមុទ្រអាស៊ីបូព៌ា ជាពិសេសទាក់ទងនឹងការអភិវឌ្ឍប្រកបដោយចីរភាពរយៈពេលវែង***

យើងចាំបាច់ត្រូវទទួលយកនូវគោលនយោបាយ និងសកម្មភាពបន្សាំសម្រាប់បរិស្ថានតំបន់ឆ្នេរនិងសមុទ្រនៃប្រទេសតំបន់សមុទ្រអាស៊ីបូព៌ាដែលមានក្របខណ្ឌដាច់ដោយឡែកពីគ្នាដោយពិចារណាលើតម្រូវការពិសេស និង ផ្សេងៗគ្នានៃប្រទេសនីមួយៗ។ ទោះជាយ៉ាងណាក៏ដោយក៏ការបន្តនូវវិធីសាស្ត្រផ្សេងៗគ្នានេះអាចចែកចេញជាកិច្ចខិតខំប្រឹងប្រែងសំខាន់ៗចំនួនបួនដោយសង្កត់ធ្ងន់លើភាពងាយរងគ្រោះ និងផលប៉ះពាល់។

១. ដោះស្រាយនូវកត្តាជម្រុញឱ្យមានភាពងាយរងគ្រោះ

២. កសាងសមត្ថភាពឆ្លើយតប

៣. គ្រប់គ្រងហានិភ័យអាកាសធាតុ និង

៤. ប្រឈមនឹងហានិភ័យអាកាសធាតុដោយផ្ទាល់

ក្នុងការសិក្សាវាយតម្លៃភាពងាយរងគ្រោះនិងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ (CCIAV) ការប្រែប្រួលអាកាសធាតុអាចនឹងរួមបញ្ចូលក្នុងក្របខណ្ឌទូលាយនៃការគ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់តំបន់ឆ្នេរទូទៅ។ ការងារនេះរួមបញ្ចូលការវិវត្តន៍នៃការគិតចាប់ពីការគ្រប់គ្រងតំបន់ឆ្នេរចម្រុះរហូតដល់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (DRR)។

បញ្ហាដែលទាក់ទងនឹងវិធានការបន្សាំកំពុងធ្វើការសិក្សាច្រើនទៀតនៅថ្នាក់តំបន់ដែលគេស្គាល់ថាជា ‘ការកំណត់មាត្រដ្ឋានទិន្នន័យអាកាសធាតុតាមតំបន់ (downscaling)’ ដើម្បីវាយតម្លៃផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុលើសហគមន៍ ។ វាមានសារៈសំខាន់ផងដែរក្នុងការពិចារណាពីគុណសម្បត្តិ និងគុណវិបត្តិ នៃការទទួលយកវិធីសាស្ត្រពី ‘លើ-ចុះក្រោម (Top-down)’ ឬ ‘ពីក្រោម-ទៅលើ (Bottom-up)’ ក្នុងវិធានការបន្សាំ និង អនុវត្តយុទ្ធសាស្ត្រដែលសមបំផុតសម្រាប់ស្ថានភាពនោះ។

មានអង្គការជាតិ និងអន្តរជាតិជាច្រើនបានចាប់ផ្តើមរួចហើយនូវកម្មវិធីឬគម្រោងបន្សាំដែលរាប់បញ្ចូលទាំងប្រទេសមួយចំនួនទៀតនៅតំបន់សមុទ្រអាស៊ីបូព៌ា។ ឧទាហរណ៍ UNFCCC បានបង្កើតបញ្ជីវិធីសាស្ត្រសម្រាប់វាយតម្លៃភាពងាយរងគ្រោះនិងការបន្សាំនិងឃ្លាំងទិន្នន័យនៃយុទ្ធសាស្ត្រតំបន់ដែលមានស្រាប់សម្រាប់ដោះស្រាយការប្រែប្រួលអាកាសធាតុ (អាកាសធាតុមិនទៀងទាត់) និងមុខសញ្ញាគ្រោះថ្នាក់។ កិច្ចខិតខំប្រឹងប្រែងបន្ថែមឱ្យប្រទេសអភិវឌ្ឍន៍តិចតួចកំណត់នូវអាទិភាពចំពោះមុខរបស់គេសម្រាប់ជម្រើសបន្សាំតាមរយៈកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAPA)។ បណ្តាញអាស៊ីប៉ាស៊ីហ្វិកសម្រាប់ការស្រាវជ្រាវការប្រែប្រួលពិភពលោក (APN) បានទទួលយកនូវគម្រោងមួយផងដែរដើម្បីជួយកសាងសមត្ថភាពបន្សាំពេញតំបន់សមុទ្រអាស៊ីបូព៌ាដោយកសាងនូវទ្រឹស្តីនិងម៉ូដែលល្អប្រសើរនៃ សមត្ថភាពបន្សាំនិងការកសាងភាពធន់នឹងអាកាសធាតុ និងការសម្របសម្រួលការយល់ដឹងកាន់តែប្រសើរឡើងក្នុងចំណោមអ្នកសម្រេចចិត្ត។ ច្បាស់ណាស់ដែលបាតុភូតនៃការប្រែប្រួលកាសធាតុបង្កើននូវសក្តានុពលចំពោះហានិភ័យអាកាសធាតុ ដូចនេះ វាជាកត្តាសំខាន់ដែលថាការកាត់បន្ថយ និង ការគ្រប់គ្រងហានិភ័យត្រូវបានរួមបញ្ចូលទៅក្នុងការកសាងផែនការ និងជាថ្នូរការប្រែប្រួលអាកាសធាតុត្រូវបានរួមបញ្ចូលក្នុងសកម្មភាពគ្រប់គ្រងហានិភ័យ និងគ្រោះមហន្តរាយ។

*វាជាកត្តាសំខាន់ដែលថាការកាត់បន្ថយ និងការគ្រប់គ្រងហានិភ័យត្រូវបានរួមបញ្ចូលក្នុងផែនការបន្សាំ និងជាថ្នូរមកវិញ ការប្រែប្រួលអាកាសធាតុនឹងត្រូវរួមបញ្ចូលក្នុង**សកម្មភាពគ្រប់គ្រងហានិភ័យ និងគ្រោះមហន្តរាយ។***

ដូចក្នុងករណីគ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់ផងដែរ ផែនការប្រើប្រាស់តំបន់ឆ្នេរគឺមិនសមភាពទៅនឹងកម្មវិធីសម្រាប់ការបន្សាំនិងការកាត់បន្ថយការប្រែប្រួលអាកាសធាតុនោះទេ ទោះជាយ៉ាងណាក៏ដោយវាបានបង្ហាញនូវភាពច្បាស់លាស់កាន់តែច្រើនឡើងៗក្នុងតំបន់ឆ្នេរជាពិសេស ការកសាងផែនការបែងចែកការប្រើប្រាស់តំបន់ឆ្នេរជាក់ស្តែងមិនអាចធ្វើទៅបានទេប្រសិនបើគ្មានការទទួលស្គាល់ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ហានិភ័យនៃការប្រែប្រួលអាកាសធាតុតាមពិតគឺជាផ្នែកតូចមួយនៃការគ្រប់គ្រងហានិភ័យ។ ប៉ុន្តែពួកគេសមនឹងទទួលបានការយកចិត្តទុកដាក់ពិសេសមួយចំណែកដោយសារមុខសញ្ញាគ្រោះថ្នាក់ជាប់ទាក់ទិននឹងប្រតិបត្តិការលើរយៈពេលវែង និង លើទូទាំងពិភពលោកដើម្បីឱ្យមានកាត់បន្ថយភាពប្រហាក់ប្រហែលនៃការកើតឡើងរបស់គេគឺលើសពីអំណាចនៃអាជ្ញាធរមូលដ្ឋាន និងសូម្បីតែថ្នាក់ក្រោមជាតិ។ ទោះជាយ៉ាងណាក៏ដោយ មានសកម្មភាពកាត់បន្ថយជាច្រើនដែលត្រូវបានដាក់ឱ្យប្រើប្រាស់នៅតាមតំបន់ផលប៉ះពាល់ត្រូវបានសាយភាយពេញពិភពលោកដែលត្រូវយកចិត្តទុកដាក់ក្នុងការកាត់បន្ថយភាពធ្ងន់ធ្ងរនៃផលប៉ះពាល់ទាំងនេះ។

អ្វីដែលអ្នកកសាងផែនការត្រូវការគឺការយល់ដឹងប្រភេទបញ្ហាទាំងឡាយណា ដែលទំនងជាមាននៅក្នុងការពិភាក្សានិងដែលបញ្ជាក់ពីទំហំនៃការបែងចែកតំបន់ប្រើប្រាស់។ ជំហានធំៗមួយចំនួនសម្រាប់ដំណើរការនេះរួមមាន:

- កំណត់ថាតើបាតុភូតប្រែប្រួលអាកាសធាតុមួយណាដែលពាក់ព័ន្ធសម្រាប់តំបន់ឆ្នេរ

- កំណត់ និងព្យាយាមកម្រិតចំនួនផលប៉ះពាល់ និងផលវិបាកដែលអាចមាន។ តារាងបន្តបន្ទាប់នេះនិយាយពីបាតុភូតការប្រែប្រួលអាកាសធាតុ។ ចូរជ្រើសរើសប្រភេទផលប៉ះពាល់ជាក់លាក់ដែលបានកើតឡើងក្នុងប្រទេសរបស់អ្នក និង តាមដានស៊ើបអង្កេតនិន្នាការថ្មីៗ ដោយសំឡឹងមើលស្ថិតិ ប៉ុន្តែចូរប្រមូលផងដែរនូវភស្តុតាងនិទានកថាពីអ្នកដែលបានតាំងទីលំនៅយូរមកហើយ។ មានអ្នកតាំងទីលំនៅជាច្រើននឹងមិនបានសង្កេតឃើញថាមានការប្រែប្រួលនោះទេ ប៉ុន្តែមានការបន្សុំាការរស់នៅរបស់គេទៅតាមលក្ខខណ្ឌដែលកំពុងប្រែប្រួលនោះ។ ចូរកត់សំគាល់ថាការស្រុតដីមិនមែនជាលទ្ធផលនៃ ការប្រែប្រួលអាកាសធាតុនោះទេ ប៉ុន្តែ មានផលប៉ះពាល់ និងផលវិបាកជាច្រើនទៀតដែលដូចគ្នានឹងលទ្ធផលទាំងនោះពីកំណើននីវ៉ូទឹកសមុទ្រ ។នៅកន្លែងណាដែលមានការបាក់ស្រុតដីកើតឡើងការឆ្លើយតបដោះស្រាយឬសគល់នៃបញ្ហាអាចមានប្រសិទ្ធភាពជាងដោយគ្រាន់តែទទួលយកអនុវត្តវិធានការឆ្លើយតបតាមរយៈការបន្សុំានឹងការប្រែប្រួលអាកាសធាតុ។
- ប្រសិនបើទិន្នន័យមិនមានដែលអាចបង្ហាញពីការប្រែប្រួលនូវផលប៉ះពាល់ដ៏មានសារៈសំខាន់ វាសមនឹងបង្កើតកម្មវិធីតាមដានត្រួតពិនិត្យជាពិសេសសម្រាប់ការឃ្លាំចាំមើលការប្រែប្រួលទាក់ទិននឹងអាកាសធាតុ។
- ចូរពិនិត្យមើលលក្ខណៈរូបវន្តតំបន់ឆ្នេរនិងការប្រឈមនឹងការប្រែប្រួលអាកាសធាតុ។ ចូរមើលជាពិសេសគឺៈ ឋានលេខាសាស្ត្រ ***(Topography)*** វិធីវាស់ជម្រៅទឹកសមុទ្រ (Bathymetry) ភូមិសណ្ឋានវិទ្យាតំបន់ឆ្នេរ ***(Coastal Morphology)*** ឧទតសាស្ត្រ ***(Hydrography)*** ធារាសាស្ត្រ ***(Hydrology)*** ភូគព្ភសាស្ត្រ ***(Geology)*** លក្ខណៈដីតិត្ថិកម្មក្នុងដី/ភាពជោរជន់ក្នុងដី ***(Soil Saturation)*** គម្របដី និងការប្រើប្រាស់ដី។ ចំពោះលក្ខណៈនីមួយៗនៃលក្ខណៈទាំងនេះចូរវាយតម្លៃប្រភេទនៃផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុដែលអាចមាន ។បន្ទាប់មកទៀតធ្វើបញ្ជីសារពើភ័ណ្ឌមួយនៃតំបន់ដែលមានផលប៉ះពាល់ និង មនុស្ស ទ្រព្យសម្បត្តិ ប្រព័ន្ធ និងមុខងារដែលអាចរងនូវផលវិបាក។

**ចូរសួរសំនួរខាងក្រោមៈ**

- តើតំបន់អ្វីនឹងមានផលប៉ះពាល់?
- តើមានទ្រព្យសម្បត្តិអ្វីខ្លះក្នុងតំបន់នឹងត្រូវបាត់បង់ រងរបួសឬខូចខាតដោយសារផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ?
- មានទ្រព្យសម្បត្តិអ្វីខ្លះដែលអ្នកតាំងទីលំនៅ និងម្ចាស់កម្មសិទ្ធទ្រព្យសម្បត្តិក្នុងតំបន់នោះចង់ការពារ?
- តើទ្រព្យសម្បត្តិទាំងនោះទំនងជានឹងប្រែប្រួលនាពេលអនាគតដូចម្តេច?

- ចូរវិភាគសមត្ថភាពបន្សាំជាលក្ខណៈបុគ្គល គ្រួសារ សហគមន៍ និងប្រព័ន្ធ (សេដ្ឋកិច្ច សង្គម ព្រមទាំងអេកូស៊ីស្ទែម) ចំពោះស្ថានភាពថ្មីទំនងជាមាន ។ប្រការនេះគឺជាការចោទសួរទៅលើភាពងាយរងគ្រោះប៉ុន្តែក៏នៅមានកត្តាផ្សេងទៀតដែរ ដូចជាៈ
  - សមត្ថភាព កសាងផែនការ និង និយតកម្ម (ដោយផ្តល់នូវប្រភេទផែនការត្រឹមត្រូវ និង និយតកម្ម និង ការគោរពតាម)
  - សមត្ថភាពបច្ចេកទេស និងរដ្ឋបាល ដោយរួមបញ្ចូលសមត្ថភាពសម្រាប់ការអនុវត្ត និងគោរពច្បាប់ និងជាពិសេសសមត្ថភាព និងឆន្ទះ រៀនសូត្រពីអង្គការដែលអាចធ្វើការបន្សាំនឹងស្ថានភាពថ្មី និង អនុម័តនូវឧបករណ៍ និងវិធីសាស្ត្រថ្មីៗ
  - សមត្ថភាពសារពើពន្ធដោយរួមបញ្ចូលទាំងប្រព័ន្ធប្រាក់ចំណូល ប្រព័ន្ធធានារ៉ាប់រង វិន័យសារពើពន្ធ និង ការទទួលខុសត្រូវ និង
  - ហេដ្ឋារចនាសម្ព័ន្ធ ដូចជាប្រព័ន្ធគ្រប់គ្រងការហូរច្រោះដី និងគ្រោះទឹកជំនន់ ផ្លូវសម្រាប់ជម្លៀស និង និតិវិធី, ទឹកដ៏សំបូរបែប អនាម័យ និងប្រព័ន្ធថាមពល ។
- ភាគច្រើននៃការវិភាគទាំងនេះនឹងកំណត់ដោយធម្មជាតិ ។ ទោះជាយ៉ាងណាក៏ដោយ ចំណុចនេះគឺត្រូវកំណត់ភាពខ្លាំង និង ខ្សោយ ជាពិសេសដែលត្រូវការដោះស្រាយបញ្ហាទាំងនោះ ។ កន្លែងជាក់ច្បាស់ដែលថាសមត្ថភាពនៃតម្រូវការមួយចំនួនត្រូវពង្រឹង អភិវឌ្ឍន៍ ឬ ជាវ ហើយតម្រូវការបែបនេះគួរត្រូវបានឆ្លុះបញ្ចាំងក្នុងកម្មវិធីអនុវត្តន៍ ក្រោមការអភិវឌ្ឍសមត្ថភាព ។
- បង្កើតសេណារីយោនិងបង្កើនកម្រិត និងប្រភេទនៃការផ្លាស់ប្តូរផ្សេងៗ ។ ប្រសិនបើគំរូទាំងនេះត្រូវបានបង្កើត (ដូចជាក្នុងដីតំបន់ឆ្នេរនៃខេត្ត **បាតាន** និងផែនការបែងចែកតំបន់ប្រើប្រាស់សមុទ្រក្នុងប្រទេសហ្វីលីពីន) ពួកគេអាចត្រូវបានប្រើជាមូលដ្ឋាន ដ៏រាបណា ពួកគេមានកត្តាត្រឹមត្រូវក្នុងប្រព័ន្ធរបស់ពួកគេ ។ មានភាពកាន់តែសាមញ្ញថែមទៀតនូវកម្រិតខុសៗគ្នានៃកំណើននីវ៉ូទឹកសមុទ្រអាចត្រូវបានធ្វើតេស្តសាកល្បងនៅលើផែនទីដើម្បីរកសូចនាករដែលតំបន់ទាំងនោះនឹងត្រូវបានជនលិច ថាតើមានទ្រព្យសម្បត្តិអ្វីខ្លះនឹងត្រូវបាត់បង់មានហេដ្ឋារចនាសម្ព័ន្ធអ្វីខ្លះនឹងត្រូវការពារ និង ថាតើមានការតាំងទីលំនៅថ្មី និងជម្រើសបន្សាំអ្វីគួរតែអនុវត្តជាក់ស្តែង ។
- បន្ទាប់មក សង្ខេបលទ្ធផលរកឃើញទាំងនេះតាមរបៀបដែលអ្នកសម្រេចចិត្តអាចយកមកប្រើប្រាស់បាន ឬ សម្រេចចិត្តកំណត់យកយុទ្ធសាស្ត្រ និងចាត់វិធានការ ។ ចូរពិចារណាលើសារៈសំខាន់ ឬតម្លៃនៃប្រព័ន្ធមួយ ដូចជាទ្រព្យសម្បត្តិ ឬ វិស័យមួយ, ទំហំនៃផលប៉ះពាល់ ការកំណត់ពេលវេលានៃការទទួលរងនូវផលប៉ះពាល់ការមិនបំបែកធាតុ និងការកែប្រែផលប៉ះពាល់ ភាពប្រាកដប្រជានៃផលប៉ះពាល់តាមរយៈការប៉ាន់ប្រមាណ និង ការគំរាមកំហែងពីសម្ពាធគាបសង្កត់មានស្រាប់ ។

ការសិក្សាពីការប្រែប្រួលអាកាសធាតុគួរបញ្ចូលទៅក្នុងដំណើរការកសាងផែនការបែងចែកតំបន់ឆ្នេរតាម មធ្យោបាយដូចខាងក្រោមៈ

- វានឹងបង្ហាញតាមរយៈផែនទី ថាតើផ្នែកណាខ្លះនៃដំណើរតំបន់ឆ្នេរងាយប្រឈមខ្លាំងនិងងាយរងគ្រោះដោយសារ បាតុភូតប្រែប្រួលអាកាសធាតុ
- វាជាមូលដ្ឋាននៃការបង្កើតយុទ្ធសាស្រ្តជាបន្តបន្ទាប់ដើម្បីតតាំងនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ
- ការឆ្លើយតបមួយចំនួនចំពោះការប្រឈម និង ភាពងាយរងគ្រោះអាចនាំទៅរកឧបញ្ញតិក្នុងផែនការបែងចែក តំបន់។ ឧទាហរណ៍ ទីធ្លាអាចត្រូវបានបែងចែកជាតំបន់ដីគោកសម្រាប់ព្រៃកោងកាង ឬដីសើមជាតំបន់ទ្រនាប់ ដែលក្នុង នោះពួលគេអាចថយចុះនៅពេលប្រឈមនឹងកំណើនកម្រិតទឹក។
- វាអាចរួមចំណែកដោយមានលក្ខខណ្ឌចំពោះតំបន់ពិសេសមួយចំនួនដោយឆ្លុះបញ្ចាំងពីប្រភេទដែលបានរំពឹងទុក ការកំណត់ពេលវេលាឬផលប៉ះពាល់នៃបាតុភូតប្រែប្រួលអាកាសធាតុ
- វាអាចផ្តល់ធាតុចូលដោយផ្ទាល់ចំពោះការគណនាតំបន់ធ្វើផែនការថយក្រោយ Setback រៀបចំលំនឹងសាងសង់ ឬតម្រូវការសម្រាប់ការធានរ៉ាប់រង និង
- វានឹងរួមចំណែកក្នុងការកំណត់អត្តសញ្ញាណនៃសកម្មភាពចាំបាច់សម្រាប់ការរួមបញ្ចូលក្នុងកម្មវិធីអនុវត្ត។ ទាំងនេះ អាចជាមូលដ្ឋានក្នុងការណែនាំឱ្យសិក្សាលំអិតបន្ថែមទៀត ឬ ការពង្រឹងសមត្ថភាពមានផលប៉ះពាល់ដោយអង្គការ។

***សេចក្តីសង្ខេបនូវបាតុភូតការប្រែប្រួលអាកាសធាតុ:***

| **បាតុភូតនៃការប្រែប្រួលអាកាសធាតុ** | **ផលប៉ះពាល់សំខាន់ៗ** | **ផលវិបាកសំខាន់ៗ** |
|---|---|---|
| កំណើនសីតុណ្ហភាពក្នុងខ្យល់<br>***ចំណាំ:*** *ដោយមិនរាប់បញ្ចូលនូវការឡើងអាស៊ីតមហាមុទ្រ រាល់បាតុភូតទាំងអស់ដែលចុះបញ្ជីនៅទីនេះ គឺត្រូវបានជម្រុញដោយកំណើនសីតុណ្ហភាពខ្យល់* | • រលកកំដៅ<br>• គ្រោះរាំងស្ងួត<br>• ភ្លើងព្រៃ<br>• ប្រភេទសត្វរាតត្បាត (invasive species)<br>• ការផ្លាស់ប្តូរប្រភេទ<br>• ការផ្លាស់ប្តូរក្នុងការកំណត់ពេលវេលា និងព្រឹត្តិការណ៍អេកូស៊ីស្ទែម<br>• ការបាត់បង់ទឹកកកសមុទ្រ<br>• ការចុះថយនូវបរិមាណផ្ទាំងទឹកកក | • ជម្ងឺ ការរងរបួស និងការបាត់ជីវិត<br>• ការបាត់បង់/ការសឹករេចរិល/ ការផ្លាស់ប្តូរ/ ផ្លាស់ទីនៃប្រព័ន្ធអេកូស៊ីស្ទែម ទំនិញ និង សេវាកម្មតំបន់ឆ្នេរ<br>• ការធ្លាក់ចុះគុណភាពទឹកសាប<br>• ការខាតបង់សេដ្ឋកិច្ច |
| កំណើននីវ៉ូទឹកសមុទ្រ | • ការលិចលង់តំបន់ឆ្នេរ<br>• ការហូរច្រោះដី<br>• ការ ជំនន់ខ្យល់ព្យុះ<br>• ប្រភពទឹកកើនឡើង<br>• ការជ្រាបចូលទឹកប្រៃ<br>• ការបំពុលគ្មានប្រភពដើម<br>• ការនាំមកនូវជាតិពុល | • ជម្ងឺ ការរងរបួស និងការបាត់ជីវិត<br>• ការបំផ្លិចបំផ្លាញ និងការខូចខាតទ្រព្យសម្បត្តិ និងហេដ្ឋារចនាសម្ព័ន្ធតំបន់ឆ្នេរ<br>• ការបាត់បង់/ការសឹករេចរិល/ ការផ្លាស់ប្តូរ/ផ្លាស់ទីនៃប្រព័ន្ធអេកូស៊ីស្ទែម ទំនិញ និង សេវាកម្មតំបន់ឆ្នេរ<br>• ការធ្លាក់ចុះគុណភាពទឹកសាប<br>• ការខាតបង់សេដ្ឋកិច្ច<br>• ការបាត់បង់នូវលទ្ធភាពប្រើប្រាស់តំបន់សមុទ្រ<br>• ការថយចុះបរិមាណ និងគុណភាពទឹកសាប<br>• ការបាត់បង់ធនធានវប្បធម៌<br>• ការផ្លាស់ទី/ការធ្វើចំណាកស្រុក |

| បាតុភូតនៃការប្រែប្រួលអាកាសធាតុ | ផលប៉ះពាល់សំខាន់ៗ | ផលវិបាកសំខាន់ៗ |
|---|---|---|
| | | របស់ប្រជាជន<br>• ការខាតបង់សេដ្ឋកិច្ច |
| កំណើនខ្យល់ព្យុះ<br>ភាពខ្លាំង/<br>ភាពញឹកញាប់ | • ជំនន់<br>• ខ្យល់ខ្លាំង<br>• រលកខ្លាំង<br>• ការហូរច្រោះដី<br>• ការប្រែប្រួលជាតិប្រៃ<br>• ការបំពុលគ្មានប្រភពដើម<br>• ការនាំមកនូវជាតិពុល | • ជម្ងឺ ការរងរបួស និងការបាត់ជីវិត<br>• ការបំផ្លិចបំផ្លាញ និងខូចខាតទ្រព្យសម្បត្តិតំបន់ឆ្នេរ និងហេដ្ឋារចនាសម្ព័ន្ធ<br>• ការបាត់បង់/ការផ្លាស់ប្តូរ/ផ្លាស់ទីនៃប្រព័ន្ធអេកូស៊ីស្ទែម ទំនិញ និងសេវាកម្មតំបន់ឆ្នេរ<br>• ការធ្លាក់ចុះគុណភាពទឹកសាប<br>• ការខាតបង់សេដ្ឋកិច្ច |
| ការផ្លាស់ប្តូររបបទឹកភ្លៀង | កំណើនរបាយទឹកភ្លៀង | |
| | • ទឹកជំនន់<br>• ការហូរច្រោះដី<br>• ការបំពុលគ្មានប្រភពដើម<br>• ការនាំមកនូវជាតិពុល<br>• ការផ្លាស់ប្តូរជាតិប្រៃ | • ជម្ងឺ ការរងរបួស និងការបាត់ជីវិត<br>• ការបំផ្លិចបំផ្លាញ និងការខូចខាតទ្រព្យសម្បត្តិ និងហេដ្ឋារចនាសម្ព័ន្ធតំបន់ឆ្នេរ<br>• ការបាត់បង់/ការសឹករេចរិល/ ការផ្លាស់ប្តូរ/ផ្លាស់ទីនៃប្រព័ន្ធអេកូស៊ីស្ទែម ទំនិញ និងសេវាកម្មតំបន់ឆ្នេរ<br>• ការធ្លាក់ចុះគុណភាពទឹកសាប<br>• ការខាតបង់សេដ្ឋកិច្ច |
| | ការធ្លាក់ចុះរបាយទឹកភ្លៀង | |
| | • គ្រោះរាំងស្ងួត<br>• ភ្លើងឆេះព្រៃ<br>• ការបំពុលគ្មានប្រភពដើម<br>• ការផ្លាស់ប្តូរជាតិប្រៃ | • ជម្ងឺ ការរងរបួស និងការបាត់ជីវិត<br>• ការបាត់បង់/ការសឹករេចរិល/ ការផ្លាស់ប្តូរ/ផ្លាស់ទីនៃប្រព័ន្ធអេកូស៊ីស្ទែម ទំនិញ និងសេវាកម្មតំបន់ឆ្នេរ<br>• ការធ្លាក់ចុះគុណភាពទឹកសាប<br>• ការខាតបង់សេដ្ឋកិច្ច |

| បាតុភូតនៃការប្រែប្រួលអាកាសធាតុ | ផលប៉ះពាល់សំខាន់ៗ | ផលវិបាកសំខាន់ៗ |
|---|---|---|
| | | • ការបំផ្លិចបំផ្លាញ និងការខូចខាតទ្រព្យសម្បត្តិ និង ហេដ្ឋារចនាសម្ព័ន្ធតំបន់ឆ្នេរ |
| ការកើនឡើងសីតុណ្ហភាពទឹក | • ការធ្វើឱ្យផ្កាថ្មមានពណ៌ស<br>• រោគខ្វះខ្យល់អុកស៊ីហ្សែន<br>• មេរោគឆ្លង និងជម្ងឺ<br>• ការកកើតស្លែគ្រោះថ្នាក់<br>• ប្រភេទសត្វចម្រៀង<br>• ការប្រែប្រួលពពួកសត្វ<br>• ផ្លាស់ប្តូរការកំណត់ពេលវេលាព្រឹត្តិការណ៍អេកូស៊ីស្ទែម | • ការបាត់បង់/ការសឹករេចរិល/ ការផ្លាស់ប្តូរ/ផ្លាស់ទីនៃប្រព័ន្ធអេកូស៊ីស្ទែម ទំនិញ និងសេវាកម្មតំបន់ឆ្នេរ<br>• ការថយចុះគុណភាពទឹក<br>• ការខាតបង់សេដ្ឋកិច្ច |
| អាស៊ីតកម្មមហាសមុទ្រ (ការកើនឡើងជាតិអាស៊ីត) | • ការរលាយកាល់ស្យូមកាបូណាតក្នុងសរីរាង្គបង្កើតកោសិកាសំបករបស់ទឹកសមុទ្រ | • ការបាត់បង់/ការសឹករេចរិល/ផ្លាស់ទីនៃប្រព័ន្ធអេកូស៊ីស្ទែម ទំនិញ និង សេវាកម្មតំបន់ឆ្នេរ<br>• ការខាតបង់សេដ្ឋកិច្ច |

## ឯកសារសម្រាប់អានបន្ថែម:

Inter-Agency Task Force on Climate Change and Disaster Risk Reduction. **Disaster Risk Reduction Tools and Methods for Climate Change Adaptation.**

Abarquez, I. and Z. Murshed, 2004. **Community-Based Disaster Risk Management: Field practictioners' handbook**, Bangkok: Asian Disaster Preparedness Center. Available at: http://www.adpc.net/pdr-sea/publications/12Handbk.pdf

ECLAC, 2003. **Handbook for Estimating the Socio-Economic and Environmental Effects of Disasters,** Santiago, Chile: Economic Commission for Latin America and the Caribbean. Available at: www.proventionconsortium.org/toolkit.htm

EMA, 2000. **The Good Practice Guide: Community awareness and education in emergency management,** Canberra: Emergency Management Australia. Available at: http://www.crid.or.cr/digitalizacion/pdf/eng/doc12728/doc12728.htm

IFRC, 2005. **Guidelines for Emergency Assessment**. Geneva: International Federation of the Red Cross and Red Crescent Societies. Available at: http://www.proventionconsortium.org/files/tools_CRA/IFRC-guidelinesassessments-LR.pdf

Wisner. B., P. Blaikie,T. Cannon and I. Davis, 2003. **At Risk: natural hazards, people's vulnerability and disasters**. Second edition. UNDP. Available at: http://www.unisdr.org/eng/library/Literature/7235.pdf

**Web sites of interest**

http://www.adpc.net Asian Disaster Preparedness Center, Bangkok.

http://www.unisdr.org International Strategy for Disaster Reduction, a United Nations initiative.

An excellent example of a climate-change adaptation strategy study, with many details of impact assessments and including participatory approaches is available from Sydney, Australia at http://www.sydneycoastalcouncils.com.au/system-approach-to-regional-climate-change-adaptation-strategies-in-metropolises/index.php.
Another Australian study has demonstrated a straightforward method to estimate the vulnerability of the shoreline itself to climate change. This uses structural categories, such as rock types, coastal slope, geomorphology, barrier type, shoreline exposure and change per year, together with coastal processes (relative sea level rise , mean wave height, mean tidal range). This study, by P.Abuodha and C Woodroffe, is entitled "Assessing Vulnerability to sea-level rise using a coastal sensitivity index: a case study from southeas Australia." It is available at: http://www.springerlink.com/content/6r23r6861n3r7104/

## ការរៀបចំផែនការបែងចែកការប្រើប្រាស់ដី និងសមុទ្រ

ការរៀបចំផែនការបែងចែកការប្រើប្រាស់តំបន់ឆ្នេរ និង សមុទ្រ (CMSP) តាមដែលឱ្យនិយមន័យដោយគណៈកម្មាធិការសាគរសាស្ត្រអន្តររដ្ឋាភិបាលរបស់អង្គការ UNESCO ថា " ជាដំណើរការវិភាគ និងកំណត់ផ្នែកមួយចំនួននៃលំហសមុទ្រដែលមានមុំបី សម្រាប់ការប្រើប្រាស់ជាក់លាក់ដើម្បីសម្រេចគោលបំណង អេកូស៊ីស្ទែម សេដ្ឋកិច្ច និងសង្គមតាមរយៈដំណើរការគោលនយោបាយ។ ដំណើរការបែងចែកតំបន់ប្រើប្រាស់សមុទ្រជាទូទៅនាំឱ្យមានផែនការឬចក្ខុវិស័យស៊ីជម្រៅមួយសម្រាប់តំបន់សមុទ្រមួយ។ " និយាយឱ្យសាមញ្ញ CMSP គឺជាឧបករណ៍មួយសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តកាន់តែប្រសើរ។ វាផ្តល់នូវក្របខណ្ឌមួយសម្រាប់ជាអាជ្ញាកណ្តាលរវាងការប្រកួតប្រជែងដោយសកម្មភាពមនុស្ស និង ការគ្រប់គ្រងនូវផលប៉ះពាល់របស់មនុស្សទៅលើបរិស្ថានសមុទ្រ។ គោលបំណងនៃ CMSP គឺធ្វើឱ្យមានតុល្យភាពផលប្រយោជន៍តាមវិស័យ និងសម្រេចឱ្យបាននូវការប្រើប្រាស់ប្រកបដោយចីរភាពនៃធនធានសមុទ្រ។

**ការកសាងផែនការប្រើប្រាស់ដីគឺមានជាប់ពាក់ព័ន្ធយ៉ាងសំខាន់នឹងសកម្មភាពផ្ទៃខាងលើដីខណៈពេលដែលការកសាងផែនការបែងចែកការប្រើប្រាស់តំបន់ឆ្នេរ និងសមុទ្រត្រូវតែប្រតិបត្តិក្នុងមុំបី។**

ការកសាងផែនការប្រើប្រាស់ដីកើតមានឡើងដើម្បីឆ្លើយតបនឹងប្រវត្តិនៃកម្មសិទ្ធិដីធ្លី។ ផ្ទុយទៅវិញទំហំមុំបីនៃសមុទ្រគឺ ***បាតសមុទ្រ, មាឌទឹក និងផ្ទៃទឹក*** គឺមិនមានជាកម្មសិទ្ធិឯកជន។ ព្រោះហេតុដូចនេះ ការកំណត់នៃលំហសមុទ្របានរៀបចំដោយស្របតាមភ្នាក់ងារតាមវិស័យតំបន់ ឬស្ថាប័នជាតិ។ CMSP គឺជាដំណើរការមួយដែលមានការប្រមូលទិន្នន័យការចូលរួមអ្នកពាក់ព័ន្ធ និង ការអភិវឌ្ឍប្រកបដោយការចូលរួមនៃផែនការដំណាក់កាលបន្តបន្ទាប់នៃការអនុវត្តការពង្រឹងការអនុវត្តច្បាប់ ការវាយតម្លៃ និងការកែតម្រូវ។

នៅក្នុងតំបន់សមុទ្រអាស៊ី-បូព៌ា (EAS)៖ ការអនុវត្ត CMSP គឺជាការទទួលខុសត្រូវរបស់រដ្ឋជាសមាជិក ប៉ុន្តែសកម្មភាពនៅកម្រិតតំបន់ EAS៖ អាចផ្តល់នូវតម្លៃបន្ថែមដ៏មានសារៈសំខាន់។ CMSP គឺជាដំណើរការរៀបចំឡើងដើម្បីជម្រុញការប្រើប្រាស់សមុទ្រឱ្យបានសមហេតុផល និងប្រកបដោយចីរភាព។ វាផ្តល់នូវក្របខណ្ឌមួយ សម្រាប់ការធ្វើឱ្យមានតុល្យភាពនៃផលប្រយោជន៍ខុសៗគ្នា និងការប្រើប្រាស់បរិស្ថានសមុទ្រ។ CMSPនិយាយពិស្តារអំពីការអភិវឌ្ឍផែនការបែងចែកតំបន់ប្រើប្រាស់ និង ការបញ្ជាក់ច្បាស់លាស់នូវសកម្មភាពតាមដាន ការវាយតម្លៃ និងការពិនិត្យឡើងវិញ ហើយវាជួយឱ្យអាជ្ញាធរសាធារណៈ និង អ្នកពាក់ព័ន្ធសម្របសម្រួលសកម្មភាពរបស់គេ និងធ្វើឱ្យបានប្រសើរឡើងនូវការប្រើប្រាស់លំហសមុទ្រដើម្បីផ្តល់ផលប្រយោជន៍សេដ្ឋកិច្ច និង បរិស្ថាន សមុទ្រ។

## ការកសាងលំនៅដ្ឋានតាមតំបន់ឆ្នេរ (CSD)

គំរូ CSD នៅតំបន់ EAS មានភាពខុស១គ្នាពីការរៀបចំភូមិជនបទ និងតំបន់មាត់ទឹកដែលទាក់ទាញចំពោះការប្រើប្រាស់សាធារណៈដែលជាផ្នែកមួយនៃមជ្ឈមណ្ឌលទីក្រុងដ៏សំខាន់។ នៅចន្លោះតំបន់ទាំងនេះយើងមានតំបន់រស់នៅមិនផ្លូវការស្ថិតក្នុងតំបន់ទីក្រុងព័ទ្ធជុំវិញព្រមទាំងតំបន់មានសាងសង់វីឡាមានតម្លៃខ្ពស់ៗច្រើនទៀតលើតំបន់ដីឡូតិ៍ឯកជនធំៗ។ ទីក្រុងតំបន់ឆ្នេរជាច្រើនគឺជាទីក្រុងទីជម្រកដែលមានប្រភពចេញពីភូមិនេសាទ។

*លក្ខណៈពិសេសមួយនៃគំរូសាងសង់ទីលំនៅតំបន់ឆ្នេរគឺការចាប់យកដីដែលនៅជាប់នឹងសមុទ្រតាមដែលអាចធ្វើទៅបានដោយមិនគិតថាមានផលប៉ះពាល់លើដីធម្មជាតិ ឬធនធានសមុទ្រ និងភាពងាយរងគ្រោះរបស់វាអ្វីទាំងអស់។*

ផែនការបែងចែកតំបន់ធ្វើឱ្យយើងខិតចូលជិតស្ថានភាពដី និង សមុទ្រដ៏ស្មុគ្រស្មាញមួយតាមមធ្យោបាយស៊ីជម្រៅមួយដោយធ្វើការជម្រះភាពស្មុគ្រស្មាញរបស់វា និងគូសបញ្ជាក់ពីជម្រើសឆ្លាស់គ្នាសម្រាប់អ្នកពាក់ព័ន្ធ។ គុណប្រយោជន៍មួយគឺអាចដោះស្រាយនិងឱ្យតម្លៃធម្មជាតិឱ្យមាននិរន្តរភាពយូរអង្វែង និងត្រៀមសម្រាប់ពិភាក្សា និងចរចានៅទីកន្លែងណាដែលការវិនិយោគរយៈពេលខ្លីជាប់គាំង។

## ការអភិវឌ្ឍឧស្សាហកម្មតំបន់ឆ្នេរទាក់ទងនឹងការអភិវឌ្ឍ កំពង់ផែនិង ការដឹកជញ្ជូនតាមកប៉ាល់

ការធ្វើនគរូបនីយកម្មតំបន់ឆ្នេរតាំងពីពាក់កណ្តាលសតវត្សរ៍ទី២០ គឺជារឿយៗបានគ្របដណ្តប់ដោយកំពុងផែ និងសកម្មភាពឧស្សាហកម្ម។ ទំនាក់ទំនងរវាងការអភិវឌ្ឍកំពង់ផែ និង សកម្មភាពឧស្សាហកម្មជុំវិញ ដែលកំពុងតែកើតឡើងអាស្រ័យលើប្រភេទទំនិញលើកដាក់នៅកំពង់ផែ ប៉ុន្តែក៏ក្នុងវិសាលភាពមួយដែលការអភិវឌ្ឍ ឧស្សាហកម្មដីគោកធំជាង និងមានតម្រូវការទីផ្លាដឹកជញ្ជូនតាមកប៉ាល់។ ការធ្វើសកលភាវូនីយកម្មនៃការផលិត និងពាណិជ្ជអន្តរជាតិគ្របដណ្តប់នៅតំបន់ EAS – ធ្លាប់ជាកត្តាគន្លឹះមួយក្នុងការលើទឹកចិត្តឱ្យមានដំណើរការនេះ។ ស្របជាមួយនឹងការអភិវឌ្ឍសេដ្ឋកិច្ចទីក្រុងនៅមាននិន្នាការមួយនៃកំពង់ផែឧស្សាហកម្មដែលត្រូវប្រឈមនឹងការអភិវឌ្ឍយ៉ាងលឿនផងដែរនូវផែកប៉ាល់ដែលបានពង្រីក និងថ្មីៗដែលមានដីស្តុក និងតំបន់ដឹកជញ្ជូនធំៗដែលបង្កើតជារបាំងទីក្រុងព័ទ្ធជុំវិញ។ ចង្អូរផ្លូវបោះយុថ្កា និងដឹកជញ្ជូនតាមកប៉ាល់ត្រូវរៀបចំឡើងដើម្បីគ្រប់គ្រងចលនាកប៉ាល់នៅសមុទ្រ និងនៅក្រៅកំពុងផែធំៗ។ តាមរយៈនៃទិដ្ឋភាពនេះ សមុទ្រត្រូវបានចាត់ទុកជាពិសេសថាជាផ្លូវទឹកមួយសម្រាប់ការដឹកជញ្ជូនក្រោមការត្រួតពិនិត្យនៃអាជ្ញាធរ ឬអាជ្ញាធរកំពង់ផែក្នុងតំបន់។ នៅទីកន្លែងដែលការគ្រប់គ្រងសំណល់ក្នុងស្រុក និងឧស្សាហកម្មមិនគ្រប់គ្រាន់ ហើយសមុទ្រក្លាយជាកន្លែងចោលសំណល់ចុងក្រោយពីទីក្រុង។

ផលប៉ះពាល់នៃការដឹកជញ្ជូនតាមកប៉ាល់ទៅលើទីជម្រកសមុទ្រដែលងាយរងគ្រោះមានការប្រែប្រួល និងផលប៉ះពាល់ដ៏មានសក្តានុពលដោយសារគ្រោះថ្នាក់ដែលទាក់ទិននឹងការផ្ទុកទំនិញដែលមានមុខសញ្ញាគ្រោះថ្នាក់ ដូចជាប្រេង និងសារធាតុគីមីផ្សេងៗត្រូវបានគេចង្អុលបង្ហាញនៅពេលមានការហៀរកំពប់ប្រេងរហូតដល់កម្រិតមួយដែលប្រទេសជាច្រើនឥឡូវនេះបានកំណត់ទីតាំងនៃភាពងាយរងគ្រោះជំរកតំបន់ឆ្នេរដោយសារប្រេងកំពប់ និង រៀបចំផែនការយថាផលដើម្បីឆ្លើយតបចំពោះករណីបន្ទាន់បែបនេះ។ ប្រទេសមួយចំនួនរួមទាំងប្រទេសថៃផងបានពង្រីកផែនទីនៃភាពងាយរងគ្រោះនេះដោយគ្របដណ្តប់សារធាតុ និងដំណើរការផ្សេងៗទៀតក្រៅពីប្រេង។

## ភាពចាំបាច់ត្រូវធ្វើសមាហរណកម្មផែនការប្រើប្រាស់ដី និងសមុទ្រ

មានភស្តុតាងកាន់តែច្បាស់លាស់ឡើងជុំវិញពិភពលោកដែលមានសកម្មភាពពីដីគោកនិងការបំពុលមានប្រភព និងមិនមានប្រភពច្បាស់លាស់ផលប៉ះពាល់គុណភាពសុខភាព និងចីរភាពនៃប្រព័ន្ធតំបន់ឆ្នេរ និងសមុទ្រ។ កម្មវិធីសកម្មភាពពិភពលោករបស់ UNEP សម្រាប់ការការពារបរិស្ថានសមុទ្រពីសកម្មភាពដីគោក (GPA-Marine) "មានគោលបំណងបង្ការការសឹករេចរិលបរិស្ថានសមុទ្រពីសកម្មភាពដីគោកដោយសម្របសម្រួលនូវការទទួលនូវភារកិច្ចរបស់រដ្ឋដើម្បីអភិរក្ស និងការពារបរិស្ថានសមុទ្រ។ វាវិសេសវិសាលដោយសារតែវាជាគំនិតផ្តួចផ្តើមសកលលោកតែមួយគត់ដែលដោះស្រាយដោយផ្តល់នូវការភ្ជាប់ទំនាក់ទំនងរវាប្រព័ន្ធដែនដី ទឹកសាប ឆ្នេរនិង សមុទ្រ។ GPA ត្រូវបានបង្កើតឡើងដើម្បីទុកជាប្រភពមួយនៃមគ្គុទេសស្មារតី និងការអនុវត្តជាក់ស្តែងដែលត្រូវបង្កើតដោយអាជ្ញាធរជាតិ និង/ឬ តំបន់សម្រាប់ប្រឹឌិតឡើង និង អនុវត្តសកម្មភាពដែលមានចីរភាពដើម្បីបង្ការ កាត់បន្ថយ ត្រួតត្រា និង/ឬលុប បំបាត់នូវការសឹករេចរិលនៃសមុទ្រពីសកម្មភាពដីគោក។

ប្រព័ន្ធអេកូស៊ីស្ទែមដូចជាព្រៃកោងកាងមានការអភិវឌ្ឍជាពិសេសដើម្បីប្រើប្រាស់ទាំងធនធាន និងប្រព័ន្ធទឹកប្រៃ និងទឹកសាប។ ប្រហែលជាអ្វីដែលមានការយល់ដឹងតិចតួចគឺថាតើសង្គមរបស់យើងពឹងផ្អែកលើប្រព័ន្ធសមុទ្រនៅជិតសមុទ្រប៉ុណ្ណា។ នៅកម្រិតថ្នាក់តំបន់ទេសចរណ៍អន្តរជាតិមានសារៈសំខាន់ចំពោះប្រទេសនៅតំបន់សមុទ្រអាស៊ីបូព៌ាបានដាក់សម្ពាធកាន់តែច្រើនឡើងៗលើប្រព័ន្ធអេកូស៊ីស្ទែមទាំងដីគោក និងសមុទ្រ។ ប្រសិនបើគ្មានការស្រាវជ្រាវ និងគ្រប់គ្រងគ្រប់គ្រាន់ទេទេសចរណ៍លើសលុបអាចបំផ្លាញលក្ខណៈពិសេសទាំងនោះ។ អេកូស៊ីស្ទែមដីគោក និង សមុទ្រដែលងាយរងផលប៉ះពាល់មានកំណត់សមត្ថភាពទទួលយកបានសូម្បី តែសម្រាប់សម្ពាធលំហែកំសាន្ត "**អកម្ម**" (Passive Recreation Pressure)។ សូមមើលឧបសម្ព័ន្ធទី២សម្រាប់ករណីសិក្សាពីប្រទេសហ្វីលីពីនដែលបញ្ចូលផែនការប្រើប្រាស់ដី និងសមុទ្រតែមួយឯកសារ។

## ជំពូកទី៤ — គំរូរៀបចំផែនការថ្មី

បរិបទសម្រាប់ការរៀបចំផែនការបែងចែកការប្រើប្រាស់ក្នុងតំបន់ EAS កំពុងផ្លាស់ប្តូរនូវអត្រាចេះតែកើនឡើង។ សង្គម និងវប្បធម៌កំពុងផ្លាស់ប្តូរដោយមានកម្លាំងមួយចំនួនរាប់ទាំង នគរូបនីយកម្ម ប្រព័ន្ធបណ្តាញសង្គម អគ្គិសនី និង ប្រជាធិបតេយ្យនិយម។ កំណើនសេដ្ឋកិច្ចនៅអាស៊ីបូព៌ា កំពុងមានសន្ទុះកើនឡើងរួមគ្នាជាមួយនឹងឧស្សាហកម្មូបណីយកម្មតំបន់ឆ្នេរ និងការធ្វើអាជីវកម្មចេះតែកើនឡើងនូវធនធានសមុទ្រ និងតំបន់ឆ្នេរក្នុងតំបន់។ តំបន់ទាំងមូលត្រូវបានធ្វើនគរូបនីយកម្មយ៉ាងខ្លាំងក្លាដោយប្រជាជនមានការផ្លាស់ប្តូរយ៉ាងលឿនពីតំបន់ជនបទមកកាន់តំបន់ទីក្រុង។ ឆ្លងតាមរយៈចំណាកស្រុកនេះតួលេខ និងដង់ស៊ីតេនៃទីក្រុងតំបន់ឆ្នេរមានការកើនឡើង។ ទីក្រុង៥ ក្នុងចំណោមទីក្រុងធំៗលំដាប់ពិភពលោកទាំង២១ (ដែលមានចំនួនមនុស្សរស់នៅជាង១០លាន) ស្ថិតក្នុងនៅតំបន់នេះ និង គេប៉ាន់ប្រមាណថាមានទីក្រុងច្រើននឹងឈានទៅរកស្ថានភាពបែបនេះក្នុងរយៈពេលប្រាំឆ្នាំទៀត។

### ***បរិបទនៃការរៀបចំផែនការបែងចែកតំបន់ប្រើប្រាស់នៅតំបន់សមុទ្រអាស៊ីបូព៌ាកំពុងមានការប្រែប្រួលយ៉ាងច្រើន***

ការប្រែប្រួលសេដ្ឋកិច្ចសង្គមទាំងនេះកំពុងកើតឡើងនូវក្នុងក្របខណ្ឌមួយនៃការកើនឡើងការយល់ដឹងនូវសារៈសំខាន់ប្រព័ន្ធអេកូស៊ីស្ទែម និង បុព្វហេតុ និងផលវិបាកនៃការប្រែប្រួលអាកាសធាតុ។ អភិក្រម និងវិធីសាស្ត្រកសាងផែនការតាមបែបប្រពៃណី កំពុងបង្ហាញនូវភាពមិនគ្រប់គ្រាន់ទាក់ទងនឹងអត្រានៃការប្រែប្រួលនឹងបញ្ហា ដែលត្រូវការយកចិត្តទុកដាក់។ ការប្រៀបធៀបនៃចរិតលក្ខណៈ "**ចាស់**" និង "**ថ្មី**" មានបង្ហាញជូនក្នុងតារាងខាងក្រោម។ មានលក្ខណៈពិសេសមួយចំនួនដែលទាមទារឱ្យមានការយកចិត្តទុកដាក់ជាពិសេស។

១. នៅក្រោមគំរូថ្មីនេះ ការកសាងផែនការត្រូវបានគេមើលឃើញថា ជាដំណើរការបន្ត និងជាឧបករណ៍មួយសម្រាប់គ្រប់គ្រងការផ្លាស់ប្តូរក្នុងទំហំការប្រើប្រាស់របស់វា។ ដំណើរការផលិតនេះបង្កើតបានផលិតផលដែលមានរយៈពេលយូរក្នុងទម្រង់ផែនការ (ផែនទី និងអត្ថបទ) ប៉ុន្តែការគូសបញ្ជាក់នៃដំណើរការ មានន័យថាការកសាងផែនការតាមបែបគ្រប់គ្រងគឺអាចបន្ស៊ាំនៅពេលដែលមានការជម្រុញ។ នៅក្រោមគំរូចាស់ផលិតផល (ផែនទី និង អត្ថបទ) គ្របដណ្តប់ច្រើនបំផុត។ ជាញឹកញាប់ ផែនការគំរូចាស់គឺមិនទាក់ទងពេលវេលាដែលពួកគេត្រូវបានអនុម័តនោះទេ តម្រូវការ និងការលានុវត្តភាពទំនងជាលឿនជាងប្រព័ន្ធកសាងផែនការដែលអាចឆ្លើយតបបានហើយនៅពេលណា និងកន្លែងណាដែលវាអាចមិនផ្តល់ការគាំទ្រដល់អ្នកគ្រប់គ្រងទេនោះវាត្រូវបានគេធ្វើមិនដឹងមិនឮ។

២. គំរូថ្មី គឺ មានលក្ខណៈជាព័ត៌មានជាង។ បច្ចេកទេសសព្វថ្ងៃនេះ ជាពិសេសឃ្លាំងទិន្នន័យនិងប្រព័ន្ធ

ព័ត៌មានភូមិសាស្ត្រ ធ្វើឱ្យវាមានលទ្ធភាពរក្សាបាននូវ "**ស្ថានភាពបច្ចុប្បន្នរហូតដល់ពេលបច្ចុប្បន្ន**"។ នៅក្នុងប្រព័ន្ធដែលមានដំណើរការរលូនមានតម្រូវការតិចតួចណាស់ដែលមានការរឹកហាត់ប្រមូលព័ត៌មានពិសេស តាមបែបសាមញ្ញគឺធ្វើបច្ចុប្បន្នកម្មព័ត៌មាន និងផែនទីចាស់។ ជាមួយគ្នាផងដែរ ទិន្នន័យ និងព័ត៌មានអាចវិភាគបានតាមមធ្យោបាយថ្មីដែលស្ទើរតែមិនអាចទៅរួចតាមបែបបុរាណដោយគ្មានប្រព័ន្ធកុំព្យូទ័រនោះ។

លទ្ធភាពទាំងនេះជាមូលដ្ឋានផ្លាស់ប្តូររបៀបប្រមូលព័ត៌មានរក្សាទុក និងប្រើប្រាស់ដោយប៉ិនប្រសព្វចាត់ចែងគ្រប់គ្រង ចែករំលែក និងប្រើប្រាស់ និងផ្លាស់ប្តូរផងដែរនូវដំណើរការនីមួយៗ នៃការកសាងផែនការបែងចែកការប្រើប្រាស់។ គំរូថ្មីនេះជាយុទ្ធសាស្ត្រផ្ទាល់សម្រាប់ប្រមូលយកព័ត៌មានដោយផ្តោតសំខាន់លើអ្វីដែលមានតម្រូវការចាំបាច់ និងអ្វីដែលអាចប្រើប្រាស់បាន ជាជាងការប្រមូលផ្តុំសម្ភារៈដែលអាចប្រើប្រាស់ទាំងអស់ រួមទាំងអ្វីដែលមិនអាច និងមិនត្រូវបានប្រើក្នុងកាលបរិច្ឆេទ '**មុនកាលកំណត់**'។ គំរូថ្មីនេះពឹងលើការយល់ដឹងអំពីធនធាន និងព្យាយាមតាមទស្សនៈវិស័យមួយដែលចែករំលែកយ៉ាងទូលាយក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់។ ការប្រឈម និងចំណុចបញ្ហាដែលបានកំណត់ទាក់ទងនឹងការទទួលយករបស់ពួកគេនូវការសម្រេចបានចក្ខុវិស័យ។ ការងារនេះនាំឱ្យមានការបង្កើតអាទិភាពប្រកបដោយភាពឆ្លាតវៃនាពេលវេលាកន្លងទៅ។ ផ្ទុយទៅវិញ ការបន្តនូវចក្ខុវិស័យមួយផ្តល់នូវទិសដៅវិជ្ជមាន និងអាចមានទំនាក់ទំនងផ្ទាល់ទៅនឹងសមាសធាតុនៃការអភិវឌ្ឍផ្សេងៗទៀត។ ការកសាងផែនការក្លាយជាឧបករណ៍ផ្សព្វផ្សាយដែលអាចត្រូវបានប្រើប្រាស់ដើម្បីលើកកម្ពស់ហិរញ្ញវត្ថុ (តាមមធ្យោបាយមួយស្រដៀងគ្នា នឹងការកសាងផែនការក្នុងការស្វែងរកប្រាក់កម្ចីធនាគារសម្រាប់ការអភិវឌ្ឍជំនួញ) ជាជាងការដាក់បទបញ្ជានិងកំហិត លក្ខខណ្ឌ។ វាបើកចំហផ្លូវ នៅកម្រិតពិស្តារជាច្រើន ដើម្បីធ្វើការងារឱ្យកាន់តែរីកចម្រើនប្រកបដោយការឆ្លៃប្រឌិត និង ស្ថាបនា '**ជាមួយ**' អ្នកអភិវឌ្ឍន៍ជាជាងគ្រាន់តែគ្រប់គ្រងពួកគេ។ ការប្រៀបធៀបនូវគំរូកសាងផែនការបែប ***ចាស់ និង ថ្មី***(អាចអនុវត្តបាននៅកម្រិតអាជ្ញាធរមូលដ្ឋាន/ក្រុង)

| គំរូកសាងផែនការបែងចែកតំបន់ប្រើប្រាស់ចាស់ | គំរូកសាងផែនការបែងចែក តំបន់ប្រើប្រាស់ថ្មី |
|---|---|
| - បទបញ្ញត្តិចំបង: លទ្ធផលរបស់វាគឺផែនទីបែងចែកការប្រើប្រាស់ដីដោយមានអត្ថបទពន្យល់<br>- តំបន់រៀបរាប់ពីទីតាំងដែលក្នុងនោះសកម្មភាពពិសេស ត្រូវបានអនុញ្ញាត ឬហាមឃាត់<br>- ផែនការលំអិតពីផែនការមេឬផែនការស៊ីជម្រៅដោយបន្ថែមនូវកម្រិតថ្មីបែបទបញ្ញត្តិ | - កត្តារួមផ្សំទាំងបទបញ្ញត្តិ និងការលើកកម្ពស់ការយល់ដឹងខណៈពេលដែលផែនទីបែងចែកតំបន់ បន្តប្រើប្រាស់សម្រាប់គោលបំណង ជាក់លាក់ ផែនទីនេះផ្តល់នូវការពិពណ៌នារយៈពេលវែងប្រកបដោយស្ថេរភាព នៃ ទំហំចក្ខុវិស័យនៃទស្សនៈវិស័យមួយ ។<br>- ផែនទីនេះមានភ្ជាប់មកជាមួយនូវអត្ថបទមួយ ដែលពិពណ៌នាពីចក្ខុវិស័យនិង កម្មវិធី សកម្មភាពដែលបន្តដោយចេតនានូវចក្ខុវិស័យនោះ ។<br>- ផែនការនេះផ្អែកលើគោលការណ៍យុទ្ធសាស្ត្រ សម្រាប់ការសម្រេចចិត្តដែលស៊ីសង្វាក់ជាមួយ ការបន្តនូវចក្ខុ-វិស័យនិងដែលអាចណែនាំនូវអន្តរកម្មបែបផ្សព្វផ្សាយ បន្សាំ និងចរចារវាង អាជ្ញាធរ និង អ្នកពាក់ព័ន្ធផ្សេងៗ ទៀតជាពិសេសអ្នកវិនិយោគ ។ |
| - ការតម្រង់ទៅរកលទ្ធផល និង ទិន្នផល : ការហ្វឹកហាត់ការកសាងផែនការគឺផ្តោតលើការបង្កើតផែនការបែងចែកតំបន់ដោយមានអមជាមួយនូវអត្ថបទ ។<br>- ផែនការបច្ចុប្បន្នកម្មត្រូវបានផលិតនៅក្នុងចន្លោះពេលដែលបានកំណត់ជាមុន (ឧ. ប្រាំឆ្នាំ) ឬនៅពេលដែលមានហិរញ្ញប្បទាន | - ការតម្រង់ទិសទៅរកដំណើរការ និងលទ្ធផល ដោយមានកត្តា រួមផ្សំដែលកើតឡើងក្នុងលក្ខណៈវិលជុំខុសៗគ្នា<br>- នៅពេលដែលគោលបំណងបែងចែកតំបន់រយៈពេលវែងមានស្ថេរភាពកម្មវិធីអនុវត្តត្រូវបានធ្វើបច្ចុប្បន្នកម្មប្រចាំឆ្នាំ ក្នុងវដ្តថវិកាធម្មតា និង ព័ត៌មានដែលត្រូវបានប្រមូលបន្តបន្ទាប់សម្រាប់ការធ្វើបច្ចុប្បន្នកម្មទិន្នន័យតាមរយៈការអនុញ្ញាត និងដំណើរការផ្សេងៗទៀត ។<br>- ការតាមដានត្រួតពិនិត្យនិងវាយតម្លៃផ្តោតលើការសម្រេចបានសមិទ្ធិផលចក្ខុវិស័យរួមដែលត្រូវពិនិត្យមើលជាប្រចាំ (ឧ. រៀងរាល់ប្រាំឆ្នាំម្តង ឬ បន្ទាប់ពីការផ្លាស់ប្តូររដ្ឋាភិបាលមូលដ្ឋាន) ។ |

| | |
|---|---|
| - ផែនការ(ជាផលិតផល) គឺឧបករណ៍មួយសម្រាប់តម្រង់ទិសដៅនៃការគ្រប់គ្រងក្នុងស្ថានភាពវិវត្តន៍យ៉ាងលឿនបំផុតកន្លែងដែលបច្ចេកវិទ្យាផ្តល់ឱ្យនូវសក្តានុពលសម្រាប់កាលានុវត្ត និងដំណោះស្រាយនវានុវត្តចំពោះជម្លោះ, ផែនការក្លាយជាការដាក់កំហិត និងជាបន្ទុករបស់អ្នកគ្រប់គ្រង | - ការកសាងផែនការត្រូវបានគេមើលឃើញថាជាឧបករណ៍គ្រប់គ្រង និង គួរតែដោះស្រាយនូវតម្រូវការគ្រប់គ្រងតាមបែបចម្រុះមួយ ។<br>- ប្រការនេះរាប់បញ្ចូលទាំងតម្រូវការត្រូវផ្តល់ឱ្យយុទ្ធសាស្ត្រពហុភាគ គោលការណ៍ធ្វើការសម្រេចចិត្ត និងភាពបត់បែន ក្នុង ការប្រឈមនឹងភាពមិនប្រាកដប្រជាដែលជាចរិកលក្ខខណៈនៃ "**អនាគត**"<br>- សមាហរណកម្ម នៃទំហំការបែងចែកការប្រើប្រាស់គឺត្រូវការ នៅពេល ដែលមានការពិចារណាអំពីកត្តាសេដ្ឋកិច្ច សង្គម និង បរិស្ថានថែមទាំងសមត្ថភាពស្ថាប័ន និងធនធានហិរញ្ញវត្ថុ ។ |
| - ការផ្តោតលើរបាយបែងចែកតំបន់នៃសកម្មភាពមនុស្សដោយផ្អែកលើតម្រូវការអនាគតសម្រាប់ការប្រើប្រាស់ដីធ្លីជាក់លាក់<br>- ការបើកចំហជាញឹកញាប់ត្រូវបានផ្តល់ឱ្យដោយផ្អែកលើមូលដ្ឋាន អនុបាតកំណត់មុនដោយគិតជាម៉ែត្រការេក្នុងមនុស្សម្នាក់និង កំណត់តំបន់ទ្រនាប់ តាមផ្លូវទឹកធម្មជាតិឬជុំវិញសកម្មភាពដែលជាមុខសញ្ញាគ្រោះថ្នាក់ ឬ ដែលមានក្លិនស្អុយ ( ស្ថានីប្រេងឥន្ធន៍) (ប្រព័ន្ធស្រះទឹក) មិនមែនដោយសារតម្លៃអេកូស៊ីស្ទែមខាងក្នុងវាទេ ។<br>- តំបន់ដែលមានជម្រាលជ្រៅ និងងាយរងទឹកជំនន់ជាញឹកញាប់មិនបានរាប់បញ្ចូលក្នុងការកាត់បន្ថយហានិភ័យនេះទេ | - ការច្របាច់បញ្ចូលដោយចេតនានូវតំបន់ដែលមានសារៈសំខាន់ និងងាយរងផលប៉ះពាល់ពីការប្រែប្រួលអេកូស៊ីស្ទែម ជាមួយសមាសភាពសង្គម វប្បធម៌ និងសេដ្ឋកិច្ច ។<br>- ចូរចាត់ទុកទីតាំងលំហថាជា "ហេដ្ឋារចនាសម្ព័ន្ធបៃតង" និង រួមបញ្ចូលគ្នាសេវាបរិស្ថានឱ្យមានភាពស្មើគ្នាជាមួយសេវាកម្មសង្គម និងសេដ្ឋកិច្ច ។<br>- អាចរួមបញ្ចូលនូវបញ្ហានៃភាពងាយរងគ្រោះនៃសង្គមភាពរឹងមាំនៃស្ថាប័ន ភាពងាយរងផលប៉ះពាល់នៃការប្រែប្រួលបរិស្ថាន និងបញ្ហាដែលពាក់ព័ន្ធ នឹងការប្រែប្រួលអាកាសធាតុ និង ការគ្រប់គ្រងហានិភ័យ ។ |

| | |
|---|---|
| - ការណែនាំនូវបញ្ហាខ្លាំងៗ<br>- បរិមាណទិន្នន័យច្រើនបានប្រមូលនិងវិភាគចំពោះបញ្ហាដែលត្រូវដោះស្រាយ<br>- ធាតុផ្សំនៃកាលានុវត្តភាព និង សក្តានុពលអាចមាន ប៉ុន្តែការផ្តល់ឱកាសឱ្យគឺជាការបង្កើតបញ្ហា<br>- គោលបំណង បានកំណត់ទាក់ទងនឹងបញ្ហាដែលត្រូវដោះស្រាយ<br>- ទស្សនៈវិជ្ជាមូលដ្ឋាន "តើមានបញ្ហាអ្វី? ចូរយើងជួសជុលវាទៅ" | - សង្កត់ធ្ងន់លើធានធានទ្រព្យសម្បត្តិ និង ចក្ខុវិស័យ<br>- ធនធានទ្រព្យសម្បត្តិគ្រប់ប្រភេទធ្វើផែនទីដើម្បីកំណត់សក្កដានុពលប៉ុន្តែត្រូវការផងដែរដើម្បីរក្សានិងលើកកម្ពស់។<br>- ចក្ខុវិស័យត្រូវបានបង្កើតជាមូលដ្ឋានសម្រាប់គោលបំណងរយៈពេលវែង។<br>- បញ្ហាដែលបានកំណត់ទំនាក់ទំនងចំពោះផលប៉ះពាល់អវិជ្ជមានទៅលើដំណើរការឆ្ពោះទៅរកចក្ខុវិស័យ។<br>- ការរួមបញ្ចូលនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ដើម្បីរក្សា និង លើកកម្ពស់ ធនធានដែលមានស្រាប់យកឈ្នះលើបញ្ហាប្រឈម, ដើរតាមនូវគោលបំណងរយៈពេលយូរដោយជៀសវាង ឬកាត់បន្ថយបញ្ហានាពេលអនាគត |
| - ជាទូទៅមិនអាចបត់បែនបាននៅពេលដែលផែនការត្រូវបានបញ្ចប់<br>- នៅកម្រិតធ្វើផែនការមេ/ភាពស៊ីជម្រៅ និងលំអិតនៃផែនការទាំងនេះ ជាញឹកញាប់មានភាពស្របច្បាប់ទាក់ទងនឹងតម្រូវការបែងចែកការប្រើប្រាស់ប៉ុន្តែ មិនមែនក្នុងន័យ អភិវឌ្ឍន៍នោះទេ ពោលគឺ ផែនការនឹងរៀបចំឡើងដោយទុកកន្លែង សម្រាប់ ផ្លូវធំ និង ហាមឃាត់ការប្រើប្រាស់ផ្សេងទៀត ប៉ុន្តែមិនអាចទាមទារថាផ្លូវនេះសាងសង់ឡើងដោយអាជ្ញាធពាក់ព័ន្ធនោះទេ។<br>- សំណើដែលឥតព្រៀងទុក និង ការអភិវឌ្ឍដែលមិនបានគិតទុកជាមុនមិនអាចដោះស្រាយបានងាយដោយអ្នកសម្រេចចិត្តនោះទេ។ | - ការធ្វើផែនការមេ/ស៊ីជម្រៅតាមធម្មតាមានលក្ខណៈជាយុទ្ធសាស្ត្រដែលនិយាយលំអិតអំពីភាពស្របច្បាប់<br>- ផែនការលំអិតជាញឹកញាប់ពង្រាងដោយមានធាតុចូលផ្ទាល់ថែមទាំងមានការចរចាជាមួយម្ចាស់ដី និងអ្នកអភិវឌ្ឍ<br>- ប្រការនេះអាចនាំទៅរកកិច្ចសន្យាដែលចងទាំងអាជ្ញាធរ និងម្ចាស់ដី ដើម្បី អភិវឌ្ឍន៍ស្របតាមផែនការឯកភាពប្រកបដោយ យោគយល់គ្នា។<br>- ផែនការយុទ្ធសាស្ត្រផ្តល់នូវមាគ៌ាដល់អាជ្ញាធរក្នុងការធ្វើការសម្រេចចិត្តរបស់ពួកគេដើម្បីឱ្យសំណើដែលមិន បានគិតទុកជាមុននេះអាចវាយតម្លៃ និង ចាត់ចែងសមសម្រប។ |

| | |
|---|---|
| - ច្រងក្រងដោយអ្នកមានវិជ្ជជីវៈ និងជំនាញ<br>- ច្បាប់ជាទូទៅតម្រូវការដាក់បង្ហាញជាសាធារណៈនូវពង្រាងចុងក្រោយ និង ពិនិត្យឡើងវិញនូវការផ្តល់មតិយោបល់ប៉ុន្តែជាទូទៅគឺថា "អាជ្ញាធរដឹងនូវអ្វីដែលសំខាន់បំផុតសម្រាប់ស្ថាប័ន"<br>- លទ្ធផលនេះជាញឹកញាប់គឺថាផែនការនេះ "**គ្រប់គ្រងដោយផ្ទាល់**" ដោយផ្នែកមួយ នៃអាជ្ញាធរ និងចាត់ទុកថាមិនថាជាការបង្ខំឱ្យទទួលដោយអ្នកពាក់ព័ន្ធនិងអ្នកតាំងទីលំនៅផ្សេងទៀតទេ | - ចក្ខុវិស័យ គោលបំណង និង មានអាទិភាពគឺត្រូវបានរៀបចំតាមរយៈដំណើរការប្រកបដោយការចូលរួម និងមានការពិគ្រោះយោបល់។<br>- ទិដ្ឋភាពបច្ចេកទេសត្រូវបានដោះស្រាយដោយអ្នកមានវិជ្ជាជីវៈ និងជំនាញដែលអាចពន្យល់ពីសំណើរបស់ពួកគេទៅដល់អ្នកនយោបាយ និងអ្នកពាក់ព័ន្ធផ្សេងទៀត។<br>- លទ្ធផលរំពឹងទុកគឺមានភាពជាម្ចាស់ការទូលំទូលាយមានឆន្ទៈដើម្បីអនុវត្តតាមមានទំនាក់ទំនងល្អរវាងអាជ្ញាធរ និងអ្នកតាំងទីលំនៅ និង ការពង្រឹងការអនុវត្តឱ្យកាន់តែប្រសើរ។ |
| - ជាញឹកញាប់ទទួលស្គាល់ថាជលទ្ធផលនៃ "អាជ្ញាធរ" ដែលប្រឈមមុខតទល់ និងដែលកំណត់ដោយបទបញ្ញត្តិ<br>- គំនិតនវានុវត្តន៍ និង ការគិតគូរប្រកបដោយគំនិតច្នៃប្រឌិតកំណត់នូវសមត្ថភាពអ្នកមានវិជ្ជាជីវៈ | - ការឆ្លុះបញ្ចាំងនូវផ្នត់គំនិតពិសេសនៃការសហការ និងសហប្រតិបត្តិការក្នុងចំណោមអ្នកពាក់ព័ន្ធដោយលើកទឹកចិត្តឱ្យមាននវានុវត្តន៍ និងគំនិតច្នៃប្រឌិតសំដៅសម្រេចនូវដំណោះស្រាយ **ឈ្នះ ឈ្នះ** ក្នុងស្ថានភាពប្រកួតប្រជែង។ |

៣.គំរូថ្មីដោយសារតែចក្ខុវិស័យរួមអាចរួមបញ្ចូលនូវបញ្ហាផ្សេងៗគ្នា ដែលបានដោះស្រាយពីមុនមកដាច់ដោយឡែកពីគ្នា និងជាលក្ខណៈបុគ្គល។ គំរូថ្មីនេះមានលក្ខណៈជាប្រព័ន្ធច្រើនជាងគំរូចាស់ និងអាចរួមបញ្ចូលទំនាក់ទំនងរវាងបញ្ហាបរិស្ថាន សង្គមកិច្ច និង សេដ្ឋកិច្ចក្នុងការបន្តការអភិវឌ្ឍប្រកបដោយចីរភាព។ បញ្ហាបែបនេះ រួមទាំងការគ្រប់គ្រងមុសញ្ញាគ្រោះថ្នាក់ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយភាពងាយរងគ្រោះ និងភាពធន់អភិបាលកិច្ច ការគ្រប់គ្រងផ្អែកលើអេកូស៊ីស្ទែម និង ការប្រែប្រួលអាកាសធាតុ។ វាក៏បានជម្រុញឱ្យធ្វើសមាហរណកម្មកាន់តែជិតស្និទ្ធទៅទៀតចំពោះការកសាងផែនការបែងចែកតំបន់ប្រើប្រាស់សមុទ្រនិងតំបន់ឆ្នេរ។

ប្រព័ន្ធចាស់ព្យាករណ៍អនាគតពីនិន្នាការសេដ្ឋកិច្ច និងប្រជាសាស្ត្រដែលមានស្រាប់ និង បន្ទាប់មកបានផ្តល់ឱ្យតាមតម្រូវការសេដ្ឋកិច្ច និងសង្គមដែលយល់ដឹងដែលអាចគណនាតាមតម្រូវការប្រើប្រាស់ដី។ គំរូថ្មីកំណត់នូវអនាគត ដែលចង់បានបន្ទាប់មកអភិវឌ្ឍយុទ្ធសាស្ត្រសមស្របដើម្បីសម្រេចបានវាខណៈដែលការលើកកម្ពស់នូវធនធាន

ដែលមានស្រាប់ដោះស្រាយការប្រឈមបច្ចុប្បន្ន និង កាត់បន្ថយការគំរាមកំហែង និង បញ្ហាអនាគត។ វាបានផ្តល់នូវក្របខណ្ឌបែងចែកតំបន់ប្រើប្រាស់រយៈពេលវែង និងកម្មវិធីអនុវត្តរយៈពេលខ្លីដែលមានទំនាក់ទំនងនឹងវដ្តថវិកា និងផែនការចំណាយរយៈពេលមធ្យម។


ដំណើរការគំរូចាស់
រៀបចំធ្វើផែនការ
ទិន្នន័យទទួលបានពីអាជ្ញាធរ ជាអ្នកពាក់ព័ន្ធពិសេស និង ការសិក្សាតាមវាលពិសេស
ប្រមូលព័ត៌មានស្ដីពីស្ថានភាពបច្ចុប្បន្ន
វិភាគព័ត៌មាន,រៀបចំ របាយការណ៍ស្ថានភាពបច្ចុប្បន្ន
របាយការណ៍: ស្ថានភាពបច្ចុប្បន្ន
គំរូនិងស្តង់ដា អត្ថប្រយោជន៍វិស័យ ឯកជនល្បីៗ ការព្យាករណ៍ប្រជាជន ផ្ដល់នូវមូលដ្ឋានគោលដៅ
រៀបចំការព្យាករណ៍ប្រជាជនតាមពសេណារីយ៉ូ
កំណត់ការប្រើប្រាស់ដី តម្រូវការឆ្លុះបញ្ចាំង សេណារីយ៉ូនិងដោយប្រៀបធៀប ស្ថានភាពបច្ចុប្បន្ន
វិភាគជម្រើសនិងជ្រើសរើសមួយសមស្រប អាចបញ្ចូលទាំង SEA
រៀបចំពង្រាងការប្រើប្រាស់ដី/ ផែនការបែងចែកតំបន់
ផែនការពង្រាង
ការពិគ្រោះយោបល់: ការផ្ដល់យោបល់ពីអ្នកពាក់ព័ន្ធនិងសាធារណ:
ចែកចាយសុំយោបល់
បញ្ចប់និងសុំអនុម័ត
ផែនការចុងបញ្ចប់
ដំណើរការគំរូចាស់
រៀបចំធ្វើផែនការ
កម្មវិធីការងារ ថវិកា ការងារបុគ្គលិក
របាយការណ៍អំពីការពិនិត្យភ្លាមៗ
ពិនិត្យភ្លាមៗនូវស្ថានភាពបច្ចុប្បន្ន
របាយការណ៍ធនធាន ចក្ខុវិស័យ និងគោលដៅសំខាន់៥ឆ្នាំ
ធនធាន ចក្ខុវិស័យ អាទិភាព សិក្ខាសាលា
ការសិក្សាពិសេស, ការប្រមូលទិន្នន័យ
របាយការណ៍ការសិក្សាពិសេស
ជម្រើស, សេណារីយ៉ូយុទ្ធសាស្ត្រ
របាយការណ៍ស្ដីពីជម្រើស ,សេណារីយ៉ូយុទ្ធសាស្ត្រ
ការវាយតម្លៃជម្រើស (SEA)
លទ្ធផលការវាយតម្លៃ និងជម្រើសអនុសាសន៍
បង្កើតផែនការ
ពង្រាងផែនការចុងបញ្ចប់
ការពិគ្រោះយោបល់អ្នកពាក់ព័ន្ធ
របាយការណ៍ស្ដីពីការពិគ្រោះយោបល់
បញ្ចប់ផែនការដើម្បីសុំការអនុម័ត
ផែនការបែងចែកតំបន់
Primarily Stakeholders' work
Experts & Stakeholders work together
Planning Team, Experts, Relevant Stakeholders' work
Paper Products

៤. ការភ្ជាប់ទំនាក់ទំនងគំរូថ្មីគឺធ្វើការត្រួតពិនិត្យ វាយតម្លៃ រៀនសូត្រ និងការគ្រប់គ្រងសម្របសម្រួលដោះស្រាយនូវភាពមិនប្រាកដប្រជា។ ការកសាងផែនការតំបន់ឆ្នេរស្ថិតនៅក្រោមគំរូថ្មីនឹងៈ

- គូសបញ្ជាក់នូវដំណើរការជាមួយនឹងផលិតកម្មយូរអង្វែងដែលត្រូវបានធ្វើបច្ចុប្បន្នកម្មជាប្រចាំដើម្បីបន្សុីគ្នាជាមួយអាទិភាព សមត្ថភាព និងថវិកា
- ផ្តោតលើគោលការណ៍សម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត ជាយុទ្ធសាស្រ្តដែលជាការលើកទឹកចិត្ត និងបន្សុាំជាងការដែលអនុវត្ត ច្បាប់បញ្ញត្តិ និងកំណត់ច្បាស់
- អនុម័តគោលការណ៍គ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែម ដែលក្នុងនោះសង្គមមនុស្សត្រូវបានគេចាត់ទុកថាធ្វើកិច្ចសហការរួមគ្នា និងពឹងពាក់លើប្រព័ន្ធអេកូស៊ីស្ទែមកាន់តែធំទូលាយ
- ត្រូវតែជាវិធានការគ្រប់ជ្រុងជ្រោយដោយស្វែងរកនូវតុល្យភាពសង្គម សេដ្ឋកិច្ច និង បរិស្ថានដើម្បីសម្រេចបាននិរន្តរភាពគ្រប់ជំនាន់;
- បញ្ចូលនូវទិដ្ឋភាពបែងចែកតំបន់ប្រើប្រាស់នៃការប្រែប្រួលអាកាសធាតុ និង ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដោយដោះស្រាយនូវបញ្ហានៃភាពងាយរងគ្រោះ និងភាពធន់ជាពិសេស ប៉ុន្តែមិនកំណត់ជាក់លាក់បរិស្ថានសង្គម
- ធ្វើសមាហរណកម្ម តាមរយៈប្រព័ន្ធនៃការគិតគូរ ការកសាងផែនការតំបន់ទឹក និងដី ដោយគិតគូរផលប៉ះពាល់ដែលមានប្រភពពីដីគោកទៅលើសមុទ្រពិភពលោក និងកងកម្លាំងផ្អែកលើសមុទ្រដែលមានសកម្មភាពលើដី។

មានភាពខុសប្លែកគ្នាយ៉ាងច្បាស់លាស់ជាច្រើនក្នុងដំណើរការរួមរវាងគំរូចាស់ និងគំរូថ្មី។ ក្នុងពេលដំណាលគ្នាចាំបាច់ត្រូវតែយល់ថា មានភាពខុសប្លែកគ្នាតាមលក្ខណៈធម្មជាតិរវាងប្រទេសតំបន់សមុទ្រអាស៊ីបូព៌ា និងក្រុមកសាងផែនការផ្សេងៗគ្នាដោយពឹងផ្អែកយ៉ាងច្រើនទៅលើឥរិយាបទផ្ទាល់ខ្លួន និងបទពិសោធន៍នៃសមាជិកក្រុ និងជាពិសេសមេដឹកនាំក្រុមធ្វើផែនការ។ វាបានបង្ហាញភស្តុតាងច្បាស់លាស់ថាមានដំណើរការនៃការផ្លាស់ប្តូរពីចាស់មកថ្មីដើម្បីឱ្យភាពជាក់ស្តែងក្នុងប្រទេសពិសេសមួយឬអាជ្ញាធរតាមតំបន់អាចស្ថិតនៅត្រង់ណាមួយនៃចំណុចចុងទាំងពីរ។ ការប្រៀប ធៀបជាទូទៅក្នុងដំណើរការគឺត្រូវបានបង្ហាញក្នុងដ្យាក្រាមខាងក្រោម។

ភាពខុសគ្នាធំបំផុតនៅដំណាក់កាលនេះគឺថានៅក្នុងគំរូថ្មីមានការយកចិត្តទុកដាក់ជាច្រើនដើម្បីកំណត់ និងវិភាគក្រុមអ្នកពាក់ព័ន្ធ។ គោលបំណងនៅទីនេះគឺត្រូវបានកំណត់ពីរបៀបដែលល្អបំផុតក្នុងការដោះស្រាយក្រុមនីមួយៗសំឡឹងមើលផលប្រយោជន៍របស់គេ និង ឥរិយាបទទូទៅដើម្បីការអភិវឌ្ឍ។ ការពិគ្រោះយោបល់ប្រកបដោយការ

ចូលរួម និងកម្មវិធីពាក់ព័ន្ធនឹងត្រូវបានរួមបញ្ចូលក្នុងដំណើរការកសាងផែនការ និងយុទ្ធសាស្ត្រទំនាក់ទំនងអ្នកពាក់ព័ន្ធត្រូវបានរៀបចំឡើង។

### *នៅក្នុងគំរូថ្មី ការយកចិត្តទុកដាក់ភាគច្រើនដើម្បីកំណត់ និងវិភាគក្រុមអ្នកពាក់ព័ន្ធ*

ជំហានបន្ទាប់ផ្តោតសំខាន់លើបញ្ហានៃការប្រមូលព័ត៌មាន។ គំរូចាស់ជាទូទៅព្យាយាមប្រមូលទិន្នន័យ និងព័ត៌មានដែលមានទាំងការសិក្សាថ្មី។ ព័ត៌មានដែលបានប្រមូលបាននឹងត្រូវបានវិភាគដើម្បីបង្កើតជារូបភាពមួយ នៃស្ថានភាពបច្ចុប្បន្ន។ រូបភាពនេះអាចត្រូវបានប្រៀបធៀបទៅនឹងឈុតមួយនៃគំរូ និង ស្តង់ដារ សេវាកម្មមូលដ្ឋាន ឬជាតិ និង/ ឬគុណភាពជីវិត។ ផលប្រយោជន៍ពិសេសនេះគួរជាផលប្រយោជន៍ទាំងឡាយដែលមានវិធានការបែងចែកតំបន់ប្រើប្រាស់– មានដូចជាក្រឡាផ្ទៃមែត្រការ៉េនៃទីតាំងសម្រាប់មនុស្សម្នាក់ៗ រឺក្រឡាផ្ទៃម៉ែត្រការ៉េនៃទីតាំងសម្រាប់ការសង់ទីលំនៅដ្ឋាន។ គំរូ និងស្តង់ដា តំណាងឱ្យកម្រិតនៃគុណភាពនៃការរស់នៅដែលប្រទេសជាតិត្រូវការ។ ពួកគេត្រូវបានបង្កើតដោយអាជ្ញាធរជាតិ។

ការវិភាគនូវស្ថានភាពបច្ចុប្បន្នគួរបញ្ជាក់កម្រិតដែលស្តង់ការនេះសម្រេច បាន។ រួមគ្នាជាមួយនឹងការវិភាគនិន្នាការ និងអត្រាកំណើន រាយប្រជាជនទាំងនេះបង្កើតបាននូវតម្រូវការនាពេល អនាគតចំពោះប្រភេទផ្សេងៗគ្នានៃសេវាកម្ម និងដីដែលត្រូវការ។ ក្នុងគំរូចាស់ ទិន្នន័យជាច្រើនមិនត្រូវបានប្រើក្នុង មធ្យោបាយសំខាន់ជាច្រើន។

ផ្ទុយទៅវិញ គំរូថ្មីកំណត់នូវដំណើរការចំនួន២ **ទីមួយ**គឺដំណើរការរៀបរាប់ឆាប់រហ័សដោយផ្អែកលើទិន្នន័យដែលមានស្រាប់ហើយទិន្នន័យដែលអាចរកបាន។ **ទីពីរគឺ** ដំណើរការចូលរួម និងពិគ្រោះយោបល់ដែលឱ្យក្រុមអ្នកពាក់ព័ន្ធសំខាន់ៗចូលរួមមានទាំងអ្នកនយោបាយផងដែរ។ គោលបំណងនៃជំហាននេះគឺត្រូវពិនិត្យមើលទ្រព្យសម្បត្តិបច្ចុប្បន្នគ្រប់ប្រភេទទាំងអស់ (មនុស្ស វប្បធម៌ សង្គម សេដ្ឋកិច្ច និងបរិស្ថាន) ដើម្បីបង្កើតជាចក្ខុវិស័យនៃស្ថានភាពអនាគតតាមសេចក្តីប្រាថ្នាសម្រាប់តំបន់, បញ្ច្រាបចក្ខុវិស័យនេះទៅក្នុងគោលបំណងតាមវិស័យរយៈពេលវែង និងដើម្បីផ្តល់អាទិភាព គោលបំណងរយៈពេលខ្លីសម្រាប់ការអនុវត្តរយៈពេល៣ទៅ៥ឆ្នាំ។

ដំណើរការអាទិភាពរួមបញ្ចូលលទ្ធផលរកឃើញនៃការរៀបរាប់ឆាប់រហ័ស និងការដឹកនាំទៅរកការពិពណ៌នាមួយអំពីតំបន់ពិសេស ឬប្រធានបទដែលមានតម្រូវការការស៊ើបអង្កេត។ វាស្ថិតក្នុងលក្ខណៈពិសេសដែលគំរូថ្មីមិនដូចគំរូចាស់ពាក់ព័ន្ធនឹងការប្រមូលទិន្នន័យ។ ប្រការនេះឥឡូវត្រូវផ្តោតលើព័ត៌មានដែលត្រូវការសម្រាប់ប្រើប្រាស់រយៈពេលខ្លីមិនមែនសម្រាប់សកម្មភាពដែលអាចអនុវត្តលើសពីរយៈពេលប្រាំឆ្នាំដំបូងនោះទេ។ នៅពេលដំណាលគ្នានេះតម្រូវការព័ត៌មានរយៈពេលវែងនឹងត្រូវបានកំណត់ និងរួមបញ្ចូលក្នុងសកម្មភាពដើម្បីអនុវត្តកំឡុងពេលអនុវត្តលើកដំបូង។ ដូច្នេះកម្មវិធីសកម្មភាពខ្លីរួមទាំងវិធានការគាំទ្រតម្រូវការផែនការអនាគត។

***នេះជាចំណុចមួយដែលផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច ផែនការតាមវិស័យ និងផែនការគ្រប់គ្រងបរិស្ថានមាន អន្តរទំនាក់ទំនងជាមួយក្របខណ្ឌបែងចែកតំបន់ប្រើប្រាស់តាមរបៀបមួយដែលមិនមានឡើងទេនៅក្រោមគំរូចាស់***

ការបែងចែកការប្រើប្រាស់ទាំងគំរូចាស់និងថ្មីនឹងផលិតនូវក្របខណ្ឌបែងចែករយៈពេលវែងសម្រាប់ការអភិវឌ្ឍជាទូទៅក្នុងទម្រង់នៃប្រភេទការកសាងផែនទីបែងចែកតាមតំបន់ដោយមានរបាយការណ៍អមជាមួយអត្ថបទ។ ជាពិសេសទៅទៀតនោះ គំរូផែនការថ្មីនឹងរួមបញ្ចូលទាំងកម្មវិធីសកម្មភាពដែលគោលបំណងរបស់គេគឺដើម្បីសម្រេចចក្ខុវិស័យនេះដែលទំហំការបែងចែកតំបន់ប្រើប្រាស់របស់វាផ្តល់ឱ្យក្នុងផែនទីបែងចែកតំបន់នេះ។

ក្នុងវិធីសាស្ត្រថ្មី ការអភិវឌ្ឍសេដ្ឋកិច្ច និងការគ្រប់គ្រងបរិស្ថាននិងបញ្ហាទាំងអស់ដែលទាក់ទងនឹងការបង្កើនគុណភាពជីវិតសម្រាប់តំបន់សង់ទីលំនៅឱ្យកាន់តែប្រសើរឡើងត្រូវបានប្រព្រឹត្តទៅរួមគ្នាក្នុងទំនើបកម្មចម្រុះមួយដែលមានទំហំគ្របដណ្តប់ផងដែរ។ ការងារនេះនាំឱ្យមានតម្រូវការសមត្ថភាពស្ថាប័ន (ការគ្រប់គ្រងការអនុវត្ត។ល។) ត្រូវបានបញ្ចូល។ មុខសញ្ញាគ្រោះថ្នាក់បង្កឡើងដោយមនុស្ស និងធម្មជាតិចំពោះសេវាកម្មបរិស្ថាន និងក្រុមងាយរងគ្រោះដោយសារសង្គមអាចត្រូវបានបញ្ចូលនៅដំណាក់កាលនេះ។ គំរូចាស់ជាទូទៅទុកការងាររៀបចំផែនការឱ្យទៅក្រុមអ្នកមានវិជ្ជាជីវៈប៉ុន្តែតម្រូវឱ្យពួកគេផ្សព្វផ្សាយសំណើពង្រាងឱ្យពិនិត្យមើលជាសាធារណៈ។ គំរូថ្មីនាំឱ្យនិងលើកទឹកចិត្តឱ្យមានការចូលរួមយ៉ាងទូលាយក្នុងការបង្កើតចក្ខុវិស័យរៀបចំគោលបំណងរយៈពេលវែង និង កំណត់អាទិភាពគោលដៅ ពិនិត្យឡើងវិញនូវយុទ្ធសាស្ត្រ និង ផ្តល់យោបល់ទៅលើផែនការពង្រាង។ ប្រការនេះ មានគោលបំណងនាំឱ្យមានការគាំទ្រឱ្យកាន់តែទូលាយ (ឧ.ការអនុវត្ត) នូវផែនការដែលមានភាពជាម្ចាស់ការដ៏ទូលំទូលាយ និងជាផែនការអាចអនុវត្តបានច្រើនទៀត។ គំរូថ្មីជម្រុញឱ្យមានការតាមដានត្រួតពិនិត្យយ៉ាងសកម្មនិងជាបន្តបន្ទាប់នូវការរីកចម្រើនក្នុងការអនុវត្តតាមរយៈការភ្ជាប់ទំនាក់ទំនងទៅនឹងដំណើរការថវិកាប្រចាំឆ្នាំនៅក្នុងរដ្ឋាភិបាលមូលដ្ឋាននិងផែនការចំណាយរយៈពេលមធ្យម។

***ការចូលរួមរបស់អ្នកពាក់ព័ន្ធចេះតែបន្តក្នុងដំណើរការតាមដានត្រួតពិនិត្យ និងការពិនិត្យឡើងវិញគឺជាកត្តាដ៏សំខាន់ក្នុងដំណើរការអភិបាលកិច្ចប្រកបដោយតម្លាភាពនិងមានគណនេយ្យភាព***

## ជំពូកទី៥—ការអនុវត្តនូវទស្សនៈទាន់ពេលនៃគោលបំណងនៅក្នុងដំណើរការរៀបចំផែនការប្រើប្រាស់តំបន់ឆ្នេរ (CSP)

### ជំហានទី១ — ការរៀបចំផែនការប្រើប្រាស់តំបន់ឆ្នេរ (CSP)

(CSP) គឺមានភាពស្មុគស្មាញយ៉ាងខ្លាំង ហើយនេះជាការពិតដោយសារតែឱណាមិកនៃសមាសភាពពិភពលោកផ្នែកជីវសាស្ត្រ និងរូបវន្ត និង ការចាប់អារម្មណ៍ ដែលមានលក្ខណៈប្រកួតប្រជែងរបស់មនុស្សចំពោះវត្ថុមានធនធានធម្មជាតិ។ នៅពេលដំណាលគ្នានេះមានតំបន់ឆ្នេរជាច្រើនត្រូវទទួលរងនូវគ្រោះថ្នាក់ផ្សេងៗគ្នា ទាំងដោយសារកត្តាមនុស្ស និងកត្តាធម្មជាតិ។ ដោយសារតែនៅខ្សែទឹកខាងក្រោមដែលបង្កឡើងដោយសកម្មភាពមនុស្សទាំងអស់នោះ តំបន់ឆ្នេរគឺជាកន្លែងទទួលរងនូវសារធាតុសំណល់ពុល និងផលប៉ះពាល់នៃសកម្មភាពពីដីគោក។ ប្រការដែលគួរឱ្យចងចាំគឺការកសាងផែនការសកម្មភាពគ្រប់គ្រងដែលមិនបញ្ចប់ត្រឹមផលិតភាពនៃឯកសារមួយនោះទេ។ វាជាដំណើរការវិលជុំនិងមានអន្តរកម្មដែលសកម្មភាពកសាងផែនការនៅកម្រិតផ្សេងៗគ្នាមានអន្តរកម្មជាមួយគ្នាទៅវិញទៅមក។ នៅពេលរៀបចំកសាងផែនការបែងចែកតំបន់ប្រើប្រាស់សំរាប់វដ្តនៃ CSP មួយនោះចូរចងចាំវដ្តសម្រាប់អនាគត និងរៀបចំមូលដ្ឋានសម្រាប់ពួកគេ។

***ការកសាងផែនការបែងចែកតំបន់ប្រើប្រាស់គឺជាសកម្មភាពគ្រប់គ្រងដែលមិនបញ្ចប់ត្រឹមផលិតភាពឯកសារមួយនោះទេ***

មានការងារសំខាន់ៗចំនួន៦ក្នុងដំណាក់កាលរៀបចំការកសាងផែនការបែងចែកតំបន់ប្រើប្រាស់

១. ការកំណត់អត្តសញ្ញាណតំបន់ CSP និងវិសាលភាពនៃមាតិការបស់វា

២. ការកំណត់អត្តសញ្ញាណនៃក្រុមអ្នកពាក់ព័ន្ធ និងការអភិវឌ្ឍយុទ្ធសាស្ត្រពាក់ព័ន្ធដើម្បីធ្វើការជាមួយពួកគេ

៣. ការរៀបចំការងារកសាងផែនការ និងកំណត់ជំនាញដែលត្រូវការ

៤. ការពង្រាងកាលវិភាគការងារ– ផែនការដំណើរការ

៥. ការរៀបចំការគ្រប់គ្រងព័ត៌មាន និង

៦. ការជូនដំណឹងនូវគោលបំណងធ្វើផែនការ និងអញ្ជើញឱ្យផ្តល់នូវធាតុចូល។

***ភារៈកិច្ចទី១: ការកំណត់អត្តសញ្ញាណនៃទីតាំង និងវិសាលភាព CSP***

មានលក្ខណៈវិនិច្ឆ័យមួយចំនួនដែលនឹងតើតួយ៉ាងសំខាន់ជាផ្នែកមួយក្នុងការកំណត់តំបន់កសាងផែនការ ។ ក្នុងករណីជាច្រើន ពួកគេត្រូវការធ្វើឱ្យមានតុល្យភាពជាមួយគ្នា ។ តារាងខាងក្រោមនិយាយពីទិដ្ឋភាពសំខាន់ៗទាំងនេះ

| **លក្ខណៈវិនិច្ឆ័យ** | **ការពន្យល់** |
| --- | --- |
| និយមន័យតំបន់ឆ្នេរ | ប្រសិនបើមាននិយមន័យស្របច្បាប់មួយនៃតំបន់ឆ្នេរ ផែនការបែងចែកការប្រើប្រាស់ តំបន់ឆ្នេរ គួររាប់ក្នុងនិយមន័យនេះ. |
| អាជ្ញាធរយុត្តាធិការ ត្រូវធ្វើផែនការតំប់ឆ្នេរ | ក្នុងករណីខ្លះ កម្រិតរដ្ឋាភិបាលផ្សេងៗគ្នាមានអាជ្ញាធរស្របច្បាប់ ដើម្បីធ្វើ ផែនការ ប៉ុន្តែ វិស័យយុត្តាធិការទាំងអស់នេះខុសៗគ្នា ។ ឧទាហរណ៍នៅប្រទេសឥណ្ឌូនេស៊ីអាជ្ញាធរមូលដ្ឋាន បាន កំណត់ ផែនការទទួលខុសត្រូវហួតដល់ចម្ងាយ ៤ម៉ៃល៍ ចំណែកឯយុត្តាធិការរបស់ អាជ្ញាធរ ខេត្តមានចម្ងាយពី ៤-១២ម៉ៃល៍ និងនៅថ្នាក់ជាតិលើសពីនោះទៀត ។ នៅប្រទេសខ្លះទៀត អាជ្ញាធរកសាងផែនការរូបវន្តគ្មានសិទ្ធិធ្វើផែនការលើស ពីសញ្ញា ទឹកនោះទេ ។ អាជ្ញាធរខ្លះ ទៀតទទួលខុសត្រូវចំពោះការកសាងផែនការក្នុងតំបន់លិចទឹកឬ តំបន់ដែលនៅខាងក្រោម សញ្ញាទឹក ។ |
| ស្ថានភាពស្របច្បាប់នៃ ផែនការ និងអាជ្ញាធរ អង្គភាពដែលរៀបចំវា | នៅប្រទេសខ្លះ ផែនការបែបនេះនឹងអាចជាយុទ្ធសាស្ត្រ ប៉ុន្តែមិនស្របច្បាប់នោះទេ ចំណែកឯ ប្រទេសផ្សេងទៀតប្រហែលជាមានការអនុវត្តច្បាប់ ។ ប្រការនេះទាមទារឱ្យមាន ការចងក្រង ធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចស្របច្បាប់ |
| យន្តការ និងអង្គភាព អនុវត្តន៍ | ការអនុវត្តផែនការតម្រូវឱ្យមានហិរញ្ញវត្ថុ និងលំហូរហិរញ្ញវត្ថុ តាមរចនាសម្ព័ន្ធរដ្ឋបាល ។ ព្រំដែនរដ្ឋបាលអាចជាកត្តាកំណត់សំខាន់ ក្នុងការជ្រើសរើសតំបន់ដែលត្រូវកសាង ផែនការ ។ ទោះជាយ៉ាងណាក៏ដោយ យើងគួរមានផែនការតំបន់ឆ្នេរ នៅក្នុងអង្គភាពរដ្ឋបាល – ដោយមិន ចាំបាច់គ្របដណ្តប់ប្រវែងតំបន់ឆ្នេរទាំងមូលនៃ អង្គភាពរដ្ឋបាលនោះទេ |

| លក្ខណៈវិនិច្ឆ័យ | ការពន្យល់ |
|---|---|
| គោលបំណងនៃផែនការ | ការលើទឹកចិត្តពិសេសសម្រាប់ផែនការបែងចែកតំបន់ប្រើប្រាស់អាចប៉ះពាល់ ដល់ការជ្រើសរើសតំបន់ ។ ប្រសិន បើគោលបំណងនេះត្រូវការពារនិងអភិវឌ្ឍប្រកបដោយចីរភាពនូវតំបន់ធម្មជាតិមួយដែលរំពឹងថាស្ថិតនៅក្រោមសំពាធនៃការអភិវឌ្ឍក្នុងពេល អនាគតនោះ ផែនការនេះគួរតែផ្តោតលើតំបន់ធម្មជាតិជាក់លាក់មួយ ។ ម្យ៉ាងវិញទៀត ប្រសិនបើគោលបំណងត្រូវផ្តល់នូវផែនការមេសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចតំបន់ឆ្នេរចម្ងាយ 200-500 គមខ្សែបន្ទាត់តំបន់ឆ្នេរទាំងមូល នឹងកំណត់តំបន់នោះ ។ នៅថ្នាក់ជាតិ ចាំបាច់ ត្រូវមានផែនការយុទ្ធសាស្ត្រតំបន់ឆ្នេរ ដែលតាមរយៈនោះផលប្រយោជន៍ជាតិក្នុង ការអភិរក្ស បរិស្ថាន ដឹកជញ្ជូនថាមពល ការតាំងលំនៅនិងទេសចរណ៍ កសិកម្ម វារីវប្បកម្ម និងការនេសាទ និងការការពារត្រូវបានកំណត់ និងលៃលកទីកន្លែងដោយយោង តាមប្រភព ដែលមានស្រាប់ និងសក្តានុពល |
| ទំហំ និងកម្រិតនៃសេចក្តី ពិស្តារ | ទាក់ទងនឹងគោលបំណងផែនការ គឺទំហំ និងកម្រិតសេចក្តីពិស្តារ និងគុណភាពរំពឹងថាមាន ។ ជាទូទៅតម្លៃ (តំបន់មួយឯកតា) នៃផែនការគុណភាព លំអិត និងខ្ពស់ និងខ្ពស់ជាងកម្រិតនៃផែនការយុទ្ធសាស្ត្រ និងមានលក្ខណៈទូទៅ |
| សមត្ថភាពកសាងផែនការ | ដំណើរការធ្វើផែនការស៊ីជម្រៅ ពិស្តារ និងសមហេតុផល តម្រូវឱ្យមានជំនាញពិសេស និងជាទូទៅមានបុគ្គលិកច្រើនរួមគ្នា ។ ភាពមានជំនាញទាំងនេះ អាចជាកត្តាមួយក្នុងការកំណត់ផែនការ ប៉ុន្តែអាចមិនរាប់បញ្ចូលនូវប្រភេទនៃតំបន់ (ឧ. តំបន់សមុទ្រ) ដែលមិនមានជំនាញច្បាស់លាស់នៅក្នុង សិទ្ធិកសាងផែនការ ។ |
| ធនធានហិរញ្ញវត្ថុ | ហិរញ្ញវត្ថុនឹងត្រូវធ្វើឱ្យមានតុល្យភាពទល់នឹងទំហំ ឬខ្នាត កម្រិតនៃភាពទំនើបនិងពិស្តារ និងសមត្ថភាពធនធានមនុស្ស និងថាតើមានការចុះហត្ថលេខានៃអ្នកជំនាញ ឯកទេសរឺក៏អត់ |

ស្ថានភាពពិសេសមួយអាចកើតមានឡើងដែលក្នុងនោះតំបន់ CSP ព័ទ្ធជុំវិញទីក្រុងទាំងមូលឬតំបន់ទីក្រុងរួមជាមួយនឹងតំបន់ឆ្នេរពុំទាន់មានការអភិវឌ្ឍ ។ វិធីសាស្ត្រ CSP ដ៏ស៊ីជម្រៅនិងអាចបំពេញបំណងការពង្រីកទីក្រុងឱ្យមានតុល្យភាព ជាមួយនឹងការការពារ និងគ្រប់គ្រងសម្បត្តិជីវសាស្ត្រ ។ បញ្ហានៃទំនាក់ទំនងរវាងតំបន់ជនបទនិងទីក្រុង ចាំបាច់ត្រូវមានការយកចិត្តទុកដាក់ថែមទៀតក្នុងការគ្រប់គ្រងក្រុមអ្នកពាក់ព័ន្ធផ្សេងទៀត ។

តំបន់ CSP នឹងកំណត់ព្រំប្រទល់ការបែងចែកផែនការដែលគូសបញ្ជាក់ពីការប្រើប្រាស់ដីធ្លី និងធនធានស្របជាមួយនឹងលក្ខខណ្ឌនៃការប្រើប្រាស់។ តំបន់នេះមិនដូចគ្នាបេះបិទទៅនឹងតំបន់ដែលមានទិន្នន័យ និងព័ត៌មានធាតុចូលត្រូវបានប្រមូលនោះទេ។ ដូចបានបញ្ជាក់តាមរយៈ (ridge-to-reef) និងទស្សនៈទាននៅក្នុងសេចក្តីផ្តើម, មានសកម្មភាព ចរិតលក្ខខណៈ និងនិន្នាការជាច្រើនកើតឡើងខាងក្រៅតំបន់រៀបចំផែនការដែលជះឥទ្ធិពលលើស្ថានភាព និងនិន្នាការខាងក្នុង។ វាជាការពិត មិនមែនតែបាតុភូតធម្មជាតិ និងអេកូស៊ីស្ទែមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកត្តាសេដ្ឋកិច្ច សង្គម ស្ថាប័ន និងនយោបាយ។ តំបន់ដែលរងឥទ្ធិពលដោយកត្តាជីវរូបវន្ត ថែមទាំងកត្តាសេដ្ឋកិច្ចសង្គមនោះអាចត្រូវបានគូសវាសយ៉ាងទូលាយដើម្បីស្នើរកកន្លែងដែលអាចប្រមូលព័ត៌មានបាន។

ប្រការនេះមានសារៈសំខាន់ណាស់សម្រាប់ការយល់ដឹងដំណើរការកំពុងប្រព្រឹត្តទៅក្នុងតំបន់កសាងផែនការ និងសម្រាប់បង្កើតសេណារីយោនិងចក្ខុវិស័យអនាគត។ វាមានសារៈសំខាន់ណាស់ដែលនៅចំណុចចាប់ផ្តើមត្រូវមានគំនិតច្បាស់លាស់អំពីទំហំផែនការ – មិនមែនគ្រាន់តែក្នុងតំបន់នោះប៉ុណ្ណោះទេ ប៉ុន្តែប្រភេទនៃផែនការគោលបំណងរបស់វា និងកម្រិតនៃភាពពិស្តារទៀតផង។ យើងត្រូវតែចោទជាសំនួរដូចខាងក្រោម៖

- តើវានឹងជាផែនការយុទ្ធសាស្ត្រ ទូទៅមួយដែលបានផ្តល់នូវគោលការណ៍ណែនាំទូលាយសម្រាប់អ្នកសម្រេចចិត្ត ឬ តើវាជាផែនការតំបន់ពិស្តារ ដែលបានកំណត់នូវលក្ខខណ្ឌច្បាស់លាស់ដើម្បីធ្វើការអភិវឌ្ឍក្នុងតំបន់នីមួយៗ?
- តើវាស្របច្បាប់ទេនៅពេលដែលអនុម័តដោយអាជ្ញាធរពាក់ព័ន្ធ?
- តើវាជាចំណុចផ្តោតដ៏សំខាន់ និងកម្លាំងជម្រុញសម្រាប់កម្មវិធីគ្រប់គ្រងតំបន់ឆ្នេរចម្រុះ ឬតើវាជាការបកស្រាយផែនការបែងចែកតំបន់នៃប្រព័ន្ធគ្រប់គ្រងតំបន់ឆ្នេរដែលមានស្រាប់?
- តើវាជាការចងក្រងផែនការតាមវិស័យដែលមានស្រាប់ ឬជាផែនការបែងចែកតំបន់ដែលគ្រប់ផ្នែកទាំងអស់ត្រូវអនុវត្តតាម?
- តើវាជាចំណុចសំខាន់នៃដំណើរការប្រកបដោយការចូលរួមរយៈពេលវែង ឬ តើវាជាផលិតផលមួយក្នុងចំណោមផលិតផលជាច្រើនទៀតដែលអនុវត្តតាមរយៈពេលវេលានោះ?

ការឆ្លើយតបចំពោះសំនួរទាំងនេះអាចជាចម្លើយត្រង់ឧទាហរណ៍នៅទីណាដែលគោលបំណងនៃផែនការ និងធម្មជាតិត្រូវបានកំណត់ដោយច្បាប់។ ស្ថានភាពផ្សេងៗទៀតអាចជាស្ថានភាពវិសេសវិសាលដោយអំពាវនាវរកដំណោះស្រាយចំពោះស្ថានភាពដ៏ពិសេសដែលអាចដោះស្រាយបានតាមរយៈដំណើរការ CSP ដែលបានរៀបចំជាពិសេសនោះ។

នៅក្នុងបរិបទនេះវាក៏មានសារៈសំខាន់ផងដែរដើម្បីបង្កើតលក្ខណៈវិនិច្ឆ័យដោយការសម្រេចចិត្តកសាងផែនការរួម ។ នៅក្នុងបរិបទនៃ CSP ជាពិសេសនៅពេលការកណត់តំបន់ និងលក្ខខណ្ឌសម្រាប់ការអភិវឌ្ឍនោះមាន

ជម្រើសជាច្រើននិងផលប្រយោជន៍ដែលមានការប្រគួតប្រជែងច្រើនទៀត។ វាចាំបាច់ត្រូវតែកំណត់នូវលក្ខណៈវិនិច្ឆ័យលើការសម្រេចចិត្តមុនពេលឈានទៅដល់ចំណុចនោះនៅពេលដែលការសម្រេចចិត្តនោះត្រូវតែធ្វើ។ អ្នកធ្វើផែនការត្រូវសួរថាតើលក្ខណៈវិនិច្ឆ័យមួយណានឹងត្រូវទទួលបន្ទុកធំបំផុតនោះ?

- ជម្រើសដែលត្រូវការការពារ និងលើកស្ទួយប្រព័ន្ធអេកូស៊ីស្ទែម និងជម្រកសំខាន់ៗ?
- ជម្រើសដែលផ្តល់នូវចំណូលជាហិរញ្ញវត្ថុដ៏ធំបំផុត?
- ជម្រើសដែលផ្តល់ផលចំណេញសម្រាប់មនុស្សភាគច្រើន?
- ជម្រើសសម្រាប់ផលប្រយោជន៍សាធារណៈឬវិស័យឯកជន?
- ជម្រើសដែលមានការគាំទ្រជាសាធារណៈទូលំទូលាយបំផុត?
- ជម្រើសដែលនាំទៅរកភាពចន់រួមដ៏ធំបំផុតក្នុងការប្រឈមនឹងភាពទន្ទត់នៃបរិស្ថាន និង សេដ្ឋកិច្ច និង សង្គម?
- ជម្រើសដែលផ្តល់នូវការងាររយៈពេលខ្លី?

## បញ្ហាពាក់ព័ន្ធមួយចំនួននៅពេលអនុវត្តន៍វិធីសាស្ត្រផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែម (EBA)

ការកសាងផែនការផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមគឺជាវិធីសាស្ត្រគ្រប់ជ្រុងជ្រោយហើយផ្តោតការយកចិត្តទុកដាក់លើទំនាក់ទំនងដែលចងក្រងនូវសមាសភាពផ្សេងៗនៃប្រព័ន្ធរួមគ្នា។ វាក៏បានកំណត់នូវសកម្មភាពមនុស្សផ្ទាល់ទៅក្នុងប្រព័ន្ធអេកូស៊ីស្ទែម។ និន្នាការប្រព័ន្ធរដ្ឋបាល សេដ្ឋកិច្ច សង្គមនិងអេកូស៊ីស្ទែមត្រូវតែប្រមូលផ្តុំប្រព័ន្ធតូចៗជាងនៅក្នុងប្រព័ន្ធធំៗជាង។ បញ្ហាពាក់ព័ន្ធមួយចំនួនចំពោះការកំណត់ព្រំដែនសម្រាប់តំបន់កសាងផែនការគួរតែ:

- ស្វែងរកប្រព័ន្ធអេកូស៊ីស្ទែម "**ទាំងមូល**" សមស្របសំរាប់ទំហំកសាងផែនការ–ឧទាហរណ៍ជៀសវាងការគូសវាស់ព្រំដែនកំណត់ផែនការជាបន្ទាត់ត្រង់មួយកាត់ព្រៃកោងកាង ឬ ផ្កាថ្ម។ ប្រសិនបើមិនបានសិក្សាដើម្បីសន្និដ្ឋាននូវព្រៃកោងកាងឬផ្កាថ្មទាំងមូលបានទេចូរកំណត់នូវផ្នែកសម្ងាត់មួយចំនួននៅក្នុងនោះដែលអាចត្រូវបានរួមបញ្ចូលក្នុងសាព័ន្ធ (Entirety) និងប្រើវាដើម្បីកំណត់ព្រំប្រទល់។
- តាមគោលនយោបាយស្រដៀងនេះចូរចាត់ទុកផ្នែករដ្ឋបាលដែលឆ្លុះបញ្ចាំងនូវទំហំនិងកម្រិតដែលផែនការនេះត្រូវ បានធ្វើរួចហើយ។ ជាទូទៅ ការអនុវត្តត្រូវបានធ្វើឡើងតាមរយៈអង្គភាពរដ្ឋបាល ហើយអាស្រ័យហេតុនេះមានតម្លៃក្នុងការគោរពអង្គភាពរដ្ឋបាលនេះ។
- ចូរទទួលស្គាល់ និងរាប់បញ្ចូលនូវដំណើរការកសាងផែនការផ្សេងៗ ដែលភ្ជាប់ទំនាក់ទំនងទៅនឹងផ្នែកមួយចំនួននៃប្រព័ន្ធធំជាងដែលនៅក្រៅតំបន់កសាងផែនការ។ ប្រការនេះធ្វើឡើងដោយស្វ័យប្រវត្តិក្នុងប្រព័ន្ធ

រដ្ឋបាលពីព្រោះច្បាប់ជាតិអនុវត្តនៅកម្រិតមូលដ្ឋាន កន្លែងដែលគោលនយោបាយ និងយុទ្ធសាស្ត្រជាតិត្រូវតែអនុវត្តតាម ។ ស្រដៀងគ្នានេះដែរ ទំនាក់ទំនងសេដ្ឋកិច្ច និងសង្គមជាទូទៅដោយទទួលខុសត្រូវលើការកសាងផែនការ–ជាពិសេសនៅពេលដែលពិចារណាអំពីកំលាំងជម្រុញដូចជាការផ្លាស់ទីនិងការធ្វើពាណិជ្ជកម្ម។ យើងត្រូវតែគិតគូរឱ្យមានភាពស្មើគ្នានូវសមាសភាពបរិស្ថាន ។ ទាំងនេះរួមមានកត្តាខ្សែទឹកខាងលើដែលប៉ះពាល់កករឬ គុណភាពទឹកផ្សេង ឬក៏របបផ្លាស់ទីរបស់ពពួកសត្វទាំងប្រព័ន្ធដី និងសមុទ្រ ។

លទ្ធផលនឹងជាព្រំដែនកំណត់មួយដែលលេចឡើងយ៉ាងរឹងមាំ ប៉ុន្តែព្រំដែនការងារមានលក្ខណៈកាន់តែ "មានភាពមិនប្រាកដប្រជា-Fuzzy" ទាក់ទងនឹងទិដ្ឋភាពដែលមានឥទ្ធិពលខាងក្រៅតំបន់គម្រោង ។ នៅទីណាដែលចាំបាច់ក្រុមកសាងផែនការ គួរគូសបញ្ជាក់ចំណុចបញ្ហាដែលត្រូវការដោះស្រាយនៅក្រៅតំបន់កសាងផែនការ និងដោយភ្នាក់ងារមកពីក្រៅដោយសារតែមានផលប៉ះពាល់របស់វាលើព្រឹត្តិការណ៍ ឬលក្ខខណ្ឌ នៅក្នុងតំបន់កសាងផែនការនោះ ។

គំនិតសមស្របបំផុតគឺត្រូវធ្វើផែនការឱ្យបាននៅកម្រិតទាំងអស់ឱ្យស្របគ្នា ។ ជាឧហរណ៍ នូវរបៀបថាតើកិច្ចការនេះអាចត្រូវធ្វើដូចម្តេចសូមមើលនូវអ្វីដែលចក្រភពកូឡុំប៊ី កាណាដា សម្រេចបាននៅគេហទំព័រ http://www.citbc.org/ ។ ការងារពហុកម្រិតនេះមិនអាចសម្រេចបាននៅពេលដំណាលគ្នានោះ ទេប៉ុន្តែនឹងធ្វើតាមបែបគំរូនៃលំហូព័តិមានមួយឡើងលើ និងចុះក្រោមដូចមានបង្ហាញក្នុងដ្យាក្រាមស្តីពីសមាហរណកម្មផែនការនៅថ្នាក់រដ្ឋបាលខុសៗគ្នា ។

បញ្ហាពាក់ព័ន្ធសម្រាប់ផែនការសមុទ្រ និងដីចម្រុះ នៅត្រង់ណាដែលមានការកសាងសមុទ្រនិងដីរួមគ្នានៃព្រំដែនសំដៅទៅសមុទ្រត្រូវតែកំណត់ ។ ដូចមានបង្ហាញក្នុងតារាងមុនៗ ប្រទេសជាច្រើនបានធ្វើការងារនេះរួចជាស្រេចតាមមធ្យោបាយជាច្រើនមានប្រទេសខ្លះមិនច្របាច់បញ្ចូលវិស័យសមុទ្រទៅក្នុងផែនការតំបន់ឆ្នេរទាល់តែសោះ ។ ប្រសិនបើមានព្រំដែនរដ្ឋបាលកំណត់ដោយច្បាប់នោះ ប្រការគួរតែត្រូវគោរព និងប្រើប្រាស់ (ចូរចងចាំនូវអ្វីដែលបាននិយាយរួចហើយនៅខាងលើអំពីការកសាងផែនការផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែម) ។ នៅទីណាមិនមានព្រំដែនកំណត់ដោយច្បាប់នោះទេ ប៉ុន្តែគ្មានការហាមឃាត់ផ្លូវច្បាប់ដោយរាប់បញ្ចូលតំបន់សមុទ្រនោះ ចូរប្រើប្រាស់ការពិចារណាស្រដៀងគ្នាដូចដែលបានអនុវត្តលើដីគោក–គឺការផ្សំផ្គុំនូវកត្តាប្រព័ន្ធ អេកូស៊ីស្ទែម ព្រំដែនរដ្ឋបាល និងការណនិយម (pragmatism) ។ ចូរពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធដែលធ្វើការលើកិច្ចការសមុទ្រលើព្រំដែនដែលមានប្រយោជន៍ ។ ទាំងនេះនឹងរួមបញ្ចូលទាំងអាជ្ញាធរដែលពាក់ព័ន្ធជាមួយការនេសាទ(ដើម្បីឱ្យវិធីសាស្ត្រគ្រប់ជ្រុងជ្រោយអាចយកមកអនុវត្តបានដើម្បីកំណត់ផ្នែកទាំងនោះ) ការធ្វើនាវាចរណ៍ កំពុងផែ ការអនុវត្តច្បាប់ និងជួយសង្គ្រោះ (ឧ. ឆ្មាំសមុទ្រ) ការរុករករ៉ែនៅក្នុងសមុទ្រ ការធ្វើស្រាវជ្រាវីការដកហូតយកប្រេង និងឧស្ម័ន ឬការជីករក និងការពារបរិស្ថានសមុទ្រ ។

## ការរួមបញ្ចូលគ្នានូវការកាត់បន្ថយហានិភ័យ និងការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ

ការប្រែប្រួលអាកាសធាតុនឹងកើតមានឡើងនៅទូទាំងពិភពលោក។ តំបន់រងផលប៉ះពាល់នៃមុខសញ្ញាគ្រោះថ្នាក់តំបន់ឆ្នេរមូលដ្ឋាន រួមមានទាំងកំណើននីវ៉ូទឹកសមុទ្រគួរត្រូវគិតគូរនៅពេលរៀបចំកំណត់ព្រំដែន។ ការបែងចែកគួរតែធ្វើឡើងរវាងមុខសញ្ញាគ្រោះថ្នាក់មានប្រភពពីសមុទ្រ (ឧ.ខ្យល់ព្យុះ រលកយក្សស៊ូណាមិ ការហូរច្រោះតំបន់ឆ្នេរ), មុខសញ្ញាគ្រោះថ្នាក់មានប្រភពមកពីដីគោក (ឧ. ទឹកជំនន់ និងសារធាតុបំពុល) ហើយទាំងនោះគឺកើតឡើងបណ្តាលមកពីទាំងធម្មជាតិ និង មនុស្ស(ឧ.ការឡើងប្រែនៃទឹកក្រោមដីតំបន់ឆ្នេរ) ។ នៅតំបន់ផ្ទៃរាប និងតំបន់ទំនាបតំបន់រងផលប៉ះពាល់ អាចពង្រីកទៅដល់ផ្ទៃដី ឆ្ងាយៗ។ ករណីបែបនេះ ចូរប្រើប្រាស់កត្តាផ្សេងៗទៀតដូចជាអង្គភាព និងប្រព័ន្ធអេកូស៊ីស្ទែមរដ្ឋបាលដើម្បីឈានដល់ដែនកំណត់ជាក់ស្តែងមួយ។ ការគំរាមកំហែងជាក់លាក់ទាំងនេះអាចដោះស្រាយបានដោយខ្លួនឯងផ្ទាល់ដោយគ្របដណ្តប់តំបន់រងផលប៉ះពាល់ទាំងមូល សូម្បីតែកន្លែងដែលលាតសន្ធឹងហួសពីតំបន់កសាងផែនការតំបន់ឆ្នេរដែលបានទទួលយក។ ទោះជាយ៉ាងណាក៏ដោយក្នុងតំបន់កសាងផែនការដែលបានកំណត់អ្នកកសាងផែនការត្រូវតែគិតគូរដល់ទិដ្ឋភាពកាន់តែធំ និងផលប៉ះពាល់លំដាប់បន្ទាប់ឬការភ្ជាប់ទំនាក់ទំនងដែលមានសារៈសំខាន់សម្រាប់តំបន់កសាងផែនការដោយស៊ីសង្វាក់ជាមួយនឹងការទទួលស្គាល់នូវទំនាក់ទំនងនេះផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែម។

**តារាងបញ្ជីសំនួរ**

១. មានអ្វីជាការជម្រុញលើទឹកចិត្តសំខាន់សម្រាប់ការអនុវត្តការកសាងផែនការ?

- តើវាជាតម្រូវការស្របច្បាប់ទេ? បញ្ហាពាក់ព័ន្ធគឺថាច្បាប់នេះមានចែងពីទំហំផែនការបែងចែកតំបន់។ ចូរប្រើប្រាស់ប្រការនេះ ដើម្បីកំណត់តំបន់កសាងផែនការ។
- តើមានតម្រូវការបន្ទាន់ត្រូវដោះស្រាយនូវតម្រូវការប្រគួតប្រជែង និង ការជំទាស់ សម្រាប់ការប្រើប្រាស់ធនធានទេ?។ ប្រការនេះមានន័យថាតំបន់កសាងផែនការ គួរតែដាក់បញ្ចូលនូវតំបន់នេះទាំងមូល ដោយអនុឡោមតាមការទាមទារដែលមានការឈ្លោះទាស់គ្នាទាំងនេះ។
- តើមានតម្រូវការដើម្បីអភិរក្សដោយគាំទ្រសកម្មភាព និង លើកម្ពស់ធនធានធម្មជាតិដែលមានស្រាប់? ការលើកឡើងនេះស្នើថា ប្រពន្ធអេកូស៊ីស្ទែមដែលអាចមើលឃើញ ឬទីជម្រកខុសៗគ្នាគួរជាមូលដ្ឋានសម្រាប់ការគូសនូវដែនកំណត់ ។
- តើអាជ្ញាធរមូលដ្ឋានប្រាថ្នាចង់បានឬមានតម្រូវការប្រើប្រាស់ផែនការបែងចែកតំបន់ ជាឧបករណ៍ដើម្បីគ្រប់គ្រង និងអភិវឌ្ឍប្រកបដោយចីរភាពនូវតំបន់ឆ្នេរទេ? ចូរចាត់ទុកការអភិវឌ្ឍផែនការបែងចែកការប្រើប្រាស់តំបន់ឆ្នេរថាជាប្រធានបទមួយនៃផែនការអភិវឌ្ឍចម្រុះសម្រាប់អង្គភាពរដ្ឋបាលទាំងមូល។ ផែនការចំផ្តល់ឱ្យនូវបរិបទដ៏សំខាន់សម្រាប់ផែនការបែងចែកការប្រើប្រាស់តំបន់ឆ្នេរកាន់តែពិសេស និងពិស្តារ។ ព្រំដែនដីគោកប្រសិនបើគ្មានព្រំដែនរដ្ឋបាលទេអាចត្រូវបានជ្រើសរើសដោយផ្អែកតាមលក្ខខណៈធម្មជាតិ ជម្រក ឬ លក្ខខណ្ឌបង្កើតដោយមនុស្សដូចជាផ្លូវសំខាន់មួយ។

២. តើប្រទេសរបស់អ្នកមាននិយមន័យផ្លូវការអំពីតំបន់ឆ្នេរដែរឬទេ?

បើមាន តើអ្នកចង់ប្រើវាក្នុងការអនុវត្តនេះទេ?

បើមាន ចូរអនុវត្តវាទៅ ប្រសិនបើអត់មាន ចូលទៅសំណួរទី៣

៣. តើអ្នកបានអនុញ្ញាតឱ្យកសាងផែនការក្រោមសញ្ញានៃកម្រិតទឹកទេ?

បើអត់ទេ កម្រិតទឹកខ្ពស់ នឹងជាព្រំដែនឆ្ពោះទៅកាន់សមុទ្ររបស់អ្នក?

ប្រសិនបើមាន តើច្បាប់បានចែងថាតើចំងាយប៉ុន្មានទៅដល់សមុទ្រដែលអ្នកអាច ឬត្រូវធ្វើផែនការនោះ?

ប្រសិនបើមាន ចូរប្រើច្បាប់នេះជាព្រំដែនធ្វើផែនការឆ្ពោះទៅសមុទ្ររបស់អ្នក។

នេះពុំមែនជាបញ្ជីពេញលេញទេ។ ស្ថានភាពពិសេសអាចកំណត់សម្ភាធផ្សេងៗទៀត ដែលចង្អុលបង្ហាញថាតើជម្រើសសំខាន់ជាអ្វី។ CSP និយាយអំពីការស្វែងរក ឱ្យឃើញនូវដំណោះស្រាយមានតុល្យភាពចំពោះផលប្រយោជន៍ ដែលមានលក្ខណៈប្រកួតប្រជែងសូម្បីតែប្រភេទនៃសំនួរខាងលើ ក៏ ជាស្ថានភាពមួយនៅក្នុងការអនុវត្តកសាងផែនការមួយ ដែលជម្រើសមួយធ្ងន់ជាងមួយទៀតក្នុងស្ថានភាពផ្សេងគ្នា. ក្នុងការអនុវត្តការកសាងផែនការដូចគ្នា ការចាត់ចំណាត់ថ្នាក់ខុសគ្នាត្រូវបានធ្វើឡើង។ ការឆ្លើយតប ដ៏សំខាន់បំផុតតបនឹងសំនួរខាងលើជាការ "ល្អប្រសើរ វាអាស្រ័យលើ " អាស្រ័យលើអ្វី? ប្រភេទនៃលក្ខខណ្ឌទាំងអស់នេះហើយដែលត្រូវការគិតគូរមុនពេលវេលាមកដល់។

**ការធ្វើការងារជាមួយអ្នកពាក់ព័ន្ធៈ**
មានបីកម្រិតនៃការធ្វើអន្តរកម្មជាមួយអ្នកពាក់ព័ន្ធៈ
១. ចូរជូនដំណឹងដល់ពួកគេៈ នេះជាទំនាក់ទំង ឯកទិស ដែលក្រុមការងារកសាងផែនការ ត្រូវជូនដំណឹងអ្នកពាក់ព័ន្ធជាប្រចាំ
២. ចូរប្រមូលយកប្រតិកម្មតបៈ នៅគ្រប់កម្រិតទាំងអស់ អ្នកពាក់ ព័ន្ធចង់បានការឆ្លើយតបណាស់ ប៉ុន្តែ ក្រុមកសាងផែនការមានការគ្រប់គ្រងពេញលេញនៃប្រធានបទនេះ ហើយអាចធ្វើអ្វីក៏ដោយឱ្យតែពេញចិត្តនូវចម្លើយឆ្លើយតប។
៣. ចូរពិគ្រោះយោបល់ជាមួយពួកគេៈនៅកម្រិតនេះ អ្នកពាក់ព័ន្ធគឺពាក់ព័ន្ធច្រើននៅថ្នាក់មូលដ្ឋាន។ ពួកគេជួយកំណត់សំនួរ កំណត់បញ្ហា ជួយបង្កើតចក្ខុវិស័យ និង កំណត់ចំណុច អាទិភាព។ នេះគឺជាកម្រិតដ៏មានន័យបំផុត នៃការចូលរួមគឺជាអំណាចខ្លាំងបំផុត ប៉ុន្តែមានតម្រូវការធនធាន និងពេលវេលាច្រើនបំផុត

## កិច្ចការទី២ -ការកំណត់អត្តសញ្ញាណកម្មនៃអ្នកពាក់ព័ន្ធ និងការបង្កើតទំនាក់ទំនង និងយុទ្ធសាស្ត្រពាក់ព័ន្ធ

**អ្នកពាក់ព័ន្ធចែកចេញជាច្រើនប្រភេទៈ**

- **អ្នកសម្រេចចិត្តសំខាន់ៗ រួមទាំងអ្នកហិរញ្ញវត្ថុ**, ដែលត្រូវកំណត់វិសាលភាព និង មាតិកានៃផែនការ ប្រហែលជាចង់ឱ្យមានឥទ្ធិពលក្នុងអំឡុងដំណើរការCSPនិងមានតួនាទីសំខាន់ក្នុងដំណើរការឯកភាពណាមួយនិងចាំបាច់ក្នុងការអនុវត្ត និងការតាមដានផលិតផលកសាងផែនការ។ នៅក្នុងក្រុមនេះអាចជាទីប្រឹក្សា សមាជិកក្រុមនាយកនិងអ្នកពិនិត្យឡើងវិញដែលនឹងមានឥទ្ធិពលច្រើនទៅលើអ្នកសម្រេចចិត្ត និងអ្នកផ្តល់ហិរញ្ញប្បទាន។ ផែនការបែងចែកតំបន់គឺជានិច្ចកាលជាឧបករណ៍មួយសម្រាប់គ្រប់គ្រងផលប្រយោជន៍ដែលមានជម្លោះ "សម្រាប់ទំនិញសាធារណៈ" ។ អ្នកសម្រេចចិត្តសំខាន់ៗជានិច្ចកាលជាតំណាងការិយាល័យរដ្ឋាភិបាល។ ទោះជាយ៉ាណាក៏ដោយអ្នកផ្តល់ហិរញ្ញប្បទានទាំងផែនការនិងការអនុវត្តមានប្រភពពីវិស័យសារធារណៈនិងវិស័យឯកជន។
- **អាជ្ញាធរសំខាន់ៗផ្សេងទៀតដែលមានអំណាចស្របច្បាប់** នៅក្នុងវិស័យ CSP ។ ក្រសួង និងមន្ទីរតាមវិស័យ

ច្រើនស្ថិត ក្នុងប្រភេទនេះ ដូចគ្នានឹងអាជ្ញាធរដែលមានឋានានុក្រមផ្សេងៗគ្នា — ដូចជាអភិបាល ខេត្ត ឬក្រុមប្រឹក្សាស្រុក។ សារៈសំខាន់នីមួយៗអាចខុសគ្នាអាស្រ័យលើលក្ខខណ្ឌ និងលក្ខណៈពិសេសនៃតំបន់។ ទោះជាយ៉ាងណាក៏ដោយពួកគេដើរតួរដ៏សំខាន់ក្នុងការចរចានូវតុល្យភាពនៃធាតុចូល និងលទ្ធផលតាមវិស័យ។ ពួកគេនឹងជាប្រភពផ្តល់ព័ត៌មានដ៏សំខាន់ផងដែរ។

- **ក្រុមទទួលផលប្រយោជន៍**ដែលអាចមានទំហំខុសៗគ្នា ធនធានហិរញ្ញវត្ថុ កម្រិត នៃផលចំណេញសេដ្ឋកិច្ចដែលជាលទ្ធផលនៃការកសាងផែនការ និងលទ្ធភាពដើម្បីបំពងសម្លេងរបស់គេឱ្យបានដឹងឮ។ ក្នុងប្រភេទនេះអាចមានក្រុមហ៊ុនមានអំណាចផ្នែកហិរញ្ញវត្ថុ និងអត្ថប្រយោជន៍ផ្នែកពាណិជ្ជកម្ម សមាគមន៍អ្នកនេសាទបែបសិប្បកម្ម ឬអង្គការមិនមែនរដ្ឋា-ភិបាល ផ្នែកបរិស្ថានដោយព្រួយបារម្ភអំពីការអភិរក្សប្រព័ន្ធអេកូស៊ីស្ទែមឬ ក្រុមសត្វ (ឧ.អ្នកមមើលសត្វបារម្ភពីការអភិរក្សជីវចម្រុះនៃរុក្ខជាតិ) ។អ្វីដែលមានលក្ខណៈរួមគ្នាចំពោះប្រភេទនេះគឺថាពួកគេមានផលប្រយោជន៍ជាក់លាក់នៃការធ្វើផែនការ និងមានជាទម្រង់ រឺជាអង្គការថាតើខ្លាំងឬខ្សោយ។
- "**សាធារណៈជនទូទៅ**" ដែលមានទំនោរទៅរកក្រុមអ្នកពាក់ព័ន្ធដែលមិនប្រាកដប្រជា ភាគច្រើនមិនបានរៀបចំទុកមុន យ៉ាងហោចណាស់ មុនពេលដំណើរការចាប់ផ្តើម។ អ្នកគាំទ្រផែនការ ជាញឹកញាប់ ចាត់ទុកនូវសំណើរបស់គេថាផ្តល់ផលប្រយោជន៍ដល់ក្រុមនេះហើយមានអ្នកទទួលផលជាច្រើនប្រហែលជាអាចស្ថិតក្នុងចំណោមពួកគេ។ អ្នកទាំងឡាយដែលបាត់បង់ដោយសារមកពីហេតុផលនៃផែនការនេះនឹងស្ថិតនៅក្នុងក្រុមនេះដែរ។ អ្នកក្រតាមបែបសង្គមជនជាតិភាគតិចជាលក្ខណៈរូបវន្តដែលគ្មានគុណសម្បត្តិ ដែលមិនបានរៀបចំ និង តាមធម្មតាមិនអាចធ្វើឱ្យការព្រួយបារម្ភរបស់គេបានផ្សព្វផ្សាយក៏ស្ថិតក្នុងក្រុមនេះដែរ។ នេះជាក្រុមដែលគួរយកចិត្តទុកដាក់ទៅលើ "ចីរភាពសង្គម," ការកាត់បន្ថយភាពក្រីក្រ និងភាពងាយរងគ្រោះ ការកើនឡើងនូវភាពធន់ក្នុងការប្រឈមនឹងគ្រោះថ្នាក់ និងការរន្ធត់ដោយធម្មជាតិសង្គម និងសេដ្ឋកិច្ច។ ប៉ុន្តែនេះជាក្រុមដែលពិបាកបំផុតក្នុងការចូលរួមប្រសិន បើគ្មានកិច្ចខិតខំប្រឹងប្រែងពេលវេលា និងវិធីដោះស្រាយពិសេសនោះទេ។

**អំណាចអ្នកពាក់ព័ន្ធ ភាពស្របច្បាប់ និងភាពបន្ទាន់**

មានឧបករណ៍វិភាគមួយចំនួនលើទស្សនៈទាន ដែលអ្នកពាក់ព័ន្ធ ផ្លាស់ប្តូរ "អំណាច" (មានឥទ្ធិពល និងការផ្តល់សិទ្ធិ), "ភាពស្រសច្បាប់" (សិទ្ធិ) និង"ភាពបន្ទាន់" ('ការគាបសង្កត់លើការបញ្ចេញយោបល់ដោយឥតសំចៃកល្បិចអន្ទង) ឧទាហរណ៍ អ្នកធ្វើការសម្រេចចិត្តជាមួយនឹងអាជ្ញាធរស្របច្បាប់(អំណាច)លើដំណើរការកសាងផែនការមិន រស់នៅក្នុងតំបន់នឹងមិនបានរងផលប៉ះពាល់ដោយផ្ទាល់លើការសម្រេចចិត្ត។ នៅពេលដំណាលគ្នានេះ ពួកគេមានសិទ្ធិស្របច្បាប់ (ភាពស្របច្បាស់)ដើម្បីធ្វើសេចក្តីសម្រេចចិត្ត។ ភ្នាក់ងារដ៏ទៃទៀត ដូចជាសាជីវកម្មអន្តរជាតិចង់ទទួលបានសិទ្ធិប្រើប្រាស់មាត់សមុទ្រភាគច្រើនអ្នកមានអំណាច (សិទ្ធិផ្នែកហិរញ្ញវត្ថុ) និងប្រើប្រាស់ទម្រង់សម្ពាធជាច្រើន (ភាពបន្ទាន់)ដើម្បីទទួលបានមធ្យោបាយរបស់ពួកគេ ប៉ុន្តែពួកគេខ្វះភាពស្របច្បាប់ដោយសារពួកគេគ្មានសិទ្ធិនៅក្នុងតំបន់។ សហគមន៍នេសាទ ភាពក្រីក្រអាចមានសិទ្ធិស្របច្បាប់ (សិទ្ធិរយៈពេលវែងដើម្បីរស់នៅ និងការប្រើប្រាស់ធនធាន) ជាញឹកញាប់ខ្វះអំណាច(ពួកគេមិនត្រូវបានរាប់បញ្ចូលពីដំណើរការសម្រេចចិត្ត)និងភាពអោនលំទោន (ពួកគេមិនអាចលើកសំឡេងរបស់គេ) ។

នៅក្នុង CSP អង្គការវិស័យសាធារណៈនឹងជាអ្នកពាក់ព័ន្ធដ៏មានសារៈសំខាន់ និងសកម្ម ហើយវាចាំបាច់ត្រូវធ្វើការវិភាគស្ថាប័នទាំងនេះ។ ភ្នាក់ងារនីមួយៗកំណត់ការទទួលខុសត្រូវសំខាន់របស់ខ្លួនក្នុងតំបន់ឆ្នេរ `អតិថិតា-Clientele´ របស់វា (អ្នកទាំងនោះដែលវាផ្តល់សេវាឱ្យ) ភ្នាក់ងារផ្សេងៗទៀតឬក្រុមដែលពួកគេពឹងពាក់លើព័ត៌មាន ឬសេវាផ្សេងទៀត។ ចូរវាយតម្លៃសារៈសំខាន់ដោយផ្ទាល់ចំពោះការអនុវត្ត CSP ជាពិសេស:

- ប្រភពនៃព័ត៌មានមូលដ្ឋាន
- ដៃគូពិភាក្សា
- ប្រភពជំនាញបច្ចេកទេស និងវិជ្ជាជីវៈសម្រាប់ការប្រមូលទិន្នន័យ ការស្រាវជ្រាវ ការវិភាគ ការការពារ និងការព្យាករណ៍ស្ថានភាពអនាគត – ឧទាហរណ៍អ្នកចូលរួមចំណែកដោយផ្ទាល់ដល់ផែនការ
- អ្នកអនុវត្ត និងអ្នកជម្រុញឱ្យមានការផ្លាស់ប្តូរ
- ប្រភពថវិកា ឬ ប្រភពផ្សេងៗទៀតទាំងសម្រាប់ការកសាងផែនការ និងការអនុវត្ត និង/ឬ
- អ្នកត្រួតពិនិត្យគុណភាព ដោយរួមទាំងការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្ត និងសកម្មភាពបន្ទាប់។

ការវាយតម្លៃនេះនឹងនាំទៅរកការសម្រេចចិត្តថាតើនៅពេលណាហើយភ្នាក់ងារនីមួយៗគួររាប់បញ្ចូល។វាផ្តល់នូវមូលដ្ឋានសម្រាប់បង្កើតទំនាក់ទំនងដំបូងជាមួយពួកគេ។ ប្រភេទនៃការវិភាគផ្សេងទៀតដែលអាចធ្វើបានដោយ

មានការចូលរួមយ៉ាងទូលំទូលាយពីអ្នកពាក់ព័ន្ធគឺ"ការវិភាគវិស័យកម្លាំង"។ ការកសាងផែនការមានន័យថាជាការនាំមកនូវការត្រួតត្រា និងបញ្ហាទៅរកស្ថានភាពមួយ និង ទៅរកអនាគត។ វាបញ្ជាក់ពីការប្រែប្រួល ជូនកាលជាការប្រែប្រួលដ៏ខ្លាំងក្លា។ មានគោលបំណងរួមមួយនៃការកសាងផែនការដើម្បី សម្រេចបាននូវស្ថានភាពមួយ"សម្រាប់សាធារណៈជន"។ ប្រការនេះមានន័យថាបុគ្គលនីមយៗ ក្រុម ឬ អង្គការប្រឈមនឹងការបាត់បង់ ឬមានជំនឿថាពួកគេនឹងបាត់បង់ដំណើរការកសាងផែនការ។ ពួកគេអាចបាត់បង់ផលប្រយោជន៍ ដែលមានស្រាប់ បើមិនដូច្នោះទេ ពួកគេអាចមានជំនឿថាពួកគេនឹងបាត់បង់ផលប្រយោជន៍ដ៏មានសក្តានុពល – ជាក់ស្តែងបំណងប្រាថ្នារបស់គេនឹងមិនបានសម្រេចនោះទេ។ កន្លែងដែលគេទទួលស្គាល់ថាមានបញ្ហាចំរូងចម្រាសជាច្រើនដែលត្រូវដោះស្រាយមានឱកាសច្រើនគួរសមដែលថានឹងមានទស្សនៈប្រឆាំងងជាច្រើននោះ។ ការវិភាគផ្នែកកម្លាំងវិស័យមានប្រយោជន៍ក្នុងការកំណត់អង្គការទាំងនោះ ជាលក្ខណៈបុគ្គល ឬក្រុមការងារសង្គមដែលគាំទ្រ ឬជំទាស់នឹងប្រភេទនៃការត្រួត ពិនិត្យ រឺការផ្លាស់ប្តូរជាក់លាក់នោះ។ បន្ទាប់ពីមានគំនិតល្អតាំងពីការចាប់ផ្តើមមកជួយក្នុងការចាត់ចែងតាមមធ្យោបាយសមហេតុផលនៃការទំនាក់ទំនងទៅកាន់ក្រុមនីមួយៗ ដោយដោះស្រាយនូវការបារម្ភរបស់គេឬ ការប្រមូលផ្តុំការគាំទ្ររបស់គេ។ សារដែលបានផ្តល់ឱ្យមានភាពស្របគ្នា – ប៉ុន្តែថាតើវាអាចធ្វើការទំនាក់ទំនង និង ពិភាក្សារបៀបណានោះប្រហែលជាខុសៗគ្នាដោយកែតម្រូវតាមប្រភេទនៃការឆ្លើយតបដែលបានរំពឹងទុក។

ក្រុមការងារ CSP ត្រូវតែមានទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធទាំងអស់នេះ។ ដើម្បីធ្វើការងារនេះប្រកបដោយប្រសិទ្ធភាពនោះ ចាំបាច់ត្រូវបង្កើតយុទ្ធសាស្រ្តទំនាក់ទំនង និងចូលរួម។ ទំនាក់ទំនងមានពីររបៀបហើយម៉្យាងទៀតយុទ្ធសាស្រ្តទំនាក់ទំនង ត្រូវតែរួមបញ្ចូលនូវយន្តការសម្រាប់ស្តាប់ទៅអ្នកពាក់ព័ន្ធសម្រាប់ប្រមូលទស្សនៈរបស់គេ ទិន្នន័យព័ត៌មាន ក្តីកង្វល់ របស់គេ ការសុបិន្ត និងសេចក្តីប្រាថ្នា ព្រមទាំងគំនិតរបស់គេ។ ការទំនាក់ទំនងគឺមិនគ្រាន់តែជាបញ្ហានៃការប្រាប់ពួកគេនៅអ្វីដែលអ្នកកសាងផែនការបានធ្វើនោះទេ។ កម្រិតផែនការនឹងធ្វើឱ្យប៉ះពាល់ដល់ទំនាក់ទំនង និងយុទ្ធសាស្រ្តពាក់ព័ន្ធសម្រាប់រយៈពេលកសាងផែនការ ដូចគ្នានឹងពេលវេលា និងធនធានហិរញ្ញវត្ថុដែរ។ តាមលក្ខណៈធម្មជាតិមានមនុស្សជាច្រើនដែលរស់នៅក្នុងតំបន់នេះនឹងជាកត្តាបន្ថែមមួយ។ ទោះជាយ៉ាងណាក៏ដោយ វាមានប្រសិទ្ធភាពក្នុងការចំណាយច្រើនបំផុតក្នុងរយៈពេលវែង ដើម្បីបង្កើតប្រព័ន្ធនៃទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធ ដែលនៅមានសូម្បីបន្ទាប់ពីផែនការត្រូវបានអនុម័ត វាចាំបាច់ត្រូវតែត្រួតពិនិត្យនៅចុងបញ្ចប់ វាចាំបាច់ត្រូវការត្រួតពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្ម។ ចូរបង្កើតប្រព័ន្ធទំនាក់ទំនងដែលមានចីរភាព និងការរីកហាត់នៅពេលអនាគតនឹងបង្ហាញនូវភាពកាន់តែងាយស្រួលដើម្បីរៀបចំ។ តាមបទពិសោធន៍បង្ហាញនូវចំណុចផែនការកាន់តែលំអិត និង មានលក្ខណៈផ្តោតលើមូលដ្ឋានផលប្រយោជន៍កាន់តែសំខាន់ដែលវាបង្កើតឡើងក្នុងចំណោមការបែងចែកអ្នកពាក់ព័ន្ធសាធារណៈទូទៅដែលមិនប្រាកដ

ប្រជា។ ផែនការទ្រង់ទ្រាយតូច និងមានលក្ខណៈទូទៅមានការលំបាកកាន់តែច្រើនដើម្បីផ្សាភ្ជាប់ទៅកាន់គ្រួសារនីមយៗ អ្នកដែលមិនអាចប្រមើលមើលនូវ ផលប៉ះពាល់ជាក់លាក់ដែលផែនការ នេះប្រហែលជាមានទៅលើការរស់នៅរបស់ពួកគេ។ ព័ត៌មានបន្ថែមស្តីពីការវិភាគ និងការធ្វើការជាមួយអ្នក ពាក់ព័ន្ធអាចរកឃើញ ក្នុងឧបសម្ព័ន្ធ ៣ និងនៅតាមគេហទំព័រដូចមានខាងក្រោមៈ

www.gtz.de/de/dokumente/en-SVMP-Instrumente-Akteuersanalyse.pdf

www.change-management-toolbook.com/mod/book/view.php?id=74&chapterid=68

បញ្ហាពាក់ព័ន្ធមួយចំនួននៃការអនុវត្តវិធីសាស្ត្រផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែម (EBA) សង្កត់ធ្ងន់លើបញ្ហាខាងក្រោមទាក់ទងនឹងការកំណត់អត្តសញ្ញាណ និងការវិភាគអ្នកពាក់ព័ន្ធៈ

សមាសភាពនៃប្រព័ន្ធនេះ ជាពិសេសប្រព័ន្ធអេកូស៊ីស្ទែមធម្មជាតិ និងជីវសាស្ត្រមិនអាចនិយាយដោយខ្លួនឯងបានទេ ហេតុនេះចាំបាច់ត្រូវកំណត់នូវអត្តសញ្ញាណបុគ្គល និងក្រុមទាំងនោះ ដែលអាចនិយាយឱ្យពួកគេបាន។ អ្នកទាំងនេះអាចជា អង្គការមិនមែនរដ្ឋាភិបាល/សង្គមស៊ីវិលផ្អែកបរិស្ថាន អ្នកបរិស្ថានវិទ្យាមេព្រៃ/អ្នកជំនាញជលផល ជីវវិទូសមុទ្រ ឬអ្នកឯកទេសបរិស្ថានផ្សេងៗទៀត មកពីពិភពវិទ្យាស្ថានអប់រំ ដែលមានចំណេះដឹងផ្អែកអេកូឡូស៊ីមូលដ្ឋានច្បាស់លាស់។

ទំនាក់ទំនងរវាងសមាសភាពប្រព័ន្ធខុសៗគ្នានេះ – ដោយរួមមានទិដ្ឋភាពនៃការគ្រប់គ្រងធនធាន ការប្រើប្រាស់ ធនធាន ការវាយតម្លៃវប្បធម៌ និងសេដ្ឋកិច្ចតម្រូវការប្រកួតប្រជែង – គួរជាផ្អែកមួយក្នុងការវិភាគនេះ។ កន្លែងណាដែលអាចធ្វើទៅបានទំនាក់ទំនងនេះគួរតែកំណត់ចំនួន ឬចាត់ចំណាត់ថ្នាក់តាមការចាំបាច់នៅពេលដែលបញ្ហា ទាំងអស់នេះមានសារៈសំខាន់ក្នុងការវាយតម្លៃយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍអនាគត។ ការដឹងអំពីផលប៉ះពាល់ត្រឡប់វិញនៃការសម្រេចចិត្តនីមួយៗធ្វើឡើងដោយវិទ្យាស្ថានឬអ្នកប្រើប្រាស់ជាក់លាក់នឹងមានសារៈសំខាន់ក្នុងការបង្កើតការវាយតម្លៃផលប៉ះពាល់ជាយុទ្ធសាស្ត្រ។

## បញ្ហាពាក់ព័ន្ធនឹងផែនការសមុទ្រ និងដីគោកចម្រុះ

ចំពោះការកសាងផែនការដីគោកនិងមុទ្រចម្រុះមានសារៈសំខាន់ណាស់សម្រាប់ធានាថា អ្នកពាក់ព័ន្ធទាំងអស់ តំណាងឱ្យតំបន់សមុទ្រត្រូវបានកំណត់អត្តសញ្ញាណ និងអញ្ជើញឱ្យចូលរួម។ ពួកគេគួរតែវិភាគតាមមធ្យោបាយដូចគ្នាទៅនឹងដីគោកដែរ។ អ្នកពាក់ព័ន្ធទាំងអស់នេះរួមមាន អាជ្ញាធរជលផល អាជ្ញាធរទាក់ទងនឹងការរុករក និងការធ្វើអាជីវកម្មរ៉ែ ប្រេង និងឧស្ម័ន (ក្រុមហ៊ុន) ឆ្នាំសមុទ្រ អាជ្ញាធរកំពង់ផែ និងនាវាចរណ៍។ ការធ្វើទំនាក់ទំនងក្នុង

ចំណោមពួកគេ និងអាជ្ញាធរដែនដីគោកគួរត្រូវបានវិភាគដើម្បីស្វែងរកចំណុចប្រសព្វរួមគ្នាផលប្រយោជន៍រួមគ្នា និងសមាហរណកម្មរួមគ្នាឬកំណត់នូវចំណុចប្រកួតប្រជែង និងជម្លោះផលប្រយោជន៍។

## បញ្ហាពាក់ព័ន្ធនឹងការរួមបញ្ចូលនូវការកាត់បន្ថយហានិភ័យ និងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ

បញ្ហាពាក់ព័ន្ធសំខាន់បំផុតគឺថាអ្នកពាក់ព័ន្ធសមស្រប ដែលទទួលខុសត្រូវចំពោះការគ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់ និងការឆ្លើយតបនឹងគ្រោះបន្ទាន់នឹងត្រូវនាំយកមកជាមួយ។ ពួកគេអាចទទួលបានព័ត៌មានដ៏មានតម្លៃទាក់ទងនឹងកន្លែងដែលមានគ្រោះមហន្តរាយផ្សេងៗកើតឡើង ព្រមទាំងកន្លែងដែលមានការគំរាមកំហែង។ ពួកគេនឹងដឹងពីប្រភេទនិងទីតាំងនៃជំរុំជ្រកកោនជនភៀសខ្លួន និងមានព័ត៌មានសំខាន់ៗទាក់ទងនឹងការចេញចូលទៅដល់ និងការជម្លៀស។ ពួកគេផ្តល់នូវគំនិត និងចំណេះដឹងមិនអាចកាត់ថ្លៃបានស្តីពីការកាត់បន្ថយហានិភ័យ និង ជាពិសេសពីរបៀបថាតើការកសាងផែនការបែងចែកការប្រើប្រាស់តំបន់ឆ្នេរអាចប្រើប្រាស់ដើម្បីកាត់បន្ថយផលប៉ះពាល់នៃប្រភេទគ្រោះមហន្តរាយជាក់លាក់ដោយរបៀបណា។ ពួកគេនឹងអាចផ្តល់ដំបូន្មានពីលក្ខខណ្ឌការអភិវឌ្ឍជាក់លាក់ដែលអាចប្រើប្រាស់ចំពោះតំបន់ប្រើប្រាស់ដីធ្លីដើម្បីពង្រួមឬកាត់បន្ថយការខូចខាតទ្រព្យ សម្បត្តិ និងការបាត់បង់អាយុជីវិតដោយសារមុខសញ្ញាគ្រោះថ្នាក់ជាក់លាក់នោះ។

## កិច្ចការទី៣ - ការរៀបចំការងារ និង កំណត់នូវជំនាញត្រូវការ

មានលទ្ធភាពច្រើនសម្រាប់រៀបចំការអនុវត្ត CSP ហើយចំពោះប្រភេទផែនការនីមួយជំនាញដែលត្រូវការដូចៗគ្នាដើម្បីទទួលបានគុណភាពទិន្នផលដូចគ្នា។ ទោះជាយ៉ាងណាក៏ដោយជម្រើសជាមូលដ្ឋានបានគូសបញ្ជាក់នៅក្នុងតារាងខាងក្រោមដែលបង្ហាញនូវជំនាញដែលអាចផ្តល់ឱ្យតាមរបៀបផ្សេងៗគ្នា។ជម្រើសទាំងនេះផ្តល់នូវឱកាសផ្សេងៗសម្រាប់ការទទួលបានគំនិតយោបល់ថ្មីៗក្នុងវិស័យនេះគឺវិធីសាស្ត្រ និងយុទ្ធសាស្ត្រថ្មីៗបំផុត។ ការដាក់លក្ខខណ្ឌជាមុនសម្រាប់ការជ្រើសរើសនីមួយៗអាចកំណត់ថាមួយណាអាចមានសម្រាប់លោកអ្នក។

| **ជម្រើសសម្រាប់រៀបចំការងារ** CSP | | | |
|---|---|---|---|
| **ការពិពណ៌នា** | **បញ្ហាពាក់ព័ន្ធ និង ការដាក់លក្ខខណ្ឌជាមុន** | **គុណសម្បត្តិ** | **គុណវិបត្តិ** |
| ចូរធ្វើការងារ CSP ក្នុងក្រុម ដោយធាតុចូល ស្នើសុំពីអាជ្ញាធរដៃគូ | - តម្រូវការក្រុមធ្វើការពេញម៉ោង ដោយមានជំនាញ  ទូលំទូលាយ<br>- តម្រូវការ ឧបករណ៍ជាច្រើនដើម្បីធ្វើការនៅមូលដ្ឋាន និង ការវិភាគ<br>- ភាគច្រើនត្រូវការអនុស្សារណៈយោគយល់ ជាមួយអាជ្ញាធរផ្សេង ដើម្បីទទួលបានធាតុចូលរបស់គេ ។ ការងារនេះត្រូវការពេល វេលា ។ | - ធ្វើការត្រួតពិនិត្យគ្រប់ផ្នែកទាំងអស់ដែលធ្វើដោយអាជ្ញាធរ<br>- មិនចាំបាច់មានការគ្រប់គ្រងកិច្ចសន្យាពិសេស ឬ ជំនាញត្រួតពិនិត្យ ទីប្រឹក្សានោះទេ | - ការត្រួតត្រា នៅមានកម្រិត និងមានលក្ខខណ្ឌ ចំពោះធាតុចូលទទួលបានពីអាជ្ញាធរផ្សេងៗ<br>- មិនចាំបាច់ទំនាក់ទំនងជាមួយអ្នកឯកទេសសំខាន់ៗ  ឬឧបករណ៍ពិសេសនោះទេ ដាក់បន្ទុកពេញទំហឹងនូវការងារប្រចាំថ្ងៃលើអាជ្ញាធរ ជាមួយគ្នានោះដែរមិនអនុញ្ញាតមានការគ្រប់គ្រងគុណភាពពេញលេញនោះទេ |
| ចុះកិច្ចសន្យាឱ្យអនុវត្ត CSP ទាំងមូលទៅក្រុមហ៊ុនទីប្រឹក្សា | - អាជ្ញាធរកសាងផែនការមាន សមត្ថភាពផ្នែកច្បាប់ (គ្រប់គ្រងកិច្ចសន្យា)  និងការគ្រប់គ្រង<br>- មានថវិកាគ្រប់គ្រាន់<br>- មានការយល់ដឹងច្បាស់លាស់នូវអ្វីដែលចង់បាន និងដំណើរការ ដើម្បីសម្រេចបាន–ដើម្បីរៀបចំលក្ខខណ្ឌការងារ | - ប្រមូលយកគំនិតនវានុវត្តន៍លើអភិក្រម និងវិធីសាស្ត្រតាមដំណើរការដេញថ្លៃ ។ ប្រការនេះអាចផ្តល់នូវមូលដ្ឋានសម្រាប់ការសិក្សាបន្តបន្ទាប់នៅក្នុងអាជ្ញាធរកសាងផែនការ<br>- ទទួលបានជំនាញប្រើប្រាស់ដែលអាជ្ញាធរកសាងផែនការមិនមាន ។ | - អាចមានការពិបាកដើម្បីបញ្ចូលនូវភាពបត់បែនទៅក្នុងលក្ខខណ្ឌការងារនិងកិច្ចសន្យាដើម្បីឱ្យមានការផ្លាស់ប្តូរប្រកបដោយដំបូន្មានដែលមានប្រភពចេញពីលទ្ធផលរកឃើញអំឡុងការធ្វើការងារ<br>- ក្រុមហ៊ុនទីប្រឹក្សាប្រហែលជាមិនមានកម្រិត ជឿជាក់ដូចគ្នា ជាមួយនឹងអាជ្ញាធរ ឬ អ្នកពាក់ព័ន្ធផ្សេងទៀត និង ត្រូវការការគាំទ្រ |

| ជម្រើសសម្រាប់រៀបចំការងារ CSP | | | |
|---|---|---|---|
| **ការពិពណ៌នា** | **បញ្ហាពាក់ព័ន្ធ និង ការដាក់លក្ខខណ្ឌជាមុន** | **គុណសម្បត្តិ** | **គុណវិបត្តិ** |
| | - ប្រហែលជាតម្រូវការដំណើរការដេញថ្លៃប្រកួតប្រជែងមួយ<br>- តម្រូវការវិធានការបើកទ្វារ (door-opening) ដើម្បីសម្រួលការងារជាមួយអាជ្ញាធរវិស័យឯកជនផ្សេងៗទៀត ។<br>- ទទួលបានលទ្ធផលល្អ បំផុត ប្រសិនបើអាជ្ញាធរនេះបានរៀបចំរចនាសម្ព័ន្ធដើម្បីប្រើប្រាស់វិធីសាស្ត្រនេះជាប្រចាំ (ដូចនេះ បង្កើតនូវជំនាញ និងសមត្ថភាពត្រឹមត្រូវ) ។<br>- ឧបមាជាមុនថាមានអង្គការ/ក្រុមហ៊ុនជាច្រើនដែលអាចធ្វើការងារនេះបាន | - ទទួលបានឧបករណ៍ឯកទេសដែលអាជ្ញាធរមិនមាន<br>- ដាក់បន្ទុកការងារនៅខាងក្រៅអាជ្ញាធរ ដោយរួមទាំងភស្តុភា និង ព័ត៌មានលំអិតរដ្ឋបាល ច្រើនទៀត<br>- នៅតែរក្សាការគ្រប់គ្រងរបស់អាជ្ញាធរទៅលើគុណភាពនៃលទ្ធផល<br>- អភិក្រមដ៏មានប្រសិទ្ធភាពប្រសិនបើអាជ្ញាធរកសាងផែនការបានរៀបចំរចនាសម្ព័ន្ធ ដើម្បីប្រើប្រាស់វាតាមធម្មនិយម ដូចការអនុវត្តការកសាងផែការជាច្រើនទៀតអាចចាត់ចែងបានដំណាលគ្នា | (បើកទ្វារចំហ).<br>- ដំណើរការដេញថ្លៃ និងការចរចាជាបន្តបន្ទាប់អាចចំណាយពេលវេលាច្រើន ។<br>ជានិច្ចកាលមិននាំឱ្យទទួលបានលទ្ធផលគួរជាទីគាប់ចិត្តនោះទេ<br>- ប្រសិនបើហិរញ្ញវត្ថុអន្តរជាតិត្រូវបានប្រើសម្រាប់ផ្តល់មូលនិធិអនុវត្តការងារនេះ អ្នកផ្តល់ហិរញ្ញវត្ថុ ប្រហែលជាដាក់លក្ខខណ្ឌ និងតម្រូវឱ្យមានការឯកភាពលើលក្ខខណ្ឌការងារ កិច្ចសន្យា និងការជ្រើសរើស ។ |
| រក្សានូវក្រុមការងារ CSP ស្នូល | - តម្រូវការក្រុមការងារជិតពេញម៉ោងដោយមានជំនាញល្មម ។ | - អនុញ្ញាតឱ្យត្រួតពិនិត្យជាក់ស្តែងលើដំណើរការរៀបចំការងារ និងធាតុចូល | - ធ្វើឱ្យបន្ទុកការងារគ្រប់គ្រងប្រចាំថ្ងៃ នូវដំណើរការកសាងផែនការអង្គការនៅក្នុងអង្គការនេះកាន់តែ |

| ជម្រើសសម្រាប់រៀបចំការងារ CSP | | | |
|---|---|---|---|
| **ការពិពណ៌នា** | **បញ្ហាពាក់ព័ន្ធ និង ការដាក់លក្ខខណ្ឌជាមុន** | **គុណសម្បត្តិ** | **គុណវិបត្តិ** |
| និង ចុះកិច្ចសន្យា អនុវត្តន៍ការងារ ជាពិសេសដែលអាជ្ញាធរ មិនមានសមត្ថភាពផ្តល់ឱ្យ | ដោយផ្អែកលើអ្វីដែលបានចុះកិច្ចសន្យានោះ និង ទាមទាឱ្យមាន ឧបករណ៍<br>- តម្រូវការជំនាញសរសេរលក្ខខណ្ឌការងារ និង កិច្ចសន្យាសម្រាប់សមាសភាពទាំងឡាយណាដែលអាជ្ញាធរមិនអាចធ្វើខ្លួនឯងបាន<br>- តម្រូវការសមត្ថភាពគ្រប់គ្រងកិច្ចសន្យា និង ជំនាញត្រួតពិនិត្យការងារទីប្រឹក្សា<br>- តម្រូវការថវិកា សម្រាប់ធាតុចូលខាងក្រៅត្រូវតែមានសក្តានុពលសម្រាប់ការផ្លាស់ប្តូរការបែងចែកថវិកាមិនទាន់បានប្រើទូទាំងឆ្នាំហិរញ្ញវត្ថុ<br>- ចូរសន្មតថាជំនាញខាងក្រៅចាំបាច់គឺអាចរកបាន និង អាចប្រើប្រាស់បាន | - អាចឱ្យប្រើប្រាស់បាននូវធាតុចូលពីប្រភពខាងក្រៅក្រោមលក្ខខណ្ឌត្រួតពិនិត្យរួមមានទាំងបុគ្គលិក និង បរិក្ខា ។<br>- អនុញ្ញាតឱ្យមាននវានុវត្តន៍មួយចំនួនក្នុងផ្នែកមួយចំនួននៃ ការងារដែលត្រូវចុះកិច្ចសន្យាក្រោមការដេញថ្លៃ ។ នវានវត្តន៍នេះផ្តល់នូវលទ្ធភាពសម្រាប់ការរៀនសូត្រដោយក្រុមការងារស្នូល ។ | មានភាពបត់បែនតិចទៅក្នុងការប្រើប្រាស់បុគ្គលិកឱ្យធ្វើការហ្វឹកហាត់នោះដោយផ្អែកលើបទបញ្ញត្តិទាំងនោះ ប្រហែលជាតម្រូវឱ្យមាននិតិវិធីដេញថ្លៃសម្រាប់ទទួលបានការហ្វឹកហាត់ខាងក្រៅ ។ ជាថ្នូរមកវិញប្រការនេះនឹងមានកាបញ្ជាក់ពីពេលវេលាដែលបានគិតទុកជាមុនដើម្បីជៀសវាងការពន្យាពេលមិនចាំបាច់ដល់គម្រោងទាំងមូល ។ |

SCP ចម្រុះដែលគាំទ្រការអភិវឌ្ឍប្រកបដោយចីរភាពត្រូវការជំនាញច្រើនប្រភេទដែលឆ្លុះបញ្ចាំងនូវតួនាទី និងការទទួលខុសត្រូវផ្សេងៗក្នុងដំណើរការនេះ។ តាមធម្មតា បុគ្គលជាច្រើនត្រូវតែធ្វើការងាររួមគ្នាជា ក្រុមស្នូលមួយ ដែលមានធាតុចូល បច្ចេកទេស និងវិជ្ជាជីវៈបន្ថែមដែលនាំមកជាមួយតាមការចាំបាច់:

- ជំនាញសម្របសម្រួលជាចំណុចសំខាន់នៃការជំរុញ និងគ្រប់គ្រងដំណើរការនេះ។ ចូរចងចាំថា CSP គឺជា <u>**ដំណើរការមួយ**</u> ហើយវាជាដំណើរការមួយដែលជាប់ពាក់ព័ន្ធនឹងកត្តាជាច្រើន។ ព្រោះហេតុដូចនេះ "បំណិនទន់ -Soft skill" នៃការធ្វើការងារជាមួយមនុស្សការសម្របសម្រួល និងការគ្រប់គ្រងដំណើរការស្មុគ្រស្មាញមួយមានសារៈសំខាន់ណាស់។ វាមានគុណសម្បត្តិ បន្ថែមទៀតប្រសិនបើ (អ្នកសម្របសម្រួលនេះ) មានសមត្ថភាពខាង CSP និងអាចធ្វើទំនាក់ទំនងយ៉ាងល្អគ្រប់វិស័យទាំងអស់។ ទោះជាយ៉ាងណាក៏ដោយ វាមិនចាំបាច់ដែលថាអ្នកសម្របសម្រួលគឺជាអ្នកធ្វើផែនការនោះទេ គាត់គួរជាអ្នកវិទ្យាសាស្ត្រធម្មជាតិ អ្នកអេកូឡូស៊ីវិទ្យា អ្នកភូមិសាស្ត្រ ឬអ្នកគ្រប់គ្រងម្នាក់។
- សមត្ថភាពខាង CSP ត្រូវតែស្ថិតនៅក្នុងក្រុមស្នូលផងដែរ។ ការមានចំណេះដឹងល្អអំពីភូមិសាស្ត្រ និងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ គឺសំខាន់ណាស់ ហើយជំនាញខាងគូផែនទីក៏ដូចគ្នាដែរ។ សមត្ថភាពកសាងផែនការនេះគួតែរាប់បញ្ចូល ទាំងចំណេះដឹងល្អៗផ្នែកគោលនយោបាយ ច្បាប់ និងនិយ័តកម្ម កសាងផែនការជាតិ ព្រមទាំងដំណើរការកសាងផែនការពិគ្រោះយោបល់ ដែលអាចទទួលយកបាន។
- ជំនាញសេដ្ឋកិច្ចសង្គមនឹងត្រូវការសម្រាប់សមាសភាពកសាងផែនការជាច្រើនគឺការសិក្សាផ្នែកប្រជាសាស្ត្រ ប្រហែលអាចតម្រូវឱ្យមានធាតុចូលនៃអ្នកឯកទេស ប៉ុន្តែលទ្ធផល នៃការសិក្សាផ្នែកប្រជាសាស្ត្រ និងការព្យាករណ៍ត្រូវការការបកស្រាយផ្នែកសេដ្ឋកិច្ច សង្គម គោលដៅសេដ្ឋកិច្ចសង្គមដែលចាំបាច់ត្រូវកែប្រែឱ្យទៅជាវិធានការជាក់លាក់ដែលបន្តដោយឧបករណ៍ សេដ្ឋកិច្ចសង្គមសមស្រប និងសេណារីយោអភិវឌ្ឍន៍អនាគតត្រូវតែបបង្កើតឡើង និង វាយតម្លៃពីទស្សនៈសេដ្ឋកិច្ចសង្គម។
- ប្រសិនបើវិធីសាស្ត្រផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមត្រូវសម្របតាមយ៉ាងម៉ត់ចត់នោះអ្នកអេកូឡូស៊ី អ្នកបរិស្ថាន និង ជំនាញខាងធនធានធម្មជាតិនឹងមានការចាំបាច់សម្រាប់ការវិភាគស្ថានភាពបច្ចុប្បន្នសម្រាប់ការស្នើសុំជម្រើសអនាគតដែលអាចមាន (តាមទិដ្ឋភាពបរិស្ថាន) និងសម្រាប់វាយតម្លៃសេណារីយោស្នើឡើងដោយក្រុម ការងារ ឬក្រុមអ្នកពាក់ព័ន្ធ។
- ជំនាញខាងការសម្របសម្រួល និងទំនាក់ទំនងមានការចាំបាច់ ជាពិសេសសម្រាប់ ការធ្វើការរួមគ្នាជាមួយអ្នកពាក់ព័ន្ធ និងសាធារណៈជនទូទៅ។
- ផ្អែកតាមកត្តាជម្រុញជាក់លាក់ និង គោលបំណងនៃការអនុវត្ត CSPពិសេស និង ចរិតលក្ខណៈនៃតំបន់ដែល

ត្រូវធ្វើផែនការនោះជំនាញផ្សេងៗទៀតនឹងតម្រូវឱ្យមានកម្រិតខុសៗគ្នានៅក្នុងវិស័យដូចខាងក្រោមៈ

- ភូគព្ភសាស្ត្រ និង ភូមិសណ្ឋានវិទ្យាតំបន់ឆ្នេរ
- វិស្វកម្មតំបន់ឆ្នេរ
- ជីវសាស្ត្រសមុទ្រ – អាចជាអ្នកឯកទេសផ្នែកផ្កាថ្ម ព្រៃកោងកាង ប្រព័ន្ធអេកូស៊ីស្ទែមផ្សេងទៀត
- ជលសាស្ត្រ
- វិស្វកម្មស៊ីវិលផ្នែកផ្គត់ផ្គង់ទឹក ការគ្រប់គ្រងសំណល់ ថាមពល ការដឹកជញ្ជូន (ផ្លូវថ្នល់ ផ្លូវរភ្លើង កំពង់ចម្លង និង កំពុងផែ) ទូរគមនាគមន៏
- ការគ្រប់គ្រងហានិភ័យសំដៅលើមុខសញ្ញាគ្រោះថ្នាក់ និងហានិភ័យបណ្តាលពីកត្តាធម្មជាតិ និង កត្តាមនុស្ស
- សង្គមវិទ្យាដោយផ្តោតលើបញ្ហាសង្គម និងវប្បធម៌ រចនាសម្ព័ន្ធសង្គម លក្ខណៈជីវភាពរស់នៅ ប្រពៃណីនិងតម្លៃមូលដ្ឋានជាពិសេសដោយសារតែបញ្ហាទាំងនេះទាក់ទងនឹងអន្តរកម្មជាមួយ ពិភពធម្មជាតិ ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងសម្ពាធអភិវឌ្ឍន៍ផ្សេងៗទៀត។

## បញ្ហាពាក់ព័ន្ធមួយចំនួននៃការអនុវត្តវិធីសាស្ត្រផ្អែកលើអេកូស៊ីស្ទែម (EBA)

EBA តម្រូវឱ្យមានជំនាញឯកទេសជាក់លាក់ដែលអាជ្ញាធរកសាងផែនការប្រើប្រាស់តំបន់ឆ្នេរមិនមានហើយ ជំនាញទាំងអស់នេះមានទំនាក់ទំនងជាពិសេសនឹងប្រព័ន្ធអេកូស៊ីស្ទែមធម្មជាតិ ប៉ុន្តែក៏ទាក់ទងទៅនឹងប្រព័ន្ធទាំងឡាយ ណាដែលគិតគូរដោយគំនិតទូលំទូលាយ។ ទំនាក់ទំនងអង្គការ និងស្ថាប័នតាមលក្ខណៈខ្សែបណ្តោយ ខ្សែទទឹង ដោយសារតែពួកគេធ្វើឱ្យប៉ះពាល់ដល់បញ្ហាមួយចំនួននៃការអនុវត្ត ការតាមដាន ការពង្រឹងការអនុវត្ត និងការសិក្សា នោះគឺមានសារៈសំខាន់ណាស់។ ផ្អែកតាមជម្រើសដែលបានជ្រើសរើសទាំងនេះ ដូចដែលមានក្នុងតារាងមុន អាជ្ញាធរ កសាងផែនការអាចរួមបញ្ចូលនូវតម្រូវការជំនាញបែបនេះនៅក្នុងលក្ខខណ្ឌការងារសម្រាប់ក្រុមទីប្រឹក្សា ឬ ងាកទៅ រកអង្គភាពវិស័យសាធារណៈសមស្របមួយដែលមានជំនាញ និងស្វែងរកការងារឆ្លងកាត់ព្រំដែនស្ថាប័ន។ តាមបទ ពិសោធន៍ បញ្ជាក់ថាបុគ្គលិក ស្ថាប័នសេវាសាធារណៈធ្វើការងារលើសលប់។ នាយកដ្ឋានដៃគូរបស់អង្គការ កសាង ផែនការអាចមានលទ្ធភាពផ្តល់នូវការគ្រប់គ្រងប្រកបដោយវិជ្ជាជីវៈក្នុងវិស័យជំនាញ ប៉ុន្តែមិនអាចធ្វើការងារដោយ ខ្លួនឯងបានទេ។ ប្រការនេះទុកឱ្យអាជ្ញាធរ កសាងផែនការដែល ពឹងផ្អែកលើផ្នែកឯកជន ឬ អ្នកផ្តល់សេវាកម្មអប់រំ ក្នុងវិស័យជំនាញទាំងនេះ។ ឱ្យតែអាជ្ញាធរជំនាញដែលមានតួនាទីត្រួតពិនិត្យនោះ ទទួលស្គាល់យុត្តាធិការត្រឹមត្រូវ

ដោយគ្មានការដាក់បន្ទុកការងារលើសលុបទៅលើពួកគេ។ លើសពីនោះ ពួកគេមានផលចំណេញពីចំណេះដឹងថ្មីៗ ទទួលបានតាមរយៈការពិគ្រោះយោបល់របស់អ្នកឯកទេស។

## បញ្ហាពាក់ព័ន្ធមួយចំនួននៃការកសាងផែនការសមុទ្រ និងដីគោកចម្រុះ

បញ្ហាស្រដៀងគ្នាអនុវត្តលើការធ្វើសមាហរណកម្មសមុទ្រជាមួយនឹងការកសាងផែនការដីគោក។ អាជ្ញាធរកសាងផែនការជាច្រើនមានជំនាញសំខាន់ៗដើម្បីអនុវត្ត ឬត្រួតពិនិត្យមើលការកសាងផែនការដែនដីប៉ុន្តែអាចខ្វះខាតនូវសមត្ថភាពជាក់លាក់សម្រាប់ការកសាងផែនការតំបន់សមុទ្រ។ ដូចគ្នានឹងវិធីសាស្ត្រផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមដែរ អាជ្ញាធរ កសាងផែនការនឹងប្រឈមមុខនូវការធ្វើផែនការជំនួសសម្រាប់ការគ្រប់គ្រងសមុទ្រ។ ជាថ្មីម្តងទៀតដោយគោរពតាមយុត្តាធិការជាក់លាក់របស់អាជ្ញាធរដៃគូមានសារៈសំខាន់ ដើម្បីជៀសវាងជម្លោះស្ថាប័នដោយបញ្ចូលនូវអាជ្ញាធរទាំងនេះទៅក្នុងពង្រាងលក្ខខណ្ឌការងារសម្រាប់ទីប្រឹក្សា និងផ្តល់ឱ្យពួកគេនូវតួនាទីក្នុងការគ្រប់គ្រងជំនាញការងារប្រហែលជាអាចមានដំណោះស្រាយមួយដែលក្នុងនោះ ភាគីទាំងអស់ទទួលបានផលប្រយោជន៍។ ឧទាហរណ៍តួនាទីនេះអាចត្រូវបានអនុវត្តតាមរយៈការបង្កើតនូវគណៈកម្មាធិការត្រួតពិនិត្យ រឺក្រុមគាំទ្រដែលអនុវត្តលើមូលដ្ឋានអន្តរស្ថាប័ន។ មានជំនាញជាក់លាក់ភាគច្រើនដែលតម្រូវឱ្យមានគឺបានចុះបញ្ជីរួចហើយនៅខាងលើ។




## បញ្ហាពាក់ព័ន្ធមួយចំនួននៃការកាត់បន្ថយគ្រោះមហន្តរាយ និការប្រែប្រួលអាកាសធាតុ

គោលការណ៍ដូចគ្នានេះបានអនុវត្តនៅទីនេះ ដូចមាននៅក្នុងផ្នែកទាំងពីរខាងលើនៅពេលនេះនិយាយពីការដោះស្រាយនូវការគ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់ ការបន្សុំា និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

## កិច្ចការទី៤ –ពង្រាងផែនការការងារ_ផែនទី

ដ្យាក្រាមទាំងពីរក្នុងផ្នែកនេះផ្តល់នូវការប្រៀបធៀបជាទូទៅមួយរវាងម៉ូដែលឬគំរូដំណើរការកសាងផែនការចាស់ និង ថ្មី ភាពខុសគ្នាសំខាន់គឺស្ថិតនៅត្រង់កម្រិត និងប្រភេទនៃការពាក់ព័ន្ធរបស់អ្នកពាក់ព័ន្ធ ប៉ុន្តែ មិនត្រឹមតែ

ប៉ុណ្ណោះនោះទេក្នុងដំណាក់កាលដំបូងនៃដំណើរការ។ នៅមានភាពខុសប្លែកគ្នាជាច្រើនទៀត ក្នុងការប្រើប្រាស់ព័ត៌មាន។ ក្នុងដំណើរការកសាងផែនការចាស់មានទិន្នន័យជាច្រើនបានប្រមូលតាមដែលអាចធ្វើទៅបានរួមទាំងទិន្នន័យថ្មីៗហើយបន្ទាប់មកធ្វើការវិភាគ។ ក្នុងគំរូថ្មីនេះ ការងារចាប់ផ្តើមដោយមានការពិនិត្យឡើងវិញយ៉ាងឆាប់រហ័សនូវព័ត៌មានដែលអាចមាន (ឧ. ឃ្លាំងទិន្នន័យ ភូមិសាស្ត្រ) រួមជាមួយនឹងការប្រមូលទិន្នន័យពិស្តារដែលផ្តោតទៅលើអាទិភាពកំណត់តាមរយៈធនធានចក្ខុវិស័យនិងការកំណត់អាទិភាពជាមួយនឹងអ្នកពាក់ព័ន្ធ។គំរូណាមួយបានត្រូវអនុម័តជាពិសេសនៅក្នុងការហ្វឹកហាត់ធ្វើផែនការវាជាការចាំបាច់ត្រូវតែកំនត់កម្មវិធីការងារ។សូម្បីតែទីប្រឹក្សាត្រូវបានប្រើប្រាស់ក្នុងដំណើរការនេះក៏អាជ្ញាធរកសាងផែនការត្រូវតែមានគំនិតច្បាស់លាស់នូវលំដាប់លំដោយជាជំហានៗទស្សនទានល្អនៃពេលវេលាជំហាននីមួយៗត្រូវតែប្រកាន់យកដើម្បីសរសេរនូវលក្ខខណ្ឌការងារចាំបាច់។

វាមានភាពចាំបាច់បំផុតក្នុងការចាប់ផ្តើមផែនការការងារពីចំណុចចុងបញ្ចប់គឺថា–កាលបរិច្ឆេទដាក់កំណត់សម្រាប់ការបញ្ចប់នូវផែនការ និងការដាក់ស្នើសុំការអនុម័ត។ ចូរកំណត់នូវពេលវេលាថយក្រោយ (រាប់ថយក្រោយ) ដោយធ្វើជាជំហានៗដោយកំណត់នូវពេលវេលាសមស្របសម្រាប់ដំណាក់កាលនីមួយៗ។ ចូរច្រេងក្រងនូវព័ត៌មានទាំងនេះលើដ្យាក្រាមមួយ (Gantt diagram) និង ចូរភ្ជាប់ទំនាក់ទំនងធនធានបុគ្គលិក និង ហិរញ្ញវត្ថុដែលត្រូវការកន្លងមក។ កិច្ចការនេះគួរតែមានអន្តរកម្មលើគ្នាទៅវិញទៅមកដែលជាលំហូរ ព័ត៌មាន ធនធានបុគ្គលិក និងគំរូ (លំហូរសាច់ប្រាក់) លេចឡើង និងត្រូវការកែតម្រូវតាម។ ដំណើរការមានតម្លៃសម្រាប់ការផលិតថវិកាសមហេតុផលដែលអាចបង្ហាញពីតម្លៃខាងក្នុង និងតម្លៃខាងក្រៅដែរ។ តាមធម្មតា តម្លៃខាងក្នុងអាចឆ្លើយតបបានតាមរយៈការរៀបចំថវិកាប្រចាំឆ្នាំចំណែកឯថវិកាខាងក្រៅអាចផ្តល់ឱ្យដោយថវិកា រដ្ឋាភិបាលពិសេស ឬដោយអ្នកផ្តល់ហរញ្ញប្បទានមកពីខាងក្រៅ ឧ. ការប្រមូលផ្តុំនូវការរួមចំណែករបស់ដៃគូអភិវឌ្ឍន៍អន្តរជាតិ និងធាតុចូលពីក្រុមផ្តល់អត្ថប្រយោជន៍សំខាន់ៗ។

ដ្យាក្រាមអាចធ្វើបានដោយដៃ ដោយការប្រើប្រាស់នូវកម្មវិធី Soft ware កុំព្យូទ័រសាមញ្ញឬ Soft ware គ្រប់គ្រងគម្រោងឯកទេសកម្ម។ ការចំណាយមិនមែនជាកត្តាមួយនោះទេ ប្រសិនបើអាជ្ញាធរមិនមានកម្មវិធី Soft ware ទំនើបទាន់សម័យកាលនោះ។ ចូរកំណត់ចំណាំថា ក្នុងដ្យាក្រាមទីនេះមានជំហានជាច្រើនអាចត្រួតស៊ីគ្នាដូចជាការប្រមូល និងការវិភាគទិន្នន័យក្នុងដំណើរការគម្រោងទាំងមូល។ គំរូថ្មីផ្តល់ព័ត៌មានស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ ប៉ុន្តែ ដោយសារការប្រើនូវទិន្នន័យភូមិសាស្ត្រ និង ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) គឺអាចផ្តល់ព័ត៌មានជាប្រចាំនិងងាយទទួលយកបាន។ ប្រព័ន្ធព័ត៌មានភូមិសាស្ត្រអាចធ្វើការវិភាគការបែងចែកតំបន់ប្រើប្រាស់ទំនើបកម្ម ព្រមទាំងបង្កើត និងធ្វើការសាកល្បងនូវសេណារីយ៉ូអនាគត និងជម្រើសការប្រើប្រាស់ដី។

## ការធ្វើផែនការតាមរយៈពេលវេលា




**បញ្ហាពាក់ព័ន្ធមួយចំនួននៃការអនុវត្តវិធីសាស្ត្រផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមដោយអនុវត្តនូវការកសាងផែនការប្រើប្រាស់សមុទ្រ និងដីគោកចម្រុះ និងដោយរួមបញ្ចូលនូវការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងបញ្ហាប្រែប្រួលអាកាសធាតុ**

### ***ការបង្កើតផែនការការងារ៖***

(១) ចូរចុះបញ្ជីសកម្មភាពសំខាន់ៗ ដែលចាំបាច់ដើម្បីបង្កើតផែនការ ដោយធ្វើការត្រឡប់ក្រោយវិញ (working backwards) ពីផលិតផលចុងក្រោយ

(២) បំបែកសកម្មភាពការងារនីមួយៗតូចៗឱ្យងាយស្រួលគ្រប់គ្រង ឧ. កិច្ចការមួយដែលអាចគ្រប់គ្រងបានដោយបុគ្គលម្នាក់ ឬក្រុមការងារមួយ និងអាចងាយស្រួលមើលឃើញនូវធនធានដែលត្រូវការ និងពេលវេលាដើម្បីធ្វើការងារនោះឱ្យចប់សព្វគ្រប់ ។

ទោះជាយ៉ាងណាក៏ដោយប្រយ័ត្នប្រយែងកំហុសរួមមួយគឺបំបែកសកម្មភាព

ឱ្យទៅជាសមាសភាពតូចៗច្រើនពេក

(៣) ជ្រើសរើសពេលវេលាសមស្របដើម្បីបញ្ជាក់ច្បាស់ថាតើពេលណាសកម្មភាពទាំងនោះនឹងកើតឡើង (ជា អាទិត្យ ជាខែ ជាត្រីមាស) ជាថ្មីម្តងទៀត ធ្វើការបកក្រោយវិញដោយគិតចាប់ពីកាលបរិច្ឆេទចុងក្រោយ

(៤) បញ្ជាក់ច្បាស់នូវលំដាប់លំដោយផលវិបាក និងការទំនាក់ទំនងកិច្ចការទាំងនោះ (តើការងារផ្សេងទៀតត្រូវតែបញ្ចប់មុនពេលការងារមួយទៀត ចាប់ផ្តើមឬ? ការងារពីរអាចធ្វើឡើង នៅដំណាលគ្នាបានទេ?

(៥) ចូរប៉ាន់ស្មាននៅពេលចាប់ផ្តើម និងរយៈពេលនៃការងារនីមួយៗ ។ កិច្ចការនេះត្រូវបានបង្ហាញនៅលើតារាងជាខ្សែបន្ទាត់ រឺរបានៅលើក្រាហ្វិក ។ ***ចូរប្រយ័ត្ន៖***

- ត្រូវរាប់បញ្ចូលនូវសកម្មភាព និងកិច្ចការសំខាន់ៗទាំងអស់
- ត្រូវចងចាំនូវបន្ទុកការងារបុគ្គលនីមួយៗនិងកំណត់ថាតើកន្លែងណាដែលត្រូវការជំនួយបន្ថែមទៀតនេៈ និង
- ត្រូវប្រាកដប្រជាអំពីថាតើការងារនេះត្រូវការពេលប៉ុន្មាន

(៦) ចូរកំណត់នូវព្រឹត្តិការណ៍សំខាន់ៗ (ចំណុចសំខាន់ៗ) ដើម្បីជួយតាមដានត្រួតពិនិត្យដំណើរការរីកចំរើន ។ ទាំងនេះគឺជាកាលបរិច្ឆេទដែលការងារនីមួយៗត្រូវបញ្ចប់ និង

(៧) ចូរចាត់តាំងសមាជិកក្រុមការងារដើម្បីទទួលកិច្ចការទាំងនោះ

ទាក់ទងនឹងការបង្កើតផែនការការងារបញ្ចូលកត្តាទាំងនេះទៅក្នុងរូបភាពនេះ មានន័យថាជាទំហំទីកន្លែង និង សម្ភារៈកាន់តែធំទូលាយព្រមទាំងបង្កើននូវចំនួនអ្នកពាក់ព័ន្ធ និងប្រភេទនៃអ្នកពាក់ព័ន្ធផ្សេងៗគ្នា។ បញ្ហាបន្ទាន់គឺថាកិច្ចការនេះមានតួអង្គច្រើន មានអន្តរកម្មច្រើនមានបញ្ហាជាច្រើនទៀតត្រូវដោះស្រាយមានទិន្នន័យ និងព័ត៌មានកាន់តែច្រើនត្រូវរួមបញ្ចូល និងវិភាគ ដូច្នេះត្រូវការពេលវេលាច្រើនថែមទៀតហើយក៏ត្រូវការការចំណាយហិរញ្ញប្បទានជាច្រើនទៀតផងដែរដោយផ្អែកលើថាតើការពិគ្រោះយោបល់បន្ថែមត្រូវបានប្រើប្រាស់រឹងអត់ ***ឬក៏អាជ្ញាធរគ្រប់គ្រងហានិភ័យ និងបរិស្ថានសមុទ្រផ្ដល់ដោយសេរីនូវពេលវេលានិងធនធានរបស់គេ។***

## កិច្ចការទី៥- ការរៀបចំសម្រាប់ការគ្រប់គ្រងព័ត៌មាន

ដំណើរការកសាងផែនការបែងចែកឆ្នេរសមុទ្រផ្ដោតលើព័ត៌មាន និងបង្កើតឯកសារជាច្រើនរួមមានៈ

- ឯកសារយោង
- ទិន្នន័យដើម (Raw Data)ដោយរួមមានសម្ភារៈស្រាវជ្រាវស្ថិតិដែលទទួលបានពីភ្នាក់ងារ ផ្សេងៗទៀត សម្ភារៈដែលបង្កើតឡើងនៅក្នុងសិក្ខាសាលា
- ការកត់ត្រា និងការថតចម្លងសម្លេងចេញពីការប្រជុំក្រុម
- ការឆ្លើយឆ្លងព័ត៌មានរួមទាំងអ៊ីមែល
- សម្ភារៈបទបង្ហាញ
- ផែនទី ទាំងធាតុចេញ និងសម្ភារៈឯកសារថតចម្លង និងឌីជីថល
- ឃ្លាំងផ្ទុកទិន្នន័យឌីជីថល ដោយបោះពុម្ពចេញតាមការចាំបាច់
- ពង្រាងឯកសារថតចម្លងសម្រាប់ការពិភាក្សា ឯកសារចម្រុះផ្សេងៗ/គោលរឿង ឯកសារការងារ ឯកសារទីតាំង/ជំហរ ។ល។
- រូបថត និងការបង្ហាញដោយមានទាំងវីដេអូ
- ការបោះពុម្ពផ្សាយចុងក្រោយ
- ឯកសារគ្រប់គ្រងគម្រោង រួមមានទាំងថវិកា និងឯកសារថវិកា របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍ដំណើរការការងារនិងតារាងពេលវេលា
- (ឯកសារសំងាត់)

ឯកសារទាំងអស់នេះបានមកពីប្រភពផ្សេងៗដោយអនុវត្តនូវវិស័យផ្សេងៗជាច្រើនមុខវិជ្ជានិងចំណេះដឹងដែលទាក់ទង នឹងដំណាក់កាលខុសៗគ្នានៃដំណើរការនិងប្រហែលជាចាំបាច់ត្រូវតែចែករំលែកទៅកាន់អ្នកចូលរួមជាទម្រង់ផ្សេងៗ ដូចជា: ឯកសារជាក្រដាស ឯកសារតាមកុំព្យូទ័រ ស៊ីឌី និងឌីវីឌី ។

វាមានសារៈសំខាន់ណាស់ ដែលថាក្រុម CSP នីមួយៗ និង ជាពិសេសមេដឹកនាំក្រុមឬអ្នកគ្រប់គ្រង CSP គួររៀបចំនូវសម្ភារៈទាំងនេះដើម្បីឱ្យវាងាយស្រួលក្នុងការដកស្រង់ រឺទទួលយកបានដោយមនុស្សភាគច្រើននៅពេលវេលាត្រឹមត្រូវមួយ ។ លើសពីនេះយើងត្រូវការពេលវេលាច្រើនដើម្បីស្វែងរកសម្ភារៈហើយដែលនាំឱ្យមានការចំណាយច្រើនដោយសារតម្រូវការថតចម្លងឯកសារបន្ថែម រឺជំនួសឯកសារដែលបាត់ ។ ដោយសារតែការប្រើប្រាស់កុំព្យូទ័រចេះតែកើនឡើង ដូច្នេះចាំបាច់ត្រូវតែមានឯកសារទាំង Hard និង Soft រឺជាកម្រងឯកសារ និងការថតចម្លងជាឌីជីថល ។

គ្មានមធ្យោបាយត្រឹមត្រូវរៀបចំឯកសារទាំងនោះទេ ។ ទិន្នន័យឌីជីថលជាកត្តាសំខាន់ដែលផ្តល់នូវមូលដ្ឋានចាំបាច់ថាតើហេតុអ្វីបានជាប្រព័ន្ធស្តង់ដាគួរតែជ្រើសរើសយក ។ បញ្ហានេះនឹងដោះស្រាយនៅក្នុងផ្នែកមួយដែលបានរៀបចំឡើងនៅក្នុងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ និងការគូសវាសនូវរចនាសម្ព័ន្ធ ។ ***សូមមើលក្នុងឧបសម្ព័ន្ធទី៤ចំពោះអនុ - សាសន៍បន្ថែមដើម្បីរៀបចំឯកសារនេះ ។***

## បញ្ហាពាក់ព័ន្ធនៃការណែនាំគំរូការកសាងផែនការថ្មី

នៅក្នុងគំរូនៃការកសាងផែនការថ្មី ការកសាងផែនការបែងចែកតំបន់បានចាត់ទុកជាចំបងថាជាដំណើរការវិលជុំហើយផែនការនេះពឹងផ្អែកលើបច្ចេកវិទ្យាព័ត៌មាន ជាពិសេស ទិន្នន័យភូមិសាស្ត្រ និង GIS ។ ទិន្នន័យភូមិសាស្ត្រត្រូវបានប្រើដើម្បីរៀបចំ និងរក្សាទុកទិន្នន័យ និងព័ត៌មាន ។ ទិន្នន័យទាំងនេះទទួលបានតាមរយៈកម្មវិធី Software សម្រាប់ការវិភាគស្ថិតិ ការបែងចែកតំបន់ប្រើប្រាស់ និង រូបភាពព្រមទាំងសម្រាប់ផលិតផែនទី (យ៉ាងលឿន និងអាចបត់បែនបានដោយយោងតាមសេចក្តីត្រូវការជាក់លាក់) តារាង និងដ្យាក្រាមស្ថិតិគឺជាព័ត៌មានទោលឬសម្រាប់បញ្ចូលទៅក្នុងអត្ថបទ ។ វាមានសារៈសំខាន់ណាស់ចំពោះការប្រៀបធៀបពេលវេលា និងតំបន់ និង អាចបង្ហាញនូវនិន្នាការបែងចែកតំបន់កន្លងមក ។

រចនាសម្ព័ន្ធដែលអាចជឿជាក់បាន និងដែលមានប្រយោជន៍បំផុតសម្រាប់ទិន្នន័យភូមិសាស្ត្រគឺជារចនាសម្ព័ន្ធមួយដែលអាជ្ញាធរនីមួយៗចងក្រងទិន្នន័យ និងព័ត៌មានដែលខ្លួនទទួលខុសត្រូវដោយយោងតាមសេចក្តីត្រូវ និង ស្របតាមស្តង់ដាគុណភាពដែលគេទទួលស្គាល់ ។ ទោះជាយ៉ាងណាក៏ដោយ គ្រប់អាជ្ញាធរចូលរួមទាំងអស់ក្នុងប្រព័ន្ធនេះត្រូវតែឯកភាពលើពាក្យជាមូលដ្ឋាន និយមន័យពាក្យ និងស្តង់ដាសម្រាប់មេទិន្នន័យ Metadata (ទិន្នន័យនិយាយ

ពីទិន្នន័យ) និងពិធីសារសម្រាប់ការផ្លាស់ប្តូរទិន្នន័យ និងព័ត៌មាន។ នៅក្នុងរចនាសម្ព័ន្ធនេះ អាជ្ញាធរបានត្រួតពិនិត្យនូវការចេញចូលបានទិន្នន័យភូមិសាស្ត្ររបស់មនុស្សផ្សេងទៀត។ អាជ្ញាធរនីមួយៗ នៅតែរក្សាការគ្រប់គ្រងសំខាន់លើទិន្នន័យរបស់ខ្លួន និង កំណត់នូវអ្វីដែលមិនអាចចែករំលែកបាន។ ដោយសារស្តង់ដាររួមព័ត៌មានដែលមានអាចចងក្រងបញ្ចូលគ្នាដោយទុកចិត្តបានជាក់ស្តែងសម្រាប់គោលបំណងការកសាងផែនការ។

នៅពេលដែលប្រព័ន្ធនេះគឺជាប្រព័ន្ធដែលគេពេញនិយមតាមបទពិសោធន៍បង្ហាញថា វាចំណាយពេលច្រើនដើម្បីឈានដល់កម្រិតខ្ពស់នៃការផ្លាស់ប្តូរទិន្នន័យ ដោយសារតែទាំងភាពស្ទាក់ស្ទើរក្នុងការចែករំលែកទិន្នន័យ "**ជាកម្មសិទ្ធិ**" និងឱ្យកាន់តែស៊ីជម្រៅដោយសារភាពលំបាកដើម្បីសម្រេចបានកិច្ចព្រមព្រៀងនៅគ្រប់ផ្នែកទាំងអស់នោះលើការកំណត់និយមន័យនៃពាក្យ។ ការឈានដល់កម្រិតមួយដ៏ល្អនៃកិច្ចសហការអន្តរភ្នាក់ងារគឺជាដំណើរការមួយពីរយៈពេលមធ្យមទៅរយៈពេលវែងដែលតម្រូវឱ្យធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់ ហើយផលប្រយោជន៍វិញទទួលបានធំធេងណាស់។

វិធីសាស្ត្រនិយមប្រើភាគច្រើនគឺថាអាជ្ញាធរកសាងផែនការតាមរយៈការទិញពីឬអនុស្សារណៈនៃយោគយល់ជាមួយតម្រូវការឱ្យមានទិន្នន័យនិងព័ត៌មានពីភ្នាក់ងារនីមួយៗស្របតាមតម្រូវការរបស់ខ្លួនបង្កើតនូវឃ្លាំងទិន្នន័យភូមិសាស្ត្រសមស្របរបស់ខ្លួននិងរក្សាទុកព័ត៌មាននៅទីនោះ។ ជាទូទៅ ការរៀបចំបែបនេះមានន័យថាជាការប្រឹងប្រែងដ៏ច្រើនក្នុងការធានានូវទិន្នន័យដូចគ្នា និងមានគុណភាព ទោះបីវិធីសាស្ត្រនេះ មិនមែនជាវិធីសាស្ត្រដ៏ល្អឥតខ្ចោះក៏ដោយជាញឹកញាប់ វាគឺជាជម្រើសរយៈពេលខ្លីដែលគួរឱ្យជឿជាក់តែមួយគត់។

ទោះជាគំរូមួយណាក៏ដោយ ឃ្លាំងទិន្នន័យភូមិសាស្ត្រមានសារៈសំខាន់ណាស់ចំពោះដំណើរការកសាងផែនការ ហើយវាក្លាយជាទំនាក់ទំនងដ៏សំខាន់រវាងការបង្កើតផែនការ និងកម្រិតផែនការ។ ក្នុងបរិបទនៃការរៀបចំផែនការគំរូកសាងផែនការថ្មីតំណាងឱ្យស្ថិរភាពព័ត៌មានរយៈពេលយូរអង្វែង។

## បញ្ហាពាក់ព័ន្ធមួយចំនួននៃការអនុវត្តវិធីសាស្ត្រផ្អែកលើប្រព័ន្ធអេកូស៊ីស្តែមដោយអនុវត្តនូវការកសាងផែនការបែងចែកតំបន់ប្រើប្រាស់ដី និងសមុទ្រចម្រុះ និងការរួមបញ្ចូលនូវការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងបញ្ហាប្រែប្រួលអាកាសធាតុ

បញ្ហាសំខាន់ៗសម្រាប់ការគ្រប់គ្រងទិន្នន័យ នៃការណែនាំនូវគន្លឹះទាំងនេះក្នុងការកសាងផែនការមានក្នុងមាតិកាទិន្នន័យ និងព័ត៌មាន។ រចនាសម្ព័ន្ធនៃឃ្លាំងទិន្នន័យភូមិសាស្ត្រនេះអាចរួមបញ្ចូលក្នុងទិន្នន័យនេះបាន។ ដោយសារតែប្រព័ន្ធអេកូស៊ីស្តែមមានភាពស្មុគស្មាញខ្លាំង វាប្រហែលជាអាចឱ្យអាជ្ញាធរពាក់ព័ន្ធដើម្បីគ្រប់គ្រងព័ត៌មាននេះ និង ដកស្រង់

យកតែព័ត៌មានទាំងឡាយណាដែលចាំបាច់សម្រាប់ដំណើរការកសាងផែនការនេះ ។ ការងារនេះពឹងផ្អែកទាំងស្រុងលើភាពជាក់លាក់នៃតំបន់ធ្វើផែនការ ។ តាមមធ្យោបាយស្រដៀងគ្នាដែរ ការកាត់បន្ថយហានិភ័យ និងវិធានការឆ្លើយតបបន្ទាន់រឺផែនការយថាផលផ្ទុកទៅដោយព័ត៌មានជាច្រើនដែលមិនចាំបាច់សម្រាប់គោលបំណងកសាងផែនការ ។ អាស្រ័យហេតុនេះគួរតែដកស្រង់នូវទិន្នន័យដែលពាក់ព័ន្ធនឹងការកសាងផែនការបែងតំបន់ប្រើប្រាស់ពីអាជ្ញាធរពាក់ព័ន្ធ ។

ទាំងការកសាងផែនការផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែម និង ការគិតគូរពីការកាត់បន្ថយហានិភ័យជាផ្នែកសំខាន់មួយនៃព័ត៌មានផ្តោតលើ ទំនាក់ទំនងរវាងសមាសភាគនៃប្រព័ន្ធប្រទាក់ក្រឡាគ្នានោះ ។ លំហូរសម្ភារៈ និងថាមពលចម្លាក់ចំណីអាហារគឺជាឧទាហរណ៍នៅក្នុងប្រព័ន្ធអេកូស៊ីស្ទែម ។ ទិដ្ឋភាពនៃភាពងាយរងគ្រោះ (ទាំងការប្រឈម និងផលប៉ះពាល់) មានសារៈសំខាន់ណាស់ក្នុងការកាត់បន្ថយហានិភ័យ ។ ទាំងនេះមានន័យថា ការប្រឈមនឹងមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិត្រូវតែភ្ជាប់ទំនាក់ទំនងទៅនឹងកត្តាសេដ្ឋកិច្ច និងសង្គម ដែលកំណត់នូវសមត្ថភាពសហគមន៍ឬលំនៅដ្ឋានដើម្បីដោះស្រាយ និងស្តារឡើងវិញពីគ្រោះមហន្តរាយនេះ ។ ប្រព័ន្ធទិន្នន័យភូមិសាស្ត្រនេះត្រូវតែបញ្ចូលនូវកត្តាកំណត់នូវភាពងាយរងគ្រោះ និង ភាពធន់ទាំងនេះដែលមានក្នុងសហគមន៍ពិសេសមួយ (ដូចជារចនាសម្ព័ន្ធសង្គមកម្រិតប្រាក់ចំណូលការចូលរួមក្នុង សង្គម បណ្តាញសង្គមការទទួលនូវធនធាន ។ល ។

ទិន្នន័យការប្រែប្រួលអាកាសធាតុមួយចំនួនអាចមានសម្រាប់វិស័យជាច្រើនប៉ុន្តែតាមការសិក្សាជាច្រើន និង តាមវិទ្យាសាស្ត្របានបង្ហាញថា ការព្យាករណ៍ការប្រែប្រួលអាកាសធាតុតាមរូបភាពផ្សេងៗ (របបសីតុណ្ហភាព បរិមាណរបាយទឹកភ្លៀង ភាពញឹកញាប់ និងកម្រិតនៃខ្យល់ព្យុះ និងខ្យល់ ។ល ។) នឹងមានការប្រែប្រួល ។ អ្នកកសាងផែនការត្រូវតែរក្សាទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរសមស្របសម្រាប់តាមដានព័ត៌មានថ្មីៗស្តីពីស្ថានភាពនិងការព្យាករណ៍បច្ចុប្បន្ន ។

## កិច្ចការទី៦ - សេចក្តីជូនដំណឹងអំពីផែនការ និងការអញ្ជើញផ្តល់នូវធាតុចូល

ប្រទេសមួយចំនួនតម្រូវឱ្យមានការជូនដំណឹងផ្តល់ដល់សាធារណជននូវការអនុវត្តនូវ CSP ។ នៅទីណាដែលវាមិនមែនជាតម្រូវការស្របច្បាប់នោះ វាអាចប្រើដើម្បីអញ្ជើញសាធារណជន និង ក្រុមដែលមានអត្ថប្រយោជន៍ ពិសេសឱ្យចូលរួម ។ តាមមធ្យោបាយនេះ វាជាជំហានដំបូងឈានទៅវិធីសាស្ត្រដោយមានការចូលរួមនេះ ។ តាមធម្មតា សេចក្តីជូនដំណឹងបែបនេះគួរចុះផ្សាយតាមកាសែតក្នុងស្រុកឬផ្សព្វផ្សាយជាប្រធានបទមួយនៃព័ត៌មានសម្រាប់សាធារណជនតាមវិទ្យុក្នុងស្រុក ។ ប្រសិនបើវិធីសាស្ត្រដោយមានការចូលរួមត្រូវតែបន្តធ្វើដោយម៉ត់ចត់នោះនេះគឺជាពេលវេលាសមស្របបំផុតដែលត្រូវបញ្ជូនព័ត៌មានទៅកាន់អ្នកពាក់ព័ន្ធសំខាន់ៗទាំងអស់ដែលបានកំណត់ដោយគូសបញ្ជាក់នូវគោលបំណងនៃការហ្វឹកហាត់នេះការកំណត់ពីពេលវេលារបស់វា និងព្រឹត្តិការណ៍ដោយមានការចូលរួមពិសេស និងវិធីសាស្ត្រដែលនឹងត្រូវប្រើ ។ ប្រការនេះជាសញ្ញា (ចាប់ផ្តើម) ពិតប្រាកដនៃការហ្វឹកហាត់នេះ ។

## បញ្ហាពាក់ព័ន្ធនៃការណែនាំនូវគំរូកសាងផែនការថ្មី

ប្រសិនបើគំរូកសាងផែនការថ្មីត្រូវបានអនុម័តនោះ យើងចាំបាច់ត្រូវតែជូនដំណឹងដល់សាធារណជន និង អនុញ្ញាតឱ្យមានការចូលរួម។ ការពន្យល់នូវរបៀបថាតើការចូលរួមនេះនឹងកើតឡើងដូចម្ដេចនោះគួរតែត្រូវផ្ដល់ឱ្យ។ ព័ត៌មានលំអិតដ៏សំខាន់មួយគឺថាគេគួរតែពិពណ៌នាវាថាជាដំណើរការពិគ្រោះយោបល់ដ៏សកម្ម ឬដោយមានការចូលរួមមួយដែលអ្នកចូលរួមអាចមានគំនិតយោបល់ចូលទៅក្នុងការកំណត់នូវអ្វីដែលសំខាន់និងថាតើប្រភេទអ្វីត្រូវតែធ្វើសេចក្ដីសម្រេចចិត្តនៅដំណាក់កាលដំបូងនោះ។

ទោះជាយ៉ាងណាក៏ដោយវាក៏មានសារៈសំខាន់ផងដែរក្នុងការធានាថាក្រុមទទួលបានផលប្រយោជន៍ជាក់លាក់និងសាធារណជនទូទៅយល់ថាធាតុចូលរបស់គេត្រូវតែដាក់រួមគ្នាជាមួយគំនិតយោបល់ផ្សេងៗទៀត និង ថាវាគឺជាអាជ្ញាធរធ្វើផែនការដែលធ្វើការដោយអនុឡោមតាមច្បាប់ជាតិដែលមានការទទួលខុសត្រូវក្នុងការស្វែងរកឱ្យសម្រេចបាននូវតុល្យភាពមួយក្នុងចំណោមការដណ្ដើមយកផលប្រយោជន៍តាមវិស័យ ដើម្បីស្វែងរកដំណោះស្រាយសមស្របសម្រាប់សង្គមទាំងមូល។ ដំណើរការពិគ្រោះយោបល់នេះគួរតែមានតម្លាភាពប៉ុន្តែត្រូវតែប្រាកដប្រជាក្នុងការដោះស្រាយនូវក្ដីរំពឹងទុករបស់សាធារណជន។

## បញ្ហាពាក់ព័ន្ធមួយចំនួន នៃការអនុវត្តវិធីសាស្ត្រផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមដោយអនុវត្តនូវការកសាងផែនការបែងចែកតំបន់ប្រើប្រាស់ដី និងសមុទ្រចម្រុះ និងការរួមបញ្ចូលនូវការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងបញ្ហាប្រែប្រួលអាកាសធាតុ

ការជូនដំណឹងណាមួយនៃគោលបំណងកសាងផែនការតាមរបៀបមួយ ដែលរួមបញ្ចូលនូវបញ្ហាថ្មីៗទាំងនេះគួរតែបង្ហាញនូវការពិតដោយមានទាំងការពន្យល់ថាតើវាមានន័យថាដូចម្ដេចទាក់ទងនឹងការគ្រប់គ្រងបរិស្ថាន ការគ្រប់គ្រងហានិភ័យ និងការប្រតិកម្មទៅនឹងការប្រែប្រួលអាកាសធាតុ។

**លទ្ធផល**

***នៅពេលដែលជំហាននេះបញ្ចប់ អ្នកគួរតែមានៈ***

- ការយល់ដឹងយ៉ាងច្បាស់ ក្នុងទម្រង់សរសេរនូវគោលបំណងនិងវិសាលភាព នៃលំហាត់ការធ្វើផែនការ
- ការចង្អុលបង្ហាញច្បាស់នូវលក្ខណៈ និងការថ្លឹងថ្លែងដែលជាប់ទាក់ទងសម្រាប់ការធ្វើការសម្រេចចិត្តក្នុងស្ថានភាព ដែលមានការប្រកួតប្រជែង ឬជម្លោះនូវអត្ថប្រយោជន៍ក្នុងការប្រើប្រាស់ធនធាន (ដោយរួមបញ្ចូលទាំងទីតាំងផងដែរ)។
- មានការសម្រេចចិត្តច្បាស់លាស់មួយទៅលើថាតើការងារនឹងត្រូវធ្វើដោយរបៀបណា-ថាតើជាលក្ខណៈផ្ទៃក្នុង ដោយទីប្រឹក្សាម្នាក់ ឬ ការបញ្ចូលគ្នាមួយ ដោយរួមមានលក្ខខណ្ឌនៃការងារ និងកិច្ចសន្យាគំរូ។
- បញ្ជីអ្នកពាក់ព័ន្ធទាំងឡាយ ដោយរៀបចំតាមរបៀបមួយដែលអ្នកដឹងអំពីតួនាទី ការទទួលខុសត្រូវ និងអត្ថប្រយោជន៍ក្នុងដំណើរការ និងលទ្ធផលទទួលបានពីផែនការ និងគំនិតច្បាស់លាស់មួយអំពីថាតើអ្នកណាអាចសំដៅរកសម្រាប់ប្រភេទនៃធាតុចូលជាក់លាក់។ ការងារនេះនឹងរួមបញ្ចូលអ្នកពាក់ព័ន្ធជាក់លាក់ដែលអាចយល់ដឹងអំពីអេកូស៊ីស្ទែមសមុទ្រនិងបញ្ហាការគ្រប់គ្រងហានិភ័យរួមទាំងការប្រែប្រួលអាកាសធាតុ។
- ការពិភាក្សា ការចូលរួម និងផែនការទំនាក់ទំនងដែលកំណត់ថាតើអ្នកនឹងធ្វើការងារជាមួយអ្នកពាក់ព័ន្ធទាំងឡាយដោយរបៀបណា តាមរយៈជំហានផ្សេងៗគ្នានៃការធ្វើផែនការ និងជាងនេះទៅទៀតនោះ។
- ប្រព័ន្ធឯកសារសម្រាប់ផ្ទុកព័ត៌មានដែលប្រមូលបាន និងប្រើប្រាស់ក្នុងដំណើរការ។ ប្រព័ន្ធនេះគួររួមមានប្រព័ន្ធព័ត៌មានភូមិសាស្ត្រនិងទិន្នន័យភូមិសាស្ត្រដែលជាមូលដ្ឋានសម្រាប់ការធ្វើផែនការរយៈពេលវែង ការអនុវត្ត ការតាមដាន និងការសិក្សា
- ផែនការការងារច្បាស់លាស់សម្រាប់ដំណើរការការងារ រួមទាំងដ្យាក្រាម Gantt ដែលពិពណ៌នាលម្អិតថាតើនរណា ឬអង្គភាពណាមួយនឹងធ្វើអ្វី និងនៅពេលណា
- ធ្វើការជូនដំណឹងជាសាធារណៈនូវការពិតដែលថាផែនការរៀបចំដីធ្លីគួរត្រូវបានបង្កើត និងការពិតដែលថាអ្នកពាក់ព័ន្ធត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងការបង្កើត។

**អ្នកក៏អាចប្រើប្រាស់បញ្ជីត្រួតពិនិត្យសំនួរដូចខាងក្រោម៖**

***តើអ្នកបានបញ្ជាក់ច្បាស់នូវ៖***

- គោលបំណងនៃផែនការ?
- ព្រំដែនភូមិសាស្ត្រនៃតំបន់ធ្វើផែនការ?
- លទ្ធផលរំពឹងទុកនៃផែនការទាំងមូល (ឧ.៖ របាយការណ៍នៃស្ថានភាពបច្ចុប្បន្ន ចក្ខុវិស័យ និងគោលដៅរយៈពេលវែង អាទិភាព និងយុទ្ធសាស្ត្រសម្រាប់រយៈពេលខ្លី ការធ្វើផែនទី និងការអនុវត្តផែនការ និងតារាងពេលវេលា)?
- ថាតើអ្នកនឹងប្រើវិធីចាត់ចំណាត់ថ្នាក់ផែនការតាមតំបន់ជាក់លាក់ ឬដ្យាក្រាមការធ្វើផែនការថ្មី?
- ថាតើអ្នកនឹងដាក់ឱ្យអនុវត្តវិធីមូលដ្ឋានប្រព័ន្ធអេកូស៊ីស្ទែម ហើយបើដូច្នោះតើអ្នកមានភាពច្បាស់លាស់លើអ្វីដែលជាការអនុវត្តនេះទេ?
- តើអ្នកនឹងរួមបញ្ចូលផែនការរៀបចំដីធ្លី និងសមុទ្រ?
- តើអ្នកនឹងរួមបញ្ចូលទិដ្ឋភាពផែនការបែងចែកការប្រើប្រាស់នូវការគ្រប់គ្រងហានិភ័យ និងផែនការសម្រាប់ពង្រឹងនៃភាពធន់ទ្រាំក្នុងចំណោមក្រុមអ្នកងាយរងគ្រោះ?
- តើអ្នកបានប្រមូលផ្តុំនូវអ្នកពាក់ព័ន្ធមួយចំនួន? តើអ្នកបានដឹងអំពីតួនាទី និងការទទួលខុសត្រូវ សិទ្ធិ និងកាតព្វកិច្ច នៃអ្នកពាក់ព័ន្ធទាំងនោះទេ? តើអ្នកអាចស្មានទុកនូវអត្ថប្រយោជន៍ជាក់លាក់ និងតើអ្នកមានយុទ្ធសាស្ត្រសម្រាប់ការស្វែងរកសមតុល្យក្នុងចំណោមជម្លោះអត្ថប្រយោជន៍បានទេ?
- តើអ្នកបានរៀបចំយុទ្ធសាស្ត្រពិគ្រោះយោបល់ និងទំនាក់ទំនងសម្រាប់អន្តរកម្មជាមួយអ្នកពាក់ព័ន្ធ?
- តើអ្នកប្រាកដថាតើអ្នកនឹងគ្រប់គ្រងព័ត៌មានដែលត្រូវការ និងតម្រូវឱ្យមានដោយដំណើរការធ្វើផែនការរឺ? ។ តើអ្នកមានយុទ្ធសាស្ត្រជាក់លាក់សម្រាប់ថាតើអ្នកនឹងធ្វើបច្ចុប្បន្នកម្មព័ត៌មាន និងការសិក្សារៀនសូត្រពីព័ត៌មាននេះដោយរបៀបណា ។
- តើអ្នកមានផែនការការងារច្បាស់លាស់សម្រាប់ដំណើរការធ្វើផែនការរួមមានដ្យាក្រាម Gantt? នោះទេ ។ តើអ្នក បានដឹងទេថានរណានឹងធ្វើអ្វី និងនៅពេលណាក្នុងកំឡុងពេលនៃដំណើរការ?
- តើអ្នកបានជូនដំណឹងជាសាធារណៈនូវបំណងចាប់ធ្វើផែនការ និងថាតើអ្នកពាក់ព័ន្ធអាចចូលរួមយ៉ាងដូចម្តេច?

## ជំហានទី២: ការវាយតម្លៃស្ថានភាពបច្ចុប្បន្ន

***នៅផ្នែកនេះ អ្នកនឹងឃើញព័ត៌មានស្តីពីៈ***

- ភាពខុសគ្នារវាងគំរូផែនការចាស់និងថ្មីក្នុងការពិពណ៌នាស្ថានភាពបច្ចុប្បន្ន
- ទស្សនៈទានលើការវាយតម្លៃស្ថានភាពបច្ចុប្បន្ន
- ពិនិត្យមើលទស្សនៈ ឬការអនុវត្តភ្លាមៗលើការប្រមូលព័ត៌មានសំខាន់ៗ
- ហេតុផល និងវិធីសាស្ត្រសម្រាប់វាស់វែងធនធានទ្រព្យទាំងអស់
- វិធីសាស្ត្រសម្រាប់កំណត់ចក្ខុវិស័យ និងរូបមន្តរយៈពេលវែង
- ការរៀបចំយុទ្ធសាស្ត្រ
- គំរូសម្រាប់ការសិក្សាពិសេស
- លំនាំគំរូសម្រាប់ធ្វើរបាយការណ៍
- ការធ្វើរបាយការណ៍ស្ថានភាពបច្ចុប្បន្ន

## ភាពខុសគ្នារវាងគំរូរៀបចំផែនការចាស់ និងថ្មី

ភាពខុសគ្នាមួយចំនួនក្នុងចំណោមភាពខុសគ្នាសំខាន់ៗរវាងគំរូផែនការចាស់និងថ្មីមាននៅដំណាក់កាលដំបូងនៃការធ្វើផែនការ ។ តារាងនេះបង្ហាញពីភាពខុសគ្នាៈ



នៅក្នុងលំនាំគំរូទាំងពីរ ប្រអប់ពណ៌សបង្ហាញពីសកម្មភាពអនុវត្តដោយអ្នកជំនាញ ហើយប្រអប់ពណ៌បៃតងខ្ចីបង្ហាញពីប្រភពព័ត៌មាន ចំណែកឯប្រអប់ពណ៌បៃតងចាស់នៅក្នុងគំរូថ្មីបង្ហាញពីសកម្មភាពអនុវត្តដំបូងដោយអ្នកពាក់ព័ន្ធ។ ដំណើរការរៀបចំផែនការចាស់ល្បីគួរសមដែរ ប៉ុន្តែប្រទេសជាច្រើនកំពុងធ្វើដំណើរឆ្ពោះទៅរកគំរូថ្មី ឬបានអនុម័តរួចហើយនូវគំរូនេះ។ កថាខណ្ឌបន្តបន្ទាប់នេះពិពណ៌នាលំអិតថែមទៀតចំពោះដំណើរការនេះ។

## ទស្សនទានស្តីពីការវិភាគស្ថានភាពបច្ចុប្បន្ន

នៅក្នុងការអនុវត្តផែនការចាស់ការពិពណ៌នានូវស្ថានភាពបច្ចុប្បន្នគឺស៊ីគ្នាទៅនឹងចំណុចគន្លឹះនៃតំបន់នោះ នៅពេលដែលចាប់ផ្តើមដំណើរការរៀបចំផែនការដោយផ្តោតសំខាន់លើការកំណត់លក្ខខណ្ឌនិងឧបសគ្គរូបវន្តនិងបញ្ហាគន្លឹះជាច្រើនដោយគ្រាន់តែជ្រើសរើសផ្នែកដែលមានសក្តានុពល។ និន្នាការមួយចំនួន ពិសេសចំនួនប្រជាជនអាចបង្ហាញស្របពេលជាមួយការផ្លាស់ប្តូរសេដ្ឋកិច្ចខ្នាតធំដូចដែលមាននៅក្នុងតារាងស្ថិតិ។

តាមបែបទំនើបវិញការផ្លាស់ប្តូរស្ថានភាពកំពុងផ្តោតលើនិន្នាការ និងកំលាំងដែលគួសបញ្ជាក់នូវនិន្នាការទាំងនេះ។ ឥឡូវនេះ ដំណើរការរៀបចំផែនការត្រូវបានគេចាត់ទុកថាជាយន្តការមួយសម្រាប់គ្រប់គ្រងគោលដៅទាំងនោះដូចដែលពួកគេបានគ្រោងទុកនៅពេលអនាគតហើយជាមួយគ្នានោះដែរក៏មានការបញ្ជាក់ជាច្រើនផងដែរចំពោះការកំណត់នូវប្រភេទធនធានដូចជា ធនធានធម្មជាតិ ជីវចម្រុះ បរិស្ថានវិទ្យា សេដ្ឋកិច្ច មនុស្ស និងសង្គម។ គោលបំណងនៃការរៀបចំផែនការគឺដើម្បីងអភិរក្ស និងលើកកម្ពស់ធនធានទាំងនេះឱ្យកាន់តែប្រសើរខណៈដែលត្រូវមានការប៉ះប៉ូវវិញនៅពេលមានកំលាំង និង និន្នាការអវិជ្ជមាន បញ្ហា និងការគម្រាមកំហែងនៅពេលបច្ចុប្បន្ន និងអនាគតចំពោះធនធានទាំងនោះព្រមទាំងតម្លៃរបស់វា។

ទស្សនទាននៃការធ្វើផែនការមានឥទ្ធិពលដល់របៀបដែលក្នុងនោះស្ថានភាពបច្ចុប្បន្នត្រូវបានស្រាវជ្រាវ វិភាគ និងស្វែងយល់ហើយនឹងប្រើប្រាស់ដើម្បីដំណើរការទៅមុខទៀត ជាពិសេសទៅទៀតនោះត្រូវយកចិត្តទុកដាក់ទៅលើគ្រោងការការងារដែលក្នុងនោះផែនការនេះត្រូវតែរៀបចំឡើង ហើយដែលសំខាន់ជាងនេះទៀតគឺត្រូវអនុវត្តផែនការនេះតែម្តង។ ក្របខណ្ឌនេះទាមទារឱ្យមានការច្របាច់បញ្ចូលគ្នានូវផ្នែកដែលមានទំនាក់ទំនងគ្នាដូចជាការរៀបចំ និងយុត្តាធិការរដ្ឋបាល និតិបញ្ញត្តិ ប៉ុន្តែរួមបញ្ចូលទាំងឥទ្ធិពលនយោបាយ សេដ្ឋកិច្ច បច្ចេកវិទ្យា បរិស្ថាន និងសង្គមដែលគេបានសំលៀងរួចហើយរឺកំពុងតែសំលៀងនិងទំនងជាមានឥទ្ធិពលទៅលើគំរូនាពេលអនាគត។ មាតិកាជាពិសេសក៏រិតនៃភាពលំអិតនឹងមានភាពខុសគ្នាដោយយោងទៅលើក៏រិតនិងប្រភេទនៃផែនការដែលបានរៀបចំឡើង ហើយ

កាតព្វកិច្ចនៅចំណុចនេះអាចត្រូវបានអនុវត្តស្របគ្នាដោយបានបង្ហាញដាច់ដោយឡែកពីគ្នា ប៉ុន្តែវាមានទំនាក់ទំនងគ្នាទៅវិញទៅមកយ៉ាងជិតស្និទ្ធ។ ការវិភាគពីស្ថានភាពបច្ចុប្បន្នមានបីដំណាក់កាលៈ

១. ការពិនិត្យមើលបច្ចេកទេសភ្លាមៗដោយអ្នកជំនាញ និងក្រុម CSP ផ្អែកទាំងស្រុងលើការប្រមូលទិន្នន័យថ្មីក្រៅផ្លូវការដែលមានស្រាប់។ ប្រសិនបើវាមិនមែនជាការអនុវត្ត CSP ដំបូងសម្រាប់ការពិនិត្យទេនោះ លទ្ធផលនេះនឹងផ្តល់ព័ត៌មានគ្រប់គ្រាន់សំរាប់ការត្រួតពិនិត្យមើលភ្លាមៗនេះ។

២. គំរូពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធសំដៅលើការរៀបចំសិក្ខាសាលាៈ

- ធនធានគ្រប់ប្រភេទបានបញ្ជាក់ៈ ធនធានធម្មជាតិ ជីវចម្រុះ មនុស្ស សង្គម និង សេដ្ឋកិច្ច
- ចក្ខុវិស័យរួម និងគោលដៅយូរអង្វែងបានបង្កើតឡើង
- មុខសញ្ញាគ្រោះថ្នាក់បច្ចុប្បន្ន និង ហានិភ័យដែលកំពុងកើតមានឡើងត្រូវបានបញ្ជាក់
- ជ្រើសរើសគោលបំណងរយៈពេលខ្លី (៥ឆ្នាំ) ដោយផ្អែកលើអាទិភាពក្នុងការឆ្ពោះទៅរកគោលដៅរយៈពេលវែង។




ធាតុចូលមួយនៃសិក្ខាសាលាគឺជាការបង្កើតឡើងភ្លាមៗនូវចក្ខុវិស័យរួម។ ទោះបីយ៉ាងណាក៏ដោយការចូលរួមផ្តល់យោបល់ជាច្រើនចំពោះធនធានទាំងនេះគឺជាការបង្កើតទស្សនៈរួម និងគោលដៅយូរអង្វែងដោយគ្មានធាតុចូលពីរបាយការណ៍របស់ក្រុមជំនាញ។ មូលហេតុគឺដើម្បីផ្តល់នូវទស្សនៈបន្ថែមដែលមិនពាក់ព័ន្ធនិងដោយមិនលម្អៀងតាមទស្សនៈរបស់ក្រុមអ្នកជំនាញ។

៣) ការសិក្សាស៊ីជម្រៅមួយចំនួនដោយរួមបញ្ចូលទាំងការស្រាវជ្រាវថ្មីៗប្រសិនបើ

សមស្របទៅក្នុងវិស័យអាទិភាពទាំងអស់នោះ ដែលនឹងត្រូវលើកយកទៅដោះស្រាយនៅក្នុងកំឡុងពេលអនុវត្តលើកដំបូង។ ដូច្នេះក្រោមពីមុននេះបានបង្ហាញពីសារៈសំខាន់នៃសិក្ខាសាលាពិគ្រោះយោបល់មិនត្រឹមតែការកំណត់វិស័យសំខាន់ៗ និងចំណុចគោលដៅនោះទេ ប៉ុន្តែថែមទាំងសម្រាប់ជំហានក្រោយៗក្នុងការរៀបចំយុទ្ធសាស្ត្រ និងធ្វើការវាយតម្លៃដោយផ្អែកទៅលើស្ថានភាពដើម្បីសម្រេចគោលដៅយូរអង្វែងទៀតផង។

## កិច្ចការទី១: ការពិនិត្យមើលបច្ចេកទេស

គោលបំណងនៃការពិនិត្យមើលបច្ចេកទេសបែបរហ័ស គឺដើម្បីទទួលបាននូវព័ត៌មានសង្ខេបនៃស្ថានភាព ដូចដែលបានបង្ហាញនៅក្នុងឯកសារដែលមានស្រាប់ ទាំងក្នុងទម្រង់ឯកសារ ឬជាឌីជីថល។ ឥឡូវនេះគេមិនរំពឹងថានឹងមានការស្ទាបស្ទង់មតិឬក៏ការងារនៅតាមមូលដ្ឋានថ្មីៗនោះទេ ហើយការវិភាគស៊ីជម្រៅណាមួយនោះដែរ ប៉ុន្តែការវិនិច្ឆ័យដ៏សមស្របមួយគឺជាការចាំបាច់ដើម្បីវាយតម្លៃនូវគុណភាពសម្ភារៈដែលមានស្រាប់។ វាគឺជាការចងក្រងជាមូលដ្ឋានគ្រឹះមួយនៃឯកសារដែលមានស្រាប់ដោយដកស្រង់នូវទិន្នន័យ និងព័ត៌មានដែលមានតម្លៃជាក់លាក់ក្នុងការកំណត់ធនធានបញ្ហាដែលទាមទារឱ្យមានការយកចិត្តទុកដាក់ភ្លាមៗនូវហានិភ័យនាពេលបច្ចុប្បន្ននិងកំពុងកើតមានឡើង។

ការពិនិត្យមើលឡើងវិញនេះគួរត្រូវធ្វើឡើងដោយក្រុមអ្នកជំនាញដែលមានបទពិសោធន៍ និងប្រវត្តិការងារសមស្រប។ ជាមួយក្រុមការងារល្អមួយ និងមានកិច្ចសហការល្អជាមួយនឹងអាជ្ញាធរក្នុងតំបន់នោះ កិច្ចការនេះគួរចំណាយពេលមិនដល់មួយខែនោះទេ ហើយបើតិចបំផុតក៏ពីរសប្តាហ៍ដែរដើម្បីចងក្រងឯកសារនេះ។ ឯកសារទាំងនេះនឹងត្រូវបង្ហាញតាមបែបជាឈុតៗ។ នៅក្នុងឧបសម្ព័ន្ធ៥ ផ្តល់នូវតារាងត្រួតពិនិត្យនៃប្រភេទប្រធានបទដែលគួរត្រួតពិនិត្យមើលឡើងវិញ។

វាមិនចាំបាច់ត្រូវបង្ហាញដោយយោងទៅតាមប្រភេទទាំងអស់នេះទេប៉ុន្តែវាគួរបង្ហាញដូចជា ឧទាហរណ៍ខាងក្រោម:

- ធនធានរូបវន្ត និងទម្រង់ដំណើរការបែបធម្មជាតិ
- ទម្រង់បែបបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ី
- ទម្រង់នៃការតាំងទីជម្រក និងការប្រើប្រាស់ដី
- ទម្រង់បែបសេដ្ឋកិច្ចសង្គម និងប្រជារាស្ត្រ
- ទម្រង់សេដ្ឋកិច្ច (ដោយរាប់បញ្ចូលទាំងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច)
- ទម្រង់ហេដ្ឋារចនាសម្ព័ន្ធវប្បធម៌សង្គម
- ទម្រង់អភិបាលកិច្ច និងវិទ្យាស្ថាន

- ទម្រង់ការត្រៀមបំរុងចំពោះគ្រោះមហន្តរាយ(រួមទាំងស្ថានភាពបន្ទាំនឹងការប្រែប្រួលអាកាសធាតុ) មិនមានមធ្យោបាយត្រឹមត្រូវដើម្បីបង្ហាញពីសម្ភារៈនេះទេប៉ុន្តែកន្លែងដែលអាចធ្វើទៅបានគួរបញ្ចូលនូវមធ្យោបាយទាំងនោះទៅក្នុងគោលការណ៍។ ស្ថានការណ៍ និងគោលបំណងជាកត្តាសំខាន់ក្នុងការកំណត់ទម្រង់របាយការណ៍ចុងក្រោយនៃការត្រួតពិនិត្យឡើងវិញ។

ការពិនិត្យឡើងវិញនេះជាសម្ភារៈផ្លូវការមួយដែលត្រូវប្រមូលនិងរក្សាទុកហើយត្រូវបានចងក្រងដោយក្រុមអ្នកជំនាញដោយប្រើប្រាស់សម្ភារៈដែលមានស្រាប់។ វាជាការពិត ដោយមានការវិនិច្ឆ័យលើសុពលភាព ភាពជឿទុកចិត្តបានភាពរួចរាល់និងថាតើវាមានបច្ចុប្បន្នភាពរបៀបណា។ ការធ្វើបែបនេះគឺមានភាពខុសគ្នាទៅនឹងប្រភេទព័ត៌មានសំខាន់ៗផ្សេងទៀត ហើយព័ត៌មានជាច្រើនមិនសូវត្រូវបានកត់ត្រាទុកក្នុងបញ្ជីស្ថិតិ និងជាគោលដៅសម្រាប់ការងារបន្ទាប់។ កិច្ចការនេះមានលក្ខណៈកាន់តែសត្យានុម័តផ្អែកលើតម្លៃ មតិយោបល់ពាក់ព័ន្ធ គំនិត សេចក្តីប្រាថ្នា និងការភ័យខ្លាច។

## កិច្ចការទី២: កំណត់ធនធាន ទស្សនៈ គោលដៅរយៈពេលវែង និងអាទិភាពដែលមានស្រាប់

កិច្ចការទី១អនុវត្តដោយអ្នកជំនាញបច្ចេកទេសធ្វើការប្រៀបធៀប និងវាយតម្លៃការពិត និងទូរលេខ ចំណែកឯកិច្ចការទី២គឺការប្រមូលទស្សនៈ ការចងចាំក្នុងចិត្ត ព័ត៌មាន និងចំណេះដឹងនូវបរិមាណ និងការបង្ហាញពីក្តីសង្ឃឹម និងការភ័យខ្លាចនៅពេលអនាគត។ ព័ត៌មានលំអិតបន្ថែមទៀតគឺផ្អែកលើកម្រិតនៃការរៀបចំផែនការ ការរៀបចំព័ត៌មានឱ្យមានប្រសិទ្ធភាព និងផ្សព្វផ្សាយព័ត៌មានឱ្យកាន់តែទូលំទូលាយដល់សាធារណៈជន។ ទស្សនៈទាននៃការអភិវឌ្ឍប្រកបដោយនិរន្តរភាពអាចពង្រីកឱ្យកាន់តែទូលំទូលាយដើម្បីធ្វើឱ្យស្របតាមធនធានទ្រព្យសម្បត្តិនិងធនធានកំណត់ដោយសហគមន៍។ ធនធានទាំងនេះរួមមាន:

- **បែបធម្មជាតិ:** ធនធានជីវសាស្ត្រនិងរូបវន្តដែលមានដោយរាប់បញ្ចូលទាំងតំបន់ហើយចំណុចនេះអាចមើលឃើញនៅក្នុងបរិបទនៃការអាចចេញចូលបាន
- **លក្ខណៈមនុស្ស:** ចំណេះដឹង ជំនាញ លទ្ធភាពធ្វើការ (រាងកាយមាំមួន) និងសុខភាព
- **លក្ខណៈសង្គម:** បណ្តាញ និងទំនាក់ទំនងសង្គម ការឯកភាពជាអន្តរក្រុម និងអន្តរបុគ្គល ស្ថាប័នសង្គមដោយរួមបញ្ចូលភាពជឿជាក់ បដិការ ភាពជិតស្និត ទឹកចិត្តរបស់សហគមន៍ និងប្រវត្តិរួម
- **លក្ខណៈរូបវន្ត:** ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានរួមមានផ្ទះ ឧបករណ៍ប្រើប្រាស់និងការដឹកជញ្ជូន
- **តាមបែបហិរញ្ញវត្ថុ:** ធនធានហិរញ្ញវត្ថុ រួមមានឥណទាន និងតម្លៃឥណទានសមស្រប។

ចំណេះដឹងមូលដ្ឋានអំពីនិរន្តរភាពរួមជាមួយអត្ថប្រយោជន៍ និងឆន្ទៈដើម្បីចូលរួមក្នុងដំណើរការ CSP អាចធ្វើឱ្យលទ្ធផលនៃផែនការនេះទទួលជោគជ័យ ។ដំណើរការ CSP អាចធ្វើឱ្យកាន់តែងាយស្រួលគឺៈ




## វគ្គធ្វើផែនការ៤ជំហានជាមូលដ្ឋាន

សកម្មភាពស្វែងរក និងរុករកធនធានទាំងអស់នេះអាចទាក់ទាញការចាប់អារម្មណ៍កាន់តែខ្លាំងឡើងនៅជុំវិញ CSP និងអាចពាក់ព័ន្ធដល់ក្រុមអ្នកពាក់ពន្ធ័តាមសហគមន៍ ។ វាមានអត្ថប្រយោជន៍ខ្លាំងណាស់ និងមានភាពសាមញ្ញដើម្បីអនុវត្តលំហាត់ "ការធ្វើផែនទីធនធាន" នៅក្នុងសិក្ខាសាលា ។ សិក្ខាកាមពិនិត្យមើលធនធានសហគមន៍សំខាន់ៗ និងអធិប្បាយពីសារៈសំខាន់ និងតម្លៃធនធានតាមប្រភេទផ្សេងគ្នាសម្រាប់ការអភិវឌ្ឍ ។ នៅក្នុងកិរិតអាជ្ញាធរមូលដ្ឋានវិធីសាស្រ្តប្រើប្រាស់នៅក្នុងសិក្ខាសាលាដំណើរការបានល្អ ។ នៅទីនេះ វាជាពេលវេលាសមស្របមួយដើម្បីជួបអ្នកតំណាងនានាមកពីវិស័យសាធារៈ វិស័យឯកជន និងសង្គមស៊ីវិល ។ អត្ថប្រយោជន៍នៃការធ្វើការងាររួមគ្នា ជាជាងតាមរយៈការសម្ភាសន៍ជាលក្ខណៈបុគ្គលជាមួយនឹងអ្នកពាក់ពន្ធ័នានា គឺថាសិក្ខាកាមមានការបញ្ចេញមតិយោបល់ច្រើន ហើយអ្នកចូលរួមអាចរំលឹកមកវិញនូវចំណេះដឹងដែលភ្លេច និង កប់ជ្រៅជាយូរមកហើយ ។ ស្របជាមួយគ្នានេះ វាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់អ្នកសម្របសម្រួលដែលទទួលបានបទពិសោធន៍កាន់តែច្រើនតាមរយៈសិក្ខាសាលា ។

- **របកគំហើញធនធានទ្រព្យសម្បត្តិ:** ការឆ្លើយសំណួរអ្វីល្អ និងតម្លៃនៅក្នុងតំបន់នោះ និងផ្អែកលើប្រភេទធនធានផ្សេងគ្នាដែលបានចុះបញ្ជីខាងលើ

- **ការបង្កើតចក្ខុវិស័យៈ** ការឆ្លើយនឹងសំនួរ តើយើងយល់យ៉ាងម៉េចដែរចំពោះតំបន់ដែលផ្តល់ធនធានអស់រយៈពេល២០ឆ្នាំមកហើយនោះ? ទស្សនៈរួមគឺនៅពេលដែលត្រូវបានប្រែសម្រួលទៅតាមកម្រិតគោលដៅយូរអង្វែង ជាពិសេសទៅតាមផ្នែកនីមួយៗ (សុខភាព ការអប់រំ បរិស្ថាន និងការអភិរក្ស ថាមពល ការដឹកជញ្ជូន និងទំនាក់ទំនង វប្បធម៌ និងអ្វីផ្សេងៗទៀត) ។

ចក្ខុវិស័យនិងគោលដៅយូរអង្វែងធ្វើឱ្យក្របខណ្ឌការងារកាន់តែយូរ និងកាន់តែធំសម្រាប់ផែនការតាមផ្នែក។ គោលបំណងរយៈពេលខ្លីបង្ហាញពីមូលនិធិសម្រាប់កម្មវិធីអនុវត្តតាមរយៈអ្វីដែលផែនការនោះគួរត្រូវបានធ្វើឱ្យប្រាកដប្រជា និងត្រូវបានអនុវត្ត។ ការយល់ឃើញចំពោះការត្រួតពិនិត្យបច្ចេកវិទ្យាទំនើបគួរត្រូវបានបញ្ចូលទៅក្នុងដំណើរការសិក្ខាសាលាតែមួយគត់ បន្ទាប់ពីអ្នកចូលរួមមានឱកាសបង្ហាញអ្វីដែលពួកគេគិតថាជាធនធាន។ ការត្រួតពិនិត្យបច្ចេកវិទ្យានឹងផ្តល់ឱ្យមានទាំងគោលដៅរយៈពេលយូរ និងការបញ្ជាក់ពីឧបសគ្គផងដែរ ហេតុដូចនេះ ចំពោះបញ្ជីអាទិភាពសម្រាប់ការស្វែងរកបន្តគឺជាផ្នែកមួយនៃជំហានបន្ទាប់ក្នុងការធ្វើផែនការ។ មិនមានបញ្ហាត្រូវលើកឡើងនៅក្នុងផ្នែកដែលរកឃើញធនធាននោះទេ។ គោលបំណងនៃការវាយតម្លៃធនធាននៅតាមផ្នែក CSP គឺសំដៅទៅលើការយល់ឃើញរបស់អ្នកពាក់ព័ន្ធដើម្បីឆ្ពោះទៅរកគោលដៅ និងការគិតឱ្យបានសមស្របចំពោះផ្នែកផ្ទាល់ខ្លួនរបស់ពួកគេមួយបន្ថែមទៀតនិងលទ្ធភាពរៀបចំផ្នែកលើធនធានដែលមានស្រាប់។ អកប្បកិរិយាសមស្រប និងការបង្ហាញពីការយល់ឃើញវិជ្ជមានសម្រាប់ផ្នែកនេះនឹងធ្វើឱ្យដំណើរការ CSP ចំគោលដៅ ជាជាងនៅតែចាំដោះស្រាយបញ្ហាដោយគាំទ្រការផ្សព្វផ្សាយផែនការតាមផ្នែកជាជាងការធ្វើផែនការតាមការបញ្ហា។

## កិច្ចការទី៣ បំផុសគំនិត គោលដៅរយៈពេលវែង និងអាទិភាពរយៈពេលខ្លីសម្រាប់ការអនុវត្ត

កិច្ចការទី១ខាងលើគឺការស្វះស្វែងរកជំនាញទៅតាមបរិបទក្នុងផ្នែក CSP និងស្ថានការណ៍ ហើយកិច្ចការទី២ផ្តោតសំខាន់លើការស្វែងរកធនធាន និងប្រភពសម្រាប់ការអភិវឌ្ឍដូចដែលបានដឹងឮដោយសហគមន៍ និងអ្នកពាក់ ព័ន្ធ។ កិច្ចការទី៣បំផុសឱ្យមានការបញ្ចេញមតិ គោលដៅ និងអាទិភាពដោះស្រាយការងារឱ្យបានឆាប់រហ័ស និង ការវិភាគស្ថានការណ៍ដើម្បីបញ្ចប់ការបង្កើតគោលដៅយូរអង្វែងដែលឆ្លុះបញ្ចាំងពីទស្សនៈ ។ផ្នែកមួយនៃគោលបំណងរបស់សិក្ខាសាលាគឺអនុញ្ញាតឱ្យអ្នកជំនាញបង្ហាញពីរបៀបត្រួតពិនិត្យការអង្កេតថ្មីៗជូនដល់មហាជន។ គោលបំណងទាំងពីរនេះគឺដើម្បីជម្រាបពួកគេពីស្ថានការណ៍ដែលបានកត់ត្រាទុកនៅក្នុងស្ថិតិ ប៉ុន្តែក៏នឹងទទួលព័ត៌មានបន្ថែមដែលអាចបញ្ជាក់នៅអ្វីដែលព័ត៌មានស្ថិតិនៅគ្រប់ផ្នែកទាំងអស់អាចមានការសង្ស័យលើគុណភាព។ វាក៏ជាឱកាសមួយផងដែរចំពោះ

ការបង់ពន្ធទៅតាមបរិមាណចំពោះសាធារណជន និងផ្នែកគុណភាពចំពោះអ្នកជំនាញ។ នៅពេលគេមើលឃើញថាព័ត៌មានទាំងពីរប្រភេទនេះសមស្របដូចនេះគោលដៅយូរអង្វែងអាចត្រូវបានឯកភាព។

មានទស្សនៈមួយក្នុងចំណោមទស្សនៈសំខាន់ៗជាច្រើនសម្រាប់ផែនការបែងចែកតំបន់រយៈពេលយូរគឺជាដំណោះស្រាយចម្រុះរបស់វា។ នេះមានន័យថាការរៀបចំផែនការបែងចែកតំបន់នេះអាចដោះស្រាយបាននូវវិស័យផ្សេងៗដូចជាតម្លៃ និងផលប្រយោជន៍ដែលមានជម្លោះក្នុងការប្រើប្រាស់ធនធានក្នុងសមុទ្រ និងលើដី។ ក្នុងករណីខ្លះផែនការបែងចែកតំបន់ទាមទារឱ្យមានការភ្ជាប់ទំនាក់ទំនងជាមួយនឹងការអភិវឌ្ឍសេដ្ឋកិច្ចគ្រប់ប្រភេទទាំងអស់ ហេតុដូចនេះ ការអភិវឌ្ឍសេដ្ឋកិច្ចនេះនឹងមានទាំងសមាសធាតុបែងចែកការប្រើប្រាស់ និងមិនបែងចែកការប្រើប្រាស់។

**ចក្ខុវិស័យ....**

- បំបែកអ្នកពាក់ព័ន្ធចេញពីព្រំដែនគំនិតរបស់ពួកគេ
- បញ្ជាក់ពីទិសដៅ និងគោលបំណង
- ជូនដំណឹងអ្នកពាក់ព័ន្ធឱ្យមានការផ្លាស់ប្តូរ
- ផ្សព្វផ្សាយពីអត្ថប្រយោជន៍ និងការប្តេជ្ញាចិត្ត
- ជម្រុញឱ្យមានការយកចិត្តទុកដាក់កាន់តែខ្លាំង
- ជម្រុញឱ្យមានការបើកចំហរចំពោះដំណោះស្រាយពិសេសៗ
- ជម្រុញ និងកសាងទំនុកចិត្ត
- កសាងភាពស្មោះត្រង់តាមរយៈការចូលរួម (ភាពម្ចាស់ការ)

ចំណុចស្នូលនៃការរៀបចំផែនការយុទ្ធសាស្ត្រគឺធ្វើឱ្យយើងដឹងថាតើត្រូវទៅកន្លែងណា និងទៅដូចម្តេចដើម្បីដល់ទីនោះ។ ចក្ខុវិស័យនេះគឺជាសារមួយដែលបានទទួល ទាំងអស់គ្នាថាតើយើងត្រូវទៅកន្លែងណានៅក្នុងតំបន់ដែលបានគ្រោងទុក ។មានអត្ថប្រយោជន៍ជាច្រើនក្នុងការខិតខំបង្កើតចក្ខុវិស័យរួមក្នុងចំណោមអ្នកពាក់ព័ន្ធ។ យើងត្រូវតែចងចាំថាចក្ខុវិស័យនេះនឹងបញ្ច្រាបទៅក្នុងគោលដៅរយៈពេលវែង និងជាញឹកញាប់ទៅតាមផ្នែកនីមួយៗដោយសារការអនុវត្តទាមទារឱ្យមានការសហការពីគ្រប់អង្គការ និងអាជ្ញាធរ។ ទោះបីយ៉ាងណាក៏ដោយគោលដៅទាំងនេះត្រូវតែស្រប ជាមួយចក្ខុវិស័យរួម។

**លក្ខណៈពិសេសនៃចក្ខុវិស័យប្រកបដោយប្រសិទ្ធភាពនឹង:**

- ធ្វើឱ្យមានភាពច្បាស់លាស់ និងកុំឱ្យភាន់ច្រឡំ
- បង្ហាញពីភាពរស់រវើក និងច្បាស់លាស់មិនឱ្យ ស្រពិចស្រពិល
- និយាយពីអនាគតដ៏ភ្លឺស្វាង
- ជាការបង្ហាញនូវការបញ្ចេញមតិ
- បង្ហាញពីបំណងប្រាថ្នាដ៏ពិតប្រាកដនិងដែលអាចសម្រេចបាន
- ស្របជាមួយតម្លៃសង្គម និងវប្បធម៌របស់សង្គមមូលដ្ឋាន

ប្រសិនបើការបង្កើតទស្សនៈផ្អែកលើការរកឃើញដែលបានចងក្រង ចេញពីអ្នកជំនាញ និងអ្នកពាក់ព័ន្ធនោះទស្សនៈនឹងបង្កើតឱ្យមានទំនាក់ទំនងកាន់តែខ្លាំងឡើង និង ភាពជាម្ចាស់នៃដំណើរការនេះ ដែលយ៉ាងហោចណាស់សម្រាប់អ្នកពាក់ព័ន្ធដែលចូលរួម ។ ដូចដែលបានបញ្ជាក់នៅផ្នែកមុនៗដំណើរការរៀបចំផែនការទាំងមូលត្រូវតែមើលឃើញថាជាដំណើរការរៀនសូត្រអន្តរកម្មនិងចេះតែបន្ត ។ ចំណេះដឹងថ្មីស្តីពីលក្ខខណ្ឌមូលដ្ឋានគឺមានន័យថា ជាគោលដៅប្រកបដោយផ្លែផ្កា ហើយការពិភាក្សាបែបយុទ្ធសាស្រ្តត្រូវតែឆ្លើយចំពោះសំនួរថាតើអ្វីទៅដែលកំពុងរារាំងយើងមិនឱ្យសម្រេចបាននូវចក្ខុវិស័យនេះ?

ចក្ខុវិស័យនេះគឺជាការយល់ឃើញដ៏ទូលំទូលាយមួយដែលចាំបាច់ត្រូវតែបញ្ចូលទៅក្នុងចក្ខុវិស័យរយៈពេលវែងប្រសិនបើវាចាំបាច់នោះ ។ មធ្យោបាយដ៏ល្អបំផុតត្រូវបង្វែរទស្សនៈនេះឱ្យទៅជាការពិភាក្សាតាមក្រុមតូចៗនៅក្នុងអង្គសិក្ខាសាលាដែលប្រហែលជាមានប្រធានបទនិងទស្សនៈតាមវិស័យជាច្រើន ។

**ឧទាហរណ៍:**

- តើចក្ខុវិស័យនេះមានអត្ថន័យដូចម្តេចចំពោះបរិស្ថាន? តើយើងមានទស្សនៈទាន និង ចំណេះដឹងអំពីធនធានទ្រព្យសម្បត្តិ និងធនធានរួមស្តីពីបរិស្ថានទេ?
- តើការអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់មានន័យដូចម្តេច? តើយើងមានទិន្នន័យគ្រប់គ្រាន់ហើយឬនៅ និងបានវិភាគឱ្យស៊ីជម្រៅចំពោះការអភិវឌ្ឍសេដ្ឋកិច្ចមួយផ្អែកលើការអភិវឌ្ឍប្រកបដោយនិរន្តរភាពដែរឬទេ?
- តើសុខភាព និងសុវត្ថិភាពមានន័យដូចម្តេច?
- តើទឹក អនាម័យ និងការគ្រប់គ្រងសំណល់មានន័យដូចម្តេច?
- តើសុវត្ថិភាពក្នុងការប្រឈមមុខនឹងគ្រោះមហន្តរាយដោយរួមបញ្ចូលទាំងការប្រែប្រួលអាកាសធាតុមានន័យដូចម្តេច?
- តើសាមគ្គីសង្គម អភិបាលកិច្ច តុល្យភាពយេនឌ័រ និងការផ្តល់អំណាចមានន័យដូចម្តេច?

ឥឡូវនេះដល់ពេលដែលយើងអាចធ្វើការពិភាក្សាពីអ្វីដែលកំពុងរារាំងយើងមិនឱ្យសម្រេចបាននូវចក្ខុវិស័យ និងធ្វើការវិភាគបញ្ហាទាំងនេះហើយ។ ការប្រឈមនេះត្រូវតែជំនះលើបញ្ហាទាំងអស់ដោយបង្កើតនូវគោលដៅរយៈពេលវែងមួយចំនួន។ ការវិភាគបញ្ហាគឺផ្អែកទៅលើចំណេះដឹងដែលមាន ការវិភាគស្ថានការណ៍ ការវាយតម្លៃប្រូហ្វាល និង ចក្ខុវិស័យភ្លាមៗគួរផ្តល់នូវមូលដ្ឋានគ្រឹះដើម្បីសម្រេចបានចក្ខុវិស័យនេះ។ ជាមួយគ្នានោះដែរ នៅមានគោលដៅជាច្រើនផងដែលបានបង្កើតឡើងនូវកម្រិតខ្ពស់ជាងនេះ ដែលអ្នករៀបចំផែនការតំបន់ឆ្នេរត្រូវតែធ្វើតាម។ ចូរចាត់ទុកអាជ្ញាធមិជាតិ និង រដ្ឋាភិបាលថាជាអ្នកពាក់ព័ន្ធដែលពួកគេមានគំនិតផ្ទាល់ខ្លួនចំពោះវិស័យនេះពោលគឺវាជាផ្នែកមួយរបស់ជាតិ។ ទាំងនេះរួមមានៈ

- គោលដៅគោលនយោបាយជាតិជាញឹកញាប់បង្ហាញតាមរយៈឯកសារដូចជា ផែនការអភិវឌ្ឍជាតិ ឬផែនការសកម្មភាពបរិស្ថានជាតិ
- ស្តង់ដានិងគំរូតាមផ្នែកដែលបង្ហាញពីទិសដៅសម្រាប់ការផ្តល់សេវាកម្ម និងចង្អុលបង្ហាញដោយប្រយោលនូវគោលដៅតាមផ្នែក។ ឧទាហរណ៍ទំហំទីធ្លាសម្រាប់មនុស្សម្នាក់នៅកន្លែងតាំងលំនៅ។ ប្រសិនបើស្តង់ដានេះមិនអាចសម្រេចបានទេនោះវានៅតែជាគោលដៅមួយដ៏ដែល។
- គោលដៅអភិវឌ្ឍន៍សហសវត្សរ៍ដែលបានបង្កើតជាសកលហើយដែលឥឡូវនេះមានប្រទេសជាច្រើនបានអនុម័ត។

**គោលដៅរយៈពេលវែងជម្រុញឱ្យដំណើរការអភិវឌ្ឍន៍ឆ្ពោះទៅមុខ។ នៅក្នុងទម្រង់នេះពួកគេគួរតែជាៈ**

- គោលការណ៍ណែនាំក្នុងន័យថាពួកគេផ្តល់ការណែនាំ និងគោលបំណង
- សមហេតុសមផល ហើយមិនដូច្នោះទេគេមិនអាចសម្រេចបានជោគជ័យ ហើយធ្វើឱ្យពួកគេមានការស្រង៉ាកចិត្ត
- ជម្រុញ ផ្តល់ឱ្យ និងរក្សាការលើកទឹកចិត្ត
- មើលឃើញនិងច្បាស់លាស់តាមរបៀបមួយដែលអ្នកទាំងអស់គ្នាអាចឈរលើវិសាលភាពនិងបញ្ហារបស់ពួកគេ
- នៅចុងបញ្ចប់គឺថានេះជាគោលដៅរយៈពេលយូរ មិនមែនរយៈពេលខ្លីនោះទេ។ ក្នុងន័យនេះ ពួកគេប្រហែលជាមិនអាចសម្រេចគោលដៅក្នុងរយៈពេល៣ទៅ៥ឆ្នាំដំបូងនោះទេ។ បើទោះយ៉ាងណាក៏ដោយគោលបំណងរយៈពេលខ្លីសម្រាប់គោលដៅនីមួយៗនឹងត្រូវជម្រុញការងារនេះឱ្យទៅមុខឆ្ពោះទៅរកគោលដៅ និងចក្ខុវិស័យរយៈពេលវែង។

ជំហានបន្ទាប់នៃដំណើរការនេះគឺការរៀបចំយុទ្ធសាស្ត្រថាតើត្រូវសម្រេចគោលដៅរយៈពេលយូរតាមរបៀប ណា។ យុទ្ធសាស្ត្រមានពីរគឺៈ អ្វីដែលយើងចង់ធ្វើ ហើយតើយើងត្រូវធ្វើវាតាមរបៀបណា។ ដើម្បីដោះស្រាយបញ្ហាការធ្វើ

ផែនការឱ្យមានប្រសិទ្ធភាព ជាទូទៅវាមានសភាពស្មុគ្រស្មាញជាច្រើន និងបានជះឥទ្ធិពលលើផែនការបែងចែកតំបន់សេដ្ឋកិច្ចសង្គម និងកត្តាបរិស្ថាន និងត្រូវការការរៀបចំឱ្យបានល្អនូវយុទ្ធសាស្ត្ររយៈពេលយូរ។ យុទ្ធសាស្ត្រ នេះបានបំពេញនូវគម្លាតរវាងគោលដៅ និងសកម្មភាពជាក់ស្តែង។ ជារួម យុទ្ធសាស្ត្រ និងសកម្មភាពបានផ្សារភ្ជាប់រវាងចំណុចបញ្ចប់ និងអត្ថន័យរបស់វា។

***ស្ថានភាពចក្ខុវិស័យពិសេសមួយអាចជា:***

"អ្នកតាំងលំនៅបច្ចុប្បន្ន និងអនាគតនៅកន្លែងណាមួយនៅក្នុងខណ្ឌមានសុវត្ថិភាព និងស្រស់បំព្រង ដោយពេញចិត្តនៅការអភិវឌ្ឍប្រកបដោយនិរន្តរភាពស្របជាមួយធនធានអេកូឡូស៊ី និង បរិស្ថានរបស់ពួកគេ។" ចក្ខុវិស័យនេះអាចបកស្រាយដូចតទៅ:

- ការបង្ហាញពី"អ្នកតាំងលំនៅពេលបច្ចុប្បន្ន និងអនាគត" ត្រូវបានរាប់បញ្ចូល និងមានន័យថារាល់អ្នកតាំងលំនៅទាំងអស់ ដោយមិនគិតពីដើមកំណើត សញ្ជាតិ ជំនាន់ ឬស្ថានភាពសេដ្ឋកិច្ច។
- "...គឺមានសុវត្ថិភាព និងស្រស់បំព្រង"មានន័យថាជាទូទៅ អត្រាបទឧក្រិតបានធ្លាក់ចុះ អ្នកតាំងលំនៅមានសុវត្ថិភាពផ្នែកសង្គម សេដ្ឋកិច្ច និងរូបវន្ត ហើយអ្នកតាំងលំនៅ ស្ថាប័នរបស់ពួកគេរឹងមាំ អ្នកតាំងលំនៅមានសន្តិភាព និងប្រជាជនទទួលបានសេវាសុខភាពសាធារណៈល្អ។
- "ដោយពេញចិត្តនូវការអភិវឌ្ឍប្រកបដោយនិរន្តរភាព"គឺជាពាក្យដ៏មានខ្លឹមសារដែលនិយាយពីស្ថានភាពមួយដែលមានតុល្យភាពរវាងការអភិវឌ្ឍសេដ្ឋកិច្ច ការប្រើប្រាស់ធនធានធម្មជាតិ ធនធានមនុស្ស និងការរស់នៅល្អប្រសើរ។

កត្តាទាំងនេះអាចត្រូវគេបញ្ចូលរួចហើយទៅក្នុងគោលដៅតាមវិស័យសម្រាប់ សុខាភិបាល ការអប់រំ លំនៅដ្ឋាន ទឹក និងអនាម័យ ការគ្រប់គ្រងសំណល់ ថាមពល ការធ្វើនយោបាយ ការគ្រប់គ្រងហានិភ័យ ការអភិរក្ស ការលំហែកំសាន្ត (ដោយរាប់បញ្ចូលទាំងការចូលទៅដល់តំបន់ឆ្នេរសមុទ្រ) ។ល។ ភាគច្រើននៃកត្តាទាំងអស់នេះអនុវត្តចំពោះសកម្មភាពរយៈពេលខ្លី ប៉ុន្តែក៏សម្រាប់ផែនការបែងចែកតំបន់ផងដែរ។

## ការកែប្រែពីចក្ខុវិស័យទៅជាគោលដៅ ពីគោលដៅទៅជាយុទ្ធសាស្ត្រ

ឧទាហរណ៍នូវគោលដៅរយៈពេលវែងផ្អែកលើចក្ខុវិស័យតំបន់ឆ្នេរៈ

១. លើកកម្ពស់ និងអភិរក្សបរិស្ថានដើម្បីទ្រទ្រង់សមុទ្រ និងធនធានក្នុងសមុទ្រ

២. ជម្រុញឱ្យទទួលបាន និងផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធ និងសេវាសុខភាពមូលដ្ឋាន

ការវិភាគការតតាំងនិងបញ្ហាអាចជួយយើងទទួលបាននូវយុទ្ធសាស្ត្រសំខាន់ៗដើម្បីជំនះលើបញ្ហាដែលបានរៀបចំឡើងនិងធ្វើសង្ខេបនៅក្នុងតារាងខាងក្រោមៈ

| គោលដៅចំបង | កំណត់ការប្រកួតប្រជែង | បញ្ហា | យុទ្ធសាស្ត្រ |
|---|---|---|---|
| ធ្វើឱ្យប្រសើរនិងអភិរក្សបរិស្ថានតំបន់ឆ្នេរដើម្បីការទ្រទ្រង់សមុទ្រនិងធនធានរបស់វានិងសុខមាលភាពមនុស្ស | បរិស្ថានតំបន់ឆ្នេរត្រូវបានបំផ្លាញ | - ការបំផ្លាញគម្របរុក្ខជាតិលើជម្រាលភ្នំ<br>- ការធ្លូរសំណល់ចូលទៅក្នុងសមុទ្រ<br>- ការកើនឡើងការហូរច្រោះផ្ទៃខាងលើបណ្តាលមកពីទឹកជំនន់ និង ការជ្រាបចូលទឹកប្រៃ<br>- ការបំផ្លាញដើមកោងកាង | - រៀបចំនិងអនុវត្តកម្មវិធីស្តារតំបន់ឆ្នេរឡើងវិញ<br>- បង្កើតនិងអនុវត្តការគ្រប់គ្រងបរិស្ថាន<br>- បង្កើតឱ្យមានចំណេះដឹង និងយុទ្ធនាការការពារ<br>- ធ្វើឱ្យប្រសើរនូវប្រព័ន្ធអនាម័យដើម្បីគ្រប់គ្រងគុណភាព |
| ជម្រុញឱ្យទទួលបាននិងផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធនិងសេវាសុខភាពមូលដ្ឋាន | ហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មមិនគ្រប់គ្រាន់ | - ប្រើប្រាស់ប្រភពទឹកមិនមានសុវត្ថិភាព និងជម្រើសប្រើប្រាស់បង្គន់រណ្តៅកាន់តែច្រើន<br>- កង្វះខាតនូវរោងចក្រប្រមូលសំណល់រឹងនិងប្រសិទ្ធភាព ប្រតិបត្តិការនៅទាប | - លើកទឹកចិត្តឱ្យមានការបង្កើតផនការអនាម័យ និងទឹកតាមសហគមន៍<br>- ជម្រុញឱ្យមានការចូលរួមពីវិស័យឯកជនក្នុងការគ្រប់គ្រងសំណល់រឹង<br>- គាំទ្រនូវការបង្កើតគំនិតកែឆ្នៃឡើងវិញ |

តាមរយៈកិច្ចដំណើរការរៀបចំផែនការនេះ យើងអាចដឹងពីកង្វះខាតព័ត៌មាន និងតម្រូវការសម្រាប់ការសិក្សាបន្ថែមទៀតផងដែរ។

យុទ្ធសាស្ត្រគឺជាធាតុមួយក្នុងចំណោមធាតុទាំងបួន(ទូរលេខខាងក្រោម)។ **ទី១.** គោលដៅ **ទី២.** យុទ្ធសាស្ត្រ និងមធ្យោបាយបង្ហាញពីធនធាន **ទី៣.** តាក់ទិច និងមធ្យោបាយដែលបានប្រើប្រាស់ និងផ្សព្វផ្សាយ និង **ទី៤.** ធនធានខ្លួនឯងតែម្តង។ ដូច្នេះយុទ្ធសាស្ត្រ និងសកម្មភាពបានបំពេញគម្លាតរវាងគ្នានិងគ្នា។




*ចំណុចសំខាន់នៃយុទ្ធសាស្ត្រ*

ការរៀបចំយុទ្ធសាស្ត្រមិនត្រូវការពេលវេលាច្រើនដូចការរៀបចំគម្រោងនោះទេ។ ហេតុដូចនេះ វាមានសារៈសំខាន់បំផុតក្នុងការបង្កើតយុទ្ធសាស្ត្រតាមរបៀបមួយដែលមិនធ្វើឱ្យមានន័យដូចជាគម្រោងនោះទេ។ ចូរប្រៀបធៀបប្រយោគទាំងពីរនេះ:

- ចូរប្រាកដថាសកម្មភាពសេដ្ឋកិច្ចផ្អែកលើធនធានក្នុងតំបន់មួយ និងការវិនិយោគទុនពីបរទេសដើម្បីនិរន្តរភាពសេដ្ឋកិច្ចរយៈពេលយូរដោយមិនធ្វើឱ្យអន្តរាយដោយសារការកើនឡើងខ្លាំងនូវវិនិយោគបរទេសនៅក្រៅទីក្រុង។
- ចូរបង្កើតមជ្ឈមណ្ឌលគាំទ្រជំនួញខ្នាតតូចមួយដើម្បីលើកទឹកចិត្តឱ្យមានការបង្កើត និងរីកលូតលាស់បន្ថែមទៀតដល់ក្រុមហ៊ុនមួយចំនួនដែលផ្អែកលើធនធានក្នុងស្រុក។

**ទីមួយ**គឺជាយុទ្ធសាស្ត្រមួយសម្រាប់និរន្តរភាពសេដ្ឋកិច្ចរយៈពេលវែងដែលទទួលរងផលប៉ះពាល់ត្រឹមកម្រិតមួយពីផលប៉ះពាល់នៃការបណ្តាក់ទុនពីបរទេស។ **ទីពីរ**គឺជាគម្រោងមួយសូម្បីតែវាស្របជាមួយយុទ្ធសាស្ត្រនេះក៏ដោយវាមិនមែនជាយុទ្ធសាស្ត្រមួយនោះទេ។

យុទ្ធសាស្ត្រខ្លះជួយបង្កើតឱ្យមានទិសដៅរយៈពេលខ្លីហើយដែលគោលដៅនេះបង្កើតបានជាមូលដ្ឋានគ្រឹះនៃកម្មវិធីអនុវត្តដែលបានបង្ហាញបន្ថែមទៀតនៅក្នុងឯកសារនេះ។

ឧទហរណ៍សម្រាប់ទិសដៅរយៈពេលខ្លីសម្រាប់រយៈពេលប្រាំឆ្នាំលើកដំបូងការអភិវឌ្ឍដែលបានគ្រោងទុកនឹងត្រូវបានណែនាំដោយទិសដៅជាក់លាក់មួយចំនួនៈ

- ផ្តល់ជាគោលការណ៍កាត់បន្ថយការបំពុលបរិស្ថាននាពេលបច្ចុប្បន្ននៅតាមស្រុក និងនៅតំបន់ជុំវិញខ្លួនសម្រាប់ការការពារតំបន់ឆ្នេរ និងធនធាននៅទីនោះ។
- ធ្វើឱ្យជីវិតរស់នៅរបស់ប្រជាជនកាន់តែប្រសើរដោយផ្សព្វផ្សាយពីសកម្មភាពបរិស្ថានបរិសុទ្ធនិងការបរិភោគទឹកស្អាតមានអនាម័យក្នុងរយៈពេលប្រាំឆ្នាំបន្ទាប់។
- លើកកម្ពស់គោលគំនិតវិនិយោគសាធារណៈនិងឯកជនតាមរយៈផលិតផល និងការកាត់បន្ថយភាពក្រីក្រ។

**កិច្ចការទី៤: កំណត់នូវតំបន់ និងប្រធានបទសំខាន់ៗសម្រាប់ការសិក្សាស្វែងយល់បន្ថែម**

ការចងក្រងនូវឯកសារត្រួតពិនិត្យបច្ចេកទេសភ្លាមៗ ការពិគ្រោះយោបល់អំពីចក្ខុវិស័យ និងធនធាន និង ការកំណត់អាទិភាពនានានឹងនាំទៅរកការសម្រេចចិត្តថាតើត្រូវសិក្សាអ្វីឱ្យបានលំអិតបន្ថែមទៀតៈ

- ចន្លោះប្រហោងព័ត៌មានសំខាន់ៗត្រូវបានកំណត់នៅក្នុងការត្រួតពិនិត្យបច្ចេកទេសភ្លាមៗ
- ប្រភេទវិស័យដែលគួរទទួលបានអាទិភាពក្នុងកម្មវិធីអនុវត្តន៍ ប៉ុន្តែចំពោះអ្វីដែលត្រូវការកាន់តែលំអិតជាងនេះទៀត
- ប្រភេទអន្តរវិស័យដែលគួរដោះស្រាយមានដូចជា អភិបាលកិច្ច (ឧ. បញ្ហាដូចជា ការអនុវត្តបទបញ្ញត្តិបរិស្ថាន) តុល្យភាពយេនឌ័រក្នុងការប្រើប្រាស់ប្រភពធនធាន ការកាត់បន្ថយភាពក្រីក្រ ហានិភ័យ និងភាពងាយរងគ្រោះ ជម្រើសបន្សុំា និងផលប៉ះពាល់ពីប្រែប្រួលអាកាសធាតុ។

ការសិក្សាគោលអាចត្រូវបានរៀបចំឡើងតាមរបៀបជាច្រើនដោយយោងទៅលើប្រធានបទនីមួយៗហើយវាជាការចាំបាច់ដែលត្រូវចាត់ចែងការងារនីមួយៗទៅតាមអង្គការសមស្របនិងដោយការទទួលខុសត្រូវប៉ុន្តែត្រូវតែបង្កើតក្រុមគោលមួយដោយរួមមានសមាសភាពពីអ្នកពាក់ព័ន្ធទាំងអស់មានវត្តមានកំឡុងពេលកិច្ចពិគ្រោះយោបល់លើកដំបូងនិងផ្នែកមួយនៃជំរើសប្រធានបទគោលដៅ។ តួនាទីក្រុមនេះមានពីរ គឺៈ

- ដាក់នូវចំណុចសំពាធមួយដែលការងារនេះអាចធ្វើបាន និងទាន់ពេលវេលាត្រឹមត្រូវ
- ធានាថាគោលបំណងនៃជំរើសដំបូងត្រូវបន្តធ្វើ និងថាការសិក្សានោះមិនបានលួចដោយអ្នកខាងក្រៅ។ ក្នុងន័យនេះ

ការផ្លាស់ប្តូរជាមូលដ្ឋាននៅក្នុងការកំណត់ទិសដៅឬក៏ការបញ្ជាក់ណាមួយត្រូវបានឯកភាពដោយក្រុមគោលនោះ។ ជាទូទៅ ការសិក្សាតាមវិស័យមួយៗមានចំណុចប្រសព្វទាក់ទងគ្នា។ ប្រសិនបើការវិភាគលើស្ថានការណ៍បច្ចុប្បន្ន និងការព្រមព្រាងគ្នានៅក្នុងសិក្ខាសាលាបង្ហាញថា ទឹកស្អាត និងអនាម័យគឺជាផ្នែកអាទិភាពការសិក្សាស៊ីជម្រៅជាច្រើននឹងអង្កេត

មើលឱ្យបានកាន់តែលំអិតបន្ថែមទៀតលើទំហំនៃស្ថានការណ៍ និងជម្រើសសម្រាប់បំពេញរាល់តម្រូវការនេះ។ វានឹងមានជាប់ទាក់ទងទៅនឹងការកំណត់យុទ្ធសាស្ត្រផងដែរដែលនឹងត្រូវអនុវត្តឱ្យប្រាកដថាមិនត្រឹមតែបំពេញតម្រូវការប៉ុណ្ណោះទេ ប៉ុន្តែរួមទាំងគោលដៅផ្សេងៗទៀតផងដែរដូចជាការរំពឹងទុកចំពោះការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព។ ជាក់ស្តែងវាអាចពាក់ព័ន្ធទៅនឹងការកសាងចំណេះដឹងក្នុងការថែរក្សាទឹកទុកប្រើប្រាស់ និង វិធានការដើម្បីធានាថា ទឹកមិនត្រូវប្រើប្រាស់ដោយខ្ជះខ្ជាយនោះទេ។ បើទោះបីជា ការសិក្សាផ្តោតលើវិស័យតែមួយ ប៉ុន្តែវិស័យជាច្រើនដែលមានការពាក់ព័ន្ធត្រូវតែពិចារណាផងដែរ។ ការសិក្សាដែលមានលក្ខណៈអន្តរវិស័យគឺមានភាពខុសៗគ្នាតាមលក្ខណៈរបស់វា។ ពួកគេដោះស្រាយបញ្ហាដែលរកឃើញតាមវិស័យផ្សេងគ្នាជាច្រើននៅពេលដំណាលគ្នា។ វាប្រហែលជាមានប្រភេទជាច្រើនដែលមានលក្ខណៈអន្តរវិស័យ។ បញ្ហាមួយចំនួនត្រូវបានបង្ហាញនៅទីនេះ:

- ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន
- អភិបាលកិច្ចល្អ
- ការការពារបរិស្ថាន ការធ្វើឱ្យបរិស្ថានបានប្រសើរឡើង
- ពង្រីកទីប្រជុំជននៅតាមតំបន់ឆ្នេរ (ដោយរួមបញ្ចូលរាល់ទិដ្ឋភាពនៃការផ្លាស់ប្តូរ និងការរីកចំរើន)
- ការកាត់បន្ថយភាពក្រីក្រ

ផ្នែកអន្តរវិស័យអាចបង្ហាញនូវគោលការណ៍ ឬការអនុវត្តរួម។ អភិបាលកិច្ចល្អ និង តុល្យភាពយេនឌ័រគឺជាឧទាហរណ៍ពីរ ឬក៏ប្រធានបទនេះអាចបង្ហាញពីគោលដៅនានាដែលវិស័យជាច្រើនគួរតែចែករំលែកនូវទំនួលខុសត្រូវសំរាប់ការសម្រេចលទ្ធផលដូចជា ការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងការលើកកម្ពស់បរិស្ថាន។ មាតិកាសំរាប់ការសិក្សាមួយចំនួនគួរតែឆ្លុះបញ្ចាំងពីរបាយការណ៍បញ្ហាតាមផ្នែកដូចដែលបានបង្ហាញក្នុងប្រអប់បន្ទាប់។ ទំរង់របាយការណ៍ជាក់លាក់នេះត្រូវបានរៀបចំដើម្បីឱ្យស្របនឹងការអនុវត្តកម្មវិធី។ ក្នុងករណីខ្លះ គោលបំណងនៃការសិក្សាអាចផ្តល់នូវព័ត៌មានកាន់តែជាក់លាក់នៃស្ថានការណ៍បច្ចុប្បន្ន និង ហេតុដូចនេះវាមិនតម្រូវឱ្យមានចំណុចបិចុងក្រោយដែលបង្ហាញនៅក្នុងគំរូនេះ។

## កិច្ចការទី៥ អនុវត្តការសិក្សាលំអិត

បញ្ជីនៃតំបន់ ឬ ប្រធានបទគោលដៅដែលគួតែធ្វើការសិក្សាឱ្យកាន់តែលំអិតថែមទៀតនោះមានខុសគ្នា ពីករណីមួយទៅករណីមួយទៀត ដោយផ្អែកលើកត្តាអាទិភាពនានាសម្រាប់រយៈពេលធ្វើផែនការប្រាំឆ្នាំខាងមុខ។ ទោះបីជាយ៉ាងនេះក៏ដោយយើងគួរបង្កើតឱ្យមានរចនាសម្ព័ន្ធរួមមួយចំនួនចំពោះការរាយការណ៍អំពីលទ្ធផលនោះក្នុងគោលបំណងដើម្បីធ្វើឱ្យងាយស្រួលនូវដំណើរការនៃការបញ្ចូលការរកឃើញទៅក្នុងការធ្វើផែនការបែងចែកតំបន់ប្រើប្រាស់និងកម្មវិធីអនុវត្តការងារ។

សមាសធាតុរួមនៃរបាយការណ៍សិក្សាគោលមានបង្ហាញនៅក្នុងប្រអប់នេះ។ ឧទាហរណ៍មួយចំនួនអំពីការសិក្សាពិសេស១មាននៅក្នុងឧបសម្ព័ន្ធទី៦ និងទី៧។

***សមាសធាតុគំរូនៃរបាយការណ៍បញ្ហាចម្រុះ៖***

- ស្ថានភាពនៃបញ្ហា
- ដើមហេតុ មូលហេតុ និងផលប៉ះពាល់ (មែកធាងបញ្ហា, "ភាពជាម្ចាស់", និងចំណុចអាទិភាព)
- ស្ថានការណ៍បច្ចុប្បន្ន (ចំណុចគោល) និន្នាការកំពុងបន្ត និងការអនុវត្តនៅពេលអនាគតដោយគ្មានសកម្មភាពរួមបញ្ចូលទាំងទិដ្ឋភាពនៃការបែងចែកតំបន់
- មាត្រដ្ឋាន និងការបែងចែកផលប៉ះពាល់
- គោលនយោបាយ គំរូ និងបទដ្ឋានមានស្រាប់ដែលមានផលប៉ះពាល់ដល់បញ្ហាទាំងនោះ
- គោលដៅរយៈពេលវែង(១០-២០ឆ្នាំ) និងគោលបំណងរយៈពេលខ្លី (៣-៥ឆ្នាំ)
- ស្នើឱ្យមានគោលការណ៍ និងយុទ្ធសាស្ត្រសម្រាប់ដោះស្រាយបញ្ហា និងយន្តការសម្រាប់ការអនុវត្ត
- ការកំណត់លក្ខខណ្ឌទុកជាមុន និងការប៉ាន់ស្មានដែលជាមូលដ្ឋានគ្រឹះដើម្បីភាពជោគជ័យ ហានិភ័យនៃការប៉ាន់ស្មានទាំងនេះកំពុងបរាជ័យ ឬការកំណត់លក្ខខណ្ឌទុកជាមុននេះមិនត្រូវបានបំពេញ
- តម្រូវការធនធាន៖ការប៉ាន់ស្មានត្រួស១លើតម្លៃហិរញ្ញវត្ថុទាំងធនធានមនុស្សតាមប្រភេទធនធានក្នុងតំបន់ឬតាមផ្នែក និងរូបវន្ត
- តម្រូវការស្ថាប័ន៖ អាជ្ញាធមិពាក់ព័ន្ធត្រូវការកិច្ចសហការ និងការសម្របសម្រួល ការបែងចែកវិលែកនូវទំនួលខុសត្រូវ និងការកំណត់នូវយុទ្ធសាស្ត្រចំបង១ជាប់ទាក់ទងនឹងវិស័យឯកជន និងសង្គមស៊ីវិល
- ការបោះជំហានដ៏ទូលំទូលាយសម្រាប់ការអនុវត្ត

ប្រយោគក្នុងអក្សរទ្រេតគួររៀបរាប់ត្រួស១ ដោយមានសូចនាករ និងពេលកំណត់។ ពួកគេនឹងចងក្រងឱ្យកាន់តែលម្អិតបន្ថែមទៀតនៅពេលក្រោយនៅពេលដែលយុទ្ធសាស្ត្រត្រូវបានអនុម័ត។ ជារឿយ១ សូចនាករនៃតម្លៃនិងតម្រូវការធនធានមួយចំនួនមានសារៈសំខាន់ណាស់ក្នុងការផ្តល់នូវការអនុម័តលើគោលការណ៍នេះ។

## កិច្ចការទី៦ ធ្វើការវាយតម្លៃលើលទ្ធផលដែលរកឃើញ

សម្ភារៈមួយចំនួនខាងក្រោមគួរតែមានដូចជាៈ

- ការត្រួតពិនិត្យបែបរហ័សនូវស្ថានភាពបច្ចុប្បន្នរួមមានៈ
    - ○ ការវាយតម្លៃពីគម្លាតព័ត៌មានដោយកំណត់អាទិភាពដើម្បីបំពេញចំណុចទាំងនោះទាំងសម្រាប់ជាមូលដ្ឋាន់រយៈពេលអនុវត្តលើកដំបូង ទាំងសម្រាប់វដ្តផែនការនៅពេលអនាគត
    - ○ ស្ថាប័ន និងរចនាសម្ព័ន្ធគ្រប់គ្រង (ច្បាប់ និងបទបញ្ជា)
- សេចក្តីប្រកាសអំពីចក្ខុវិស័យរួម និងគោលដៅរយៈពេលវែងសំរាប់តំបន់នោះ - ទាំងនេះគួរផ្តល់នូវក្របខណ្ឌការងារទូលំទូលាយសម្រាប់ការងាររយៈពេលវែង
- អាទិភាពរយៈពេលខ្លី គួរផ្តល់ការយកចិត្តទុកដាក់សម្រាប់៥ឆ្នាំដំបូង និងដែលនាំឱ្យការសិក្សាគោលកាន់តែលំអិត
- ការចុះបញ្ជីដំបូងនូវ ការប្រឈម ឧបសគ្គរាំង និងបញ្ហាដែលទាមទារឱ្យមានការដោះស្រាយក្នុងផែនការនិងកម្មវិធីអនុវត្ត
- លទ្ធផលនៃការសិក្សាគោលរួមមានៈ
    - ○ ការវាយតម្លៃមុខសញ្ញាគ្រោះថ្នាក់ ហានិភ័យ និងការឆ្លើយតបថ្មីមួយ ឬដែលត្រូវបានកែសម្រួល
    - ○ ការវាយតម្លៃសង្គម សេដ្ឋកិច្ច ភាពងាយរងគ្រោះរបស់ស្ថាប័ន និងភាពធន់ថ្មីមួយ ឬដែលត្រូវបានកែសម្រួល
    - ○ ការវាយតម្លៃបញ្ហាជាប់ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុដូចដែលមាននៅពេលនេះថ្មីមួយ ឬដែលត្រូវ បានកែសម្រួល
    - ○ ការវាយតម្លៃប្រព័ន្ធអេកូស៊ីស្ទែម និងធនធានធម្មជាតិក្នុងតំបន់ថ្មីមួយ ឬដែលត្រូវបានកែសម្រួល។

ឯកសារ និងផែនទីទាំងនេះ ផ្តល់នូវព័ត៌មានសង្ខេបដែលបង្ហាញពីស្ថានភាពបច្ចុប្បន្ន។ តាមការត្រួតពិនិត្យមើលឯកសារនេះផ្តល់នូវព័ត៌មានមូលដ្ឋានប្រៀបនឹងការផ្លាស់ប្តូរណាដែលត្រូវវាស់វែងនោះដោយមិនមានមធ្យោបាយផ្លូវកាត់ណាមួយដើម្បីសរសេរសង្ខេបឯកសារនោះទេ។ ជាមួយគ្នានោះដែរ មានមធ្យោបាយផ្សេងៗក្នុងការរៀបចំព័ត៌មានប៉ុន្តែមិនមានណាមួយត្រូវ **(Right)** នោះទេ។ ទោះបីជាយ៉ាងណាក៏ដោយមានគំនិតមួយចំនួនត្រូវពិចារណាក្នុងការរៀបចំឯកសារស្តីពីស្ថានភាពបច្ចុប្បន្នរួមមានៈ

- ចូរពិចារណានូវការរៀបចំជាពីរប្រភេទៈ ផ្នែកទី១សំរាប់បុគ្គលិកបច្ចេកទេស និងអ្នកប្រឹក្សា និងផ្នែកទី២សំរាប់សាធារណជន និងអ្នកនយោបាយ។ នៅក្នុផ្នែកទី២គួរឱ្យខ្លីជាង ការរៀបចំឱ្យបានល្អដោយមានដ្យាក្រាម និង

រូបភាព។ ផ្នែកបច្ចេកទេសអាចជាទម្រង់អត្ថបទសំខាន់មួយដោយភ្ជាប់ជាមួយនូវឧបសម្ព័ន្ធមួយចំនួន និង សេចក្តីសង្ខេប។

- ចូរគូសបញ្ជាក់អំពីការចូលរួមដោយអ្នកពាក់ព័ន្ធផ្សេងៗដោយសារតែការចូលរួមនេះនឹងបង្កើនការចាប់អារម្មណ៍ពីអ្នកអានហើយយើងមានសិទ្ធិផ្តល់នូវឥណទាន
- ចូរគូសបញ្ជាក់អំពីចក្ខុវិស័យនិងគោលដៅរយៈពេលវែងតំបន់អាទិភាពនិងបញ្ហាសំខាន់ៗដែលនឹងត្រូវដោះស្រាយក្នុងដំណាក់កាលអនុវត្តន៏លើកដំបូង។ សូមឱ្យប្រាកដថា បញ្ហាទាំងអស់នោះត្រូវបានបរិយាយទាក់ទងទៅនឹងចក្ខុវិស័យនេះ។ប្រការនេះនឹងផ្តល់នូវចំណាប់អារម្មណ៏ដែលថាការដោះស្រាយបញ្ហាសំខាន់ៗមិនមែនបញ្ចប់ដោយខ្លួនឯងនោះទេ ប៉ុន្តែវាជាផ្នែកមួយនៃដំណើរការឆ្ពោះទៅរកអនាគត មួយដែលចង់បាន។

សូមពន្យល់ពីជំហានបន្ទាប់នៅក្នុងដំណើរការនេះ និងថាតើខ្លឹមសារដែលមាននៅក្នុងរបាយការណ៏នេះនឹងត្រូវយកទៅប្រើប្រាស់ដោយរបៀបណាដើម្បីពង្រាងផែនការប្រើប្រាស់តំបន់ឆ្នេរ និងដើម្បីរៀបចំកម្មវិធីអនុវត្តន៏មួយ។

## បញ្ហាពាក់ព័ន្ធលើការអនុវត្តវិធីសាស្ត្រផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមដោយអនុវត្តន៏នូវផែនការសមុទ្រ និងដីគោកចម្រុះ និងការបញ្ជ្រាបនូវការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុនៅក្នុងដំណាក់កាលទី២

ក្នុងដំណាក់កាលនេះ បញ្ហាពាក់ព័ន្ធក្នុងការបញ្ចូលវិធីសាស្រ្តថ្មីៗគឺ:

▪ ដើម្បីធានាថា មានការយកចិត្តទុកដាក់ពិសេសក្នុងការត្រួតពិនិត្យមើលស្ថានភាពប្រព័ន្ធអេកូស៊ីស្ទែម និងទីជម្រកសុខភាពរបស់ពួកគេ ការប្រើប្រាស់របស់ពួកគេឱ្យមាននិរន្តរភាពរយៈពេលយូរនៅក្រោមលក្ខខណ្ឌនិងរបបគ្រប់គ្រងបច្ចុប្បន្ន។ ការយកចិត្តទុកដាក់នេះត្រូវតែពន្យល់ទាំងនៅក្នុងការត្រួតពិនិត្យភ្លាមៗ និងការរៀបរាប់ដែលធ្វើឡើងដោយអ្នកជំនាញ និងនៅក្នុងការពិភាក្សាស្តីពីធនធាន គោលដៅ បញ្ហា និងការគម្រោមកំហែងនៅក្នុងកិច្ចប្រជុំអ្នកពាក់ព័ន្ធ។ យើងត្រូវការយកចិត្តទុកដាក់ជាពិសេសដើម្បីធានាថាអ្នកជំនាញផ្នែកសមុទ្រ និងអ្នកប្រើប្រាស់បានចូលរួមនៅក្នុងការអនុវត្តលំហាត់ទាំងនេះ។

▪ ដើម្បីប្រមូលព័តិមានដែលមានស្រាប់ ឬធ្វើការសិក្សាពិសេស ទៅលើសេវាកម្មនានាដែលផ្តល់ដោយប្រព័ន្ធអេកូស៊ីស្ទែមធម្មជាតិដល់សង្គមមនុស្ស និងដើម្បីកំណត់តម្លៃចំពោះមុខងារទាំងនេះ។ ដំណើរការនេះនឹងគាំទ្រលើទល្ហីករណ៏ចំពោះការអភិរក្ស និងការពង្រឹងប្រព័ន្ធស្តីពីកម្រិតនិរន្តរភាពមួយ។ ប្រសិនបើការសិក្សា នេះមិនអាចធ្វើទៅបានក្នុងពេលវេលាកំណត់នៃកម្មវិធីការងាររៀបចំផែនការទេ ពួកគេគួរតែប្រកាន់យកនូវកម្មវិធីអនុវត្តន៏រយៈពេល៣-៥ឆ្នាំ

ដំបូងដើម្បីធានាថាលទ្ធផលនឹងមានសម្រាប់វដ្តនៃការធ្វើផែនការបន្ទាប់។ ផែនការត្រួតពិនិត្យបរិស្ថានមួយដែលបានបញ្ចូលសូចនាករប្រព័ន្ធអេកូស៊ីស្ទែមគួរតែបញ្ជ្រាបទៅក្នុងកម្មវិធីអនុវត្តន៍នេះ។ ការរៀបចំប្រព័ន្ធត្រួតពិនិត្យសមស្របមួយគួរតែអាចធ្វើបានក្នុងក្របខណ្ឌពេលវេលានៃការធ្វើផែនការ។

- ការយកចិត្តទុកដាក់ជាពិសេសនឹងត្រូវការជាចាំបាច់ដើម្បីបញ្ចូលអ្នកប្រើប្រាស់ធនធានសមុទ្រ និងផ្សារភ្ជាប់សកម្មភាពរបស់ពួកគេចំពោះការប្រើប្រាស់ធនធានលើដី។ វិវាទក្នុងចំណោមអ្នកប្រើប្រាស់ដែនសមុទ្រ និងរវាងក្រុមអ្នកប្រើប្រាស់ដូចគ្នានិងផលប្រយោជន៍លើដែនដីចាំបាច់ត្រូវតែគិតគូរ និង និងកំណត់ឱ្យបានត្រឹមត្រូវដើម្បីឱ្យយុទ្ធសាស្ត្រសម្រាប់ការដោះស្រាយវិវាទអាចរៀបចំឡើងបាន។ ការប្រើប្រាស់ទាំងអស់នេះផ្សារភ្ជាប់ទៅនឹងឌីណាម៉ិចប្រព័ន្ធអេកូស៊ីស្ទែមផងដែរដូចនេះ ក្នុងករណីខ្លះ សមត្ថភាពផ្ទុកបានរបស់ប្រព័ន្ធអេកូស៊ីស្ទែមស្ថិតក្រោមសំពាធប្រភេទផ្សេងៗគ្នា និងកម្រិតសំពាធត្រូវការការវាយតម្លៃដើម្បីកំណត់ព្រំដែន និងលក្ខខណ្ឌប្រើប្រាស់តាមរយៈប្រព័ន្ធបែងចែកតំបន់។ ឧទាហរណ៍គឺត្រូវសិក្សាពីទំនាក់ទំនងអេកូឡូស៊ី (ដោយនិយាយជាពិសេសចំពោះប្រភេទត្រី) រវាងដើមកោងកាង ស្មៅសមុទ្រ ផ្កាថ្មប៉ប្រះទឹកដោយសារតែពួកគេមានទំនាក់ទំនងក្នុងវិស័យជលផលសិប្បនិម្មិត (ដោយរួមទាំងវិធីសាស្ត្រ) និងវិស័យទេសចរណ៍ (ការមុជទឹក ការជិះទូក ការទស្សនាស្វែងយល់ពីដើមកោងកាង)។ ការសិក្សាទាំងនេះនឹងផ្តល់នូវធាតុចូលក្នុងការធ្វើផែនការគ្រប់គ្រងធនធានផ្សេងៗ ប៉ុន្តែការសិក្សានេះគួរសង្កត់ធ្ងន់ផងដែរលើផែនការបែងចែកតំបន់ឆ្នេរ និងសមុទ្រ និងលក្ខខណ្ឌប្រើប្រាស់។

- ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុទាមទារឱ្យមានការយកចិត្តទុកដាក់ជាក់លាក់ដោយសារតែវាមានឥទ្ធិពលដល់លក្ខណៈ និងប្រព័ន្ធអេកូស៊ីស្ទែមរូបវន្ត។ បើទោះបីជាសកម្មភាពកាត់បន្ថយផលប៉ះពាល់មានសារៈសំខាន់យ៉ាងណាក៏ដោយ កិច្ចប្រឹងប្រែងក្នុងតំបន់នឹងជួយដោះស្រាយបានតិចតួចចំពោះឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ហើយជាមួយគ្នានោះដែរពួកគេចូលរួមចំណែកក្នុងកិច្ចការបន្សាំ។ ដោយសិក្សាពីផលប៉ះពាល់ការប្រែប្រួលអាកាសធាតុដែលអាចមាននោះនឹងនាំឱ្យមានត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់នូវវិធានការឆ្លើយតបនិងយុទ្ធសាស្ត្របន្សាំនៅក្នុងដំណាក់កាលបន្ទាប់នៃដំណើរការរៀបចំផែនការនេះ។

- ដើម្បីបញ្ចូលនូវការធ្វើផែនទីមុខសញ្ញាគ្រោះថ្នាក់ និងការវាយតម្លៃហានិភ័យលើកដំបូងដែលរួមមាន មុខសញ្ញាគ្រោះថ្នាក់ដោយសារធម្មជាតិ និងមនុស្សនិងហានិភ័យចំពោះប្រព័ន្ធអេកូស៊ីស្ទែម សុខភាពមនុស្ស ហេដ្ឋារចនា សម្ព័ន្ធសេដ្ឋកិច្ច និង សង្គម។ ការសិក្សាទាំងនេះគួរបញ្ចូលនូវការកំណត់ និងការវាយតម្លៃក្រុមដែលងាយរងគ្រោះ ដោយពិពណ៌នាថាតើពួកគេនៅកន្លែងណា លក្ខណៈធម្មជាតិ និងកម្រិតនៃភាពងាយរងគ្រោះរបស់ពួកគេ។ ការពិពណ៌នានេះគួរធ្វើឡើងតាមរបៀបមួយដែលអាចផ្តល់នូវវិធានការព្យាបាលសមហេតុសមផលហើយដែលគួរតែធ្វើឡើងជាមួយក្រុមងាយរងគ្រោះរបស់ពួកគេផ្ទាល់តែម្តង។ នៅគ្រប់ករណីទាំងអស់យើងត្រូវប្រកាន់យកវិធីសាស្ត្របែបអភិរក្ស ដោយសន្មត់ថាសេណារីយ៉ូដែល

អាក្រក់បំផុតនឹងកើតឡើងនិងត្រូវត្រៀមខ្លួនសម្រាប់សំរាប់ទប់ទល់នឹងពួកគេ។ ជាថ្មីម្តងទៀត ប្រសិនបើការសិក្សានេះមិនអាចធ្វើទៅបានក្នុងរង្វង់ពេលវេលានៃការរៀបចំផែនការនោះទេ ការងារទាំងនេះគួរតែដាក់បញ្ចូលក្នុងកម្មវិធីអនុវត្តន៍ដើម្បីឱ្យលទ្ធផលទាំងនេះអាចប្រើប្រាស់បានសំរាប់វដ្តនៃការធ្វើផែនការបន្តបន្ទាប់។ យើងគួរតែធ្វើការត្រួតពិនិត្យភ្លាមៗចំពោះមុខសញ្ញាគ្រោះថ្នាក់ ហានិភ័យ និងភាពងាយរងគ្រោះក្នុងក្របខណ្ឌពេលវេលាធ្វើផែនការ។

**លទ្ធផលទទួលបានពីដំណាក់កាលនេះ**

នៅចុងបញ្ចប់នៃជំហាននេះ អ្នកគួរតែទទួលបាននូវលទ្ធផល និងទិន្នផលដូចតទៅ:

- ឯកសារត្រួតពិនិត្យបច្ចេកវិទ្យាភ្លាមៗដែលបានចងក្រងមួយដែលអាចជាក្នុងទម្រង់ប្រូហ្វាលតាមវិស័យផ្សេងៗ ហើយផែនទីគួរតែប្រើប្រាស់នៅកន្លែងណាដែលអាចប្រើបានដើម្បីបង្ហាញពីលក្ខណៈពិសេសរបស់វា។
- ការចងក្រងនូវធនធានទាំងអាចរាប់បាននិងមិនអាចរាប់បានដែលកើតឡើងពីការត្រួតពិនិត្យបច្ចេកវិទ្យាភ្លាមៗ និងដំណើរការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធហើយគួរតែរៀបចំផែនទីការធនធានទាំងនេះឱ្យបានច្រើនបំផុតតាមដែលអាចធ្វើបាន។
- មានចក្ខុវិស័យច្បាស់លាស់នៅតំបន់ត្រូវធ្វើផែនការ
- បញ្ជាក់ច្បាស់នូវគោលដៅរយៈពេលយូរសម្រាប់តំបន់នេះដោយផ្អែកលើ និងស្របជាមួយចក្ខុវិស័យនេះ។
- គោលបំណងរយៈពេលខ្លីដើម្បីសម្រេចបានក្នុងរយៈពេល៣–៥ឆ្នាំខាងមុខនេះដោយផ្អែកលើទស្សនៈ និងគោលដៅ និងចក្ខុវិស័យរយៈពេលវែង
- ការចុះបញ្ជីនូវវិស័យអាទិភាព និងតំបន់សម្រាប់ការអង្កេតលំអិតដោយឆ្លុះបញ្ចាំងពីបញ្ហាដែលត្រូវដោះស្រាយក្នុងរយៈពេល៣–៥ឆ្នាំខាងមុខនេះ
- លទ្ធផលនៃការអង្កេតតំបន់ និងវិស័យសំខាន់ៗរួមទាំងជម្រើសយុទ្ធសាស្ត្រសម្រាប់សកម្មភាពនៅពេលអនាគត និងប្រហែលជាមានការសិក្សាពិសេសៗជាច្រើន ប៉ុន្តែវិស័យពិសេសៗទាំងនេះគួរបញ្ចូលឱ្យបានតិចបំផុតដូចជា:
    - ការវាយតម្លៃប្រព័ន្ធអេកូស៊ីស្ទែមក្នុងតំបន់ ស្ថានភាព និងតម្លៃសេវាកម្មដែលពួកគេផ្តល់ឱ្យ
    - ការវាយតម្លៃស្ថានភាពគ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់បច្ចុប្បន្ន និងភាពងាយរងគ្រោះដោយមានផែនទីបង្ហាញពីតំបន់ដែលប្រកបដោយគ្រោះថ្នាក់ ការប្រឈមហានិភ័យ ព្រមទាំងកម្រិតភាពងាយ រងគ្រោះ
    - ការវាយតម្លៃផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដ៏មានសក្តានុពលដោយពិពណ៌នា និងរៀបចំតាមប្រភេទ ដីក្រេ និងទីតាំង

- ការចងក្រងពីស្ថានភាពបច្ចុប្បន្នចុងក្រោយមួយដែលជាមូលដ្ឋានគ្រឹះសម្រាប់ពេលអនាគត ប៉ុន្តែក៏មានការបង្ហាញពីកាលានុវត្តភាព ឧបសគ្គនិងបញ្ហាសំខាន់ៗដែលត្រូវការការយកចិត្តទុកដាក់ និងជម្រើសយុទ្ធសាស្ត្រ ។ ជម្រើសនេះមានពីរឯកសារ:
    - ○ ឯកសារបច្ចេកទេសពេញលេញ និង
    - ○ ឯកសារសង្ខេប

***អ្នកអាចប្រើប្រាស់កម្រងសំនួរដូចតទៅ:***

- តើអ្នកមានបញ្ជីធនធានរូបវន្ត អេកូឡូស៊ី សង្គម វប្បធម៌ មនុស្ស និងធនធានសេដ្ឋកិច្ចសម្រាប់តំបន់នោះទេ និងកន្លែងដែលផែនទីបង្ហាញពីទីកន្លែងធនធានទាំងអស់នោះទេ
- តើអ្នកមានព័ត៌មានច្បាស់លាស់ស្តីពីចក្ខុវិស័យរួមសម្រាប់តំបន់នោះដែលពិពណ៌នាពីលក្ខណៈតំបន់ក្នុងរយៈពេលប្រហែល២០ឆ្នាំដែរឬទេ?
- តើអ្នកមានគោលដៅតាមវិស័យរយៈពេលយូរច្បាស់លាស់ (កន្លែងដែលមានអនុវិស័យសមស្រប) ដែលស្របតាមចក្ខុវិស័យនេះទេ?
-តើអ្នកដឹងពីឧបសគ្គនិងការរារាំងដែលត្រូវតែពុះពារដើម្បីសម្រេចគោលដៅនេះទេ?
-តើអ្នកមានយុទ្ធសាស្ត្រអភិរក្ស និងបង្កើននូវធនធានដែលមានស្រាប់ដើម្បីបន្តដោះស្រាយឧបសគ្គ និងការរាំងដែលការគម្រាមកំហែងនាពេលអនាគតទេ?
- តើអ្នកឯកភាពលើការបញ្ហា ចក្ខុវិស័យ គោលដៅរយៈពេលយូរ និង យុទ្ធសាស្ត្រដែរឬទេ?
- តើអ្នកបានកំណត់អាទិភាពច្បាស់លាស់សម្រាប់សកម្មភាពរយៈពេលខ្លីដែលជាមូលដ្ឋានគ្រឹះសម្រាប់កម្មវិធីអនុវត្តន៏ទេ?
- តើអ្នកបានសិក្សាពីស្ថានភាពបច្ចុប្បន្ន តាមរយៈការវាយតម្លៃភ្លាមៗ ឬការស៊ើបអង្កេតដើម្បីដោះស្រាយដូចជា:
    - ○ ប្រព័ន្ធអេកូស៊ីស្ទែម ស្ថានការណ៍ និងសេវាកម្មដែលពួកគេផ្តល់ឱ្យសង្គមមនុស្ស ព្រមទាំងអន្តរទំនាក់ទំនងរបស់វាជាមួយប្រព័ន្ធសង្គម សេដ្ឋកិច្ច និងវប្បធម៌
    - ○ ធនធានសមុទ្រ ស្ថានការណ៍និងការប្រើប្រាស់ និងទំនាក់ទំនងរបស់វាទៅនឹងធនធាននិងសកម្មភាពនៅលើដី
    - ○ មុខសញ្ញាគ្រោះថ្នាក់ដោយសារមនុស្ស និងធម្មជាតិ ហានិភ័យ ការប្រែប្រួលអាកាសធាតុ និងភាពងាយរងគ្រោះដែលកើតឡើងចំពោះពួកគេ?

- តើអ្នកដឹងទេថា ការស៊ើបអង្កេតអ្វីគួរអនុវត្តក្រោមកម្មវិធីអនុវត្តន៍និងការរៀបចំរង្វង់រៀបចំផែនការបន្ទាប់នោះ?

-តើអ្នកមានរបាយការណ៍ស្ថានភាពបច្ចុប្បន្នដែលអាចធ្វើជាមូលដ្ឋានគ្រឹះសម្រាប់ការប្រៀបធៀបនៅពេលអនាគតតាមរយៈការត្រួតពិនិត្យ និងការវាយតម្លៃទេ? តើអ្នកមានរបាយការណ៍នេះជាពីរផ្នែកទេះ ជាឯកសារបច្ចេកទេស និងឯកសារសង្ខេប?

## ជំហានទី៣ ពង្រាងផែនការបែងចែកតំបន់ប្រើប្រាស់

នៅក្នុងផ្នែកនេះពង្រាងផែនការបែងចែកតំបន់ត្រូវបានបង្ហាញដូចខាងក្រោមៈ

- ការកំណត់យុទ្ធសាស្ត្រច្រាំងសមុទ្រជាក់លាក់
- ការបង្កើតនូវវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្របានស្នើឡើងនៅក្នុងការសិក្សាគោល និងកិច្ចពិគ្រោះយោបល់
- ពង្រាងផែនការបែងចែកតំបន់ដាច់ដោយឡែក
- ការប្រើប្រាស់នូវ Set back និងការកំណត់តំបន់។




ដ្យាក្រាមខាងលើបង្ហាញពីភាពខុសគ្នារវាងគំរូផែនការចាស់និងថ្មីក្នុងដំណាក់កាលបង្កើតផែនការ ។ គំរូចាស់ប្រើប្រាស់និន្នាការដែលមានស្រាប់ដើម្បីព្យាករណ៍កំណើនប្រជាជននៅពេលអនាគត បន្ទាប់មកគណនាតម្រូវការដោយយោងតាមតម្រូវការការប្រើប្រាស់ដីធ្លីដោយផ្អែកតាមស្តង់ដា និងគំរូដែលបានផ្តល់ឱ្យ ។ នៅក្នុងគំរូផែនការថ្មី មានការព្យាករណ៍មួយចំនួនដោយផ្អែកលើការវិភាគនិន្នាការ ប៉ុន្តែវិធីសាស្ត្រខាងក្រោមគឺដើម្បីស្វែងរកចក្ខុវិស័យសម្រាប់ពេលអនាគតមិនមែនគ្រាន់តែឆ្លើយតបនឹងផលប៉ះពាល់ "ដែលមិនអាចគ្រប់គ្រងបាននោះទេ" ។ និន្នាការបច្ចុប្បន្នកំពុងប្រើប្រាស់ក្នុងគំរូផែនការថ្មីគឺដើម្បីកែសម្រួលយុទ្ធសាស្ត្រតាមមធ្យោបាយមួយដែលអាចគ្រប់គ្រងបាននៅពេលអនាគត ។ ក្នុងបរិបទនៃការប្រែប្រួលអាសកាសធាតុដែលតាមនិន្នាការនេះ វាមានលក្ខណៈជាសកលនិងហួសពីសមត្ថភាពគ្រប់គ្រងរបស់អាជ្ញាធមិមូលដ្ឋាន ប៉ុន្តែបញ្ហានេះនៅតែ

អាចមានវិធានការដោះស្រាយបានជាពិសេសតាមរយៈវិធានការឆ្លើយតបភ្លាមៗ នេះហើយសកម្មភាពកាត់បន្ថយ និងការបន្សុំា នឹងការប្រែប្រួលអាកាសធាតុគឺឆ្លើយតបនឹងនិន្នាការរយៈពេលវែងដែលមិនអាចគ្រប់គ្រងបាន។

ក្នុងគំរូផែនការថ្មីគឺផ្ដោតការយកចិត្តទុកដាក់សំខាន់ទៅលើជំរើសជាយុទ្ធសាស្ត្រ មិនមែនជាជំរើសបច្ចេកទេសដូចដែលមាននៅក្នុងគំរូផែនការចាស់នោះទេហើយការវាយតម្លៃផលប៉ះពាល់គឺត្រូវអនុវត្តដំបូងគេតាមបែបយុទ្ធសាស្ត្រ។ឯកសារយោងសំរាប់ជំរើសទាំងនេះគឺជាចក្ខុវិស័យមួយដែលត្រូវបានបកស្រាយនៅក្នុងគោលដៅតាមវិស័យរយៈពេលយូរ។ ភាពខុសគ្នាមួយទៀតរវាងគំរូទាំងពីរនេះគឺថាអ្នកពាក់ព័ន្ធទាំងអស់បានផ្ដល់តួនាទីដ៏ធំមួយនៅក្នុងវិធីសាស្ត្រថ្មី។ ពួកគេធ្វើជាមួយអ្នកជំនាញដើម្បីកំណត់ជំរើសយុទ្ធសាស្ត្រនិងកំណត់លក្ខណៈវិនិច្ឆ័យសំរាប់ធ្វើការវាយតម្លៃ។ គោលការណ៍អភិបាលកិច្ចល្អអនុវត្តនៅទីនេះដើម្បីលើកកម្ពស់ការចូលរួម និងតម្លាភាពនៅក្នុងដំណើរការទាំងនេះ។

គោលបំណងការងារមុនៗទាំងអស់គឺដើម្បីកំណត់ថាតើកន្លែងណាដែលសកម្មភាពមួយចំនួនអនុញ្ញាតឱ្យធ្វើ និងថាតើនៅក្រោមលក្ខខណ្ឌអ្វីខ្លះ។ វាត្រូវបានបង្ហាញក្នុងទម្រង់ជាផែនទីមួយ ឬផែនទីដែលចង្អុលបង្ហាញពី "តំបន់ទាំងឡាយ" និងមានអត្ថបទអមដែលនិយាយពីប្រភេទតំបន់នីមួយៗ សកម្មភាពអ្វីខ្លះបានលើកទឹកចិត្តឱ្យអនុវត្ត បានអនុញ្ញាត ឬហាមឃាត់ និងអនុញ្ញាតនៅកន្លែងណា និងលក្ខខណ្ឌនានាអនុវត្តចំពោះសកម្មភាពទាំងនេះ។ តំបន់ខ្លះនឹងត្រូវបានកំណត់សំរាប់ការពារដែនជម្រក ជាជីវស្ថាន ឬតំបន់ខ្លះទៀតដែលងាយរងផលប៉ះពាល់ដោយសកម្មភាពមនុស្ស។ តំបន់មួយចំនួនដែលបានស្នើសុំគឺសមស្របសម្រាប់ការប្រើប្រាស់ដីធ្លី ឬការប្រើប្រាស់សមុទ្រជាក់លាក់ដូចជា វារីវប្បកម្ម ឬវិស័យទេសចរណ៍។ នៅពេលដែលមានការស្នើសុំដីដើម្បីអភិវឌ្ឍដោយប្រៀបធៀបទៅនឹងការហាមឃាត់តំបន់មួយចំនួននោះ ជាការប្រសើរនោះត្រូវតែមានការយល់ដឹងទូលំទូលាយ និងភាពបទបែនចំពោះការប្រើប្រាស់ដីនៅពេលអនាគត និងត្រូវមានព័ត៌មានលំអិតថាតើតំបន់ណាខ្លះត្រូវបានកំណត់ព្រំដែន និងត្រូវបានពិពណ៌នានោះមានកម្រិតធ្វើផែនការខុសៗគ្នា។ ចំពោះការធ្វើផែនការខ្នាតធំ (ផែនការលំអិត) តំបន់ទាំងនោះអាចកំណត់ព្រំប្រទល់ឱ្យកាន់តែជាក់លាក់ និងលក្ខខណ្ឌនានាបានពិពណ៌នា។ ជាទូទៅ ផែនការលំអិតបែបនេះត្រូវការតែនៅពេលដែលមានតំរូវការចាំបាច់ដោយសារតែសំពាធនៃការអភិវឌ្ឍ។ នៅកម្រិតខ្ពស់ជាងនេះបន្តិច - ដោយគ្របដណ្ដប់តំបន់កាន់តែធំទូលាយ និងនូវកម្រិតតូចមួយ - មានព័ត៌មានមិនសូវលម្អិតនៅក្នុងផ្នែកខ្លះ ប៉ុន្តែមានព័ត៌មានប្រហាក់ប្រហែលនឹងផ្នែកផ្សេងទៀតដែរ។ ឧទាហរណ៍ តំបន់ការពារមួយនឹងត្រូវបានបង្ហាញឱ្យឃើញទាំងផែនការលំអិតនិងផែនការទូទៅ និងមានការដាក់កម្រិតលើសកម្មភាពមួយចំនួនហើយការប្រើប្រាស់នឹងដូចគ្នា។ ទោះបីយ៉ាងណាដ៏ដោយផែនការទូទៅ ប្រហែលជាអាចកំណត់តំបន់មួយសំរាប់ "តាំងលំនៅដ្ឋាន" នាពេលអនាគតដោយមិនបាននិយាយលំអិតថាតើផ្ទៃដីទំហំប៉ុណ្ណានឹងត្រូវបានផ្ដល់ឱ្យសាងសង់ផ្ទះសម្បែង ផ្លូវដឹកជញ្ជូន ឧស្សាហកម្ម ឬពាណិជ្ជកម្ម។ ព័ត៌មានទាំងនេះនឹងត្រូវបានធ្វើឡើងក្នុងផែនការលំអិត។ ជាទូទៅនៅពេលដែលកម្រិតនៃព័ត៌មានកាន់តែខ្ពស់វាមានលក្ខណៈកាន់តែយុទ្ធសាស្ត្រ

និងទូទៅ។ នៅក្នុងដំណើរការដែលបានរៀបរាប់នៅទីនេះកម្រិតលំអៀងគឺឆ្ពោះទៅរកកម្រិតមធម្យមឬស៊ីជម្រៅ។ នៅកម្រិតនេះតម្រូវការរយៈពេលយូរនឹងត្រូវបានបង្ហាញ ព្រមទាំងតំបន់សម្រាប់ការអភិវឌ្ឍនៅក្នុងរយៈពេលខ្លី។ ប្រហែលជាអាចមានតំបន់មួយចំនួនសំរាប់ការរៀបចំផែនការប្រើប្រាស់តំបន់ឆ្នេរ "ដែលមិនបានប្តេជ្ញាចិត្តឱ្យមានការស៊ើបអង្កេតនាពេលអនាគតរឺសម្រាប់ការរក្សាទុកនាពេលអនាគត។ ក្នុងន័យនេះត្រូវបើកចំហានូវជម្រើសទាំងនេះសម្រាប់អ្នកធ្វើសេចក្តីសម្រេចចិត្តនៅពេលអនាគត ដោយស្ថិតនៅក្រោមគោលការណ៍ប្រុងប្រយ័ត្នជាមុន។

## កិច្ចការទី១: កំណត់ជម្រើសយុទ្ធសាស្ត្រតាមតំបន់ឆ្នេរពិតប្រាកដ

មានគេនិយាយថាដំណើរការ CSP គួររួមបញ្ចូលនូវការវាយតម្លៃអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដ៏មានសក្តានុពលដូចដែលបានបរិយាយខាងលើ។ ការសិក្សានោះនឹងបរិយាយពីប្រភេទនៃផលប៉ះពាល់ និងផលវិបាករបស់វា។ ផលប៉ះពាល់នីមួយៗ គួរទទួលបានការចាប់អារម្មណ៍ក្នុងការធ្វើផែនការយុទ្ធសាស្ត្របន្សាំ ហើយមានភាពខុសគ្នាយ៉ាងខ្លាំងពីតំបន់មួយទៅតំបន់មួយទៀត។ ទោះបីយ៉ាងណាក៏ដោយមានការព្យាករណ៍ពីការរកើនឡើងនូវកម្ពស់ទឹកសមុទ្រដោយនិយាយផ្ទាល់សំដៅលើតំបន់ឆ្នេរ ឬច្រាំងសមុទ្រ។ ហេតុដូចនេះហើយ រាល់ផែនការប្រើប្រាស់តំបន់ឆ្នេរទាំងអស់ប្រឈមមុខនឹងបញ្ហាបទាំងអស់នេះ។ យុទ្ធសាស្ត្រដែលបានជ្រើសរើសគឺសំរាប់តំបន់ជាក់លាក់ហើយការកំណត់ច្រាំងឆ្នេរ (ឬកករតាមតំបន់ឆ្នេរ) កន្លែងដែលមានចំណុចរូបសាស្ត្ររួមអាចឱ្យមានការជ្រើសរើសយុទ្ធសាស្ត្រមួយសំរាប់តំបន់នីមួយៗ។ ទទ្ទឹមនឹងនោះដែរយុទ្ធសាស្ត្រដែលមានគឺដូចគ្នាខ្លាំងទៅនឹងយុទ្ធសាស្ត្រសំរាប់ការពារនូវការហូរច្រោះតំបន់ឆ្នេរសព្វថ្ងៃនេះ:

- **មិនធ្វើអ្វីទាំងអស់** (Do nothing): មានករណីជាច្រើនដែលអាចនាំឱ្យមានការបោះបង់ចោល ប៉ុន្តែមានករណីផ្សេងទៀត (តំបន់មានផ្ទាំងថ្មធំៗ) អាចជាយុទ្ធសាស្ត្រដែលអាចដោះស្រាយបានមួយ
- **ការអន្តរាគមន៍មានកំរិត** (Limited intervention) : ចំណុចសំខាន់នៅចំណុចនេះគឺការបន្សាំនឹងទឹកជំនន់ ឧទាហរណ៍ តាមរយៈការប្រើប្រាស់បច្ចេកទេសសាងសង់ថ្មីៗ (ដាំបង្គោល) ឬលើកដីឱ្យបានខ្ពស់ដើម្បីដាំបង្គោលនៅលើនោះ។ យុទ្ធសាស្ត្រនេះអាចជាប់ពាក់ព័ន្ធនឹងការធ្វើរបងជីវសាស្ត្រ ដូចជា ព្រៃកោងកាង ឬតំបន់ដីសើម ដើម្បីចាប់យក និងទប់កករ និងកាត់បន្ថយផលប៉ះពាល់ពីរលក និងកំលាំងខ្យល់បក់។
- **យុទ្ធសាស្ត្រដកថយឬតម្រឹម** (**Managed retreat, or realignment**): នៅក្នុងយុទ្ធសាស្ត្រនេះគឺរៀបចំឡើងដើម្បីទប់ទៅនឹងការកើនឡើងកម្ពស់ទឹកសមុទ្រ ដោយប្តូរការវិនិយោគទុនមួយចំនួនទៅលើដីគោក ឬក៏មិនអនុញ្ញាតឱ្យធ្វើវិនិយោគទុនថ្មីៗ នៅតំបន់ដែលអាចជនលិចហើយការប្រើប្រាស់វិធីសាស្ត្រ Set Back គឺជាគាក់ទិកមួយនៅក្នុងយុទ្ធសាស្ត្រនេះ។

- **កំណត់ខ្សែបន្ទាត់ឆ្នេរ (Hold the line) :** ផ្តល់នូវរបងការពារឆ្នេរសមុទ្រសិប្បនិម្មិត ប្រសិនបើចាំបាច់ដើម្បីរក្សាច្រាំងឆ្នេរឱ្យនៅទីតាំងដដែល។ ជារឿយៗ នេះជាយុទ្ធសាស្ត្រដ៏មានតម្លៃមួយ ប៉ុន្តែក៏អាចជាយុទ្ធសាស្ត្រសមស្របសម្រាប់កន្លែងដែលមានធនធានចាំបាច់ត្រូវការការពារនោះ ដូចជានៅកន្លែងទីប្រជុំជនធំៗ។ នៅមានវិធីសាស្ត្រវិស្វកម្មធនស្រាល ដូចជា ការថែរក្សាខ្សាច់តាមឆ្នេរសមុទ្រ និងការសាងសង់ផ្នុកខ្សាច់។ ដំណោះស្រាយវិស្វកម្មធន់ធ្ងន់រួមមាន ការកសាងជញ្ជាំងទប់ទឹកសមុទ្រ ខឿន (Revetments) របាំងការពារខ្យល់ និងទំនប់ការពារកំលាំងរលក (groins)។
- **រំកិលឆ្ពោះទៅសមុទ្រ (Move seawards):** នេះគឺជាការឆ្លើយតបដ៏ខ្លាំងក្លាមួយ ដែលរនាំងការពារសមុទ្រថ្មីមួយត្រូវបានកសាងឡើងសំដៅទៅរកសមុទ្រនៅចំណុចខ្សែបន្ទាត់បច្ចុប្បន្ន។ ការធ្វើបែបនេះ អាចសមស្របនៅកន្លែងដែលមានការខ្វះខាតដីប្រើប្រាស់ និងមានសក្តានុពលល្អសំរាប់ការវិនិយោគដែលធ្វើឱ្យយុទ្ធសាស្ត្រនេះមានតម្លៃផ្នែកហិរញ្ញវត្ថុ និងសេដ្ឋកិច្ច។

វិធីសាស្ត្រដែលអាចអនុវត្តបាន ដើម្បីជ្រើសរើសយុទ្ធសាស្ត្រជាក់លាក់សំរាប់តំបន់ឆ្នេរមានបង្ហាញក្នុងឧបសម្ព័ន្ធទី៧។ វិធីសាស្ត្រផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមដើម្បីដោះស្រាយបញ្ហាទាមទារឱ្យមានទិដ្ឋភាពបន្ថែម នោះគឺដើម្បីកាត់បន្ថយភាពងាយរងគ្រោះ ពីផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុ តាមរយៈការកាត់បន្ថយបញ្ហាប្រឈម ឬបង្កើនសមត្ថភាព បន្សុាំ។ នៅក្នុងវិធីសាស្ត្រនេះ ធាតុបង្កនៃការហូរច្រោះតំបន់ច្រាំងឆ្នេរដែលមានស្រាប់ ឬដែលមានការគម្រាមកំហែងត្រូវបានចោទជាសំនួរដើម្បីកំណត់ថាតើប្រព័ន្ធធម្មជាតិដែលបានផ្តល់ការការពារត្រូវបានលុបចោលឬធ្វើឱ្យចុះខ្សោយដល់កំរិតមួយដែលមិនមានលទ្ធភាពទប់ទល់ទៅនឹងឥទ្ធិពលនៃសំណឹករីកក៏អត់។ មានការឆ្លើយតបជាមូលដ្ឋានចំនួនពីរកន្លែងដែលចម្លើយចំពោះសំនួរទាំងនេះមានលក្ខណៈវិជ្ជមាន។ វិធានការទាំងពីរនេះអាចអនុវត្តដោយផ្ទាល់ក្នុងផែនការប្រើប្រាស់តំបន់ឆ្នេរ។

- បង្កើនសមត្ថភាពបន្សុាំចំពោះប្រព័ន្ធធម្មជាតិដែលងាយរងគ្រោះតាមរយៈការកាត់បន្ថយកត្តាផ្សេងៗមិនមែនជាកត្តាអាកាសធាតុ និង ក្នុងករណីសមស្របមួយចំនួនដែលលុបចោលនូវរបាំងបំលាស់ទីពោះប្រភេទប្រព័ន្ធអេកូស៊ីស្ទែមសំខាន់ៗ ឬធានាថា ទំហំនិរន្តភាពអប្បបរមានៃប្រព័ន្ធអេកូស៊ីស្ទែមត្រូវបានថែរក្សា។
- បង្វែរនិន្នាការដែលធ្វើឱ្យចុះខ្សោយដល់ប្រព័ន្ធការពារអេកូស៊ីស្ទែម និងតាមរយៈនោះបង្កើនភាពងាយរងគ្រោះរបស់ពួកគេ។ ឧទាហរណ៍មួយចំនួនអាចជាការកំណត់តំបន់ហាមនូវការបង្ហូរទឹក និងកាន់កាប់តំបន់ដីសើមការកាប់បំផ្លាញដើមកោងកាង ដោយធ្វើផ្លូវដើរលើទំនប់ខ្សាច់ និងការដាំដំណាំលើទំនប់ខ្សាច់ឡើងវិញ។

ដោយមិនគិតពីយុទ្ធសាស្ត្រតំបន់ឆ្នេរនោះយើងចាំបាច់ត្រូវតែគិតគូរលើការអភិវឌ្ឍតំបន់និង/ឬធ្វើ Set back តាមបណ្តោយឆ្នេរ។ វាក៏មានហេតុផលល្អផងដែរដើម្បីដាក់ចេញនូវវិធានការគ្រប់គ្រងបន្ថែមតំបន់សមុទ្រ ឧទាហរណ៍ ការកំណត់

ល្បឿនលើការដឹកជញ្ជូនតាមផ្លូវទឹក ការហាមឃាត់ ឬបទបញ្ជាតឹងរឹងចំពោះការយករ៉ែក្នុងដីខ្សាច់ និងការបូមខ្សាច់ និងសមុទ្រ។ ប្រការទាំងនេះប្រហែលជាមានសារៈសំខាន់ណាស់នៅកន្លែងមានកាធ្វើអាជីវកម្មរ៉ែ ប្រេង រឺហ្គាសនៅតំបន់សមុទ្រ។

## កិច្ចការទី២: ធ្វើការវាយតម្លៃយុទ្ធសាស្ត្របរិស្ថានដោយផ្អែកលើជម្រើសសមស្រប

ពាក្យថាការវាយតម្លៃយុទ្ធសាស្ត្របរិស្ថានបានប្រើប្រាស់យ៉ាងទូលំទូលាយដោយសំដៅលើ ***"ផែនការ កម្មវិធី និងគោលនយោបាយវាយតម្លៃផលប៉ះពាល់បរិស្ថាន"***។ ការវាយតម្លៃយុទ្ធសាស្ត្របរិស្ថានបានធ្វើឡើងមុនការធ្វើការសម្រេចចិត្ត វាមិនមែនជាការវាយតម្លៃផលប៉ះពាល់បរិស្ថានដែលផ្តោតតែលើគម្រោងនោះទេហេតុដូចនេះហើយគេបានចាត់ទុកយុទ្ធសាស្ត្រនេះជាឧបករណ៍គន្លឹះមួយសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ ការវាយតម្លៃយុទ្ធសាស្ត្របរិស្ថានសម្រាប់ផែនការ និងកម្មវិធីមានរយៈពេលនិងការអនុវត្តកាន់តែយូរនិងគួរត្រៀមរៀបចំដើម្បីធ្វើការវាយតម្លៃផលប៉ះពាល់បរិស្ថានសម្រាប់គម្រោងនីមួយៗ ថាជាប្រភេទមួយនៃ **"ក្របខណ្ឌវាយតម្លៃយុទ្ធសាស្ត្របរិស្ថាន"** និងផ្អែកលើទស្សនៈវិស័យនៃការវិភាគស្ថានភាពបរិស្ថានដ៏ស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ។

ជាធម្មតា និតិវិធីនៃការវាយតម្លៃយុទ្ធសាស្ត្របរិស្ថានប្រហែលជាត្រូវបានធ្វើបញ្ញតិកម្ម និងខុសប្លែកគ្នារវាងប្រទេស និងតំបន់។ ការវាយតម្លៃយុទ្ធសាស្ត្របរិស្ថានដែលមានលក្ខណៈទូលំទូលាយ និងប្រកបដោយយុទ្ធសាស្ត្រអាចផ្តល់នូវក្របខណ្ឌមិនលម្អៀងដែលអាចទទួលយកបានជារួម និងកាន់តែខ្លាំងជាងមុនសម្រាប់ការវាយតម្លៃផលប៉ះពាល់បរិស្ថានជាបន្តបន្ទាប់រហូតដល់មានគម្រោងថ្មីមួយដែលត្រូវកំណត់នូវតំបន់ដីនិងលំហសមុទ្រ។ សម្រាប់ការវាយតម្លៃយុទ្ធសាស្ត្របរិស្ថានមួយប្រកបដោយជោគជ័យវាគួរត្រូវបានណែនាំមុនគេនៅក្នុងដំណើរការធ្វើផែនការ និងប្រើប្រាស់ជាឧបករណ៍វាយតម្លៃនូវសេណារីយោ និង ជម្រើសអភិវឌ្ឍន៍ផ្សេងៗគ្នា។ ចំណាប់អារម្មណ៍នាពេលបច្ចុប្បន្នចំពោះទស្សនៈទានស្តីពីការអភិវឌ្ឍប្រកបដោយនិរន្តរភាពបានលើកឡើងជាសំនួរថាតើការវាយតម្លៃផលប៉ះពាល់បរិស្ថាន ហើយជាពិសេសនោះការវាយតម្លៃយុទ្ធសាស្ត្របរិស្ថានអាចរួមចំណែកឱ្យសម្រេចបានសង្គមមួយប្រកបដោយនិរន្តរភាពដែរឬទេ? ការអភិវឌ្ឍប្រកបដោយនិរន្តរភាពគឺនិយាយអំពីការធ្វើឱ្យប្រជាជនពេញចិត្តនឹងតំរូវការជាមូលដ្ឋានរបស់ពួកគេ និងធ្វើឱ្យគុណភាពជីវិតកាន់តែប្រសើរ និងមិនធ្វើឱ្យប៉ះពាល់ដល់គុណភាពនៃជីវិតរបស់ក្មេងជំនាន់ក្រោយហើយវាគឺជាការរួមបញ្ចូលគ្នានូវគោលដៅសេដ្ឋកិច្ច បរិស្ថាន និងសង្គម។ ជារឿយៗ ពាក្យថានិរន្តរភាពទំនោរទៅរក ទិដ្ឋភាពផ្នែកសេដ្ឋកិច្ច និងបច្ចេកទេសដែលជាការងាយស្រួលគណនា និងវាយតម្លៃចំណែកឯលក្ខខណ្ឌ និងគុណភាពនៃការរស់នៅ និង បរិស្ថានគឺពិបាកធ្វើការវិភាគក្នុងបរិបទនិរន្តរភាពណាស់។ ប្រសិនបើការយល់ឃើញលើបញ្ហាសុខភាព សង្គម និង បរិស្ថានត្រូវបានរួមបញ្ចូលជាប្រព័ន្ធទៅក្នុងការវាយតម្លៃយុទ្ធសាស្ត្របរិស្ថាន នោះវាអាចជាឧបករណ៍ដ៏មានប្រយោជន៍ មួយសម្រាប់ការវាយតម្លៃជម្រើសការអភិវឌ្ឍប្រកបដោយតុល្យភាព។

សម្រាប់ការអានបន្ថែមលើការវាយតម្លៃយុទ្ធសាស្ត្របរិស្ថានមាននៅក្នុងរបាយការណ៍ UNEP "ការវាយតម្លៃផលប៉ះពាល់បរិស្ថាននិងយុទ្ធសាស្ត្រវាយតម្លៃបរិស្ថានៈដំណើរឆ្ពោះទៅរកដំណោះស្រាយរួម" http://www.unep.ch/etu/ publications/ textONUBr.pdf ព័ត៌មានទាំងនេះដកស្រង់ចេញពីរបាយការណ៍ដែលបានលើកឡើងខាងលើៈ

"គោលបំណងរបស់ SEA មានសង្ខេបនៅក្នុងជំពូកសំខាន់ចំនួនពីរៈ

- ជម្រុញការអភិវឌ្ឍប្រកបដោយនិរន្តរភាពសង្គម និងបរិស្ថាន (ESSD) តាមរយៈ :
    - ការត្រៀម និងការការពារផលប៉ះពាល់ផ្សេងៗនៅចំណុចបង្កហេតុ
    - ការពិចារណា និងការកំណត់ជម្រើសបរិស្ថានជាក់ស្តែងយ៉ាងល្អបំផុត
    - ការធានាថាគោលនយោបាយ និងផែនការឱ្យមានភាពប្រទាក់ក្រឡាជាមួយនឹងគោលដៅ ESSD និងការការពារសុវត្ថភាព
- ពង្រឹង និងរៀបចំគម្រោង EIAតាមរយៈ :
    - ការសំអាត (clearance) បញ្ហាគោលនយោបាយ និងផែនការបរិស្ថានដែលត្រូវបានដោះស្រាយទាំងដោយគ្មានប្រសិទ្ធភាព និងមិនបានត្រូវបានធ្វើ EIA (តម្រូវការ, ការធ្វើយុត្តិកម្ម និងជម្រើស សំខាន់ៗ)
    - ការជូនដំណឹងមុននូវផលប៉ះពាល់
    - ការត្រួតពិនិត្យជាមុននូវផលប៉ះពាល់សំខាន់ៗដ៏មានសក្តានុពលនៃសំណើជាក់លាក់ ដែលតាមរយៈនោះធ្វើការកាត់បន្ថយពេលវេលា និងកិច្ចខិតខំប្រឹងប្រែងចាំបាច់សម្រាប់ EIA (នៅពេលដែលគេភ្ជាប់ទៅនឹង SEA ដូចត្រូវបាននិយាយនៅពេលបន្ទាប់) ។

គោលការណ៍ណែនាំចំនួន៨សម្រាប់ការរៀបចំ និងការអនុវត្តដំណើរការ SEA មាននៅខាងក្រោម។ គោលការណ៍សំខាន់ៗទាំងអស់នេះផ្តល់នូវការណែនាំចង្អុលបង្ហាញលើវិសាលភាពសមស្រប ការណែនាំ និងមាតិកា នៃដំណើរការ SEA :

- ធ្វើឱ្យត្រូវតាមគោលបំណង-ដំណើរការ SEA គួរធ្វើឱ្យស្របតាមបរិបទនិងលក្ខណៈគោលនយោបាយ និងការធ្វើផែនការ
- គោលបំណងដឹកមុខ- ដំណើរការ SEA ត្រូវធ្វើដោយយោងតាមអាទិភាព និងគោលដៅបរិស្ថាន
- ជម្រុញទៅរកនិរន្តរភាព- ដំណើរការ SEA គួរបង្ហាញថាតើជម្រើស និងសំណើអភិវឌ្ឍន៍របៀបណា ផ្តល់ឱ្យមានការអភិវឌ្ឍប្រកបដោយនិរន្តរភាពសង្គម និងបរិស្ថាន

- វិសាលភាពដ៏ទូលំទូលាយ-ដំណើរការគួរគ្របដណ្ដប់លើគ្រប់ប្រភេទ និងកម្រិតនៃការធ្វើការសម្រេចចិត្តទាំងអស់ ដែលទំនងជាមានផលប៉ះពាល់បរិស្ថានសំខាន់ៗ
- ប្រមូលផ្ដុំនូវការសម្រេចចិត្ត-ដំណើរការ SEA គួរផ្ដល់ព័ត៌មានសមស្របតាមទម្រង់មួយស្របតាមកម្រិត នៃការសម្រេចចិត្ត (ឧទាហរណ៍ ការនិយាយពីភាពពាក់ព័ន្ធ បញ្ហា និង/រឺផលប៉ះពាល់)
- តាមបែបសមាហរណកម្ម- ដំណើរការ SEA គួររួមបញ្ចូលនូវការគិតគូរពីផលប៉ះពាល់សង្គម សុខភាព និងកត្តាផ្សេងៗទៀតតាមការចាំបាច់
- តាមបែបចូលរួម- ដំណើរការ SEA គួរផ្ដល់នូវកាលានុវត្តភាពឱ្យមានចូលរួមជាសាធារណៈដែលសមស្របទៅតាមកម្រិត និងបញ្ហានៃការធ្វើការសម្រេចចិត្ត

ប្រភពព័ត៌មានស្ដីពីការវាយតម្លៃយុទ្ធសាស្ត្របរិស្ថាន ឬ ការវាយតម្លៃផលប៉ះពាល់ជាយុទ្ធសាស្ត្ររួមមានៈ http://www.adb.org/Documents/Guidelines/Environmental_Assessment/Strategic_Environmental_Assessment.pdf

http://www.environment-agency.gov.uk/research/policy/32913.aspx - Here there are links to many specific tools for use in SEA

## កិច្ចការទី៣ ការរៀបចំពង្រាងផែនការបែងចែកតំបន់

ដ្យាក្រាមខាងក្រោមនិយាយពីដំណើរការមួយដែលចាប់ផ្ដើមដោយមានតម្រូវការរយៈពេលវែងសំខាន់ៗដើម្បីទ្រទ្រង់ប្រព័ន្ធអេកូស៊ីស្ទែមសម្រាប់ការរស់នៅរបស់ក្មេងៗ និងខ្លួនយើងផ្ទាល់។ ប្រអប់ពណ៌បៃតងប្រផេះនិយាយពីការងារដែលធ្វើរួចទៅជំហានមុននៅពេលដែលបានកំណត់នូវចក្ខុវិស័យ និងអាទិភាពនានា ហើយលក្ខណៈវិនិច្ឆ័យសម្រាប់ធ្វើការសម្រេចចិត្តក៏បានឯកភាពគ្នាផងដែរ។ ប្រអប់ពណ៌បៃតងបង្ហាញពីជំហានជាក់លាក់មួយចំនួនដែលត្រូវបានប្រើប្រាស់នៅពេលដែលព័ត៌មានមូលដ្ឋានត្រូវបានប្រមូល តាមរយៈការត្រួតពិនិត្យបច្ចេកទេសបែបរហ័ស និងតាមរយៈការសិក្សាគោលដៅ និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ពន្ធ័មួយចំនួន។ មានការបែងចែករវាងផែនការបែងចែកតំបន់ប្រើប្រាស់ដែលមានទស្សនៈទានរយៈពេលខ្លី និងវែង និងកម្មវិធីអនុវត្តន៍រយៈពេលខ្លី។




**សេចក្តីសង្ខេបនូវដំណើរការពង្រាងផែនការតាមបែបងាយស្រួល**

ដំណើរការនេះគឺមានលក្ខណៈងាយស្រួលនៅពេលដែលមានព័តិមានហើយព័តិមានភាគច្រើនត្រូវបានរៀបរាប់ជាលក្ខណៈផែនទី ។ ខាងក្រោមនេះជាការបកស្រាយតាមលេខរាងដែលមាននៅក្នុងដ្យាក្រាមៈ

១.ចូរចាប់ផ្តើមដោយកត់សម្គាល់នូវរាល់តំបន់ការពារដែលមានស្រាប់ទាំងអស់ទីជម្រកសំខាន់ៗផ្សេងទៀតតំបន់ដែលសម្បូរទៅដោយជីវចម្រុះ តំបន់ដែលងាយរងផលប៉ះពាល់ផ្នែកបរិស្ថាន តំបន់មានសារៈសំខាន់ផ្នែកវប្បធម៌ៈ ថ្មប៉ប្រះទឹក ស្មៅសមុទ្រ ផ្នូកខ្សាច់ ដើមកោងកាង វាលល្បប់សាហ្គ កូនកោះ ដៃសមុទ្រ តំបន់ដីសើម និងល្បាប់ភក់ផ្សេងទៀត ច្រាំងថ្មដែលសត្វបក្សាបក្សីធ្វើសំបុក តំបន់ជ្រាបទឹកក្រោមដី ច្រាំងមាត់ទន្លេ និងស្ទឹង តំបន់ធ្វើសំបុករបស់សត្វអណ្តើក និងតំបន់សំបុក្រសត្វបក្សាបក្សី ។ តំបន់វាលភក់រួមទាំងតំបន់ដែលមានសារៈសំខាន់ផ្នែកវប្បធមិ ជាវិមានប្រវត្តិសាស្រ្តកន្លែងប្រារព្ធពិធីសាសនា ទីតាំងបុរាណវត្ថុវិទ្យា ឬផ្នែកដ៏មានសារៈសំខាន់ៗនៃកេរ្តិ៍ដំណែលវប្បធមិ ។

២. ចូរកំណត់នូវតំបន់ប្រកបដោយគ្រោះថ្នាក់ដូចជា ទីជម្រាលចោទជ្រៅ ជាពិសេសតំបន់ដែលមានទម្រង់ដីប្រែប្រួល តំបន់ដែលងាយជនលិច ថាមានប្រភពពីដីគោក ឬសមុទ្រ តំបន់រញ្ជួយដីធ្ងន់ធ្ងរ តំបន់ខ្សត់ដី (មិនសំដៅតែលើតំបន់ចំណោទខ្ពស់នោះទេ) តំបន់ដីទទួលរងនូវការហូរច្រោះ តំបន់ឆ្នេរដែលសឹករេចរិលខ្លាំង ជាពិសេសច្រាំងថ្មទន់ៗ។

៣. គ្របដណ្ដប់លើការប្រើប្រាស់ដីដែលមានស្រាប់: ការតាំងទីជម្រក កសិកម្ម ស្រែអំបិល តំបន់នេសាទ ព្រៃឈើ របៀងដឹកជញ្ជូន (រួមមានផ្លូវទឹកតូចៗ-Sea Lane) ចំណតវ៉ានា សកម្មភាពជីករករ៉ែ តំបន់ឧស្សាហកម្ម សេវាកម្ម។ល។ កម្រិតនៃការធ្វើផែនការនឹងកំណត់កម្រិតលំអិតដែលត្រូវបង្ហាញនៅទីនេះ។

៤. ធ្វើផែនទីកំណត់តំបន់សឹករេចរឹល និងតំបន់ដែលទទួលការគម្រាមកំហែង ប្រសិនបើតំបន់ទាំងនេះ មិនត្រូវបានបង្ហាញនោះទេ។ ចូរបង្ហាញពីប្រភេទឆ្នេរសមុទ្រ និងរៀបចំយុទ្ធសាស្ត្រសម្រាប់ដោះស្រាយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។

៥. ធ្វើផែនទីតំបន់ដែលមិនអាចដកហូតឬធ្វើអាជីវកម្មធនធានដែលជាប្រភពនៃសំភារៈសាងសង់ (ថ្មម៉ាប ថ្មតូចៗ គ្រួសក្រហម ដីឥដ្ឋសម្រាប់ធ្វើឥដ្ឋ រ៉ែ តំបន់ប្រេង និងហ្គាស តំបន់កំពុងផែដែលមិនទាន់អភិវឌ្ឍ តំបន់សម្រាប់ទាក់ទាញភ្ញៀវទេសចរណ៍។ល។

៦. ឥឡូវនេះ អ្នកមានតួនាទីមួយដើម្បីកំណត់នូវតំបន់ដែលមានជំលោះ និងមានបញ្ហាដែលមានស្រាប់ និង ប្រហែលជាតំបន់ដែលអាចមានបញ្ហាកើតឡើងនៅពេលអនាគតផងដែរ។ តំបន់ទាំងនេះគួរត្រូវធ្វើកំណត់ចំណាំនៅលើផែនទីដោយធ្វើការបែងចែកនូវប្រភេទនៃបញ្ហា និងការប្រឈម។ ការវិភាគនេះនឹងផ្ដល់នូវធាតុចូលទាំង ក)កន្លែងដែលអនុញ្ញាតធ្វើនូវសកម្មភាពមួយចំនួន និង ខ) ថាតើស្ថិតនៅក្រោមកាលៈទេសៈអ្វី។

៧. យោងតាមការសិក្សាកន្លងមក អ្នកនឹងមានការប៉ាន់ស្មានពីកំណើនប្រជាជននៅពេលអនាគត ការព្យាករណ៍ពីសេដ្ឋកិច្ច និងអាចគណនាពីប្រភេទនៃតម្រូវការដីសម្រាប់វិស័យជាច្រើនដូចជា ការសង់ផ្ទះសម្បែង ឧស្សាហកម្ម សេវាដឹកជញ្ជូន និងវិស័យច្រើនទៀត។ ការគូសបញ្ជាក់នៅក្នុងផែនទីជំហានទី៣ និងទី៤ខាងលើនឹងបង្ហាញថាតើដីតំបន់ណាខ្លះអាចធ្វើការអភិវឌ្ឍបានថាតើប្រការនេះមានជាការផ្លាស់ប្ដូរនៅការប្រើប្រាស់ដែលមានស្រាប់ការទាមទារមកវិញនូវដីដែលរេចរិល ឬក៏ផ្លាស់ប្ដូរទៅតំបន់ដែលមិនទាន់ប្រើប្រាស់ ប៉ុន្តែវាមិនមែនជាតំបន់រសើបសម្រាប់បរិស្ថាននោះទេ។

៨. វាអាចធ្វើទៅបាន ក្នុងការបង្កើតសេនារីយ៉ូផ្សេងមួយចំនួនទៀតសម្រាប់:

- ទិសដៅនៃការអភិវឌ្ឍស្ថិតក្រោមលក្ខខណ្ឌផ្សេងៗគ្នា (សូមពិនិត្យមើលលក្ខខណ្ឌផ្សេងៗគ្នាសម្រាប់តំបន់នីមួយៗ ដើម្បីវាយតម្លៃសេណារីយ៉ូផ្សេងៗគ្នា)
- សំណើសម្រាប់ការគ្រប់គ្រង និងការការពារបរិស្ថាន

៩. ទាំងអស់នេះនឹងក្លាយជាប្រធានបទមួយសម្រាប់ការសិក្សាវាយតម្លៃយុទ្ធសាស្ត្របរិស្ថាន

១០. តាមរយៈការពិភាក្សា និងចរចាជាមួយនឹងក្រុមអ្នកពាក់ព័ន្ធជាក់លាក់ និងតួរអង្គសំខាន់ៗ ជម្រើសដ៏ពេញចិត្តមួយនឹងត្រូវជ្រើសរើសយក ហើយជម្រើសនេះអាចត្រូវបានបំលែងទៅជាពង្រាងផែនការប្រើប្រាស់តំបន់ឆ្នេរ។ ចូរចំណាំថាផែនការនេះនឹងមានទាំងលើផែនទី និងអត្ថបទពន្យល់ជាពិសេសដោយពិពណ៌នាពីលក្ខខណ្ឌមួយចំនួនដែលបានភ្ជាប់ជាមួយតំបន់នីមួយៗ។

១១. ថាផ្ទុយមកវិញ ប្រការនេះគឺជាមូលដ្ឋានគ្រឹះសម្រាប់ពង្រាងកម្មវិធីអនុវត្តន៍សំរាប់សកម្មភាព ដែលត្រូវការពេល ៣-៥ឆ្នាំ សំរាប់ការអនុវត្ត និង អនុម័តនូវផែនការបែងចែកតំបន់ប្រើប្រាស់។ កម្មវិធីនេះត្រូវតែស្របគ្នាទៅនឹងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចផ្សេងទៀត ប៉ុន្តែវាក៏អាចនឹងផ្តល់នូវធាតុចូលចំពោះផែនការទាំងអស់នេះដែរ។ សូមពិនិត្យមើលឧបសម្ព័ន្ធទី៩ ស្តីពីមាតិកាគំរូសំរាប់ការពង្រាងផែនការបែងចែកតំបន់ប្រើប្រាស់។

## គោលបំណងនៃការកំណត់ខ្សែបន្ទាត់ Set Back

**Set Back** គឺជាឧបករណ៍កំណត់តំបន់ដ៏សំខាន់មួយក្នុងការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរ។ ដោយសារសារៈសំខាន់នេះហើយ ប៉ុន្តែវាក៏ដោយសារតែមានបញ្ហាដ៏ចំរូងចំរាស់មួយចំនួនផងនោះ ការណែនាំអំពីប្រធានបទនេះ ក៏ត្រូវបង្ហាញនូវផ្នែកនេះដែរ។ ក្នុងបណ្តាប្រទេសនៅក្នុងតំបន់សមុទ្រអាស៊ី-បូព៌ាមានបទបញ្ញាតិទាក់ទងនឹងប្រធានបទនេះរួចស្រេចហើយ ដូច្នេះហើយ ការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរគឺ "គោរពតាមបទបញ្ញាតិនេះ" ។ នៅទីកន្លែងផ្សេងទៀត មានភាពបទបែន ប៉ុន្តែចាំបាច់ត្រូវតែផ្តល់នូវយុត្តិកម្មសមស្របមួយចំពោះការសម្រេចចិត្តនេះ។ ជាទូទៅ Set Back គឺជាខ្សែបន្ទាត់មួយដែលរត់ស្របទៅនឹងឆ្នេរដែលកំណត់ដោយចំងាយ ដែលគេបានកំណត់ជាមុនដោយការគូសបន្ទាត់ កំណត់តំបន់ចំផ្នែកបែរទៅរកឆ្នេរដែលមានការហាមឃាត់តឹងរឹងមួយចំនួនទាក់ទងនឹងការប្រើប្រាស់ ឬការអភិវឌ្ឍ។ គេអាចប្រើប្រាស់សម្រាប់ហេតុផលសំខាន់ៗចំនួនបួនរួមមាន:

- **ការពារសិទ្ធិចេញចូលច្រាំងឆ្នេរជាសាធារណៈ:** នេះគឺជាការប្រើប្រាស់ផ្អែកទៅលើសិទ្ធិដែលបានអនុវត្តក្នុងប្រទេសជាច្រើនដោយរួមបញ្ចូលទាំងការចេញចូលជាសាធារណៈទៅដល់តំបន់ដីមួយចំនួន( ព្រៃឈើ ឆ្នេរសមុទ្រឆ្នេរចន្លោះទឹកជោរនិងទឹកនាច ។ល ។) ទោះបីជាដីគ្រប់គ្រងដោយឯកជនក៏ដោយ ។ ជារឿយៗប្រទេសទាំងនោះក៏បានបញ្ចូលនូវការរឹតបន្តឹងសិទ្ធិជាប្រពៃណីរបស់គេមួយចំនួនថាតើជិតប៉ុណ្ណាដែលអ្នកមិនមែនជាម្ចាស់ទាំងអស់នោះអាចចេញចូលទៅដល់ ។ ដើម្បីជៀសវាងជម្លោះរវាងការគោ- រពចំពោះការហាមឃាត់នេះនិងការគោរពចំពោះសិទ្ធិចូលទៅកាន់តំបន់ឆ្នេរ Set back បានដាក់កំហិតលើការសាងសង់ទីជម្រក ។ ប្រព័ន្ធច្បាប់មួយចំនួនត្រូវបានប្រើប្រាស់ដើម្បីធ្វើការលើកលែងមួយចំនួន ។

***គម្រុយចំៗស្តីពីការបែងចែកតំបន់:***

ការគិតគូរជាទូទៅនៅពេលរៀបចំផែនការបែងចែកតំបន់អាចបញ្ចូលនូវវិធីសាស្ត្រខាងក្រោម:

- កាត់បន្ថយការប្រើប្រាស់ឆ្នេរដែលមិនត្រូវការទឹក
- ធ្វើផែនការបែងចែកតំបន់ឱ្យសាមញ្ញ និងងាយយល់
- នៅពេលហាមប្រាមផែនការដែលមានស្រាប់នៅក្នុងតំបន់ ចូរព្យាយាមដាក់លក្ខខណ្ឌលើការប្រើប្រាស់តំបន់ទាំងនេះនៅផ្នែកផ្សេងៗទៀតនៃតំបន់នេះ
- ការបែងចែកតំបន់ប្រើប្រាស់ឆ្នេរគួរស្របជាមួយការបែងចែកនៅតំបន់ខ្ពង់រាបនិងដែនទឹក
- ចូរចៀសវាងការឆ្លងកាត់ភ្លាមៗនៅក្នុងតំបន់នេះដូចជាការតភ្ជាប់ដែនជម្រកតឹងតែងទៅតំបន់សមុទ្រ
- ចូរប្រើចំណុចគោលធម្មជាតិដើម្បីកំណត់ព្រំដែនតំបន់ឱ្យបានច្រើនតាមដែលអាចធ្វើបាន
- ចូរពិចារណានូវប្រភពនិងផ្លូវអេកូឡូស៊ីរវាងទីជម្រកផ្សេងៗនៅពេលបង្កើតតំបន់
- ចូរធ្វើឱ្យស្របជាមួយតំបន់ដឹកជញ្ជូនមានស្រាប់ តំបន់នៅជិតដែននេសាទនិងរបបគ្រប់គ្រងក្នុងតំបន់ និង
- ចូរប្រយ័ត្ននូវការប្រើប្រាស់ទីជម្រកធម្មជាតិឆ្នេរដូចជាជម្រកសត្វអណ្តើកសមុទ្រដែលទាមទារឱ្យមានការអភិវឌ្ឍតិចតួចនិងមិនប្រើពន្លឺសិប្បនិម្មិតនៅពេលយប់

***Source:*** DENR, 2001. *Managing Coastal Habitats and Marine Protected Areas*.Manila. Philippines. p.35.

- **ដើម្បីថែរក្សារបាំងការពារសមុទ្រធម្មជាតិ:** ជាពិសេសសម្រាប់តំបន់ឆ្នេរសមុទ្រដែលជាតំបន់ងាយ ទទួលរងនូវខ្យល់បក់បោកខ្លាំង ការហូរច្រោះលឿន និងការបាក់ស្រុតពុំនូកខ្សាច់នៅតំបន់ឆ្នេរ (ច្រាំងថ្មទន់) ។ របាំងទាំងនេះត្រូវបានប្រើប្រាស់ដោយប្រយោលដើម្បីការពារទ្រង់ទ្រាយតំបន់ឆ្នេរដោយខ្លួនឯង កន្លែងដែលស្ថានភាពតំបន់ឆ្នេរផ្តល់ឱ្យនូវការការពារ ។ ពុំនូកខ្សាច់គឺជាឧទាហរណ៍មួយ ឬព្រៃឈើនៅតំបន់ ឆ្នេរដូចជាដើមកោងកាង ។ លក្ខណៈបែបនេះនឹងផ្តល់ការការពារដល់ប្រព័ន្ធអេកូស៊ីស្ទែម និងការតាំងជម្រកលើដី ។ ប្រសិនបើពួកវាត្រូវបានបំផ្លាញ ឬតួនាទីរបស់ពួក

គេត្រូវបានកែសម្រួលតាមរយៈការអភិវឌ្ឍនិងប្រើប្រាស់ហួសប្រមាណដូចនេះតម្លៃរបស់វាជារបាំងសមុទ្រនឹងត្រូវបាត់បង់។

- កាត់បន្ថយការខាតបង់ទ្រព្យសម្បត្តិដែលមានតម្លៃសេដ្ឋកិច្ច ជាពិសេសអាគារ និងហេដ្ឋារចនាសម្ព័ន្ធ នានាដោយសារតែការហូរច្រោះនៅតំបន់ឆ្នេរកំណើនកម្ពស់ទឹកសមុទ្រ បញ្ហាធាតុអាកាសដោយរួមទាំងខ្យល់ព្យុះ និងកត្តាទឹកជំនន់។
- ដើម្បីរក្សាសោភ័ណ្ឌភាពដែលមើលឃើញមិនត្រូវបានរំខានតាមបណ្តោយច្រាំងឆ្នេរនិងតាមរយៈនោះរក្សានូវទេសភាពតំបន់ឆ្នេរ។

គោលបំណងសំខាន់ទាំងបួននេះនឹងផ្តល់មូលដ្ឋានសម្រាប់ការកំណត់ថាតើគួរប្រើ ឬមិនគួរប្រើ Set Back ទាំងនេះថាជាយន្តការត្រួតពិនិត្យការអភិវឌ្ឍ និងប្រើជាលក្ខណៈវិនិច្ឆ័យ សម្រាប់ការកំណត់ថាតើ Set Back ទាំងនេះមានជម្រៅប៉ុណ្ណានោះ ប៉ុន្តែក៏មានករណីបន្ថែមផ្សេងទៀតដែរ។

- លក្ខណៈនៃតំបន់ឆ្នេរខ្លួនឯង ជាពិសេសជម្រាលរបស់វា និងការរៀបចំសម្ភារៈតាមរបៀបមួយដែលតំបន់នេះប៉ះពាល់ដោយសំណឹក
- តម្លៃមុខងាររបស់ប្រព័ន្ធអេកូស៊ីស្តែមតំបន់ឆ្នេរមានលក្ខណៈជាធម្មជាតិ និងជារបាំងការពារសមុទ្រដ៏ល្អ
- ស្ថានភាព រឺក៏ការកើនឡើងនូវសំណឹកបច្ចុប្បន្ន ប្រសិនបើមាន
- ភាពញឹកញាប់ និងភាពធ្ងន់ធ្ងរនៃព្រឹត្តិការណ៍ទឹកឡើងខ្ពស់ (ខ្ពស់ជាងទឹកជោរនៅនិទាឃរដូវ) មុខសញ្ញាគ្រោះថ្នាក់ដូចជាខ្យល់ព្យុះហើរីខែន (Hurrican) និងស៊ូណាមិ
- កំណើនកម្ពស់ទឹកសមុទ្រនាពេលបច្ចុប្បន្ន និងការកើនឡើងកម្ពស់ទឹកសមុទ្ររយៈកាល៦០ឆ្នាំខាងមុខ (ឬក្នុងកំឡុងពេលប្រើប្រាស់ដើម្បីសម្រេចបាននូវផលចំណេញជាទុនវិនិយោគសាច់ប្រាក់) (កំណើនកម្ពស់ទឹកសមុទ្រ តំណាងឱ្យការបាត់បង់ផ្ទៃដីនៅកន្លែងដែលកើតឡើង) (relative sea level rise accounts for land subsidence where this occurs);
- ប្រភេទ និងកម្រិតនៃទុនវិនិយោគក្នុងការកសាងអាគារ និងហេដ្ឋារចនាសម្ព័ន្ធ
- បច្ចេកវិទ្យាសាងសង់ដែលត្រូវប្រើប្រាស់ (ភាគច្រើននៃតំបន់សមុទ្រអាស៊ីបូព៌ា មានបច្ចេកវិទ្យា បែបបុរាណដែលប្រើប្រាស់វត្ថុធាតុដើមដែលអាចរកបាន និងដែលកកើតឡើងវិញដើម្បីកសាងនៅលើផ្ទៃទឹកនៅតំបន់ខ្លះទៀតនៅលើពិភពលោក សម្ភារៈទំនើបៗត្រូវបានប្រើប្រាស់ក្នុងរៀបចំស្រដៀងគ្នា- ពោលគឺការកសាងអាគារឱ្យនៅលើក៏រិតនៃខ្យល់ព្យុះ)។

ជាទូទៅ ការធ្វើ Set back ដោយកំណត់តំបន់ច្បាស់លាស់នោះអាចមានចំណុចខ្សោយមួយចំនួនផងដែរដូចជាៈ វាអាចកាត់តាមព្រំដែនដែលមានអេកូស៊ីស្តែម និងព្រំដែនទឹក ហើយជារឿយៗ វាមានទំនាក់ទំនងបន្តិចបន្តួចទៅនឹងមុខ

សញ្ញាគ្រោះថ្នាក់។ ជាងនេះទៅទៀត ផ្អែកតាមពេលវេលា និងដោយសារតែការសឹករេចរិលតំបន់ឆ្នេរនោះវានឹងមាន ការសាងសង់នៅក្នុងតំបន់ Set back នោះ។ Set back គឺមានទស្សនៈទានសាមញ្ញមួយប៉ុន្តែវាជាការខកចិត្តមួយនៅពេលធ្វើ Set back ជាក់លាក់មួយនៅលើដី។ វាទាមទារឱ្យមានចំណុចគោលជាក់លាក់មួយ (ចំណុចខ្សែទឹកខ្ពស់) ប៉ុន្តែចំណុចខ្សែទឹកខ្ពស់ពិតប្រាកដនោះមិនមែនជាការងារងាយស្រួលនោះទេក្នុងការកំណត់ នូវទីតាំង និងនៅតាមបណ្តោយខ្សែឆ្នេរទាំងនោះ។

ការកំណត់ Set back អណ្តែតលើទឹកជាវិធីសាស្ត្រមានអត្រាប្រែប្រួលច្រើន និងមានភាពបទបែនតិចតួច។ Set back ទាំងនេះត្រូវបានកំណត់យ៉ាងទូលំទូលាយតាមរយៈការសន្និដ្ឋានតំបន់ឆ្នេរប្រវត្តិសាស្ត្រ ឬអាត្រាសំណឹកដែលហូរចេញតាមចង្អូរច្រាំងថ្ម ធៀបទៅនឹងកាលបរិច្ឆេទដែលបានជ្រើសរើសមួយចំនួន។ ដំណើរការនេះត្រូវបានធ្វើឡើងជាលក្ខណៈវិទ្យាសាស្ត្រដោយមានកំណត់នូវលក្ខខណ្ឌទុកជាមុនមួយចំនួនដូចជា:

- វិធីសាស្ត្រទៀតទាត់សម្រាប់ការកំណត់អាត្រាសំណឹកជាប្រវត្តិសាស្ត្រ
- ទិន្នន័យមានគុណភាពខ្ពស់ដែលស្របតាមពេលវេលា
- លទ្ធភាពដើម្បីគណនាឱ្យបានត្រឹមត្រូវនូវកំរិតនៃការផ្លាស់ប្តូរស្ថានភាពជាប្រវត្តិសាស្ត្រដែលកំណត់លក្ខណៈវិនិច្ឆ័យដោយដំណើរការបំលាស់ទីតំបន់ឆ្នេរមិនជាប់គ្នា វិលជុំវិញដោយច្របូកច្របល់
- ការយល់ពីដំណើរការដែលបង្កឡើងដោយការកែសម្រួលច្រាំងឆ្នេរដោយមនុស្សនៅតំបន់ដែលមានការអភិវឌ្ឍរួចជាស្រេចទៅហើយ
- ការជ្រើសរើសនូវកាលបរិច្ឆេទគោលដៅសមស្រប។ វិធីសាស្ត្រមួយលើកឡើងថា កាលបរិច្ឆេទគោលដៅគួរតែផ្សារភ្ជាប់ទំនាក់ទំនងទៅនឹងរយៈពេលទទួលបានផលចំណេញនូវទុនវិនិយោគសំរាប់ការសាងសង់។ ជាការពិតប្រការនេះមានភាពខុសគ្នាខ្លាំងដោយផ្អែកលើសម្ភារៈបច្ចេកទេស និងប្រភេទនៃការសាងសង់។

វិធីសាស្ត្រនេះក៏បានសន្មត់ផងដែរថាអាត្រាសំណឹកជាប្រវត្តិសាស្ត្រនឹងត្រូវយកទៅអនុវត្តបានល្អនៅពេលអនាគត។ កិច្ចពិភាក្សាពីការប្រែប្រួលអាកាសធាតុនៅពេលដែលវាបានប្រើប្រាស់ទាក់ទងនឹងតំបន់ឆ្នេរបង្ហាញយ៉ាងច្បាស់ថាការសន្មត់នេះគឺមិនមានសុពលភាពឡើយហើយចំណុចខ្សោយទាំងនេះអាចត្រូវបានប៉ះប៉ូវសងវិញ។ មេគុណលំអៀងមួយអាចនឹងត្រូវបានដាក់បន្ថែមទៅលើអត្រាសំណឹកដែលគេបានគណនា ហើយតំបន់ទ្រនាប់អាចបង្កើតឡើងក្នុងចំងាយមួយសំរាប់គោលបំណងជាក់លាក់ដូចជាការការពារខ្យល់ព្យុះ និង ប្រព័ន្ធអេកូស៊ីស្ទែម ហើយក៏អាចអនុវត្តលើការកើនឡើងកំពស់ទឹកសមុទ្រ និងអាយុកាលនៃរចនាសម្ព័ន្ធនេះបង្កើតឡើងតាមបែបសិប្បនិម្មិត។ ការកសាងឆាកជីវិតអាចមានភាពប្រសើរឡើង។ សេចក្តីសង្ខេបពីភាពគុណសម្បត្តិ និងគុណវិបត្តិនៃ Set back មានដូចខាងក្រោម:

| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| **Setbacks:**<br>- ការពារការបាត់បង់ និង ការខូចខាតរចនាសម្ព័ន្ធដោយសារសំណឹក<br>- ការពារទីជម្រកតំបន់ឆ្នេរនិងគុណភាពទឹក<br>- ផ្ដល់នូវទីធ្លាទូលាយសម្រាប់បរិស្ថានតំបន់ឆ្នេរធម្មជាតិ<br>- ផ្ដល់នូវរម្យនីយដ្ឋាន និងការចេញចូលតំបន់ឆ្នេរ<br>- ធ្វើឱ្យមានវដ្ដនៃកំណើនការហូរច្រោះបែបធម្មជាតិ<br>- អាចចូលរួមចំណែកក្នុងការគ្រប់គ្រងប្រព័ន្ធឆ្នេរប្រកបដោយនិរន្តរភាព | **Setbacks:**<br>- មិនអាចផ្ដល់ការការពារគ្រប់គ្រាន់វិធីសាស្រ្តជាក់លាក់មិនអាចគិតគូរពីឋានលេខា និងកម្រិតលំអៀងដំណើរការការហូរច្រោះតំបន់ឆ្នេរ ហើយតំបន់ទ្រនាប់មិនអាចកាត់បន្ថយផលប៉ះពាល់បាន<br>- អាចកំណត់មូលដ្ឋានពន្ធ<br>- អាចជាមូលដ្ឋានទិន្នន័យផ្អែកលើអត្រាការហូរច្រោះមិនទៀងទាត់<br>- មិនអាចដោះស្រាយបញ្ហានៃរចនាសម្ព័ន្ធដែលមានស្រាប់<br>- ត្រូវការយុទ្ធសាស្រ្តបន្ថែមដើម្បីដោះស្រាយរចនាសម្ព័ន្ធឋិតនៅក្នុងតំបន់ setbackនៅពេលការធ្វើ Set back ថយចុះតាមពេលវេលា<br>- ខ្សែបន្ទាត់ Set Back ដែលនៅស្របគ្នាជា បន្ទាត់ច្រាំងឆ្នេរមិនរាប់បញ្ចូលតំបន់សមុទ្រទេ<br>- អាចអាស្រ័យលើកត្តាវប្បធម៌ និងបែបបទរដ្ឋបាល។ |

ទោះបីជាមានផលវិបាកយ៉ាងណាក៏ដោយប្រទេសជាច្រើនបានប្រើប្រាស់ set back នេះ។ ក្នុងប្រទេសខ្លះ គិតគូរថាតើគួរកំណត់ Set back ជ្រៅប៉ុណ្ណាហើយប្រទេសខ្លះគិតគូរតាម "បែបវិទ្យាសាស្ត្រ"។ ឧបសម្ព័ន្ធទី១២ រួមបញ្ចូលទាំងដ្យាក្រាមនៃដំណើរការដែលត្រូវប្រើប្រាស់ក្នុងខេត្តមួយក្នុងប្រទេសអាហ្វ្រិកខាងត្បូង និងបានផ្ដល់នូវឧទាហរណ៍មួយចំនួនទាក់ទងនឹងដែនយុត្តាធិការជាច្រើនទៀតនៅជុំវិញពិភពលោក។

នៅក្នុងស្ថានភាពជាច្រើនក្នុងតំបន់សមុទ្រអាស៊ីបូពា៌ ប្រហែលជាមិនតម្រូវការឱ្យមាន Set back ទូទៅនោះទេ។ នៅតំបន់មួយចំនួនទៀតដែលមានប្រជាពលរដ្ឋនៅតាមតំបន់សមុទ្រជាច្រើនសតវត្សរ៍មកហើយនោះ ទស្សនៈទាននេះដូចជាមិនសូវមានការយល់ដឹងដោយប្រជាជនដែលរស់នៅតាមមូលដ្ឋាននោះទេ។ នៅតំបន់ផ្សេងទៀតគឺមានតម្រូវការចាំបាច់ដើម្បីត្រួតពិនិត្យបរិស្ថាននៅជិតឆ្នេរ។ ប្រទេសផ្សេងគ្នា តំបន់ឆ្នេរខុសៗគ្នានាំឱ្យមានវិធីសាស្ត្រនិងដំណោះស្រាយផ្សេងៗគ្នាដែរ។ ខាងក្រោមនេះគឺជាមធ្យោបាយមួយឆ្ពោះទៅរកបញ្ហានេះ:

- កំណត់គោលដៅមូលដ្ឋានជាមួយនឹងប្រព័ន្ធ **setback** ក្នុងតំបន់៖ តើគោលដៅទាំងនេះអាច សម្រេចបានតាមរយៈកត្តាផ្សេងទៀត ល្អប្រសើជាង និងមធ្យោបាយអ្វី? តើ setbacks តែមួយនឹងសម្រេចគោលដៅទាំងនេះបានទេ ឬនឹងតម្រូវឱ្យមានលក្ខខណ្ឌក្នុងតំបន់បន្ថែមទៀត?
  - ធានាឱ្យមានការប្រើប្រាស់តំបន់ឆ្នេរជាសាធារណៈ
  - ការពារច្រាំងឆ្នេរសមុទ្រ និងប្រព័ន្ធធម្មជាតិ backshore
  - កាត់បន្ថយបញ្ហាដែលបំផ្លាញទ្រព្យសម្បត្តិដោយសារទឹកជំនន់ រឺសំណឹកនៅពេលអនាគត
  - ថែរក្សាបូរណភាពដ៏ស្រស់ស្អាត និងសោភ័ណ្ឌភាពនៃតំបន់ឆ្នេរ ។
- កំណត់លក្ខណៈវិនិច្ឆ័យជាមូលដ្ឋានដើម្បីប្រើប្រាស់ក្នុងការកំណត់អត្រា **setback** :
  - សម្រួលនូវការអនុវត្ត មិនមានភាពស្មុគ្រស្មាញក្នុងការគណនា ឬអនុវត្តទេ
  - អាត្រាប្រែប្រួល ឬកំណត់ជាក់លាក់ ប្រសិនបើប្រែប្រួល......
  - ការផ្លាស់ប្តូរយោងទៅតាមអាត្រាសំណឹក ប្រភេទ និងទំហំនៃការសាងសង់
  - អាត្រាសំណឹកប្រចាំឆ្នាំគុណនឹងអាយុមធ្យមកាល
  - ផ្តល់នូវតំបន់ទ្រនាប់បន្ថែមទៀតសម្រាប់ភាពមិនច្បាស់នៃការកើនឡើងកំពស់ទឹកសមុទ្រ
  - គណនាតាមខ្សែបន្ទាត់មិនមែនតាមកម្រិតកំពស់ទឹកខ្ពស់នោះទេ (ឧទាហរណ៍ ពីខ្សែកុងទួរជាក់លាក់មួយ ឬក៏ពីខ្សែបន្ទាត់នៃដើមរុក្ខជាតិដែលមានជាអចិន្ត្រៃយ៍ដំបូង)
  - ពង្រីកការប្រើប្រាស់ផ្នែកសេដ្ឋកិច្ច នៃទ្រព្យសម្បត្តិតំបន់ឆ្នេរ
  - តម្រូវផ្លូវច្បាប់ និងសម្រួលការអនុវត្តច្បាប់
  - ការទទួលស្គាល់ជាសាធារណៈ និងការយល់ដឹងនូវវិធីសាស្ត្រកំណត់អត្រា Set back
- តំបន់សម្រាប់ការការពារ និងការគ្រប់គ្រងតឹងរឹងនូវប្រព័ន្ធអេកូស៊ីស្ទែមសំខាន់ៗ៖ រួមមាន តំបន់ងាយរងផលប៉ះពាល់បរិស្ថានច្រាំងទន្លេ និងដៃស្ទឹង តំបន់សំបូរជីវចម្រុះ ទីជម្រក ឬក៏ទីតាំងសំខាន់ៗ (តំបន់ឆ្នេរដែលជាជម្រក ពងកូនរបស់សត្វអណ្តើកនិងការធ្វើសំបុករបស់សត្វបក្សី ។ល ។) ។ កន្លែងណាដែលមានលក្ខណៈសមស្រប ចូរផ្តល់នូវតំបន់ទ្រនាប់បន្ថែមទៀត បង្កើនសមត្ថភាពបន្សាំនៃប្រព័ន្ធអេកូស៊ីស្ទែមចំពោះការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយការអនុវត្តដែលបង្កើននូវភាពងាយរងគ្រោះ ។
- ចូរកុំរាប់បញ្ចូលនូវតំបន់ឆ្នេរទាំងនេះនៅក្នុងលំហាត់ការងារនេះ ។ ចូរកំណត់តំបន់សមុទ្រ និង ឆ្នេរ សមុទ្រផ្សេងទៀតដែលតាមទំនៀមទំលាប់ជាកន្លែងកសាងឡើងនៅលើផ្ទៃសមុទ្រ ដោយប្រើប្រាស់ ធនធាន កកើតឡើងវិញ និងបច្ចេក

ទេសបុរាណ ។តំបន់ទាំងនេះអាចតម្រូវឱ្យមានការយកចិត្តទុកដាក់ខ្លាំងក្នុងការកំណត់តំបន់តាមលក្ខណៈពិសេសមួយ ។ ការប្រើប្រាស់ការកំណត់ព្រំឆ្នេរក្នុងតំបន់ទាំងនេះគឺមិនសមស្របប្រសិនបើវាមិនបានអនុវត្តផ្សេងពីគ្នាចំពោះសហគមន៍ផ្សេងគ្នានោះទេ ។

- ចូរកុំរាប់បញ្ចូលនូវតំបន់ទាំងនេះនៅក្នុងលំហាត់ការងារនេះ ។ចូរកំណត់តំបន់ទាំងឡាយណាដែលគោលបំណងសំខាន់ៗ គឺតម្រង់ទៅរកធនធានសមុទ្រ មិនមែនកន្លែងទេសចរណ៍ដូចជាៈ កន្លែងនេសាទ កំពង់ផែ ចំណតនាវា ។ នៅតំបន់ទាំងនេះតម្រូវឱ្យមានលក្ខខណ្ឌអភិវឌ្ឍន៍ ប៉ុន្តែជាទូទៅការប្រើប្រាស់ Set Back គឺមិនទាន់ សមស្រប នោះទេ ។
- ចូរកុំរាប់បញ្ចូលនូវតំបន់ទាំងនេះនៅក្នុងលំហាត់ការងារនេះ ។ ចូរកំណត់នូវតំបន់ឆ្នេរកន្លែងដែលយុទ្ធសាស្ត្រធ្វើឡើងដើម្បីគួសខ្សែបន្ទាត់ រឺពង្រីកចូលទៅក្នុងសមុទ្រ ។ ជាពិសេស តំបន់ទាំងនេះស្ថិតនៅក្នុងតំបន់ទីក្រុងដែលបានអភិវឌ្ឍរួចហើយ ។ ចូរផ្តល់នូវការកំណត់ Set back សមស្របនៅក្នុងតំបន់ទាំងនេះ សម្រាប់គោលបំណងការពារការចេញចូលជាសាធារណៈទៅកាន់តំបន់ច្រាំងឆ្នេរ ។ (ការចេញចូលជាសាធារណៈទៅកាន់តំបន់ច្រាំងឆ្នេរគឺសំខាន់ណាស់នៅតំបន់ទីក្រុងកន្លែងដែលជាទូទៅមានទីធ្លាមិនមានគ្រប់គ្រាន់នោះទេ) ។

សម្រាប់តំបន់ឆ្នេរផ្សេងៗទៀត ចូរធ្វើមួយស្រទាប់ម្តងមួយស្រទាប់ម្តង និងចូរប្រើប្រាស់នូវលក្ខណៈវិនិច្ឆ័យនិងវិធីសាស្ត្រគណនាដែលបានជ្រើសរើស ។ នៅពេលប្រើប្រាស់លក្ខណៈវិនិច្ឆ័យនេះ សូមកុំដាក់កម្រិតខ្លួនឯងឆ្ពោះទៅរកដី គោក ។ វាអាចជាការសំខាន់ក្នុងការដាក់លក្ខខណ្ឌតំបន់ច្រាំងឆ្នេរឆ្ពោះទៅរកសមុទ្រដូចជាដាក់កម្រិតទៅលើវិធីសាស្ត្រគ្រប់គ្រងសំណឹកមួយចំនួន ការកំណត់ល្បឿនកប៉ាល់ធនធំៗ ដែលបើកបរស្ថិតក្នុងចំងាយមួយពីឆ្នេរ(កាត់បន្ថយផលប៉ះពាល់បោសសំអាត-Wash effect), ការដាក់កម្រិត ឬលក្ខខណ្ឌទៅលើការខួងរ៉ែ រឺការដាក់ពង្រាយបំពង់ប្រេង/ឧស្ម័ន និងខ្សែរកាប ។

## បញ្ហាពាក់ព័ន្ធមួយចំនួនក្នុងការប្រើប្រាស់វិធីសាស្ត្រផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមដោយធ្វើផែនការវេទង ដីគោក និងសមុទ្រចម្រុះ និងការបញ្ជ្រាបការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុនៅក្នុងដំណាក់កាលទី៣

ផ្នែកដ៏សំខាន់នៃជំហាននេះ ដូចបានពិពណ៌នានៅទីនេះ គឺផ្តោតសំខាន់ទៅលើយុទ្ធសាស្ត្រដែលគាំទ្រដល់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ។ ទាក់ទងនឹងជំហាននេះ បញ្ហាពាក់ព័ន្ធនៃការដាក់បញ្ចូលវិធីសាស្ត្រថ្មីៗទាំងនេះគឺៈ

- ដើម្បីធានាថា នៅពេលធ្វើការកំណត់តំបន់សំរាប់ការការពារប្រព័ន្ធអេកូស៊ីស្ទែម តំបន់សមស្របត្រូវបានត្រូវដាក់បញ្ចូលដើម្បីធានាពីបូរណភាពនៃប្រព័ន្ធអេកូស៊ីស្ទែមទាំងមូល ។ ចូរពិចារណាអំពីផលប៉ះពាល់ទាំងនេះ ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ហើយប្រសិនបើចាំបាច់គួរបង្កើតទីធ្លាបន្ថែមសម្រាប់ប្រព័ន្ធអេកូស៊ីស្ទែមដើម្បីបន្សាំ

ទៅនឹងលក្ខខណ្ឌថ្មីៗ។ ឧទាហរណ៍ ការកើនឡើងកម្ពស់ទឹកសមុទ្រអាចបណ្តាលឱ្យព្រៃកោងកាងនៅតំបន់មួយចំនួនរំកិលទៅរកដីគោក។ នៅពេលធ្វើការពិចារណាអំពីការកំណត់តំបន់សម្រាប់ការការពារព្រៃកោងកាងវាជាការចាំបាច់នោះត្រូវតែទុកតំបន់ទំនេរណាមួយនៅលើដីសម្រាប់ការផ្លាស់ប្តូរនេះ។

- ការប្រែប្រួលអាកាសធាតុគឺជាផ្នែកមួយដ៏សំខាន់នៃការគ្រប់គ្រងការហូរច្រោះនៅតាមតំបន់ឆ្នេរតែបញ្ហានេះវាមិនមែនមកពីកត្តាតែមួយនេះទេ។ ជាពិសេស នៅពេលធ្វើការអង្កេតពីមូលហេតុនៃសំណឹកនៅតាមតំបន់ឆ្នេរនោះសូមគិតគូរលើការប្រើប្រាស់សមុទ្រដែលអាចធ្វើឱ្យដំណើរការនេះកាន់តែមានបញ្ហាធ្ងន់ធ្ងរឡើងៗ។ ជាពិសេស តំបន់នៅជាប់ប្រជុំកោះជាកន្លែងនាវាអ្នកដំណើរ និងនាវាដឹកទំនិញជាច្រើនបានឆ្លងកាត់ជាប្រចាំ។ វាក៏អាចមានសកម្មភាពជាច្រើនទៀតដូចជា ការរុករករ៉ែ ប្រេង ហ្គាស ការបូមភក់និងការដាក់ពង្រាយបំពង់ដែលអាចរំខានដល់ឥទ្ធិពលធម្មជាតិធ្វើឱ្យកាន់តែចុះខ្សោយនូវសេវាកម្មប្រព័ន្ធការពារអេកូស៊ីស្ទែម និងរុក្ខជាតិធម្មជាតិ និងបង្កឱ្យមានសំណឹក។ សូមដោះស្រាយបញ្ហាទាំងអស់នេះនៅប្រភពដើមរបស់វា។
- ធ្វើការសិក្សាស្រាវជ្រាវលើភាពងាយរងគ្រោះដោយសារការកើនឡើងកម្ពស់ទឹកសមុទ្រតំបន់ឆ្នេរ
- ចូរកំណត់តំបន់ជាពិសេសដើម្បីកាត់បន្ថយការប្រឈម (ជាពិសេសក្រុមងាយរងគ្រោះដោយកត្តាសេដ្ឋកិច្ច-សង្គម) ចំពោះមុខសញ្ញាគ្រោះថ្នាក់ ម្យ៉ាងវិញទៀតចូរធានាថាការកំណត់តំបន់នេះអាចចេញចូលទៅបាននិងអាចភាសខ្លួនបាន។ កន្លែងដែលក្រុមងាយរងគ្រោះតាំងទីលំនៅនៅតំបន់ប្រឈមនឹងហានិភ័យនោះរៀបចំផែនការដើម្បីកំណត់ដីដែលជាជម្រើសសមស្របសម្រាប់ពួកគេ និងថាតើកន្លែងណាដែលពួកគេអាចគេចខ្លួនពីព្រឹត្តិការណ៍គ្រោះមហន្តរាយនេះបាន។

**លទ្ធផល**

នៅចុងបញ្ចប់នៃជំហាននេះ អ្នកគួរទទួលបានលទ្ធផល និងសមិទ្ធិផលដូចតទៅ:

- ការពិពណ៌នា និង ផែនទីដែលបង្ហាញពីតំបន់ឆ្នេរសមុទ្រដោយមានយុទ្ធសាស្ត្រសមស្របសម្រាប់ការគ្រប់គ្រងទាំងផ្នែកលើដី និងផ្ទៃសមុទ្រ
- តំបន់ Set back រឺតំបន់ត្រួតពិនិត្យការអភិវឌ្ឍដែលមានសមមូលគ្នា ដោយមានការពិពណ៌នាពីមូលហេតុ និងលក្ខខណ្ឌដែលបានភ្ជាប់ជូន
- វាយតម្លៃយុទ្ធសាស្ត្របរិស្ថាននៃជម្រើសអភិវឌ្ឍន៍ដែលបានបញ្ជាក់ក្នុងដំណាក់កាលទី២
- ពង្រាងផែនការការប្រើប្រាស់តំបន់រួមមាន: ផែនទី និងអត្ថបទ និងលក្ខខណ្ឌមួយចំនួនដែលបានភ្ជាប់ជាមួយ
- ប្រសិនបើអាច ឯកសារ និងផែនទីអាចផ្តល់ឱ្យជាទៅពីរផ្នែក ***ផ្នែកបច្ចេកទេសពេញលេញដោយមានជាឯកសារ និងឧបសម្ព័ន្ធ និងផ្នែកសង្ខេបសំខាន់ៗសម្រាប់អ្នកធ្វើការសម្រេចចិត្ត និងសាធារណៈជនទូទៅ***។

***អ្នកអាចប្រើប្រាស់បញ្ជីសំនួរខាងក្រោមផងដែរ:***

- តើការការកំណត់ច្រាំងសមុទ្របានបញ្ចប់ហើយឬនៅដោយរាប់បញ្ចូលការទាំងការរៀបរាប់ពីដំណើរការស្រដៀងគ្នា?
- តើយុទ្ធសាស្ត្រច្រាំងសមុទ្រត្រូវបានកំណត់សម្រាប់គ្រប់ផ្នែកនៃតំបន់ឆ្នេរទាំងអស់ដែលទាក់ទងនឹងសំណឹក និងផលប៉ះពាល់ពីកំណើនកម្ពស់ទឹកសមុទ្រទេ?
- តើលក្ខណៈវិនិច្ឆ័យសមស្របសម្រាប់តំបន់ឆ្នេរត្រូវបានបង្កើត និងកំណត់ហើយរឺនៅ?
- តើយុទ្ធសាស្ត្រការពារច្រាំងសមុទ្រត្រូវបានពិចារណា និងជ្រើសរើសឱ្យបានសមស្របទេ?
- តើជម្រើសជាយុទ្ធសាស្ត្រត្រូវបានស្នើឡើង និងវាយតម្លៃទាក់ទងនឹងបរិស្ថាន សង្គម និងនិរន្តរភាពសេដ្ឋកិច្ចដែរឬទេ? (ឧ. តើការវាយតម្លៃផលប៉ះពាល់ជាយុទ្ធសាស្ត្រត្រូវបានអនុវត្តដែរឬទេ?)។
- តើផែនការបែងចែកតំបន់ត្រូវបានធ្វើឡើងដោយធ្វើការពិពណ៌នានូវការប្រើប្រាស់ ការហាមឃាត់ និងអនុញ្ញាតដែររឺទេ?
- តើអត្ថបទអមមកជាមួយនេះធ្វើហើយរឺនៅ? តើវាមានពីរផ្នែក-ផ្នែកបច្ចេកវិទ្យានិងផ្នែកសង្ខេបសំខាន់ៗទេ?

## ជំហានទី៤: ការចរចា

***នៅផ្នែកនេះអ្នកនឹងឃើញ:***

- ការចរចាកើតឡើងពេញដំណើរការ CSP ដែលជាផ្នែកមួយនៃការពិភាក្សាយ៉ាងសកម្មជាមួយអ្នកពាក់ព័ន្ធ
- ប្រសិនបើការពិភាក្សា/ការចរចាដូចដែលពួកគេគួរធ្វើឡើងក្នុងដំណើរការនេះមែនវានឹងមានការលំបាកកាន់តែច្រើន និងទាមទារឱ្យមានការសម្របសម្រួលលើបញ្ហាទាំងនេះ នៅពេលដែលពង្រាងផែនការប្រើប្រាស់តំបន់ឆ្នេរបានរៀបចំឡើង
- ការផ្តល់គំនិតរៀបចំការពិភាក្សាចុងក្រោយនៅមុនពេលបញ្ចប់ផែនការប្រើប្រាស់តំបន់ឆ្នេរ និងកម្មវិធីអនុវត្តន៍។

ដ្យាក្រាមខាងក្រោមបង្ហាញពីការប្រៀបធៀបរវាងគំរូផែនការថ្មី និងចាស់ស្តីពីការចូលរួមរបស់អ្នកពាក់ព័ន្ធ។ បើទោះបីជាការចរចាធ្វើឡើងនៅជំហ៊ានទី៤នេះក៏ដោយ អន្តរកម្មរវាងក្រុមអ្នកធ្វើផែនការ និងក្រុមអ្នកពាក់ពន្ធ័កើតមានឡើងនៅដំណាក់ជាច្រើនក្នុងការដំណើរការធ្វើផែនការនេះ។ ប៉ុន្តែ វាមិនមែនផ្តោតតែលើពេលវេលា និងភាពញឹកញាប់នៃអន្តរកម្មដែលមានភាពខុសគ្នារវាងផែនការថ្មី និងចាស់ ប៉ុន្តែសូម្បីតែតួនាទី និងការទទួលខុសត្រូវ និងសារៈសំខាន់ដែលបានផ្តល់ឱ្យចំពោះទំនាក់ទំនងទាំងនេះផងដែរ។

នៅក្នុងគំរូផែនការចាស់ ជាទូទៅ អ្នកពាក់ព័ន្ធផ្តល់ព័តិមានទៅតាមសំណូមពរ។ នៅក្នុងផ្នែកខាងដើមនៃ ដំណើរការនេះ អ្នកពាក់ព័ន្ធភាគច្រើនគឺស្ថាប័នវិស័យសាធារណៈដែលផ្តល់ព័តិមានតាមផ្នែក។ នៅពេលខ្លះ ក៏មានការស្ទាបស្ទង់កម្រិតគ្រួសារ ដែលតាមរយៈនោះក្រុមរៀបចំផែនការទទួលបានទិន្នន័យតាមរយៈរបៀបរៀបចំរចនាសម្ព័ន្ធ។ ការធ្វើបែបនេះនៅបន្ទាប់ពីការធ្វើពង្រាងផែនការដែលអ្នកពាក់ព័ន្ធទាំងអស់មានឱកាសឆ្លើយតបនឹងសំណើនេះ។ ការចូលរួមស្ថិតក្រោមគំរូចាស់គឺវាមានលក្ខណៈបែបប្រតិកម្ម និងឆ្លើយតប។

នៅក្រោមគំរូផែនការថ្មី អ្នកពាក់ព័ន្ធមានតួនាទីកាន់តែទូលំទូលាយ និងកាន់តែស៊ីជម្រៅ។ ពួកគេបន្តផ្តល់ព័តិមាន ប៉ុន្តែឥឡូវនេះស្ថិតនៅក្នុងតួនាទីមួយដែលមានឥទ្ធិពលដល់ការកំណត់ទិសដៅនៃផែនការដោយចូលរួមយ៉ាងសកម្មក្នុងការបង្កើតនូវចក្ខុវិស័យដែលបញ្ជ្រាបទៅក្នុងគោលដៅរយៈពេលវែង កំណត់អាទិភាព ពិភាក្សាពីជម្រើសយុទ្ធសាស្ត្រ និងលក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃរបស់ពួកគេ។ ហេតុដូចនេះ ពួកគេមានតួនាទីកាន់តែខ្លាំងថែមទៀតក្នុងការពិនិត្យពង្រាងឯកសារចុងក្រោយ និងផ្តល់នូវមតិយោបល់។




គោលបំណងមួយនៃជំហានទី៤គឺដើម្បីកំណត់នូវភាពមិនស៊ីគ្នាជាមួយនឹងកម្រិត និងប្រភេទនៃការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរ ធ្វើការតាមដានលើបញ្ហា និងវិវាទដ៏មានសក្ដានុពលជាមួយនឹងគោលនយោបាយ និងសារាចរផ្សេងៗទៀត។ ប្រការនេះនាំឱ្យមានការពិភាក្សាគ្នាមួយចំនួនតាមបែបចរចាទាក់ទងនឹងបញ្ហាសំខាន់ៗ។

យើងចាំបាច់ត្រូវគូសបញ្ជាក់នូវទស្សនៈទាននៃការចរចាក្នុងដំណើរការពីខាងដើម ដោយសារតែ នេះជាមធ្យោបាយមួយផ្សេងទៀតក្នុងការដោះស្រាយទំនាស់ផលប្រយោជន៍ ដូច្នេះចូរកុំយកចិត្តទុកដាក់ ឬចាត់ទុកពួកគេថាជាបញ្ហាដែលមិនអាចដោះស្រាយបាន។ ក្នុងការពិភាក្សា និងជជែកវែកញែកនោះមានការយកចិត្តទុកដាក់ស្តាប់តិចតួចណាស់ ហើយភាគច្រើនព្យាយាមបញ្ចុះបញ្ចូលភាគីប្រឆាំងនូវរឿងអ្វីមួយ។ ជារឿយៗ បញ្ហានេះអាចបង្កឱ្យមានឧបសគ្គមួយចំនួនដល់ការពិភាក្សា។ ប្រសិនបើអ្នកមានបំណងជជែកវែកញែកជាមួយដៃគូនោះអ្នកនឹងមានឱកាសស្វែងរកដំណោះស្រាយប្រកបដោយការច្នៃប្រឌិតវិសាលភាព និងទស្សនៈវិស័យថ្មីៗចំពោះបញ្ហា និងវិវាទ។ ជានិច្ចកាល អ្នកសម្របសម្រួលប្រកបដោយភាពប៉ិនប្រសព្វគឺយល់ដឹងពីរបច្ចេកទេស និងមធ្យោបាយជម្រុញឱ្យមានការជជែកវែកញែកជាជាងការពិភាក្សា។

មានដ្យាក្រាមមួយនៅផ្នែកខាងស្តាំជួយរំលឹកនាក់នូវដំណើរការនេះ។ ដ្យាក្រាមលើកឡើងនៅទីនេះដើម្បីបង្ហាញថាការពិគ្រោះយោបល់ជាមួយអ្នកពាក់ពន្ធ័ផ្តល់នូវធាតុចូលចំពោះជំហានបន្តបន្ទាប់ៗហើយការចូលរួមរបស់ពួកគេគួរតែបន្ត។ លទ្ធផលទទួលបានពីសិក្ខាសាលាអ្នកពាក់ព័ន្ធស្តីពីការធ្វើផែនទីធនធាន ការបង្កើតចក្ខុវិស័យ និងគោលដៅ និងលទ្ធផលទទួលបានពីការសិក្សាសំខាន់ៗដូចដែលបានចងក្រងនៅក្នុង "របាយការណ៍ស្តីពីស្ថានការណ៍បច្ចុប្បន្ន" នោះគឺអនុឡោមតាមការវិភាគ និង ការវាយតម្លៃបច្ចេទេស និងកិច្ចពិភាក្សារបស់អ្នកពាក់ព័ន្ធ។ ភាពជោគជ័យនៃការអនុវត្តផែនការមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងថាតើនឹងមានការចូលរួមរបស់អ្នកពាក់ពន្ធ័តាំងពីការចាប់ផ្តើមដំណើរការដល់កម្រិតណា។ ឧទាហរណ៍យើងមានប្រធាននាយកដ្ឋានតាមវិស័យមួយៗដែលទទួលខុសត្រូវចំពោះថវិកាតាមវិស័យ និងទិសដៅរយៈពេលខ្លីដែលអាចមានភាពខុសគ្នាពីអ្នកមានមុខជំនួញផ្នែកទេសចរណ៍តូចតាចនិងមិនផ្លូវការមួយចំនួននៅតាមឆ្នេរសមុទ្រ។

សមាសធាតុមួយក្នុងចំណោមសមាសធាតុសំខាន់ៗនៅក្នុងផែនការគឺជាទស្សនៈទាននៃ "ភាពជាម្ចាស់នៃផែនការ-Plan Ownership"។ ប្រការត្រូវគិតគូរថាតើនរណាជាកត្តាជម្រុញនៃដំណើរការទាំងមូលនេះព្រមទាំងថាតើអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តផែនការនោះ។ មូលដ្ឋានគ្រឹះសម្រាប់ការពិភាក្សាជាមួយអ្នកពាក់ពន្ធ័សំខាន់ៗអំពីការជ្រើសរើសអាទិភាពគួរតែមានតាំងពីចំណុចចាប់ផ្តើមនៃដំណើរការនេះនិងមានទំនាក់ទនងយ៉ាងច្បាស់ទៅនឹងចក្ខុវិស័យ និង គោលដៅរយៈពេលវែង។ នៅពេលរបាយការណ៍ស្តីពីការវិភាគស្ថានការណ៍បច្ចុប្បនធ្វើរួចរាល់នោះ របាយការណ៍នេះអាចត្រូវចែកចាយឱ្យអ្នកពាក់ពន្ធ័ដើម្បីសុំយោបល់ និងបញ្ជាក់ពីការចូលរួមរបស់ពួកគេក្នុងការរៀបចំផែនការនេះ។ លទ្ធផលល្អនៃដំណើរការរៀបចំផែនការនេះអាស្រ័យលើថាតើអ្នកពាក់ព័ន្ធបានចូលរួមដល់កម្រិតណាដើម្បីអនុវត្តតាមដំណើរការធ្វើផែនការដោយមានការយល់ដឹងពីជម្រើសអភិវឌ្ឍន៍។

នៅពេលសំណើគម្រោងផែនការ(ផែនទីកំណត់តំបន់និងរបាយការណ៍ផែនការ)បានរៀបចំរួចរាល់យើងចាំបាច់ត្រូវចែករំលែកសម្ភារៈធ្វើផែនការទាំងនេះទៅកាន់ភាគីពាក់ពន្ធ័ និងក្រុមអ្នកពាក់ពន្ធ័ឱ្យបានកាន់តែទូលំទូលាយថែមទៀតសម្រាប់

ការពិភាក្សានិងការផ្តល់យោបល់កែលំអរ ។ ការវិភាគពីផលប៉ះពាល់នៃជម្រើសសេណារីយោអភិវឌ្ឍន៍នានាដែលអាចធ្វើបានគួរតែអនុវត្តជាក់ស្តែង និងត្រូវបង្ហាញឱ្យច្បាស់នូវជម្រើសដោះស្រាយសមស្រប ។

***គម្រូយនៃការពិភាក្សា និងការចរចាមួយចំនួនៈ***

- នៅពេលពិភាក្សាពីបញ្ហាចម្រុងចម្រះត្រូវពិចារណាលើការចូលរួមរបស់អ្នកសម្របសម្រួលអព្យាក្រិត
- យើងត្រូវជៀសវាងនូវការផ្តល់គំនិតផ្សេងៗគ្នាជាលក្ខណៈបុគ្គល ។ អ្នកសម្របសម្រួល ឬប្រធាន នៃកិច្ចប្រជុំគួរផ្តោតការយកចិត្តទុកដាក់លើបញ្ហាជាក់ស្តែង និងត្រូវសម្រេចបាននូវដំណោះស្រាយមួយ
- រក្សាទស្សនៈនេះទុកក្នុងចិត្ត និងប្រើប្រាស់វាដើម្បីស្វែងរកមូលដ្ឋានរួមសំរាប់ដោះស្រាយឱ្យបានសម្របសម្រួល និងប្រកបដោយការច្នៃប្រឌិត
- ពិនិត្យលើការវិភាគរបស់អ្នកពាក់ព័ន្ធមុនពេលបញ្ចូលទៅក្នុងការពិភាក្សា ។ រៀនសូត្រពីអកប្បកិរិយារបស់អ្នកពាក់ព័ន្ធនិងការធ្វើបទបង្ហាញពីផែនការរបស់អ្នកនិងប្រធានបទសម្រាប់កិច្ចពិភាក្សាក្នុងរបៀបមួយដែលនឹងកាត់បន្ថយការខ្វែងគំនិតគ្នា និងឆ្ពោះទៅរកដំណោះស្រាយឈ្នះ-ឈ្នះ
- ប្រសិនបើអាចធ្វើទៅបានយើងត្រូវផ្សព្វផ្សាយផែនការនោះនៅក្នុងសារព័ត៌មានថ្នាក់តំបន់ និងក្នុងស្រុក ។
- សម្ភារៈផ្សព្វផ្សាយគួររួមជាមួយនូវអត្ថបទពន្យល់នូវគោលបំណងនៃការពិគ្រោះយោបល់សំនួរសំខាន់ៗមួយចំនួនដែលត្រូវឆ្លើយព័ត៌មានទាក់ទងផ្ទាល់ទៅដល់អ្នករៀបចំផែនការដែលមានទំនួលខុសត្រូវនិងកំណត់កាលបរិច្ឆេទចុងក្រោយដើម្បីសំយោបល់ជាលាយល័ក្ខអក្សរ
- ពង្រឹងការផ្សាយពីផែនការ និងគួរតែមានកិច្ចពិភាក្សា និងឱ្យដឹងឮជាសាធារណៈ
- ទាំងឯកសារថតចម្លង និងឯកសារអេឡិចត្រូនិចត្រូវតែចែកជូនដល់អ្នកពាក់ព័ន្ធ
- រៀបចំសិក្ខាសាលាអ្នកពាក់ព័ន្ធដោយមានអ្នកសម្របសម្រួលប្រកបដោយទេព្យកោសល្យនោះអាចឱ្យយើងសម្រេចបាននូវលទ្ធផលយ៉ាងឆាប់រហ័សនិងមានប្រសិទ្ធភាពជាងការរៀបចំកិច្ចប្រជុំដាច់ដោយឡែកនិងជាលក្ខណៈឯកជន ។ ប៉ុន្តែបញ្ហាខ្លះមានលក្ខណៈរសើបដែលទាមទារឱ្យមានកិច្ចប្រជុំដាច់ដោយឡែកយ៉ាងហោចណាស់នៅដំណាក់កាលចាប់ផ្តើម ដើម្បីផ្តល់នូវមធ្យោបាយដ៏មានអត្ថប្រយោជន៍សម្រាប់ដំណើរឆ្ពោះទៅមុខ ។
- ជួនកាលយើងចាំបាច់ត្រូវភ្ជាប់ទំនាក់ទំនងទៅនឹងសារព័ត៌មានក្នុងស្រុកដូចជា សារព័ត៌មានប្រចាំសប្តាហ៍ ឬកម្មវិធីតាមស្ថានីយ៍ទូរទស្សន៍ប្រចាំតំបន់
- សម្រាប់អ្នកពាក់ព័ន្ធដ៏មានឥទ្ធិពលមួយចំនួនកិច្ចប្រជុំគួរតែរៀបចំឡើងនៅតាមការិយាល័យនីមួយៗរបស់ពួកគេ

ឥឡូវនេះ មតិកែលំអរសំខាន់ៗដែលបង្កើននូវនូវទំនាស់ផលប្រយោជន៍ និងតម្រូវការប្រើប្រាស់ដីជាប់គាំងនៅពេលដែលអ្នកពាក់ពន្ធ័មួយចំនួនអាចយល់ថាក្តីស្រម័យផ្ទាល់របស់ពួកគេចំពោះទម្រង់នៃការអភិវឌ្ឍជាក់លាក់ប្រហែលជាមិនដឹង។ ទិន្នផលនៃពង្រាងផែនការប្រើប្រាស់តំបន់ឆ្នេរគឺជាឯកសារសំខាន់មួយដែលផ្តល់នូវឱកាសពិសេសមួយសម្រាប់ការពិភាក្សា និងកិច្ចចរចា។

## កិច្ចការទី១: ការចែកចាយ បោះពុម្ពផ្សាយ និងការផ្តល់យោបល់

នេះគឺជាការងារដ៏ងាយស្រួលដើម្បីធានាថាអ្នកពាក់ព័ន្ធសំខាន់ៗ និង ក្រុមអ្នកពាក់ព័ន្ធទាំងអស់បានទទួលនូវពង្រាងផែនការនេះ។ ពង្រាងផែនការនេះអាចធ្វើឡើងតាមវិធីជាច្រើនៈ

- **ផ្សព្វផ្សាយតាមប្រព័ន្ធក្នុងស្រុក** ដែលពង្រាងផែនការនេះត្រូវបានបញ្ចប់សម្រាប់ ការពិភាក្សា និង ការផ្តល់មតិយោបល់កែលំអរ។ សូមបញ្ជាក់ថាតើគេអាចរកឯកសារថតចម្លងនេះបាននៅកន្លែងណា។ នេះគឺជាវិធីសាស្ត្រអកម្ម ដែលទទួលបានចម្លើយតិចតួចលើកលែងតែកន្លែងដែលផែនការនេះនិយាយលំអិតនិងមានប្រយោជន៍ដល់ក្រុមគ្រួសារនីមួយៗ។
- **បញ្ចូលឯកសារទៅក្នុងប្រពន្ឋ័អ៊ីនធើណេត** និងតាមរយៈប្រព័ន្ធផ្សព្វផ្សាយ បង្ហាញថា សូមសាធារណៈជនចូលមើលផែនការនេះ និងសូមផ្តល់មតិយោបល់កែលំអរ។ វិធីសាស្ត្រនេះអាចមានផលវិបាកមួយចំនួនប្រសិនបើមិនបានគ្រប់គ្រងបច្ចេកទេសឱ្យបានល្អទេ។ យើងអាចសន្មត់ថានឹងអាចមានការផ្តល់នូវមតិយោបល់កែលំអរនៅតាមគេហទំព័រនេះដែលជាថ្នូរមកវិញទាមទារឱ្យមានទីធ្លាគ្រប់គ្រាន់ដើម្បីឱ្យគេផ្តល់យោបល់។ ប្រសិនបើផែនការនេះត្រូវបានដាក់ជាលក្ខណៈបើកចំហរនោះវាអាចទទួលបានមតិយោបល់កែលំអរពីអន្តរជាតិច្រើនជាងមតិយោបល់កែលំអរពីអ្នកពាក់ពន្ធ័ក្នុងស្រុក។ យើងក៏ត្រូវកំណត់នូវបច្ចេកទេសជាក់លាក់មួយចំនួនដើម្បីកាពារកុំឱ្យអ្នកនៅក្រៅតំបន់សិក្សារបស់យើងអាចផ្តល់យោបល់បាន។
- **ផ្តល់ឯកសារថតចម្លងដល់អ្នកពាក់ព័ន្ធសំខាន់ៗ** ទាំងឯកសារអេឡិចត្រូនិច និងឯកសារថតចម្លង ដែលយើងអាចធ្វើតាមរយៈប៉ុស្តិ៍ប្រៃសណីយ៍ និងដោយដៃដោយផ្អែកលើកាលៈទេសៈជាក់ស្តែង។ សូមធ្វើលិខិតភ្ជាប់មួយដែលស្នើសុំឱ្យផ្តល់មតិយោបល់កែលំអរជាលាយលក្ខ័អក្សរ និងបញ្ជាក់ពីកាលបរិច្ឆេទជាក់លាក់។
- **បញ្ជាក់ពីទីកន្លែង និងអញ្ជើញអ្នកពាក់ព័ន្ធចូលរួមប្រជុំ** ដើម្បីស្តាប់បទបង្ហាញ និងចូលរួមក្នុងការពិភាក្សាជាសាធារណៈលើពង្រាងផែនការ។ សារៈប្រយោជន៍របស់វាគឺថាអ្នកចូលរួមនឹងផ្តល់មតិយោបល់កែលំអរបន្ថែមទៀតរួមគ្នាជាជាងការនៅតែម្នាក់ឯង ពួកគេនឹងរៀនពីបទពិសោធន៍ទាំងនេះ ហើយពួកគេរិតតែមានភាពជាម្ចាស់នៅពេលដែលពួកគេឃើញមានការពិភាក្សាគ្នាទៅវិញទៅមកលើពង្រាងផែនការនេះ។
- **ធ្វើទាំងពីរៈ** ផ្ញើរចេញនូវពង្រាងផែនការជាមួយនឹងលិខិតភ្ជាប់ដោយអញ្ជើញអ្នកពាក់ពន្ធ័ទាំងនោះឱ្យប្រមូលផ្តុំ

គ្នាក្នុងគោលបំណងស្តាប់បទបង្ហាញនៃពង្រាងផែនការនេះនឹងធ្វើការពិភាក្សា។ លិខិតនេះ គួរបញ្ជាក់ផងដែរថា សូមស្វាគមន៍ចំពោះមតិយោបល់កែលំអរជាលាយលក្ខ័អក្សរ។ នៅក្នុងកិច្ចប្រជុំជាសាធារណៈ អ្នកចូលរួមត្រូវបានក្រើនរំលឹកផងដែរថា សូមស្វាគមន៍រាល់មតិយោបល់កែលំអរជាលាយលក្ខ័អក្សរសម្រាប់រយៈពេលជាក់លាក់ណាមួយ។ វាមានសារៈសំខាន់ដើម្បីផ្តល់នូវកាលកំណត់សមស្រប បើមិនអញ្ចឹងទេ អ្នកពាក់ពន្ធ័ភាគច្រើននឹងមិនបានផ្តល់មតិយោបល់កែលំអរនោះទេ។
ក្រុម CSP ត្រូវតែត្រៀមខ្លួនដើម្បីរៀបចំ និងធ្វើការវាយតម្លៃលើមតិយោបល់កែលំអរទាំងអស់នោះ។

## កិច្ចការទី២ ការរៀបចំពង្រាងផែនការបែងចែកតំបន់ប្រើប្រាស់ដោយផ្អែកលើការពិនិត្យយ៉ាងហ្មត់ចត់នូវមតិយោបល់ដែលទទួលបាន

នៅពេលដែលទទួលបានមតិយោបល់កែលំអរ ឬកិច្ចប្រជុំជាមួយអ្នកពាក់ព័ន្ធក្រុម CSP អាចចាប់ផ្តើមវាយតម្លៃលើមតិយោបល់កែលំអរទាំងអស់នោះ។ ពួកគេគួរអនុវត្តការងារនេះ ដោយប្រុងប្រយត្ន័ ប៉ុន្តែក៏ត្រូវប្រកបដោយបត្យានុម័តផងដែរហើយពួកគេគួរធ្វើការវាយតម្លៃជាប្រចាំចំពោះការរកឃើញនូវការវាយតម្លៃផ្ទៃក្នុង និងបញ្ហាពាក់ព័ន្ធមួយចំនួនដើម្បីម្រេចបានគោលដៅរយៈពេលយូរ។ នៅពេលទទួលបានមតិយោបល់កែលំអរ ពង្រាងផែនការនេះគួរតែកែសម្រួលឡើងវិញ និងសរសេរឡើងវិញ។ របាយការណ៍ចុងក្រោយត្រូវរៀបចំដើម្បីដាក់ជូនសុំការឯកភាពជាផ្លូវការ។

យើងចាំបាច់ត្រូវតែប្រមូលនូវរាល់មតិយោបល់កែលំអរ និង ចាត់ថ្នាក់មតិយោបល់ទាំងនេះដោយយោងទៅតាមគម្រោងសំណើនិងយុទ្ធសាស្រ្តអនុវត្តន៏ទាំងអស់នោះ។ មតិយោបល់កែលំអរទាំងអស់នេះមានសារៈសំខាន់សម្រាប់ជំហានបន្ទាប់។ ក្នុងប្រទេសមួយចំនួន ពង្រាងផែនការចុងក្រោយបានដាក់ជូនរួមជាមួយនឹងរបាយការណ៍ស្តីពីដំណើរការពិគ្រោះយោបល់។ ក្នុងករណីបែបនេះ អាជ្ញាធមិដែលទទួលខុសត្រូវលើការអនុម័តត្រូវតែធានាថាការពិគ្រោះយោបល់ពិតជាមានមែនហើយថាផែនការនេះទទួលបានការគាំទ្រយ៉ាងទូលំទូលាយ។ ដំណើរការអនុម័តអាចធ្វើឱ្យមានការកែប្រែ និងកែសម្រួលឡើងវិញលើផែនការនេះផងដែរ។ ដោយផ្អែកលើលក្ខណៈ និងកំរិតនៃការកែសម្រួលឡើងវិញនេះ ដំណើរការអនុម័តអាចត្រូវការពេលយូរបន្តិច។ នៅពេលដែលឯកសារចុងក្រោយត្រូវបានរៀបចំនិងអនុម័តរួចរាល់នោះអ្នកពាក់ពន្ធ័ទាំងអស់នោះគួរជូនដំណឹងនិងថ្លែងអំណរគុណចំពោះការចូលរួមចំណែកផ្តល់នូវមតិយោបល់របស់ពួកគេ និងអញ្ជើញពួកគាត់បន្តចូលរួមត្រួតពិនិត្យនិងវាយតម្លៃចំពោះការអនុវត្តផែនការនេះ។

## បញ្ហាពាក់ព័ន្ធក្នុងការប្រើប្រាស់វិធីសាស្ត្រផ្អែកលើប្រព័ន្ធអេកូស៊ីស្តែមដោយធ្វើផែនការវាងដីគោក និងសមុទ្រចម្រុះនិងការបញ្ជ្រាបការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុ

ដោយបញ្ចូលនូវបញ្ហាថ្មីៗទាំងនេះទៅក្នុងដំណើរការធ្វើផែនការនាំឱ្យមានវិសាលភាពថ្មីៗដែលពង្រីងកិច្ចការនេះឱ្យទទួលបាននូវការចូលរួមកាន់តែទូលំទូលាយចំពោះគំរូថ្មីនេះ ។ វាជាការពិតសម្រាប់ហេតុផលមួយចំនួនដូចខាងក្រោមៈ

- ប្រព័ន្ធអេកូស៊ីស្តែមធម្មជាតិមិនអាចនិយាយឱ្យខ្លួនឯងផ្ទាល់នោះទេ និងត្រូវការ "**អ្នកគាំទ្រ**" ដើម្បីជួយនិយាយឱ្យពួកគេ។ នៅក្នុងស្ថានធម្មតា បរិស្ថានធម្មជាតិបានទទួលនូវអាទិភាពទាបបំផុត។ ជារឿយៗ នៅក្រោមវិធីសាស្ត្រនេះ ដីដែលមិនចាំបាច់សំរាប់ការងារអ្វីទៀតនោះត្រូវបានកំណត់សម្រាប់ការអភិរក្ស។ នេះគឺដោយសារតែមានទំនោរឆ្ពោះទៅរក "ទីរហោដ្ឋាន" ប៉ុន្តែវាក៏ដោយសារតែអ្នកធ្វើផែនការខ្វះការបណ្តុះបណ្តាល និងការយល់ដឹងពីសេវាកម្មផ្តល់ដោយប្រព័ន្ធអេកូស៊ីស្តែមចំពោះសង្គមមនុស្សផងដែរ។ នៅពេលដែលបញ្ហានេះត្រូវទទួលស្គាល់យ៉ាងទូលំទូលាយនោះមានការផ្លាស់ប្តូរអកប្បកិរិយាឆ្ពោះទៅរកធម្មជាតិ។ ទោះបីយ៉ាងណាក៏ដោយសម្ពាធដ៏ខ្លាំងក្លាសំរាប់ដែនទឹកតំបន់ឆ្នេរ និងដីគោកក៏ដោយប្រព័ន្ធអេកូស៊ីស្តែមដ៏សំខាន់នេះទាមទារឱ្យមានសំឡេងគាំទ្រខ្លាំងក្លានិងច្បាស់លាស់ដើម្បីការពារពួកគេសម្រាប់ពេលអនាគត ។ការបញ្ចូលនូវអាជ្ញាធរបរិស្ថានសាធារណៈអត្ថប្រយោជន៏នៃការស្រាវជ្រាវបរិស្ថាននិងក្រុមដែលមានប្រយោជន៏ផ្នែកបរិស្ថានរបស់អង្គការមិនមែនរដ្ឋាភិបាលគឺជាមធ្យោបាយដ៏សំខាន់ដើម្បីសម្រេចបានគោលនៅនេះ។ ការចូលរួមនេះត្រូវមានតាំងពីដំណាក់កាលដំបូងនៅពេលដែលរបៀបវារៈការធ្វើផែនការត្រូវបានកំណត់ហើយចក្ខុវិស័យបានបង្កើតឡើងតាមរយៈការរៀបចំយុទ្ធសាស្ត្រ និងកម្មវិធីអនុវត្តន៏ដ៏សកម្មមួយចំនួន។

- ការរៀបចំផែនការតំបន់សមុទ្រ គឺជារឿងថ្មីមួយ ជាពិសេសចំពោះអាជ្ញារៀបចំផែនការប្រើប្រាស់តំបន់ឆ្នេរ ឬផែនការរូបវន្តទូទៅ។ យើងចាំបាច់ត្រូវបញ្ចូលនូវអ្នកពាក់ពន្ធ័ និងតួអង្គធ្វើការផ្នែកសមុទ្រ ចាប់ពីដំណាក់កាលដំបូង និងនៅគ្រប់ដំណើរការទាំងមូលដើម្បីធានាថា ការរួមបញ្ចូលគ្នានៃផែនការដែនដី និងសមុទ្រត្រូវបានអនុវត្តតាមមធ្យោបាយដ៏មានអត្ថន័យ និងអត្ថប្រយោជន៏។

- បញ្ហាដែលមានទំនាក់ទំនងទៅនឹងហានិភ័យ និងមុខសញ្ញាគ្រោះថ្នាក់នោះ ជានិច្ចកាលគឺផ្អែកលើតម្លៃ និងការយល់ឃើញមិនមែនជាការពិតនោះទេ។ ប្រការនេះមានន័យថា វាមានលក្ខណៈមិនគ្រប់គ្រាន់ដើម្បីទទួលនូវធាតុចូលពីអ្នកគ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់ដែលមានមុខជំនាញ និងវិជ្ជាជីវៈកំរិតខ្ពស់ខាងផ្នែកភរវនីយភាពស្ថិតិ និងសេដ្ឋកិច្ច។ សមាសធាតុដ៏សំខាន់មួយក្នុងការគ្រប់គ្រងហានិភ័យមាននៅក្នុងសំនួរថា "តើហានិភ័យ កម្រិតណាដែលសហគមន៏មានបំណងទទួលយកនោះ?" ហើយប្រការនេះមានភាពខុសប្លែកគ្នានៅក្នុងសហគមន៏តែមួយ និងជារឿយៗ វាទាក់ទងទៅនឹងការយល់ដឹងនៃបញ្ហាសេដ្ឋកិច្ច និងកម្រិតសន្តិសុខដែលសហគមន៏អាច "**លៃលកបាន**"។ នេះគឺជាទិដ្ឋភាពមួយដែល អ្នកជំនាញបច្ចេក

ទេសមិនអាចនាំយកទៅធ្វើការពិភាក្សាបាន។ វាមានសារៈសំខាន់ដែលថាសមាជិកសហគមន៍ និងអ្នកដឹកនាំសង្គមចូលរួមនៅក្នុងការពិភាក្សាអំពីការចាត់អាទិភាពមុខសញ្ញាគ្រោះថ្នាក់ ការកំណត់ និងការឱ្យនិយមន័យហានិភ័យ ព្រមទាំងការស្នើថាតើវិធានការអ្វីខ្លះទទួលបានការធានាខ្លាំងបំផុត ចំពោះសហគមន៍ដែលប្រឈមមុខនឹងមុខសញ្ញាគ្រោះថ្នាក់នៅពេលអនាគត។ ប្រការនេះអាចអនុវត្តបានចំពោះមុខសញ្ញាគ្រោះថ្នាក់ភ្លាមៗដូចជា ទឹកជំនន់ រញ្ជួយដី និងខ្យល់ព្យុះ ដូចដែលមានបញ្ជាក់នៅក្នុងបញ្ហាការប្រែប្រួលអាកាសធាតុរយៈពេលវែង។

## ជំហានទី៥: កម្មវិធីអនុវត្តន៍

នៅក្នុងផ្នែកនេះ អ្នកនឹងឃើញនូវទស្សនៈវិស័យនៅក្នុង:

- ការបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងសម្រាប់ធានានូវការអនុវត្តដែលបានកើតឡើងយ៉ាងពិតប្រាកដ
- ការបញ្ចូលនូវកម្មវិធីស្រាវជ្រាវ និងត្រួតពិនិត្យ កម្មវិធី និងយន្តការវាយតម្លៃ និងការឆ្លើយតបដើម្បីកែសម្រួលផែនការ និងកម្មវិធី និងសម្រាប់ការបណ្តុះបណ្តាលស្ថាប័ន
- ការអភិវឌ្ឍ និងការរួមបញ្ចូលសមាសធាតុការកសាងសមត្ថភាពដើម្បីឱ្យសមត្ថភាពស្ថាប័ន និងបុគ្គលផ្ទាល់ខ្លួនត្រូវបានចាត់ទុកថាជាមូលដ្ឋានគ្រឹះសម្រាប់ការអនុវត្ត
- ការតភ្ជាប់នូវកម្មវិធីអនុវត្តទៅនឹងវដ្តថវិកាប្រចាំឆ្នាំនិងចាត់ទុកវាថាជាយន្តការមួយសម្រាប់ដំណើរការត្រួតពិនិត្យ និងកែតម្រូវតាមអត្រានៃការអនុវត្ត។

ផែនការមួយចំនួនអាចត្រូវបានទុកចោល ពីព្រោះផែនការទាំងនោះមិនត្រូវបានរៀបចំ និង បង្កើតឡើងជាក់លាក់សម្រាប់ការអនុវត្ត។ ភាពខុសគ្នាសំខាន់មួយរវាងគំរូរៀបចំផែនការប្រើប្រាស់តំបន់ឆ្នេរចាស់ៗ និងផែនការថ្មីគឺថាផែនការថ្មីផ្តោតសំខាន់តែទៅលើការអនុវត្ត។ វាគឺជាផែនការសម្រាប់ផ្សព្វផ្សាយមិនមែនជាបទបញ្ញត្តិ និង មានលក្ខណៈបង្ការក្នុងការបង្កើតកម្មវិធីឱ្យសម្រេចបាននូវចក្ខុវិស័យនៃតំបន់នោះ។ នេះមានន័យថា នៅក្នុងបរិបទនេះ ផែនការប្រើប្រាស់តំបន់ឆ្នេរថ្មីៗមានផ្នែកមួយដែលពិពណ៌នាជាក់លាក់ពីអ្វីនឹងត្រូវធ្វើដើម្បីធានាថា ការកំណត់តំបន់នឹងមិនគ្រាន់តែត្រូវអនុវត្តតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅក្នុងតំបន់សមស្របមួយចំនួនទៀតផង។

**លទ្ធផល**

***នៅចុងបញ្ចប់នៃជំហាននេះនឹងទទួលបាននូវលទ្ធផល និងផលិតផលដូចខាងក្រោម៖***

- ឯកសារនៃការពិគ្រោះយោបល់ត្រូវរៀបចំឡើងនៅគ្រប់ដំណើរការរៀបចំ CSP ទុកជាកំណត់ត្រាសម្រាប់អ្នកធ្វើការសម្រេចចិត្ត អ្នកផ្តល់ហិរញ្ញវត្ថុ និងអ្នកពាក់ព័ន្ធ និងជាឯកសារដែលអាចទទួលយកបាន និងផ្តល់នូវភាពជឿជាក់។
- ទទួលបាននូវការផ្តល់យោបល់មួយចំនួនទៅលើពង្រាងផែនការបែងចែកតំបន់ពីអ្នកពាក់ព័ន្ធរួមមាន៖
  - ការធ្វើបទបង្ហាញ និងលទ្ធផលនៃសិក្ខាសាលាអ្នកពាក់ព័ន្ធ កិច្ចប្រជុំជាសាធារណៈ
- ទទួលបានផែនការកែសម្រួលមួយដាក់ជូនសុំការឯកភាពជាផ្លូវការហើយផែនការនេះរួមបញ្ចូលនូវព័ត៌មានលំអិតស្តីពីកម្មវិធីអនុវត្តន៍។

***អ្នកក៏អាចប្រើប្រាស់ផងដែរនូវបញ្ជីសំនួរដូចតទៅ៖***

តើក្រុមអ្នកពាក់ព័ន្ធសំខាន់ៗទាំងអស់ចូលរួមជាមួយដំណើរការធ្វើផែនការប្រកបដោយអត្ថន័យ និងយ៉ាងសកម្មដែរឬទេ?

- តើមានអ្នកបរិស្ថានវិទ្យា អ្នកជីវសាស្ត្រសមុទ្រ ឬអ្នកបរិស្ថានវិទ្យាពាក់ព័ន្ធផ្សេងៗទៀត និងក្រុមទទួលបានផលប្រយោជន៍ពីបរិស្ថានចូលរួមដែរឬទេ? តើកង្វល់ចំពោះបរិស្ថាន និងបរិស្ថានវិទ្យាត្រូវបានគិតគូរឱ្យសមតាមអ្វីដែលពួកអាចទទួលបានទេ?
- តើវិស័យសមុទ្រដែលតំណាងឱ្យដំណើរការនេះគ្រប់គ្រាន់ដែរឬទេ?
- តើអ្នកដែលទទួលរងហានិភ័យ ព្រមទាំងក្រុមដែលងាយរងគ្រោះចូលរួមយ៉ាងសកម្មនៅក្នុងផ្នែកដែលពាក់ព័ន្ធនឹងដំណើរការដែរឬទេ?
- តើបញ្ហា/ការជំទាស់ នៃផែនការដែលមានស្រាប់នៅកម្រិតផ្សេងៗគ្នាត្រូវបានបញ្ជាក់ឬដោះស្រាយទេ?
- តើវិវាទដែលមានស្រាប់ និងវិវាទអន្តរវិស័យដ៏មានសក្តានុពលត្រូវបានកំណត់ និងដោះស្រាយឡើងវិញទេ?
- តើមន្ត្រីអាជ្ញាធរតាមផ្នែក និងអង្គការពាក់ព័ន្ធផ្សេងទៀតបានប្តេជ្ញាអនុវត្តផែនការដើម្បីអនុម័ត និង អនុវត្តផែនការតាមរយៈកម្មវិធីគម្រោងជាក់លាក់ទេ?
- តើឯកសារពិគ្រោះយោបល់នូវគ្រប់ដំណើរការរៀបចំផែនការត្រូវបានចងក្រងទេ?តើទទួលបានបទពិសោធន៍ពីដំណើរការពិគ្រោះយោបល់នេះទេ និងតើមេរៀនទាំងនេះត្រូវបានកត់ត្រាទុកទេ?
- តើពង្រាងផែនការបែងចែកតំបន់ចុងក្រោយមានបញ្ចូលនូវការផ្តល់យោបល់ទេហើយតើការផ្តល់យោបល់ទាំងនេះត្រូវបានចងក្រងទេ?

- តើការផ្តល់យោបល់នេះនាំឱ្យមានការកែប្រែផែនការឱ្យមានគុណភាពគ្រប់គ្រាន់ដើម្បីដាក់ជូនសុំការការឯកភាព ឬទេ?

ឧទាហរណ៍ជាក់ស្តែង ផែនការកំណត់តំបន់អាចកំណត់ពីប្រព័ន្ធអេកូស៊ីស្ទែមសមុទ្រដែលងាយរងគ្រោះ និងបែងចែកតំបន់សម្រាប់ការការពារប្រព័ន្ធទាំងនោះ។ ផែនការនេះជាប់ពាក់ព័ន្ធទៅនឹងការហាមឃាត់ការប្រើប្រាស់មួយចំនួន ឬពាក់ព័ន្ធនឹងការដាក់លក្ខខណ្ឌតឹងរឹងលើការប្រើប្រាស់ដែលអនុញ្ញាតឱ្យ។ នៅក្រោមគំរូផែនការចាស់មានលក្ខណៈ គ្រប់គ្រាន់ហើយនៅក្រោមគំរូផែនការថ្មី ការរំពឹងទុកគឺថាអាជ្ញាធរពាក់ពន្ធ័នឹងបង្ហាញកម្មវិធីយ៉ាងសកម្មភាពមួយដែលនឹងធានាថាតំបន់នេះត្រូវបានកំណត់ព្រំប្រទល់ច្បាស់លាស់ ការហាមឃាត់ត្រូវបានអនុម័តហើយលក្ខខណ្ឌសម្រាប់ប្រើប្រាស់ត្រូវបានផ្សព្វផ្សាយដល់អ្នកប្រើប្រាស់ដែលពាក់ព័ន្ធនិងក្រុមដែលទទួលបានអត្ថប្រយោជន៍។ប្រសិនបើករណីចាំបាច់ការបណ្តុះបណ្តាលពិសេសគួរត្រូវបានរៀបចំឡើងដើម្បីធានាថាលក្ខខណ្ឌទាំងនោះបានយល់ដឹង និងអាចទទួលយកបាន។

ភាពជាក់ស្តែងនៃការអនុវត្តទាមទារឱ្យមានពិចារណាល្អិតល្អន់នៅគ្រប់តដំណើរការ CSP ហើយកំហុសរួមមួយនៅជុំវិញពិភពលោកគឺថាផែនការប្រើប្រាស់តំបន់ឆ្នេរមិនគួរដាក់បញ្ចូលអ្វីផ្សេងក្រៅពីការកំណត់ទិសដៅថាតើកន្លែងដែលសកម្មភាពមួយចំនួននឹងត្រូវបានអនុញ្ញាតធ្វើ និងថាតើនៅក្រោមលក្ខខណ្ឌអ្វី។ នេះមានន័យថា បញ្ហាសមត្ថភាពអនុវត្តថាជាអង្គការ និងបុគ្គល ឬក៏ហិរញ្ញវត្ថុដែលបានមកពីការគាំទ្រផ្នែកនយោបាយមិនត្រូវបានពិចារណានោះទេ។ ជាការប្រសើរផែនការប្រភេទនេះគឺគ្រាន់តែជាបទបញ្ញាតិមួយ និងទទួលបានកេរ្តិ៍ឈ្មោះពីការដាក់កម្រិតទៅលើការបន្តតាមរកសេចក្តីប្រាថ្នារបស់ប្រជាពលរដ្ឋ។ក្នុងនាមជាតួបករណ៍បទបញ្ញាតិរបស់រដ្ឋាភិបាលវាផ្តល់ឱ្យវិស័យសាធារណៈនូវកេរ្តិ៍ឈ្មោះមួយដែលជាឧបសគ្គ និងការរារាំងដល់ការអភិវឌ្ឍ និងកំណើន។

ទស្សនៈបែបផ្សព្វផ្សាយនៃផែនការផ្អែកលើចំណុចមួយដែលថាវិស័យសាធារណៈនឹងចាត់វិធានការជាជំហានមួយចំនួនដើម្បីសម្រេចគោលបំណងដែលបានកំណត់នៅក្នុងផែនការនេះ។ការជាប់ពាក់ព័ន្ធរបស់អ្នកពាក់ព័ន្ធក្រៅពីវិស័យសាធារណៈបានបើកផ្លូវសម្រាប់ស្ថាប័នមិនមែនរដ្ឋាភិបាលក្នុងការបង្ហាញការយល់ឃើញផ្ទាល់ខ្លួនរបស់ពួកគេ និងធ្វើការប្តេជ្ញាចិត្តរបស់ពួកគេផ្ទាល់។ យ៉ាងហោចណាស់មានការកំណត់លក្ខខណ្ឌទុកជាមុនសំខាន់ចំនួន៦សម្រាប់ការអនុវត្តកម្មវិធីប្រកបដោយជោគជ័យរួមមាន:

- គោលបំណងគោលនយោបាយស្របគ្នា និងច្បាស់លាស់
- វិទ្យាសាស្ត្រដែលទាក់ទងនឹងគោលនយោបាយល្អ(ការសម្រេចចិត្តផ្អែកលើទិន្នន័យនិងវិធីសាស្ត្រដែលអាចទុកចិត្តបាន)

- សិទ្ធិអំណាច និងយុត្តាធិការគ្រប់គ្រាន់( និងត្រូវបានសម្របសម្រួលយ៉ាងល្អដែលសិទ្ធិអំណាច និងយុត្តាធិការទាំងអស់នេះស្ថិតនៅក្នុងស្ថាប័នអង្គការផ្សេងគ្នា)
- រចនាសម្ព័ន្ធអនុវត្តល្អ
- ការប្តេជ្ញាចិត្ត និងការប្រកួតប្រជែងរបស់បុគ្គលិក
- រក្សាអាទិភាពកម្មវិធីអនុវត្តន៍ស្តីពីរបៀបវារៈសាធារណៈ ។

កិច្ចការដែលបានពិពណ៌នានៅទីនេះផ្តល់មូលដ្ឋានគ្រឹះសម្រាប់ផែនការអនុវត្តន៍ ប្រសិនបើយកវាទៅអនុវត្តបាននឹងធានាថា ផែនការប្រើប្រាស់តំបន់ឆ្នេរត្រូវបានបញ្ជ្រាបទៅក្នុងការងារប្រចាំថ្ងៃរបស់ស្ថាប័ន និងថាតួរអង្គសំខាន់សម្រាប់វិស័យសាធារណៈនឹងគាំទ្រអ្នកពាក់ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដោយផ្ទាល់និងដោយប្រយោលដើម្បីឆ្ពោះទៅរកគោលដៅផ្ទាល់ខ្លួនរបស់ពួកគេ ប៉ុន្តែត្រូវស្របតាមលក្ខខណ្ឌមួយចំនួន ។ កម្មវិធីអនុវត្តន៍នឹងៈ

- ពិពណ៌នាពីអ្វីដែលនឹងត្រូវធ្វើ ទីកន្លែង និងពេលវេលា
- ថាតើអ្នកណានឹងទទួលខុសត្រូវលើអ្វីខ្លះ
- ថាតើនឹងត្រូវគ្រប់គ្រង និងសម្របសម្រួលតាមរបៀបណា
- ថាតើនឹងមានតម្លៃប៉ុន្មាន និង
- ថាតើនឹងត្រូវត្រួតពិនិត្យ និងវាយតម្លៃរបៀបណា ។

ផែនការប្រើប្រាស់តំបន់ឆ្នេររួមបញ្ចូលនូវផែនទីដែលពិពណ៌នាថាតើកន្លែងណាដែលសកម្មភាពនឹងអាចកើតឡើង និងស្ថិតនៅក្រោមលក្ខខណ្ឌអ្វី ។ ទោះបីជាសមាសភាពផ្សេងៗគ្នានៃផែនការអនុវត្តត្រូវបានពិពណ៌នាខាងក្រោមថាជាកិច្ចការដាច់ដោយឡែកក៏ដោយ តែតាមការពិតពួកគេត្រូវបានធ្វើស្របគ្នា និងក្នុងលក្ខណៈអន្តរកម្មគ្នា ។ ជំហានទី៣ និងទី៤ផ្តល់នូវការកំណត់ច្បាស់លាស់ពីអាទិភាពដែលអ្នកពាក់ព័ន្ធបានធ្វើឡើងតាមរយៈដំណើរការ CSP ។ ផែនទីផែនការប្រើប្រាស់តំបន់ឆ្នេរបានបង្ហាញថាតើកន្លែងណាដែលប្រភេទសកម្មភាពច្បាស់លាស់និងការប្រើប្រាស់ធនធានឬការប្រើប្រាស់ដីត្រូវបានអនុញ្ញាតហើយលក្ខខណ្ឌកំណត់តំបន់សម្រាប់ផ្នែកផែនទីនីមួយៗ នឹងត្រូវបានពន្យល់ក្នុងអត្ថបទអម ។

**គោលការណ៍អនុវត្តន៍:**

- បំបែក និងបកស្រាយផែនការបែងចែកតំបន់ជាផែនការសកម្មភាពតូចៗ និងបញ្ចូលទៅក្នុងការពិពណ៌នាគម្រោងនិងការងារដែលមាន និងសមស្រប ។ ចូរប្រើវិធីសាស្ត្រក្របខណ្ឌជាក់លាក់ និងម៉ាទ្រីសដើម្បីជួយសម្រួល ។
- ធានាថាកម្មវិធី គម្រោង និងផែនការយុទ្ធសាស្ត្រអនុវត្តនៅដំណាក់កាលមុនៗមានភាពពិតប្រាកដតាមរយៈការពិនិត្យឡើងវិញដោយតំណាងជាច្រើន ។ ចូរប្រើ SMART ដើម្បីបង្កើតគោលដៅគោលបំណង និងធាតុចេញ ។
- ចូរចងចាំថាមានសូចនាករសម្រាប់ការបញ្ចប់ រឺការរីកចំរើននូវរាល់គម្រោង រឺសកម្មភាពនីមួយៗ ។ ចូរចងចាំផងដែរថា មធ្យោបាយផ្ទៀងផ្ទាត់សូចនាករទាំងនេះមានបញ្ជាក់នៅក្នុងឯកសារគម្រោងដែលចាំបាច់សម្រាប់ការត្រួតពិនិត្យ វាយតំម្លៃ និងអនុវត្តប្រកបដោយប្រសិទ្ធភាព ។
- បង្កើតតួនាទីនិងការទទួលខុសត្រូវសំខាន់ៗសម្រាប់គម្រោងរឺសកម្មភាពនីមួយៗ ឧ.បញ្ចូលនូវអ្នកតំណាងមកពីអង្គការ ក្រុមហ៊ុន និងសហគ្រាសសំខាន់ៗ ។
- ចំពោះគម្រោងរឺសកម្មភាពនីមួយៗចូរបញ្ជាក់ថាតើនរណាកំពុងធ្វើអ្វី និងនៅពេលណា និងចូរប្រើដ្យាក្រាម GANTT ។
- បញ្ជាក់ច្បាស់ពីតួនាទី និងការទទួលខុសត្រូវការអនុវត្តរួមនៃផែនការ
- ធានាថាមានកម្មវីធីរាយការណ៍ និងពិនិត្យឡើងវិញជាប្រចាំ ។ គោលដៅ និងគោលបំណងនៃផែនការជានិច្ចកាល គួរតែបញ្ចូលក្នុងការពិនិត្យឡើងវិញនូវការអនុវត្ត ។
- ដំណើរការឆ្លើយតបត្រូវតែធ្វើនៅពេលវេលាជាក់លាក់ដើម្បីសម្រួល កែតម្រូវ រឺចាត់វិធានការកាត់បន្ថយនៅ ពេលចាំបាច់ ។

ទោះបីយ៉ាងណាក៏ដោយ ការសម្រេចចិត្តទាក់ទងនឹងផែនទីទាមទារឱ្យមានអន្តរាគមពីភាគីពាក់ព័ន្ធជាច្រើន ។ ចូរចាប់ផ្តើមតាមរយៈការរៀបចំបញ្ជីសកម្មភាពងាយៗថាតើសកម្មភាពអ្វីត្រូវអនុវត្ត ។ សកម្មភាពនេះកើតចេញពីដំណាក់កាលដំបូង និងមានការត្រួតពិនិត្យយ៉ាងហ្មត់ចត់នូវផែនការប្រើប្រាស់តំបន់ឆ្នេរដោយរួមទាំងផែនទីផងដែរ ។

ចូរកំណត់ថាតើអង្គការមួយណា និង ផ្នែកណាជាអ្នកទទួលខុសត្រូវដើម្បីធានាថាសកម្មភាពនីមួយៗបានអនុវត្ត ។ ចូរចុះបញ្ជីអង្គការនិងអ្នកពាក់ព័ន្ធផ្សេងៗទៀត ។ ការងារទាំងនេះរួមមានធាតុចូលមកពីគ្រប់អង្គការជាច្រើនប៉ុន្តែមានអង្គការតែមួយគត់ដែលមានទំនួលខុសត្រូវដើម្បីធានាថាកិច្ចការនោះបានធ្វើរួចរាល់ហើយ ។ (នេះអាចជាគណៈកម្មាធិការសម្របសម្រួលមួយជាមួយនឹងអង្គការជាច្រើនទៀតដែលជាតំណាង ប៉ុន្តែទោះបីជាអញ្ចឹងក៏ដោយប្រធាននៃគណៈកម្មាធិការនេះនឹងទទួលខុសត្រូវដើម្បីធានាថាសកម្មភាពនេះបានដោះស្រាយរួចស្រេច) ។

**កិច្ចការទី១ ចូរពិពណ៌នាពីការសម្របសម្រួលការអនុវត្តផែនការ(រចនាសម្ព័ន្ធគ្រប់គ្រង ការត្រួតពិនិត្យប្រព័ន្ធឆ្លើយតប)**

ផែនការប្រើប្រាស់តំបន់ឆ្នេរដូចដែលបានពិពណ៌នានៅក្នុងឯកសារនេះបានបញ្ចូលធាតុចូលពីអាជ្ញាធរ និងភ្នាក់ងារវិស័យសាធារណៈ វិស័យឯកជន និងសង្គមស៊ីវិល។ ផែនការប្រើប្រាស់តំបន់ឆ្នេរ នៅពេលដែលមានការឯកភាពថាជាឧបករណ៍រួមមួយសម្រាប់ណែនាំនូវសកម្មភាពរយៈពេលខ្លី(៥ឆ្នាំ) ប៉ុន្តែមានចក្ខុវិស័យនឹងគោដៅយូរអង្វែង។ ហេតុដូចនេះបញ្ហាគឺថារាល់ផ្នែករួមចំណែកដល់អាជ្ញាធរវិស័យសាធារណៈមានជាប់ពាក់ព័ន្ធទៅនឹងការអនុវត្ត។នេះមានន័យថាគោលបំណងរយៈពេលខ្លីដែលបានពិពណ៌នានៅក្នុងផែនការនេះបានបំបែកទៅជាកម្មវិធីសកម្មភាពជាក់លាក់សម្រាប់ភ្នាក់ងារអនុវត្តន៏។ វាគួរតែជាស្ថាបន័សម្របសម្រួលមួយ វាមិនចាំបាច់ជាអាជ្ញាធរនោះទេ។ បើទោះបីជា កន្លែងដែលមានអាជ្ញាធរតែមួយក៏ដោយ (ឧទារហណ៍ក្រុមប្រឹក្សាក្រុង) អាជ្ញាធរនោះមិនអាចធ្វើអ្វីគ្រប់យ៉ាងដែលមានក្នុងផែនការនោះទេ ហើយអាជ្ញាធរនីមួយៗត្រូវតែទទួលខុសត្រូវលើបញ្ហាផ្ទាល់ខ្លួនរបស់ពួកគេ និងនៅក្នុងដែនសមត្ថកិច្ចផ្ទាល់។

អ្វីដែលសំខាន់គឺថាផែនការប្រើប្រាស់តំបន់ឆ្នេរបានចាត់ទុដំណើរការអនុវត្ត និងប្រព័ន្ធសម្របសម្រួល ថាជាភ្នាក់ងារតែមួយរឺ ឬអង្គភាពសម្របសម្រួលមួយដោយមានអ្នកតំណាងមកពីច្រើនអង្គការ។ **សូមកុំបង្កើតនូវរចនាសម្ព័ន្ធថ្មី ប្រសិនបើមានរចនាសម្ព័ន្ធរួចហើយ**។ រចនាសម្ព័ន្ធគ្រប់គ្រង ទាមទារឱ្យមានរូបរាងច្បាស់លាស់ ជាពិសេសត្រូវទទួលស្គាល់នូវប្រភេទនៃសម្រេចចិត្តដែលបានធ្វើឡើង។ ការត្រួតពិនិត្យដំណើរការរីកចម្រើនដោយអនុវត្តធៀបនឹងថវិកា និងពេលវេលាគឺទាមទារឱ្យមានការពិពណ៌នា។ ដោយសារតែពេលវេលាចេះតែទៅមុខ បទពិសោធន៏ការងារបានបង្ហាញថា **"គ្មានអ្វីជោគជ័យដូចដែលបានគ្រោងទុកនោះទេ"។** ព្រឹត្តិការណ៍ដែលមិនបានគ្រោងទុកជាមុននឹងកើតឡើង ដូចដែលវានឹងកើតមាននៅក្នុងដំណើរការ រីកចម្រើនដែលនេះមានន័យថាការឆ្លើយតបដែលបានមកពីការត្រួតពិនិត្យធ្វើឱ្យមានការផ្លាស់ប្តូរកម្មវិធី។ ផែនការនោះចាំបាច់ត្រូវពិពណ៌នាថាតើការឆ្លើយតបនេះនឹងកើតឡើងដោយរបៀបណា ហើយថាតើមានការផ្លាស់ប្តូរកម្មវិធីអនុវត្តន៏របៀបណានឹងត្រូវបានឯកភាពនោះ។

នៅពេលដែលពិពណ៌នាពីរចនាសម្ព័ន្ធគ្រប់គ្រង យើងចាំបាច់ត្រូវពិនិត្យមើលថាតើៈ

- រចនាសម្ព័ន្ធដែលស្នើរឡើងត្រូវបានទទួលយក និងឯកភាពតាមរឺទេ
- ធាតុសំខាន់ៗ ជាពិសេសអង្គភាពសម្របសម្រួលមានអាជ្ញាធរផ្លូវការក្នុងការបំពេញមុខងាររបស់ខ្លួទេ
- មានបុគ្គលិកគ្រប់គ្រាន់ទេ ហើយពួកគេដឹងពីតួនាទីរបស់ខ្លួនទេ។

## រចនាសម្ព័ន្ធសម្របសម្រួលអន្តរភ្នាក់ងារសម្រាប់ការគ្រប់គ្រងធនធានតំបន់ឆ្នេរ CRM




***តារាងការគ្រប់គ្រងធនធានតំបន់ឆ្នេរនៅ ខេត្តដាវ៉ៅដែលស៊ី ប្រទេសហ្វីលីពីន***

***ប្រភព: ខេត្តដាវ៉ៅដែលស៊ី ស្តីពីផែនការគ្រប់គ្រងធនធានតំបន់ឆ្នេរខេត្ត២០០១-២០០៥ p 6-5***

**កិច្ចការទី២: ចូរកំណត់ពីតម្រូវការស្រាវជ្រាវ ការត្រួតពិនិត្យ និងកម្មវិធីឆ្លើយតប**

ផែនការប្រើប្រាស់តំបន់ឆ្នេរមានការកំណត់រយៈពេលវែងដែលភាគច្រើនផ្តោតលើផែនការរយៈពេល៥ឆ្នាំដំបូង។ ទោះបីយ៉ាងណាក៏ដោយវាគឺជាការពិតដែលថា ការត្រួតពិនិត្យភ្លាមៗនូវស្ថានភាពបច្ចុប្បន្នបង្ហាញពីគម្លាតជាច្រើនទាក់ទងនឹងចំណេះដឹងនេះ។ ការកំណត់វិស័យ និងផ្នែកសិក្សាគោល នឹងបញ្ចូលធនធាននានាទៅ ក្នុងវិស័យទាំងនោះ ដែលព័ត៌មានទាំងនោះអាចប្រមូលបានយ៉ាងរហ័សដើម្បីសម្រេចឱ្យបាននូវការផ្លាស់ប្តូររយៈពេល ៥ឆ្នាំដំបូងឱ្យទទួលបានជោគជ័យ។ ទោះបីយ៉ាងណាក៏ដោយនៅមានវិស័យជាច្រើនទៀតដែលក្នុងនោះក្របខណ្ឌពេលវេលានិងហិរញ្ញវត្ថុមិនគ្រប់គ្រាន់ក្នុងការបំពេញនូវគម្លាតចំណេះដឹងនោះទេ។

យើងចាំបាច់ត្រូវគិតគូរឱ្យលើសពីរយៈកាល៥ឆ្នាំដំបូង សម្រាប់ព័ត៌មានដែលត្រូវការជាចាំបាច់ ប៉ុន្តែគេមិន បានប្រមូលព័ត៌មានទាំងអស់នេះនៅក្នុងរយៈកាលនៃការរៀបចំផែនការទេ។ កម្មវិធីអនុវត្តន៍គួរបញ្ចូលនូវការស្រាវជ្រាវដើម្បីបំពេញតម្រូវការនៅពេលខាងមុខ។ ទាំងនេះអាចរាប់បញ្ចូលទាំងកម្មវិធីត្រួតពិនិត្យរយៈពេលវែង ការវាយតម្លៃ ប្រព័ន្ធអេកូស៊ីស្ទែម ឬក៏ការសិក្សាស្រាវជ្រាវដែលត្រូវចំណាយច្រើនប៉ុន្តែទទួលបាននូវលទ្ធផលជាក់លាក់ទាក់ទងនឹងដំណើរការតំបន់ឆ្នេរ ការកែសម្រួលប្រព័ន្ធអេកូស៊ីស្ទែមដើម្បីកំណត់នូវកត្តាជាច្រើន ការប្រែប្រួលអាកាសធាតុ ឬក៏ការធ្វើគំរូម៉ូដែលការហូរច្រោះតាមបែបគណិតវិទ្យា ឬការថយចុះនៃដី។

ទិដ្ឋភាពសំខាន់ដែលត្រូវបញ្ជាក់គឺថាការកែលំអរមូលដ្ឋានចំណេះដឹងសម្រាប់ផែនការនៅពេលអនាគតទាមទារឱ្យមានវិធានការចាប់ពីឥឡូវនេះមិនមែនពេលអនាគតនោះទេ។ នេះគឺជាវិស័យដ៏ល្អដែលត្រូវបញ្ចូលមហាវិទ្យាល័យ និងស្ថាប័នស្រាវជ្រាវផ្សេងៗទៀត ទាំងស្ថាប័នក្នុងស្រុក ឬក្រៅស្រុក។ ការត្រួតពិនិត្យ ការវាយតម្លៃ និងការសិក្សារៀនសូត្រទាមទារឱ្យមាននៅក្នុងកម្មវិធីអនុវត្តន៍។ ផែនការប្រើប្រាស់តំបន់ឆ្នេរបានបញ្ចូលនូវសំណើរសកម្មភាពជាក់លាក់ជាច្រើនដែលសំណើសកម្មភាពនីមួយៗត្រូវការសូចនាករមួយ ឬច្រើនដើម្បីវាស់វែងពីកម្រិតនៃភាពជោគជ័យ។ កម្មវិធីត្រួតពិនិត្យ និងវាយតម្លៃគួររៀបចំយ៉ាងច្បាស់លាស់ដោយមានយន្តការឆ្លើយតបដើម្បីឱ្យការបណ្តុះបណ្តាលអាចធ្វើទៅបាន។ ប្រការនេះតម្រូវការឱ្យមានៈ

- គោលបំណងច្បាស់លាស់ និងអាចវាស់វែងបាន
- សូចនាករត្រូវតែកំណត់សម្រាប់គោលបំណងទាំងនេះ
- មធ្យោបាយផ្ទៀងផ្ទាត់ត្រូវតែបញ្ជាក់ផងដែរ
- ភ្នាក់ងារត្រួតពិនិត្យ និងការទទួលខុសត្រូវរបស់ពួកគេដើម្បីធ្វើការត្រួតពិនិត្យនិងមាននៅក្នុងយុត្តាធិការ
- ព័ត៌មានប្រមូលបានត្រូវរៀបតាមលំដាប់ដោយភ្នាក់ងារគ្រប់គ្រង/សម្របសម្រួលការអនុវត្តនិងត្រូវបានប្រើប្រាស់ក្នុងដំណើរការកែសម្រួលផែនការ និងចំណេះដឹង និង

- ការផ្តល់ហិរញ្ញវត្ថុចាំបាច់ត្រូវដាក់បញ្ចូលដើម្បីធានាថា ការត្រួតពិនិត្យត្រូវបានអនុវត្ត និងថាមូលដ្ឋានចំណេះដឹងត្រូវបានអភិវឌ្ឍ និងប្រើប្រាស់។

សម្រាប់ការត្រួតពិនិត្យ និងការកត់ត្រាការផ្លាស់ប្តូរការប្រើប្រាស់តំបន់ឆ្នេរ ឧបករណ៍ GIS គឺជាឧបករណ៍ដ៏មានតម្លៃមួយ។ វាបានបញ្ចូលគ្នាជាមួយនឹងរូបភាពពីផ្កាយរណប រូបភាពពីលើអាកាសសម្រាប់ការផ្លាស់ប្តូរប្រព័ន្ធធម្មជាតិ និងប្រព័ន្ធអនុញ្ញាតឱ្យអភិវឌ្ឍន៍ដើម្បីកត់ត្រានូវការផ្លាស់ប្តូរការប្រើប្រាស់ដី(ដែលបានអនុមត័)។

**កិច្ចការទី៣: ពិពណ៌នាអំពីការកសាងសមត្ថភាពដែលចាំបាច់ ( ជាពិសេសជួយសម្រួលដល់ការអនុវត្តការងារ)**

តាមធម្មតា ផែនការនេះបង្ហាញពីការផ្លាស់ប្តូរដែលកើតឡើងនៅក្នុងរយៈពេល៥ឆ្នាំខាងមុខ។ កម្មវិធីអនុវត្តន៍បង្ហាញថាតើអ្វីដែលត្រូវតែធ្វើ។ ដោយចាប់ផ្តើមពីបញ្ជីដើមនៃសកម្មភាព និងដោយមានការចូលរួមរបស់អង្គការនានា ចូរកំណត់នូវជំនាញធនធានមនុស្ស និងតម្រូវការរបស់ស្ថាប័ន។ ចូរធ្វើការទាក់ទងជាមួយអង្គការដែលបានចូលរួមនីមួយៗ និងកំណត់ថាតើគួរមានតម្រូវការសម្រាប់ពង្រឹងសមត្ថភាពជាលក្ខណៈបុគ្គល ឬក៏ស្ថាប័ន។ ការកសាងសមត្ថភាពអាចជាប់ពាក់ព័ន្ធនឹង:

- ការបង្កើនចំនួនបុគ្គលិកជាមួយនឹងជំនាញសំខាន់ៗ
- ការបណ្តុះបណ្តាលបុគ្គលិកដែលមានស្រាប់នូវជំនាញថ្មី
- ការទទួលយក ឬការសម្របសម្រួលនូវបច្ចេកវិទ្យាដើម្បីធ្វើអ្វីដែលថ្មី ឬធ្វើឱ្យបុគ្គលិកធ្វើការកាន់តែមានប្រសិទ្ធភាព។
- ការអនុម័តវិធីសាស្រ្តថ្មី និងទម្លាប់ឱ្យគេធ្វើការឱ្យបានសម្រេច និង
- ការរៀបចំបុគ្គលិកតាមរបៀបថ្មីៗ។

ចូរលើកទឹកចិត្តអង្គការមួយចំនួនដើម្បីណែនាំពីសកម្មភាពកសាងសមត្ថភាព និងនៅកន្លែងដែលសកម្មភាពទាំងនេះមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងការអនុវត្តផែនការប្រើប្រាស់តំបន់ឆ្នេរដោយដាក់បញ្ចូលផែនការនេះទៅក្នុងកម្មវិធីអនុវត្តន៍។ ចូរលើកទឹកចិត្តអង្គការទាំងអស់ឱ្យប្រើប្រាស់ផែនការប្រើប្រាស់តំបន់ឆ្នេរនិងកម្មវិធីអនុវត្តន៍របស់ខ្លួនថាជាការលើកទឹកចិត្តមួយដើម្បីបង្កើនការផ្តល់ហិរញ្ញវត្ថុសម្រាប់ការកសាងសមត្ថភាព។

**កិច្ចការទី៤: ចូរផ្តល់នូវកម្មវិធីមួយដែលរួមបញ្ចូលនូវការត្រួតពិនិត្យផែនការ ការវាយតម្លៃ និងបច្ចុប្បន្នភាព ( ដោយបញ្ចូលការរកឃើញពីការស្រាវជ្រាវ) ដោយរួមបញ្ចូលនូវការត្រួតពិនិត្យ និងតាមដានកិច្ចការសមុទ្រ**

ដោយប្រើប្រាស់បញ្ជីសកម្មភាពដំបូង កម្មវិធីកសាងសមត្ថភាព និងស្រាវជ្រាវចងក្រងនូវដ្យាក្រាម Gantt ។ នៅក្នុងកូឡោនខាងឆ្វេងកម្មវិធីកសាងសមត្ថភាព និងស្រាវជ្រាវបានដាក់ជាមួយក្រុមអង្គការទទួលខុសត្រូវ ។ កូឡោននៅខាង ស្តាំបង្ហាញពីពេលវេលា ចាប់ពីកាលបរិច្ឆេទចាប់ផ្តើម រហូតដល់រយៈពេល៥ឆ្នាំខាងមុខ ។ កូឡោនដែលតំណាងឱ្យរយៈពេលពី ៣ ទៅ ៦ខែប្រហែលជាគ្រប់គ្រាន់នៅដំណាក់កាលនេះ ។ ចូរធានាថាការត្រួតពិនិត្យ ការវាយតម្លៃសកម្មភាពឆ្លើយតប និង ការរាយការណ៍ និង ការកំណត់កាលបរិច្ឆេទត្រូវបានដាក់បញ្ចូលទៅក្នុងតារាងដ្យាក្រាម Gantt ។ ការទទួលខុសត្រូវចំពោះការត្រួតពិនិត្យនេះប្រហែលជាអាចចែករំលែកឱ្យអ្នកពាក់ព័ន្ធឱ្យបានសមស្រប ។ ទោះបីយ៉ាងណា ក៏ដោយវាគួរតែមានការផ្ទៀងផ្ទាត់នូវទិន្នន័យត្រួតពិនិត្យដែលក្រុមគ្រប់គ្រង ឬ អ្នកគ្រប់គ្រងសម្របសម្រួលអាចប្រើប្រាស់ដើម្បីពិនិត្យមើលដំណើរការរីកចម្រើន ។ ***សូមពិនិត្យមើលប្រអប់ខាងក្រោមដែលពិពណ៌នាអំពីមាតិកានៃរបាយការណ៍ត្រួតពិនិត្យ ។***

ការប្រមូលព័ត៌មាន គឺត្រូវចំណាយច្រើន ហេតុនេះហើយកម្មវិធីត្រួតពិនិត្យនីមួយៗទាមទារឱ្យមានត្រួតពិនិត្យឱ្យបានល្អ។ ធាតុសំខាន់មួយគឺការកំណត់សូចនាករដែលអាចប្រើប្រាស់ដើម្បីវាស់វែងការផ្លាស់ប្តូរ។ ប្រការនេះបង្ហាញថាមានការវាស់វែងសូចនាករជាមូលដ្ឋានមួយចំនួនដែលបានកំណត់ការផ្លាស់ប្តូរ និងការវិភាគ។ កន្លែងដែលអាចធ្វើទៅបានចូរជ្រើសរើសនូវសូចនាករដែលគេបានប្រមូលរួចជាស្រេច ដោយសារតែប្រការនេះជួយកាត់បន្ថយការចំណាយបន្ថែម។ ចំណុចចាប់ផ្តើម

> ***សូចនាករ SMART:***
>
> សូចនាករនេះគួរតែជាៈ
>
> **ជា**ក់លាក់ចំពោះស្ថានភាពកំពុងដំណើរការ
>
> **អា**ចវាស់វែងបានតាមបរិមាណ និងប្រៀបធៀបជាមួយទិន្នន័យដូចគ្នានៅពេល និងទីកន្លែងដូចគ្នា
>
> **អា**ចមាននិងទទួលយកបានៈចូរប្រើទិន្នន័យដែលប្រមូលបាន
>
> **គួរ**ឱ្យជឿបាននៅក៏រិតជាក់លាក់និងពឹងពាក់បាន។ កន្លែងដែលសូចនាករបានមកពីការវិភាគ វិធីសាស្រ្តជាក់លាក់សម្រាប់គោលបំណងកំណត់ និងប្រៀបធៀប
>
> **ពេល**វេលាជាក់លាក់ៈ ភាពញឹកញាប់នៃការវាស់វែងគួរស្របគ្នាជាមួយគោលបំណង និងកម្រិតលំអៀងនូវសូចនាករ

ដ៏ល្អមួយសម្រាប់ការកំណត់នូវសូចនាករមួយចំនួននិងកម្មវិធីត្រួតពិនិត្យមួយគឺត្រូវផ្អែកលើការវាយតម្លៃនិរន្តរភាពដែលស្ថិតក្រោមដំណាក់កាលទី៣។ ប្រអប់ខាងស្តាំផ្តល់នូវចំណុចសំខាន់ៗដើម្បីពិចារណានៅពេលជ្រើសរើសសូចនាករ។ សូចនាករតែឯងគឺមិនគ្រប់គ្រាន់ទេ វាត្រូវតែធ្វើការវាស់វែងជាប្រចាំ ហើយរយៈពេលនីមួយៗខុសគ្នាតាមសូចនាករ និងបញ្ហាដែលកំពុងសិក្សា។ សូចនាករមួយចំនួនចាំបាច់តម្រូវឱ្យបង្ហាញពីការផ្លាស់ប្តូរតាមរដូវដូច្នេះធ្វើឡើង ២ ឬ៤ដងក្នុងមួយឆ្នាំហើយបញ្ហាផ្សេងៗទៀត ត្រូវការការវាស់វែងប្រហាក់ប្រហែលគ្នា។ ការពិភាក្សាទូលំទូលាយត្រូវការជាចាំបាច់ជាមួយនឹងអង្គការអនុវត្តនីមួយៗទាក់ទងនឹងការរៀបចំលំអិត និងការកំណត់ពេលវេលាធ្វើសកម្មភាព។ នៅក្នុងកម្មវិធីអនុវត្តន៏ យើងត្រូវផ្តល់នូវការពិពណ៌នាសកម្មភាពបែប **"ខ្លីៗ-Thumnail"** និងត្រូវការប្រតិទិនតាមត្រីមាស និងប្រចាំឆ្នាំក្នុងកំឡុងពេលធ្វើសកម្មភាពឡើង។ ការងារភាគច្រើនអាចអនុវត្តតាមរយៈគម្រោង។ យើងមិនចាំបាច់ផ្តល់នូវព័ត៌មានលំអិតបន្ថែមនៃគម្រោងនីមួយៗ នៅដំណាក់កាលនេះទេ។ ប៉ុន្តែ គ្រប់គម្រោងទាំងអស់គួរកំណត់ និងភ្ជាប់ទំនាក់ទំនងទៅនឹងភ្នាក់ងារប្រតិបត្តិ។ កាលបរិច្ឆេទគួរសម្រេចនៅពេលដែលការពិពណ៌នាពីគម្រោងបានបញ្ចប់ និងក្នុងកំឡុងពេលថាតើឆ្នាំណាមួយដែលគម្រោងនីមួយៗបានអនុវត្តនោះ។

**ប្រភេទមាតិកានៃរបាយការណ៍ត្រួតពិនិត្យ:**

១. ប្រវត្តិផែនការ (ឱ្យលំអិតជាងនេះទៀត)

២. គ្រើនរំលឹកពីគោលដៅរយៈពេលវែង និងទិសដៅរយៈពេលខ្លី

៣. ពិនិត្យសកម្មភាពដែលរំពឹងទុក លទ្ធផលសម្រាប់រយៈកាលធ្វើរបាយការណ៍

៤. ការបង្ហើយរបាយការណ៍ប្រចាំឆ្នាំ

៥. ការពន្យល់ពីភាពផ្សេងគ្នារវាងការពិត និងក្តីរំពឹងទុក

៦. ការផ្លាស់ប្តូររបៀបអង្កេតតាមរយៈការត្រួតពិនិត្យសូចនាករជាក់លាក់និងការប្រៀបធៀបជាមួយនឹងការស្វែងរកការវាយតម្លៃនិរន្តរភាពដើម

៧. មេរៀនស្តីពីរបៀបបញ្ចប់ និងការផ្លាស់ប្តូររបៀបអង្កេត

៨. បញ្ហាខាងមុខរួមមានការផ្តល់អនុសាសន៍ និងការបញ្ជាក់ផែនការ ឬរបៀបអនុវត្ត

៩. សកម្មភាព និងលទ្ធផលរំពឹងទុកពីរបាយការណ៍ដែលនឹងមកដល់ (ច្បាប់ដើមត្រូវបានកែសម្រួលដោយការបញ្ជាក់ការពិតនៃរយៈកាលធ្វើរបាយការណ៍ក្នុងចំណុច៤, ៦ , និង៧ ខាងលើ

១០. ឧបសម្ព័ន្ធរួមមាន:

- តារាងត្រួតពិនិត្យលទ្ធផល
- តារាងសកម្មភាព និងលទ្ធផលខាងមុខ (ស្រដៀងគ្នានឹងតារាងខាងលើដែលបញ្ជាក់ពីការទំនួលខុសត្រូវ សូចនាករ និងឯកសារយោង) ។

**ទាំងនេះមិនតាមតារឱ្យមានចំណងជើងជំពូក ប៉ុន្តែរបាយការណ៍នេះគួរមានព័ត៌មាននេះ។**

## កិច្ចការទី៥: ចូរភ្ជាប់ទៅនឹងថវិកា ពេលវេលា និងការប្តេជ្ញាចិត្តរបស់អ្នកពាក់ព័ន្ធ

ហិរញ្ញវត្ថុគឺជាចំណុចចំបងទី២នៃចំណុចខ្សោយក្នុងការអនុវត្តផែនការ ហេតុដូចនេះហើយត្រូវយកចិត្តទុកដាក់ជាពិសេស។ ការផ្តល់ហិរិញ្ញវត្ថុសម្រាប់អនុវត្តន៏ផែនការមានទម្រង់ជាច្រើន ប៉ុន្តែជានិច្ចកាលវាមានសមាសធាតុបញ្ចូលគ្នាមួយ។ ក្នុងករណីមួយចំនួនការផ្តល់មូលនិធិមួយគួរទុកដោយឡែកពិសេសសម្រាប់ផែនការអភិវឌ្ឍន៏តំបន់ឆ្នេរចម្រុះដោយផ្អែកលើផែនការប្រើប្រាស់តំបន់ឆ្នេរ។ប្រការនេះអាចបង្កើតឡើងដើម្បីផ្តល់មូលនិធិដល់ធាតុចូលទុនសំខាន់ៗ។ ក្នុងករណីមួយចំនួនទៀតគ្រប់អាជ្ញាធរនិងអង្គការដែលពាក់ពន្ធ័ទាំងអស់រំពឹងថានឹងនិយាយគ្រប់សកម្មភាពទាំងអស់ដែលពួកគេទទួលខុសត្រូវស្របច្បាប់។ បន្ទាប់មក មានបញ្ហាមួយសម្រាប់គ្រប់ៗគ្នាដើម្បីដោះស្រាយបញ្ហាហិរញ្ញវត្ថុក្នុងប្រព័ន្ធគ្រប់គ្រងថវិកាផ្ទាល់ខ្លួន។



ទិដ្ឋភាពមួយចំនួននៃការធ្វើផែនការនេះត្រូវការដើមទុនថ្មីតិចបំផុត។ ឧទាហរណ៍ បទបញ្ញាតិកំណត់តំបន់មិនទាមទារដើមទុនវិនិយោគនោះទេបន្ទាប់ពីបានអនុម័តរួចមក។ ទោះបីជាយ៉ាងណាក៏ដោយ បទបញ្ញតិនេះទាមទារឱ្យអនុម័ត ហេតុដូចនេះហើយ វាទាមទាឱ្យមានភ្នាក់ងារអនុម័ត និងការទទួលបានមូលនិធិដើម្បីបើកផ្លូវឱ្យពួកគេធ្វើការងារ។ ការផ្តល់ហិរិញ្ញវត្ថុប្រភេទនេះត្រូវដោះស្រាយដោយត្រង់តាមរយៈការផ្តល់ថវិកាឱ្យវិញ។ វាពិតជាមានភាពខុសគ្នាពីសំណើមួយដែលផ្តល់ទីកន្លែងថ្មីដល់សហគមន៍ដែលកំពុងទទួលរងការគម្រាមកំហែងដោយកំណើនកម្ពស់ទឹកសមុទ្រ។ នៅពេលដែលកម្មវិធីអនុវត្តន៏ត្រូវបានបំបែកទៅក្នុងអង្គការ និងអាជ្ញាធរសមស្របនោះ ស្ថាប័ននីមួយៗត្រូវតែគណនាខ្ទង់ថវិកាសមស្របមួយសម្រាប់តម្លៃទុនវិនិយោគព្រមទាំងតម្លៃប្រតិបត្តិការផងដែរ។ ដំណើរការនេះ គួរតែជាផ្នែកមួយនៃជំហានចរចាដែលបានពិពណ៌នាខាងលើ។ មានចំណុចតូចមួយត្រូវបញ្ចូលក្នុងផែនការនេះ ដែលលក្ខណៈវិសកម្មភាពមួយចំនួនដែលមិនមានអង្គការណាមួយមានឆន្ទៈផ្តល់ហិរិញ្ញវត្ថុនោះទេ។ កម្មវិធីអនុវត្តត្រូវតែមានពេលវេលាកំណត់ដែលស្របទៅនឹងលំហូរហិរញ្ញវត្ថុដែលមាន ។សម្រាប់ធាតុចូលទទួលបានពីភ្នាក់ងារវិស័យសាធារណៈមានន័យថាដំណើរការផ្តល់ថវិកាប្រចាំឆ្នាំត្រូវតែយកមកពិចារណា។ ដោយសារតែកម្មវិធីអនុវត្តរយៈពេល៥ឆ្នាំបានកំណត់ទុកនោះអង្គការនានាមានរយៈពេលរហូតដល់៤ឆ្នាំដើម្បីរៀបចំសម្រាប់ការប្តេជ្ញាផ្នែកហិរញ្ញវត្ថុផ្សេងគ្នា ។ដោយសារតែមានប្រទេសនិងអង្គការជាច្រើនបានធ្វើការជាមួយនឹង"ផែនការចំណាយរយៈពេលមធ្យម" ដូចេះនេះមិនមែនជាបាតុភូតថ្មីទេ។

ទស្សនៈទាននៃការធ្វើផែនការរំកិលត្រូវបានណែនាំឱ្យធ្វើ។ ផែនការមួយសម្រាប់រយៈពេល ៥ឆ្នាំពេញត្រូវបានបង្កើតឡើង ប៉ុន្តែត្រូវបែងចែកទៅតាមអង្គភាពប្រចាំឆ្នាំ។ ក្នុងឆ្នាំនីមួយៗជាផ្នែកមួយនៃដំណើរការរៀបចំថវិកាអង្គការសម្របសម្រួលផែនការធ្វើការត្រួតពិនិត្យឡើងវិញនូវភាពរីកចំរើនចងក្រងព័ត៌មានស្តីពីការប្រែប្រួលចំពោះផែនការអនុវត្តពីដំបូង និងប្រើប្រាស់ព័ត៌មាននេះដើម្បីកែសម្រួលកម្មវិធីនៅឆ្នាំបន្ទាប់និងតម្លៃរួម។ ទន្ទឹមនឹងនោះដែរការកំណត់ផែនការហិរញ្ញវត្ថុត្រូវពង្រីករយៈពេលមួយឆ្នាំ។ នៅឆ្នាំទី៤ ការត្រួតពិនិត្យឡើងវិញសំខាន់មួយនៃផែនការប្រើប្រាស់តំបន់ឆ្នេរត្រូវបានអនុវត្តដែលរួមបញ្ចូល ការវាយតម្លៃឡើងវិញនូវគោលដៅរយៈពេលវែង និងអាទិភាពរយៈពេលខ្លី។ វាគឺជាដំណើរការកែសម្រួល និងត្រួតពិនិត្យទៀតទាត់សំរាប់ការធ្វើផែនការនិងត្រូវបានអនុវត្តក្នុងលក្ខណៈមួយស្របទៅនឹងដំណើរការធ្វើផែនការហិរញ្ញវត្ថុ។

**លទ្ធផលទទួលបានពីដំណាក់កាលនេះ :**

នៅចុងបញ្ចប់នៃដំណាក់កាលនេះ អ្នកទទួលបានលទ្ធផល និងទិន្នផលដូចតទៅ:

- មានការយល់ដឹងនិងសេចក្ដីសម្រេចច្បាស់លាស់អំពីប្រព័ន្ធសម្របសម្រួលការអនុវត្តផែនការដោយរួមបញ្ចូលនូវរចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងការទទួលខុសត្រូវ ការត្រួតពិនិត្យ ការឆ្លើយតប និងការកែសម្រួល
- បានឯកភាពលើកម្មវិធីត្រួតពិនិត្យ និងស្រាវជ្រាវដែលនឹងផ្ដល់មូលដ្ឋានបន្ថែមសម្រាប់វដ្តធ្វើផែនការនៅពេលអនាគត
- ទទួលបានកម្មវិធីកសាងសមត្ថភាពដែលបានឯកភាពមួយ (ជាពិសេសស្ថាប័ន)ដែលអាចអនុវត្តបានព្រមទាំងធ្វើឱ្យប្រសើរនូវការអនុវត្ត CSP នៅពេលអនាគត
- ទទួលបានកម្មវិធីត្រួតពិនិត្យផែនការ ការវាយតម្លៃ និងបច្ចុប្បន្នកម្មការអនុវត្ត បទពិសោធន៍ ដោយរួមមានការត្រួតពិនិត្យ SEA និងការតាមដាន
- កម្មវិធីអនុវត្តមួយដែលមានទំនាក់ទំនងទៅនឹងដំណើរការផ្ដល់ថវិកាដល់វិស័យសាធារណៈដោយរួមទាំងពេលវេលានិងការប្ដេជ្ញាចិត្តរបស់អ្នកដឹកនាំ។
    - ទាំងនេះអាចរួមបញ្ចូលទាំងការណែនាំលើការរៀបចំគម្រោងដែលជាវិធីសាស្ត្រសម្រាប់អនុវត្តន៍រួមជាមួយនឹងបញ្ជីគម្រោងដែលនឹងសម្រេចបានតាមគោលបំណងសម្រាប់រយៈពេល៣–៥ឆ្នាំបន្តបន្ទាប់គ្នា។

***អ្នកក៏អាចប្រើប្រាស់បញ្ជីសំនួរខាងក្រោមនេះផងដែរ:***

- តើអង្គការអនុវត្តន៍ដែលពាក់ព័ន្ធផ្ដល់ឱ្យនូវព័ត៌មានស្ដីពីកម្មវិធីសកម្មភាពរបស់ពួកគេដែរឬទេ?
- តើរចនាសម្ព័ន្ធត្រួតពិនិត្យតាមបែបសម្របសម្រួលមួយត្រូវបង្កើតឡើង ឬត្រូវបានរៀបចំឡើង និងបង្កើតឡើងដើម្បីសម្របសម្រួលដំណើរការកម្មវិធីអនុវត្តន៍ដែរឬទេ?
- តើកម្មវិធីស្រាវជ្រាវរយៈពេលវែងបានបញ្ចូលទៅក្នុងផែនការអនុវត្តន៍ដែរឬទេ?
- តើកម្មវិធីត្រួតពិនិត្យបានរៀបចំឡើងឬ? និងតើរាល់តួនាទី និងការទទួលខុសត្រូវបានបង្ហាញច្បាស់ដែររឺអត់? តើវារួមបញ្ចូលទាំងយន្តការសិក្សា និងការឆ្លើយតបឬទេ?
- តើតម្រូវការកសាងសមត្ថភាពដែលទាក់ទងនឹងការអនុវត្តផែនការបានកំណត់រឺនៅ (ឬការវាយតម្លៃដែលបានគ្រោងទុក) ដើម្បីឱ្យគ្រប់អង្គការពាក់ព័ន្ធទាំងអស់មានសមត្ថភាពបច្ចេកទេស និងសមត្ថភាពផ្ទាល់ខ្លួនដើម្បីបំពេញកតព្វកិច្ចរបស់ពួកគេនៅក្រោមផែនការនេះទេ?
- តើកម្មវិធីអនុវត្តន៍បានភ្ជាប់ទៅនឹងប្រព័ន្ធថវិការបស់អង្គការដើម្បីឱ្យដំណើរការនេះអាចពិនិត្យឡើងវិញ ហើយសកម្មភាពប្រចាំឆ្នាំត្រូវធ្វើការកែសម្រួលតាមការចាំបាច់ពីមួយឆ្នាំទៅមួយឆ្នាំឬទេ?
- តើការពិពណ៌នាពីគម្រោង និងសកម្មភាពដែលបានដាក់ជូនមានភ្ជាប់ជាមួយនៅព័ត៌មានលំអិតដែលពាក់ព័ន្ធរឺនៅ?
- តើឯកសារកម្មវិធីអនុវត្តន៍បានបង្កើតឡើង និងឯកភាពគ្នាដែរឬទេ?

# គន្ថនិទ្ទេស និងប្រភព

Abuodha, P.A.O., and C. Woodroffe (2010) *Assessing vulnerability to sea-level rise using a coastal sensitivity index: a case study from southeast Australia*, J. Coast. Conserv. 14: 189-205.

ADB (2004) *Appendix 1 Guidelines For Preparing A City Development Strategy*, City Development Strategies To Reduce Poverty, Manila, p 89.

Anker, H.L., V.Nellemann, S.Svendrup-Jensen (1998). Integrated Coastal Zone Management in Denmark. Pg 4.

Arquiza, Y.D. (1999) *Rhythm of the Sea, Coastal Environmental Profile of San Vicente*, Palawan, Philippines, Coastal Resource Management Project, Department of Environment and Natural Resources.

Australian Government (2005) *Socio-Economic Impact Assessment Toolkit, A guide to assessing the socio-economic impacts of Marine Protected Areas in Australia*, Australian Government Department of the Environment and Heritage.

Baker, J.M., M. Spalding and J. Moore (2008) *Sensitivity Mapping Worldwide: Harmonization and the Needs of Different User Groups*.

Bensted-Smith, R., and H. Kirkman (2010), *Comparison of Approaches to Management of Large Marine Areas*, Flora & Fauna International (FFI), Conservation International (CI).

Bindoff, N.L., J. Willebrand, V. Artale, A. Cazenave, J. Gregory, S. Gulev, K. Hanawa, C. Le Quéré, S. Levitus, Y. Nojiri, C.K. Shum, L.D. Talley and A. Unnikrishnan (2007) *Observations: Oceanic Climate Change and Sea Level*. In: Climate Change 2007: The Physical Science Basis. Contributing of Working Group I to the Fourth Assessment Report of the Intergovernmental Panel on Climate Change, Solomon, S., D. Qin, M. Manning, Z. Chen, M. Marquis, K.B. Averyt, M. Tignor and H.L. Miller (eds), Cambridge University Press, Cambridge, United Kingdom and New York, NY, USA.

Broadhead, J.S. and R.N. Leslie (2007) *Proceedings of the Workshop on Coastal Area Planning and Management in Asian Tsunami-affected Countries*, 27-29 September 2006, Bangkok, Thailand, RAP Publication 2007/06, Food and Agriculture Organization of the United Nations, Regional Office for Asia and the Pacific.

Christie, P., N.B. Armada, A.T. White, A.M. Gulayan and H.H.Y. de Dion (2006) *Coastal Environmental and Fisheries Profile of Danajon Bank, Bohol, Philippines*, Fisheries Improved for Sustainable Harvest (FISH) Project, Cebu City, Philippines, 63 p.

Chua, Thia-Eng, (2006). *The Dynamics of Integrated Coastal Management: Practical Applications in the Sustainable Coastal Development in East Asia*, 468 p. Global Environment Facility/United Nations Development Programme/International Maritime Organization Regional Programme on Building Partnerships in Environmental Management for the Seas of East Asia (PEMSEA), Quezon City, Philippines.

Cicin-Sain, B, and R. Knecht, (1998). *Integrated coastal and ocean management: concepts and practices.* Island Press.

Coastal Council of NSW (2006) Coastal Design Guideline for NSW, Australia.

COBSEA (2010) www.cobsea.org.

Coombes, K. (2000) *Managing Coastal Development in an Urban Area, The Development of North Shore City's Coastal Controls,* New Zealand, Planning Quarterly, December 2000.

Cooper, L.M. (2004) *Guidelines for Cumulative Effects Assessment in SEA of Plans*, EMPG Occasional Paper 04/LMC/CEA, Imperial College London.

Dalal-Clayton, B. and B. Sadler (1998) *The Application of Strategic Environmental Assessment in Developing Countries.* Environmental Planning Issues No. 18.London: IIED.

Dalal-Clayton, B. and B. Sadler (2004) *Strategic Environmental Assessment: A Global Overview*. London: IIED and Earthscan.

DEAT (Department of Environmental Affairs and Tourism) and CSIR (2000) Guideline Document: Strategic Environmental Assessment in South Africa. Pretoria, South Africa.

De Jesus, E.A., D.A.D. Diamante-Fabunan, C.L. Nanola, A.T. White, and H.J. Cabangon (2001) *Coastal Environmental Profile of Sarangani Bay Area*, Mindanao, Philippines, Coastal Resources Management Project, Department of Environment and Natural Resources.

Department for Communities and Local Government (2009) *Multi-criteria Analysis: A Manual*, London, www.communities.gov.uk.

Department of the Environment, Welsh Office (1992) Planning Policy Guidance: Coastal Planning, PPG 20, September 1992.

Department of Environment and Natural Resources, Bureau of Fisheries and Aquatic Resources of the Department of Agriculture, and Department of the Interior and Local Government (2001) *Philippine Coastal Management Guidebook No. 7: Managing Impacts of Development in the Coastal Zone*, Coastal Resources Management Project of the Department of Environment and Natural Resources, Cebu City, Philippines, 108 p.

Department of Environment and Natural Resources, Bureau of Fisheries and Aquatic Resources of the Department of Agriculture, and Department of the Interior and Local Government (2001) *Philippine Coastal Management Guidebook No. 5: Managing Coastal Habitats and Marine Protected Areas*, Coastal Resource Management Project of the Department of Environment and Natural Resources, Cebu City, Philippines.

Department of Environment and Natural Resources, Bureau of Fisheries and Aquatic Resources of the Department of Agriculture, and Department of the Interior and Local Government (2001) *Philippine Coastal Management Guidebook No. 3: Coastal Resource Management Planning*, Coastal Resources Management Project of the Department of Environment and Natural Resources, Cebu City, Philippines, 94 p.

Department of Environment and Natural Resources, Bureau of Fisheries and Aquatic Resources of the Department of Agriculture, and Department of the Interior and Local Government (2001) *Philippine Coastal Management Guidebook No. 1: Coastal Management: Orientation and Overview*, Coastal Resources Management Project of the Department of Environment and Natural Resources, Cebu City, Philippines, 58 p.

Donnelly, A., B. Dalal-Clayton and R. Hughes (1998) *A Directory of Impact Assessment Guidelines* (Second Edition). London: IIED.

Dusik, J. (ed.) (2001) *Proceedings of International Workshop on Public Participation and Health Aspects in Strategic Environmental Assessment*. Regional Environmental Centre for Central and Eastern Europe, Szentendre, Hungary.

EAS East Asian Seas Congress (2009) *Partnerships at work: Local Implementation and Good Practices, Theme 1: Coastal and Ocean Governance, Workshop 5: The Science in Ecosystem-based Management*, 25 November 2009.

EAS East Asian Seas Congress (2009) *Partnerships at work: Local Implementation and Good Practices, Theme 1: Coastal and Ocean Governance, Workshop 6: Land and Sea Use Zoning: Challenges and Opportunities*, 23 November 2009.

EAS East Asian Seas Congress (2009) *Partnerships at work: Local Implementation and Good Practices, Theme 1: Coastal and Ocean Governance, Workshop 7: Making Mainstreaming Work: Driving National Action to Address Marine and Coastal Challenges*, 25 November 2009.

EAS East Asian Seas Congress (2003) *Putrajaya Declaration of Regional Cooperation for the Sustainable Development of the Seas of East Asia, Sustainable Development Strategy for the Seas of East Asia*, Regional Implementation of the World Summit on the Sustainable Development Requirements for the Coasts and Oceans, December 2003.

Ehler, C. and F. Douvere, (2009), *Marine Spatial Planning: a step-by-step approach toward ecosystem-based management*. Intergovernmental Oceanographic Commission and Man and the Biosphere Programme. IOC Manual and Guides No. 53, ICAM Dossier No. 6 Paris: UNESCO.

Elliot, M (2005) *Estuarine, Coastal and Marine Science and Management: broad thoughts from home*, Presentation from the University of Hull, Institute of Estuarine & Coastal Studies (IECS), England.

Environmental Management of the Coastal Zone Project (2006) *Cambodia Shoreline Management Strategy, Executive Summar,*. Ministry of Environment and Danida.

Environmental Management of the Coastal Zone Project (2002) *Physical Framework Plan Koh Kong Province*, Ministry of Environment and Danida.

European Commission (2009) *The Economics of Climate Change Adaptation in EU Coastal States, Summary Report*, Socio-Economic Studies in the field of the Integrated Maritime Policy for the European Union.

Farber, S.C., R. Costanza and M.A. Wilson (2002) *Economic and ecological concepts for valuing ecosystem services*, Ecological Economics 41: 375-392.

Fenster, M.S. (2005) *Coastal Setbacks*, in Maurice L. Schwartz, (ed) (2005). Encyclopedia of coastal science. Springer, Netherlands pg. 866.

Fredman, P., (1997) *En dag i skogen, 200:-*, Article in Forskning & Framsteg 2/97 (in Swedish).

Green, S.J., R.D. Alexander, A.M. Gulayan, C.C. Migrino III, J. Jarantilla-Paler, and C.A. Courtney (2002) *Bohol Island, Its Coastal Environment Profile, Philippines*, Coastal Resource Management Project, Department of Environment and Natural Resources.

Green, S.J., R.P. Monreal, A.T. White, T.G. Bayer (2000) *Coastal Environmental Profile of Northwestern Bohol, Philippines*, Coastal Resource Management Project, Department of Environment and Natural Resources.

Greenhow, T. (ed). (2007) The Strategic Urban Planning Guideline. General Organisation for Physical Planning, Ministry of Housing, Utilities and Urban Communities. Cairo.

Greenhow, T. (ed). (2008) Strategic Governorate Planning Guidelines. General Organisation for Physical Planning, Ministry of Housing, Utilities and Urban Communities. Cairo.

He, S. and C.. Wang (2010) *Socio-Economic Impact Assessment for Exploration of Coastal Zone in Yantai Region*, Journal of Sustainable Development, March 2010, www.ccsenet.org/jsd.

IMO/IPIECA (1994) *Sensitivity Mapping for oil Spill Response*, IMO/IPIECA Report Series, Volume One.

IOPC Funds (2010), http://www.iopcfund.org/

IPIECA/ITOPF (2007) *Oil Spill Compensation, A guide to the international conventions on liability and compensation for oil pollution damage*, a joint IPIECA/ITOPF Publication, February 2007.

ITOPF (2010a), http://www.itopf.com
ITOPF (2010b) http://www.itopf.com/spill-compensation/cost-of-spills/
Kay, R. and J. Alder, (2005), *Coastal Planning and Management*, Second Edition, Spon Text, Taylor & Francis.
King, P., D. Annandale and J. Bailey (2000) *A Conceptual Framework for Integrated Economic and Environmental Planning in Asia – A Literature Review*, Journal of Environmental Assessment Policy and Management, Vol. 2, No. 3, September 2000, pp. 279-315.
King, S.D. and D.R. Green (2001) *Redefining the Limits of the Coastal Zone: Bridging the Gap Between Land and Sea Using Remote Sensing, GIS, and the Internet*, GeoCoast, Vol. 2, No. 1, pp 1-15, April 2001.
Kjorven, O. and Lindhjem, H. (2002) *Strategic Environmental Assessment in World Bank Operations: Experience to Date – Future Potential*. Environmental Strategy paper No. 4, Environment Department, Washington DC. World Bank.
Klein,R.J.T., R.S.J. Tol (1997) *Adaptation to Climate Change: Options and Technologies – An Overview Paper*. Technical Paper FCCC/TP/1997/3 United Nations Framework Convention on Climate Change Secretariat, Bonn Germany.
KSLA (Royal Swedish Academy of Agriculture and Forestry) (2009) *Fisheries, Sustainability and Development, Fifty-two authors on coexistence and development of fisheries and aquaculture in developing and developed countries*.
Lau, M. (2006) *Coastal Zone Management in the People's Republic of China – An Assessment of Structural Impacts on Decision-making Processes*, Working Paper FNU-28, DINAS-COAST Working Paper 4.
Lee, N. and George, C. (eds.) (2000) *Environmental Assessment in Developing and Transitional Countries.* Chichester: John Wiley & Sons, Ltd.
Lloyd's (2008) *Coastal Communities and Climate Change, Maintaining a Future Insurability*, 360 Risk Project, Driving the Debate on Emerging Risk.
Lysekil Municipality (2006) Comprehensive Plan 2006, Document No. KF 2006-06-21.
MA (United Nations Millennium Ecosystem Assessment), (2005), *Ecosystems and Human Well-being, Wetlands and Water, Synthesis*, MA and Island Press, World Resources Institute, Washington, D.C., www.millenniumassessment.org.
MA (United Nations Millennium Ecosystem Assessment), (2003), *Ecosystems and Human Well-being, A Framework for Assessment*, MA and Island Press, World Resources Institute, Washington, D.C., www.millenniumassessment.org.
MA (United Nations Millennium Assessment), (2005), *Global Assessment Report, Volume 3: Policy Responses*, MA and Island Press, World Resources Institute, Washington, D.C., www.millenniumassessment.org.
McIntosh, D.J. and M.M. Epps (2008) *Mangroves in a Changing Climate*, in Tropical Coasts, Vol. 15, No. 2, December 2008.
Ministry for the Environment, Manatu Mo Te Taiao (2008) Preparing for Climate Change, A Guide to Local Government in New Zealand, New Zealand Government, Publication No 891, http://www.mfe.govt.nz/publications/climate/preparing-for-climate-change-guide-for-local-govt/preparing-for-climate-change-guide-low-res.pdf.
Mugerezi, E. (2006) *An Environmental Management Information System (EMIS) for Iringa Municipality, Tanzania Implementation Challenges*, InfoBridge Consultants Limited, Tanzania.

National Oceanic and Atmospheric Administration (NOAA) (2010) *Adapting to Climate Change: A Planning Guide for State Coastal Managers*, NOAA Office of Ocean and Coastal Resource Management, http://coastalmanagement.noaa.gov/climate/adaptation.html.

National Oceanic and Atmospheric Administration (NOAA) (2002) *Environmental SensitivityIndex Guidelines Version 3.0*, Hazardous Materials Response Division, NOAA Technical Memorandum NOS OR&R 11.

Nelleman, C., Corcoran, E., Duarte, C. M., Valdés, L., De Young, C., Fonseca, L., Grimsditch, G. (Eds), (2009), *Blue Carbon. A Rapid Response Assessment.* United Nations Environment Programme. GRID-Arendal, www.grida.no.

New South Wales Department of Planning (2006) *The CCA Integrated Decision Framework: A guide for sustainable land use planning,* prepared for the Comprehensive Coastal Assessment (Department of Planning) Sydney.

Norman, B. (2009) *Planning for Coastal Climate Change, An insight into international and national approaches*, Future Coasts Program, Published by the Victorian Government Department of Planning and Community Development and Department of Sustainability and Environment, Melbourne, Australia, June 2009. www.climatechange.vic.gov.au/futurecoasts.

O'Donnell, V., M. Cronin and V. Cummins (2003) *Sustainable Coastal Habitats: GIS Tools for Effective Decision Support*, Coastal & Marine Resources Centre, Environmental Research Institute, University College Cork.

OECD (1997) *Strategic Environmental Assessment (SEA) in Development Cooperation: State-of-the-art-Review*. Final Report. Paris: OECD/DAC Working Party on Development Assistance and Environment.

Office of the Prime Minister (2005) *Sustainability Appraisal of Regional Spatial Strategies and Local Development Documents, Guidance for Regional Planning Bodies and Local Planning Authorities*, November 2005, www.odpm.gov.uk.

PEMSEA (2010) www.pemsea.org.

Phan, Nguyen Hong (ed.), (2006), *The role of mangroves and coral reef ecosystems in natural disaster mitigation and coastal life improvements*. IUCN, MERD, Hanoi, Vietnam, 387 p.

Provincial Government of Bataan (2007) Coastal Land- and Sea Use Zoning Plan of the Province of Bataan.

Provincial Government of Davao del Sur (2001) *Provincial Coastal Resource Management Plan 2001-2005*. Province of Davao del Sur, Philippines.

Queensland Government (2003) *Environmental Economic Valuation, An introductory guide for policy-makers and practitioners*, Prepared by the Inter-Departmental Committee (IDC) on Environmental Economic Valuation, August 2003.

Sadler, B. (1996) *Environmental Assessment in a Changing World: Evaluation Practice to ImprovePerformance*. (Final Report of the International Study of the Effecrtiveness of Environmental Assessment). Canadian Environmental Assessment Agency and International Association for Impact Assessment, Ottawa.

Sadler, B. (1999) A Framework for Environmental Sustainability Assessment and Assurance, in Petts, J. (ed.) *Handbook of Environmental Impact Assessment* (Vol. 1). Blackwell Scientific, Oxford. (pp. 12-32).

Sadler, B. (2001a) A Framework Approach to Strategic Environmental Assessment: Aims, Principles and Elements of Good Practice, in Dusik, J. (ed.) *Proceedings of International Workshop on Public Participation and Health Aspects in Strategic Environmental Assessment.* Regional Environmental Centre for Central and Eastern Europe, Szentendre, Hungary (pp. 11-24).

Sadler, B. (2001b) EIA Reconsidered, *Environmental Assessment Yearbook*. Institute of Environmental Assessment and Management, Lincoln and EIA Centre, Manchester (pp. 8-12).

Sadler, B. (2002) From environmental assessment to sustainability appraisal? *Environmental Assessment Yearbook 2002*, Institute of Environmental Management and Assessment, Lincoln and EIA Centre, University of Manchester (pp. 145-152).

Sadler, B. and Verheem, R. (1996) *Strategic Environmental Assessment: Status, Challenges and Future Directions*, Ministry of Housing, Spatial Planning and the Environment, Publication No. 53, The Hague.

Sharples, C., C. Attwater and J. Carley (2008) *Three Pass Approach to Coastal Risk Assessment*, IPWEA 2008.

Siry, H.Y. (2007) *Making Decentralized Coastal Zone Management Work for the Southeast Asian Region: Comparative Perspectives*, Division for Ocean Affairs and the Law of the Sea, Office of Legal Affairs, The United Nations, New York, 2007.

Shintaro, G., O. Masumi, H. Seiichi, S. Nobuhiro, S. Kunihisa and S. Kazuko (2004) *Environment Sensitivity Analysis for Near ShoreRegion Using GIS Based ESI Map*, Faculty of Geo-Environmental Sciences, Rissho University, Japan.

Snover, A.K., L. Whitely Binder, J. Lopez, E. Willmott, J. Kay, D. Howell, and J. Simmonds (2007) *Preparing for Climate Change: A Guidebook for Local, Regional, and State Governments.* Center for Science in the Earth System (The Climate Impacts Group), Joint Institute for the Study of the Atmosphere and Ocean, University of Washington. In association with and published by ICLEI – Local Governments for Sustainability, Oakland, CA, USA.

Sotto, F.B., J.L. Gatus, M.A. Ross. M.F.L. Portigo and F.M. Freire (2001) *Coastal Environmental Profile of Olango Island, Cebu, Philippines*, Coastal Resource Management Project, Department of Environment and Natural Resources.

SSPA Sweden AB (2003) *Socio-Economic Survey of the South Western Coastal Areas of Mauritius, Feasibility Study and Environmental Impact Assessment for Large Scale Sand Extraction in the Lagoon at La Prairie*, Project No 20012639, Report from 2003-01-31.

Söderqvist, T. (2004) *Presentation av miljöekonomi (Introduction to environmental economics)*, National Economics, Stockholm University, (in Swedish) http://www.ne.su.se/education/grundutbild/a/ht04/mikro/soederqvist.pdf

Söderqvist, T., (1996) *Ekonomisk värdering av miljön: Metoder och svenska erfarenheter (Economic valuation of the environment: Methods and Swedish experiences*) Beijer Occasional Paper Series, Beijer International Institute of Ecological Economics (in Swedish).

TEEB (The Economics of Ecosystems and Biodiversity) (2010) *The TEEB for Local and Regional Policy Makers*, Report from Sept 2010. www.teebweb.org

TEEB (The Economics of Ecosystems and Biodiversity) (2009a) *The TEEB for National and International Policy Makers, Summary: Responding to the Value of Nature.*

TEEB (The Economics of Ecosystems and Biodiversity) (2009b) *The TEEB Climate Issues update*, Report from Sept 2009. www.teebweb.org

TEEB (The Economics of Ecosystems and Biodiversity) (2008) *The Economics of Ecosystems and Biodiversity Interrim Report,* from 2008. www.teebweb.org

Tegner Anker, H., V. Nelleman and S. Sverdrup-Jensen (1998) *Integrated Coastal Zone Management in Denmark, Ways and means for further integration*, Discussion paper for the Transnational Seminar on the European Spatial Development Perspective, Göteborg, Sweden, October 1998.

The Sustainable Scale Project (2010), *Ecosystem functions and services*, http://www.sustainablescale.org/ConceptualFramework/UnderstandingScale/BasicConcepts/EcosystemFunctionsServices.aspx

Titus, J.G. (2003) *Some Social and Policy Implications of Shore Erosion,* Presentation by U.S. Environmental Protection Agency.

Tridech, S., P. Simcharoen and P. Chongprasith (2008) *Using Coastal Environment Sensitivity Index Map as a Tool for Integrated Coastal Zone Management*, Marine Environment Division, Water Quality Bureau, Pollution Control Department, Bangkok, Thailand.

Tropical Coasts (2005) Special Issue on: *Call to Action: Disaster Risk Reduction and Post-Tsunami Reconstruction*, Vol. 12, No. 1, July 2005.

Tropical Coasts (2005) Special Issue on: *Port Safety, Security, Health and Environment*, Vol. 12, No. 2, December 2005.

Tropical Coasts (2003) Special Issue on: *The Regional Approach, Harnessing Intergovernmental Partnerships for Sustainable Development of the World's Seas*, Vol. 10, No. 1, July 2003.

Tropical Coasts (1999) Special Issue on: *Getting Our Acts Together, Resolving Conflicts n Coastal Zones*, Vol. 6,No. 2, December 1999.

Turner, R.K., W.N. Adger and I. Lorenzoni (1998) *Land-Ocean Interactions in the Coastal Zone (LOICZ), Towards Integrated Modelling and Analysis in Coastal Zones: Principles and Practices,* LOICZ Reports and Studies No. 11, Core Project of the International Geosphere-Biosphere Programme: A Study of Global Change (IGBP) of the International Council of Scientific Unions (ICSU).

Ulep, E.M.C. (2002) *GIS Cookbook for LGUs: Guidelines for Comprehensive Land Use Planners using GIS*, Housing and Land Use Regulatory Board (HLURB), Philippines, Paper 1197.

UNECE (2007) *Protocol on SEA, Resource Manual to Support Application of the UNECE Protocol on Strategic Environmental Assessment*, United Nations Economic Commission for Europe & Regional Environmental Center for Central & Eastern Europe.

UNEP/COBSEA (2010), *State of the Marine Environment Report for the East Asian Seas 2009*, Ed. Chou, L.M., COBSEA Secretariat, Bangkok, 156 p.

UN/UNEP (2010), *United Nations Environment Programme Medium-term Strategy 2010-2013*, Environment for Development, UNEP/GCSS.X/8.

UNEP (2009) *Opportunities in Environmental Management for Disaster Risk Reduction: Recent Progress, A Practice Area Review: In contribution to the Global Assessment Report on Disaster Risk Reduction*, United Nations Environment Programme.

UN-HABITAT (2010) State of the World's Cities 2010/2011.

Valle, I.A., M.C.B. Cristobal, A.T. White and E. Deguit (2000) *Coastal Environmental Profile of Malalag Bay Area, Davao del Sur, Philippines*, Coastal Resource Management Project, Department of Environment and Natural Resources.

Velasquez, J. and P. Tran, (2010), *Climate Change Adaptation and Disaster Risk Reduction – Institutional and Policy Landscape in Asia*, Draft report July 2010, ISDR.

Willows, R. and R. Connell (2003) *Climate Adaptation: Risk, Uncertainty and decision-making*, UKCIP Technical Report, May 2003, UK Climate Impact Programme, Department for Environment, Food and Rural Affairs, and Environment Agency.

Woodroffe, C.D. and P.A. Abuodha (2009) *GIS where have we been? Where are we going?* Presentation from School of Earth and Environmental Sciences, University of Wollongong, Australia.

World Bank (2009) Reshaping Economic Geography, World Bank Report 2009.

World Bank (1999) *Case Studies on Regional and Sectoral EA:An Analysis of Lessons Learned*. Washington DC: World Bank.

World Bank (1991) Environmental Assessment Sourcebook Vol. 1: Policies, Procedures and Cross-Sectoral Issues. *Technical Paper Number 139*. Washington DC: World Bank.

WSP Africa Coastal Engineers (2010) *Development of a Methodology for Defining and Adopting Coastal Development Setback Lines*. Department of Environment Affairs and Development Planning, Provincial Government of the Western Cape, South Africa.

Yambao, A.C., A.T. White, W.E. Ablong and M.R.Alcala (2001) *Coastal Environmental Profile of Negros Oriental, Philippines*. Coastal Resources Management Project, Cebu City, Philippines.

## ឧបសម្ព័ន្ធទី១: ឧបករណ៍សម្រាប់វាយតម្លៃមុខសញ្ញាគ្រោះថ្នាក់ និងហានិភ័យ

ឧបករណ៍ដែលគេប្រើប្រាស់ជាទូទៅសម្រាប់វាយតម្លៃមុខសញ្ញាគ្រោះថ្នាក់ និងហានិភ័យគឺដំណើរការ "APELL" (ការយល់ដឹង និងការត្រៀមរៀបចំ (Preparedness) សម្រាប់ការសង្គ្រោះបន្ទាន់នៅមូលដ្ឋាន)។ ឯកសារនេះមិនបានផ្តល់នូវព័ត៌មានលំអិតនៃដំណើរការនេះទេ ប៉ុន្តែវាបានបង្ហាញពីជំហានដំបូង និងទំនាក់ទំនងរបស់វាទៅនឹងផែនការបែងចែកតំបន់ប្រើប្រាស់។ អ្នកអានទាំងឡាយដែលចាប់អារម្មណ៍ទៅលើព័ត៌មានលំអិតសូមមើលកម្មវិធី UNDP-ISDR និងមជ្ឈមណ្ឌលអាស៊ីសម្រាប់ការការពារគ្រោះមហន្តរាយនៅក្នុងទីក្រុងបាងកក។ នីតិវិធីជាមូលដ្ឋានមានដូចខាងក្រោម:

១. ក្រុមដែលកំពុងធ្វើការឬដែលកំពុងបញ្ជាការងារគួរសម្រេចទៅលើគោលបំណងសម្រាប់ការវាយតម្លៃ ជាពិសេសកម្រិតលម្អិតដើម្បីទទួលបានព័ត៌មាននេះ។ ផែនទីតំបន់សិក្សាត្រូវមានទំហំល្មមឱ្យស៊ីគ្នាទៅនឹងកម្រិតលម្អិតដែលបានគិតទុក។ តារាងនេះគួរបង្កើតឡើងដូចខាងក្រោម:

២. ចូរចុះបញ្ជីនូវដើមហេតុ (Objects) ដែលត្រូវជ្រើសរើសធ្វើការវិភាគក្នុងតារាងជួរឈរទី១ ។" ***ដើមហេតុហានិភ័យ -Risk Objects"*** គឺមានលក្ខណៈពិសេសនិងមុខសញ្ញាគ្រោះថ្នាក់ហើយដើមហេតុគួរតែមាននៅក្នុងផែនទី។ ដើមហេតុទាំងនេះអាចបែងចែកជាក្រុមៗដូចតទៅ: ប្រភពហានិភ័យដោយធម្មជាតិដោយមនុស្ស និងប្រភពហានិភ័យ ធម្មជាតិធ្វើឡើងដោយសកម្មភាពមនុស្ស។ "ដើមហេតុហានិភ័យ" ធម្មជាតិរួមមាន តំបន់ទទួលរងគ្រោះថ្នាក់ពីទឹកជំនន់ (ពីទឹកទន្លេ ឬទឹកសមុទ្រឬតំបន់ទីក្រុងដែលមានប្រព័ន្ធបង្ហូរអន់) តំបន់ដែលទទួលរងនូវការហូរច្រោះតំបន់ឆ្នេរ ជម្រាលគ្មានស្ថេរភាពចំណោទជ្រៅជាដើម ។ល។ មានមុខសញ្ញាគ្រោះថ្នាក់មួយចំនួនដូចជាខ្យល់ព្យុះដែលមិនមានទីតាំងជាក់លាក់នោះទេ ប៉ុន្តែស្ថិតក្នុងតំបន់មួយដោយផ្នែកខ្លះទៀតងាយប្រឈម និងងាយរងគ្រោះដោយខ្យល់ព្យុះនេះជាងបាតុភូតអ្វីផ្សេងទៀត។ ដើមហេតុហានិភ័យបង្កឡើងដោយមនុស្សមានដូចជា តំបន់ឧស្សាហកម្មកន្លែងដែលមានដំណើរការប្រកបដោយគ្រោះថ្នាក់ដែលឧបករណ៍ប្រកបគ្រោះថ្នាក់ត្រូវបានប្រើប្រាស់ ស្តុកទុក ដឹកជញ្ជូន ឬបោះចោល។ នេះមានន័យថាផ្លូវសាងសង់ឡើងដើម្បីដឹកទំនិញប្រកបដោយគ្រោះថ្នាក់ផ្លូវដែក និងកំពង់ផែនឹងត្រូវដាក់បញ្ចូលក្នុងតារាងនេះផងដែរ។ ដើមហេតុ ហានិភ័យផ្សេងៗទៀតអាចជាទីលានចាក់សំរាម ទីបញ្ចេញសំណល់រាវ បណ្តាញខ្សែអគ្គីសនីកំលាំងខ្លាំង ។ល។ ដើមហេតុហានិភ័យធម្មជាតិបង្កឡើងដោយមនុស្សគឺជាដើមហេតុទាំងឡាយណាដែលក្នុងនោះសកម្មភាពមនុស្សជាច្រើនអាចបង្កឱ្យមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិកាន់តែមានហានិភ័យធ្ងន់ធ្ងរឡើងៗ។ ឧ.ដូចជាជម្រាលជ្រៅត្រូវកាត់ដំណាំសម្រាប់ការប្រើប្រាស់របស់មនុស្សទំនងជាបង្កឱ្យមានគ្រោះថ្នាក់កើតឡើង និង បង្កើននូវផលប៉ះពាល់ដោយសារគ្រោះមហន្តរាយនេះដូច្នេះផែនការបែងចែកតំបន់ប្រើប្រាស់អាចដោះស្រាយបញ្ហាទាំងនេះបានដោយដាក់កម្រិតលើការអភិវឌ្ឍតំបន់មុខសញ្ញាគ្រោះថ្នាក់ទាំងនោះ។

៣. ក្នុងជួរឈរទី២ ផ្តល់នូវសញ្ញាបញ្ជាក់ច្បាស់បន្ថែមទៀតនៃដំណើរការនេះដែលតាមរយៈនេះមុខសញ្ញាគ្រោះថ្នាក់បញ្ចេញឱ្យឃើញតែម្តង។ ឧ. មុខសញ្ញាគ្រោះថ្នាក់កើតមាននៅទីជម្រាលជ្រៅអស្ថេរភាព គឺជាដំណើរការនៃការបាក់ដី រឹភក់។ ក្នុងករណីតំបន់ឧស្សាហកម្ម ប្រហែលជាមានមុខសញ្ញាគ្រោះថ្នាក់ជាប់ទាក់ទងនឹងការស្តុកទំនិញមួយចំនួន។ ដំណើរការមួយចំនួន ដូចជាផ្នែកអាហាររួមមានមុខសញ្ញាគ្រោះថ្នាក់ជីវសាស្ត្រដែលបង្កឱ្យមានជំងឺឆ្លងផ្សេងៗ។ ដោយយោងលើកំរិតសិក្សានេះអាចឱ្យយើងកំណត់បានច្បាស់នូវតំបន់ឧស្សាហកម្មទាំងមូលថាជាដើមហេតុហានិភ័យកន្លែងដែលដំណើការប្រកបដោយគ្រោះថ្នាក់ទាំងអស់អាចរួមបញ្ចូលនូវអ្វីៗគ្រប់យ៉ាង ដោយមានចាប់ពី ***ការដឹកជញ្ជូន ការស្តុក ការប្រើប្រាស់ ការបោះចោលនូវឧបករណ៍គ្រោះថ្នាក់*** ប៉ុន្តែក៏អាចជាប្រភពនៃការបំពុលខ្យល់ ទឹក ដី និងសំលេង ដែលទាំងនេះនាំឱ្យមានហានិភ័យដល់មនុស្សនៅតំបន់ជិតខាង។ យើងអាចនិយាយលំអិតបន្ថែមដោយសំដៅលើអាគារឧស្សាហកម្មនីមួយៗដោយប្រើប្រាស់នូវនីតិវិធីដូចគ្នា។

៤. ជួរឈរទី៣និយាយពីចំនួនឬកំរិតនៃមុខសញ្ញាគ្រោះថ្នាក់នេះ។ ភាពជាក់លាក់នៃព័តិមាននេះឆ្លុះបញ្ចាំងពីគោលបំណងនៃការអនុវត្តនិងកំរិតលម្អិតរបស់វា។ ព័តិមាននេះត្រូវប្រើដើម្បីកំណត់នូវទំហំ និងមូលហេតុនៃគ្រោះថ្នាក់ដែលអាចកើតឡើងពាក់ព័ន្ធនឹងដើមហេតុហានិភ័យនេះ។ ចំពោះគោលបំណងនៃផែនការបែងចែកតំបន់ប្រើប្រាស់វិញមានការពិពណ៌នាកាន់តែទូទៅដូចជា ***តិច (minor) ច្រើនល្មម (significant) ច្រើនខ្លាំង (Great) ច្រើនណាស់ (Very great)*** ។ កន្លែងសារធាតុគីមីជាប់ពាក់ព័ន្ធនឹងកន្លែងមួយអាចកំណត់នូវកំរិតនៃធាតុពុលក្នុងតារាងនេះ។ កន្លែងដែលមានការផលិតសារធាតុគីមីយើងត្រូវតែពិនិត្យនៅកម្រិតជាតិពុលរបស់វានៅក្នុងកូឡោននេះ ហើយប្រការនេះអាចពិភាក្សានៅក្នុងសមាជិកក្រុមដែលធ្វើការសិក្សានេះ។

៥. ប្រភេទហានិភ័យនេះមានបញ្ជាក់នៅក្នុងជួរឈរទី៤ដែលនៅទីនេះគេរំពឹងថាស្វែងរកពាក្យបែបពិពណ៌នា ដូចជាការបាក់ដី ការរលំអាគារ ទឹកជំនន់ ការលិចធ្លាយហ្គាសប្រកបដោយគ្រោះថ្នាក់ អគ្គីភ័យ ការផ្ទុះ ការធ្លាក់ចុះប្រព័ន្ធអេកូឡូស៊ី ។

៦. ក្នុងជួរឈរទី៥មានចុះបញ្ជី របស់របរ ទីតាំងមនុស្ស និងសកម្មភាពដែលត្រូវទទួលរងការគំរាមកំហែងដោយដើមហេតុហានិភ័យនីមួយៗ។ នៅក្នុងបរិបទនៃការបែងចែកតំបន់ប្រើប្រាស់ដែលមានអភិក្រមតម្រង់ទៅរកប្រព័ន្ធអេកូឡូស៊ី និងនិរន្តរភាពមួយនោះកូឡោននេះអាចប្រើជាចំណុចចាប់ផ្តើម ឧទាហរណ៍ការកំណត់ទីជម្រកងាយរងគ្រោះដែលជាទូទៅប្រឈមនឹងហានិភ័យបណ្តាលមកពីសកម្មភាពអភិវឌ្ឍន៍ជាច្រើនមកពីការបំពុល ទឹក ខ្យល់ ការទន្ទ្រានដី ការប្រើប្រាស់លើសកម្រិត។ល។ ប្រាសាទបុរាណវប្បធម៌មួយចំនួនដែលសាងសង់ឡើងពីថ្មកំបោរឬ ផ្ទាំងថ្មមានជាតិកំបោរប្រហែលជាអាចទទួលរងនៅហានិភ័យដោយសារការបំពុលខ្យល់ខ្លាំង។ វត្ថុដើមហេតុដែលទទួលរងនូវការគំរាមកំហែងបែបនេះអាចកំណត់ចំណាំជាលើកទី១ និងបន្ទាប់ ដើមហេតុហានិភ័យនេះអាចកំណត់បានជារួម ហើយជាធម្មតាបើសិនគ្មានមនុស្សទេ លក្ខណៈទ្រព្យ

សម្បត្តិបរិស្ថានត្រូវទទួលរងនូវការគម្រាមកំហែងដោយសារដើមហេតុហានិភ័យដែលគេមិនសូវយកចិត្តទុកដាក់ធ្វើការវិភាគនេះនៅផ្នែកបន្តបន្ទាប់នេះ។

៧. ផលវិបាកនៃព្រឹត្តិការណ៍កើតឡើងត្រូវបានពិពណ៌នានៅក្នុងកូឡោនបន្ទាប់។ សំរាប់ផែនការការប្រើប្រាស់ដីធ្លី ផលវិបាកអាចពិពណ៌នាដោយយោងតាមថាតើវារីកធំប៉ុណ្ណា ថាតើនៅបានយូរប៉ុណ្ណា តើមានការខូចខាតប៉ុណ្ណា ប៉ុន្តែនៅក្នុងតារាងយើងចាំបាច់ត្រូវចំណាំនូវប្រភេទនៃផលវិបាក។ ទំហំវិសាលភាពនៃផលវិបាកនេះមានសារៈសំខាន់ណាស់ក្នុងការរៀបចំផែនការប្រើប្រាស់ដីធ្លីដើម្បីកំណត់នូវតំបន់ទ្រនាប់ ហើយប្រភេទនិងភាពធ្ងន់ធ្ងរប្រហែលជាមានឥទ្ធិពលលើលក្ខខណ្ឌផ្សេងៗទៀតសំរាប់សកម្មភាពមួយចំនួន។ ជាក់ស្តែង តំបន់រញ្ជួយដីអាចកំណត់បានដោយយោងលើកំរិតធ្ងន់របស់ពួកគេ ប៉ុន្តែ វាមិនមែនអាចឱ្យយើងជៀសវាងការតាំងទីលំនៅនៅក្នុងតំបន់បែបនោះទេ។ ដូច្នេះ បទបញ្ញត្តិ និងលក្ខខណ្ឌផ្សេងៗត្រូវតែមានដើម្បីកាត់បន្ថយផលប៉ះពាល់នៃការរញ្ជួយដីទៅលើជីវិតមនុស្ស ទ្រព្យសម្បត្តិ និងបរិស្ថាន ។

៨. តារាងបង្ហាញពីភាពធ្ងន់ធ្ងរទាក់ទងនឹងផលប៉ះពាល់លើជីវិតមនុស្ស (L) បរិស្ថាន (E) និងទ្រព្យសម្បត្តិ (P) ។ ល្បឿន (S) ដែលព្រឹត្តិការណ៍មួយអាចកើតមានឡើងមានសារៈសំខាន់ណាស់ក្នុងការកំណត់ថាតើមានមនុស្សប៉ុន្មាននាក់ មានទ្រព្យសម្បត្តិ និងបរិស្ថានប៉ុន្មានអាចទទួលរងនូវផលប៉ះពាល់ក្នុងពេលវេលាមួយនោះ ដែលតាមរយៈនោះមានផលប៉ះពាល់ទៅលើភាពជោគជ័យនៃវិធានការឆ្លើយតប។ តារាងទាំងនេះប្រើដើម្បីកំណត់ភាពធ្ងន់ធ្ងរនៃគ្រោះថ្នាក់ ឬព្រឹត្តិការណ៍ដែលបានកើតឡើង។ ភាពធ្ងន់ធ្ងរនេះបែងចែកជា៥ថ្នាក់ដូចដែលមានបង្ហាញក្នុងតារាងខាងក្រោម ។

៩. តារាងជួរឈរទី២គឺសំរាប់កំណត់ចំណាំនូវការប៉ាន់ស្មាននៃព្រឹត្តិការណ៍បន្ទាន់ដែលកើតមានឡើង និងចំណុចអាទិភាពដែលមុខសញ្ញាគ្រោះថ្នាក់គួរទទួលបានការដោះស្រាយ។ ការប៉ាន់ស្មាននេះជាទូទៅចែកចេញជា៥ថ្នាក់ដែលលេខ៥បង្ហាញពីភាពប្រហែលខ្លាំង (Very probable) (ប្រេកង់ច្រើនជាង ម្តងក្នុង១ឆ្នាំ) ទៅ ១ "មិនប្រហែលកើតឡើង-Improbable" (តិចជាង១ដងក្នុងរាល់១000ឆ្នាំ) ចូរមើលក្នុងម៉ាទ្រីសខាងក្រោម។ អ្នកអានដែលចាប់អារម្មណ៍អាចស្វែងរកសៀវភៅអានដែលនិយាយពិស្តារអំពីនីតិវិធីនេះ។




***ដូចដែលបានធ្វើកំណត់ចំណាំខាងលើតម្លៃនៃនីតិវិធីនេះសម្រាប់ផែនការបែងចែកតំបន់ប្រើប្រាស់ត្រូវ:***

- កំណត់ប្រភេទ និងទីតាំងដើមហេតុហានិភ័យ
- កំណត់ប្រភេទ និងទីតាំងនៃលក្ខណ:ហានិភ័យ-រួមមានសហគមន៍បរិស្ថាន លំនៅដ្ឋាន វប្បធម៌ ឬលក្ខណ:ហេដ្ឋារចនាសម្ព័ន្ធ
- ប្រើប្រាស់ផែនការបែងចែកតំបន់ដោយដាក់នូវកំហិតតំបន់លើដើមហេតុហានិភ័យទាក់ទងនឹងលក្ខណ:ប្រឈមហានិភ័យដោយប្រើប្រាស់នូវវិធានការផ្សេងៗដូចជាតំបន់ទ្រនាប់ និងការកំណត់បន្ទាត់ថយក្រោយ Setback lines
- ប្រើប្រាស់ផែនការបែងចែកតំបន់នៅក្នុងការបែងចែកតំបន់ដើម្បីកំណត់នូវលក្ខខណ្ឌសម្រាប់ការអភិវឌ្ឍនៅកន្លែងដែលមុខសញ្ញាគ្រោះថ្នាក់មួយចំនួនមិនអាចជៀសវាងបានដើម្បីកាត់បន្ថយផលប៉ះពាល់នៃឧបទ្ទវហេតុណាឬព្រឹត្តិការណ៍ដែលបានកើតឡើង
- កណត់តំបន់ពិសេសក្រុមមនុស្សងាយរងគ្រោះមួយ ឬច្រើន និងអ្នកមិនអាច ឬទំនងជាមិនអាចធូរស្បើយបានពីគ្រោះថ្នាក់នេះ
- កំណត់ និង ផ្តល់អាទិភាពដល់កម្មវិធីអនុវត្តនៃសកម្មភាពពិសេសដែលអាចធានាក្នុងការគាំទ្រឱ្យធ្វើដំណើរទៅរកសង្គមមួយប្រកបដោយសុវត្ថភាព។ ឧ. សកម្មភាពបែបនេះអាចរួមមានកម្មវិធីកំណត់ទីតាំងតំបន់សម្រាប់ក្រុមសង្គមដែលងាយរងគ្រោះដោយសារគ្រោះមហន្តរាយ ។

របាយការណ៍ចេញផ្សព្វផ្សាយថ្មីៗគឺ ***Harnessing Synergies***: ការបញ្ជ្រាបការបន្សាំនឹងការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធី និងគោលនយោបាយកាត់បន្ថយហានិភ័យគ្រោះថ្នាក់ (Harris &Bahadur,2011)-ផ្តល់នូវទស្សនៈល្អៗអំពីគោលការណ៍ និងដំណាក់កាលពាក់ព័ន្ធ។ ដោយសារតែនេះជាការចូលរួមចំណែកលើកដំបូង របាយការណ៍នេះបានដកស្រង់យកបទពិសោធន៍អ្នកគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយជាង១០០នាក់មកពីតំបន់ផ្សេងៗទូទាំងអាស៊ីនិងអាហ្វ្រិច។ របាយការណ៍នេះផ្តល់នូវតម្រុយការអនុវត្តជាក់ស្តែង ចំណុចសកម្មភាព ដំបូន្មាន និងគោលការណ៍ណែនាំស្តីពីដំណើរការបញ្ជ្រាបនេះ។ របាយការណ៍នេះផ្តោតជាសំខាន់ទៅលើការបញ្ជ្រាប CCA ទៅក្នុងកម្មវិធី និងគោលនយោបាយ DRR ។

អ្នកនយោបាយ និង អ្នកអនុវត្តដែលធ្វើការទូទាំងពិភពលោកកំពុងទទួលស្គាល់នូវសារៈសំខាន់នៃការបញ្ចូលគ្នានូវការកាត់បន្ថយគ្រោះហានិភ័យ (DRR) និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ (CCA) ហើយមានការទទួលស្គាល់ច្រើនឡើងៗនូវតម្លៃនៃការបញ្ជ្រាប CCA ទៅក្នុងសកម្មភាព DRR ដើម្បីកាត់បន្ថយភាពងាយរងគ្រោះ និងបង្កើនភាពធន់។ របាយការណ៍នេះជាមូលដ្ឋានសម្រាប់ដំណើរការដែលស្វែងរកការពិតដែលជាមូលដ្ឋានគ្រឹះក្នុង ការបញ្ជ្រាប CCA ទៅក្នុង DRR: ថាតើនរណាជាអ្នកដឹកនាំនូវគំនិតផ្តួចផ្តើមនេះហើយថាតើអ្វីជាការលើកទឹកចិត្តដល់តួរអង្គទាំងនេះ? តើអ្វីជាការប្រឈមមុខនឹងពិភពលោកពិត និងថាតើពួកគេអាចពុះពារបានប៉ុណ្ណា? តើវិធីសាស្រ្ត និងល្បិចកលអ្វីអាចប្រើដើម្បីធ្វើការបញ្ជ្រាប និងថាតើត្រូវការចំណេះដឹង និងជំនាញអ្វីខ្លះ?

១០ ឆ្នាំកន្លងមក របៀបវារៈនៃការដាក់បញ្ចូល DRR និង CCA មានសន្ទុះកើនឡើង ។ ប៉ុន្តែមានការរីកចម្រើនកាន់តែខ្លាំងឡើងតាមរយៈការយល់ឃើញ និងនៅលើក្រដាសជាងការអនុវត្តជាក់ស្តែង។ ទោះបីជាមានគោលដៅរួមដើម្បីកាត់បន្ថយភាពក្រីក្រ ភាពងាយរងគ្រោះ និងការកើនឡើងភាពធន់ក៏ដោយ CCA និង DRR ជាធម្មតាខ្វះខាតនូវការប្តេជ្ញាចិត្តគាំទ្រថវិកា និងគោលនយោបាយ។ នៅក្នុងស្ថានភាពសេដ្ឋកិច្ចថ្មីៗនេះនិន្នាការសំរាប់ម្ចាស់ជំនួយ និងរដ្ឋាភិបាលចង់បានលទ្ធផល "រឹងមាំ-Hard" ហើយការវិនិយោគការអភិវឌ្ឍរូបវន្តបន្ត រារាំងការគាំទ្រដែលត្រូវការសម្រាប់សកម្មភាព (ទន់-Soft) រួម។

ឧបករណ៍ផ្នែកស្មារតីដែលមានឈ្មោះថា Zebra ត្រូវបានបង្កើតឡើង។ Zebra គឺជាដំណើរការមួយដែលអាចប្រើដោយអ្នកធ្វើសេចក្តីសំរេចចិត្តផ្នែកនយោបាយ និង អ្នកអនុវត្តដោយសារតែគេទទួលស្គាល់ថាមិនមានអត្ថន័យពីរដូចគ្នានោះទេ។ គោលបំណងសំខាន់នៃឧបករណ៍នេះគឺដើម្បីផ្តល់គ្រោងការការងារមួយសំរាប់អ្នកគ្រប់គ្រងកម្មវិធីក្នុងការគិតគូរលំអិតនូវដំណើរការបញ្ជ្រាបនេះ។ Zebra ផ្តល់នូវមធ្យោបាយដើម្បីគិតគូរលំអិតពីស្ថានភាពជីវិតពិតដើម្បីកំណត់នូវតម្រុយងាយស្រួល ចំណុចសកម្មភាព គំនិតយោបល់ និងគោលការណ៍ថាតើត្រូវបញ្ជ្រាប CCA ទៅក្នុងកម្មវិធី និង គោលនយោបាយ DRR ដោយរបៀបណា។ វាមិនមែនមានតែវិធីមួយទេក្នុងការបញ្ជ្រាប CCA ទៅក្នុងកម្មវិធី និង គោលនយោបាយ DRR

ហើយមិនមែនជាវិធីសាស្ត្រសំខាន់ (silver bullets) សំរាប់បង្កើតវិធីសាស្ត្រ DRR នោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ គេអាចសិក្សាពីបទពិសោធន៍ ពិភាក្សានូវគំនិត និងកំណត់ថាតើសំណើណាខ្លះទំនងជាមានប្រសិទ្ធភាពនៅក្នុងស៊ីណារីយោនេះ។ វាមានភាពសំខាន់សំរាប់អ្នកគ្រប់គ្រងគ្រោះហានិភ័យដើម្បីយល់ពីធម្មជាតិប្រែប្រួលដែលពួកគេមានគោលបំណងនិងការស្រមៃមើលសេចក្តីបញ្ចប់នៃដំណើរការបញ្ជ្រាបនេះដើម្បីកំណត់យ៉ាងយកចិត្តទុកដាក់នូវទិសដៅដែលពួកគេត្រូវទៅ។ ធ្វើការជ្រាបការផ្លាស់ប្តូរតម្រូវការទៅក្នុងរចនាសម្ព័ន្ធប្រតិបត្តិការ ទីតាំងស្ថាប័ន វិធីសាស្ត្របណ្តាញ លំហូរថវិកា និងគោលនយោបាយគ្រប់គ្រងការងារដែលបានអនុវត្តមានឈ្មោះថា CCAនិង DRR។ ទោះបីជាយ៉ាងណាក៏ដោយការប្រែប្រួលអាកាសធាតុបន្តិចម្តងៗអាចបង្កើននូវភាពងាយរងគ្រោះដល់អ្នកក្រីក្រ និង ធ្វើឱ្យអ្នកគ្រប់គ្រងហានិភ័យគ្រោះថ្នាក់កាន់តែមានការលំបាក។ ដូចនេះមានការអំពាវនាវឱ្យមានការបញ្ជ្រាបកាន់តែច្រើនឡើងៗ CCA ទៅក្នុង DRR ហើយបញ្ជ្រាបទៅក្នុងផែនការអភិវឌ្ឍន៍ជាតិ។ ដោយទាញយកផលប្រយោជន៍ពីភាពជាន់គ្នារវាង CCA និង DRR ជាវិធីមួយដើម្បីធានាថាអ្នកគ្រប់គ្រងហានិភ័យគ្រោះថ្នាក់អាចបន្តទទួលបាននូវផលប៉ះពាល់វិជ្ជមានលើការកាត់បន្ថយភាពងាយរងគ្រោះនេះ។

ការបន្សាំនឹងការប្រែប្រួលអាកាសធាតុគឺជារបៀបវារៈគោលនយោបាយអន្តរជាតិហើយមានសក្តានុពលក្នុងការទទួលបានការគាំទ្រពីម្ចាស់ជំនួយថ្មីៗ។ ការតភ្ជាប់រវាង CCA និង DRR កំពុងតែបញ្ជាក់ច្បាស់នៅក្នុងប្រកខណ្ឌ និងកិច្ចព្រមព្រៀងនានានៅថ្នាក់ជាតិនិងអន្តរជាតិ។ ការគ្រប់គ្រងហានិភ័យគ្រោះថ្នាក់ (DRM) ចាំបាច់ត្រូវតែផ្លាស់ប្តូរនីតិវិធីគណនាហានិភ័យនិងការរៀបចំបទអន្តរាគមន៍ ដើម្បីបញ្ចូលនូវគំរូអាកាសធាតុ និងភាពមិនទៀងទាត់របស់វា។ មានចំណុចមួយចំនួនត្រួតគ្នារវាង CCAនិងDRR ដែលងាយឱ្យគេទាញយកផលចំណេញដើម្បីទទួលបានបទអន្តរាគមន៍កាន់តែប្រសើរ និងមានប្រសិទ្ធ-ភាព។ និយាយឱ្យទូលំទូលាយទៅ គេអាចដឹងបានថា CCA មានបំណងជួយសហគមន៍ឱ្យអនុវត្តនូវការសម្របសម្រួលរយៈពេលវែងចំពោះការប្រែប្រួលលក្ខខណ្ឌអាកាសធាតុមធ្យម ផ្ទុយទៅវិញ DRR និយាយពីការភ្ជាប់ទំនាក់ទំនងទៅនឹងព្រឹត្តិ-ការណ៍អាកាសធាតុដ៏មានសក្តានុពល។ ដូច្នេះហើយ CCAនិងDRR មិនដូចគ្នា ហើយមិនគួរដាក់បញ្ចូលគ្នាដែរ។ DRR និយាយពីរាល់មុខសញ្ញាគ្រោះថ្នាក់ទាំងអស់រួមទាំងមុខសញ្ញាគ្រោះថ្នាក់ភូគព្ភរូបវន្ត។ ចំណែកឯ CCA និយាយជាពិសេសនូវមុខសញ្ញាគ្រោះថ្នាក់ទាក់ទងនឹងអាកាសធាតុដែលរួមជាមួយការប្រែប្រួលអាកាសធាតុមធ្យមហើយទាំងពីរនេះ CCA និង DRR មានគោលដៅកាត់បន្ថយផលប៉ះពាល់ពីមុខសញ្ញាគ្រោះថ្នាក់ផ្អែកឧតុនិយម ប៉ុន្តែពេលវេលាខុសៗគ្នា។ CCA មានគោលបំណងជួយដល់សហគមន៍អនុវត្តនីតិវិធានការសម្របសម្រួលរយៈពេលវែងចំពោះការប្រែប្រួលអាកាសធាតុមធ្យម ចំណែក DDR ផ្តោតទៅលើការដោះស្រាយហេតុការណ៍កើតឡើងរយៈពេលខ្លី។ ដំណើរការភាគច្រើននៃ CCA និង DRR នៅថ្នាក់ជាតិនៅតែមានលក្ខណៈស្របគ្នា។

Zebraគឺជាឧបករណ៍ផ្អែកស្នារតីមួយដែលជួយដល់អ្នកគ្រប់គ្រងគ្រោះហានិភ័យនូវវិធីមួយដោយគិតគូរលំអិតពីស្ថានភាពជីវិតពិតដោយបង្ហាញពីស៊ីណារីយ៉ូពិត និងប្រឌិតឡើងលើការបញ្ជ្រាប CCA ទៅក្នុង DRR និង DRR ទៅក្នុងកម្មវិធីអភិវឌ្ឍន៍។ Zebra ប្រឈមមុខជាមួយអ្នកនយោបាយនិងអ្នកអនុវត្តជាក់ស្តែងដើម្បីឆ្លុះបញ្ចាំងពីការសិក្សា រៀនសូត្រ បទពិសោធន៍ និងសកម្មភាពផ្ទាល់របស់ពួកគេដើម្បីផ្តល់នូវការណែនាំជាក់ស្តែងសំរាប់ការបញ្ជ្រាបនេះ។ Zebra ផ្អែកលើការសន្ទតដែលលើកកម្ពស់ និងតភ្ជាប់រវាង CCA និង DRR ដែលតម្រូវឱ្យមានគោលការណ៍ណែនាំតាមបែប ស្ថាបនា និងដ៏សកម្ម ហើយវាអាចផ្តល់នូវមធ្យោបាយដើម្បីកំណត់នូវតម្រុយងាយៗ ចំណុចសកម្មភាព ការយល់ដឹង និង គោលការណ៍ណែនាំអំពីថាតើត្រូវធ្វើសមាហរណកម្ម CCA ទៅក្នុងកម្មវិធី និងគោលនយោបាយ DRR របៀបណា ហើយសសរទ្រូងផ្អែកស្មារតីទាំង៣នេះបង្កើតបានជាមូលដ្ឋានគ្រឹះនៃវិធីសាស្ត្រនេះ។ Zebra គឺជាឧបករណ៍មួយដែលឱ្យអ្នកគ្រប់គ្រងកម្មវិធីដែលយកចិត្តទុកដាក់យ៉ាងខ្លាំងលើការគ្រប់គ្រងប្រចាំថ្ងៃនៃគម្រោងនីមួយៗឱ្យផ្អាកឬ ឆ្លុះបញ្ចាំង និងបង្កើតយុទ្ធសាស្ត្រប្រកបដោយគំនិតច្នៃប្រឌិតដើម្បីធានាថាការងាររបស់ពួកគេអាចមានទំនាក់ទំនងគ្នាទោះបីជានិយាយលំអិតតែលើ ការប្រែប្រួលអាកាសធាតុក៏ដោយ។

## ឧបសម្ព័ន្ធទី២: ការរួមបញ្ចូលការប្រើប្រាស់ដី និងសមុទ្រនៅក្នុងផែនការមួយ

***ករណីសិក្សា: ផែនការបែងចែកតំបន់ប្រើប្រាស់សមុទ្រ និងដីឆ្នេរនៅខេត្តបាតាន ប្រទេសហ្វីលីពីន (CLSUZP)***

CLSUZP ដែលធ្វើឡើងសម្រាប់តែខេត្តបាតាន់ ប្រទេសហ្វីលីពីននោះគេចាត់ទុកថាជាឧបករណ៍មួយសំរាប់ពង្រឹងការប្រើប្រាស់ធនធានឆ្នេរសមុទ្រ។ ខេត្តបាតាន់គឺជាឧបទ្វីបមួយដែលមានសាលាក្រុង ១១ និងទីក្រុងមួយ ដែលមានទំហំផ្ទៃដី ១.៣៧៣គ.ម$^2$ ។ តំបន់ឈូងសមុទ្រមានីលគឺជាតំបន់សំខាន់មួយនៃប្រទេសហ្វីលីពីនសម្រាប់សកម្មភាពសេដ្ឋកិច្ច ដើម្បីជម្រុញកំណើន និងការអភិវឌ្ឍដែលមានចាប់ពីផ្នែកដឹកជញ្ជូនតាមកប៉ាល់ ឧស្សាហកម្ម ពាណិជ្ជកម្ម នេសាទ ជលវប្បកម្មរហូតដល់សកម្មភាពទេសចរណ៍។ ផែនការបែងចែកតំបន់របស់ឈូងសមុទ្រមានីលគឺជាការចាំបាច់ក្នុងការដោះស្រាយជម្លោះ ការប្រើប្រាស់ជាច្រើនហើយនឹងដោះស្រាយបញ្ហាផ្សេងៗដែលកើតមានឡើង។ បាតាន់គឺជាតំបន់សាកល្បងសំរាប់ការបែងចែកតំបន់ប្រើប្រាស់ឆ្នេរនៃឈូងសមុទ្រមានីល ។

ឈូងសមុទ្រមានីលខេត្តបាតាន់




> ***“ផែនការប្រើប្រាស់ដីដ៏ស៊ីជម្រៅ (CLUPs) នៃសាលាក្រុងនីមួយៗ និងផែនការរូបវន្តត្រូវបានតភ្ជាប់និងធ្វើឱ្យសុខដុមនីយកម្មជាមួយផែនការបែងចែកការប្រើប្រាស់តំបន់ឆ្នេរនេះដើម្បីផ្តល់នូវផែនការប្រើប្រាស់ដី និងសមុទ្រចម្រុះដ៏ស៊ីជម្រៅមួយសម្រាប់ខេត្តនេះ ។”***

សមាសភាពរៀបចំផែនការសំខាន់ៗដែលបានប្រើនៅក្នុងផែនការខេត្តបាតាន់ត្រូវបានជ្រើសរើសតំបន់ចំនួន១២។

**NEW COASTAL LAND AND SEA USE ZONES**

| | |
|---|---|
| 1 | Agricultural Zone *(farms and fishpond)* |
| 2 | Aquaculture *(fish pens/cages, shellfish farms)* |
| 3 | Built-up Area Zone<br>*(Commercial, Residential, Institutional)* |
| 4 | Coral Reef Restoration<br>and Protection Zone |
| 5 | Industrial Zone |
| 6 | Mangrove & Mudflat Restoration<br>and Protection Zone |
| 7 | Municipal Fishing Zone |
| 8 | Sanctuaries |
| 9 | Seagrass Restoration & Protection Zone |
| 10 | Shipping & Navigational Use Zone |
| 11 | Tourism Zone *(recreation, cultural & eco-tourism)* |
| 12 | Traditional Fishing Zone |

| | |
|---|---|
| (red) | New |
| (grey) | Existing |
| | NA |

**Note:** *Fish Sanctuary, Marine Turtle Sanctuary (Strict Protection)*
*Mangrove,coral,seagrass (Restoration, Protection and Habitat Management Zone)*

ខាងក្រោមនេះដកស្រង់ចេញពីផែនការបង្ហាញពីតំបន់អនុញ្ញាតិ  ហាមឃាត់  និងប្រើប្រាស់ដោយមានបទបញ្ញតិដែលអាចទាក់ទងទៅនឹងតំបន់ទាំង១២។  គោលការណ៍ណែនាំ  លក្ខណៈបទបញ្ញតិ  និងវិសាលភាពតំបន់បានចុះបញ្ជី  និងចែកចាយតាមលក្ខណៈភូមិសាស្ត្រតំបន់សម្រាប់សាលាក្រុងនីមួយៗដែលបង្ហាញនៅក្នុងផែនទី និងតារាង។

Table 7. Guidelines for the Coastal Land- and Sea-Use Zones *(continued from page 52)*

| ZONES | ALLOWED USES | | | PROHIBITED/ RESTRICTED USES | SUPPORTING NATIONAL POLICIES | RESPONSIBLE AGENCY/ INSTITUTION |
|---|---|---|---|---|---|---|
| | DOMINANT | COMPATIBLE | REGULATED | | | |
| **Coral Reef Restoration and Protection Zone** | • Breeding, spawning, feeding area for marine fishes, turtles, etc.<br>• Coral reef sanctuary or protected area<br>• Fish sanctuary | • Marine reserve<br>• Tourism<br>• Research and study | • Tourism and recreation (diving & snorkelling)<br>• Research and study | • Collection/ harvesting of any type of corals<br>• All fishing activities<br>• Use as shipping and navigational lane | R.A. 9147;<br>R.A. 7586;<br>R.A. 8550;<br>P.D. 1219 | LGUs*<br>DENR<br>DA-BFAR<br>PNP<br>PCG<br>DOT<br>DOST-PCMARD<br>POs, NGOs<br>Private sector |
| **Industrial Zone** | • Industrial development | • Commercial | • Establishment/ expansion of refinery oil and chemical depot, quarrying activities, & mangrove planting | • Tourism development<br>• Fishing activities<br>• Untreated liquid, solid, toxic, and hazardous waste disposal<br>• Residential | P.D. 1152 Sec.24;<br>R.A. 9003;<br>R.A. 9275;<br>R.A. 6969;<br>P.D. 1151;<br>P.D. 1586;<br>R.A. 7942 | LGUs*<br>DTI<br>PEZA<br>DENR<br>PPA |
| **Mangrove and Mudflat Protection Zone**<br><br>Mangroves | • Mangrove planting.<br>• Rehabilitation and protection<br>• Food and sanctuary for birds and marine life<br>• Mangrove nursery and collection of propagules for replanting<br>• Protection of shoreline | • Ecotourism sites<br>• Bird sanctuary<br>• Research and educational purposes; avifauna monitoring<br>Conversion of abandoned fishponds back into mangroves. | • Mudcrab culture<br>• Collection of dried branches for fuelwood<br>• Establishment of ecotourism structures (e.g., boardwalks, etc.)<br>• Collection of associated mangrove species, (e.g., nipa) | • Cutting of mangroves<br>• Conversion of mangrove areas into other uses<br>• Building structures within mangrove areas<br>• Encroachment of built-up areas (settlement) | R.A. 8550;<br>P.D. 705;<br>R.A. 9147;<br>R.A. 7161;<br>R.A. 9003;<br>DENR DAO 15-90;<br>P.D. 1067, Art. 51;<br>CA 141; CA349 | LGUs*<br>DENR<br>DA-BFAR<br>DOT<br>PNP<br>POs, NGOs |
| **Mudflats** | • Mudflat protection<br>• Habitat for shrimp, crabs, etc. | • Bird sanctuary<br>• Research and educational purposes | • Mangrove planting<br>• Dredging for fishing vessel navigational lane | • Conversion/ reclamation of mudflat areas (e.g., settlement, commercial, & industrial purposes) | | |

## ឧបសម្ព័ន្ធ ៣៖ ការធ្វើការជាមួយភាគីពាក់ព័ន្ធ

ដំណើការជាមូលដ្ឋានក្នុងការកំណត់ និងវិភាគភាគីពាក់ព័ន្ធ:

១. ចូរកំណត់ការអនុវត្ត CSP របស់អ្នកនៅថ្នាក់តំបន់ មជ្ឈឹម និងថ្នាក់ជាតិ។ នេះគួរតែមានផលប៉ះពាល់ដល់ជំរើសភាគីពាក់ព័ន្ធ និងតំណាងក្រុមភាគីពាក់ព័ន្ធ ។

២. ចូរកំណត់នៅក្នុងស្ថាប័នផ្ទាល់របស់អ្នកថាតើនរណាជាអ្នកសំរេចចិត្តដំបូងទាក់ទងនឹងតំបន់សិក្សា CSP របស់អ្នក ហើយចូរបញ្ចូលការងារទាំងឡាយដែលប៉ះពាល់ដល់ផ្នែកហិរញ្ញវត្ថុផងដែរ។ តារាងរបស់អ្នកនឹងរួមបញ្ចូលនូវអ្នកគ្រប់គ្រងផ្ទាល់។ វាមានសារៈសំខាន់ដែលអ្នកនូវតែបន្តជូនដំណឹងដល់អ្នកពាក់ព័ន្ធនូវភាពរីកចម្រើន និងដំណើរការដែលអ្នកកំពុងប្រើ និងធ្វើការឱ្យមានការគាំទ្ររបស់ពួកគេ។

៣. ចូរកំណត់នូវអាជ្ញាធរតាមវិស័យសាធារណៈដែលចូលរួមដោយផ្ទាល់ក្នុងការងារគ្រប់គ្រងនិងរដ្ឋបាលនៃធនធានដែលមាននៅក្នុងតំបន់ CSP។ អាជ្ញាធរទាំងនោះរួមមាន តំណាងផ្នែកជលផល កសិកម្ម ព្រៃឈើ ទេសចរណ៍ គមនាគមន៍ បរិស្ថាន និង ការអភិរក្សនិងរដ្ឋបាលមូលដ្ឋាន ប៉ុន្តែអាចមានចំនួនច្រើនជាងនេះទៀត។ ចូរប្រយ័ត្នសូម្បីតែនៅថ្នាក់នាយកដ្ឋានការទទួលខុសត្រូវលើ ការនេសាទបែបជំនួញ ការនេសាទទ្រង់ទ្រាយតូច និងវារីវប្បកម្មប្រហែលជាស្ថិតនៅក្នុងអង្គភាពផ្សេងៗគ្នាក្រោមអាជ្ញាធរដូចគ្នា។ អាជ្ញាធរទាំងនេះ (ឬអ្នកតំណាងនៅមូលដ្ឋានរបស់ពួកគេ) អាចបកស្រាយបានថាមានសំលេងស្របច្បាប់ នៅក្នុងដំណើការរៀបចំផែនការនិងគួរតែធ្វើសកម្មនៅក្នុងដំណើរការនេះ។ ប្រហែលជាមានអង្គការផ្សេងៗទៀតដែលមានតួនាទីមិនផ្ទាល់ហើយពួកគេមិនមានតួនាទីត្រួតពិនិត្យជាប្រចាំថ្ងៃនោះទេប៉ុន្តែអាចមានសារៈសំខាន់បើគិតពីទស្សនៈគោលនយោបាយវិញ។

៤. ចូរបង្កើតបណ្តាញដ្យាក្រាមមួយដែលនិយាយពីទំនាក់ទំនងអាជ្ញាធរទាំងនេះ។ ចូរចំណាំថាតើព័តិមានបែបណាក្នុងចំណោមពួកគេ និងចូរប្រយ័ត្នថាតើអ្នកនឹងកែប្រែនូវប្រភេទព័តិមាន ឥទ្ធិពល និងការគាំទ្រផ្សេងៗនៅកន្លែងណា។ ចូរចាំណាំថាតើអាជ្ញាធរណាមួយមានឈ្មោះល្បីថាមាន "**អំណាច**" តិចឬច្រើនដើម្បីសម្រេចបានគោលដៅតាមផ្នែករបស់ពួកគេនោះដែលអាចមានដោយសារតែទំហំ និងប្រសិទ្ធភាពផ្ទាល់របស់ពួកគេ រឺដោយសារតែវិស័យផ្ទាល់របស់គេមានចំណុចអាទិភាពក្នុងរង្វង់រដ្ឋាភិបាល។ ចូរចំណាំនៅកន្លែងដែលមានអត្ថប្រយោជន៏រួម និងកន្លែងដែលអាចមានទំនាស់។ ទិដ្ឋភាពនេះនឹងធ្វើឱ្យប៉ះពាល់ដល់ការងាររបស់អ្នកហើយនឹងត្រូវការវិធីសាស្ត្រពិសេសៗ។ នៅក្នុងតំបន់ឆ្នេរ ទំនាស់តាមផ្នែកអាចកើនឡើងរវាងរុក្ខាប្រម៉ាញ់និងវារីវប្បកម្មរវាងការនេសាទទ្រង់ទ្រាយតូច និង ការនេសាទបែបពាណិជ្ជកម្មរវាងទេសចរណ៍ និង ការអភិរក្សរវាងការអភិរក្សនិងការអភិវឌ្ឍ ។ល។

៥. ចូរកំណត់ភាគីពាក់ព័ន្ធនិងវិស័យពាណិជ្ជកម្ម។ ដោយអាស្រ័យថាតើផែនការរបស់អ្នកស្ថិតនៅថ្នាក់ជាតិឬ មូលដ្ឋានអ្នកត្រូវធ្វើការជាមួយនឹងសភាពាណិជ្ជកម្មហើយនឹងសមាគមន៍មួយចំនួនទៀតនៅថ្នាក់ជាតិហើយក៏អាចធ្វើការជាមួយសហគ្រាសខ្នាតធំនៅថ្នាក់មូលដ្ឋានផងដែរ។ ចូរយល់ឱ្យច្បាស់នូវអត្ថប្រយោជន៍ជាក់លាក់របស់ពួកគេទាំងវិនិយោគដើម្បីផលចំណេញ និងរូបភាពសាធារណៈនិងការទទួលខុសត្រូវរួមរបស់សង្គម។ ចូរបញ្ចូលនូវភាគីពាក់ព័ន្ធទាំងនេះទៅក្នុងដ្យាក្រាមបណ្តាញ និងដោយចំណាំថាតើវិស័យឯកជនណាដែលពាក់ព័ន្ធនឹងអាជ្ញាធរវិស័យសាធារណៈ។

៦. ចូរកំណត់ភាគីពាក់ព័ន្ធសង្គមស៊ីវិលដោយបែងចែករវាងអង្គការក្រៅរដ្ឋាភិបាលជាតិ រឺអន្តរជាតិ តំបន់សហគមន៍ផ្អែកលើមូលដ្ឋាន រឺអង្គការផ្អែកលើលទ្ធិសាសនា និងក្រុមទទួលផលប្រយោជន៍។ នៅពេលធ្វើការនៅថ្នាក់មូលដ្ឋាន ចូរធានាថាមានស្ថាប័នសង្គមស៊ីវិលមួយចំនួនដែលអាចជួយក្នុងការចូលរួមផ្ទាល់ ប៉ុន្តែថែមទាំងអាចជម្រុញឱ្យវិស័យសាធារណៈទូទៅចូលរួមផងដែរ។ ចូរចំណាំម្តងទៀតនូវរាល់ប្រភេទនៃការគាំទ្រដ៏មានសក្តានុពល ឬការប្រឆាំងនឹងការងាររបស់អ្នកប៉ុន្តែក្នុងចំណោមភាគីពាក់ព័ន្ធ (វាមានការជំទាស់រវាងអង្គការសង្គមស៊ីវិលខ្លះ និងផ្នែកឧស្សាហកម្មឬរវាងអង្គការអ្នកពាក់ព័ន្ធសហគមន៍ (CSOs) និងអាជ្ញាធរវិស័យសាធារណៈជាក់លាក់មួយចំនួន)។ ចូរចងចាំថាដំណើរការកសាងផែនការរបស់អ្នកអាចពង្រឹងទំនាក់ទំនង និងសំរេចបានដំណោះស្រាយ **ឈ្នះ-ឈ្នះ** ទៅលើបញ្ហាដែលមានគោលគំនិតខុសគ្នាស្រឡះ។ ចូរបន្ថែមនូវភាគីពាក់ព័ន្ធទាំងនេះទៅក្នុងដ្យាក្រាមបណ្តាញ ដោយចង្អុលបង្ហាញទំនាក់ទំនងទាំងនេះ (ការគាំទ្រ ឬប្រឆាំង) រវាង CSOs អត្ថប្រយោជន៍ផ្នែកពាណិជ្ជកម្ម វិស័យឯកជន និងអាជ្ញាធរសាធារណៈ។

៧. ចូរកំណត់ថាតើអ្នកនឹងធ្វើការនេះដោយរបៀបណាជាមួយភាគីពាក់ព័ន្ធនីមួយៗ។ យើងមិនអាចប្រើវិធីសាស្ត្រដូចគ្នានិងយន្តការដូចគ្នាសំរាប់រាល់ភាគីពាក់ព័ន្ធទាំងអស់នោះទេ ហើយនៅក្នុងដំណាក់កាលនេះអ្នកត្រូវការរៀបចំនូវយុទ្ធសាស្ត្រទំនាក់ទំនង និងកម្មវិធីពាក់ព័ន្ធរបស់អ្នក។ ចូរភ្ជាប់ទិដ្ឋភាពទាំងនេះជាមួយនឹងដំណើរការរៀបចំផែនការផ្សេងៗជាពិសេសទាក់ទងនឹងការប្រមូលផ្តុំព័ត៌មានបច្ចេកទេសមូលដ្ឋានដោយបង្កើតនូវចក្ខុវិស័យ និងគោលដៅរយៈពេលវែងដោយធ្វើការសិក្សាពិសេសដោយបង្កើតយុទ្ធសាស្ត្រដោយពិនិត្យឡើងវិញនូវផែនការ និងបញ្ហាពាក់ព័ន្ធនឹងការបែងចែកតំបន់ព្រមទាំងការរៀបចំកម្មវិធីអនុវត្តរយៈពេលខ្លី។ ថវិការបស់អ្នកនឹងធ្វើឱ្យប៉ះពាល់ដល់កម្មវិធីពីគ្រោះយោបល់នេះ។ ម្យ៉ាងវិញទៀត ការវិភាគភាគីពាក់ព័ន្ធដ៏ប្រសើរមួយដែលគួសបញ្ជាក់នូវតំរូវការសំរាប់ការសំរេចចិត្តប្រកបដោយការផ្សះផ្សារតាមរយៈវិធីសាស្ត្រពាក់ព័ន្ធអាចជាមធ្យោបាយមួយដើម្បីស្នើឱ្យមានថវិកាពិគ្រោះយោបល់ និងទំនាក់ទំនងកាន់តែធំ។

ការវិភាគកម្រិតនៃអ្នកពាក់ព័ន្ធដែលត្រូវការនឹងផ្អែកលើថាតើមានបញ្ហាចម្រុងចម្រាសដែលត្រូវដោះស្រាយនៅក្នុងផ្នែក CSP យ៉ាងណា។ កន្លែងដែលមានទំនាស់ឬប្រជែងផលប្រយោជន៍លើធនធាន រឺទីតាំងដូចគ្នានោះវានឹងមានតម្រូវការច្រើនទៀតដើម្បីយល់នូវអត្ថប្រយោជន៍ទាំងនេះ និងថាតើអ្វីជាការគាំទ្រក្រុម រឺប្រឆាំងពួកគេ (ដោយអនុវត្តន៍នូវការវិភាគ

វិស័យកម្លាំង)។ ប្រភេទពិសេស នៃអន្តរកម្មមានដូចជាវេទិកា និងសិក្ខាសាលាប្រហែលជាត្រូវការដើម្បីស្រាវជ្រាវរកដំណោះស្រាយ **ឈ្នះ-ឈ្នះ**ក្នុងដំណើរការ CSP ។

## ឧបសម្ព័ន្ធទី៤: ការផ្តល់នូវអនុសាសន៍មួយចំនួនសំរាប់រៀបចំឯកសារ

ជាគោលការណ៍គ្របដណ្តប់មួយ-បើសិនអាជ្ញាធរធ្វើផែនការមានការរៀបចំឯកសារ ឬប្រព័ន្ធគ្រប់គ្រងព័ត៌មានដ៏ស៊ីជម្រៅដែលរួមបញ្ចូលរាល់សារព័ត៌មានដោយធ្វើតាមក្បួននៃប្រព័ន្ធនោះ។ បើសិនមិនមានប្រព័ន្ធមជ្ឈការបែបនេះចូរអនុវត្តនូវគំនិតខាងក្រោម:

- រាល់គម្រោងធ្វើផែនការគួរមានលេខកូដដែលមានទាំងលេខនិងឈ្មោះដោយលេខអាចជាលេខកូដទីក្រុងហើយប្រព័ន្ធលេខកូដផ្តល់នូវវិធីងាយស្រួលទាក់ទងនឹងព័ត៌មានក្នុងគម្រោង និងរវាងគម្រោង ទោះបីជានៅកំរិតផ្សេងៗគ្នាក៏ដោយ (ដូចជា- សង្កាត់ សាលាក្រុង ខណ្ឌ ខេត្ត និងតំបន់សេដ្ឋកិច្ច)។
- ការផ្តល់ជូនទូដាក់សៀវភៅដល់គម្រោងជាបណ្ណាល័យ។ ចូររក្សានូវឯកសារយោង (ជារបាយកាណ៍សៀវភៅ ។ល។)
- ការរៀបចំឯកសារ-ដូចជាកំណត់ហេតុ និងរបាយការណ៍កិច្ចប្រជុំ ឯកសារចំលងនៃការឆ្លើយឆ្លង ។ល។ ដោយដាក់ក្នុងក្រូណូ និងមានមាតិកាច្បាស់លាស់នៅខាងក្នុងរៀបចំឯកសារដោយដាក់វាតាមប្រភេទ និងធ្វើតារាងមាតិកាថ្មីៗនៅលើក្របមុខ។
- ឯកសារជាឌីជីថលត្រូវតែរៀបចំផងដែរ។ បើសិនអ្នកមិនទាន់រួចរាល់ទេ ត្រូវបង្កើតប្រព័ន្ធរៀបចំសឺមីឌីជីថលសំរាប់ឯកសារនោះ និងឃ្លាំងផ្ទុកទិន្នន័យដើម ហើយចូរប្រើប្រាស់ប្រព័ន្ធនេះជាគំរូសំរាប់ប្រព័ន្ធឯកសារ Hard copy។ ក្នុងស្ថានភាពមួយចំនួន អ្នករៀបចំផែនការនឹងមានកុំព្យូទ័រផ្ទាល់របស់ពួកគេ ប៉ុន្តែមិនអាចភ្ជាប់ទៅនឹងបណ្តាញបាន។ វាមានសារៈសំខាន់ណាស់នៅក្នុងស្ថានភាពបែបនេះដោយរក្សាឯកសារនៅក្នុងសឺមីឌីជីថលមួយនិងបែងចែកជាផ្នែកតូចៗនៅក្នុងសឺមីធំ។ ឈ្មោះនិងរចនាសម្ព័ន្ធសឺមីលើកុំព្យូទ័រនីមួយៗត្រូវស្របជាមួយកន្លែងផ្ទុកដើម្បងាយរកឃើញ។
- សំភារៈនៅក្នុង CD និង DVD ត្រូវទុកតាមរបៀបមួយដែលមិនធ្វើឱ្យខូចខាត និងប្រកបដោយសុវត្ថិភាព។ បើសិនជាអាចចូរថតចម្លងនូវរាល់គ្រប់ CD ឬ DVD ចូររក្សាទុកនូវឯកសារដើមក្នុងទីតាំងប្រកបដោយសុវត្ថិភាពមួយ និងប្រើតែឯកសារថតចម្លង។
- ចាំបាច់ត្រូវថតចម្លងឯកសារច្រើន ហើយចែករំលែកឯកសារទាំងនោះ ចូរកុំអោយគេខ្ចីឯកសារដើមសំរាប់រយៈពេលយូរចំណែកឯកសារខ្ចីៗ ចូរថតចម្លងដើម្បីទុកឱ្យគេខ្ចី។

- ចាំបាច់ត្រូវបំបែកព័ត៌មានសំងាត់ពីឯកសារដែលអាចចែកឱ្យក្រុមហើយក្បួននៃការរៀបចំនេះគួរធ្វើតាម ។

ជាធម្មតា ឧបករណ៏ស្ទាបស្ទង់នៅតាមគេហដ្ឋានគួររក្សានៅកន្លែងមានសុវត្ថភាព ស្របតាមបទបញ្ជាថ្មី១ ។ ប្រព័ន្ធព័ត៌មានភូមិសាស្ត្រថាតើវាត្រូវបានគេហៅប្រព័ន្ធគ្រប់គ្រងព័ត៌មានបរិស្ថានទិន្នន័យបែងចែកតំបន់ឬទិន្នន័យភូមិសាស្ត្រ វាគឺជាឧបករណ៏ដ៏មានតម្លៃ និងមានឥទ្ធិពលក្នុងការធ្វើផែនការ ។ ប្រសិនបើប្រទេសនេះមានប្រព័ន្ធទិន្នន័យភូមិសាស្ត្រ ចូរប្រើវា និងប្រើប្រាស់វាដោយប្រយ័ត្នប្រយ៉ែង ។ ការធ្វើបែបនេះនឹងជួយសន្សំពេល និងកិច្ចប្រឹងប្រែង ។ ប្រសិនបើមិនមានប្រព័ន្ធបែបនេះទេ ចូរស្វែងរកការណែនាំថាតើត្រូវបង្កើតប្រព័ន្ធនេះដោយរបៀបណា ។ ការហ្វឹកហាត់ជាក់លាក់នៃ CSP គឺមិនមែនជាមូលដ្ឋានគ្រប់គ្រាន់សម្រាប់បង្កើតទិន្នន័យភូមិរយៈពេលវែង ប៉ុន្តែ រចនាសម្ព័ន្ធទិន្នន័យគោលផ្ទាល់របស់វាគួរតែរៀបចំដើម្បីសម្របតាមនិងបញ្ជូនទៅកាន់ប្រព័ន្ធរួមមួយក្នុងពេលអនាគត ។ ប្រទេសជាច្រើនបានបង្កើតទិន្នន័យភូមិផ្ទាល់របស់ពួកគេសំរាប់ប្រើក្នុងការរៀបចំ និងការគ្រប់គ្រងបរិស្ថាន ។ ឧទាហរណ៏ សៀវភៅគោលការណ៏ណែនាំ GIS របស់ហ្វីលីពីនដែលអាចមើលក្នុងគេហទំព័រ:

http://www.cookbook.hlurb.gov.ph/book/export/html/34.

និង http://www.unhabitat.org/downloads/docs/2907_70876_EMIS_.pdf

## ឧបសម្ព័ន្ធទី ៥

| ប្រធានបទ/សាច់រឿង (themes) /ផ្នែក | ផ្នែកដែលត្រូវពិនិត្យ និងរួមបញ្ចូល |
|---|---|
| ដែន និង ស្ថាប័នរដ្ឋបាល | • ចុះញ្ជីរាល់អាជ្ញាធរវិស័យសាធារណៈដែលសកម្មនៅក្នុងតំបន់រួមជាមួយការពិពណ៌នា (ឬនៅលើផែនទី) ពីតំបន់ និងទំហំដែនពួកគេ<br>• កំណត់នូវវិស័យឯកជនសំខាន់ៗ និងអង្គការក្រៅរដ្ឋាភិបាល ស្ថាប័នសង្គមស៊ីវិល ដែលមានការចាប់អារម្មណ៍ ការគ្រប់គ្រងធនធានឆ្នេរ និងការអភិវឌ្ឍប្រកបដោយចីរភាព<br>• ចូរចំណាំនូវភាពស្ទួនគ្នា ភាពមិនប្រាកដប្រជា និងចំណុចខ្វះខាត ជាពិសេសសំរាប់ប្រភេទចាំបាច់នៃធនធានតំបន់ឆ្នេរ (ឧ: នរណាជាអ្នកទទួលខុសត្រូវក្នុងការពិនិត្យមើលបញ្ហាពាក់ព័ន្ធទៅនឹងផលិតផលអំបិលដោយបង្ហូតពីត្រពាំង?) |
| គោលនយោបាយច្បាប់និងបទបញ្ញត្តិ | • រាល់គោលនយោបាយ និងបរិធានច្បាប់ពាក់ព័ន្ធនឹង CSP ការគ្រប់គ្រងធនធាន និងអភិវឌ្ឍតំបន់ឆ្នេរ។ ចូរបញ្ចូលនូវអនុសញ្ញាអន្តរជាតិនៃប្រទេសចុះហត្ថលេខី និងឧបករណ៍ស្របច្បាប់ដ៏ទៃទៀត ឧបករណ៍ស្របច្បាប់នៅថ្នាក់ជាតិ ខេត្ត ឬស្រុក និង ថ្នាក់មូលដ្ឋាន កិច្ចសន្យាសម្រាប់ការអភិវឌ្ឍ លក្ខន្តិកៈ ឧបករណ៍គ្រប់គ្រងធនធាន។ ច្បាប់ខ្លះមិនមានផែនការបែងចែកតំបន់និងមានរយៈពេលខ្លីដែលទិដ្ឋភាពទាំងនេះយើងគួរតែយកចិត្តទុកដាក់ ។<br>***ចូរពិនិត្យមើលជាពិសេសទៅលើបដិធានច្បាប់ដូចខាងក្រោម:***<br>• ការការពារតំបន់ឆ្នេរ និងសមុទ្រ<br>• ការគ្រប់គ្រងបរិស្ថាន (ការកំណត់ និងការគ្រប់គ្រងតំបន់ការពារ)<br>• ផ្នែកធនធាន: មច្ឆាជាតិ គង្គា ព្រៃឈើ រ៉ែ (រួមទាំងការរុករក) ការដកហូតប្រេងនិងហ្គាស ។ល។<br>• ការត្រួតពិនិត្យការបំពុល-***ខ្យល់ ទឹក សមុទ្រ ដី*** និងការគ្រប់គ្រងសំណល់ផងដែរ |

| ប្រធានបទ/សាច់រឿង (themes) /ផ្នែក | ផ្នែកដែលត្រូវពិនិត្យ និងរួមបញ្ចូល |
| --- | --- |
| | • ការគ្រប់គ្រងគ្រោះមហន្តរាយ និងសេវាកម្មសង្គ្រោះបន្ទាន់<br>• សន្តិសុខសង្គម<br>• ការវាយតម្លៃផលប៉ះពាល់-ថាតើ EIA/ SIA នៅកម្រិតគម្រោងឬ យុទ្ធសាស្ត្រ<br>***ចូរពិនិត្យមើលគោលនយោបាយ យុទ្ធសាស្ត្រ ឬគោលការណ៍ណែនាំដែលមានស្រាប់ស្តីពីៈ***<br>• ការបង្កើតរចនាសម្ព័ន្ធ benthic<br>• ការបង្កើត Marinas<br>• ការបង្កើតបណ្តាញខ្សែកាប និងបំពង់បង្ហូរ<br>• ការធ្វើផែនការ ការសាងសង់និងជួសជុលដើម្បីពង្រឹង និង ការពារច្រាំងឆ្នេរសមុទ្រ<br>• ការគ្រប់គ្រងឆ្នេរ<br>• ការធ្វើអាជីវកម្មខ្សាច់<br>• ការខួងជីកនៅដែសមុទ្រ ចំណតនាវា និងកំពង់ផែ<br>• ការគ្រប់គ្រងផ្កាថ្ម<br>• ការគ្រប់គ្រងស្មៅសមុទ្រ និងរុក្ខជាតិសមុទ្រតូចៗ<br>• ការគ្រប់គ្រងព្រៃកោងកាង និងតំបន់ឆ្នេរដីសើម និងបឹង<br>• ការគ្រប់គ្រងដៃសមុទ្រ<br>• ការគ្រប់គ្រងផ្នូកខ្សាច់ (ទំនប់ខ្សាច់)<br>• ការដាក់កម្រិតលើការអភិវឌ្ឍតំបន់ឆ្នេរ<br>• ការអភិវឌ្ឍទេសចរណ៍ water-front<br>• ការការពារសមុទ្រនិងតំបន់ឆ្នេរ សួនកំសាន្ត និងតំបន់ការពារឯទៀតៗ<br>• ការគ្រប់គ្រងការនេសាទ<br>• ជីវៈចម្រុះ និងការត្រួតពិនិត្យប្រភេទសត្វចម្រៃ |

| ប្រធានបទ/សាច់រឿង (themes) /ផ្នែក | ផ្នែកដែលត្រូវពិនិត្យ និងរួមបញ្ចូល |
|---|---|
| | • ការគ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់ ទាំងដោយសារធម្មជាតិ ឬមនុស្ស និងវាយតម្លៃហានិភ័យ<br>• ការត្រៀមរៀបចំទប់ស្កាត់គ្រោះមហន្តរាយ វិធានការឆ្លើយតបគ្រោះមហន្តរាយ ការស្តារឡើងវិញ និងការធ្វើអោយប្រសើរឡើងវិញ សេវាកម្មសង្គ្រោះបន្ទាន់ ការរៀបចំផែនការយថាភាព<br>• ការកាត់បន្ថយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ<br>• ការវាយតម្លៃផលប៉ះពាល់ជាយុទ្ធសាស្ត្រ និង ការវាយតម្លៃសេដ្ឋកិច្ចសង្គម និងហេតុផលប៉ះពាល់បរិស្ថាន<br>***ចូរចំណាំចំណុចខ្វះចន្លោះ ជម្លោះ ឬការភាន់ច្រឡំ:***<br>• ចូរដកស្រង់នូវសមាសធាតុសំខាន់ៗដែលអាចបង្ហាញពីផែនការជាក់លាក់។ ស្តង់ដាជាតិអាចចាត់ទុកថាជាចក្ខុវិស័យរបស់រដ្ឋទាក់ទងនឹងគុណភាពនៅក្នុងប្រធានបទស្តង់ដាពិសេសដែលស្តង់ដាគុណភាពទឹកជាតិបញ្ជាក់ពីគុណភាព ទឹកនៅកំរិតទាបដែលគួរផ្គត់ផ្គង់ដល់ប្រជាជននៅតាមទីក្រុងហើយប្រហែលជាមានស្តង់ដាដូចគ្នាចំពោះបរិស្ថាន ដូចជាគុណ ភាពខ្យល់ ទឹក ដី។ ប្រហែលជាមានបទដ្ឋាន និងស្តង់ដាផ្សេងៗអនុវត្តចំពោះការប្រើប្រាស់ដី ដង់ស៊ីតេនៃអ្នកតាំងលំនៅការឱ្យនិយមន័យនៃលក្ខខណ្ឌប្រកបដោយគ្រោះថ្នាក់។ល។ |
| ផែនទី និងផែនការបច្ចុប្បន្ន | ចូរកំណត់នូវផែនទីមូលដ្ឋានដែលប្រើប្រាស់នៅពេលបច្ចុប្បន្ន ផែនទីឋានលេខានៅកម្រិតមូលដ្ឋានផ្សេងៗគ្នាធ្វើឡើងដោយអាជ្ញាធរផែនទីជាតិ។ តើផែនទីនេះនៅថ្មីៗប៉ុណ្ណា? តើផលិតផល Remote sensing ថ្មីប៉ុណ្ណាដែលបានផលិត? (ព័ត៌មាននេះគួរតែមាននៅលើក្រដាសឋានលេខាផលិតដោយអាជ្ញាធរនេះ។) ចូរចំណាំថាតើផលិតផលទាំងនេះអាចប្រើប្រាស់ដើម្បីធ្វើជាផែនទីមូលដ្ឋានសម្រាប់ផែនការបែងចែកតំបន់។<br>***ចូរកំណត់ផែនការដែលមានស្រាប់គ្របដណ្តប់គ្រប់ផ្នែកទាំងអស់ ឬផ្នែកខ្លះរួមមាន:*** |

| ប្រធានបទ/សាច់រឿង (themes) /ផ្នែក | ផ្នែកដែលត្រូវពិនិត្យ និងរួមបញ្ចូល |
|---|---|
| | • ផែនការអភិវឌ្ឍន៍រូបវ័ន្តចម្រុះ ផែនការតំបន់ទីក្រុង និងផែនការបែងចែកតំបន់<br>• ផែនការគ្រប់គ្រងបរិស្ថាន ផែនការតំបន់អភិរក្ស<br>• ផែនការគ្រប់គ្រងធនធាន ដូចជាផែនការគ្រប់គ្រងផ្កាថ្ម ឬ ដើមកោងកាង<br>• ផែនទីទីជម្រក និងផែនទីប្រើប្រាស់ធនធាន<br>• ផែនការតាមផ្នែកដែលបានបង្ហាញនៅលើផែនទី (ឧ: ផែនការធ្វើផ្លូវគោក ផ្លូវដែក និងការអភិវឌ្ឍកំពង់ផែ)<br>• ផែនទីទីជម្រកដែលត្រូវចងក្រងសំរាប់ផែនទីតំបន់រសើប និងផែនការឆ្លើយតប<br>• ផែនការយថាភាព ជាពិសេសទាក់ទងទៅនឹងថាតើមុខសញ្ញាគ្រោះថ្នាក់នេះកើតឡើងនៅទីណាហើយថាតើហានិភ័យជាក់លាក់នេះមាននៅទីណា (ឧ: តំបន់ងាយរងគ្រោះដោយសារទឹកជំនន់)<br>គោលបំណងសម្រាប់ទស្សនៈទាននេះត្រូវតែកំណត់ចំណាំនូវទិន្នន័យបែងចែកតំបន់ដ៏មានតម្លៃដែលអាចប្រមូលបាន រឺប្រើប្រាស់បានយ៉ាងលឿន។ សូមមើលជាពិសេសលើផែនការការប្រើប្រាស់ដី-ផែនការអភិវឌ្ឍន៍រូបវ័ន្តដូចជា ផែនការតំបន់ទីក្រុងនិងអភិវឌ្ឍន៍ថ្នាក់តំបន់ ផែនការថ្នាក់ស្រុក ផែនការ ថ្នាក់ខេត្ត-ផែនការដែលបញ្ជាក់ថាតើកន្លែងណាដែលមានការអភិវឌ្ឍខុសៗគ្នា។ ចូរចំណាំនូវចំណុចសំខាន់ៗដូចខាងក្រោម :<br>• តើផែនការនេះស្របច្បាប់ រឺជាការផ្តល់ដំបូន្មាន? ប្រសិនបើស្របច្បាប់ តើភាពស្របច្បាប់នេះមានពេលកំណត់ទេ ហើយបើដូច្នោះតើវានៅតែស្របច្បាប់រឺ ហើយថាតើមានរយៈពេលប៉ុន្មាន ?<br>• តើផែនការមានអាយុកាលប៉ុន្មានហើយតើមានវិធានការថ្មីៗទេ? តើមាតិការបស់វានៅតែមានទំនាក់ទំនងគ្នារឺ?<br>• តើផែនការនេះគឺជាធាតុសំខាន់ក្នុងការអនុវត្ត និងការអនុម័តឬ? រឺក៏មានផែនការពិស្តារ |

| ប្រធានបទ/សាច់រឿង (themes) /ផ្នែក | ផ្នែកដែលត្រូវពិនិត្យ និងរួមបញ្ចូល |
|---|---|
| | បន្ថែមទៀតសំរាប់តំបន់តូចៗ ដែលជាធាតុសំខាន់ៗដើម្បីអនុម័តឬ? តើផែនការទាំងនេះនៅតែមានទេ?<br>• តើផែនការនេះគ្របដណ្តប់តំបន់ CSP ប៉ុណ្ណា? តើតំបន់ CSP គ្របដណ្តប់ដោយផែនការច្រើនប៉ុណ្ណាហើយ តើផែនការនេះនិយាយលំអិតដល់កម្រិតណា ?<br>• តើការបែងចែកតំបន់ត្រូវប្រើជាឧបករណ៍មួយដើម្បីជម្រុញ រឺដាក់បញ្ញត្តិលើការអភិវឌ្ឍឬ? តើផែនការនេះហួសពីការប្រើប្រាស់ដីដែលអនុញ្ញាតិឱ្យ ឬ ដើម្បីបូកបញ្ចូលបញ្ហានៃប្រភេទការអភិវឌ្ឍ បច្ចេកវិទ្យា ទំហំទីតាំង ភាពទទួលយកបាន បញ្ហាគ្រប់គ្រងហានិភ័យ និងមុខសញ្ញាគ្រោះថ្នាក់ សេវាកម្មដែលត្រូវផ្តល់ឱ្យ ។ល ។? តើផែនការកំណត់តំបន់ឆ្នេរ Set back កំពុងដាក់ឱ្យដំណើការឬ បើសិនដូចនេះ តើអ្វីជាគោលបំណង និងខ្លឹមសារសំខាន់របស់វា?<br>• តើទទួលបានផែនការនេះល្អប៉ុណ្ណា?ទោះបីជាយ៉ាងនៅមានបញ្ហាលើសមត្ថភាពក្នុងការប្រតិបត្តិ រឺការចូលរួមរបស់សារធារណៈជនក្នុងដំណើការបង្កើតវាឡើង ។<br>• តើមានប្រព័ន្ធត្រួតពិនិត្យការអនុវត្តផែនការ និងការប្រតិបត្តិឬទេ? តើមានសមត្ថភាពគ្រប់គ្រាន់ដើម្បីរក្សាការត្រួតពិនិត្យ និងមុខងារប្រតិបត្តិឬទេ?<br>ចម្លើយចំពោះសំនួរទាំងនេះនឹងផ្តល់គំនិតថាតើត្រូវធ្វើបច្ចុប្បន្នកម្មប៉ុណ្ណា ហើយថាតើប្រភេទឧបករណ៏ជាក់លាក់អ្វីទំនងជាអាចប្រតិបត្តិបានរឺអត់? សំនួរពាចុងក្រោយនឹងលើកឡើងពីបញ្ហាថាតើវិធានការការកសាងសមត្ថភាពអ្វីបន្ថែមទៀតនឹងត្រូវការដើម្បីធានាថាផែនការបែងចែកតំបន់អាចធ្វើបានតាមបំណង ។ |
| ការគ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់ និងហានិភ័យ និងបញ្ហាការប្រែប្រួល | ចូរពិនិត្យមើលផែនការគ្រប់គ្រងគ្រោះហានិភ័យដែលមាន ។ សំនួរដែលត្រូវពិនិត្យមើលជាមូលដ្ឋាននៅទីនេះគឺៈ តើមានផែនទីមុខសញ្ញាគ្រោះថ្នាក់ឬទេ? តើមានផែនការយថភាពណាមួយទេ? តើមានផែនការកាត់បន្ថយគ្រោះហានិភ័យណាមួយទេ? បើសិនមិនមានទេ ចូរចំណាំនូវការពិតទាំងនេះ ។ ***បើសិនណាមួយក្នុងចំណោមនេះពិតជាមានចូរពិនិត្យមើលព័ត៌មានបែងចែកតំបន់ដែល*** |

| ប្រធានបទ/សាច់រឿង (themes) /ផ្នែក | ផ្នែកដែលត្រូវពិនិត្យ និងរួមបញ្ចូល |
|---|---|
| អាកាសធាតុ | ***ពួកគេផ្តល់ឱ្យនូវៈ***<br>• មុខសញ្ញាគ្រោះថ្នាក់ដោយសារធម្មជាតិ និងដោយសារមនុស្ស (តើនៅកន្លែងណា និងតើអ្វីជាប្រភពនៃគ្រោះថ្នាក់នេះ)?<br>• តើលក្ខណៈអ្វី របស់របរអ្វី និងក្រុមមនុស្សណាដែលទទួលរងនូវគ្រោះថ្នាក់នេះ? (រួមមានទីជម្រក និង ប្រព័ន្ធអេកូស៊ីស្ទែម -ឧ. កន្លែងចិញ្ចឹមត្រីធម្មជាតិ ផ្កាថ្ម ផ្នូកខ្សាច់ តំបន់ដីសើម និងផ្សេងៗទៀត)<br>• តើមានពាក់ព័ន្ធនឹងហានិភ័យកំរិតណា?<br>• តើយើងគិតថាការប្រែប្រួលអាកាសធាតុមានឥទ្ធិពលពីមុខសញ្ញាគ្រោះថ្នាក់ដែលមានស្រាប់ដោយរបៀបណា និងស៊ីណារីយ៉ូហានិភ័យ ឬណែនាំប្រភេទថ្មី?<br>• តើមានតំបន់ណាខ្លះ ឬក្រុមមនុស្សងាយរងគ្រោះជាងកន្លែងផ្សេងៗឬ ហើយបើសិនដូចនេះ តើតំបន់និងក្រុមទាំងនេះនៅកន្លែងណាហើយអ្វីជាហេតុផលនៃភាពងាយរងគ្រោះ? តើមានសកម្មភាពណាខ្លះដែលអាចជួយកាត់បន្ថយភាពងាយរងគ្រោះ និងបង្កើនភាពធន់ ?<br>• តើផែនទី និងផែនការថ្មីប៉ុណ្ណា?<br>• តើយើងកំពុងធ្វើអ្វីថ្មីៗនេះដើម្បីកាត់បន្ថយ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុ? តើយុទ្ធសាស្ត្រ និងគោលនយោបាយជាក់ស្តែងដែលមានស្រាប់នៅទីនោះដើម្បីកាត់បន្ថយ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុទេ?<br>ព័ត៌មាននៅទីនេះនិយាយពីផែនទីនៃមុខសញ្ញាគ្រោះថ្នាក់ និងហានិភ័យនិង លក្ខណៈដ៏មានតម្លៃនៃ (ធម្មជាតិព្រមទាំងវប្បធម៌ សង្គម ឬសេដ្ឋកិច្ច) និងកំណត់លក្ខណៈពិសេសក្នុងការកាត់បន្ថយហានិភ័យ និងភាពងាយរងគ្រោះ (ឧៈ ព្រៃកោងកាង)។ |
| ប្រជាធិបតេយ្យសេដ្ឋកិច្ចសង្គម | ជាធម្មតាមានចំនួនស្ថិតិប្រជាជន និងសេដ្ឋកិច្ចសង្គមច្រើន ហើយគោលបំណងនៃការពិនិត្យភ្លាមៗគឺមិនត្រូវវាយតម្លៃឱ្យបានទូលំទូលាយនូវស្ថិតិទាំងនេះទេ ប៉ុន្តែដើម្បីដកស្រង់ព័ត៌មានសំខាន់ៗ ដែល |

| ប្រធានបទ/សាច់រឿង (themes) /ផ្នែក | ផ្នែកដែលត្រូវពិនិត្យ និងរួមបញ្ចូល |
|---|---|
| ទិដ្ឋភាពសេដ្ឋ និង វប្បធម៌ | ការងារនេះមាននៅក្នុងកិច្ចការទី៣។ ចូរមើលដោយប្រុងប្រយត្ន័នូវព័ត៌មានស្តីពីៈ<br>• ទំហំនៃចំនួនប្រជាជន និងការផ្លាស់ប្តូររចនាសម្ព័ន្ធ -ទិន្នាការទៅរកពេលវេលាពី១០-២០ ឆ្នាំកន្លងទៅ<br>• ការផ្លាស់ប្តូរនូវរបាយប្រជាជនតាមតំបន់ឧៈកន្លែងពង្រីកលំនៅដ្ឋានដោយសារប្រជាជនច្រើន ការរុករានដីព្រៃក្នុងតំបន់ងាយរងផលប៉ះពាល់បរិស្ថាននិងតំបន់ដែលមានហានិភ័យខ្ពស់។<br>• រចនាសម្ព័ន្ធសេដ្ឋកិច្ចសង្គមនៃចំនួនប្រជាជននិងទិន្នាការជាពិសេសការបំលាស់ទីក្នុងចំណោមអ្នកមានចំណូលតិច<br>• ទិន្នន័យសេដ្ឋកិច្ច រចនាសម្ព័ន្ធវិស័យឧស្សាហកម្ម និង ពាណិជ្ជកម្ម និងនិន្នាការ<br>• ព័ត៌មានស្តីពីប្រភពថាមពល និងការប្រើប្រាស់ ជាពិសេសតាមវិស័យ និងតំបន់<br>• ការសិក្សាពីតម្លៃនៃធនធានធម្មជាតិ និងប្រព័ន្ធអេកូស៊ីស្ទែម<br>• សំរាប់គុណភាពជីវិតនិងលក្ខខណ្ឌផ្តល់នូវសេវាកម្ម ចូរពិនិត្យមើលទិន្នន័យនៃសមាមាត្រលំនៅដ្ឋានជាមួយ ទឹក អនាម័យ សេវាកម្មប្រមូលសំណល់ និងថាមពល។<br>• ក្នុងករណីមានសំភារៈត្រៀមសំរាប់គ្រោះមហន្តរាយ ចូរពិនិត្យមើលទិន្នន័យថ្មីៗស្តីពីក្រុមងាយរងគ្រោះជាពិសេសតាមតំបន់ ប៉ុន្តែត្រូវពិនិត្យនូវចំនួននិងកំរិតនៃភាពងាយរងគ្រោះនោះដែរ ។<br>• ចូរកត់ត្រានូវរាល់ព័ត៌មានស្តីពីទីតាំងនៃតម្លៃបុរាណវិទ្យា វប្បធម៌ និងតម្លៃប្រវត្តិសាស្ត្រធនធានធម្មជាតិ ជាពិសេសព័ត៌មាននេះត្រូវដាក់ក្នុងផែនទី និងពិពណ៌នា។ |
| រូបវន្ត លក្ខខណ្ឌធម្មជាតិ និង ប្រភេទលក្ខណៈ | ចំពោះផែនការបែងចែកតំបន់ដោយផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមវិញមានសារៈសំខាន់ក្នុងការប្រៀបធៀបសំភារៈដែលមានស្រាប់ និងប្រព័ន្ធអេកូស៊ីស្ទែមធាតុអាកាសនិង កំលាំងឌីណាម៉ិចដែលមានឥទ្ធិពលលើតំបន់ឆ្នេរផ្ទាល់។ ចូរមើលព័ត៌មានដែលបានប្រមូលស្តីពីៈ<br>• ភូគព្ភសាស្ត្រនិងចលនាតិចតូនិច ភូមិសាស្ត្រ លក្ខណៈរូបវន្តដូចជាផ្នុកខ្សាច់ របាំងខ្សាច់ |

| ប្រធានបទ/សាច់រឿង (themes) /ផ្នែក | ផ្នែកដែលត្រូវពិនិត្យ និងរួមបញ្ចូល |
|---|---|
| | ច្រាំងទន្លេ និងការពិពណ៌នាលក្ខណៈរូបវន្តនៃតំបន់ឆ្នេរ ។<br>• ទីតាំងនៃធនធានរូបវន្តមានសារៈសំខាន់ដល់សេដ្ឋកិច្ចដូចជា អាងបម្រុង រ៉ែ ប្រេងនិងហ្គាស ហើយនឹង សំភារៈសំណង់ (ថ្មធំៗ គ្រួស និងធនធានខ្សាច់ ។ល។)<br>• ទីជម្រក និងតំបន់អេកូ របាយធនធានជីវសាស្ត្រជាក់លាក់ និងការប្រើប្រាស់របស់ពួកគេ<br>• ឋានលេខាសមុទ្រ (វិធីវាស់ជំរៅសមុទ្រ) ចរន្តទឹកសមុទ្រ (ពិនិត្យតាមរដូវ) ទឹកជោរ ការហូរច្រោះនិងការកើនឡើង<br>• អាកាសធាតុនិងធាតុអាកាស រួមមាននិន្នាការនៃរបបភ្លៀងធ្លាក់ (តាមពេល ញឹកញាប់ និង ក្រាស ។ល ។) សីតុណ្ហភាព ខ្យល់ ខ្យល់ព្យុះនិងកំលាំងខ្យល់ព្យុះ និងលក្ខណៈស្រដៀងគ្នា<br>• ស្រដៀងគ្នាជាមួយការងារដែលបានធ្វើទាក់ទងនឹងមុខសញ្ញាគ្រោះថ្នាក់ ចូរពិនិត្យមើលមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ និងអ្នកកែសម្រួលធម្មជាតិនៃគ្រោះហានិភ័យទាំងនេះ ដូចជាការ ការពារជីវសាស្ត្រ ។<br>• គំរូដំណើរការមានស្រាប់ ជាពិសេសគំរូដែលផ្អែកលើទស្សនៈការឆ្លើតប ផលប៉ះពាល់ ស្ថានការ និងសំពាធ ប៉ុន្តែសំភារៈដែលបង្ហាញពីលំហូរថាមពល និង សំភារៈ ការសិក្សាពី EIA ដែលមានស្រាប់សំរាប់គម្រោងធំៗដែលរួមមានព័ត៌មាននៃដំណើការធម្មជាតិដ៏មានតម្លៃ ។<br>• គំរូតំបន់ឆ្នេរដោយមានផែនទីដែលពិពណ៌នាពីប្រភេទតំបន់ឆ្នេរ ។ ការចំណាត់ថ្នាក់តំបន់ឆ្នេរ និង/រឺកាចែកស្រទាប់ (Sediment cells) (ផ្នែកនៃតំបន់ឆ្នេរដែលមានការដឹកជញ្ជូនកករដូចគ្នានិងលក្ខណៈរូបសាស្ត្រស្រដៀងគ្នា ហើយប្រហែលជាដំណើរការនៅក្នុងកោសិកាមួយមិនធ្វើឱ្យប៉ះពាល់ដល់កោសិកាជិតគ្នាទេ) ។<br>• ទីកន្លែងដែលមានសារៈសំខាន់ផ្នែកសេដ្ឋកិច្ចដូចជា ចំណតនាវាធម្មជាតិ ដីកសិកម្មមានជីរជាតិ អាងទឹកសាប (ទឹកលើដី និងទឹកក្រោមដី) និង ទំនប់ទឹក ។ |

| ប្រធានបទ/សាច់រឿង (themes) /ផ្នែក | ផ្នែកដែលត្រូវពិនិត្យ និងរួមបញ្ចូល |
|---|---|
| | តំបន់ឆ្នេរគឺមានឱ្យណាមិុចខ្ពស់ និងមានសារៈសំខាន់ក្នុងរយៈពេលវែងដើម្បីចាប់យកនូវដំណើរការ និង កំលាំងពាក់ព័ន្ធដើម្បីអាចជូនដំណឹងពីការសំរេចចិត្តថាតើនៅពេលណាដូចម្តេច និងនៅទីកន្លែងណាដែលបទអន្តរាគមន៍គួរមានរឺមិនគួរមានក្នុងដំណើរការនេះ ហើយអាចកំណត់សកម្មភាពនៅលើដី ឬនៅតំបន់ឆ្នេរ និងនៅក្នុងសមុទ្រដែលនឹងមានការរំខានជាអវិជ្ជមានចំពោះដំណើរការនេះ ។ |

## ឧបសម្ព័ន្ធទី ៦: អនុវត្តន៍ការធ្វើផែនទីធនធានតំបន់ឆ្នេរដោយមានការចូលរួម

ផែនទីធនធានតំបន់ឆ្នេរគឺជាឧបករណ៍ដ៏សំខាន់មួយសំរាប់ CSP ។ ផែនទីនេះអាចធ្វើបានតាមរយៈការចូលរួមរបស់សហគមន៍ក្រោមគោលការណ៍ណែនាំនេះ ។ អត្ថប្រយោជន៍នៃការប្រើប្រាស់ចំពោះសមាជិកសហគមន៍តំបន់ឆ្នេរគឺថាពួកគេមានចំណេះដឹងមូលដ្ឋានច្រើន ជាពិសេសអ្នកនេសាទអាចផ្តល់ព័ត៌មានស្តីពីដៃសមុទ្រ និងព្រែកទឹកប្រៃ ។ ចូរប្រើនូវផែនទីដែលមានមាត្រដ្ឋាន១:២០០០០ឬធំជាងឬការថតរូបពីលើអាកាសដែលធ្វើឱ្យមានការកំណត់ងាយស្រួលនូវលក្ខណៈរូបវន្តទាំងនេះ ។

***ជំហានទី១:*** ចូរធ្វើការជាមួយនឹងសហគមន៍ដើម្បីកំណត់ប្រភេទទីជម្រកសំខាន់ៗក្នុងតំបន់នេះ ។ តារាងនេះមើលទៅដូចតារាងក្នុងប្រអប់ហើយប្រភេទនីមួយៗគួរដាក់ពណ៌ ។

**ប្រភេទទីលំនៅតំបន់ឆ្នេរគំរូ**

- តំបន់ឆ្នេរ
- វាលភក់
- ស្មៅសមុទ្រ
- ព្រៃកោងកាង
- ច្រាំងសមុទ្រ
- ផ្កាថ្ម
- ជួរថ្មច្រាំងសមុទ្រ
- ទំនាបជិតច្រាំង, វាលភក់
- ត្រពាំងទឹកក្បែរមាត់សមុទ្រ

***ជំហានទី២:*** ចូរបង្កើតតារាងជាមួយដោយមានគុឡោនសម្រាប់ប្រភេទទីជម្រកនីមួយៗដែលបាន កំណត់ និង នៅចំហៀងខាងឆ្វេងដៃ ដាក់ឈ្មោះថា "លក្ខខណ្ឌ" នៅខាងក្រោមកូឡោន ឆ្វេងដៃនៃជួរដេក មានសរសេរ "***ល្អណាស់***" - "***ល្អ***" - "***ល្មម***" - "***ខ្សោយ***" ។ ក្រោយមក ពិពណ៌នាលក្ខណៈដើម្បីវាយតម្លៃប្រភេទទីជម្រកនីមួយៗយោងតាមជំហរនីមួយៗ ។ មានឧទាហរណ៍នៅទំព័របន្ទាប់និយាយពីប្រទេសហ្វីលីពីន ។

***ជំហានទី៣:*** ដោយប្រើលក្ខណៈទាំងនេះ និងដោយធ្វើការជាមួយសហគមន៍ ចូរកំណត់ធនធានជាក់លាក់នៃទីជម្រកនីមួយៗតាមប្រភេទ និងឈ្មោះ ។ កំណត់បញ្ហាពិសេសទាក់ទងនឹងលក្ខខណ្ឌ ឬការគ្រប់គ្រងនៃប្រភពនេះ ។ ក្នុងតារាងចង្អុលបង្ហាញនូវលក្ខខណ្ឌរួមនៃតំបន់ដែលកំណត់លើផែនទី ។

***ជំហានទី៤:*** បង្កើតបន្ទាត់កាត់ទទឹងពីចំហៀងខាងដីឆ្ពោះទៅសមុទ្រ និង ចូរបង្ហាញនូវលក្ខណៈរួម ប្រភេទ និងការប្រើប្រាស់ធនធានតាមបណ្តោយប្រតិចារឹតនេះ ។ សូមមើលឧទាហរណ៍នៅខាងស្តាំ ហើយផែនទីខាងក្រោមការចង្អុលបង្ហាញពីទីកន្លែងនៃទីជម្រកដោយមានដាក់ពណ៌ ប្រភេទនៃធនធានដោយនិមិត្តសញ្ញា ដោយប្រើប្រាស់និមិត្តសញ្ញាផ្សេងៗគ្នា ព្រមទាំងបញ្ហាដោយប្រើនិមិត្តសញ្ញាសំរាប់តំបន់នីមួយៗ ។

| CONDITION | BEACH | SEAGRASS | CORAL REEF | MANGROVE |
|---|---|---|---|---|
| Excellent | Undisturbed wide beach | 76-100% Live seagrass, no sediment | 76-100% Live Coral Cover | 76-100% No cutting or disturbance |
| Good | Undisturbed narrow beach | 51-75% Suspended sediments only | 51-75% Live Coral Cover | 51-75% Cutting for firewood, poles |
| Fair | Some pollution, erosion, fallen trees | 26-50% Seasonal sedimentation on bottom | 26-50% Live Coral Cover | 26-50% Fishponds |
| Poor/Low | Heavy pollution, seawalls, major erosion, modification | 0-25% Permanent sedimentation on bottom | 0-25% Live Coral Cover | 0-25% Land or trees removed, reclamation |

***វាយតម្លៃប្រភេទសំរាប់ប្រភពទីលំនៅ:*** Yambao, A.C. et al. 2001. *Coastal environmental profile of Negros Oriental, Philippines. Pg 11.*

***ជំហានទី ៥:*** ដោយបន្ថែមលើតារាង និងផែនទីនូវការពិពណ៌នា ជាលាយលាក់អក្សរនៃតំបន់ និងសហគមន៍ដោយរួមបញ្ចូលទិន្នន័យទំហំចំនួនប្រជាជន ទីតាំងរូបវន្តរបស់សហគមន៍សកម្មភាពរួមនៅក្នុងសហគមន៍។ ប្រភេទលំហាត់នេះមិនចាំបាច់បញ្ចប់វានោះទេ ហើយចាំបាច់ត្រូវតែមានអ្នកជំនាញអេកូស៊ីស្ទែម និងបរិស្ថានដើម្បីជួយក្នុងដំណើរការនេះព្រមទាំងជាអ្នកសម្របសំរួលដូចជាក្នុងសិក្ខាសាលានៅក្នុងសហគមន៍នូវព័ត៌មាន និងការបណ្តុះបណ្តាលមូលដ្ឋានត្រូវតែមាន។ ទោះបីជាយ៉ាងណាក៏ដោយ វាជាវិធីសាស្រ្តមួយដែលមិនត្រូវការឧបករណ៍ថ្លៃៗនោះទេ ប៉ុន្តែផ្តល់នូវព័ត៌មានមានប្រយោជន៍ច្រើន និងបង្កើននូវភាពជាម្ចាស់របស់សហគមន៍ក្នុងដំណើការ CSP នេះ។ វាអាចប្រើជាជំហានដំបូងឆ្ពោះទៅរកការគ្រប់គ្រងផ្អែកលើសហគមន៍នៃធនធានបរិស្ថានក្នុងស្រុក។ ព័ត៌មានលំអិតស្តីពីការអនុវត្តគំរូបរិស្ថានតំបន់ឆ្នេររបស់ Negros Oriental មាននៅក្នុងគេហទំព័រ: http://www.oneocean.org/download/20010825/negros_profile/intro.pdf.




Coastal Resource Map of Bais, Philippines
*Source: Yambao et al. 2001. Coastal Environmental Profile of Negros Orientale, Philippines, p 21.*

## ឧបសម្ព័ន្ធទី ៧: ការវិភាគដំណើរការរៀបចំតំបន់ឆ្នេរ ការបែងចែកតំបន់ឆ្នេរទៅជា ' ក្រុមតូចៗ'

ការធ្វើផែនការបែងចែកតំបន់ឆ្នេរ និងសមុទ្រចម្រុះត្រូវមានការយល់ជាមូលដ្ឋាននូវដំណើរការនេះ ដែលសង្កត់ធ្ងន់លើអន្តរកម្មរវាងអាណាចក្រពីរ ព្រមទាំងរវាងកត្តារូបវន្ត ជីវៈសាស្ត្រ និង សេដ្ឋកិច្ចសង្គម។ ដោយផ្អែកលើភាពស្មុគ្រស្មាញ និងទំហំនៃតំបន់ CSP ការយល់ដឹងជាមូលដ្ឋាននេះអាចចំណាយពេលច្រើនខែ ឬក៏ច្រើនឆ្នាំដើម្បីសំរេចវា។ អភិក្រមដែលបានរៀបរាប់នេះអាចធ្វើបាននៅកំរិតខុសៗគ្នា ហើយអាចជាការសិក្សាមួយក្នុងចំណោមការសិក្សាសំខាន់ៗ ឬវាអាចធ្វើជាសកម្មភាពពិសេសនៅក្នុងកម្មវិធីអភិវឌ្ឍន៍ដូចជា មូលដ្ឋានវដ្តផែនការបែងចែកតំបន់ប្រើប្រាស់អនាគត។ គេស្វែងរកឱ្យមានការបង្កើតនូវការយល់ដឹងនៃការផ្លាស់ប្តូរជម្រុញដោយកម្លាំងក្នុងប្រព័ន្ធនេះដើម្បីឱ្យរៀបចំអន្តរាគមន៍សមស្របដែលគាំទ្រ និងលើកកម្ពស់ ការផ្លាស់ជាវិជ្ជមាននិងដោយចីរភាពជាមួយគ្នានោះដែរដោយជៀសវាង ឬកាត់បន្ថយដំណើរបំផ្លិចបំផ្លាញ និង ដែលធ្វើឱ្យវិនាសអន្តរាយ។ វិធីសាស្ត្រមួយក្នុងចំណោមវិធីសាស្ត្រសាមញ្ញបំផុតគឺត្រូវបែងចែកនូវតំបន់ឆ្នេរទៅជាក្រុមកំណរ (Sediment) និង រូបសាស្ត្រតូចៗដែលនេះជាការលាតសន្ធឹងរបស់ឆ្នេរដែលមានការដឹកជញ្ជូនកករ និង លក្ខណៈរូបសាស្ត្រស្រដៀងគ្នា។

**ប្រភេទច្រាំសមុទ្រពិសេសៈ**

- ឆ្នេរខ្សាច់
- ឆ្នេរគ្រួស
- ច្រាំងថ្មរឹង
- ថ្មរឹង
- ទំនប់ភក់ (Mudbank)
- ស្រែអំបិល
- ដៃសមុទ្រ
- ព្រៃកោងកាង
- ព្រៃ Sago Palm
- ផ្ទាំងថ្ម រឹរបាំងសមុទ្រសិប្បនិម្មិត
- ឆ្នេរខ្សាច់ការពារដោយផ្លូកខ្សាច់ជាមួយផ្កាថ្ម









***ចំណាត់ថ្នាក់តំបន់ឆ្នេរ និងការបែងចែកចំណែកមាត់សមុទ្រតូចៗនៅក្នុងប្រទេសកម្ពុជា***

គេអាចចាប់ផ្តើមដោយបែងចែកចំណាក់ថ្នាក់ជួរច្រាំងសមុទ្រដោយផ្ទាល់ដូចដែលបានធ្វើចំពោះការវិភាគភាពរសើបនៃការកំពប់ប្រេង។ ជាក់ស្តែង នេះគឺស្រដៀងនឹងផែនទីទីជម្រកហើយចំពោះតំបន់ច្រាំងសមុទ្រខ្លះចាត់ទុកថាជាដើមកោងកាង។ បន្ទាប់មកជំហានទី២ គឺត្រូវកំណត់នូវកំរិតនៃការហូរច្រោះ ឬការរីកធំឡើងនៅតាមបណ្តោយឆ្នេរ។ វិស្វករតំបន់ឆ្នេរអាចណែនាំនូវការគូសបន្ទាត់សមស្របនៃកោសិកាតំបន់ឆ្នេរ។ ជាថ្នូរវិញ ការធ្វើបែបនេះជាមូលដ្ឋានសម្រាប់បទអន្តរាគមន៍ការគ្រប់គ្រងជាក់លាក់ និងលំអិត។ ការបញ្ចូលគ្នានូវរូបសាស្ត្រតូចៗ និងកោសិកាកំណរជាមួយប្រភេទទីជម្រកមិនគ្រាន់តែគាំទ្រការសំរេចចិត្តពីប្រភេទវិធានការត្រួតពិនិត្យការហូរច្រោះដែលមានឱ្យបានសមរម្យ ប៉ុន្តែថែមទាំងអាចចូលរួមចំណែកតភ្ជាប់ការគ្រប់គ្រងអេកូស៊ីស្ទែមជាមួយនឹង ការការពារសមុទ្រ ការអភិរក្ស និងកិច្ចការពារជីវៈចម្រុះទៀតផង។ ឧទាហរណ៍នៃការចំណាត់ថ្នាក់តំបន់ឆ្នេរមានបញ្ជាក់នូវទំព័រមុនរួចហើយ។[1] ចំណុចខ្សោយនៃវិធីសាស្ត្រនេះគឺថាវានៅមានកម្រិតច្រើនដោយការបែងចែកតំបន់នេះវានៅជាប់តែតំបន់ឆ្នេរដោយមិនប៉ះពាល់ដល់ជម្រកសមុទ្រ និងតំបន់ដីគោកឆ្ងាយនោះទេ។

ជាក់ស្តែង វាមិនបានបញ្ចូលព្រៃកោងកាងទាំងមូលទេ ដូច្នេះវាមិនបានដោះស្រាយនូវវិបត្តិតំបន់ឆ្នេរទាំងមូលនោះទេដែលមានចម្ងាយរាប់រយម៉ែត្រពីតំបន់ឆ្នេរនោះ។ វិធីសាស្ត្រដែលមានលក្ខណៈទំនើបប៉ុន្តែមានប្រយោជន៍នោះគឺត្រូវបង្កើតគំរូតំបន់ឆ្នេរហើយប្រការនេះមិនត្រឹមតែផ្តល់ព័ត៌មានការបែងចែកតំបន់នោះទេថែមទាំងបញ្ជាក់នូវសមាសភាព និងដំណើរការសំខាន់ៗទៀតផង។ ការធ្វើបែបនេះមានតម្លៃណាស់សូម្បីតែផ្នែកស្មារតីដើម្បីធ្វើតេស្តពីស៊ីណារីយោនៅកំរិតរួមមុនពេលពិនិត្យឱ្យកាន់តែលំអិតនោះ។

គំរូនេះគឺផ្អែកលើគំនិតដែលប្រព័ន្ធឌីណាមិចនៅមាន និងនៅពេលវេលាពិសេសណាមួយនោះ វាស្ថិតក្នុងស្ថានភាពប្រាកដប្រជាមួយ។ នៅពេលមានការដាក់សំពាធផ្សេងៗ ការផ្លាស់ប្តូរនឹងកើតឡើងក្នុងស្ថានភាពជាប្រពន្ធ័។ ការផ្លាស់ប្តូរស្ថានភាពនេះនឹងមានផលប៉ះពាល់ដែលនឹងនាំទៅរកវិធានការឆ្លើយតប។ វិធានការឆ្លើយតប ឬការប្រតិកម្មអាចនាំឱ្យមានសម្ពាធខ្លាំងឡើង ឬចាត់វិធានការដើម្បីកាត់បន្ថយ ឬបំបាត់ចោលនូវសំពាធដើម្បីស្តារឡើងវិញឱ្យដូចស្ថានភាពដើម។ ដោយសារតែជំហានសំខាន់ទាំងនេះមានក្នុងដំណើការនេះ ជាធម្មតាគំរូនេះនិយាយសំដៅទៅលើគំរូ P-S-I-R ។




ក្នុងបរិបទនេះ**ផែនការបែងចែកតំបន់**គឺជា ឧបករណ៍មួយស្ថិតក្នុងសមាសភាព "***វិធានការឆ្លើយតប*** -response "។ ដោយការសិក្សាពីសម្ពោធដែលត្រូវប្រើក្នុងប្រព័ន្ធនេះ ចូរចំណាំថាការផ្លាស់ប្តូរស្ថានភាពនៃប្រព័ន្ធនេះ និងផលប៉ះពាល់នៃការផ្លាស់ប្តូរនេះមាន នោះអាជ្ញាធរអាចធ្វើតារាងឆ្លើយតបមួយសមាសភាពមួយរបស់វាគឺផែនការបែងចែកតំបន់ ឬសមាសភាពរបស់វា។ ការវាយតម្លៃផលប៉ះពាល់បរិស្ថានជាយុទ្ធសាស្ត្រ និងការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាននៃគម្រោងនីមួយៗជាក់ស្តែងអនុវត្តន៍នូវគំរូនេះនៅពេលដែលពួកគេស្វែងរកដើម្បីកំណត់នូវផលប៉ះពាល់ឱ្យកាន់តែទូលំទូលាយ ឬកម្មវិធី ឬគម្រោង ។

គំរូនេះសំរាប់តំបន់ឆ្នេរនឹងបង្កើតបានជាដ្យាក្រាមលំហូរសំភារៈ និង ថាមពលពាក់ព័ន្ធជាច្រើនដែលដំបូងឆ្លុះបញ្ចាំងនូវទំនាក់ទំនងរវាងសមាសភាពខុសៗគ្នាក្នុងប្រព័ន្ធនេះ និង ទី២បង្ហាញពីផលប៉ះពាល់បណ្តាលមកពីសម្ពាធពិសេសមួយដែលអាចជាលទ្ធផលនៃការឆ្លើយតបដំបូងចំពោះផលប៉ះពាល់ដំបូងដែរ។ ជាឧទាហរណ៍ សម្ពាធសង្គមសេដ្ឋកិច្ចនៃប្រភេទផ្សេងៗគ្នា (ជំរុញឱ្យមានការលើកកម្ពស់សេដ្ឋកិច្ច តម្រូវការដីច្រើនដើម្បីតាំងលំនៅដ្ឋានតំរូវការប្រេងឥន្ធនះ) អាចនាំឱ្យមានការកាប់បំផ្លាញតំបន់ព្រៃកោងកាងដោយផ្នែកមួយសម្រាប់ការតាំងលំនៅដ្ឋាន ផ្នែកមួយសំរាប់សំណង់ និងអុសធ្យូង និងផ្នែកមួយទៀតសម្រាប់ធ្វើស្រែបង្គា។ ស្ថានភាពនៃការផ្លាស់ប្តូរប្រព័ន្ធអេកូស៊ីស្ទែម ជាពិសេស តុល្យការរវាងទំហំព្រៃកោងកាង និង មុខងាររបស់វាអាចជួយចាប់យកករដី ការពារព្យុះខ្លាំង និងខ្យល់ខ្លាំង កន្លែងបន្តពូជសំរាប់មច្ឆា និងសត្វសមុទ្រ។ល។ ផលប៉ះពាល់នេះមួយផ្នែកវិជ្ជមានផ្តល់នូវហិរញ្ញវត្ថុដល់អ្នកធ្វើស្រែបង្គាប៉ុន្តែវាបានបំផ្លាញនូវធនធានមួយចំនួនបើគិតតាមរបៀបផ្សេងទៀត

ទាក់ទងនឹងការរស់នៅរបស់ផ្កាថ្ម និងវាលស្មៅសមុទ្រ ផលិតផលនេសាទ (និយាយពាក់ព័ន្ធនឹងអ្នកនេសាទ និងអ្នកផលិត និងអ្នកប្រើប្រាស់ត្រី ការហូរច្រោះតំបន់ឆ្នេរ ការកើនឡើងជីវជាតិសមុទ្រ និងការកើនឡើងនូវអង់ទីបីយូទិចពីកសិដ្ឋានបង្គា ដែលនាំឱ្យមានផលវិបាកធ្ងន់ធ្ងរឡើង)។ ហើយផលប៉ះពាល់ទាំងនេះនាំឱ្យមានវិធានការឆ្លើយតបជាក់លាក់ ជាលក្ខណៈបុគ្គល សហគមន៍ រឺ ថ្នាក់ជាតិ។ ដូច្នេះទាមទារអោយមានការបង្កើតគំរូហ្គត់ចត់មួយដើម្បីគណនាចំនួនសម្ពាធនេះ ការផ្លាស់ប្តូរស្ថានភាពផលប៉ះពាល់ ។ល ។ ដំណើរការគណនាចំនួននេះត្រូវកំណត់នូវតម្លៃស្តង់ដាមួយចំនួន (ជាឧទាហរណ៍ ចំនួននៃការដកហូតអុស-ធ្យូងក្នុងព្រៃកោងកាងមួយហិចតា)។ ក្រោយមក ទាំងនេះអាចប្រើប្រាស់ការសាកល្បងស៊ីណារីយោឆ្លើយតបផ្សេងគ្នា ដើម្បីឱ្យមានការវិភាគតាមបែបប្រៀបធៀបនូវផលប៉ះពាល់ដ៏មានសក្តានុពលនៃគោលនយោបាយ បទបញ្ញត្តិ ផែនការ កម្មវិធី និងគម្រោងថ្មីៗ ។

## ឧបសម្ព័ន្ធទី ៨: ការវាយតម្លៃសេវាកម្មប្រព័ន្ធអេកូស៊ីស្ទែម

### *សេវាកម្ម និងមុខងារប្រព័ន្ធអេកូស៊ីស្ទែម*

ប្រព័ន្ធអេកូស៊ីស្ទែមធម្មជាតិមានសារៈសំខាន់ណាស់សំរាប់ការរស់នៅរបស់យើង និងផ្តល់ឱ្យយើងនូវសេវាកម្ម និងមុខងារដែលត្រូវបានបំផ្លាញដោយសារការប្រើធនធានខុសនិងការបំពុលបរិស្ថាន។ មនុស្សជាតិទទួលអត្ថប្រយោជន៍ពីធនធាន និងដំណើរការមួយចំនួនដែលត្រូវផ្គត់ផ្គង់ដោយប្រព័ន្ធអេកូស៊ីស្ទែមធម្មជាតិ។ តាមបែបសមូហកម្ម អត្ថប្រយោជន៍ទាំងនេះគឺសេវាកម្មប្រព័ន្ធអេកូស៊ីស្ទែម ហើយរួមមានផលិតផលដូចជា ទឹកពិសារស្អាត និងដំណើរការជាច្រើនដូចជា ការធ្វើកំប៉ុស្តិ៍ពីសំណល់។ ចំណែកឯអ្នកវិទ្យាសាស្ត្រ និងអ្នកបរិស្ថានបានពិភាក្សាគ្នាពីសេវាកម្ម អេកូស៊ីស្ទែមអស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ ហើយសេវាកម្មទាំងនេះមានប្រជាប្រិយភាពណាស់ និងខ្លឹមសាររបស់វាទទួលស្គាល់ដោយអង្គការសហប្រជាជាតិឆ្នាំ២០០៤ ផ្អែកលើការវាយតម្លៃអេកូស៊ីស្ទែមសហស្សវត្សរ៍ដែលជាការសិក្សារយៈពេល៤ឆ្នាំដែលមានអ្នកវិទ្យាសាស្ត្រចូលរួមជាង ១៣០០ នាក់ លើពិភពលោក។ ក្រុមអ្នកជំនាញទាំងនេះបានចែកសេវាកម្មប្រព័ន្ធអេកូស៊ីស្ទែមជា៤ ផ្នែកធំៗហើយបញ្ជីឈ្មោះខាងក្រោមនេះតំណាងឱ្យសំណាកនីមួយៗ[2]:

***<u>សេវាកម្មដែលផ្តល់ឱ្យរួមមាន :</u>***

- អាហារ (រួមមាន អាហារសមុទ្រ និងល្បែងកំសាន្ត) ដំណាំ អាហារសត្វ និងគ្រឿងទេស
- ទឹកបរិសុទ្ធ
- ឱសថកម្ម ជីវគីមី និងផលិតផលឧស្សាហកម្ម
- ធនធានសេណេទិច

- ថាមពល (ថាមពលវារីអគ្គិសនី ជីវ:ឧស្ម័ន)
- សរសៃអំបោះ

***សេវាកម្មនិយតកម្ម :***

- ការស្រូបយកកាបូន និងលំនឹងអាកាសធាតុ
- ការបន្សាបវិស: និងធ្វើកំប៉ុស្តិ៍
- បទបញ្ជាពីធនធានទឹក
- បន្សុតភាពទឹក និងខ្យល់
- ការរាយបាយគ្រាប់ដំណាំ
- ការត្រួតពិនិត្យជំងឺ និងថ្នាំសំលាប់សត្វល្អិត

***សេវាកម្មវប្បធម៌ :***

- ការទទួនទានផ្នែកវប្បធម៌ បញ្ញវន្ត និងសតិអារម្មណ៏
- កន្លែងលំហែកំសាន្ត (រួមទាំង អេកូទេសចរណ៏)
- សោភ័ណ្ឌភាព
- ការទាក់ទាញអារម្មណ៏
- ការអប់រំ
- របកគំហើញវិទ្យាសាស្រ្ត
- ជំនឿតំបន់
- បីតិកភណ្ឌវប្បធម៌

***សេវាកម្មគាំពារ :***

- ការចែកចាយ និងវដ្តចំណីអាហារ
- ការចែកចាយនូវគ្រាប់ពូជ
- ការបង្កើតដី
- ផលិតកម្មដំបូង
- វដ្តនៃទឹក
- ការផ្តល់ទីជម្រក

**តារាងទី ១: ប្រភេទនៃសេវាកម្មប្រព័ន្ធអេកូស៊ីស្ទែម**[3]

| **ប្រភេទនៃសេវាកម្មប្រព័ន្ធអេកូស៊ីស្ទែម** | | **ការពិពណ៌នា** |
|---|---|---|
| សេវាកម្មដែលផ្តល់ឱ្យ | អាហារ និងសសៃអំបោះ | ប្រភេទនេះរួមមានផលិតផលអាហារជាច្រើនមានប្រភពពីរុក្ខជាតិ សត្វ និងមីក្រុប ព្រមទាំងសំភារៈដូចជា ឈើ ដើមក្រចៅ ដើមឆ្នៃ អំបោះសូត្រ និងផលិតផលដ៏ទៃទៀតបានពីប្រព័ន្ធអេកូស៊ីស្ទែម |
| | ឥន្ធនៈ | ឈើ លាមកសត្វ និងសំភារៈជីវៈសាស្ត្រដ៏ទៃទៀតដែលជាប្រភពនៃថាមពល |
| | ធនធានសេណេទិច | រួមមានៈ កោសិកាបន្តពូជ និងព័ត៌មានសេណេទិចប្រើសំរាប់ការបង្កាត់ពូជសត្វ និងរុក្ខជាតិ និងបច្ចេកវិជ្ជាជីវៈសាស្ត្រ |
| | ជីវៈគីមី ឱសថធម្មជាតិ និងឱសថកម្ម | ថ្នាំពេទ្យជាច្រើន ជីវឃាត អាហារបំប៉នដូចជា រុក្ខជាតិសមុទ្រ និងសំភារៈជីវៈសាស្ត្រមានប្រភពពីប្រព័ន្ធអេកូស៊ីស្ទែម |
| | ធនធានគ្រឿងតុបតែង | ផលិតផលសត្វព្រៃដូចជា ស្បែក និងសំបក និងផ្កាប្រើជាគ្រឿងតុបតែង ទោះបីជាប្រភេទទាំងនេះមានតម្លៃផ្អែកវប្បធមិក៏ដោយ |
| | ទឹកសាប | ទឹកសាបគឺជាឧទាហរណ៍មួយផ្សេងទៀតនៃការតភ្ជាប់រវាងប្រភេទទាំងនោះ-ក្នុងករណីនេះគឺរវាងសេវាកម្មដែលផ្តល់ឱ្យ និងសេវាកម្មបញ្ញត្តិកម្ម ។ |
| សេវាកម្មធ្វើឱ្យមានលំនឹង | ការរក្សាគុណភាពខ្យល់ | ប្រព័ន្ធអេកូស៊ីស្ទែមផ្តល់នូវទាំងសារធាតុគីមីដល់បរិយាកាស និងស្រូបយកសារធាតុគីមីពីបរិយាកាសដោយមានឥទ្ធិពលច្រើនលើនៃគុណភាពខ្យល់ |

| | | |
|---|---|---|
| | លំនឹងអាកាសធាតុ | ប្រព័ន្ធអេកូស៊ីស្ទែមមានឥទ្ធិពលលើអាកាសធាតុទាំងក្នុងតំបន់ និងពិភពលោកទាំងមូល ។ ឧទាហរណ៍នៅថ្នាក់តំបន់ ការប្រែប្រួលគំរបដីអាចមានឥទ្ធិពលទាំងសីតុណ្ហភាព និងសំណើម ។ នៅលើពិភពលោកវិញ ប្រព័ន្ធអេកូស៊ីស្ទែមដើរតួសំខាន់ក្នុងអាកាសធាតុដោយស្រូបយក និងបញ្ចេញឧស្ម័នផ្ទះកញ្ចក់ |
| | របបទឹក | ពេល និងទំហំ នៃការហូរច្រោះ ទឹកជំនន់ និងការស្រូបយកទឹកក្រោមដី អាចទទួលឥទ្ធិពលខ្លាំងក្នុងការប្រែប្រួលគម្របដី រួមមានការប្រែប្រួលដែលកែប្រែនូវអាងស្តុកទឹក ដ៏មានសក្តានុពលនៃប្រព័ន្ធនេះ ដូចជាការកែប្រែតំបន់ដីសើម ឬផ្លាស់ប្តូរតំបន់ព្រៃឈើទៅជាតំបន់ចំការបន្លែ រឺទៅជាតំបន់ទីក្រុង |
| | ការត្រួតពិនិត្យសំណឹក ការហូរច្រោះ | គម្របបន្លែដើរតួយ៉ាងសំខាន់ក្នុងការការពារដី និងទប់ស្កាត់ការបាក់ដី |
| | បន្សុតភាពទឹក និង ប្រព្រឹត្តិកម្មសំណល់ | ប្រព័ន្ធអេកូស៊ីស្ទែមអាចជាប្រភពនៃភាពមិនសុទ្ធនៅក្នុងទឹកសាប ប៉ុន្តែអាចជួយចម្រោះ និងបំលែងឱ្យទៅជាកំប៉ុស្តិ៍សំណល់សរីរាង្គ ដែលមាននៅក្នុងទឹកទន្លេ និង អេកូស៊ីស្ទែមតំបន់ឆ្នេរ និងសមុទ្រ |
| | លំនឹងនៃជំងឺ | ការប្រែប្រួលក្នុងប្រព័ន្ធអេកូស៊ីស្ទែមអាចមានការផ្លាស់ប្តូរផ្ទាល់នូវធាតុបង្កជម្ងឺរបស់មនុស្សដូចជា ជម្ងឺ អាសន្នរោគ និងអាចផ្លាស់ប្តូរនូវមេចម្លងជម្ងឺឆ្លងផ្សេងៗដូចជា មូសជាដើម |
| | ការត្រួតពិនិត្យជីវសាស្ត្រ | ការប្រែប្រួលប្រព័ន្ធអេកូស៊ីស្ទែមប៉ះពាល់លើការរីករាលដាលនៃដំណាំនិងសត្វចញ្ចឹមនិងជម្ងឺផ្សេងៗ |
| | ការរោយលំអង | ការប្រែប្រួលប្រព័ន្ធអេកូស៊ីស្ទែមប៉ះពាល់លើរបាយ ភាពសំបូរបែប និង ប្រសិទ្ធភាពនៃលំអង |

| | | |
|---|---|---|
| | ប្រព័ន្ធការពារខ្យល់ព្យុះ | វត្តមាននៃប្រព័ន្ធអេកូតំបន់ឆ្នេរដូចជាព្រៃកោងកាង និង ផ្កាថ្មអាចកាត់បន្ថយវិនាដកម្មដោយសារព្យុះសង្ឃរា និង រលកយក្ស |
| សេវាកម្មវប្បធម៌ | នានាភាពនៃវប្បធម៌ | នានាភាពនៃប្រព័ន្ធអេកូគឺជាផ្នែកមួយដែលមានឥទ្ធិពល លើនានាភាពនៃវប្បធម៌ចំរុះ |
| | តម្លៃផ្លូវស្មារតី និងជំនឿសាសនា | មានសាសនាជាច្រើនភ្ជាប់ទំនាក់ទំនងទៅនឹងតម្លៃផ្លូវចិត្ត និងជំនឿទៅនឹងប្រព័ន្ធអេកូស៊ីស្ទែម ឬសមាសធាតុរបស់ពួកគេ |
| | ប្រព័ន្ធចំណេះដឹង (ប្រពៃណីឬផ្លូវការ) | ប្រព័ន្ធអេកូស៊ីស្ទែមមានឥទ្ធិពលលើប្រភេទប្រព័ន្ធចំណេះដឹងបង្កើតឡើងដោយមានវប្បធម៌ខុសៗគ្នា |
| | តម្លៃផ្នែកអប់រំ | ប្រព័ន្ធអេកូស៊ីស្ទែម និងសមាសធាតុ និងដំណើរការរបស់ពួកវាផ្តល់នូវមូលដ្ឋាន សម្រាប់ការអប់រំទាំងក្នុងផ្លូវការ និងក្រៅផ្លូវការនៅក្នុងសង្គមជាច្រើន |
| | ការទូន្មាន | ប្រព័ន្ធអេកូស៊ីស្ទែមជាធនធានឱ្យដំបូន្មានល្អជាច្រើនសំរាប់វិស័យសិល្បះ ប្រពៃណី និមិត្តសញ្ញាជាតិ ស្ថាបត្យកម្ម និងការផ្សព្វផ្សាយ |
| | តម្លៃផ្នែកសោភ័ណ្ឌភាព | មនុស្សជាច្រើនបានមើលឃើញនូវភាពស្រស់ស្អាត រឺ តម្លៃសោភ័ណ្ឌភាពនូវទិដ្ឋភាពផ្សេងៗគ្នានៃប្រព័ន្ធអេកូស៊ីស្ទែម ដូចដែលបានបង្ហាញនៅក្នុងការគាំទ្រសម្រាប់សួនកំសាន្ត “ផ្នែកទេសភាព-Scenic Drives” និង ការជ្រើសរើសទីតាំងលំនៅដ្ឋាន |
| | ការភ្ជាប់ទំនាក់ទំនងសង្គម | ប្រព័ន្ធអេកូស៊ីស្ទែមមានឥទ្ធិពលលើប្រភេទនៃទំនាក់ទំនងសង្គមដែលត្រូវបង្កើតឡើងក្នុងផ្នែកវប្បធម៌ ។ ជាក់ស្តែង ការនេសាទខុសគ្នា កសិកម្ម និងការចិញ្ចឹមសត្វបែបពនេចរ ។ |

| | | |
|---|---|---|
| | ជំនឿទីកន្លែង (Sense of place) | មនុស្សជាច្រើនឱ្យតម្លៃលើ "***ជំនឿទីកន្លែង***" រួមជាមួយលក្ខណៈបរិស្ថានដែលគេទទួលស្គាល់ដោយរួមទាំងទិដ្ឋភាពប្រព័ន្ធអេកូស៊ីស្ទែម |
| | តម្លៃកេរ្តិ៍តំណែលវប្បធម៌ | សង្គមជាច្រើនឱ្យតម្លៃខ្ពស់លើការមើលថែទាំទាំងតំបន់ទេសភាពសំខាន់ៗ (តំបន់ទេសភាពវប្បធម៌) ទាំងប្រភេទសត្វដែលមានសារៈសំខាន់ផ្នែកវប្បធម៌ |
| | កន្លែងកំសាន្ត និង អេកូ-ទេសចរណ៍ | ជាធម្មតាមនុស្សជ្រើសរើសថាតើត្រូវចំណាយពេលកំសាន្តរបស់គេនៅកន្លែងណា ដោយពឹងផ្អែកជាពិសេសលើលក្ខណៈ ទេសភាពធម្មជាតិ ឬទេសភាពដែលគេបង្កើតឡើងនៅក្នុងតំបន់ពិសេស |
| សេវាកម្មជំនួយ | របាយវិវដ្តសារធាតុចិញ្ចឹម<br>ការបង្កើតទម្រង់ដី<br>របាយគ្រាប់ពូជ<br>ផលិតផលដំបូង<br>វដ្តទឹក<br>ការផ្តល់ឱ្យនូវទីជម្រក | សេវាកម្មជំនួយគឺជាសេវាកម្មទាំងឡាយណាដែលមានសារៈសំខាន់សំរាប់ផលិតផលសេវាកម្មប្រព័ន្ធអេកូស៊ីស្ទែមទាំងអស់។ ពួកគេខុសគ្នាពីសេវាកម្មផ្តល់ឱ្យ សេវាកម្មលំនឹង និងសេវាកម្មវប្បធម៌ដែលផលប៉ះពាល់របស់ពួកគេទៅលើមនុស្សគឺទាំងដោយផ្ទាល់ ឬមិនផ្ទាល់ឬកើតឡើងអស់រយៈពេលវែងផ្ទុយទៅវិញការប្រែប្រួលផ្សេងទៀតមានផលប៉ះពាល់ដោយផ្ទាល់ និងរយៈពេលខ្លីទៅលើមនុស្ស ។ |

សង្គមចាប់ផ្តើមទទួលស្គាល់ថាសេវាកម្មប្រព័ន្ធអេកូស៊ីស្ទែមមិនត្រឹមតែទទួលការគំរាមកំហែង និងមានកម្រិតនោះទេ ប៉ុន្តែថែមទាំងមានសម្ពោធដែលទាមទារឱ្យមានការប៉ះប៉ូវរវាងតម្រូវការរយៈពេលវែងនិងមធ្យមទៀតផង។ ដើម្បីជូនដំណឹងដល់អ្នកធ្វើសេចក្តីសម្រេចចិត្តពីតម្លៃសេដ្ឋកិច្ចគឺត្រូវរួមបញ្ចូលជាមួយសេវាកម្មប្រព័ន្ធអេកូស៊ីស្ទែម ហើយជាធម្មតាដោយផ្អែកលើតម្លៃនៃការជំនួស។[4] ការវាយតម្លៃសេវាកម្មប្រព័ន្ធអេកូស៊ីស្ទែមជួយ ពួកយើងឱ្យដឹងពីតម្លៃ និងអត្ថប្រយោជន៍ហើយស្វែងរកយុទ្ធសាស្ត្រមូលដ្ឋានសមស្របមួយសំរាប់លើកកម្ពស់ និរន្តរភាពសេដ្ឋកិច្ច និងសុខមាលភាពមនុស្ស។ ការវិភាគបង្ហាញថាការរក្សាប្រព័ន្ធអេកូស៊ីស្ទែមដែលល្អជាធម្មតាចំណាយច្រើនជាងវិធានការការពារផ្សេងៗទៀត។ នៅភាគឥសាននៃប្រទេសវៀតណាមមានប្រជាជនជាង៧០%ត្រូវទទួលរងគ្រោះ ដោយមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ។ ដើម្បីការពារតំបន់ឆ្នេរ សហគមន៍មូលដ្ឋានបានដាំនិងការពារព្រៃកោងកាងជាយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពតម្លៃជាងការសាងសង់និងការជួសជុលរបាំងសិប្បនិម្មិត (ទំបន់ការពារសមុទ្រ)។ ការវិនិយោគលើព្រៃកោងកាង (ប្រហែលជា១.១លានដុល្លា) បានសន្សំនូវវិនិយោគតាមការប៉ាន់ស្មានប្រចាំឆ្នាំប្រហែល ៧.៣លានដុល្លា គ្រាន់តែផ្នែកជួសជុលទំបន់តែមួយប៉ុណ្ណោះ។[5] ដោយការប៉ាន់ស្មាន និងវាយតម្លៃសេវាកម្មប្រព័ន្ធអេកូស៊ីស្ទែមអាចធ្វើឡើង តាមវិធីសាស្ត្រ ទូលាយមួយដូចដែលបានលើកឡើងដោយ TEEB។ ជំហានទាំង ៦ សំរាប់បញ្ជ្រាបសេវាកម្មប្រព័ន្ធអេកូស៊ីស្ទែមទៅក្នុងគោលនយោបាយមូលដ្ឋាន និងថ្នាក់តំបន់ និងការធ្វើសេចក្តីសម្រេចចិត្តគឺ៖

**ជំហានទី ១:** បញ្ជាក់ច្បាស់ និងយល់ព្រមព្រៀងពីបញ្ហាទាំងនោះជាមួយភាគីពាក់ព័ន្ធ។ ប្រការនេះពាក់ព័ន្ធនឹងការវិភាគអ្នកពាក់ព័ន្ធដំបូងហើយធានាថាទិដ្ឋភាពសំខាន់ៗទាំងអស់ត្រូវតែយកចិត្តទុកដាក់ និងជៀសវាងនូវការយល់ខុសក្នុងពេលធ្វើការសំរេចចិត្ត ។

**ជំហានទី ២:** ចូរកំណត់ថាតើសេវាកម្មណាដែលពាក់ព័ន្ធខ្លាំងហើយសំនួរដែលត្រូវសួរគឺ៖ តើសេវាកម្មប្រព័ន្ធអេកូស៊ីស្ទែមមានសារៈសំខាន់ចំពោះសង្គមមូលដ្ឋាន និងតំបន់យ៉ាងណា? តើនរណាពឹងផ្អែកខ្លាំងលើពួកវា? តើសេវាកម្មមួយណាដែលប្រឈមហានិភ័យ? តើគោលនយោបាយបែបណាមានឥទ្ធិពលលើពួកគេ?

**ជំហានទី ៣:** ចូរកំណត់និយមន័យតំរូវការព័ត៌មាន និងជ្រើសរើសវិធីសាស្ត្រសមស្របដោយមុនធ្វើការវាយតម្លៃ ចូរកំណត់នូវថាតើអ្វីជាប្រភេទព័ត៌មានសេវាកម្មប្រព័ន្ធអេកូស៊ីស្ទែមដែលអ្នកត្រូវការឧទាហរណ៍ប្រសិនបើអ្នកត្រូវការការពិពណ៌នាបែបគុណភាពមួយ បរិមាណជីវរូបសាស្ត្រមួយ ឬវាយតម្លៃរូបិយវត្ថុមួយ។

**ជំហានទី ៤:** ក្រោមពីវាយតម្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី ចូរប្រើក្របខណ្ឌការងារដែលគិតគូរលើសេវាកម្មប្រព័ន្ធអេកូស៊ីស្ទែមដោយសួរនូវសំនួរដូចជា "***តើការសម្រេចចិត្តនឹងត្រូវប៉ះពាល់ដល់សេវាកម្មប្រព័ន្ធអេកូស៊ីស្ទែមកម្រិតណា?***" ឬ

"តើការសម្រេចចិត្តបានកម្រិតណាដោយគ្មានសេវាកម្មប្រព័ន្ធអេកូស៊ីស្ទែមនោះ?" ។ ជំហាននេះទំនងជាធ្វើឡើងដោយអ្នកវិភាគដោយពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល ឬបុគ្គលិកនយោបាយក្នុងស្រុក ។

**ជំហានទី ៥:** ចូរកំណត់ និងវាយតម្លៃជម្រើសគោលនយោបាយ ។ នេះគឺនីតិវិធីវាយតម្លៃដ៏សំខាន់នៃជម្រើសនយោបាយនេះ ។ ការយល់ឃើញពីការវាយតម្លៃនេះអាចស៊ីគ្នាទៅនឹងគោលនយោបាយតាមរយៈដំណើរការចូលរួមដូចជា ការវិភាគផលចំណេញ និងការចំណាយ ឬជាធាតុចូលសំរាប់ការវិភាគពហុលក្ខណៈវិច្ឆ័យ ។

**ជំហានទី ៦:** ចូរវាយតម្លៃផលប៉ះពាល់នៃរបាយ ។ ជំហានចុងក្រោយវាយតម្លៃថាតើអ្នកពាក់ព័ន្ធណាមួយទំនងជាអ្នកឈ្នះ/រឺ ចាញ់ចំពោះសំណើនេះ ។ ការប្រែប្រួលនៃរបាយសេវាកម្មប្រព័ន្ធអេកូស៊ីស្ទែមនេះប៉ះពាល់លើប្រជាជនដោយរបៀបផ្សេងៗដោយតាមការប្រាស្រ័យលើគ្នា ។ ជំហានទាំង៦ដែលបានពិពណ៌នាខាងលើនេះគឺជាវិធីបែបប្រព័ន្ធនៃការបញ្ចូលនូវសេវាកម្មប្រព័ន្ធអេកូស៊ីស្ទែមហើយដែលតាមរយៈនោះបញ្ចូលនូវទុនធម្មជាតិទៅក្នុងគោលនយោបាយមូលដ្ឋាន ។

***តារាងខាងក្រោមពិពណ៌នាក្របខណ្ឌតម្លៃ និងការវាយតម្លៃពីជីវៈចម្រុះ និងប្រព័ន្ធអេកូស៊ីស្ទែម***[6]

| **ចំណាប់អារម្មណ៍** | **ក្របខណ្ឌការងារ** | **គោលបំណង និងកម្មវត្ថុ** |
|---|---|---|
| អេកូឡូស៊ី-សង្គម | ការវាយតម្លៃប្រព័ន្ធអេកូស៊ីស្ទែមសហស្សវត្ស (MA) | ធ្វើចំណាត់ថ្នាក់អត្ថប្រយោជន៍ប្រព័ន្ធអេកូស៊ីស្ទែមជាផ្នែកៗ (ឧ:សេវាកម្មគ្រាំទ្រ និងដាក់និយ័តកម្ម) ដែលអាចធ្វើរូបិយកម្មនៅក្នុងករណីខ្លះ |
| សេដ្ឋកិច្ច | តម្លៃសេដ្ឋកិច្ចសរុប (TEV) | យុទ្ធសាស្ត្រសេដ្ឋកិច្ចបែបសាមញ្ញដើម្បីវាយតម្លៃប្រព័ន្ធអេកូស៊ីស្ទែមស្ដីពីរូបិយវត្ថុ ។ ចូរពិចារណានូវតម្លៃខាងក្នុង ឧ:ការអភិរក្សសម្រាប់ហេតុផលផ្ទាល់ខ្លួនដោយមិនគិតពីប្រយោជន៍ទៅលើមនុស្ស |
| ផ្នែកអេកូឡូស៊ី | តំបន់ជីវៈចម្រុះសំខាន់ៗ (KBA) | កំណត់អាទិភាពសម្រាប់ការអភិរក្ស ប៉ុន្តែផ្អែកជាពិសេសលើលក្ខណៈអេកូឡូស៊ី ។ តើអាចប្រើប្រាស់ស្របជាមួយការវិភាគសេដ្ឋកិច្ចទេ ប៉ុន្តែវា " **មានតែមួយគត់-**Stand alone" ។ ទាក់ទងទៅនឹង MA ផ្ដោតលើដំណើរការជីវរូបសាស្ត្រ ។ |

| | | |
|---|---|---|
| ការអភិវឌ្ឍ | វិធីសាស្ត្រចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព (SLA) | វិធីសាស្ត្រវប្បធម៌-សង្គមដែលគិតគូរទៅលើការកសាងសមត្ថភាព និងការប្រឈមនូវហានិភ័យនេះ មានការពាក់ព័ន្ធនឹងអត្ថប្រយោជន៍ និងតម្លៃសេដ្ឋកិច្ច ប៉ុន្តែក្នុងវិធីផ្សេងៗគ្នា។ |

***វិធីសាស្ត្រការប៉ាន់ស្មានពីតម្លៃបរិស្ថាន***

តម្លៃបរិស្ថានរួមមានការប៉ាន់ស្មាន និងវាយតម្លៃពីការបាត់បង់នូវមុខងារ និងសេវាកម្មប្រព័ន្ធអេកូស៊ីស្តែម។ គ្មានបទបញ្ហាណាដែលកំណត់នូវសំណង ឬការប៉ាន់ស្មានពីតម្លៃបរិស្ថាន ប៉ុន្តែមានករណីជាក់លាក់មួយចំនួនដែលមានការប៉ាន់ស្មានដោយផ្អែកលើស្ថានភាពតំបន់និងកាលៈទេសៈទាំងមូល។ ការប៉ាន់ស្មានពីការខាតបង់សេដ្ឋកិច្ចលើប្រព័ន្ធអេកូស៊ីស្តែម ឬបរិស្ថានអាចត្រូវធ្វើឡើងក្នុងវិធីផ្សេងៗគ្នា។ របៀបខ្លះរួមបញ្ចូលការវាស់វែងធនធានធម្មជាតិដោយផ្អែកលើទីផ្សារដែលមានស្រាប់ ឬទីផ្សារដូចគ្នាឧទាហរណ៍ តម្លៃសេដ្ឋកិច្ចនៃទឹកសម្រាប់ទទួលទានស្អាតគឺអាចវាស់វែងបានតាមតម្លៃនៅលើទីផ្សារទឹកពិសារ។ តម្លៃព្រៃឈើត្រូវពឹងលើតម្លៃទីផ្សារសេដ្ឋកិច្ចឈើមូល។ វិធីនេះក៏បង្ហាញផងដែរថាការប្រើប្រាស់ទីផ្សារជាមូលដ្ឋានសម្រាប់ការវាយតម្លៃផ្តល់នូវតម្លៃផ្សេងៗនៅទូទាំងពិភពលោក។

***វិធីសាស្ត្រចំបងទាំង៦សម្រាប់ការវាយតម្លៃសេវាកម្មប្រព័ន្ធអេកូស៊ីស្តែមជារូបិយវត្ថុមានដូចខាងក្រោម:***[7]

- ***តម្លៃត្រូវជៀសវាង***–សេវាកម្មធ្វើឱ្យសង្គមជៀសវាងនូវតម្លៃដែលនឹងកើតមានឡើងដោយមិនមានវត្តមានសេវាទាំងនោះ (ឧ: ធ្វើប្រព្រឹត្តិកម្មសំណល់តាមរយៈទីជម្រកដីសើមជៀសវាងនូវតម្លៃសុខភាព)
- ***តម្លៃជំនួស***–តើតម្លៃអ្វីសំរាប់ជំនួសឱ្យប្រភពធនធានដែលបានបាត់បង់? សេវាកម្មអាចជំនួសដោយប្រព័ន្ធដែលបង្កើតឡើងដោយមនុស្ស (ឧ: ការស្តារទីជម្រាលចំណាយតិចជាងការសាងសង់រោងចក្របន្សុតទឹក)
- ***កត្តាចំណូល***–សេវាកម្មផ្តល់នូវការពង្រឹងប្រាក់ចំណូល (ឧ:កែលំអរគុណភាពទឹក បង្កើនការចាប់ត្រីបែបពានិជ្ជកម្ម និងបង្កើនប្រាក់ចំណូលដល់អ្នកនេសាទ)
- ***ថ្លៃធ្វើដំណើរ***- តម្រូវការសេវាកម្មអាចទាមទារឱ្យមានការធ្វើដំណើរដែលតម្លៃនេះអាចឆ្លុះបញ្ចាំងពីតម្លៃនៃសេវាកម្មនេះ (តម្លៃនៃការណែនាំអេកូទេសចរណ៍គឺយ៉ាងហោចណាស់ជាអ្វីដែលអ្នកទស្សនាមានបំណងចំណាយថវិកាដើម្បីទៅដល់ទីនោះ) ។

- ***ការឱ្យតម្លៃតម្រែក* (Hedonic Pricing)**- តើទ្រព្យសម្បត្តិអ្វីមានតម្លៃនៅលើទីផ្សារមុនពេល ឬក្រោយពេលគ្រោះថ្នាក់មួយឬព្រឹត្តិការណ៍អ្វីមួយនេះ? តម្រូវការសេវាកម្មអាចឆ្លុះបញ្ចាំងក្នុងតម្លៃដែលមនុស្សមានបំណងចំណាយទៅលើទំនិញ (ឧ:តម្លៃផ្ទះតាមតំបន់ឆ្នេរថ្លៃជាងផ្ទះនៅលើដីគោក ) ។
- ***ការវាយតម្លៃយថាផល*** (CV ឬស្ថ័គ្រចិត្តចំណាយ) តម្រូវការសេវាកម្មអាចដកហូតបានដោយស៊ីណារីយ៉ូដែលជាសម្មតិកម្មទាក់ទងនឹងការវាយតម្លៃជំនួស(ឧ:អ្នកទេសចរណ៍មានបំណងចំណាយសំរាប់ការទស្សនាសួនកំសាន្ត ជាតិ) ។ CV អាចប្រើនៅពេលវាយតម្លៃការផ្លាស់ប្តូរកន្លងមក ឬការជម្រើសរវាងជម្រើសផ្សេងៗ ។

## *វិធីសាស្ត្រផ្សេងៗទៀតដែលប្រើគឺ:*

- ការបាត់បង់ប្រាក់ចំណូល – តើមានចំនួនប៉ុន្មានដែលបុគ្គលម្នាក់ៗបាត់បង់ដោយសារការបំផ្លាញធនធានបរិស្ថាន?
- តម្លៃសម្រាប់ការស្តាបនាឡើងវិញ ឬការបង្កើតឡើងវិញអាចប្រើប្រាស់ជាការវាយតម្លៃ ។

ជាទូទៅធនធានធម្មជាតិមានតម្លៃ២ ***តម្លៃប្រើប្រាស់*-Use Value *និងមិនប្រើប្រាស់*-Non use value** ។ ដោយលើកយកវិស័យព្រៃឈើជាឧទាហរណ៍ វាមានតម្លៃប្រើប្រាស់ខ្ពស់ជាធនធានមួយសំរាប់កន្លែងកំសាន្ត និងសម្រាប់បេះផ្លែឈើ ។ល ។ វាក៏មានតម្លៃអ្នកប្រើប្រាស់ផងដែរសំរាប់ប្រើប្រាស់អនាគតកន្លែងលំហែកំសាន្តនៅថ្ងៃស្អែក ។ តម្លៃមិនប្រើប្រាស់នៃព្រៃឈើ គឺជាការតម្លៃកម្រមានរបស់ព្រៃឈើហើយប្រើប្រាស់សំរាប់ក្មេងជំនាន់ក្រោយៗ ។ ការវាយតម្លៃសេដ្ឋកិច្ចភាគច្រើននៃធនធានបរិស្ថាន ឬប្រព័ន្ធអេកូស៊ីស្ទែមបង្កើតឡើងដើម្បីជូនដំណឹងដល់អ្នកសំរេចចិត្ត និងដើម្បីមានឥទ្ធិពលលើការសំរេចចិត្ត ។ ការវាយតម្លៃសេដ្ឋកិច្ចពីធនធានបរិស្ថាន និងប្រព័ន្ធអេកូស៊ីស្ទែមគឺមិនងាយស្រួល ឬទៀងទាត់នោះទេ ។ ការវាយតម្លៃនេះពឹងផ្អែកលើស្ថានភាពជាក់លាក់ តំបន់ជាក់លាក់និង/រឺបុគ្គលជាក់លាក់ដែលបានសម្ភាសន៍ ។ មានវិធីសាស្ត្រមួយចំនួនសំរាប់ការវាយតម្លៃដែលត្រូវប្រើនៅក្នុងប្រទេសជាច្រើន ប៉ុន្តែមិនមានការយល់ស្រប ឬកិច្ចព្រមព្រៀងជាអន្តរជាតិលើការជ្រើសរើសវិធីសាស្ត្រនេះទេ ។ ការលំបាកគឺថាមិនមានចំលើយត្រឹមត្រូវទៅលើថាតើបរិស្ថានមានតម្លៃអ្វី ។

## *ព័ត៌មានបន្ថែមស្តីពីវិធីសាស្ត្រវាយតម្លៃបរិស្ថាន*

វិធីសាស្ត្រសំរាប់ធ្វើការវាយតម្លៃបរិស្ថានមានច្រើនវិធីសាស្ត្រមួយប្រើប្រាស់ទូលំទូលាយជាងវិធីសាស្ត្រផ្សេងៗទៀត ។ របាយការណ៍ និងគេហទំព័រមានដូចខាងក្រោម :

- គេហទំព័រទិន្នន័យដែលអាចស្រាវជ្រាវបានដោយចុះបញ្ជីនិងដោយប្រៀបធៀបទៅនឹងវិធីសាស្ត្រផ្សេងៗសម្រាប់ប្រភេទនៃការវាយតម្លៃអេកូស៊ីស្ទែមជាច្រើនអាចមើលនៅក្នុង: http://assessmentmethods.nbii.gov.

- របាយការណ៍វាយតម្លៃប្រព័ន្ធអេកូស៊ីស្ទែមសហស្សវត្សរ៍កំណត់ ពិពណ៌នា និងវិភាគលើវិធីសាស្ត្រវាយតម្លៃបរិស្ថាន និងសេវាកម្មប្រព័ន្ធអេកូស៊ីស្ទែម៖ www.millenniumassessment.org
- របាយការណ៍ពីទំនាក់ទំនងមហាសមុទ្រ និងដីគោកនៅតំបន់ឆ្នេរ (LOICZ) ឆ្ពោះទៅរកការធ្វើគំរូ និងការវិភាគចម្រុះនៅតំបន់ឆ្នេរ៖ គោការណ៍ និងការអនុវត្តដោយ Turner et al (១៩៩៨) និងការពិភាក្សាវិធីសាស្ត្រពាក់ព័ន្ធ និងការឆ្លើយតបចំពោះវិធានការនានា។

របាយការណ៍ជាច្រើនក៏ពិភាក្សាផងដែរពីសេវាកម្មប្រព័ន្ធអេកូស៊ីស្ទែម ផលប្រយោជន៍របស់ពួកគេ និងវិធីសាស្ត្រវាយតម្លៃ៖

- របាយការណ៍គម្រោងការអភិវឌ្ឍដោយចីរភាព៖ សេវាកម្ម និងមុខងារប្រព័ន្ធអេកូស៊ីស្ទែមអាចមើលនៅ៖ http://www.sustainablescale.org/ConceptualFramework/UnderstandingScale/BasicConcepts/EcosystemFunctionsServices.aspx
- សេដ្ឋកិច្ច នៃប្រព័ន្ធអេកូស៊ីស្ទែម និងជីវៈចម្រុះ (TEEB) បានបោះពុម្ពរបាយការណ៍ជាច្រើនដែលកំណត់ និងវិធីពិភាក្សានូវវិធីសាស្ត្រវាយតម្លៃសេវាកម្មប្រព័ន្ធអេកូស៊ីស្ទែម៖ TEEB នេះសំរាប់អ្នកសំរេចចិត្តថ្នាក់មូលដ្ឋាន និងតំបន់ និង TEEB សំរាប់អ្នកសម្រេចចិត្តថ្នាក់ជាតិ និងអន្តរជាតិ របាយការណ៍សង្ខេប៖ ការឆ្លើយតបទៅនឹងតម្លៃធម្មជាតិ។ របាយការណ៍នេះអាចមើលនៅក្នុង៖ www.teebweb.org
- http://www.derm.qld.gov.au/register/p00870aa.pdf (រដ្ឋាភិបាល Queensland ក្នុងឆ្នាំ ២០០៣៖ ការវាយតម្លៃសេដ្ឋកិច្ច-បរិស្ថាន។ គោលការណ៍ណែនាំសំរាប់អ្នកនយោបាយ និងអ្នកអនុវត្ត)
- http://www.environment.gov.au/epbc/assessments/strategic.html
- http://webarchive.nationalarchives.gov.uk/+/http://www.communities.gov.uk/documents/planningandbuilding/pdf/142520.pdf (ការិយាល័យឧបនាយករដ្ឋមន្ត្រីនៅឆ្នាំ២០០៥។ ការវាយតម្លៃប្រកបដោយចីរភាពនៃយុទ្ធសាស្ត្របែងចែកតំបន់ និងឯកសារអភិវឌ្ឍន៍មូលដ្ឋានរបស់ទីក្រុងឡុង។)

## ឧបសម្ព័ន្ធទី៩: គំរូមាតិកាសម្រាប់ផែនការបែងចែកតំបន់ប្រើប្រាស់ដី និងកម្មវិធីអនុវត្តន៍

នៅក្នុងប្រទេសខ្លះ ច្បាប់ឬគោលការណ៏ណែនាំដែលមានស្រាប់អាចបញ្ជាក់ច្បាស់នូវអ្វីដែលគួរមាននៅក្នុងផែនការបែងចែកតំបន់ (ឬការប្រើប្រាស់ដីឬរូបវន្ត) និងថាតើឯកសារបែបនេះគួររៀបចំដោយរបៀបណា។ ចូរធ្វើតាមស្តង់ដាជាតិនូវកន្លែងណាដែលមាន។ ខាងក្រោមនេះជាឧទាហរណ៏មួយមានបំណងផ្តល់នូវគំនិតកន្លែងដែលគ្មានតម្រូវការ ឬគោលការណ៏ណែនាំតឹងរ៉ឹងនោះ។ ជារួម ឧទាហរណ៏នេះទាក់ទងនឹងវិធីសាស្រ្តគំរូធ្វើផែនការថ្មីដែលប្រើប្រាស់នូវវិធីសាស្រ្តដោយមានការចូលរួមហើយដែលក្នុងនោះកម្មវិធីអនុវត្តន៏ដើម្បីដើរតាមគោលដៅនេះត្រូវបានបញ្ចូលនេះគឺជាផ្នែកទី២។

**Executive Summary**

**Part One Background and Long Term Zoning Plan**

1. Introduction and Background
2. Description of Process
    1. Overview of the process
    2. Participatory and consultative elements
    3. Special studies
    4. …
3. Description of Area
    1. The area within the region
    2. Physical Characteristics
    3. Shoreline classification
    4. Habitats and Ecosystems
    5. Current resource use
4. National, regional and local Interests
5. Vision and Long-Term Goals
    1. Current Assets, Potentials
    2. Common Vision
    3. Long-Term Sectoral Goals (*These should be fairly brief statements.*)
        1. Environmental Management, Green and Blue Structure
        2. Fisheries
        3. Forestry
        4. …
        5. Shoreline management
        6. Social well-being, resilience
        7. Economic Development
        8. Settlement Development

        9. Transportation
    4. Constraints, Hindrances and Priorities (*Usually problems cross sectoral and spatial boundaries, and should be treated in an integrated and coordinated manner. It is useful to show the interconnections between issues in diagram form – either as cause and effect diagrams or "horrendograms."This also provides a good background for presenting and discussing priorities.*)
6. Strategies for Achieving the Long-Term Goals
    1. Strategies for protecting & enhancing assets
    2. Strategies to overcome constraints and hindrances
    3. Strategies to avoid future threats
    4. Climate change mitigation and adaptation strategies
    5. Specific shoreline management strategies
    6. Specific strategies for reducing risks, and vulnerability and for increasing resilience
7. Land use and development management zones (*Refer to map(s); describe what is permitted and/or prohibited in each zone. Zones are given main and subordinated classifications. Create zone classes and sub-classes according to national standards, or in the event these don't exist, create them according to need.)*
    1. E Environmental protection
        1. E1 Protected areas
        2. E2 Limited use conservation areas
        3. E3 …
    2. A Agriculture
        1. A1 Crop Husbandry
        2. A2 Mixed Crop and Animal HusbandryHusbandry
        3. A3 Animal Husbandry
        4. A4 Horticulture, Orchards, Permanent Tree Crops other than Forestry
    3. Fo Forestry
    4. Fi Fisheries
        1. Fi1 Marine Protected Area (no fishing)
        2. Fi2 Fishing Conservation Areas (seasonal restrictions on fishing...)
        3. Fi3 Terrestrial Aquaculture
        4. Fi4 Marine Aquaculture
        5. …
    5. T Transportation and Communications
        1. T1 Land Transportation corridors and ancillary (non-urban areas)
        2. T2 Marine shipping lanes (can be subdivided to allow for special regulations like speed restrictions close to sensitive shorelines, or marine ecosystems)
        3. T3 Ports and harbours
        4. T4 Tele-Communication infrastructure
        5. …
    6. P Energy infrastructure
        1. P1 …

7. U Urban land uses
    1. U1 …
8. ….
9. R Reserved for future unspecified uses.

**Part Two Implementation Program**

8. Introduction and reference to Part 1, especially Chapters 5, and 6 (*This introduction is provided so that Part Two can stand alone. However, it need not repeat everything that has already been written in Part One*)
9. Overview of Implementation Program

    The program in Tabular form with Time-frame (*provide a table showing all sectoral goals, strategies and proposed activities/projects, identifying responsible actor and other participating agencies. Follow this with a Gantt diagram showing each activity/project's timing through the 3-5 year period.*)

    Management structure for integrating and coordinating implementation program

    Mechanisms to link progress reviews and updating to annual budget process,

    Monitoring and feedback goals, methods, responsibilities
10. Long term research and development needs

    Role of universities and research institutions

    Coordination of institutional geodatabases, including standards for data exchange

11. Coordinated institutional capacity development efforts related to program implementation
12. Sectoral implementation programs and projects (*for each sector/sector institution give "thumbnail" descriptions of each activity or project, its location and impact area, its contribution to the goals and vision, its estimated budget, estimated time-frame, and responsible unit.*)

    Environmental Protection Agency (*or equivalent*)

    Agriculture

    Forestry

    Fisheries

    Public works (*or the agency responsible for sea defence, and shoreline protection*)

## ឧបសម្ព័ន្ធទី ១០: ការណែនាំដោយសង្ខេបនូវវិធីសាស្ត្រ បច្ចេកទេស និងជំនួយ

ការធ្វើផែនការបែងចែកតំបន់គឺជាវិធីសាស្ត្រមួយដើម្បី:

- ដោះស្រាយទំនាស់ក្នុងការប្រើប្រាស់ដីធ្លី
- ដាក់បញ្ហានៅពេលប្រឈមនឹងភាពមិនច្បាស់លាស់ដោយបង្កើតទំហំបែងចែកតំបន់សម្រាប់គំរូអនាគត
- ផ្តល់នូវគំនិតអំពីអនាគត និងផ្តល់នូវវិញ្ញាណប្រកបដោយស្ថេរភាពដល់អ្នកតាំងលំនៅ និងអ្នកវិនិយោគ
- ការផ្តល់នូវទិសដៅដល់តួអង្គ និងភាគីពាក់ព័ន្ធទាក់ទងនឹងធាតុចូលដើម្បីសម្រេចបានគោលដៅរយៈពេលវែង។

ក្នុងដំណើរការនៃការធ្វើផែនការនេះ ឧបករណ៍ បច្ចេកទេស និងជំនួយភាគច្រើនបានប្រើប្រាស់។ ក្នុងន័យទូលំទូលាយ ពួកគេមានលំដាប់ថ្នាក់ដូចខាងក្រោម:

- គំរូ (Models) : ទាំងនេះគឺជាការពិពណ៌នាដ៏សាមញ្ញ ទាំងគុណភាព ទាំងបរិមាណ។ ពួកគេអាចមានភាពធម្មតា និងធ្វើឱ្យជាទូទៅ ឬស្មុគ្រស្មាញនិងពិស្តារ។ មានឧទាហរណ៍ខ្លះៗដូចខាងក្រោម :
  - ផែនទីទីជម្រកសហគមន៍
    - Sites.google.com/site/communitymappingandplanning/
  - ការបកស្រាយជាទូទៅពី "វដ្តទឹក" និងជីវជាតិផ្សេងទៀត ឬធាតុផ្សំតាមធម្មជាតិ
    - En.wikipedia.org/wiki/Water_cycle, etc.
    - Studenten.samenvatteningen.com/documenten/show/046760/ - a presentation of different system models
  - គំរូប្រព័ន្ធអេកូស៊ីស្ទែម ទាំងគុណភាព (បែបពិពណ៌នា) ទាំងបរិមាណ (ដោយផ្អែកទំនាក់ទំនងកំណត់តាមបែបគណិតវិទ្យារវាងសមាសធាតុទាំងនេះ) ។
    - www.mssanz.org.au/modsim05/papers/villa.pdf A semantic model of Computation for Natural System Modelling.
    - Gisweb.ciat.cgiar.org/dapablogs/dapa-ecosystems/?cat=5
  - គំរូសេដ្ឋកិច្ចសង្គម
  - គំរូការប្រែប្រួលអាកាសធាតុតាមបែបគណិតវិទ្យាដោយប្រើកំព្យូទ័រ
  - ស៊ីណារីយោឆ្លាស់នៃការអភិវឌ្ឍអនាគតដ៏មានសក្តានុពល
  - មូលហេតុ និងឥទ្ធិពលតារាងលំហូ
    - www.mindtools.com/pages/article/newTMC_80.htm
    - www.mindtools.com/pages/article/newTMC_03.htm
  - ព័ត៌មាន ដ្យាក្រាមលំហូសំភារ:និង ថាមពល ចង្វាក់ចំណីអាហារ
  - ដ្យាក្រាមបណ្តាញស្ថាប័ន
  - គំរូវិភាគជីវភាពរស់នៅ

- ការប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ
- ការវាយតម្លៃផលប៉ះពាល់ជាយុទ្ធសាស្ត្រ ដោយផ្អែកលើអន្តរទំនាក់ទំនងរវាងសមាសធាតុប្រព័ន្ធ
- រូបភាព និងការវិភាគរូបភាព - "ដោយដៃ/ចក្ខុវិញ្ញាណ" ឬដោយស្វ័យប្រវត្តិ និងការទទួលស្គាល់គំរូ

- របៀប វិធីសាស្ត្រ និងបច្ចេកទេសសំរាប់លើកទឹកចិត្ត និងគ្រប់គ្រងការចូលរួមរបស់ភាគីពាក់ព័ន្ធ។ ភាគច្រើនអាចធ្វើដោយផ្ទាល់ ឬក្រុមតូចៗ-រួមមានការរៀបចំផែនការក្រុមស្នូល។ ក្នុងរយៈពេលវែង វាគួរតែប្រកាន់ភ្ជាប់ដ៏មានប្រសិទ្ធភាព និងការប្រតិបត្តិផែនការនេះ។
  - ការវិភាគភាគីពាក់ព័ន្ធ
    - www.eestum.edu/voorbeelden/Stakheholders_analysis_guidelines.pdf
    - erc.msh.org/quality/ittools/itstkan.cfm
    - www.pmhut.com/what-is-stakeholder-analysis
    - www.euforic.org/gb/stake1.html#assess
    - www.mindtools.com/pages/article/newPPM_07.htm
    - Assets.panda.org/downloads/1_1_stakeholder_analysis_11_01_05.pdf
    - www.12manage.com/methods_stakeholder_mapping.html
  - ការវិភាគភាគីពាក់ព័ន្ធដោយប្រើដ្យាក្រាម Venn ភាពសបច្បាប់ និងភាពបន្ទាន់
    - www.12manage.com/methods_stakeholder_mapping.html
    - www.saltlane.co.uk/Resources/stakeholder%20analysis.HTML
  - ការវិភាគភាគីពាក់ព័ន្ធដោយប្រើ ៤ Rs
    - www.odi.org.uk/resources/details.asp?id=791&title=4rw-valuable-tool-management-benefit-sharing-decisions-bimbia-bonadikombo-forest-cameroon
  - ការវិភាគភាគីពាក់ព័ន្ធដោយប្រើការវិភាគកំលាំង
    - www. mindtools.com/pages/article/newTED_06.htm
    - www.12manage.com/methods_lewin_force_field-analysis.html
    - www.accel-team.com/techniques/force_field_analysis.html
  - កិច្ចប្រជុំ សិក្ខាសាលាដោយមានប្រភេទសម្របសម្រួលផ្សេងៗគ្នាដើម្បីជម្រុញឱ្យមានការពិភាក្សាដ៏រស់រវើក និងប្រកបដោយការស្ថាបនាដើម្បីសម្រេចបានការឯកភាពលើបញ្ហានេះចក្ខុវិស័យ គោលដៅ ចំណុចអាទិភាព និងសកម្មភាព
    - Treegroup.info/topics/facilitation_primer.pdf
    - https://engineering.purdue.edu/~iwla/iwla/resources/Academy/Group_Facilitation_Strategies.pdf
  - បញ្ជីសំនួរ និងការប្រមូលទិន្នន័យ ឧបករណ៍ប្រមូលនិងវាយតម្លៃ – បញ្ជីសំនួរបើក និងបិទ, ការសម្ភាសន៍
    - asq.org/learn-about-quality/data-collection-analysis-tools/overview/survey.html
  - ផែនទីទ្រព្យសម្បត្តិ
    - extension.missouri.edu/about/fy00-03/assetmapping.htm
    - backspace.com/notes/2004/06/what-is-asset-mapping.php
    - www.rwmc.usguelph.ca/cms/documents/11/Asset_Mapping1.pdf
  - The Have-Want Grid
    - In environment.sipuweb.se/Docs/ProjectDesignPresentations/24_5_2 Project_Design.ppt

- ការវិភាគស្ថានភាព
  - cmsdata.iucn.org/downloads/approach_andMethod.pdf
  - pqdl.care.org/gendertoolkit/Pages/context%20default.aspx
- ការវិភាគឫសគល់ហេតុផល /ការវិភាគ Problem Tree/ការវិភាគ Pareto /ឌីយ៉ាក្រាម Ishikawa /ដ្យាក្រាមរប៉ាត់រប៉ាយ (Diagram scatter)
  - www.toolkitsportdevelopment.org/html/resources/91/910EE48E-350A-47FB-953B-374221B375CE/03%20Problem%20tree%20analysis.pdf
  - www.mindtools.com/pages/article/newTMC_03.htm
  - asq.org/learn-about-quality/cause-analysis-tools/overview/pareto.html
  - asq.org/learn-about-quality/cause-analysis-tools/overview/scatter.html
  - asq.org/learn-about-quality/cause-analysis-tools/overview/fishbone.html
- ការវិភាគស្ថានប័ន (ការវិភាគប្រព័ន្ធការងារ, អភិបាលកិច្ច)
  - ageconsearch.umn.edu/bitstream/24542/1/0s05he03.pdf
  - siteresources.worldbank.org/INTTOPPSISOU/Resources/Volume201Tool-Sourcebook.pdf
  - www.governorat.eu/files/pb_world-bank-tools-for-policy-analysis.pdf
- ការកសាងស៊ីណារីយោការពិភាក្សា
  - www.mindtools.com/brainstorm.htm
  - www.slideshare.net/adgo/scenario-building-workshop-how-to-build-and-use-scenarios
- ការកសាងក្រុម
  - www.accel-team.com/index.html
  - www.atpl.net.au/sample/pdf/atpsample_11969.pdf
  - Managementhelt.org/grp_skll/teams/teams.html
- ការវិភាគពីទំនាស់ និងការដោះស្រាយ
  - www.cios.org/encyclopedia/conflict/Eskills4_assessmenttools.htm
- ការវិភាគភាពងាយរងគ្រោះ
  - www.proventionconsortium.org/themes/default/pdfs/VCA-ws04.pdf
  - www.proventionconsortium.org/?pageid=39
  - siteresources.worldbank.org/INTTOPPSISOU/Resources/Volume201Tool-Sourcebook.pdf
- ក្រុមបច្ចេកទេសតូចៗ (ដើម្បីជៀសវាងការត្រួតពិនិត្យបុគ្គលមួយចំនួន និងផ្តល់នូវឱកាសសំរាប់អ្នកចូលរួមដ៏ស្ងប់ស្ងាត់ផ្តល់គំនិត)
  - www.cdc.gov/HealthyYouth/evaluation/pdf/brief7.pdf
  - www.joe.org/joe/1984march/iw2.php
  - En.wikipedia.org/wiki/Nominal_group_technique
- “មួយនឹងទទួលបាន ១០” – ការបង្កើតគំនិត និងការចែកចាយ
  - In www.atpl.net.au/sample/pdf/atpsample_11969.pdf

- ការគ្រប់គ្រងព័តិមានៈ ការរៀបចំព័តិមាន និងទិន្នន័យមូលដ្ឋានក្នុងការរៀបចំផែនការ និងជាពិសេសគំរូធ្វើផែនការថ្មី។ ទិន្នន័យភូមិសាស្ត្រមានៈ
  - ឯកសាររាយឈ្មោះ /បណ្ណាល័យ

- ទិន្នន័យពាក់ព័ន្ធ
- ទិន្នន័យភូមិសាស្ត្រ - លក្ខណៈជាក់លាក់នៃ RDBs គឺថាពួកគេអាចស្តុក និងរៀបចំទិន្នន័យ និងព័ត៌មាន (ភូមិសាស្ត្រ) តំបន់
- ប្រព័ន្ធព័ត៌មានបរិស្ថាន (EMS)
- ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS)
- ប្រព័ន្ធព័ត៌មានការគ្រប់គ្រង (MIS)

- ជំនួយក្នុងការចងចាំពាក្យកាត់ដែលជាធម្មតាសំដៅលើឧបករណ៍ និងវិធីសាស្ត្រជាក់លាក់
  - PEST, STEP, STEEPIL, ពាក្យកាត់តាមវិស័យត្រូវពិចារណាក្នុងការវិភាគទិន្នាការ ការកសាងស៊ីណារីយោ ការវាយតម្លៃហេតុផលប៉ះពាល់: សង្គមវប្បធម៌ បច្ចេកទេស បរិស្ថាន-អេកូស៊ីស្ទែម សេដ្ឋកិច្ច គោល នយោបាយ ស្ថាប័ន និងបរិធានច្បាប់
  - SWOT : ភាពខ្លាំង (S) ភាពខ្សោយ (W) ឱកាស (O) និងការគំរាមកំហែង (T)
  - DRUGS, ប្រភេទនៃអ្នកពាក់ព័ន្ធសំខាន់ៗក្នុងដំណើរការឯកភាពៈ អ្នកសំរេចចិត្ត អ្នកផ្តល់អនុសាសន៍ អ្នកប្រើប្រាស់ អ្នកឃាម ភាគីឯទៀតៗ ។
  - 5Ms – សំរាប់ធ្វើផែនការថវិកា និងពេលវេលាៈ កំលាំងមនុស្ស (បុគ្គលិក-ជាប្រចាំ រឺចុះកិច្ចសន្យា) ម៉ាស៊ីន (ទំនិញមូលធន–ដែលមិនអាចប្រើប្រាស់បាន) សម្ភារៈ (ប្រសិនបើទិញរឺបង្កើតឡើងជាក្រុម-កម្មវិធី Soft ware, និងតម្លៃអភិវឌ្ឍន៍ដំណើរការមិនផ្ទាល់) លុយ (ការសរុបការចំណាយសរុបនៃសមាសភាពទាំង៤មុន)

***យើងផ្តល់ជូនឲ្យអ្នកអានស្រាវជ្រាវតាមអ៊ិនធឺណិតរកឯកសារខាងលើ***

## ឧបសម្ព័ន្ធទី ១១: ការជ្រើសរើសយុទ្ធសាស្ត្រដាក់លាក់សំរាប់ច្រាំងសមុទ្រ

វិធីសាស្ត្រដែលអាចធ្វើបានក្នុងការជ្រើសរើសយុទ្ធសាស្ត្រជាក់លាក់សំរាប់តំបន់ច្រាំងសមុទ្រមានដូចខាងក្រោមៈ

- តើអ្វីជាលក្ខណៈតំបន់ឆ្នេរជាក់លាក់ ពាក់ព័ន្ធនឹងការហូរច្រោះនាពេលបច្ចុប្បន្ន និងអនាគត- តើវាជាខ្សាច់ ភក់ ថ្មឬឆ្នេរគ្របដណ្តប់ដោយដំណាំបន្លែ? តើមានគំនរផ្ទុកខ្សាច់ទេ? តើមានរលកសមុទ្រដែលមានការដឹកជញ្ជូនកករទេ? តើច្រាំងសមុទ្រត្រូវបានរៀបចំវិធានការត្រួតពិនិត្យការហូរច្រោះរួចស្រេចរឺនៅ ដូចជា របាំងការពារកំលាំងទឹក (Groins) របាំងសមុទ្រ (Sea wall) រឺការបង្កើតឆ្នេរខ្សាច់?
- បើសិនជាការហូរច្រោះគឺបញ្ហាថ្មី ដំបូងចូរមើលដើមហេតុដែលអាចមាន ឬភ្នាក់ងារធ្វើឱ្យធ្ងន់ធ្ងរឡើងៗ។ ឧទាហរណ៍ទាំងនេះអាជីវកម្មខ្សាច់ ការដុះលាងចេញពីកប៉ាល់ធំៗតាមផ្លូវដឹកជញ្ជូននៅក្បែរនោះ វិធានការត្រួតពិនិត្យ ការហូរច្រោះមិនបានល្អ ឬមិនសមស្របពីតំបន់ខាងលើ ការបាត់បង់របាំងធម្មជាតិការពារ។ ប្រសិនបើមានភស្តុតាងបែបនេះ ចូរចាត់វិធានការកែតម្រូវពួកគេ
- ចូរកំណត់លក្ខណៈជាក់លាក់នូវកន្លែងសំដៅទៅរកដីគោកសំរាប់តំបន់ជាក់លាក់នោះ–តើអ្វីគឺជាគំរបដីឬការប្រើប្រាស់ដី, តើអ្វីគឺជា "ទិន្នន្នាការនៃការអភិវឌ្ឍ" (តើវាជាតំបន់ជនបទដាច់ស្រយាលមិនសូវមានផែនការអភិវឌ្ឍន៏នាពេលអនាគត ឬក៏ជាតំបន់ទាក់ទាញវិនិយោគ)?
- ប្រសិនបើអាចចូរបញ្ជាក់នូវផលប៉ះពាល់សំខាន់ៗពីការប្រែប្រួលអាកាសធាតុទំនងជាមាននៅបណ្តោយឆ្នេរសមុទ្រនេះ ហើយតើបញ្ហាការកើនឡើងកម្ពស់ទឹកសមុទ្រជាបញ្ហាតែមួយគត់ ឬនឹងមានបញ្ហាផ្សេងៗទៀតដែលអាចមានឥទ្ធិពលលើប្រព័ន្ធអេកូធម្មជាតិ ព្រមទាំងការប្រើប្រាស់ដីប្រកបដោយផ្លែផ្កា ?
- តើអ្វីជាជម្រើសបន្សាំ ដែលនិយាយច្បាស់ចំពោះតំបន់ឆ្នេរសមុទ្រ ដូចជាបានពិភាក្សាខាងលើ?
- តើអ្វីជាឧបសគ្គចំពោះជម្រើសទាំងនេះ?
- ចូរគណនា និងឱ្យតម្លៃជំរើសទាំងនេះ និងចូរប្រៀបធៀបជាមួយការផ្លាស់ប្តូរតម្លៃក្រោមស៊ីណារីយោ ***Do nothing*** ។
- ចូរប្រៀបធៀបតម្លៃនៃវិធានការនិងផលប្រយោជន៏ដែលមានដោយប្រើវិធីបញ្ចុះតម្លៃសមស្របដើម្បីបញ្ចូលតម្លៃសំរាប់អនាគត និងតម្លៃថៃទាំ។ ចូរចំណាំនូវតម្លៃអរូបិយដែលអាចមានប្រៀបលើការគណនាសេដ្ឋកិច្ចត្រង់ៗ (ឧៈ កន្លែងសាសនា, តម្លៃវប្បធម៌ដ៏សំខាន់ ។ល ។)
  - ចូរវាយតម្លៃការដោះដូរតាមជម្រើសដែលត្រូវប្រៀបធៀប
  - ចូរផ្តល់អនុសាសន៏នូវវិធានការបន្សាំកាន់តែប្រសើរ

## ឧបសម្ព័ន្ធទី ១២: ការកំណត់ Set Back តំបន់ឆ្នេរ




**ដំណើរការកំណត់ Set back នៅអាហ្វ្រិចខាងត្បូង**

| ឧទាហរណ៍ពីការកំណត់ Set back តំបន់ឆ្នេរ និងសមមូលតំបន់ឆ្នេរ | | |
|---|---|---|
| ប្រទេសដាណឺមាក | ច្បាប់ការពារធម្មជាតិ (១៩៩៤) | តំបន់ការពារចម្ងាយ៣០០ម៉ែត្រ ពីឆ្នេរនៅតាមបណ្តោយតំបន់ឆ្នេរប្រទេសដាណឺមាក (ការបែងចែកពីតំបន់ក្រុង) ។ សកម្មភាពថ្មីត្រូវបានហាមឃាត់ក្នុងតំបន់ការពារតំបន់ឆ្នេរលុះត្រាតែកាលៈទេសៈពិសេសចង្អុលបង្ហាញនូវតម្រូវការមួយផ្តល់នូវការលើកលែង ។[៩] |
| ប្រទេសស៊ុយអែត | ច្បាប់សាងសង់ និងសំណង់អាគារ | មានចម្ងាយ ១០០ ម៉ែត្រពីដែនដីដែលមិនមានការអភិវឌ្ឍដោយគ្មានការអនុញ្ញាតិនោះទេ ហើយគោលបំណងសំខាន់គឺដើម្បីធានានូវការចេញចូលជាសាធារណៈទៅដល់មាត់ទឹក |
| ប្រទេសបារបាដូស (Barbados) | | កន្លែងដែលមានឆ្នេរ ការកំណត់ Set back មានចម្ងាយ ៣០ ម៉ែត្រពីតំបន់កម្ពស់ទឹកខ្ពស់សំរាប់សាងសង់សំណង់ កន្លែងដែលកំពូលច្រាំងថ្មនៅមាន ហើយមានចម្ងាយ Set back ១០ ម៉ែត្រ ពីចំណុចទិសទៅខាងដីគោក<br>***ករណីលើកលែង:***<br>• បង្កើន Set back ដោយសារគោលនយោបាយដើម្បីការពារ និងអភិរក្សតំបន់ទេសភាពតាមបណ្តោយតំបន់ឆ្នេរពិសេស<br>• បន្ថយ Set back អាចកើតឡើងក្នុងតំបន់ដែលមានអាគារដែលមានស្រាប់ |
| រដ្ឋដីឡាវែរ (State of Delaware) | | ចម្ងាយ១០០ហ្វីត (៣០,៥ ម៉ែត្រ) ពីដីគោក ដោយគិតចេញពីរយៈកម្ពស់ទឹកសមុទ្រ ៧ ហ្វីត (២,១ ម៉ែត្រ) ។ |
| ប៉ូឡូញ | រដ្ឋបាលកិច្ចការសមុទ្រ | ជម្ងាយ ២០០ ម៉ែត្រទៅដីគោកនៃនៃផ្នែកខ្សាច់ ឬចម្ងាយ២០០ ម៉ែត្រពីមាត់ច្រាំងថ្មខាងលើ |
| Minnesota, | | អត្រាការហូរច្រោះប្រចាំឆ្នាំ ៥០ ដង និងបូក ២៥ ហ្វីត |

| | | |
|---|---|---|
| USA | | នៅតំបន់ដែលមានទិន្នន័យការហូរច្រោះ និងមានស្តង់ដា ១២៥ ហ្វីត នៃ Set back |
| North Carolina, USA | កូដរដ្ឋបាលសម្រាប់តំបន់ប្រកបដោយគ្រោះថ្នាក់នៃមហាសមុទ្រ ។ | ដោយវាស់វែងពីតំបន់ដំណាំធម្មជាតិនៅទីនោះផ្ដួចផ្ដើមតំបូង ដោយផ្អែកលើអត្រាសំណឹកប្រចាំឆ្នាំ ។ លំនៅដ្ឋានទោល និង រចនាសម្ព័ន្ធតូចៗ (<៥000 ft2 និងតិចជាង ៥ ឯកតា) គឺ Set back មានអត្រាសំណឹកជាមធ្យមប្រចាំឆ្នាំ ៣0ដង ឬតិចជាង ៦0 ហ្វីត ។ សំរាប់រចនាសម្ព័ន្ធធំៗ Set back មានអត្រាសំណឹកប្រចាំឆ្នាំ ៦ដងឬយ៉ាងហោចណាស់ ១២0 ហ្វីត ហើយអាងហែលទឹកអាចសាងសង់នៅតំបន់ Set back ។ |
| Hawaii State Minimum standards | | ដីដែលមានជម្រៅតិចជាង ១00ហ្វីត ត្រូវការ Set back ចំនួន ២៥ ហ្វីតសំរាប់សាងសង់អាគារ ។ ដីជម្រៅលើសពី ១00-១៦0 ត្រូវការ Set Back ៤0 ហ្វីត ។ ដីដែលមានជម្រៅលើសពី ១៦0 ហ្វីត , ត្រូវការ Set back ១៥0 ហ្វីតឬ មួយភាគបួននៃជម្រៅដី ។ |
| Maui County, Hawaii | គណៈកម្មការធ្វើផែនការ Maui | ជាមូលដ្ឋាន: អត្រាសំណឹកប្រចាំឆ្នាំជាមធ្យម ៥0ដងបូក ២0 ហ្វីត ឬប្រើស្តង់ដាទូទាំងរដ្ឋដែលកាន់តែធំ ។ រចនាសម្ព័ន្ធដែលមានស្រាប់ស្ថិតនៅក្នុងតំបន់ Set back អាចកសាងឡើងវិញដែលពួកត្រូវបំផ្លាញដោយមុខសញ្ញាគ្រោះថ្នាក់មិនមែនតំបន់ឆ្នេរ ។ តំបន់ដីនោះត្រូវតែមានជម្រៅ ៣0 ហ្វីត ដែលអាចសាងសង់បាន បន្ទាប់ពីការកំណត់ Set Back ប្រសិនបើមិនអាចធ្វើបានទេ កម្រិតលំអៀងប្រហែលជាអាចនាំឱ្យមានផ្នែកខ្លះនៃសំណង់កាត់លើបន្ទាត់ Set back ។ ឆ្នេរថ្ម ឬច្រាំងសមុទ្រដែលធ្វើឱ្យរឹងបែបសិប្បនិម្មិតត្រូវការតែផ្នែកភ្ជាប់ទៅនឹងផ្នែកខាងក្រោមរបស់រដ្ឋដោយមានស្តង់ដាទាបបំផុត ។ |
| ប្រទេសឥណ្ឌា | សេចក្តីជូនដំណឹង CRZ | បទបញ្ញតិប្រើប្រាស់ក្នុងតំបន់នេះស្ថិតចំងាយ ៥00 ម៉ែត្រពីខ្សែបន្ទាត់ទឹកជោរឡើងបូកនឹងតំបន់នេះរវាងខ្សែបន្ទាត់ទឹកជោរ និងនាដហើយខ្សែ |

| | | |
|---|---|---|
| | | បន្ទាត់នេះរត់ស្របគ្នាទៅនឹងតំបន់ឆ្នេរ ។ ក្បួនពិសេសអនុវត្តលើដីតាមបណ្តោយមាត់ទន្លេមានតំបន់ ៤គឺៈ<br>I. (i) – មានសារៈសំខាន់ និងងាយរងផលប៉ះពាល់ផ្នែកអេកូស៊ីស្ទែម (ឧទ្យានជាតិ ជម្រកសត្វព្រៃ ព្រៃបំរុង ទីជម្រកសត្វព្រៃ ព្រៃកោងកាង ផ្កាថ្ម តំបន់ នៅជិតកន្លែងបង្កាត់ពូជ និងត្រីពង តំបន់ស្រស់ស្អាត តំបន់ប្រវត្តិសាស្ត្រ និង វប្បធម៌ តំបន់សំបូរទៅដោយជីវៈចម្រុះ តំបន់ដែលទំនងជាលិចទឹកដោយសារកើនឡើងកម្ពស់ទឹកសមុទ្រនិងតំបន់ផ្សេងៗទៀតដូចបានពិពណ៌នា ។)<br>I. (ii) – តំបន់ស្ថិតនៅចន្លោះបន្ទាត់ទឹកជោរ និងនាច<br>II – តំបន់អភិវឌ្ឍន៍រួចរាល់រហូតដល់ ឬនៅជិតតំបន់ឆ្នេរ (ក្នុងឆ្នាំ១៩៩១) - ជាធម្មតាជាតំបន់ទីក្រុង<br>III –តំបន់ដែលមិនទទួលរងការរំខាន និងដែលមិនស្ថិតក្នុងលេខ I រឺ II: តំបន់ឆ្នេរក្នុងតំបន់ជនបទ និងតំបន់មិនទាន់អភិវឌ្ឍក្នុងតំបន់ក្រុង<br>IV – តំបន់លាតសន្ធឹងតាមតំបន់ Andaman និង Nicobar, Lakshadweep និងកោះតូចៗ លើកលែងតែក្នុងចំណាក់ថ្នាក់ I, II ឬ III ។ បទបញ្ញត្តិដែលចែងថាតើសកម្មភាពអ្វីត្រូវអនុវត្តក្នុងតំបន់នីមួយៗ ហើយការត្រួតពិនិត្យ ការអនុវត្តនិងប្រតិបត្តិគឺធ្វើឡើងដោយអាជ្ញាធរគ្រប់គ្រងតំបន់ឆ្នេររបស់រដ្ឋ ។ |

តារាងខាងលើបង្ហាញថាមានការប្រែប្រួលជាច្រើនទាក់ទងនឹង Set backដោយមានខ្លះ មិនមានន័យថាដូចគ្នាទាំងអស់នោះទេ គឺផ្អែកលើការយល់ដឹងនូវកម្រិតការហូរច្រោះប្រចាំជាមធ្យម ។ នៅក្នុងស្ថានភាពភាគច្រើនប្រការនេះនឹងមិនងាយស្រួលគណនានោះទេ ។ ភាពលំបាកនេះអាចដោះស្រាយបានតាមរយៈធ្វើការប៉ាន់ស្មានដោយជូនដំណឹងមុនបន្ទាប់ធ្វើការកែតម្រូវ ។

## ឯកសារយោងរបស់ Footnote នីមួយៗ

[1] The three illustrations are from Environmental Management of the Coastal Zone Project. 2006. **Cambodia Shoreline Management Strategy**. Ministry of Environment and Danida. pgs. 76, 81, 97

[2] ការវាយតម្លៃសហស្សវត្សរ៍ (2005)

[3] Millennium Assessment (2003)

[4] The Sustainable Scale Project (2010)

[5] TEEB The Economics of Ecosystems and Biodiversity, www.teebweb.org (2010)

[6] TEEB The Economics of Ecosystems and Biodiversity, www.teebweb.org (2010)

[7] Farber et al( 2002), Söderqvist (2004), Fredman (1997) and Söderqvist (1996)

[8] Anker, H.L., V.Nellemann, S.Svendrup-Jensen, 1998. Integrated Coastal Zone Management in Denmark. Pg 4.

# ផ្នែកទី២

## កម្រងឯកសារជាតិស្តីពីការរៀបចំផែនការយុទ្ធសាស្ត្របែងចែកការប្រើប្រាស់តំបន់ឆ្នេរសមុទ្រដើម្បីគ្រប់គ្រងគ្រោះមហន្តរាយបរិស្ថានកំពុងកើតឡើង

## ជំពូកទី ១: ស្ថានភាពទូទៅនៃតំបន់ឆ្នេរសមុទ្រប្រទេសកម្ពុជា

តំបន់ឆ្នេរសមុទ្រប្រទេសកម្ពុជាស្ថិតនៅតាមបណ្តោយខេត្តកោះកុង ព្រះសីហនុ កែប និងកំពតដែលគ្របដណ្តប់លើផ្ទៃដី១៧.២៣៧គម$^{២}$ ។ សមុទ្រកម្ពុជាមានកោះ និងប្រជុំកោះតូចធំចំនួនប្រមាណ៧២ ក្នុងនោះខេត្ត កោះកុងមានកោះ២៣ ខេត្តព្រះសីហនុមានកោះ៣៤ ខេត្តកំពតមានកោះ២ និង ខេត្តកែបមានកោះ១៣ (យុទ្ធសាស្ត្រលំហសមុទ្រ, ២០១១) ។ ខេត្តព្រះសីហនុត្រូវបានចាត់ទុកជាមជ្ឈមណ្ឌលសេដ្ឋកិច្ច និងវប្បធម៌មួយ និងមានកំពង់ផែស្វ័យ័ត្តធំជាងគេដែលបច្ចុប្បន្នអាចទទួលទំនិញឆ្លងកាត់ជាមធ្យមប្រមាណ១.៩១០.៩៧៦តោនក្នុងមួយឆ្នាំ ។




***តួលេខទី១: ស្ថានភាពតំបន់ឆ្នេរប្រទេសកម្ពុជា***

ជាមួយគ្នានោះដែរ ដោយអនុលោមតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ(UNCLOS)ចុះហត្ថលេខានៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២ នាទីក្រុងម៉ុងតេហ្គោល ប្រទេសចាម៉ៃកា កម្ពុជាមានសិទ្ធិលើអធិបតេយ្យសមុទ្រដែនដីចម្ងាយ ១២ម៉ៃល៏ តំបន់តភ្ជាប់ចម្ងាយ២៤ម៉ៃល៏ តំបន់សេដ្ឋកិច្ចផ្តាច់មុខចម្ងាយ២០០ម៉ៃល៏ ។ តំបន់ឆ្នេរកម្ពុជាសំបូរទៅដោយជីវ:ចម្រុះដូចជា: មច្ឆាសមុទ្រចំនួន៥២០ប្រភេទ បង្កង ក្តាម បង្គាចំនួន២០ប្រភេទ ឧទរចាទចំនួន៤២ប្រភេទ និងគ្រំ, លៀសចំនួន ២៤ប្រភេទ (រដ្ឋបាលជលផល, ឆ្នាំ២០១០) ។

ដីតំបន់ឆ្នេរមានលក្ខណ:ជាដីខ្សាច់ដែលអំណោយផលដល់ ដំណាំដូងប្រេង កៅស៊ូ ម្រេច ដូង ធុរេន ព្រមទាំងដំណាំហូបផ្លែ និងបន្លែច្រើនមុខផ្សេងទៀត ។ល ។ ជាពិសេសតំបន់នេះសម្បូរទៅដោយព្រៃកោងកាងព្រៃឈើប្រណិតសត្វព្រៃគ្រប់ប្រភេទទឹកធ្លាក់ឆ្នេរខ្សាច់ស្រស់ស្អាតដែលញ៉ាំងឱ្យឆ្នេរសមុទ្រកម្ពុជាក្លាយជាតំបន់អេកូទេសចរណ៍ដ៏គួរឱ្យទាក់ទាញ ។ក្រៅពីនេះសមុទ្រកម្ពុជាមានធនធានប្រេងកាត និងរ៉ែសំខាន់ៗមួយចំនួនទៀតដែលកំពុងធ្វើការរុករក និងត្រៀមធ្វើការដកហូត ។

ប្រទេសកម្ពុជាទទួលឥទ្ធិពលរបបខ្យល់មូសុងត្រូពិចដែលជាប្រភេទក្តៅហើយសើមមានសីតុណ្ហភាពមធ្យមប្រចាំឆ្នាំ ២៧$^{o}$C និងមានការផ្លាស់ប្តូរកំណកអាកាសប្រចាំឆ្នាំជាមធ្យមពី ២.០០០មម ទៅ ៤.០០០មម (ក្រសួងបរិស្ថាន, ២០០៨) ។ តំបន់ឆ្នេរមានប្រជាជនប្រហែល ៨១% រស់នៅតំបន់ជនបទ និង១៩%រស់នៅទីប្រជុំជន (JICA, ២០១០) ។ ដីកសិកម្មត្រូវបានពង្រីកប្រហែល ៥.១៩% ដែលមានការប្រែប្រួលរហូតដល់ ៣.៦៨% បើប្រៀបធៀបរវាងឆ្នាំ១៩៩៣ និងឆ្នាំ២០០២ ដែលឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរការប្រើប្រាស់ដីចេះតែកើនឡើងដែលមិនធ្លាប់មានពីមុនមក (ក្រសួងបរិស្ថាន, ឆ្នាំ២០០៧) ។ នៅពេលបច្ចុប្បន្នក្នុងខេត្តកំពតមានដីស្រែអំបិលប្រហែល ៣.៣៣៤.២៤ ហិចតា (គ្រប់គ្រងដោយរដ្ឋ: ១.៩៩៤.៣៨ ហិចតា

និងសហគមន៍: ១.៣៣៩.៨៦ ហិចតា)។ ផលិតផលអំបិលប្រចាំឆ្នាំ ក្នុងខេត្តនេះមានប្រហែលជា ៧០.០០០ ទៅ ៨០.០០០តោន។ នៅខេត្តកែបមានផលិតផលអំបិលប្រហែល២.០០០ហិចតានៃស្រែអំបិលសរុប (ក្រសួងបរិស្ថាន, ឆ្នាំ២០០៧)។ ជាក់ស្តែង ប្រទេសកម្ពុជាបានរៀបចំច្បាប់ និងគោលនយោបាយមួយចំនួនទាក់ទងនឹងការគ្រប់គ្រង និងការបែងចែកការប្រើប្រាស់ដីជាពិសេសគឺអនុវត្តនៅតំបន់ទំនាប និង ខ្ពង់រាបជាពិសេសនៅក្រោយរបបប៉ុលពតរាជរដ្ឋាភិបាលបានបែងចែកកម្មសិទ្ធិកាន់កាប់ដីឱ្យប្រជាពលរដ្ឋទូទាំងប្រទេស ប៉ុន្តែគោលនយោបាយនេះបានផ្អាកវិញដោយសារការផ្លាស់ប្តូរគោលនយោបាយរបស់រដ្ឋាភិបាលដើម្បីធានាប្រសិទ្ធភាពក្នុងការគ្រប់គ្រងដែនដី។ នៅពេលថ្មីៗនេះដោយមើលឃើញនៅការខ្វះខាតដីរបស់ប្រជាជន រដ្ឋាភិបាលបានចេញគោល នយោបាយថ្មីដើម្បីផ្តល់ដីកម្មសិទ្ធិឱ្យប្រជាពលរដ្ឋណាដែលដីប្រើប្រាស់សំរាប់ធ្វើស្រែ និងចំការចិញ្ចឹមជីវិត ទោះបីយ៉ាង ណាប្រទេសកម្ពុជាមិនទាន់មានច្បាប់ស្តីពីការបែងចែកការប្រើប្រាស់ដី និងសមុទ្រឡើយ។

## ជំពូកទី២: គោលនយោបាយ យុទ្ធសាស្ត្រ និងក្របខណ្ឌគតិយុត្តិទាក់ទងនឹងការប្រើប្រាស់ និងគ្រប់គ្រងតំបន់ឆ្នេរសមុទ្រដើម្បីដោះស្រាយនឹងគ្រោះមហន្តរាយកំពុងកើតឡើង

## ទាក់ទងនឹងវិស័យបរិស្ថាន

រាជរដ្ឋាភិបាលកម្ពុជាបានចូលជាសមាជិកនៃកិច្ចសហប្រតិបត្តិ និងព្រមព្រៀងថ្នាក់អន្តរជាតិ និងថ្នាក់តំបន់ ដើម្បីអភិវឌ្ឍន៍ដោយចិរភាព។ ផ្អែកលើកិច្ចព្រមព្រៀងទាំងនេះ ប្រខណ្ឌច្បាប់ គោលយោបាយ និងយុទ្ធសាស្ត្រមួយចំនួនត្រូវបានអនុម័តដើម្បីនាំប្រទេសឆ្ពោះទៅរកវិធីសាស្ត្រអភិវឌ្ឍន៍ដោយចិរភាពជាពិសេសក្នុងតំបន់ឆ្នេរ។

### ១. អនុសញ្ញាអន្តរជាតិ

- អនុសញ្ញាបាសែល ស្តីពីការត្រួតពិនិត្យការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ឆ្លងដែន និងការបោះបង់ចោល ក្នុងឆ្នាំ២០០១ ដែលមានគោលបំណងកាត់បន្ថយការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ឆ្លងដែន ការកាត់បន្ថយការបង្កើតសំណល់ហាមឃាត់ដឹកជញ្ជូនសំណល់គ្រោះថ្នាក់ទៅប្រទេសដែលខ្វះសមត្ថភាពក្នុងការបោះចោល ដោយមិនធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន
- អនុសញ្ញាអន្តរជាតិ ស្តីពី ការប្រយុទ្ធនឹងវាលរហោស្ថានក្នុងប្រទេសដែលទទួលរងនូវគ្រោះរាំងស្ងួត និង/រឺវាលរហោស្ថាន ជាពិសេសទ្វីបអាហ្វិច ទីក្រុងប៉ារីស, ១៩៩៤ (ហត្ថលេខាក្នុងឆ្នាំ ១៩៩៤, អនុម័តក្នុង ឆ្នាំ១៩៩៧)
- អនុសញ្ញា ស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិនូវប្រភេទសត្វ និងរុក្ខជាតិជិតផុតពូជ Washington, ក្នុង ឆ្នាំ១៩៧៣ (ហត្ថលេខាក្នុងឆ្នាំ ១៩៧៣, អនុម័តក្នុងឆ្នាំ ១៩៩៧)

- វិធីសារម៉ុងត្រេអាល់ ស្តីពី សារធាតុដែលបំផ្លាញស្រទាប់អូសូន (១៩៨៧)
- អនុសញ្ញា ស្តីពី តំបន់ដីសើមដែលមានសារៈសំខាន់អន្តរជាតិ ជាពិសេស ជំរកសត្វបក្សីទឹក, តំបន់រាមសា ឆ្នាំ១៩៧១ (ហត្ថលេខាក្នុងឆ្នាំ១៩៩៩, ក្រម ២២ ខែតុលា ឆ្នាំ១៩៩៦)
- អង្គភាពសម្របសម្រួលសមុទ្រអាស៊ី-បូព៌ា (COBSEA) ក្នុងឆ្នាំ ១៩៩៥
- អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ, ទីក្រុងញូយ៉ក ឆ្នាំ១៩៩២ (ហត្ថលេខា ១៩៩២ អនុម័តឆ្នាំ១៩៩៥, ក្រម ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៦)
- កិច្ចព្រមព្រៀងផលិតផលឈើត្រូពិកអន្តរជាតិនៅទីក្រុងហ្សឺណែវ (ហត្ថលេខ ឆ្នាំ១៩៩៥)
- អនុសញ្ញា ស្តីពីជីវៈចម្រុះនៅទីក្រុង Rio de Janeiro, ឆ្នាំ១៩៩២ (ហត្ថលេខាក្នុងឆ្នាំ១៩៩២, អនុម័ត ឆ្នាំ១៩៩៥)
- វិធីសារ**កាតាហ្គាណា** ស្តីពីជីវៈសុវត្ថិភាព ក្នុងថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៣ ដែលប្រទេសកម្ពុជាក្លាយ ជាប្រទេសទី២ បន្ទាប់ពីប្រទេសម៉ាឡេស៊ី នៅក្នុងតំបន់អាស៊ី-បូព៌ាជាសមាជិកក្នុងពិធីសារនេះ
- អនុសញ្ញាអន្តរជាតិ ស្តីពីការការពារការបំពុលពីកប៉ាល់ ឆ្នាំ១៩៧៣ និងពិធីសារ ឆ្នាំ១៩៧៨
- អនុសញ្ញាអន្តរជាតិ ស្តីពីនិតិសមុទ្រ (UNCLOS)ក្នុងឆ្នាំ១៩៩៤
- អនុសញ្ញាអន្តរជាតិ ស្តីពីការពិន័យលើការបំពុលដោយការកំពប់ប្រេងឆ្នាំ ១៩៦៩ និង
- អនុសញ្ញាការការពាររុក្ខជាតិអន្តរជាតិ(IPPC)ក្នុងគោលបំណងដើម្បីធានានូវសកម្មភាពរួម និងមានប្រសិទ្ធភាព ដើម្បីការពារការរីករាលដាល និងការប្រើប្រាស់ថ្នាំសំលាប់រុក្ខជាតិ និងផ្សព្វផ្សាយវិធានការណ៍ ដើម្បីត្រួតពិនិត្យ ហើយប្រទេសកម្ពុជាបានអនុម័តអនុសញ្ញានេះក្នុងឆ្នាំ១៩៥២ ។

## ២. កិច្ចព្រមព្រៀង និងកិច្ចសហការថ្នាក់តំបន់

- កិច្ចព្រមព្រៀងហៃគួ នាថ្ងៃទី១៥ ធ្នូ ឆ្នាំ២០០៦ ដែលជាថ្ងៃចុះហត្ថលេខារបស់ប្រទេសទាំង ១១ ហើយបង្កើត PEMSEA ជាផ្លូវការក្នុងការរៀបចំសម្របសម្រួលយន្តការតំបន់សម្រាប់អនុវត្តន៍ SDS-SEA
- កម្មវិធីថ្នាក់តំបន់ASEANស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ (២០០៤-២០១០) និង (កិច្ចព្រមព្រៀង ASEAN ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងវិធានការណ៍សង្គ្រោះបន្ទាន់ ក្នុងឆ្នាំ២០០៥)
- សេចក្តីប្រកាស នៃកិច្ចសហការតំបន់ **ពុត្រាចាយ៉ា (Putrajaya)** សម្រាប់ការអភិវឌ្ឍដោយ ចីរភាព នៃសមុទ្រអាស៊ី-បូព៌ា នាថ្ងៃទី១២ ខែធ្នូ ឆ្នាំ ២០០៣
- ផែនការសកម្មភាពយុទ្ធសាស្ត្រ ASEAN លើបញ្ហាបរិស្ថានឆ្នាំ ១៩៩៩-២០០៤
- ផែនការសហប្រតិបត្តិការ ASEAN ស្តីពីការបំពុលឆ្លងដែន អនុម័តនៅខែមិថុនា ឆ្នាំ១៩៩៥ និង ASEAN

ឆ្នាំ១៩៩៥ដែលគ្របដណ្តប់លើការបំពុលបរិយាកាស និងប្រភពចេញពីកប៉ាល់និងការដឹកជញ្ជូនសំណល់គ្រោះថ្នាក់

- អនុស្សារណៈយោគយល់ ស្តីពីកិច្ចការពារ និងអភិរក្សអណ្តើកសមុទ្រ ក្នុងឆ្នាំ ១៩៩៧
- កិច្ចព្រមព្រៀង ស្តីពីការអភិរក្សធម្មជាតិ និងធនធានធម្មជាតិ (១៩៨៥)
- អនុស្សារណៈនៃការយោគយល់ថ្នាក់រដ្ឋមន្ត្រីអាស៊ាន ស្តីពីកិច្ចសហប្រតិបត្តិការនេសាទ ក្នុងឆ្នាំ ១៩៨៣
- សេចក្តីប្រកាសទីក្រុងម៉ានីល (Manila) ស្តីពីបរិស្ថានអាស៊ាន ក្នុងឆ្នាំ ១៩៨១
- ផែនការសកម្មភាពយុទ្ធសាស្ត្រអាស៊ាន ស្តីពីបរិស្ថានឆ្នាំ១៩៩៤ និងស្ថិតនៅក្រោមយុទ្ធសាស្ត្រទី៦ ដើម្បីលើកកម្ពស់កិច្ចការពារ និងគ្រប់គ្រងតំបន់ឆ្នេរ និងធនធានសមុទ្រ

## ៣. ច្បាប់ និងបទបញ្ញត្តិស្តីពីការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ

ដើម្បីឆ្លើយតបទៅនឹងរដ្ឋធម្មនុញ្ញ មាត្រាទី ៥៩ និងមូលដ្ឋានច្បាប់សម្រាប់អនុវត្ត SDS-SEA រដ្ឋាភិបាលបានអនុម័ត និងចែងនូវ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាសជាច្រើន ក្នុងកិច្ចការពារ គ្រប់គ្រង និង ការប្រើប្រាស់ធនធាន ធម្មជាតិ និងធនធានរ៉ែ និងបរិស្ថានប្រកបដោយចីរភាព។ បទដ្ឋានច្បាប់មួយចំនួន ដែលបានបង្កើតឡើងរួមមាន៖

### ក. ព្រះរាជក្រឹត្យ

នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ព្រះបាទសម្តេចនរោត្តមសីហនុនៃព្រះរាជាណាចក្រកម្ពុជាចេញផ្សាយនូវព្រះរាជក្រឹត្យ ស្តីពីការបង្កើតនិងកំណត់តំបន់ការពារ ចំនួន២៣ កន្លែងគ្របដណ្តប់លើផ្ទៃដីចំនួន ៣.៣ លាន ហិចតាស្មើនឹង ១៨.២៣ ភាគរយ(%) នៃផ្ទៃដីសរុប។ គោលបំណងនៃព្រះរាជក្រិត្យនេះដើម្បីដោះស្រាយនូវដំណើរការគ្រប់គ្រងធនធានធម្មជាតិដោយស្របគ្នាទៅនឹងបញ្ជីឈ្មោះរបស់អង្គការសហប្រជាជាតិស្តីពីឧទ្យានជាតិ និងតំបន់ការពារ។ ព្រះរាជក្រឹត្យនេះកំណត់នូវតួនាទីរបស់ក្រសួងបរិស្ថានក្នុងការគ្រប់គ្រងផែនការអភិវឌ្ឍន៍ និងគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ ស្របតាមកិច្ចការពារនូវបរិស្ថានដែនដី តំបន់ដីសើមនិងតំបន់ឆ្នេរសមុទ្រ។ តំបន់ការពារចែកចេញជា៤ គឺ៖ **ឧទ្យានជាតិ ដែនជម្រកសត្វព្រៃ តំបន់ការពារទេសភាព និង តំបន់ប្រើប្រាស់ច្រើនយ៉ាង** ។

### ខ. ច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ (១៩៩៦)

ច្បាប់នេះត្រូវបានរៀបចំដោយក្រសួងបរិស្ថានពីឆ្នាំ១៩៩៣ ដល់ឆ្នាំ១៩៩៥ និងឆ្លងដោយរដ្ឋសភាជាតិនៅ ថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៦។ ច្បាប់នេះគឺជាឧបករណ៍ច្បាប់កំពូលដែលបញ្ជាក់ច្បាស់អំពីគោលបំណងឆ្ពោះទៅរកកិច្ចការពារបរិស្ថាន និងអភិរក្សធនធានធម្មជាតិដូចមានខាងក្រោម៖

- ដើម្បីការពារ និងលើកកម្ពស់គុណភាពបរិស្ថាន និងសុខភាពសាធារណៈតាមរយៈការការពារ ការកាត់បន្ថយ និងត្រួតពិនិត្យប្រភពបំពុលដែលស្គាល់ និងមិនស្គាល់ចំណុចគោលដៅ

- ដើម្បីវាយតម្លៃនូវផលប៉ះពាល់បរិស្ថាន នៃគម្រោងស្នើសុំមុនពេលចេញសេចក្ដីសំរេចដោយ រាជរដ្ឋាភិបាល
- ដើម្បីធានាការអភិរក្ស អភិវឌ្ឍ គ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាពនៅប្រទេសកម្ពុជា
- ដើម្បីលើកទឹកចិត្ត និងធានាទៅបានកាចូលរួមជាសាធារណៈក្នុងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ និង
- ដើម្បីបង្កាបរាល់សកម្មភាពដែលបណ្ដាលអោយបំផ្លាញបរិស្ថាន ។

## គ. ច្បាប់ ស្ដីពីតំបន់ការពារ (២០០៨)

ច្បាប់នេះអនុវត្តន៏នៅក្នុងតំបន់ការពារកំណត់ដោយព្រះរាជក្រឹត្យស្ដីពីការបង្កើតនិងកំណត់តំបន់ការពារនៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ និងច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិដែលប្រកាសអោយប្រើដោយព្រះរាជក្រឹត្យ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦។

## ឃ. ច្បាប់ ស្ដីពីជីវៈសុវត្ថភាព (ខែកុម្ភៈ ឆ្នាំ២០០៨)

ច្បាប់នេះមានគោលបំណងដើម្បីៈ

- ទប់ស្កាត់ផលបះពាល់អវិជ្ជមានលើអភិរក្សជីវៈចម្រុះនិងធនធានធម្មជាតិក្នុងព្រះរាជាណាចក្រកម្ពុជាបណ្ដាលមកពីដឹកជញ្ជូនឆ្លងដែន ការលើកដាក់ ការផ្ទេរ ការរក្សាទុក និងបោះបង់ចោលសរីរាង្គកែ ច្នៃរស់បានមកពីបច្ចេកវិទ្យាជីវសាស្ត្រទំនើប ។
- ធានានូវប្រសិទ្ធភាពអភិរក្សជីវៈចម្រុះនិងការប្រើប្រាស់ធនធានជីវៈចម្រុះប្រកបដោយចីរភាពដោយគិតគូរពីហានិភ័យលើសុខភាពមនុស្ស
- ផ្ដល់ដំណើរការប្រកបដោយតម្លាភាពមួយសម្រាប់បង្កើត និងពិនិត្យមើលសេចក្ដីសំរេចស្ដីពី សរីរាង្គកែ ច្នៃរស់ និងសកម្មភាពនិងដំណើរការទាក់ទង
- អភិវឌ្ឍការអប់រំជីវៈបច្ចេកទេសនៅពេលដែលធ្វើការទប់ស្កាត់ហានីភ័យសុខភាព និងបរិស្ថានរួមជាមួយនឹងការប្រើប្រាស់ និងការបញ្ចេញសរីរាង្គកែច្នៃរស់
- អនុវត្តពិធិសារ Cartagena ស្ដីពីជីវៈសុវត្ថភាពនៃអនុសញ្ញាស្ដីពីជីវៈចម្រុះដែលប្រទេសកម្ពុជាជាសមាជិកនៃអនុសញ្ញា ។

***ក្រៅពីច្បាប់ និងបទបញ្ញតិខាងលើនៅមានឧបករណ៍ច្បាប់សំខាន់ៗខ្លះៗទៀតពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាន និងអភិរក្សធនធានធម្មជាតិរួមមានៈ***

- ច្បាប់ ស្ដីពីការគ្រប់គ្រងរដ្ឋបាលនៃរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ (២០០៨)

- ច្បាប់ ស្តីពីគ្រប់គ្រងធនធានទឹក (២០០៧)
- ច្បាប់ ស្តីពីស្តង់ដាប្រទេសកម្ពុជា (២០០៧)
- ច្បាប់ ស្តីពីជលផល (២០០៦)
- ច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោកប្រទេសកម្ពុជា (ខែធ្នូ ឆ្នាំ២០០៦)
- ច្បាប់ ស្តីពីព្រៃឈើ (២០០២)
- ច្បាប់ ស្តីពីការគ្រប់គ្រងធនធានរ៉ែ និងការធ្វើអាជីវកម្មរ៉ែ (២០០១)
- ច្បាប់ភូមិបាល (២០០១)
- ច្បាប់ ស្តីពីរដ្ឋបាលមូលដ្ឋាន (ខែមីនា ឆ្នាំ២០០១)
- ច្បាប់ ស្តីពីការគ្រប់គ្រងគុណភាព និងសុវត្ថិភាពផលិតផលនិងសេវាកម្ម (ខែមិថុនាឆ្នាំ២០០០)
- ច្បាប់ ស្តីពីកិច្ចការពារកេរ្តិ៍ដំណែលវប្បធម៌ (ខែមករា ឆ្នាំ១៩៩៦)
- ច្បាប់ ស្តីពីការគ្រប់គ្រងដែនដី នគរូបណីយកម្ម និងសំណង់ (១៩៩៤) និង
- ច្បាប់ ស្តីពីវិនិយោគទុនកម្ពុជា ថ្ងៃទី ៤ ខែសីហា ឆ្នាំ១៩៩៤ ។
- ព្រះរាជក្រឹត្យ និងអនុក្រឹត្យស្តីពីការអភិរក្សបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព
- ព្រះរាជក្រឹត្យលេខ នស\រកត\០២០២\០៤០ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០២ និង ព្រះរាជក្រឹត្យត្រូវបានកែសម្រួលលេខ នស\រកត\០៨០៤\២៦៣ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ នាថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៤
- អនុក្រឹត្យ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងវត្ថុភាពលំហសមុទ្រ(២០០៩)
- អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំណល់សុខាភិបាល (២០០៨)
- អនុក្រឹត្យលេខ៦១អនក្រ.បកស្តីពីការបង្កើតគណៈកម្មាធិការឃុំ/សង្កាត់ដើម្បីគ្រប់គ្រងគ្រោះមហន្តរាយ ក្នុងព្រះរាជាណាចក្រកម្ពុជា (ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៦)
- អនុក្រឹត្យ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងប្រែប្រួលអាកាស (២០០៦)
- អនុក្រឹត្យ ស្តីពីសុវត្ថិភាពកំពង់ផែ និងកប៉ាល់ (២០០៦)
- អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ (ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០០៥)
- អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសារធាតុបំផ្លាញស្រទាប់អូហ្សូន (ខែមីនា ឆ្នាំ២០០៥)
- អនុក្រឹត្យ ស្តីពីសហគមន៍ព្រៃឈើ ( ថ្ងៃទី២ ខែធ្នូ ឆ្នាំ២003)

- អនុក្រឹត្យ ស្តីពីការបង្កើតព្រៃការពារ អភិរក្សធនធានធម្មជាតិ តំបន់ការពារជីវិតសត្វព្រៃ និងព្រៃការពារសម្រាប់អភិរក្សជីវៈចម្រុះ (២០០២ និង២០០៤)
- អនុក្រឹត្យស្តីពីការរៀបចំនិងតួនាទីនៃគណៈកម្មាធិការសុរិយោដីសម្រាប់ដំណោះស្រាយទំនាស់ដីធ្លីក្រៅប្រព័ន្ធតុលាការ (ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២)
- អនុក្រឹត្យ ស្តីពីនីតិវិធីក្នុងការបង្កើតផែនទីនិទស្សន៍សុរិយោដី និងការចុះបញ្ជីដីធ្លី (ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២)
- អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងរំខានដោយសំលេង (ខែកក្កដា ឆ្នាំ២០០០)
- អនុក្រឹត្យ ស្តីពីការបំពុលទឹក (១៩៩៩)
- អនុក្រឹត្យ ស្តីពីការគ្រប់គ្រង និងរដ្ឋបាល និងការប្រើប្រាស់ដីកសិកម្ម (ខែមេសា ឆ្នាំ១៩៨៥)
- អនុក្រឹត្យ ស្តីពីការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន (EIA) (ខែកញ្ញា ឆ្នាំ១៩៩៩)
- អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំណល់រឹង (ខែមេសា ឆ្នាំ១៩៩៩)
- អនុក្រឹត្យ ស្តីពីផែចំណតនាវាសម្រាប់នាវាបរទេស (១៩៨៣)
- អនុក្រឹត្យ ស្តីពីការបង្កើតគណៈកម្មាធិការបច្ចេកទេសអន្តរក្រសួងសម្រាប់ការរុករក និងការធ្វើអាជីវកម្ម ប្រេងកាត (១៩៩៥)
- អនុក្រឹត្យ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់អភិវឌ្ឍ និងអនុវត្តគោលនយោបាយព្រៃឈើ
- អនុក្រឹត្យ ស្តីពីនីតិវិធីរៀបចំផែនការប្រើប្រាស់ដីធ្លីភូមិបាល
- អនុក្រឹត្យ ស្តីពីកសិករអ្នកប្រើប្រាស់ទឹក។

## ៤. គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការជាតិគ្រប់គ្រងតំបន់ឆ្នេរ

មានគោលនយោបាយ យុទ្ធសាស្ត្រ និងសកម្មភាព ជាច្រើនត្រូវបានបង្កើតឡើងដូចខាងក្រោមៈ

### ក. ផែនការសកម្មភាពបរិស្ថានជាតិ (១៩៩៨-២០០២), (២០០៣-២០០៨) និង (៣ព្រាង ឆ្នាំ២០១១-២០១៥)

ផែនការសកម្មភាពបរិស្ថានគឺជាឯកសារសំខាន់មួយក្នុងការកំណត់បញ្ហាសំខាន់ៗ និងសកម្មភាពឆ្លើយតបដែលគ្របដណ្តប់លើវិស័យចំនួន៦: ព្រៃឈើ,នេសាទនិងកសិកម្មតំបន់លិចទឹកក្នុងតំបន់ទន្លេសាប, ជលផលតំបន់ឆ្នេរ, តំបន់ការពារ និងជីវៈចម្រុះ, ការអភិវឌ្ឍថាមពល និងការគ្រប់គ្រងសំណល់ទីក្រុង។ ប៉ុន្តែ វិស័យផ្សេងៗទៀតនឹងដាក់បញ្ចូលនៅពេលដែលគិតជាបញ្ហាសំខាន់ដូចជាប្រែប្រួលអាកាសធាតុ និងបញ្ហាបរិស្ថានផ្សេងៗទៀត។ ផែនការសកម្មភាពនេះនឹងត្រូវបានអនុវត្តរៀងៗខ្លួន។ ថ្មីៗនេះ ក្រសួងបរិស្ថានកំពុងធ្វើពង្រាងលើផែនការ សកម្មភាពបរិស្ថានថ្មីរយៈពេល៥ឆ្នាំ (២០១១-២០១៥)។

**ខ. ផែនការយុទ្ធសាស្ត្របរិស្ថានជាតិ (២០០១-២០០៣), (២០០៤-២០០៨), និង(២០០៩-២០១៣)**

ផែនការយុទ្ធសាស្ត្របរិស្ថានគឺចេញផ្សាយដោយក្រសួងបរិស្ថានតាមឆ្នាំនីមួយៗ ២០០១- ២០០៤ និង ២០០៩។ ផែនការយុទ្ធសាស្ត្រទាំងនេះពិនិត្យឡើងវិញនូវរាល់បទបញ្ញតិមានស្រាប់ កំណត់បញ្ហា និងទាក់ពាក់ព័ន្ធសំខាន់ៗ និងកម្មវិធីសកម្មភាពលំអិតផ្សេងៗសម្រាប់កំឡុងឆ្នាំ (២០០១-២០០៣), (២០០៤-២០០៨), (២០០៩-២០១៣) ដើម្បីធានាការកែលំអនិងគ្រប់គ្រងបរិស្ថានប្រកបដោយចិរភាពដើម្បីបុព្វហេតុសុខភាព និងសង្គម បរិស្ថានទាំងមូល។

**គ. យុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចម្រុះជាតិ (២០០២)**

យុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចម្រុះជាតិ (NBSAP) ត្រូវបានចេញផ្សាយអោយប្រើប្រាស់ដើម្បីពង្រឹងការពារនិងគ្រប់គ្រងជីវៈចម្រុះជាតិដើម្បីធានាថាប្រទេសកំពុងរអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ខ្លួនដោយមិនព្រងើយកន្តើយនូវទស្សនៈការអភិវឌ្ឍប្រកបដោយចិរភាពនោះទេ។ ម្យ៉ាងវិញទៀត ប្រទេសកម្ពុជាកំពុងស្ថិតនៅក្នុងការពិចារណាដើម្បីបង្កើតច្បាប់ស្តីពីតំបន់ការពារ និងអភិរក្សជីវៈចម្រុះ ។

**ឃ. ផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការគ្រប់គ្រងការបំពុលពីដីគោក (២០០៦-២០១០)**

ផែនការគ្រប់គ្រងជាយុទ្ធសាស្ត្រដោយផ្អែកលើការបំពុលពីដីគោក មានគោលដៅបង្កើតព័តិមាន និង ទិន្នន័យជាមូលដ្ឋានពាក់ព័ន្ធនឹងប្រភពនៃការគ្រប់គ្រងការបំពុលពីដីគោក រៀបចំ និងអនុវត្តផែនការដើម្បីការពារការបំពុលពីដីគោក និងពង្រឹងការរៀបចំ និងគ្រប់គ្រងស្ថាប័ន ព្រមទាំងរៀបចំ និងពង្រឹងការគ្រប់គ្រងកម្មវិធីមូលនិធិ។

**ង. យុទ្ធសាស្ត្រគ្រប់គ្រងឆ្នេរសមុទ្រកម្ពុជា** (shoreline) **(២០០៦)**

គោលបំណងនៃយុទ្ធសាស្ត្រគ្រប់គ្រងឆ្នេរសមុទ្រ (SMS)គឺដើម្បីលើកកម្ពស់ការយល់ដឹងដល់ប្រជាជន កម្ពុជា មន្ត្រីគ្រប់ជាន់ថ្នាក់ និស្សិត សាស្ត្រាចារ្យ គ្រូបង្រៀន ភ្នាក់ងារជាតិ និងអន្តរជាតិលើបញ្ហាទាំងឡាយ វិធានការណ៍ច្បាប់ និងបទបញ្ញតិពាក់ព័ន្ធលើការគ្រប់គ្រងតំបន់ឆ្នេរនៅកម្ពុជា និងការផ្តល់អនុសាសន៍ក្នុងការគ្រប់គ្រងឆ្នេរសមុទ្រអោយបានល្អធានាចិរភាពនៃធនធានធម្មជាតិ និងបរិស្ថានតំបន់ឆ្នេរព្រះរាជាណាចក្រកម្ពុជា។ គោលបំណងជាក់លាក់នៃការគ្រងគ្រងតំបន់ឆ្នេរសមុទ្រ មានចំណុចសំខាន់២: ១). ដើម្បីត្រួតពិនិត្យ និងគ្រប់ គ្រងការពារឆ្នេរ ២). ការពារឆ្នេរតាមរយៈការកំណត់តំបន់ និងគោលការណ៍ណែនាំការអភិវឌ្ឍសមស្រប។

**ច. ផែនការសកម្មភាពគ្រប់គ្រងបរិស្ថានតំបន់ឆ្នេរ (២០០៧-២០១១)**

ផែនការនេះរៀបចំឡើងដើម្បីបង្ហាញពីទស្សនៈនៃដំណើរការគ្រប់គ្រងចម្រុះតំបន់ឆ្នេរក្នុងការរៀបចំផែនការនិងសេចក្តីសំរេចរួមលើសកម្មភាពពហុវិន័យជាពិសេសក្នុងវិស័យព្រៃឈើ ជលផល សំណល់រឹង និងរាវព្រមទាំងផែនការប្រើប្រាស់ដីតំបន់ឆ្នេរ។

**ឆ. គោលការណ៍ណែនាំ និងគោនយោបាយជាតិ ស្ដីពីការប្រើប្រាស់សសារធាតុសំអាតប្រេងកំពប់នៅកម្ពុជា (២០០៨)**

ប្រទេសកម្ពុជាបង្កើតគោលនយោបាយ និងគោលការណ៍ណែនាំជាតិ ស្ដីពីការប្រើប្រាស់សារធាតុសំអាត ប្រេងកំពប់ ដើម្បីផ្ដល់នូវការគាំទ្រផ្នែកបច្ចេកទេសដើម្បីពង្រឹងការអនុវត្តផែនយថាភាពក្នុងការឆ្លើយតបទៅនឹងប្រេងកំពប់នៅប្រទេស កម្ពុជា។ ម្យ៉ាងទៀត គោលការណ៍ណែនាំនេះគឺរៀបចំឡើងដើម្បីសម្រួល និងណែនាំការសំរេចចិត្តភ្លាម១លើការប្រើប្រាស់ សារធាតុសំអាតប្រេងកំពប់ នៅពេលមានឧបទ្ទវហេតុកំពប់ប្រេងកើតមានឡើង។

**ជ. ក្របខណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងជលផល (២០១០-២០១៩)**

ដើម្បីធានាឱ្យមានចីរភាពត្រីនៅកម្ពុជាក្របខណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលត្រូវបានរៀបចំ ដើម្បីដាក់ចេញនូវចក្ខុវិស័យរដ្ឋាភិបាលលើអនាគតនៃការគ្រប់គ្រងវិស័យជលផលនិងរៀបរាប់នូវទិសដៅដែលគួរតែសម្រេចបានដើម្បីធានាកំណើនត្រីនៅក្នុងដែនទឹកប្រទេសកម្ពុជាទាំងទឹកប្រៃនិងទឹកសាប និងប្រព័ន្ធអេកូឡូស៊ីទាំងមូល។ យុទ្ធសាស្ត្រមានគោលបំណងផង ដែរក្នុងការគាំទ្រការសំរេចអោយបាននូវគោលដៅអភិវឌ្ឍ សហស្សវត្សកម្ពុជា ផែនការយុទ្ធសាស្ត្រជាតិ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងការគោរពតាមច្បាប់ជលផល។ យុទ្ធសាស្ត្រនេះបញ្ជាក់យ៉ាងច្បាស់នូវការប្ដេជ្ញាចិត្តយ៉ាងរឹងមាំរបស់រដ្ឋាភិបាលដើម្បីការពារ និង អភិរក្សប្រភេទកម្រ និងងាយរងគ្រោះកុំអោយផុតពូជ និងការពារកុំឱ្យមានការជ្រាបចូលរឺនាំចូលនូវ ប្រភេទ សត្វចម្រៃទៅក្នុងដែនទឹកកម្ពុជា។

***ក្រៅពីនេះនៅមានគោលនយោបាយ កម្មវិធី និងវិធានការផ្សេង១ទៀត ស្ដីពីការគ្រប់គ្រងធនធានធម្មជាតិ និង បរិស្ថានដែលបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា រួមមានៈ***

- កម្មវិធីព្រៃឈើជាតិ (២០១០)
- គោលនយោបាយជាតិស្ដីពី ការចុះបញ្ជី និងសិទ្ធិក្នុងការប្រើប្រាស់ដីធ្លីនៃសហគមន៍ជនជាតិដើមភាគតិច (២០០៩)
- គណៈកម្មការស្ដីពីការត្រួតពិនិត្យនិងវាយតម្លៃដើម្បីបង្ក្រាបការរុករានដីចូលទៅក្នុងដីព្រៃកោងកាង និងការចាប់យកតំបន់ឆ្នេរបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា (២០០៥) (សេចក្ដីសំរេចលេខ ២៨ស.សរ)
- ផែនការសកម្មភាពយុទ្ធសាស្ត្រជាតិ (SNAP) សម្រាប់កាត់បន្ថយគ្រោះមហន្តរាយ (២០០៨-២០១៣)
- ការបង្កើនការអនុវត្តកម្មវិធីសមាហរណកម្មគ្រប់គ្រងតំបន់ឆ្នេរ (ICM) ក្នុងខេត្តព្រះសីហនុនាអំឡុងឆ្នាំ ២០០៨-២០១១
- គោលការណ៍ណែនាំការអភិវឌ្ឍអេកូទេសចរណ៍ជាតិក្នុងតំបន់ឆ្នេរ (២០០៧)
- ផែនការយុទ្ធសាស្ត្រសម្រាប់វិស័យធនធានទឹក (២០០៦-២០១០)
- កម្មវិធីសកម្មភាពជាតិបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (NAPA) (២០០៦)

- គោលនយោបាយជាតិវិស័យជលផល (២០០៥)
- គោលដៅជាតិលើសុវត្ថិភាពទឹកឆ្នាំ២០០៥-២០១៥
- ផែនការសកម្មភាពជាតិសម្រាប់ការគ្រប់គ្រងថ្មប៉ប្រះទឹក និងស្មៅសមុទ្រ (២០០៦-២០១៥)
- គោលនយោបាយជាតិ ស្ដីពីការគ្រប់គ្រងធនធានទឹក (២០០៤)
- ផែនការមេសម្រាប់ការអភិវឌ្ឍទេសចរណ៍នៅតំបន់ឆ្នេរសម្រាប់យន្តការការពង្រីក និងបង្កើតវិស័យទេសចរណ៍ ខែមិថុនា ២០០៤
- សេចក្ដីប្រកាសរួមរវាងក្រសួងក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន លេខ៨០ ស្ដីពី ការគ្រប់គ្រងសំណល់ (២៥ កុម្ភៈ ២០០៣)
- គោលនយោបាយជាតិ ស្ដីពីការផ្គត់ផ្គង់ទឹក និងអនាម័យ (២០០៣)
- យុទ្ធសាស្ត្រក្របខ័ណ្ឌគ្រប់គ្រងគោលនយោបាយដីធ្លី (២០០២)
- គោលនយោបាយជាតិវិស័យព្រៃឈើ (២០០២)
- គោលនយោបាយដីធ្លីជាតិ (២០០១)
- ផែនការសកម្មភាពជាតិតំបន់ដីសើម (១៩៩៩)
- ផែនការយុទ្ធសាស្ត្រសម្រាប់ប្រតិកម្មតប និងការកាត់បន្ថយការបំពុលសមុទ្រពីដីកោះ
- យុទ្ធសាស្ត្រអភិវឌ្ឍន៍អេកូទេសចរណ៍ ក្នុងព្រះសីហនុ "ឧទ្យានជាតិរាម"
- យុទ្ធសាស្ត្រអភិវឌ្ឍន៍អេកូទេសចរណ៍ ក្នុងខេត្តកែប
- យុទ្ធសាស្ត្រអភិវឌ្ឍន៍អេកូទេសចរណ៍ ដែនជំរកសត្វព្រៃពាមក្រសោប
- យុទ្ធសាស្ត្រវាយតម្លៃបរិស្ថានសម្រាប់រៀបចំផែនការអភិវឌ្ឍន៍ក្នុងការគ្រប់គ្រងធនធានតំបន់ឆ្នេរក្នុង ខេត្តកែប ក្រុងព្រះសីហនុ កំពត និងកោះកុង
- ផែនការយថាហេតុ ឆ្លើយតបទៅនឹងការកំពប់ប្រេង

## ៥. គម្រោងទាក់ទងនឹងការគ្រប់គ្រងតំបន់ឆ្នេរ

### ៥.១ គម្រោងគ្រប់គ្រងតំបន់ឆ្នេរគាំទ្រដោយអង្គការ DANIDA :

គម្រោងគ្រប់គ្រងតំបន់ឆ្នេរប្រទេសកម្ពុជាត្រូវបានអនុវត្តក្នុងឆ្នាំ១៩៩៧ដោយមានការគាំទ្រពីភ្នាក់ងារ អភិវឌ្ឍន៍អន្តរជាតិដាណឺម៉ាក់ (DANIDA) ក្រោមកម្មវិធីបរិស្ថាន និងធនធានធម្មជាតិ។ គោលបំណងនៃគម្រោងនេះគឺ ដើម្បីធានា "ការអភិវឌ្ឍដោយចីរភាពនៃតំបន់ឆ្នេរសមុទ្រប្រទេសកម្ពុជារួមមាន កិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធាន

តំបន់ឆ្នេរដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនមូលដ្ឋាន និងសុខមាលភាពជាតិ។ គម្រោងនេះចែកចេញជាបីជំហានបន្តបន្ទាប់គ្នា:

- ***ជំហានទី១***: **ខែឧសភា ១៩៩៧ -មីនា ២000**: រៀបចំឡើងដើម្បីអភិវឌ្ឍជំនាញមូលដ្ឋានក្នុងការគ្រប់គ្រងតំបន់ឆ្នេរនៅថ្នាក់ខេត្ត ក៏ដូចជាការបង្កើតនូវមូលដ្ឋានទិន្នន័យរូបវ័ន្ត ស្តីពីតំបន់ឆ្នេរប្រទេសកម្ពុជា និងរៀបចំនូវផែនការគាំទ្ររយៈពេលវែងដើម្បីគ្រប់គ្រងតំបន់ឆ្នេរសមុទ្រ។

- ***ជំហានទី២*** **ខែមីនា ២000-២00២**: ដើម្បីលើកកម្ពស់ សមត្ថភាពរដ្ឋាភិបាលអោយចូលរួមក្នុងការគ្រប់គ្រងតំបន់ឆ្នេរដើម្បីធានាថាក្រុមការងារ ថ្នាក់ខេត្តកាន់តែសកម្ម និងចូលរួមច្រើនដើម្បីធ្វើការសម្របសម្រួលការចរចា និងរៀបចំផែនការច្បាប់ រដ្ឋបាល និងសកម្មភាពបច្ចេកទេសដើម្បីពង្រឹងការគ្រប់គ្រងបរិស្ថាន និងលើកកម្ពស់ជីវភាពរស់នៅក្នុងតំបន់ ឆ្នេរផងដែរ។ ជំហាននេះមានបំណងដើម្បីបង្កើតសហគមន៍មួយ រឺពីរនៅក្នុងខេត្តតំបន់ឆ្នេរនីមួយៗដើម្បីរៀបចំគម្រោងសាកល្បងដើម្បីធ្វើវិនិយោគក្នុងការអភិវឌ្ឍបរិស្ថានដោយចីរភាព និងធ្វើឱ្យសេដ្ឋកិច្ចសង្គមមានដំណើរការជាមួយនឹងសកម្មភាពសេដ្ឋកិច្ចថ្មី ឬកែលំអបច្ចេកវិទ្យាដើម្បីបង្កើនជីវភាពរស់នៅរបស់ក្រុមងាយរងគ្រោះបំផុត។

- ***ជំហានទី៣*** **ខែសីហា ២00២-២00៧**: ដើម្បីគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិពីជំហានដំបូងជំហាននេះបង្កើតឡើងដើម្បីពង្រឹងសមត្ថភាពការគ្រប់គ្រងបរិស្ថានក្នុងតំបន់ឆ្នេរដើម្បីអោយយើងអាចបង្កើនការយល់ដឹង និង ការអប់រំស្តីពីការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថានក្នុងតំបន់ឆ្នេរ។ ជំហាននេះរួមចំណែកដើម្បីកែលំអការគ្រប់គ្រងធនធានធម្មជាតិផ្អែកលើសហគមន៍ និងដោយពង្រឹងគោលនយោបាយលើកកម្ពស់ជីវភាពរស់នៅប្រកបដោយចីរភាព ព្រមទាំងពង្រឹងក្របខ័ណ្ឌ និងការអនុវត្តច្បាប់សម្រាប់ EMCZ។

### ៩.២ គម្រោងគ្រប់គ្រងធនធានព្រៃកោងកាងដោយមានការចូលរួម (PMMR)

ដោយសារតែធនធានធម្មជាតិ ត្រូវបានបំផ្លាញ ហើយបរិស្ថានក៏បានខូចខាតនោះ គម្រោងគ្រប់គ្រងធនធានធម្មជាតិផ្អែកសហគមន៍ (CBNRM) ត្រូវបានបង្កើតឡើង ដោយមានការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីមជ្ឈមណ្ឌលស្រាវជ្រាវការអភិវឌ្ឍអន្តរជាតិកាណាដា (IDRC) ក្នុងគោលបំណងគ្រប់គ្រងធន ធានធម្មជាតិប្រកបដោយចីរភាព។ គម្រោងនេះត្រូវអនុវត្តក្នុងដែនជំរកសត្វព្រៃពាមក្រសោប (PKWS) ខេត្តកោះកុង។ គម្រោងនេះត្រូវបានអនុវត្តដោយទទួលបាននូវសមិទ្ធិផល ជាបន្តបន្ទាប់:

■ **ជំហានទី១ ខែធ្នូ ឆ្នាំ១៩៩៧-មិថុនាឆ្នាំ២០០០:**

ក្នុងជំហាននេះ អ្នកស្រាវជ្រាវប្រើប្រាស់វិធីសាស្ត្រ ចូលរួមមួយដើម្បីកំណត់ធនធានដែលឋិតនៅក្រោមសម្ពាធ និងពង្រឹងការពាក់ព័ន្ធរបស់សហគមន៍មូលដ្ឋានតំបន់ឆ្នេរក្នុងការគ្រប់គ្រងធនធាន។ បច្ចេកទេសស្រាវជ្រាវដោយមានការចូលរួមដូចជាការគូសផែនទីកំណត់ប្រតិទិនរដូវកាល តារាងកំណត់បញ្ហា (problem trees) ចំណុចប្រសព្វប្រវត្តិសាស្ត្រ ការសួរផ្ទាល់មាត់ ដ្យាក្រាមវ៉េន និងលំហាត់ដាក់ចំណាក់ថ្នាក់ដើម្បីប្រមូលបានព័ត៌មានពីក្រុមខុសៗគ្នានេះ រួមមានអាជ្ញាធរមូលដ្ឋាន នាយកដ្ឋានបច្ចេកទេស ចាស់ស្រុក អ្នកស្រុកនៅយូរហើយនិងអ្នកចំណូលថ្មីត្រូវបានប្រើប្រាស់ដោយក្រុមស្រាវជ្រាវ។

■ **ជំហានទី២ ខែកក្កដា ឆ្នាំ២០០០-ខែឧសភា ឆ្នាំ២០០៤:**

គោលបំណងនៃជំហាននេះផ្តោតលើការអនុវត្តរបរចិញ្ចឹមជីវិតផែនការគ្រប់គ្រងធនធានព្រៃកោងកាងដោយមានការចូលរួមការបង្កើតរូបមន្តគ្រប់គ្រងសហគមន៍តំបន់ឆ្នេរ ការអប់រំបរិស្ថានតំបន់ឆ្នេរ និងការអភិវឌ្ឍធនធានមនុស្ស។ ជំហានទី២ គម្រោងធ្វើការស្រាវជ្រាវ និងបោះពុម្ពឯកសារមួយចំនួនដូចជា ការប្រើប្រាស់ធនធានព្រៃកោងកាង ការវិភាគសេដ្ឋកិច្ច-សង្គម ការវិភាគច្បាប់និងស្ថាប័ន ផែនការគ្រប់គ្រងធនធានតំបន់ឆ្នេរដោយមានការចូលរួមវិភាគ និង ការធ្វើសារពើភ័ណ្ឌធនធានតំបន់ឆ្នេរ និងការអនុវត្តទស្សនៈទានលើការលើកកម្ពស់ជីវភាពរស់នៅប្រកបដោយចីរភាព។ ម្យ៉ាងវិញទៀត ក្នុងជំហានទី២ គណៈកម្មាធិការគ្រប់គ្រងថ្នាក់ភូមិ (VMCs) ត្រូវបានបង្កើតក្នុងភូមិចំនួន៤ ក្នុងគោលបំណងកាត់បន្ថយសកម្មភាពខុសច្បាប់ ដោះស្រាយទំនាស់នេសាទ គ្រប់គ្រងសំណល់ ដាំដើមកោងកាងឡើងវិញ ជម្រុញអោយធ្វើឧទ្យានតាមផ្ទះ និងបង្កើតជលវប្បកម្មខ្នាតតូច។

### ៩.៣ កម្មវិធីថ្នាក់តំបន់ស្តីពីភាពជាដៃគូក្នុងការគ្រប់គ្រងបរិស្ថាននៅតំបន់សមុទ្រអាស៊ីបូព៌ា (PEMSEA) ផ្តល់មូលនិធិដោយ GEF/UNDP/IMO

កម្មវិធីនេះបានអនុវត្តលើកទី១នៅកម្ពុជានាឆ្នាំ១៩៩៣ ដែលមានគោលបំណងដើម្បីធានាការអភិវឌ្ឍប្រកបចីរភាពនៅតំបន់ឆ្នេរកម្ពុជាជាពិសេសគឺខេត្តព្រះសីហនុដែលកាលនោះហៅថាទីក្រុងព្រះសីហនុហើយ ទស្សនៈទាន ស្តីពីការគ្រប់គ្រងតំបន់ឆ្នេរចម្រុះ(តាមបែបសមាហរណកម្ម)ត្រូវបានអនុវត្តនៅកម្ពុជាតាំងពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០០០។ ជំហានទី១នៃគម្រោងនេះអោយឈ្មោះថា: ***ការអនុវត្តលើការរៀបចំរបាយការណ៍ ស្តីពីគម្រោងសាកល្បងគ្រប់គ្រងតំបន់ឆ្នេរចម្រុះជាតិក្នុងខេត្តព្រះសីហនុ*** ក្នុងបំណងធានាការអភិវឌ្ឍតំបន់ឆ្នេរកម្ពុជាប្រកបដោយចីរភាពដែលរួមមាន កិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានតំបន់ឆ្នេរសម្រាប់លើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន និងសុខមាលភាពជាតិ។ ប្រទេសកម្ពុជាពិតជា

ត្រូវការជំនួយជាចាំបាច់ពី PEMSEA សម្រាប់ការកសាងសមត្ថភាពស្ថាប័នលើកកម្ពស់ការអប់រំ និងការគ្រប់គ្រង អភិរក្សធនធានធម្មជាតិព្រមទាំងវិធានការឆ្លើយតប និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ។

### ៥.៤ អង្គការសម្របសម្រួលតំបន់សមុទ្រអាស៊ីបូព៌ា (COBSEA) :

ប្រទេសកម្ពុជាក្លាយជាសមាជិក COBSEA ក្នុងឆ្នាំ១៩៩៤, ក្នុងមុខងារនេះប្រទេសកម្ពុជាមានឱកាសទទួល និង បានអនុវត្តគម្រោងអភិវឌ្ឍន៍តំបន់ឆ្នេរឈ្មោះថា *“ការកែប្រែនិន្នាការការសឹករេចរិលបរិស្ថាននៅតំបន់សមុទ្រចិនខាងត្បូង និង ឈូងសមុទ្រថៃ ”* ដែលមានគោលបំណងដើម្បីដោះស្រាយបញ្ហាបរិស្ថាននៃប្រទេសសមាជិក COBSEA ដូចជា ការផ្តត់ផ្តង់ការលើកទឹកចិត្ត និងលើកកម្ពស់សមត្ថភាពរដ្ឋាភិបាលដែលចូលរួមដើម្បីបញ្ជ្រាបបញ្ហាបរិស្ថានទៅក្នុងផែនការអភិវឌ្ឍន៍ជាតិ។ COBSEA ថ្មីៗនេះកំពុងរៀបចំនូវទិសដៅយុទ្ធសាស្ត្រថ្មីសម្រាប់ ឆ្នាំ២០០៨-២០១២ ដើម្បីពង្រឹងតួនាទីក្នុងនាមជាអង្គការ អន្តររដ្ឋាភិបាលថ្នាក់តំបន់ដែលអាចពង្រឹងសមត្ថភាពជាតិ នៃប្រទេសជាសមាជិកនិងជួយក្នុងការកំណត់និងដោះស្រាយពាក់ព័ន្ធ នឹងយុទ្ធសាស្ត្រ និងបញ្ហាដែលកើតឡើង ។

## ៦. គណៈកម្មាធិការជាតិនិងអង្គភាពទាក់ទងនឹងការគ្រប់គ្រងតំបន់ឆ្នេរ និងសមុទ្រ

### ៦.១ គណៈកម្មាធិការជាតិគ្រប់គ្រងតំបន់ឆ្នេរ (NCSC)

NCSC បានបង្កើតឡើងដើម្បីជួយសម្រួលការគ្រប់គ្រង ការពារធនធានធម្មជាតិ និងបរិស្ថានតំបន់ឆ្នេរដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនតំបន់ឆ្នេរតាមរយៈការប្រើប្រាស់និងការអភិវឌ្ឍប្រកបដោយចីរភាពក្នុងតំបន់ឆ្នេរ ។

### ៦.២ អង្គភាពសម្របសម្រួលតំបន់ឆ្នេរ (CCU)

អង្គភាពសម្របសម្រួលតំបន់ឆ្នេរ (CCU) មានតួនាទីជាលេខាធិការដ្ឋានសម្រាប់ NCSC ដែលមានទីតាំងក្នុងក្រសួងបរិស្ថាន ។ តួនាទីសំខាន់ៗរបស់ CCU មានដូចតទៅ:

- សម្របសម្រួល និងសហប្រតិបត្តការជាមួយស្ថាប័នជំនួយស្ថាប័នរដ្ឋាភិបាលអង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជន
- ជម្រុញការអនុវត្តគម្រោងតំបន់ឆ្នេរនិងសមុទ្រប្រកបដោយចីរភាពធានាថាគ្មានមានការងារជាន់គ្នាជាមួយគម្រោងផ្សេងទៀត
- រៀបចំរបាយការណ៍ជូនក្រសួងបរិស្ថាន ស្តីពីសកម្មភាពតំបន់ឆ្នេរក៏ដូចទៅមន្ទីរក្រោមក្រសួងក្នុងខេត្ត

- ការប្រមូល វិភាគ និងផ្តល់ការណែនាំលើព័ត៌មានទាក់ទងនឹងផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមាននៃសកម្មភាពអភិវឌ្ឍន៍ក្នុងតំបន់ឆ្នេរ និង
- ដើរតួជាលេខាធិការនៃ NCSC ។

### ៦.៣ គណៈកម្មាធិការត្រួតពិនិត្យនិងវាយតម្លៃសម្រាប់បង្ក្រាបការរុករានដីទៅក្នុងតំបន់ព្រៃកោងកាងនិងការចាប់យកដីតំបន់ឆ្នេរ (២០០៥)

រាជរដ្ឋាភិបាលកម្ពុជាជាមួយនឹងសេចក្តីសម្រេចលេខ ២៨ ស.ស.រ២០០៥ បានបង្កើតគណៈកម្មាធិការស្តីពី ***ការត្រួតពិនិត្យ និងវាយតម្លៃក្នុងការបង្ក្រាបរុករានដីទៅក្នុងតំបន់ព្រៃកោងកាង និងការចាប់យកដីតំបន់ឆ្នេរ*** ដើម្បីបញ្ឈប់ការរុករានស្តារឡើងវិញនូវដីដែលបានរុករាន និងចាប់យក និងបញ្ជាអោយដាំព្រៃឡើងវិញនៅ តំបន់ព្រៃកោងកាងដែលបាត់បង់ ។

### ៦.៤ គណៈកម្មាធិការជាតិគ្រប់គ្រងសន្តិសុខលំហរសមុទ្រ (ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៩)

គណៈកម្មាធិការនេះបានបង្កើតឡើងក្នុងឆ្នាំ២០០៩ ដោយអនុក្រឹត្យក្នុងគោលបំណងជួយរដ្ឋាភិបាលដឹកនាំ និង អនុវត្តនូវកិច្ចការពារដែនដីរបស់ប្រទេសកម្ពុជា និងប្រទេសជិតខាងកុំឱ្យមានការគំរាមកំហែងដែលអាចកើតឡើង និងកេងផលចំណេញពីវិស័យសមុទ្រ, គណៈកម្មាធិការនេះនឹងជួយរដ្ឋាភិបាលក្នុងការដឹកនាំគ្រប់គ្រងនិងសម្របសម្រួលការអនុវត្តច្បាប់ដើម្បីការពារនិងទប់ស្កាត់ប្រកបដោយប្រសិទ្ធភាព នូវរាល់ការ គំរាមកំហែងព្រមទាំងធានានូវសុវត្ថិភាព និង សន្តិសុខ ការអភិវឌ្ឍសេដ្ឋកិច្ចនិងកិច្ចសហការជាមួយប្រទេសជិតខាងទាំង កិច្ចព្រមព្រៀងទ្វេភាគីនិងពហុភាគី ។ គណៈកម្មាធិការនេះទទួលខុសត្រូវផងដែរក្នុងការរៀបចំ និងបង្កើត ***គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពរយៈ ពេលវែង មធ្យម និងខ្លី*** ដើម្បីពង្រឹងសន្តិសុខ និងសុវត្ថិភាពជាតិនៅលំហសមុទ្រព្រមទាំងជាមួយប្រទេសជិតខាង ។

### ៦.៥ គណៈកម្មាធិការសម្របសម្រួលកងនាវាចរណ៍ (NCC) (មេសា ២០០៧) :

គោលបំណងសំខាន់នៃគណៈកម្មាធិការនេះគឺដើម្បីអនុវត្តផែនការមេសម្រាប់ការដឹកជញ្ជូនតាមទឹកនៅ ប្រព័ន្ធដងទន្លេមេគង្គនៅកម្ពុជា, រៀបចំ និងសម្របសម្រួលសកម្មភាពដែលបានលើកឡើងនៅក្នុងផែនការមេ ស្តីពីការរៀបចំរចនាសម្ព័ន្ធស្ថាប័នឡើងវិញ ការធ្វើវិសោធនកម្មច្បាប់ សុវត្ថិភាព សន្តិសុខ អភិវឌ្ឍកំពុងផែ និងរៀបចំតំបន់ទន្លេ ការកសាងសមត្ថភាពផ្នែកបរិស្ថាន, ដើម្បីរៀបចំគោលនយោបាយជាតិស្តីពីការប្រើប្រាស់ប្រភេទនៃការដឹកជញ្ជូន, និងជម្រុញគោការណ៍ពហុប្រភេទព្រមទាំងដើរតួជាអ្នកសម្របសម្រួលរវាងវិស័យ ឯកជន សមាគមន៍អ្នកជំនាញការ ភ្នាក់ងារផ្តល់ជំនួយក្រសួងសាធារណៈការនិងដឹកជញ្ជូន និងអាជ្ញាធរ និងក្រសួងពាក់ព័ន្ធឯទៀតៗ ។

### ៦.៦ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (NCCC) (២០០៦) :

NCCC បានបង្កើតឡើងក្នុងឆ្នាំ២០០៦ ដែលមានតួនាទីរៀបចំ សម្របសម្រួល និងត្រួតពិនិត្យ ការអនុវត្ត គោលនយោបាយ យុទ្ធសាស្ត្រ ច្បាប់ ផែនការ និងកម្មវិធីរបស់រាជរដ្ឋាភិបាលដើម្បីដោះស្រាយ បញ្ហាទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសដើម្បីចូលរួមចំណែកការពារបរិស្ថាន និងធនធាន ធម្មជាតិ ព្រមទាំងព្យាករណ៍ និង ទប់ស្កាត់ការប្រែប្រួលអាកាសធាតុបណ្តាលមកពីមនុស្សដែលអាចប៉ះពាល់យ៉ាងខ្លាំងដល់សុខមាលភាពមនុស្ស ។

### ៦.៧ គណៈកម្មាធិការជាតិគ្រប់គ្រងដែនដី នគរូបណីយកម្ម និងសំណង់ (១៩៩៧):

គណៈកម្មាធិការនេះបានបង្កើតក្នុងឆ្នាំ១៩៩៧ ដោយអនុក្រឹត្យនៃរាជរដ្ឋាភិបាលដែលមានតួនាទី និងភារៈកិច្ចគឺត្រូវលើការរៀបចំផែនការប្រើប្រាស់ដីធ្លីរួមទាំងនគរូបណីយកម្ម, ការពារបេតិកភ័ណ្ឌ បរិស្ថាន ការអភិវឌ្ឍសេដ្ឋកិច្ច និងធនធានធម្មជាតិ, ត្រួតពិនិត្យការងារសាងសង់ និងការដំឡើងស្ថានីយ៍ ដាក់ទោស និងបញ្ឈប់ការងារនិងរឹបអូសឧបករណ៍សាងសង់ស្របតាមកំរិតនៃការប្រព្រឹត្តបទល្មើស ។

### ៦.៨ យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខលម្ហសមុទ្រឆ្នាំ២០១២:

យុទ្ធសាស្ត្រនេះរៀបចំឡើងសម្រាប់វិធានការឆ្លើយតបនៅក្នុងការការពារអធិបតេយ្យដែនសមុទ្រកម្ពុជាផ្សំឡើងដោយគោលការណ៍សំខាន់៤ដូចខាងក្រោម:

- ការបែងចែកតំបន់សកម្មភាព
- ការដាក់ពង្រាយកម្លាំងសម្ភារៈគ្រឿងបំពាក់
- ការសម្របសម្រួលកម្លាំង និងមធ្យោបាយ
- ការបំពេញនីតិសម្បទានដល់មន្ត្រី។នៃអគ្គលេខាធិការដ្ឋាន គ.ជ.ស.ស.

បច្ចុប្បន្នកងទ័ពជើងទឹកនិងកសាងទីតាំងឈរជើងយ៉ាងរឹងមាំនៅលើបណ្តាកោះ មានជាអាទិ៍ កោះយ៉ កោះកុង កោះរុង កោះរុងសន្លឹម កោះតាង កោះព្រីង កោះពូលូវៃ និងកោះសេះ។ នៅក្នុងគោលដៅពង្រឹងប្រសិទ្ធភាពសេដ្ឋកិច្ចសហប្រតិបត្តិការក្នុងឈូងសមុទ្រដោយរាប់បញ្ចូលទាំងការរុករក និងសង្គ្រោះផងនោះ អគ្គលេខាធិការដ្ឋាន គ.ជ.ស.ស.នឹងសម្របសម្រួលដាក់ពង្រាយកម្លាំង និងមធ្យោបាយចល័តនៅតាមគោលដៅមួយចំនួនតាមការចាំបាច់ ។

## ៧. ផែនការអនុវត្តន៍យុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៃសមុទ្រអាស៊ីបូព៌ា (SDS-SEA) សម្រាប់ប្រទេសកម្ពុជាដើម្បីការពារបរិស្ថានតំបន់ឆ្នេរ

ការធ្វើចំណាត់ថ្នាក់គម្រោងសកម្មភាពនេះគឺផ្អែកលើសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើកដំបូងដែលបានធ្វើឡើងនៅទីក្រុងភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ២០១០។ ដោយផ្អែកលើសិក្ខាសាលាពិគ្រោះ យោបល់នេះ សកម្មភាព និងគម្រោងអាទិភាពដូចខាងក្រោមនឹងត្រូវអនុវត្តជាបន្តបន្ទាប់ និងដោយសហការគ្នា:

## ៧.១ ពង្រឹងការគ្រប់គ្រងធនធានធម្មជាតិក្នុងតំបន់ឆ្នេរ

ធនធានធម្មជាតិក្នុងតំបន់ឆ្នេរបង្កើតបានជាជីវៈចម្រុះសំខាន់ៗរួមមាន ទន្លេ ព្រៃកោងកាង ច្រាំងទន្លេ ឆ្នេរ ផ្កាថ្មសមុទ្រ ពពួក សត្វព្រៃ និងជីវិតសត្វសមុទ្រ។ ផ្កាថ្មសមុទ្រត្រូវបានគេរកឃើញនៅកន្លែងមួយចំនួន តាមបណ្តោយ ឆ្នេរសមុទ្រកម្ពុជា។ ស្ថានភាពផ្កាថ្មសមុទ្ររស់នៅមានសុខភាពមិនសូវល្អ (ដោយមិនសូវមានច្រើន ប្រភេទ) ដោយមានទំរង់ បែបផែនជាច្រើន។ ប្រភេទទាំងនេះផ្តល់ជម្រកអោយទាំង ប្រភេទសត្វជិតផុតពូជ ឬងាយរងគ្រោះ និងទាំងប្រភេទសត្វអាចធ្វើអាជីវកម្មបាន ឬប្រភេទសត្វសំរាប់ផ្តល់ជាអាហារដល់សហគមន៍ តាមរីជាប់តំបន់ឆ្នេរ។ ដើម្បីធានាការគ្រប់គ្រងធនធានធម្មជាតិប្រកដដោយនិរន្តរភាពនោះសកម្មភាពខាងក្រោមគួរតែត្រូវបានគេយកចិត្តទុកដាក់:

- ***ការពង្រឹងក្របខណ្ឌច្បាប់:*** ពង្រឹងច្បាប់ គោនយោបាយ បទបញ្ញត្តិ និងយុទ្ធសាស្ត្រដើម្បីសំរួលដល់ការការពារការបំពុលសមុទ្រ និងការអភិរក្សសមុទ្រតាមរយៈការបង្កើតតំបន់ការពារសមុទ្ររចនាសម្ព័ន្ធគ្រប់គ្រងសមស្របដើម្បីគ្រប់គ្រងប្រព័ន្ធអេកូសមុទ្រ និង ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចដែលស្របជាមួយនឹងការប្រើប្រាស់ធនធានធម្មជាតិប្រកបចីរភាព ។
- ***ការគ្រប់គ្រងដោយផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែម:*** ការគ្រប់គ្រងប្រព័ន្ធអេកូស៊ីស្ទែម និងប្រភេទសត្វដ៏ច្រើន ឧទាហរណ៍ នៅតំបន់ឆ្នេរសមុទ្រជាតិ និងតំបន់ឆ្នេរសេដ្ឋកិច្ចពិសេសតំរូវអោយមានផែនការប្រកបដោយប្រសិទ្ធភាព ការអនុវត្តការត្រួតពិនិត្យ និងវាយតម្លៃ និងការប្រើប្រាស់ព័ត៌មានបច្ចេកទេសពហុជំនាញ។
- ***សមត្ថភាព និង ស្ថាប័នគ្រប់គ្រាន់:*** សមត្ថភាព និងក្របខ័ណ្ឌស្ថាប័នគ្រប់គ្រង រួមមាន បុគ្គលិក និងរចនាសម្ព័ន្ធសំរាប់បង្កើតរចនាសម្ព័ន្ធការងាររដ្ឋាភិបាលអោយដំណើរការមានប្រសិទ្ធភាព។ ប្រការនេះ គ្របដណ្តប់ទាំងអាជ្ញាធរ និងភាគីពាក់ព័ន្ធដែលចូលរួម ដូចជា សហគមន៍ក្នុងតំបន់ វិស័យជំនួញ អង្គការ ក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិលឯទៀតៗ ហើយនឹងការបង្កើតសម្ព័ន្ធភាពក្នុងចំណោមពួកគេ។
- ***ការចូលរួមពីវិស័យឯកជន:*** សកម្មភាពសេដ្ឋកិច្ចសំខាន់ៗគឺស្របតាមការអភិរក្ស ហើយពិសេសកន្លែងដែលអាចធ្វើទៅបានគឺតភ្ជាប់យ៉ាងមានប្រសិទ្ធភាព និងអាចធ្វើទៅបានជាមួយនឹងការគ្រប់គ្រងដោយចីរភាពនូវប្រព័ន្ធអេកូដើម្បីអោយដំណើរការអភិរក្ស និងអភិវឌ្ឍន៍ស្របគ្នា។

- ***ការគាំទ្រពីសង្គម និងនយោបាយៈ*** ការអភិរក្សដែនសមុទ្រ គឺត្រូវតែមានស្ថេរភាពសង្គម និងនយោបាយពីព្រោះគេចាត់ទុកថាវាជាផ្នែកចម្រុះនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងមានការគាំទ្រនៅគ្រប់កំរិតចាប់ពីនាក់ពាក់ព័ន្ធតំបន់គ្រប់គ្រងតាមមូលដ្ឋានរហូតដល់មេដឹកនាំថ្នាក់ជាតិ។ ប្រការនេះរាប់បញ្ចូល ទាំងភាពជាម្ចាស់នៃកម្មវិធីអភិរក្ស និងការចូលរួមស្ថាប័នក្នុងការគ្រប់គ្រង។
- ***ការរក្សា និង ស្តារឡើងវិញនូវដំណើរការអេកូស៊ីស្ទែម គុណភាពបរិស្ថាន និង ទីជម្រកពិសេសៈ*** ការខិតខំប្រឹងប្រែងគ្រប់គ្រងតំបន់ឆ្នេរ ការស្តារឡើងវិញ និងរក្សានូវជម្រកពិសេសដើម្បីអោយដំណើរការសេវា អេកូស៊ីស្ទែម និងប្រព័ន្ធអេកូស៊ីស្ទែមគឺត្រូវអោយមានលក្ខណៈប្រកបដោយចិរភាព។
- ***ការស្តារឡើងវិញនូវប្រភេទសត្វទទួលរងការគំរាមកំហែងៈ*** កិច្ចប្រឹងប្រែងអភិរក្សសមុទ្របញ្ចៀសនូវ ការធ្លាក់ចុះនៃប្រភេទសត្វសមុទ្រដែលរងការគំរាមកំហែង និងកំអោយប្រភេទសត្វសមុទ្រដែលរងការ គំរាមកំហែងនោះមានចំនួនកើនឡើង។
- ***អត្ថប្រយោជន៍ដល់សុខមាលភាពមនុស្សៈ*** ការគ្រប់គ្រង តំបន់ឆ្នេរ និង សមុទ្រ ពង្រឹងដល់សុខភាពសង្គម (រួមមានច្បាប់ និង គោនយោបាយ) សេដ្ឋកិច្ច និងវប្បធម៌នៃសហគមន៍មនុស្ស ផ្អែកលើធនធានសមុទ្រ និងតំបន់ឆ្នេរ និងប្រព័ន្ធអេកូស៊ីស្ទែម។
- ***យន្តការទីផ្សារ និងហិរញ្ញវត្ថុប្រកបដោយចីរភាពៈ*** កម្មវិធីអភិរក្សដែនសមុទ្រគួរតែធានានូវស្ថេរភាពហិរញ្ញវត្ថុមានន័យថាការផ្តល់មូលនិធិត្រូវតែមានស្ថេរភាពមានច្រើនប្រភេទ និងមានចំនួនល្មមគ្រប់គ្រាន់សំរាប់អនុវត្តន៍រាល់សកម្មភាពគម្រោងជាអាទិភាព។ ប្រការនេះរួមបញ្ចូលការផ្តល់ថវិកាដោយចិរភាពនៃការសម្របសម្រួលនិងសហការលើការត្រួតពិនិត្យតំបន់ឆ្នេរ និងអេកូស៊ីស្ទែម។

## ៧.២ ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពនៅតំបន់ឆ្នេរ

ការគាំទ្រហិរញ្ញវត្ថុសំរាប់អនុវត្តន៍ការគ្រប់គ្រងតំបន់ឆ្នេរអាចបានមកពីប្រភពផ្សេងៗគ្នា។ កង្វះខាតថវិកា បណ្តាលឱ្យបរាជ័យក្នុងការអនុវត្តផែនការសកម្មភាពគ្រប់គ្រងហើយជាទូទៅត្រូវបានគេប្រើជាលេសសំរាប់ភាពអសកម្មនៃគម្រោង។ យន្តការហិរញ្ញវត្ថុតម្រូវអោយធានាថា ផែនការសកម្មភាពនឹងនូវតែបន្តអនុវត្តន៍ ទោះបីជាជំនួយថវិកាប្រើប្រាស់អស់ក៏ដោយ។ បច្ចុប្បន្នមានការអភិវឌ្ឍជាច្រើននូវវិស័យច្បាប់ និងបទបញ្ញតិនានា តែមានការងារជាច្រើនទៀតដែលត្រូវធ្វើដើម្បីរក្សា និងពង្រឹងកំណើនម៉ាក្រូសេដ្ឋកិច្ច វិន័យសារពើពន្ធ និងវិស័យ ហិរញ្ញវត្ថុដែលចេះតែកើនឡើងដើម្បីបន្តការរីកចម្រើនជាប្រចាំ។

អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលអាចអនុវត្តគោលការណ៍អ្នកបំពុលត្រូវបង់ថ្លៃ **(Polluters Pay Principle)** ដើម្បីជម្រុញនូវកំណើនតម្លៃបរិស្ថាន។ ដើម្បីធានាការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយចីរភាពវិធានការខាងក្រោមគួរតែយកចិត្តទុកដាក់ៈ

***ក. ប្រភពមូលនិធិពីខាងក្រៅ***

ម្ចាស់ជំនួយសំខាន់ៗសំរាប់គម្រោងគ្រប់គ្រងតំបន់ឆ្នេរក្នុងប្រទេសកម្ពុជាមានដូចជា **DANIDA, IDRC, UNEP** និង ភ្នាក់ងារអភិវឌ្ឍន៍ផ្សេងៗទៀតរួមទាំងអង្គការក្រៅរដ្ឋាភិបាលផងដែរ។ មូលនិធិខាងក្រៅ ដើរតួនាទីយ៉ាងសំខាន់សំរាប់សង្គមកម្ពុជានៅពេលបច្ចុប្បន្ន ប្រសិនបើគ្មានពួកគេទេ គម្រោងទាំងឡាយមិនមានដំណើរការឡើយ។ ដូច្នេះរដ្ឋាភិបាលគួរតែកៀរគរមូលនិធិពីខាងក្រៅតាមរយៈការបង្កើតកិច្ចសហប្រតិបត្តិការ ជាមួយនឹង ដៃគូអភិវឌ្ឍន៍ ស្ថាប័ន និងកម្មវិធីអភិវឌ្ឍន៍ ដូចជា FAO, WB, ADB, AUsAID, USAID, Dfid, etc.។ល។ និងប្រទេសផ្តល់ជំនួយដើម្បីធានាការហូរចូលហិរញ្ញវត្ថុសំរាប់គាំទ្រគម្រោងតំបន់ឆ្នេរសមុទ្រ។

***ខ. ថវិការដ្ឋាភិបាល***

វាជាវិធីសាមញ្ញ និងអាចធ្វើបានដោយបញ្ចូលតម្លៃការរៀបចំការអនុវត្ត និងការសម្របសម្រួលព្រមទាំងផែនការសកម្មភាពទៅក្នុងថវិកាជាតិ។ វាមិនមានមន្ទិលសង្ស័យដែលថាតើកន្លែងណាដែលផែនការសកម្មភាព ទាក់ទងនឹងវិស័យវឹបញ្ហាជាក់លាក់និងសមស្របគួរត្រូវគេបញ្ចូលទៅក្នុងថវិកានៃក្រសួង និងស្ថាប័នពាក់ព័ន្ធសម ស្របនោះទេ។

***គ. ពន្ធអាករ និងតម្លៃឈ្នួល***

វិធីមួយទៀតគឺត្រូវប្រមូលថ្លៃអ្នកប្រើប្រាស់ ថ្លៃលិខិតអនុញ្ញាតិ និងថ្លៃសេវាកម្ម។ ប្រព័ន្ធតម្លៃគឺជាយន្តការដ៏មានប្រយោជន៍សំរាប់បង្កើតចំណូលថ្មីក្នុងការគ្រប់គ្រងបរិស្ថាន និងផ្តល់សេវាកម្មនាំចេញ និងគម្រោងបរិស្ថានឯទៀតៗ។ យើងអាចពិចារណាពីតម្លៃអនុញ្ញាតិក្នុងការប្រើប្រាស់ទឹកតំបន់ឆ្នេរ កន្លែងជួសជុលវឹចតកប៉ាល់ កន្លែងកំសាន្ត នេសាទ និងសកម្មភាពផ្សេងៗទៀតដែលប្រើប្រាស់ទឹកតំបន់ឆ្នេរ។

***ឃ. ភាពជាដៃគូរវាងវិស័យឯកជន-សាធារណៈ** (PPP)*

PPPsគឺជាយន្តការហិរញ្ញវត្ថុមួយទៀតដែលអាចជម្រុញកិច្ចខិតខំប្រឹងប្រែងជាសាធារណៈក្នុងការគ្រប់គ្រងបរិស្ថាន។ វិស័យឯកជនទាំងមូលមានទាំងធនធានហិរញ្ញវត្ថុ និង ទាំងជំនាញក្នុងការរៀបចំបង្កើត កសាង និងផ្ទេរទីកន្លែង និងសេវាដើម្បីពង្រឹងផ្នែកបរិស្ថានៈ ឧទាហរណ៏-ផែនការនិងការប្រតិបត្តិនៃប្រព្រឹត្តិកម្មសំណល់ទឹកការអនុវត្តវគ្គបណ្តុះបណ្តាលជំនាញពិសេស និងការធ្វើការស្ទាបស្ទង់លើបញ្ហាបរិស្ថាន និងធនធានធម្ម ជាតិ។

## ៧.៣ ការគ្រប់គ្រងការបំពុលនៅតំបន់ឆ្នេរ

ក្រសួងបរិស្ថានបានរៀបចំផែនការយុទ្ធសាស្ត្រជាតិឆ្នាំ២០០៩-២០១៣ លើការងារគ្រប់គ្រងបរិស្ថាន ដែលក្នុងនោះ

ក្រសួងបានបញ្ជាក់ច្បាស់លើការងារគ្រប់គ្រងសំណល់និងការបំពុលផ្សេងៗ។ ការគ្រប់គ្រងការបំពុលបរិស្ថានមានគោលបំណង ដើម្បីទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកដោយផ្តោតលើសកម្មភាពមួយ ចំនួនដូចជា:

- ច្បាប់ ស្តីពីការត្រួតពិនិត្យការបំពុលទឹក ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត
- វគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រីបរិស្ថានរាជធានី/ខេត្តត្រូវបានរៀបចំធ្វើដើម្បីបង្កើនចំណេះដឹងរបស់មន្ត្រីបរិស្ថាន រាជធានី/ខេត្ត ត្រូវបានអភិវឌ្ឍន៍
- គុណភាពទឹកសាធារណៈត្រូវបានតាមដាន និងត្រួតពិនិត្យជាប្រចាំ
- ទិន្នន័យសំណល់រាវ និងទិន្នន័យប្រភពបំពុល ទូទាំងប្រទេសត្រូវបានចងក្រង និងផ្សព្វផ្សាយ
- សំណល់រាវបញ្ចេញពីទីប្រជុំជនរាជធានី/ខេត្ត ត្រូវបានធ្វើការសំអាតទៅតាមបទដ្ឋានច្បាប់
- របាយការណ៍ ស្តីពីស្ថានភាពបំពុលទឹកត្រូវបានចងក្រង និងផ្សព្វផ្សាយ ។
- ការវាយតម្លៃសំណល់ទឹក និងសមុទ្រគឺជាការវាស់វែងជា ប្រចាំនៅកន្លែង នូវការបញ្ចេញសំណល់ទឹកគុណភាពទឹក និងកករជុំវិញកន្លែងបង្ហូរទឹកស្អុយទៅសមុទ្រ ។ កម្មវិធីវាយតម្លៃទឹកសមុទ្រនឹងត្រូវរៀបចំឡើងដើម្បីការពារការប្រែប្រួលបរិស្ថានក្នុងទឹក និងនៅបាតសមុទ្រជុំវិញចំណុចសំខាន់ៗ។ ផែនការនេះគ្របដណ្តប់លើការគ្រប់គ្រងសំណល់រឹងផងដែរដែលមានគោលបំណងអនុវត្តការគ្រប់គ្រងសំណល់រឹងប្រកបដោយសុវត្ថិភាពបរិស្ថានដោយផ្តោតលើសកម្មភាពមួយចំនួនដូចជា:
  - ច្បាប់ ស្តីពីកាគ្រប់គ្រងសំណល់រឹង និងសំណល់ប្រកបដោយគ្រោះថ្នាក់ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត
  - វគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រីបរិស្ថានរាជធានី/ខេត្តត្រូវបានរៀបចំធ្វើ ។ ចំណេះដឹងរបស់មន្ត្រីបរិស្ថានរាជធានី/ខេត្តលើការគ្រប់គ្រងសំណល់រឹង និង សំណល់គ្រោះថ្នាក់ត្រូវបានអភិវឌ្ឍន៍ហើយការគ្រប់គ្រងសំណល់រឹង និងសំណល់ប្រកបដោយគ្រោះថ្នាក់ និងធានាបាននូវសុវត្ថិភាពបរិស្ថាន
  - ការគ្រប់គ្រងសំណល់រឹង និងសំណល់ប្រកបដោយគ្រោះថ្នាក់នៅតាមរាជធានី/ខេត្តត្រូវបានធ្វើការកែលម្អព្រមទាំងមានការគ្រប់គ្រងសមស្របតាមលក្ខណៈបច្ចេកទេស និងប្រកបដោយសុវត្ថិភាពបរិស្ថាន
  - ឯកសារគោលការណ៍ណែនាំស្តីពីការគ្រប់គ្រង និងការអនុវត្តន៍គោលការណ៍ ៣R ត្រូវបានដាក់ឱ្យអនុវត្ត ហើយសកម្មភាពអនុវត្តគោលការណ៍៣R នៅក្នុងរាជធានី/ខេត្តមួយត្រូវបានជ្រើសរើសជាគំរូសម្រាប់ការអនុវត្តនៅទូទាំងប្រទេស

- របាយការណ៍សារពើភ័ណ្ឌសំណល់រឹងរាជធានី/ខេត្តត្រូវបានចងក្រងនិងធ្វើការផ្សព្វផ្សាយដើម្បីរកដំណោះស្រាយលើភាពខ្វះចន្លោះនៃការអនុវត្តន៍លើការគ្រប់គ្រងសំណល់រឹងរាជធានី/ខេត្ត ហើយប្រព័ន្ធនៃការគ្រប់គ្រងសំណល់ រឹងនឹងត្រូវបានធ្វើការអភិវឌ្ឍន៍ឱ្យកាន់តែប្រសើរឡើង។

## ៧.៤ តួនាទីអង្គការក្រៅរដ្ឋាភិបាល(NGOs) សម្រាប់យុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពក្នុងការគ្រប់គ្រងតំបន់ឆ្នេរ

តួនាទីសំខាន់របស់ NGOs នៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពក្នុងការគ្រប់គ្រងតំបន់ឆ្នេរគឺដើម្បីគាំទ្រសហគមន៍តំបន់ឆ្នេរដោយធានាថាពួកគេទទួលបានប្រយោជន៍សង្គមបានយ៉ាងច្រើនពីកម្មវិធីនេះ។ NGOs មានតួនាទីផ្សេងៗគ្នា ដូចជាគម្រោងផ្តោតលើការលើកកម្ពស់ជីវភាពរស់នៅ ការកសាងជម្រកឡើងវិញ ការអប់រំពីការប្រើប្រាស់សំណល់ឡើងវិញ និងអំពីសហគមន៍ ហើយនឹងទាក់ទងទៅនឹងការប្រតិបត្តិគម្រោងផ្ទាល់ ក្នុងលក្ខណៈដូចគ្នាជាមួយអន្តរជាតិ អង្គការសហប្រជាជាតិ និងភ្នាក់ងារអន្តរជាតិ។ NGOs ធ្វើជាស្ពានតភ្ជាប់រវាងរដ្ឋាភិបាលក្នុងស្រុកដែលគ្រប់គ្រងតំបន់ឆ្នេរ និងសហគមន៍ទទួលរងផលប៉ះពាល់ វិជ្ជមាន ឬអវិជ្ជមានដោយអន្តរាគមន៍លើការគ្រប់គ្រង។

## ៧.៥ ការបង្កើតយន្តការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការវិស័យសាធារណៈជាមួយវិស័យឯកជនក្នុងតំបន់ឆ្នេរ

វិស័យឯកជនចូលរួមកាត់បន្ថយភាពក្រីក្រ និងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជន។ វិស័យឯកជនដែលជាក្បាលម៉ាស៊ីនដ៏សំខាន់សំរាប់កំណើនសេដ្ឋកិច្ចនោះអាចដើរតួសំខាន់ផ្ទាល់ក្នុងការកាត់បន្ថយភាពក្រីក្រនិងក្នុងដំណើរការអភិវឌ្ឍន៍ដើម្បីលើកកំពស់ជីវភាពរស់នៅតំបន់ឆ្នេរ។ ប្រការនេះអាច នឹងសំរេចបានតាមរយៈគន្លឹះ យុទ្ធសាស្ត្រចំនួន៣: ***១) ការបង្កើតបរិស្ថានពង្រឹងសមត្ថភាពធ្វើជំនួញ និងវិនិយោគទុនក្នុងតំបន់ឆ្នេរ ២) ការបង្កើតឱកាសជំនួញជាពិសេសតាមរយៈភាពជាដៃគូសាធារណៈ ឯកជនដែលមាននវានុវត្តភាព និង ៣) ការជម្រុញអោយមានឯកជនភាវូបនីយកម្ម*** (Rahman, S.T, ២០០៨)។ ដើម្បីកៀរគរវិស័យឯកជនឱ្យចូលរួមកសាងសមត្ថភាពធនធានមនុស្សក្នុងតំបន់ឆ្នេរចាំបាច់ត្រូវរៀបចំស្ថាប័នភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជន។ រដ្ឋាភិបាលគួរតែជួយសំរួលសកម្មភាពនៃអ្នកវិនិយោគទុនឯកជនក្នុងស្រុកក៏ដូចជានៅក្រៅស្រុកផងដែរ។

## ៧.៦ យេនឌ័រក្នុងការគ្រប់គ្រងតំបន់ឆ្នេរ

ក្នុងការងាររាល់ថ្ងៃ ស្ត្រីគឺជានាក់ប្រើប្រាស់បរិស្ថាន ធម្មជាតិដោយផ្ទាល់ច្រើនជាងបុរស ប៉ុន្តែស្ត្រីមានការអប់រំតិចតួចពីបញ្ហាបរិស្ថានជាងបុរស។ ជាច្រើនឆ្នាំកន្លងទៅនេះ ការចូលរួមរបស់បុរសនិងស្ត្រីក្នុងការគ្រប់គ្រងធនធានធម្មជាតិមិនមានតុល្យភាពគ្នាទេក្នុងតំបន់ឆ្នេរដោយសារតែសង្គមឱ្យតម្លៃខុសៗគ្នាទៅលើការងាររវាងបុរសនិងស្ត្រី។ ដើម្បីគ្រប់គ្រង និងអភិរក្សតំបន់ឆ្នេរសមុទ្រប្រកបដោយចីរភាពពីព្រោះស្ត្រីប្រើប្រាស់ធនធានធម្មជាតិដោយផ្ទាល់ ហើយពួកគេគឺជាមនុស្សដែលងាយរងគ្រោះផងដោយសារការបាត់បង់ធនធានធម្មជាតិ។

## ៧.៧ ការគ្រប់គ្រងតំបន់ឆ្នេរដោយពឹងផ្អែកលើសហគមន៍ (CBM)

វិធីសាស្ត្រនេះ គឺជាទំរង់មួយផ្សេងទៀតនៃការគ្រប់គ្រងតំបន់ឆ្នេរដែលអនុវត្តលើវិសាលភាពភូមិសាស្ត្រ ខ្នាតតូច មួយ។ CBM អនុញ្ញាតឱ្យសហគមន៍មានការទទួលនូវតួនាទីជាអ្នកពាក់ព័ន្ធកាន់តែផ្ទាល់ក្នុង ការកំណត់ ការប្រើប្រាស់ និងការលៃលកធនធានធម្មជាតិនៅក្នុងព្រំដែនកំណត់មួយ។ វិធីនេះអាចធានាផងដែរ នូវការសង្កេត មើលកម្មសិទ្ធិប្រពៃណីយ៍ និងចាត់ទុកសហគមន៍ចូលរួមថាជាភាគីពាក់ព័ន្ធដ៏សំខាន់ក្នុងដំណើរការធ្វើសេចក្តីសំរេចចិត្ត។ CBM ត្រូវបានចាត់ទុកថាជាការគ្រប់គ្រងធនធានតំបន់ឆ្នេរមួយ ហើយវិធីសាស្ត្រនេះផ្តោតសំខាន់ទៅលើកិច្ចការពាររចនាសម្ព័ន្ធប្រព័ន្ធអេកូ មុខងារ និងដំណើរការសំខាន់ៗមានអន្តរទំនាក់ទំនងនៅក្នុង និងចំណោមប្រព័ន្ធ និងអន្តរទំនាក់ទំនងរវាងអេកូស៊ីស្ទែម សង្គម សេដ្ឋកិច្ច និងស្ថាប័ន។

**ឯកសារសម្រាប់អានបន្ថែមៈ**

- របាយការណ៏ស្ទង់មតិសហគមន៏តំបន់ឆ្នេរ និងសមុទ្រៈ របាយការណ៏សម្រាប់គម្រោងរបស់ធានាគារអភិវឌ្ឍន៏អាស៊ី លេខ 5712-REG ស្តីពីការគ្រប់គ្រងតំបន់ឆ្នេរ និងសមុទ្រនៅសមុទ្រចិនខាងត្បូងជំហានទី២ ឆ្នាំ១៩៩៩
- គោលដៅអភិវឌ្ឍន៏សហស្សវត្សរ៏កម្ពុជា (CMDG) ឆ្នាំ២០០៣, រាជរដ្ឋាភិបាលកម្ពុជា
- ការវាយតម្លៃជាតិលើការអនុវត្តរបៀបវារៈទី២១នៅកម្ពុជា ឆ្នាំ២០០៣
- ឌីណាមិចនៃការគ្រប់គ្រងតំបន់ឆ្នេរចម្រុះៈ ការអនុវត្តជាក់ស្តែងក្នុងការអភិវឌ្ឍតំបន់ឆ្នេរប្រកបដោយនិរន្តរនៅអាស៊ីបូព៌ាដោយលោកសាស្ត្រាចារ្យ Chu, Thia Eng, ឆ្នាំ២០០៦
- ការគ្រប់គ្រងធនធានធម្មជាតិតាមបែបវិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា
- គ្រប់គ្រងតំបន់ឆ្នេរចម្រុះៈ ការអនុវត្ត និងបទពិសោធន៏របស់គម្រោង PEMSEA ។ កម្មវិធីថ្នាក់តំបន់របស់ GEF/UNDP/IMO ស្តីពីភាពជាដៃគូរក្នុងការគ្រប់គ្រងបរិស្ថានសម្រាប់សមុទ្រអាស៊ីបូព៌ា(PEMSEA) ឆ្នាំ២០០៤
- ការសិក្សាទៅលើយុទ្ធសាស្ត្រសមាហរណកម្មថ្នាក់ជាតិនៃភូមិសាស្ត្រតំបន់ឆ្នេរ និងផែនការមេខេត្តព្រះសីហនុ សម្រាប់យុទ្ធសាស្ត្រសមាហរណកម្មថ្នាក់ជាតិដើម្បីអភិវឌ្ឍន៏ប្រកបដោយនិរន្តរភា នៅតំបន់ឆ្នេរ, JICA, ឆ្នាំ២០១០
- ឯកសារសិក្សាដំបូង (White Paper) ស្តីពីកម្មវិធីយុទ្ធសាស្ត្រ និងកម្មវិធីការងារសម្រាប់បបង្កើតនូវគោលនយោបាយនិងសកម្មភាពជាតិដើម្បីការ អភិវឌ្ឍន៏ប្រកបដោយនិរន្តរ ភាពនៃឆ្នេរ និងមហាសមុទ្រក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៨,ក្រសួងបរិស្ថាន
- ផែនការយុទ្ធសាស្ត្រនិងការងារដើម្បីធ្វើឱ្យប្រសើរនូវការសម្របសម្រួល នៃកម្មវិធីលើកកម្ពស់ការគ្រប់គ្រងតំបន់ឆ្នេរចម្រុះនៅប្រទេសកម្ពុជា, ក្រសួងបរិស្ថាន ២០០៧
- ផែនការសកម្មភាពគ្រប់គ្រងបរិស្ថានតំបន់ឆ្នេរ ២០០៧ ដល់ ២០១១, ក្រសួងបរិស្ថាន ២០០៧
- របាយការណ៏បរិស្ថានតំបន់ឆ្នេរនិងសេដ្ឋកិច្ច និងសង្គមលើកទី២ ឆ្នាំ២០០៧ ,ក្រសួងបរិស្ថាន ២០០៧
- វាយតម្លៃយុទ្ធសាស្ត្របរិស្ថាន លើវិស័យទេសចរណ៏នៅប្រទេសកម្ពុជា, ក្រសួងទេសចរណ៏ ២០០៧
- កម្មវិធីសកម្មភាពជាតិបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (NAPA), ក្រសួងបរិស្ថាន ២០០៦

- ផែនការក្របខណ្ឌរូបវន្តនៅខេត្តកំពត ។ ការគ្រប់គ្រងបរិស្ថានក្នុងតំបន់ឆ្នេរដោយ ក្រុមការងារខេត្តកំពត, ក្រសួងបរិស្ថាន ២០០២ ។
- ផែនការក្របខណ្ឌរូបវន្តនៅខេត្តកែប: ការគ្រប់គ្រងបរិស្ថានក្នុងតំបន់ឆ្នេរដោយ ក្រុមការងារខេត្តកែប, ក្រសួងបរិស្ថាន ២០០២
- ផែនការក្របខណ្ឌរូបវន្តនៅខេត្តកោះកុង: ការគ្រប់គ្រងបរិស្ថានក្នុងតំបន់ឆ្នេរដោយ ក្រុមការងារខេត្តកោះកុង, ក្រសួងបរិស្ថាន ២០០២
- ផែនការក្របខណ្ឌរូបវន្តនៅខេត្តព្រះសីហនុ: ការគ្រប់គ្រងបរិស្ថានក្នុងតំបន់ឆ្នេរដោយ ក្រុមការងារខេត្ត ព្រះសីហនុ, ក្រសួងបរិស្ថាន ២០០២
- ការវាយតម្លៃភាពងាយរងគ្រោះ និងបន្សុាំនឹងការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកម្ពុជា, ក្រសួងបរិស្ថាន ២០០២
- ក្របខណ្ឌផែនការយុទ្ធសាស្ត្រជាតិលើវិស័យជលផលឆ្នាំ ២០០៩-២០១៥, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០១០
- ក្របខណ្ឌយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការឆ្នាំ២០០៥, ក្រសួងមហាផ្ទៃ
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣, ក្រសួងផែនការ
- យុទ្ធសាស្ត្រចតុកោណជំហានទី២ សម្រាប់កំណើន ការងារ សមធម៌ និងប្រសិទ្ធភាពក្នុងប្រទេសកម្ពុជា, រាជរដ្ឋាភិបាលកម្ពុជា
- លទ្ធផលបូកសរុបការងារពាក់កណ្តាលអណ្តតិ ឆ្នាំ២០០៨ លើការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០, ក្រសួងផែនការ
- យុទ្ធសាស្ត្រជាតិស្តីពីសន្តិលំហសមុទ្រ, រាជរដ្ឋាភិបាល ឆ្នាំ២០១២
- យុទ្ធសាស្ត្រជាតិគ្រប់គ្រងគ្រោះមហន្តរាយ ២០០៨-២០១៣
- ពង្រាងច្បាប់គ្រប់គ្រងគ្រោះមហន្តរាយ ២០១២
- កម្រងឯកសារច្បាប់គ្រប់គ្រងគ្រោះមហន្តរាយ

## នាក់ទងនឹងការខារប្រែប្រួលអាកាសធាតុ

## ១. ការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់នៅកម្ពុជា

ការប្រែប្រួលអាកាសធាតុដែលបណ្តាលអោយមានកំណើនកម្ពស់ទឹកសមុទ្រ និងធ្វើអោយមានផលប៉ះពាល់រូបវន្ត និង អេកូឡូស៊ីតំបន់ឆ្នេរផ្សេងៗគ្នាដែរ។ ផលប៉ះពាល់ទាំងនោះរួមមានៈការលិចដោយទឹកជំនន់និងការបំផ្លាញដោយព្យុះការបាត់បង់ តំបន់ដីសើម សំណឹក ការជ្រាបចូលទឹកប្រៃ និងការកើនឡើងកំពស់ទឹក។ ផលប៉ះពាល់ផ្សេងទៀតនៃការប្រែប្រួលអាកាស ធាតុ ដូចជា សីតុណ្ហភាពទឹកសមុទ្រឡើងខ្ពស់ ការប្រែប្រួលកំណកអាកាស និងការផ្លាស់ប្តូរដំណើរខ្យល់ព្យុះ ព្រៀងកង់ និង អាំងតង់ស៊ីតេដែលនឹងជះឥទ្ធិពលអាក្រក់ដល់ប្រព័ន្ធតំបន់ឆ្នេរទាំងដោយផ្ទាល់ និងតាមរយៈអន្តរអំពើរជាមួយការកើនឡើង កម្រិតទឹកសមុទ្រ។ ឧទាហរណ៍ ការកើនឡើងសីតុណ្ហភាព ទឹកសមុទ្រទំនងជាបណ្តាលអោយផ្កាថ្មឡើងពណ៌ (Coral bleaching) និងបណ្តាលឱ្យមានការផ្លាស់ទីរបស់សត្វសមុទ្រទៅតំបន់ខ្ពស់ៗជាង។ ការផ្លាស់ប្តូរកំណកអាកាស និង របបខ្យល់ព្យុះនឹងបង្កើនហានិភ័យការបំផ្លាញដោយទឹកជំនន់និងខ្យល់ព្យុះកាន់តែកើនឡើង។ ផលប៉ះពាល់នៃភូគោលជីវសាស្ត្រនឹងជះ ឥទ្ធិផលទៅលើសេដ្ឋកិច្ចសង្គមដោយផ្ទាល់និងដោយប្រយោល និងមានផលប៉ះពាល់លើវិស័យទេសចរណ៍ ការតាំងទីលំនៅ របស់មនុស្ស ការធ្វើកសិកម្ម ការផ្គត់ផ្គង់ទឹក និងគុណភាពទឹក ការនេសាទ សេវាកម្មហិរញ្ញវត្ថុ និងសុខភាពនៅ តំបន់ឆ្នេរ។ ប្រជាជនដែលរស់នៅតំបន់ឆ្នេរ (កម្រិតបច្ចុប្បន្ន ឬកម្រិតដែលគេទស្សទាយ) អាចត្រូវបានរងផលប៉ះពាល់ដោយទឹកជំនន់ដែល ចេះតែកើនឡើង និងចាំបាច់ត្រូវតែផ្លាស់ប្តូរទីលំនៅដោយសារតែទឹកជំនន់ញឹកញាប់ ឬពីការបាត់បង់ដីបណ្តាលមកពីសំណឹក។ វានឹងមានការប្រែប្រួលតម្លៃទីផ្សារ និង សេវាកម្ម ដូចជា ដី ហេដ្ឋារចនាសម្ព័ន្ធ និងផលិតភាព ឧស្សាហកម្ម និងកសិកម្ម។ គេបានរាយការណ៍ថាការកើនឡើងកំពស់ទឹកសមុទ្រ ១ម នឹងបណ្តាលអោយតំបន់សរុបប្រហែល ២៥ពាន់ហិចតារបស់ខេត្ត កោះកុងនឹងត្រូវបានជន់លិចជាអចិន្ត្រៃយ៍និងលិចលុងរហូតដល់ទៅ ៣៨ពាន់ហិចតា ប្រសិនបើកំណើនកម្ពស់ទឹកសមុទ្រកើន ឡើងដល់ ២ម (ពង្រាង SNC ២០១០)។ គេបានបញ្ជាក់ផងដែរថា ការកើតមានឡើងនូវទឹកជោរ និងទឹកនាចនៅតំបន់ឆ្នេរ នឹងធ្វើឱ្យលិចតំបន់ទំនាបតំបន់ឆ្នេរជាបណ្តោះអាសន្ន។ បន្ថែមពីនេះទៅទៀត ផ្អែកលើការស្រាវជ្រាវនៅខេត្តព្រះសីហនុនៅ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១០ ទឹកជោទឹកនាចនៅតំបន់នេះមានកំពស់ខ្ពស់ជាង១ម និងមានរយៈពេល៦ម៉ោង។

ការសិក្សាស្រាវជ្រាវថ្មីៗនេះបង្ហាញថា ប្រព័ន្ធអេកូតំបន់ឆ្នេរ ដូចជា ព្រៃកោងកាង ច្រាំងសមុទ្រ ស្មៅសមុទ្រ គឺជា អាងស្តុកកាបោនដ៏មានប្រសិទ្ធភាពបំផុត (UNEP, ២០០៩)។ ទទ្ទឹមនឹងនេះដែរ ការរេចរិលនៃប្រព័ន្ធអេកូស៊ីស្ទែមសមុទ្រ អាចបញ្ចេញកាបោនរាប់ម៉ឺនឆ្នាំនៃកាបោនដែលរក្សាទុក។ ដោយសារសារៈសំខាន់នៃប្រព័ន្ធអេកូតំបន់ឆ្នេរចេះតែកើនឡើងៗ ក្នុងការកាត់បន្ថយការប្រែប្រួលអាសធាតុ (ដោយសារការស្រូបយកឧស្ម័នផ្ទះកញ្ចក់) ផែនការ និងសកម្មភាពដើម្បីស្តារនិង រក្សាទុកនូវជម្រកតំបន់ឆ្នេរដើម្បីគាំទ្រដល់ការនេសាទដែលមានសារៈសំខាន់សម្រាប់សុវត្ថិភាពស្បៀងអាហារ និងការពារព្យុះ

នោះអាចត្រូវបានគេរំពឹងថានឹងផ្តល់តម្លៃសេដ្ឋកិច្ចនៅពេលអនាគតដោយធ្វើជាអាងស្តុកកាបោន។ ទោះបីជាយ៉ាងណាក៏ដោយ ការដែលធ្វើអោយប្រព័ន្ធអេកូសមុទ្រមានការខូចខាតដែលនឹងបញ្ចេញសារធាតុកាបោនចាំបាច់ត្រូវតែខាតបង់នាពេលអនាគត ប្រសិនបើតំបន់ឆ្នេរត្រូវបានធ្វើឱ្យខូចខាត និងក្លាយទៅជាប្រភពមួយនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (GHG)។

## ២. គោលនយោបាយ និងយុទ្ធសាស្ត្រជាតិសម្រាប់ដោះស្រាយនឹងការប្រែប្រួលអាកាសធាតុ

គោលនយោបាយប្រែប្រួលអាកាសធាតុកម្ពុជាត្រូវបានរៀបចំឡើងដើម្បីរួមចំណែក កសាងសង្គមមួយដែលបៃតងជាងមុនធន់នឹងការប្រែប្រួលអាកាសធាតុ និងធានាបាននូវការ អភិវឌ្ឍដោយសមធម៌ និងចីរភាពសម្រាប់ប្រជាពលរដ្ឋទូទៅក្រោមលក្ខខណ្ឌនៃការប្រែប្រួលអាកាសធាតុ។ គោលនយោបាយនេះគឺជាត្រីវិស័យសម្រាប់ដឹកនាំសម្របសម្រួលការងារប្រែប្រួលអាកាសធាតុសំដៅឆ្លើយតបនឹងបញ្ហាដ៏ប្រឈមនេះនាពេលអនាគតឱ្យកាន់តែទូលំទូលាយ ស៊ីជម្រៅ និងចំទិសដៅ ដោយគាំទ្រដល់សរសរស្តម្ភទាំង ៤ ជុំវិញអភិបាលកិច្ចល្អនៃយុទ្ធសាស្ត្រចតុកោណពោលគឺៈ ***ការលើកស្ទួយវិស័យកសិកម្ម ការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស និងការអភិវឌ្ឍផ្នែកឯកជន និងការងារ***។ គោលនយោបាយនេះត្រូវផ្តល់អាទិភាព ជាពិសេសដល់វិស័យដែលជាឆ្អឹងខ្នងនៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ដូចជាវិស័យកសិកម្ម ធនធានទឹក ជលផល ព្រៃឈើ តំបន់ការពារធម្មជាតិ ថាមពល ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ក៏ដូចជាបញ្ហាអន្តរវិស័យនានា រួមមានការពង្រឹងស្ថាប័ន ការកសាងធនធានមនុស្ស ការសិក្សាស្រាវជ្រាវ ការកៀរគរធនធានហិរញ្ញវត្ថុ ការអនុវត្តបច្ចេក វិទ្យាសមស្រប ការអប់រំ និងលើកកម្ពស់ការយល់ដឹងពីបញ្ហាយេនឌ័រ តាំងពីថ្នាក់ជាតិ រហូតដល់ថ្នាក់ក្រោមជាតិ។

### យុទ្ធសាស្ត្រទី ១: ការរៀបចំ និងពង្រឹង ស្ថាប័ន គោលនយោបាយ ច្បាប់ និងផែនការ

- ពង្រឹងសមត្ថភាពគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និង ក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ
- ជម្រុញ និង គាំទ្រការរៀបចំអង្គភាពទទួលខុសត្រូវការងារប្រែប្រួលអាកាសធាតុនៅតាមក្រសួង-ស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- សម្របសម្រួលការពិនិត្យ និងរៀបចំបរិធានច្បាប់ពាក់ព័ន្ធនឹងការងារប្រែប្រួលអាកាសធាតុ ដោយរួមទាំងបរិធានច្បាប់គ្រប់គ្រងឥណទានកាបូន
- ជម្រុញការរៀបចំ គោលនយោបាយ ច្បាប់ និងផែនការនានាឆ្លើយតបការងារប្រែប្រួលអាកាសធាតុ កម្ពុជា

- គាំទ្រការរៀបចំផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុតាមវិស័យពាក់ព័ន្ធ
- ជម្រុញការបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុ ទៅក្នុងគោលនយោបាយ និងផែនការនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងតាមវិស័យពាក់ព័ន្ធ

**យុទ្ធសាស្ត្រទី២: កសាងសមត្ថភាព អប់រំផ្សព្វផ្សាយ និងលើកកំពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ**

- ជម្រុញការកែលំអរចនាសម្ព័ន្ធ រៀបចំប្រព័ន្ធព័ត៌មាន និងចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុ ត្រួតពិនិត្យ និងវិភាគលើការផ្តល់ចំណេះដឹង និងព័ត៌មាននានា
- លើកកំពស់គុណភាពបណ្តាញផ្សព្វផ្សាយព័ត៌មានអោយមានលក្ខណៈជាប្រព័ន្ធ និងមាន ស្តង់ដាច្បាស់លាស់
- ជម្រុញការរៀបចំវិធីសាស្ត្រផ្សព្វផ្សាយ គោលការណ៍ណែនាំ និងបែបបទប្រតិបត្តិតាមស្តង់ដាបច្ចេកទេស
- ជម្រុញការលើកកំពស់ ការពង្រឹងសមត្ថភាព និងការងារសិក្សាស្រាវជ្រាវនៅតាមស្ថាប័នពាក់ព័ន្ធនានា
- បង្កើនភាពសំបូរបែបនៃព័ត៌មានទាក់ទងនឹងការប្រែប្រួលអាកាសធាតុទៅក្នុងការអប់រំទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ
- លើកកម្ពស់ការបញ្ជ្រាបចំណេះដឹងនិងព័ត៌មានអំពីការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីសិក្សាឱ្យកាន់តែទូលំទូលាយ
- ជម្រុញការរៀបចំឯកសារជាមូលដ្ឋានឯកសារនានាសម្រាប់បំរើការងារផ្សព្វផ្សាយទាក់ទងការងារប្រែប្រួលអាកាសធាតុ
- គាំទ្រ និងជំរុញការអនុវត្តប្រព័ន្ធផ្តល់ព័ត៌មានជាមុន តាមរយៈបណ្តាញផ្សព្វផ្សាយព័ត៌មានទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

**យុទ្ធសាស្ត្រទី៣: ជម្រុញការអនុវត្តវិធានការបន្សាំនឹងការប្រែប្រួលអាកាសធាតុ**

- ជម្រុញការអនុវត្តនិងធ្វើបច្ចុប្បន្នកម្មកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- រៀបចំផែនការបន្សាំនឹងការប្រែបរួលអាកាសធាតុជាតិ (National Adaptation Plan) ជម្រុញការសិក្សាស្រាវជ្រាវវាយតម្លៃភាពងាយរងគ្រោះ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- សិក្សាវាយតម្លៃលើតម្រូវការបច្ចេកវិទ្យាបន្សាំនឹងការប្រែប្រួលអាកាសធាតុនិងជម្រុញការផ្ទេរបច្ចេកវិទ្យាសមស្របដែលងាយអនុវត្តចំណាយតិចតែផ្តល់ប្រសិទ្ធភាពខ្ពស់

- ជម្រុញការអនុវត្តបណ្តាវិធានការបន្សាំ និងកសាងភាពធន់ទ្រាំនានា ដែលគាំទ្រដល់ យុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ ដូចជា ការលើកស្ទួយផលិតភាព ការបង្កើនផ្ទៃដីដាំដុះ ការបង្កើនរដូវដាំដុះ និងពិពិធភាវូបនីយកម្ម។

**យុទ្ធសាស្ត្រទី៤: ជម្រុញការអភិវឌ្ឍដែលបញ្ចេញកាបូនតិច**

- កែលំអសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យមូលដ្ឋាន
- រៀបចំប្រព័ន្ធចុះបញ្ជីគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ
- សិក្សានិងវាយតម្លៃលើសក្តានុពលកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីវិស័យពាក់ព័ន្ធ
- សិក្សា និងវាយតម្លៃលើបច្ចេកវិទ្យាកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងជម្រុញ ការផ្ទេរបច្ចេកវិទ្យាណាដែលឆ្លើយតបនឹងអាទិភាពអភិវឌ្ឍន៍ជាតិ
- ជម្រុញការអនុវត្តវិធានការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលគាំទ្រដល់ការអភិវឌ្ឍដោយចីរភាពដូចជា ការសន្សំសំចៃថាមពល ប្រសិទ្ធភាពថាមពល ការអភិវឌ្ឍថាមពលកកើតឡើងវិញ កិច្ចការពារនិងអភិរក្សព្រៃឈើ ការអនុវត្តគម្រោងឥណទានកាបូននានាដោយរួមទាំងយន្តការអភិវឌ្ឍន៍ស្អាត
- ជម្រុញការអភិវឌ្ឍបទដ្ឋានសំណង់ដែលរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

**យុទ្ធសាស្ត្រទី៥: លើកកំពស់សមត្ថភាពកៀរគរ ចាត់ចែង និងប្រើប្រាស់ធនធានដោយ ប្រសិទ្ធភាព**

- សិក្សាស្វែងយល់អំពីប្រភព និងយន្តការហិរញ្ញប្បទានប្រែប្រួលអាកាសធាតុនានា ទាំងទ្វេ ភាគី និងពហុភាគី
- ជម្រុញការរៀបចំ និងគ្រប់គ្រងយន្តការហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុជាតិ ដែលមានភាពទាក់ទាញ និងគួរឱ្យទុកចិត្តបាន កៀរគរធនធានសម្រាប់គាំទ្រដល់ការងារប្រែប្រួលអាកាសធាតុ។

**យុទ្ធសាស្ត្រទី៦: លើកកំពស់កិច្ចសហប្រតិបត្តិការថ្នាក់ជាតិ តំបន់ និងអន្តរជាតិ**

- បន្តរៀបចំរបាយការណ៍ជាតិក្រោមអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួល អាកាសធាតុ
- ចូលរួមក្នុងកិច្ចប្រជុំសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុដោយឈរលើផលប្រយោជន៍ជាតិ និងគោលការណ៍សំខាន់ៗនៃអនុសញ្ញាប្រែប្រួលអាកាសធាតុ
- ចូលរួមក្នុងកិច្ចប្រជុំថ្នាក់ជាតិ តំបន់ និងអន្តរជាតិនានា ស្តីពីការប្រែប្រួលអាកាសធាតុ
- ពង្រឹងភាពជាដៃគូរវាងវិស័យសាធារណៈ ឯកជន ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិលក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

## ៣. ការបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម (NSDP) ២០០៩-២០១៣

NSDP បច្ចុប្បន្នកម្មគឺជាឯកសារផែនការថ្នាក់ជាតិទី ១ ដែលទទួលស្គាល់ការប្រែប្រួលអាកាសធាតុថាជាបញ្ហាពហុវិស័យរួមចំណែកដាក់សម្ពាធលើសេដ្ឋកិច្ច និងជាអាទិភាពចំបងមួយរបស់រាជរដ្ឋាភិបាលៈ

- ដាក់ចុះនូវផែនការសកម្មភាពឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យពាក់ព័ន្ធផ្តោតលើ
- ពង្រឹងសមត្ថភាពរបស់លេខាធិការដ្ឋានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ
- ជំរុញ និងសម្របសម្រួលការបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុទៅក្នុងវិស័យពាក់ព័ន្ធ
- រៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
- ជំរុញនូវការបង្កើតមូលនិធិប្រែប្រួលអាកាសធាតុជាតិ
- ជំរុញការអនុវត្ត និងធ្វើបច្ចុប្បន្នកម្ម កម្មវិធីសកម្មភាពជាតិស្តីពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- បន្តកំណត់រកនិងជំរុញការអនុវត្តយន្តការអភិវឌ្ឍន៍ស្អាត និងគម្រោងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់នានា
- អប់រំ និងផ្សព្វផ្សាយដល់សាធារណជន ស្តីពីការប្រែប្រួលអាកាសធាតុ និង
- កៀរគរធនធាន និងការគាំទ្រសម្រាប់ដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ

## ៤. កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAPA)

កម្ពុជាបានទទួលថវិកាពីមូលនិធិបរិស្ថានពិភពលោក នាខែមិថុនា ឆ្នាំ២០០៣ដើម្បីរៀបចំកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុសំដៅឆ្លើយតបទៅនឹងតំរូវការបន្ទាន់របស់កម្ពុជាក្នុងការបន្សាំទៅនឹងឥទ្ធិពលអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យសំខាន់ៗមួយចំនួន ដូចជា កសិកម្ម ធនធានទឹក តំបន់ឆ្នេរ និងសុខភាពមនុស្ស។ កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុត្រូវបានរៀបចំឡើងដើម្បីឱ្យកម្ពុជាអាចឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុដោយគ្រោងទុកជាមុនដែលគណៈរដ្ឋមន្ត្រីបានអនុម័តក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៦។ គម្រោងនេះផ្តោតលើវិស័យមួយចំនួនរួមមានៈ

- តំបន់ឆ្នេរ : គម្រោងចំនួន ៨
- ជំងឺគ្រុនចាញ់ : គម្រោងចំនួន ៦
- កសិកម្ម និងធនធានទឹក : គម្រោងចំនួន ២០ និង
- ពហុវិស័យ : គម្រោងចំនួន ៥

ដែលមានគម្រោងសរុបចំនួន ៣៩ លើសំណើថវិកាសរុបចំនួន ១៩៦.៣៥០.០០០ ដុល្លារអាមេរិច ដែលក្នុងនោះមានគម្រោងអាទិភាពខ្ពស់ និងមធ្យមចំនួន ២០ លើសំណើថវិកា ១២៨.៨៥០.០០០ ដុល្លារអាមេរិច។

***ឯកសារអានបន្ថែម:***

- *របាយការណ៍ជាតិលើកទី១ ស្តីពីការប្រែប្រួលអាកាសធាតុឆ្នាំ២០០២*
- *ពង្រាងរបាយការណ៍ជាតិលើកទី២ស្តីពីការប្រែប្រួលអាកាសធាតុ ឆ្នាំ២០១២*
- *ផែនការសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុឆ្នាំ២០០៦*
- *របាយការណ៍ទិទស្សន៍ការអភិវឌ្ឍមនុស្សឆ្នាំ២០១១ ដោយ UNDP*
- *ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣*
- *ពង្រាងគោលនយោបាយបរិស្ថានជាតិឆ្នាំ២០១២*
- *យុទ្ធសាស្រ្តបរិស្ថានជាតិឆ្នាំ២០០៨-២០១៣*
- *យន្តការអភិវឌ្ឍន៍ស្អាតនៅកម្ពុជាឆ្នាំ២០១២*

## ទាក់ទងនឹងការងាររៀបចំដែនដី

### ១. បទបញ្ជាលេខ០១បបចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២របស់រាជរដ្ឋាភិបាលស្តីពី“ការពង្រឹងនិងការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច”

ដោយអនុលោមទៅតាមគោលនយោបាយស្តីពី **“ការពង្រឹងប្រព័ន្ធគ្រប់គ្រងបែងចែកនិងប្រើប្រាស់ដី”** ក្នុងគោលដៅធានាដល់ការប្រើប្រាស់ដីក្នុងគោលដៅសម្បទានដីសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាព និងចីរភាពដែលធានាដល់សមធម៌ដោយពង្រឹងនិងបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងការផ្តល់ជូននូវសម្បទានដីសេដ្ឋកិច្ច

រាជរដ្ឋាភិបាលបានដាក់ចេញនូវបទបញ្ជាឱ្យ ក្រសួងស្ថាប័ននិងអាជ្ញាធរពាក់ព័ន្ធដូចខាងក្រោមៈ

- ផ្អាកជាបណ្តោះអាសន្ននូវការផ្តល់សម្បទានដីសេដ្ឋកិច្ច
- ក្រសួងស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធត្រូវអនុវតគោលនយោបាយ( គោលនយោបាយស្បែកខ្លា) និង លក្ខខណ្ឌទាំងឡាយ ស្តីពីការផ្តល់ដីសម្បទានសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល ដែលមិនធ្វើឱ្យប៉ះពាល់ដល់ ប្រជាពលរដ្ឋ
- ដកហូតដីសម្បទានសេដ្ឋកិច្ចពីក្រុមហ៊ុនដែលបំពានកិច្ចសន្យាបំពានដីប្រជាពលរដ្ឋនិងសហគមន៍ដាក់ឱ្យនៅក្រោមការគ្រប់គ្រងរបស់រដ្ឋដោយផ្ទាល់

### ១. សេចក្តីណែនាំលេខ០១៧សណនកគងស្តីពីការអនុវត្តបទបញ្ជាលេខ០១បបចុះថ្ងៃទី០៧ខែឧសភាឆ្នាំ២០១២របស់រាជរដ្ឋាភិបាលស្តីពី “ការពង្រឹងនិងការបង្កើនប្រសិទ្ធិភាពនៃការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ចពាក់ព័ន្ធនឹងផ្លូវថ្នល់ផ្លូវដែក ផ្លូវលំ បឹង ទន្លេ ឆ្នេរនិងទីតាំងសាធារណៈ”

ដោយឃើញពីភាពចាំបាច់ និងបពាះាដែលកំពុងតែកើតមានយ៉ាងក្តៅគគុកនៅក្នុងវិស័យដីធ្លី និងដើម្បីជួយជម្រុញ និងគាំទ្រដល់ការអនុវត្តបទបញ្ជាលេខ០១បបស្តីពីវិធានការពង្រឹងនិងបង្កើនប្រសិទ្ធិភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់បានចេញនូវសេចក្តីណែនាំលេខ ០១៧ស.ណ.ន.ក.គ.ដើម្បីធានាបាននូវបទដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម និងររក្សានូវហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត សង្គមនិងបរិស្ថានក្នុងការធ្វើអត្តសញ្ញាណកម្ម និងចុះវាស់វែងដីជូនប្រជាពលរដ្ឋ ដីផ្លូវសាធារណៈ ព្រៃសហគមន៍ ដីសហគមន៍ បឹងឆ្នេរសមុទ្រច្រាំងទន្លេប្រឡាយនិងផ្លូវទឹកនានាដូចជាព្រែកអូរស្ទឹងជាដីសាធារណៈរបស់រដ្ឋដោយកំណត់ព្រំប្រទល់តាមការអនុវត្តកន្លងមកត្រូវរក្សាទុកជាដីសាធារណៈរបស់រដ្ឋ។

**២. ព្រះរាជក្រឹត្យនស.រកត.០២១២.០៧៩ចុះថ្ងៃទី០៦ខែកុម្ភៈឆ្នាំ២០១២ស្តីពី“ការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា” ( គអឆក)**

**គអឆក**ត្រូវបានបង្កើតឡើងដើម្បីធ្វើជាសេនាធិការផ្ទាល់របស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៏តំបន់ឆ្នេរសមុទ្រកម្ពុជាប្រកបដោយនិរន្តរភាពនិងការទទួលខុសត្រូវខ្ពស់ដែលមានវិសាលភាពអនុវត្តការងាររបស់ខ្លួនលើឆ្នេរសមុទ្រ ដីចំណីឆ្នេរសមុទ្រតំបន់រណបកោះដៃសមុទ្រស្ទឹងព្រែកផ្លូវទឹកដែលតភ្ជាប់ទៅនឹងសមុទ្រ និង ផ្ទៃទឹកដែលជាប់នឹងឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជាដែលមានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ និងមានតួនាទី និងភារៈកិច្ចដូចខាងក្រោមៈ

- រៀបចំគោលនយោបាយផែនការយុទ្ធសាស្ត្រផែនការមេផែនការសកម្មភាពកម្មវិធីនិងគម្រោងផ្សេងៗដែលទាក់ទងនឹងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ
- រៀបចំបទដ្ឋានគតិយុត្តនិងគោលការណ៏ចាំបាច់នានាដើម្បីធានាបាននូវការគ្រប់គ្រងការអភិរក្ស និងការអភិវឌ្ឍនៅតាមតំបន់ឆ្នេរសមុទ្រប្រកបដោយតម្លាភាពសមធម៌និងនិរន្តរភាពបរិស្ថាន
- ពិនិត្យនិងចាត់វិធានការចាំបាច់ដើម្បីទប់ស៉ាត់រាល់សកម្មភាពអសកម្មទាំងឡាយដែលប៉ះពាល់ដល់បរិស្ថាន និងធនធានធម្មជាតិនៅតាមតំបន់ឆ្នេរសមុទ្រ
- ពិនិត្យនិងវាយតម្លៃរាល់គម្រោងអភិវឌ្ឍ និងការអនុវត្តគម្រោងទាំងនេះនៅតាមតំបន់ឆ្នេរសមុទ្រឱ្យស្របតាមគោលការណ៏ណែនាំរបស់រាជរដ្ឋាភិបាលសម្រាប់ការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ
- ចូលរួមពិនិត្យនិងផ្តល់មតិជូនស្ថាប័នសម្ថកិច្ចចំពោះសំណើរស៊ីវិនិយោគដែលពាក់ព័ន្ធលើឆ្នេរសមុទ្រ ដីចំណីឆ្នេរសមុទ្រ តំបន់រណបកោះដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលតភ្ជាប់ទៅនឹងសមុទ្រ និងផ្ទៃទឹកដែលជាប់នឹងឆ្នេរសមុទ្រ
- ពិនិត្យតាមដាននិងសម្របសម្រួលរាល់សកម្មភាពដែលកំពុងអនុវត្តគ្រោងនឹងអនុវត្តរបស់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់អង្គការជាតិនិងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិលនានា និងផ្នែកឯកជនដែលមាននៅតាមតំបន់ឆ្នេរសមុទ្រ ដើម្បីឱ្យការងារមានភាពរលូន ប្រកបដោយប្រសិទ្ធភាព និងធានបាននូវនិរន្តរភាព
- បញ្ជ្រាបការយល់ដឹងដល់រដ្ឋបាលថ្នាក់ក្រោមជាតិផ្នែកឯកជននិងគ្រប់ភាគីពាក់ព័ន្ធឱ្យយល់ដឹងអំពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ
- ធ្វើសហការជាមួយនឹងក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោកនិងស្ថាប័នអន្តរជាតិពាក់ព័ន្ធនានាដើម្បីជម្រុញការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ
- អប់រំបណ្តុះបណ្តាលធនធានមនុស្សដើម្បីឆ្លើយតបនិងតម្រូវការក្នុងការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ

### ៣. ព្រះរាជក្រឹត្យនស.រកត.០៤១២.២៨១ចុះថ្ងៃទី០៦ខែមេសាឆ្នាំ២០១២ស្តីពី "ការតែងតាំងសមាសភាពអគ្គលេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា "

ថ្វីបើអគ្គលេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជាទើបតែបង្កើតឡើងនាពេលថ្មីៗនេះ តែកិច្ចការតំបន់ឆ្នេរមិនមែនជាកិច្ចការថ្មីសុទ្ធសាធនោះទេការងារនេះបានចាប់ផ្តើមជាបន្តបន្ទាប់ ដោយមានការអភិរក្សនិងអភិវឌ្ឍប្រកបដោយនិរន្តរភាព និងឆន្ទៈទទួលខុសត្រូវខ្ពស់បំផុតរបស់រាជរដ្ឋភិបាលរហូតក្លាយជាសមាជិកក្លឹបឆ្នេរសមុទ្រស្អាតជាងគេបំផុតលើសកលលោក។ ដើម្បីធានាដល់ដំណើរការការងារគ្រប់គ្រង និងអភិវឌ្ឍអនុវត្តទៅបានដោយរលូនសមាសភាពជាក់ស្តែងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជាត្រូវបានបង្កើតឡើង។ អគ្គលេខាធិការដ្ឋាននៃ**គអឆក**មានសមាសភាពចម្រុះចំនួន០៩រូបមកពីស្ថាប័នពាក់ព័ន្ធ។

### ៤. សារាចរណែនាំលេខ០១សរណនចុះថ្ងៃទី០៣កុម្ភៈ២០១២ស្តីពី "ការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា"

ឆ្នេរសមុទ្រកម្ពុជាត្រូវបានដាក់បញ្ចូលជាសមាជិកក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោកកាលពីថ្ងៃទី២៥ និងទី២៦ ខែឧសភា ឆ្នាំ២០១១ នៅទីក្រុងទូបាគូតាប្រទេសសេណាហ្គាល់ទាំងនេះគឺដោយសារភាពសម្បូរបែបនៃជីវចម្រុះភាពប្រណិតនៃបរិស្ថានធម្មជាតិតម្លៃអេកូស៊ីស្ទែមសេដ្ឋកិច្ច-សង្គមវប្បធម៌និងប្រពៃណីយក្នុងតំបន់។ ដើម្បីគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរឱ្យត្រឹមត្រូវមានប្រសិទ្ធិភាពនិងមានចីរភាពរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវសារាចរស្តីពី **"ការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា"** នេះឡើងដើម្បីណែនាំដល់ក្រសួងស្ថាប័នពាក់ព័ន្ធនិងរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យអនុវត្តនូវគោលការណ៍គ្រប់គ្រងប្រើប្រាស់ ថែរក្សាការពារ និងអភិវឌ្ឍតំបន់ឆ្នេរកម្ពុជាដែលរួមមានដែនគោកកោះ និងដែនទឹកដោយមានផែនការគ្រប់គ្រង និង អភិវឌ្ឍន៍តំបន់ឆ្នេរឱ្យបានត្រឹមត្រូវមានប្រសិទ្ធិភាពនិងចីរភាពដើម្បីចៀសវាង និង ទប់ស្កាត់ផលប៉ះពាល់ដល់ការអភិវឌ្ឍទេសចរណ៍សេដ្ឋកិច្ច-សង្គមបរិស្ថានវប្បធម៌និងប្រពៃណីក្នុងតំបន់ឆ្នេរសមុទ្រដែលចាំបាច់សម្រាប់អាជ្ញាធរដែលមានសមត្ថកិច្ចពាក់ព័ន្ធនឹងតំបន់ឆ្នេរសមុទ្រត្រូវរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី និងផែនការអភិវឌ្ឍតំបន់ឆ្នេរសមុទ្ររាល់ទីតាំងដែលពុំទាន់មានប្លង់គោលនិងផែនការប្រើប្រាស់ដី។ ការអភិវឌ្ឍនេះត្រូវបានកំណត់ដូចខាងក្រោម:

- **ឆ្នេរសមុទ្រ**ត្រូវកំណត់ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតនៃទឹកសមុទ្រឡើងមកលើរហូតដល់ខ្សែបន្ទាត់ហាមឃាត់ការកាន់កាប់សាងសង់នានាជាថ្នដីខ្សាច់ដែលបានកំណត់ទុកជាតំបន់សម្រាប់ប្រើប្រាស់ជាសាធារណៈ
- **ដីចំណីឆ្នេរសមុទ្រ**គឺជាផ្ទៃដីដែលចាប់រាប់ពីខ្សែបន្ទាត់ឆ្នេរខាងលើមកទិខាងដីគោកជាទូទៅប្រើប្រាស់សម្រាប់ជាសួនបៃតង និងបណ្តាញទេសភាព) សម្រាប់ដាំដើមឈើសំគាល់ព្រំឆ្នេរនិងចំណីឆ្នេរដោយបន្តទៅជាប់នឹងផ្លូវ

សាធារណៈដែលស្ថិតក្នុងទិសខាងដីគោកដែលការប្រើប្រាស់នេះមានលក្ខណៈ ពិសេសៗដោយឡែកពីគ្នាទៅតាមទីតាំងជាក់ស្តែង

- **ផ្លូវសាធារណៈតាមបណ្តោយដីចំណីឆ្នេរសមុទ្រ**គឺជាផ្លូវដែលសាងសង់ឡើងនៅជាប់ខ្សែបន្ទាត់ខាងក្រៅនៃដីចំណីឆ្នេរសមុទ្រដែលខណ្ឌចែកដីចំណីឆ្នេរសមុទ្រជាមួយតំបន់រណប ។ ផ្លូវនេះត្រូវមានចំណីផ្លូវទំហំយ៉ាងតិច១៥ម៉ែត្រពីសងខាងអ័ក្សផ្លូវ
- **តំបន់រណប**គឺជាតំបន់មួយប្លុកស្ថិតនៅចន្លោះផ្លូវសាធារណៈតាមបណ្តោយឆ្នេរសមុទ្រនិងផ្លូវស្របបន្ទាប់មួយទៀតដែលស្ថិតក្នុងទិសខាងដីគោក ។ រាល់ការអភិវឌ្ឍនិងការសាងសង់សំណង់នានានៅក្នុងតំបន់នេះត្រូវគោរពតាមប្លង់គោល និងផែនការប្រើប្រាស់ដីនិងបទប្បញ្ញត្តិជាធរមាន ។
- **ផ្លូវសាធារណៈ ផ្លូវថ្មើរជើងនិងសួនច្បារ) បណ្តាញបៃតងក្នុងទិសឆ្ពោះទៅមាត់សមុទ្រ** ដែលតភ្ជាប់ទៅចំណុចប្រសព្វនឹងផ្លូវដែលជាប់នឹងដីចំណីឆ្នេរសមុទ្រដោយរក្សាទុកចិញ្ចើមផ្លូវសងខាងយ៉ាងតិច៦ម៉ែត្រដើម្បីរៀបចំសួនច្បារផ្លូវថ្មើរជើងនិងដើមឈើនៅសងខាងបង្កើតជាបណ្តាញបៃតងភ្ជាប់ទៅនឹងដីចំណីឆ្នេរសមុទ្រ ។
- **ដែសមុទ្រ**គឺជាផ្ទៃទឹកដែលតភ្ជាប់ទៅនឹងសមុទ្រ ។
- **ស្ទឹងព្រែកផ្លូវទឹកដែលនាវាក្បូនអាចចេញ-ចូលបានបណ្តែតបាន** គឺជាផ្ទៃទឹកសាបដែលតភ្ជាប់ទៅនឹងផ្ទៃទឹកសមុទ្រ ។
- **ផ្លូវសាធារណៈតាមបណ្តោយដីចំណីដែសមុទ្រស្ទឹងព្រែកផ្លូវទឹកដែលនាវាក្បូនអាចចេញ-ចូលបានបណ្តែតបាន** គឺជាផ្លូវសាងសង់ឡើងនៅជាប់ខ្សែបន្ទាត់ខាងក្រៅនៃដីចំណីដែសមុទ្រស្ទឹងព្រែក ផ្លូវទឹក ដែលនាវា ក្បូនអាចចេញ-ចូលបានបណ្តែតបានទាំងនេះដែលខណ្ឌចែកដីចំណីដែសមុទ្រស្ទឹងព្រែកផ្លូវទឹកដែលនាវាក្បូនអាចចេញ-ចូលបានបណ្តែតបានជាមួយតំបន់រណប ។
- **កោះ**ជាផ្ទៃដីដែលហ៊ុមព័ទ្ធដោយទឹកសមុទ្រ ។ព្រំប្រទល់ដីកោះក្នុងសមុទ្រត្រូវកំណត់ត្រឹមខ្សែទឹកជោរអតិបរមាឡើងលើ ។កោះអាចជាកម្មវត្ថុសម្រាប់ការរស់នៅ និងការអភិវឌ្ឍស្របតាមគោលដៅនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចការពារជាតិនិងទេសចរណ៍ ។ រាល់ការអភិវឌ្ឍនិងសាងសង់នានា នៅលើកោះត្រូវមានសន្ទស្សន៍ទាបមធ្យមដោយការពារធនធានធម្មជាតិនិងរក្សាព្រៃឈើដែលមានស្រាប់យ៉ាងតិច៦០ភាគរយ ។ ត្រូវសង់សំណង់ដែលមានលក្ខណៈជាខ្មែរ ។ មានការគ្រប់គ្រងកាកសំណល់រឹងនិងរាវដោយត្រូវធ្វើការថែរក្សាការពារកែច្នៃ និងប្រើប្រាស់ធនធានសមុទ្រប្រព័ន្ធអេកូស៊ីស្ទែមជីវចម្រុះគ្រប់ប្រភេទដូចជាផ្កាថ្មត្រីនិងរុក្ខជាតិសមុទ្រជាដើមដែលមាននៅជុំវិញកោះសម្រាប់គោលដៅទេសចរណ៍ ។

- **ដែនទឹកសមុទ្រ**សំដៅដល់ផ្ទៃទឹកនៅខាងលើនិងក្នុងទឹក ។ដែនទឹកសមុទ្រដែលមានធនធានសមុទ្រ ប្រព័ន្ធអេកូស៊ីស្ទែមនិងជីវចម្រុះនានាដូចជាផ្កាថ្មត្រីធំតូចចម្រុះពណ៌និងរុក្ខជាតិសមុទ្រត្រូវគ្រប់គ្រងការពារអភិរក្ស និងអភិវឌ្ឍឱ្យបានត្រឹមត្រូវមានប្រសិទ្ធិភាពនិងប្រកបដោយចីរភាពការបូមខ្សាច់ និងការសាងសង់ផ្សេងៗ ដូចជាស្ថានីយសិក្សាស្រាវជ្រាវស្ថានីយ៍រុករករ៉ែត្រូវមានការយល់ព្រមពីរដ្ឋាភិបាល និងរក្សាច្រកផ្លូវនាវាធំៗ ចេញ-ចូលកំពង់ផែ ។
- រាល់ការអភិវឌ្ឍក្នុងតំបន់ឆ្នេរសមុទ្រនិងកោះនិងការធ្វើសកម្មភាពសេដ្ឋកិច្ចនិងទេសចរណ៍ត្រូវធានាដល់សុវត្ថិភាពសាធារណៈសង្គមបរិស្ថានដោយត្រូវគោរពតាមច្បាប់បទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេស អាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ។

## ៥. របាយការចុងក្រោយ(សៀវភៅទី១និង២) យុទ្ធសាស្ត្រជាតិសមាហរណកម្មតំបន់ឆ្នេរនិងប្លង់គោលក្រុងព្រះសីហនុ និងយុទ្ធសាស្ត្រអភិវឌ្ឍខេត្តកំពតសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព”

តំបន់ឆ្នេរសមុទ្រគឺជាប៉ូលសេដ្ឋកិច្ចដ៏សំខាន់មួយក្នុងចំណោមប៉ូលសេដ្ឋកិច្ចសំខាន់ៗទាំង៣របស់កម្ពុជា និងជាមុខព្រួញដ៏សំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមតាមរយៈវិស័យទេសចរដឹកជញ្ជូនឧស្សាហកម្ម ពាណិជ្ជកម្ម និងសេវាកម្ម។ ចំណុចសំខាន់របស់ឆ្នេរសមុទ្រកម្ពុជាគឺជាអ័ក្សអភិវឌ្ឍដ៏សំខាន់របស់កម្ពុជា និងអាស៊ាន ដែលក្នុងនោះអ័ក្សនៃតំបន់ឆ្នេរ តភ្ជាប់ពីខេត្តកោះកុងមកខេត្តព្រះសីហនុខេត្តកំពតនិងខេត្តកែបឆ្ពោះទៅប្រទេសថៃ និង វៀតណាមព្រមជាមួយផ្លូវអាស៊ានហាយវេលេខ១២៣និងភ្ជាប់មករាជធានីភ្នំពេញ តាមរយះអ័ក្សអភិវឌ្ឍភ្នំពេញ-ព្រះសីហនុជាមួយផ្លូវអាស៊ានហាយវេលេខ១១និងតភ្ជាប់ទៅអន្តរជាតិតាមផ្លូវទឹកសមុទ្រជ្រៅបំផុតរបស់កម្ពុជា ។ **“យុទ្ធសាស្ត្រជាតិសមាហរណកម្មតំបន់ឆ្នេរនិងប្លង់គោលក្រុងព្រះសីហនុ និង យុទ្ធសាស្ត្រអភិវឌ្ឍខេត្តកំពតសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព”** ត្រូវបានរៀបចំដោយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់សហការណ៍ជាមួយនិងអង្គការកិច្ចសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ក្នុងគោលបំណងបង្កើតនូវយុទ្ធសាស្ត្រជាតិសមាហរណកម្មតំបន់ឆ្នេរនិងប្លង់គោលខេត្តព្រះសីហនុសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព តាមរយះការពិគ្រោះយោបល់ជាសាធារណះ ។ ដោយឈរលើកិច្ចសហការពីគ្រប់ភាគីពាក់ព័ន្ធទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិការកំណត់គម្រោងជាក់លាក់និងការគ្រប់គ្រងរួមគ្នានៅក្នុងគោលដៅនៃការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាពនិងចីរភាពដើម្បីជាប្រយោជន៏ដល់សង្គមសេដ្ឋកិច្ចបរិស្ថានដោយផ្សារភ្ជាប់នឹងយន្តការនៃការធ្វើអភិបាលកិច្ចរួមគ្នាការធ្វើផែនការរួមគ្នានិងការគ្រប់គ្រងនិងប្រើប្រាស់រួមគ្នា ។

## ៦. យុទ្ធសាស្ត្រអភិវឌ្ឍន៍ផែនការរៀបចំដែនដី

ដំណើរការនគរូបនីយកម្មត្រូវបានកើតឡើងដោយសារអ្នកចំណាកស្រុកពីជនបទមកទីក្រុង ហើយការចំណាកស្រុកនេះកើតឡើងដោយសារមានសម្ពាធសង្គម២យ៉ាងគឺឥទ្ធិពលរុញច្រាននិងឥទ្ធិពលអូសទាញ។ ពេលដែលទីក្រុងអាចផ្តល់កាលានុវត្តភាពការងារបានច្រើនទៅតាមតម្រូវការអ្នកចំណាកស្រុកបញ្ហាសង្គមនឹងត្រូវបានកាត់បន្ថយ។ ដូច្នេះការគ្រប់គ្រងកំណើន នគរូបនីយកម្ម ដែលប្រកបដោយប្រសិទ្ធភាពគួរតែត្រូវបានបង្កើតឡើងដោយមានការប្រុងប្រយ័ត្នដើម្បីពិនិត្យមើលលើសមត្ថភាពផ្ទុករបស់តំបន់ទីក្រុងនិងជនបទ។ ប្រសិនបើការបំផ្លាញបរិស្ថាន កើតឡើងដោយសារសកម្មភាពអភិវឌ្ឍន៍ កំណើនអភិវឌ្ឍន៍ប្រកបដោយចីរភាពគឺមិនអាចធានាបានទេនៅពេលអនាគត: វិស័យទេសចរណ៍នឹងមិនទទួលបានការលើកទឹកចិត្តហើយចំណាយសង្គម ខ្ពស់រួមជាមួយនឹងការបំផ្លាញ បរិស្ថាននឹងក្លាយជាបន្ទុករបស់អ្នកជំនាន់ក្រោយ។ ជួរឆ្នេរនិងតំបន់ព្រៃមានសារៈសំខាន់ណាស់ហើយពួកវាគួរតែត្រូវបានទទួលការការពារពីសកម្មភាពអភិវឌ្ឍន៍ដែលគ្មានសណ្តាប់ធ្នាប់។ រាល់មន្ត្រីដែលពាក់ព័ន្ធនឹងការរៀបចំផែនការនិងការគ្រប់គ្រងការអភិវឌ្ឍត្រូវតែយល់ដឹងពីទិដ្ឋភាពនេះហើយច្បាប់និងបទប្បញ្ញត្តិត្រូវតែត្រូវបានរឹតបន្តឹងដើម្បីឱ្យការប្រើប្រាស់ធនធានទាំងនោះមានប្រសិទ្ធភាពខ្ពស់ និងប្រកបដោយចីរភាព។

## ៧. យុទ្ធសាស្ត្រអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ

យុទ្ធសាស្ត្រនិងផែនការសកម្មភាពដើម្បីផ្តល់នូវបណ្តាញផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធដែលទាក់ទងនឹងខេត្តនីមួយៗគឺមានរៀបរាប់ដូចខាងក្រោម:

- ការកែលម្អនូវលក្ខខណ្ឌផ្ទៃកំរាលផ្លូវនៅផ្លូវជាតិលេខ ៤៨ និងមធ្យោបាយឆ្លងកាត់ព្រំដែននៅព្រំដែនរបស់ប្រទេសថៃ
- ការផ្តល់ជូនទាំងផ្លូវឧស្សាហកម្ម និងផ្លូវទេសចរណ៍ និងការកែលម្អផ្លូវជាតិលេខ ៤ និងផ្លូវ ជាតិលេខ៣
- កែលម្អមធ្យោបាយឆ្លងកាត់ព្រំដែននៅព្រំប្រទល់ប្រទេសវៀតណាមនិងការផ្តល់ទាំងផ្លូវដែលអាចទៅដល់កំពង់ផែកំពតនិងបណ្តាញផ្លូវថ្នល់របស់ក្រុងកំពតដែលជាទីប្រសព្វរវាងផ្លូវបីគឺផ្លូវជាតិលេខ៣ (ពីភ្នំពេញទៅកំពត) ផ្លូវជាតិលេខ៣ (ពីព្រះសីហនុទៅកំពត) និងផ្លូវជាតិលេខ ៣៣ (ពីកែបទៅកំពត)
- ការអភិវឌ្ឍផ្លូវឆ្នេរពីព្រំប្រទល់ប្រទេសវៀតណាមទៅកាន់កែប

## ៤. គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា

ទឹកនិងដីគឺជាធនធានធម្មជាតិដ៏សំខាន់ដែលជាមូលដ្ឋានគ្រឹះប្រើសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និង សម្រាប់ទ្រទ្រង់ជីវិត។ ដោយសារកំណើនប្រជាសាស្ត្រកំណើននៃការប្រើប្រាស់ធនធានធម្មជាតិ និងការប្រែប្រួលអាកាសធាតុគ្រប់ស្ថាប័នពាក់ព័ន្ធនឹងដីត្រូវមានយន្តការដឹកនាំការគ្រប់គ្រងនិងការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនិងចីរភាព។ ចក្ខុវិស័យនៃគោលនយោបាយជាតិរៀបចំដែនដីសំដៅធានាថាការគ្រប់គ្រងប្រើប្រាស់ការពារនិងអភិវឌ្ឍតាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដីនិងការធ្វើឱ្យរលូននូវវិធាន និងឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្ត្រនីមួយៗ។

ដោយកត្តាកំណើនប្រជាជនធនធានមានកំណត់និងដើម្បីធានានូវការផ្គត់ផ្គង់ការរៀបចំដែនដីត្រូវធ្វើឡើងទៅតាមលំដាប់នៃអាទិភាពចំពោះតំបន់ដែលមានលំដាប់អាទិភាពចំពោះតំបន់ដែលមានកំណើនប្រជាជន និង សេដ្ឋកិច្ចខ្ពស់មានជាអាទិ៍ប៉ូលអភិវឌ្ឍរាជធានីភ្នំពេញប៉ូលអភិវឌ្ឍសៀមរាបនិងប៉ូលអភិវឌ្ឍព្រះសីហនុគឺជាប៉ូលនៃកំណើនខ្ពស់ដែលបានលេចចេញជារូបរាងពិតប្រាកដតាមរយៈសក្តានុពលនិងសកម្មភាពព្រមទាំងអ័ក្សនៃការអភិវឌ្ឍរួមមានអ័ក្សភ្នំពេញ-ព្រះសីហនុតាមបណ្តោយផ្លូវជាតិលេខ៤អ័ក្សភ្នំពេញ-តំបន់ឆ្នេរតាមបណ្តោយផ្លូវជាតិលេខ៣និងលេខ៤អ័ក្សតំបន់ឆ្នេរដែលភ្ជាប់ពីប្រទេសថៃកាត់តាមខេត្តកោះកុងខេត្តព្រះសីហនុខេត្តកំពត និងខេត្តកែបទៅប្រទេសវៀតណាម។

## ៥. សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលស្តីពីគោលនយោបាយដីធ្លី

**ចក្ខុវិស័យ**នៃគោលនយោបាយដីធ្លីនៅកម្ពុជាគឺ “គ្រប់គ្រងរៀបចំប្រើប្រាស់និងបែងចែកដីប្រកបដោយសមធម៌ តម្លាភាពប្រសិទ្ធភាពនិងចីរភាពដើម្បីរួមចំណែកធ្វើឱ្យសម្រេចគោលដៅជាតិនៃការកាត់បន្ថយភាពក្រីក្រ ការធានាសន្តិសុខស្បៀងការការពារបរិស្ថាននិងធនធានធម្មជាតិកិច្ចការពារជាតិនិងអភិវឌ្ឍសេដ្ឋកិច្ចសង្គមក្នុងបរិបទសេដ្ឋកិច្ចទីផ្សារ”។

អនុវិស័យដីធ្លីមាន៣គឺ: **អនុវិស័យរដ្ឋបាលដីធ្លី អនុវិស័យរៀបចំដែនដីនិង អនុវិស័យរដ្ឋបាលដីធ្លី។**

**<u>គោលបំណង</u>**

- **អនុវិស័យរដ្ឋបាលដីធ្លី:** ធ្វើការចុះបញ្ជីកម្មសិទ្ធិនិងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុទាំងអស់(រដ្ឋ និង ឯកជន) ឱ្យបានច្បាស់លាស់ធ្វើការផ្ទេរសិទ្ធិលើទ្រព្យទាំងនោះជាផ្លូវការទប់ស្កាត់និងដោះស្រាយវិវាទដីធ្លី សំដៅពង្រឹងសុវត្ថិភាពនៃការកាន់កាប់ដីធ្លីធានាបាននូវទំនុកចិត្តនិងប្រសិទ្ធិភាពនៃទីផ្សារដីធ្លី។
- **អនុវិស័យរៀបចំដែនដី:** គឺធានាការគ្រប់គ្រងការពារនិងការប្រើប្រាស់ដីនិងធនធានធម្មជាតិប្រកបដោយតម្លាភាពនិងប្រសិទ្ធិភាពដើម្បីរក្សានិរន្តរភាពបរិស្ថាននិងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយសមធម៌ នៅទីប្រជុំជន និង

ជនបទព្រមទាំងទប់ស្កាត់វិវាទលើការប្រើប្រាស់ដោយដាក់បញ្ញត្តិលើការអភិវឌ្ឍដីលើ ការកែសម្រួលក្បាលដីលើការសាងសង់លើការតាំងទីលំនៅជាថ្មីអនុលោមតាមច្បាប់ស្តីពីការរៀបចំ ទឹក ដី នគរូបនីយកម្ម និងសំណង់ក្របខណ្ឌយុទ្ធសាស្ត្រគោលនយោបាយដីធ្លីគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និងអភិបាលកិច្ចល្អ។

- **អនុវិស័យបែងចែកដីធ្លី:** គឺផ្តល់ទិសដៅច្បាស់លាស់ដើម្បីធ្វើការបែងចែកនិងការប្រើប្រាស់ដីរដ្ឋសម្រាប់គោលបំណងឯកជននិងសាធារណៈ ប្រកបដោយតម្លាភាព និងសមធម៌ដោយឆ្លើយតបទៅនឹងតម្រូវការដីរបស់ប្រជាពលរដ្ឋទូទៅជាពិសេសប្រជាពលរដ្ឋក្រីក្រយុទ្ធជនពិការនិងគ្រួសារយុទ្ធជនពលីដែលគ្មានដី និងខ្វះដីតាមរយៈកម្មវិធីសម្បទានដីសង្គមកិច្ច។

## ១០. អនុក្រឹត្យលេខ១១៨អនក្រ.បកស្តីពី“ការគ្រប់គ្រងដីរដ្ឋ”ចុះថ្ងៃទី៧ខែតុលាឆ្នាំ២០០៥នៅក្នុងអនុក្រឹត្យនេះបានចែងផងដែរអំពីការកំណត់ប្រភេទដីរដ្ឋ

ដីរដ្ឋសំដៅដល់ដីទាំងឡាយណាដែលជារបស់រដ្ឋហើយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង រឺស្ថាប័នថ្នាក់ជាតិ និងដីដែលត្រូវបានប្រគល់អោយនីតិបុគ្គលសាធារណៈ រឺគ្រឹស្ថានសាធារណៈ ដែលបានទទួលស្គាល់ដោយច្បាប់ថាជា នីតិបុគ្គលដើម្បីកានកាប់។ អនុក្រឹត្យនេះមានគោលដៅកំណត់គោលការណ៍ នីតិវិធីនិងការរៀបចំផ្នែកស្ថាប័នសម្រាប់ការគ្រប់គ្រងដីរដ្ឋលើៈ ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ ការចុះបញ្ជី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ការបង្កើត និងការថែរក្សាប្រព័ន្ធទិន្នន័យដីរដ្ឋ ការបែងចែក និការគ្រប់គ្រងដីរដ្ឋ និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ។ នៅក្នុងអនុក្រឹត្យនេះក៏បានចែងផងដែរអំពីការកំណត់ប្រភេទដីរដ្ឋ ដីសាធារណៈរបស់រដ្ឋជាដីដែលមានជាប់ផលប្រយោជន៍ជាសាធារណៈ និងស្ថិតនៅក្នុងប្រភេទជាក់លាក់នៃទ្រព្យដែលមានប្រយោជន៍សាធារណៈដូចខាងក្រោមៈ

ក. ទ្រព្យទាំងឡាយដែលបង្ហាញពីការកើតឡើងពីធម្មជាតិៈ

- ព្រៃឈើ
- ផ្លូវទឹកដែលនាវា រឺក្បូនអាចេញ ចូល បានបណ្តែតបាន
- បឹងធម្មជាតិ
- ច្រាំងទន្លេដែលនាវា រឺក្បូនអាចេញ ចូល បានបណ្តែតបាន
- ត្រើយសមុទ្រ

## ១១. សេចក្តីថ្លែងការណ៍ព្រាចាយ៉ាស្តីពីយុទ្ធសាស្ត្រអភិវឌ្ឍន៍ដោយចីរភាពសម្រាប់សមុទ្រអាស៊ីបូព៌ា

ជាឯកសារដែលបានរៀបចំឡើងដោយមានការចូលរួមពីរដ្ឋចំនួន១២នៅអាស៊ី-បូព៌ាដើម្បីពិភាក្សាអំពីគោលនយោបាយនិងសកម្មភាពសម្រាប់សម្រេចគោលបំណងអភិវឌ្ឍន៍ដោយចីរភាពនៃសមុទ្រនានានៅអាស៊ី-បូព៌ា។ យុទ្ធសាស្ត្រអភិវឌ្ឍន៍ដោយចីរភាពនៃសមុទ្រនៅក្នុងភូមិភាគអាស៊ីបូព៌ាផ្តល់នូវវិធានជាយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍ និងគ្រប់គ្រងធនធានសមុទ្រ និងតំបន់ឆ្នេរប្រកបដោយនិរន្តរភាពដោយធ្វើការយកចិត្តទុកដាក់ជាទីបំផុត ចំពោះការប្រើប្រាស់ការយល់ឃើញអំពីគុណតម្លៃ និងអាទិភាពខុសៗគ្នាដែលរាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានាបានកំណត់សម្រាប់ធនធានទាំងនោះ។ យុទ្ធសាស្ត្រនេះគឺជាការតម្រង់ទិស និងជាវិធានដ៏មានសារៈសំខាន់ទាំងនៅកម្រិតជាតិតំបន់ និងពិភពលោកដែលអាចឱ្យអាជ្ញាធរនិងអ្នកពាក់ព័ន្ធនានាចាត់វិធានការនិងដោះស្រាយបញ្ហាបរិស្ថាន និងធនធានធម្មជាតិនៅក្នុងមូលដ្ឋាន។

***ឯកសារសម្រាប់អានបន្ថែម:***

- *បទបញ្ជាលេខ០១បប ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២របស់រាជរដ្ឋាភិបាលស្ដីពី“ ការពង្រឹងនិងការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច”*
- *សេចក្ដីណែនាំលេខ០១៧សណន.កគដស្ដីពីការអនុវត្តបទបញ្ជាលេខ០១បបចុះថ្ងៃទី០៧ខែឧសភាឆ្នាំ២០១២របស់រាជរដ្ឋាភិបាលស្ដីពី “ការពង្រឹងនិងការបង្កើនប្រសិទ្ធិភាពនៃការគ្រប់គ្រងដី សម្បទានសេដ្ឋកិច្ចពាក់ព័ន្ធ នឹងផ្លូវថ្នល់ផ្លូវដែក ផ្លូវលំ បឹង ទន្លេ ឆ្នេរនិងទីតាំងសាធារណៈ”*
- *ព្រះរាជក្រឹត្យនស.រកត.០២១២.០៧៩ចុះថ្ងៃទី០៦ ខែកុម្ភះ ឆ្នាំ២០១២ស្ដីពី “ការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា” ( គអឆក)*
- *ព្រះរាជក្រឹត្យនស.រកត.០៤១២.២៨១ចុះថ្ងៃទី០៦ខែមេសាឆ្នាំ២០១២ស្ដីពី“ការតែងតាំងឧត្តមទីប្រឹក្សា...*
- *គោលនយោបាយជាតិស្ដីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា*
- *សេចក្ដីប្រកាសរបស់រាជរដ្ឋាភិតាំងសមាសភាពអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា”*
- *សារាចរណែនាំលេខ០១សរណនចុះថ្ងៃទី០៣កុម្ភះ២០១២ស្ដីពី“ ការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃ ព្រះរាជាណាចក្រកម្ពុជា”*
- *របាយការចុងក្រោយ( សៀវភៅទី១និង២) “យុទ្ធសាស្ត្រជាតិសមាហរណកម្មតំបន់ឆ្នេរនិងប្លង់គោលក្រុងព្រះសីហនុ និង យុទ្ធសាស្ត្រអភិវឌ្ឍន៍ខេត្តកំពតសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព”*
- *អនុក្រឹត្យលេខ១១៨អនក្រ.បកស្ដីពី“ ការគ្រប់គ្រងដីរដ្ឋ” ចុះថ្ងៃទី៧ខែតុលាឆ្នាំ២០០៥នៅក្នុងអនុក្រឹត្យនេះក៏បានចែងផង ដែរអំពីការកំណត់ប្រភេទដីរដ្ឋ*
- *សេចក្ដីថ្លែងការណ៍ពុត្រាចាយ៉ាស្ដីពី យុទ្ធសាស្ត្រអភិវឌ្ឍន៍ដោយចីរភាពសម្រាប់សមុទ្រអាស៊ី-បូព៌ា*

## ទាក់ទងនឹងគ្រោះមហន្តរាយ

## ១. ចំណុចលេចធ្លោនៃមុខសញ្ញាគ្រោះថ្នាក់

មុខសញ្ញាគ្រោះថ្នាក់ធម្មជាតិដែលប្រទេសកម្ពុជាជួបប្រទះគឺទឹកជំនន់និងរាំងស្ងួតព្រមទាំងមុខសញ្ញាគ្រោះថ្នាក់ផ្សេងៗទៀតដូចជា រោគរាតត្បាត ខ្យល់ព្យុះ ។ល។ ទឹកជំនន់បានជះឥទ្ធិពលមកលើប្រជាជនមួយចំនួនធំ ហើយបានបង្កឱ្យមានការខូចខាតយ៉ាងច្រើនក្នុងចន្លោះពេលពីឆ្នាំ១៩៨៧ដល់២០០៧។ គ្រោះទឹកជំនន់ក៏បានបណ្តាលឱ្យមានមនុស្សស្លាប់មួយចំនួនធំផងដែរ នោះក៏ដោយសារការកើតមានមកជាមួយនូវរោគរាតត្បាត។ ម្យ៉ាងវិញទៀត ការកើតមានគ្រោះរាំងស្ងួតក៏បានជះឥទ្ធិពលដល់សេដ្ឋកិច្ច និងការងារកសិកម្មរបស់ប្រជាជានព្រមទាំងផ្តល់នូវផលប៉ះពាល់ទៅលើវិស័យសេដ្ឋកិច្ច និង កសិកម្មរយៈពេលយូរ និងមានឥទ្ធិពលមិនល្អមកលើប្រជាជនដែលពឹងផ្អែកតែទៅលើទំនិញ និងសេវាកម្មដែលបានមកពីតំបន់ដែលរងគ្រោះដោយរាំងស្ងួត ប៉ុន្តែការកើតឡើងនូវគ្រោះរាំងស្ងួតនៅក្នុងប្រទេសគឺមានតិចជាងគ្រោះទឹកជំនន់។

## ២. ទឹកជំនន់

ទឹកជំនន់នៅកម្ពុជាគឺជាបញ្ហាមួយទាក់ទងនឹងភូមិសាស្ត្រ ដែលស្ថិតក្នុងចំណោមបញ្ហានានារបស់ប្រទេស។ ប្រការនេះធ្វើឱ្យប្រទេសកម្ពុជាងាយទទួលទឹកជំនន់ជារៀងរាល់ឆ្នាំ ជាពិសេសតាមបណ្តាបឹងទន្លេសាប និងតំបន់ទំនាបទន្លេមេគង្គ។ ទឹកជំនន់មានផលពីរយ៉ាង នៅពេលទឹកជំនន់ធំវាធ្វើឱ្យខូចបង់ ប៉ុន្តែបើទឹកជំនន់ធម្មតាធ្វើឱ្យមានផលប្រយោជន៍លើការចិញ្ចឹមជីវិតផ្អែកកសិកម្មព្រោះធ្វើឱ្យដីមានសំណើមនិងមានជីវជាតិសម្រាប់ដំណាំកសិកម្មបង្កប់ឡើងវិញនូវជាតិទឹកដែលបាត់បង់ទាំងនៅក្នុងដី និង នៅផ្នែកខាងលើហើយវាថែមទាំងមានផលប្រយោជន៍ ផ្នែកអេកូស៊ីស្ទែមសម្រាប់ពពួកត្រីទៀតផង ដែលប្រជាជនតាមដងទន្លេពឹង ផ្អែកលើការចិញ្ចឹមជីវិតរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ ប៉ុន្មានឆ្នាំកន្លងមកនេះ គ្រោះទឹកជំនន់បានក្លាយទៅហេតុការណ៍ដ៏ធ្ងន់ធ្ងរបណ្តាលឱ្យបាត់បង់ជីវិតមនុស្ស បំផ្លិចបំផ្លាញផលដំណាំ និងសត្វពាហនៈព្រមទាំងបង្កឱ្យមានការខូចខាតផ្ទះសំបែង និងបណ្តាញហេដ្ឋារចនាសម្ព័ន្ធនៅតាមមូលដ្ឋានទៀតផង(មានជាអាទិ៍ សាលារៀន មណ្ឌលសុខភាព ផ្លូវថ្នល់ និងស្ពាន)។ នៅក្នុងប្រទេសកម្ពុជាគ្រោះមហន្តរាយដោយទឹកជំនន់មានពីរប្រភេទសំខាន់ៗ។

## ៣. ទឹកជំនន់ទន្លេមេគង្គ

ការធ្លាក់ភ្លៀងផ្ទួនៗនៅតំបន់ខាងលើក្នុងមួយរដូវវស្សាហើយចរន្តទឹកហូរយឺតដែលនាំឱ្យទឹកឡើងរយៈពេលច្រើនថ្ងៃ។ ប្រការនេះអាចបង្កឱ្យកាន់តែដុនដាបដោយសារកត្តាពីរ:

**ទីមួយ:**នៅពេលកម្រិតទឹកទន្លេរួមផ្សំជាមួយទឹកភ្លៀងយ៉ាងគំហុកនៅតាមជុំវិញបឹងទន្លេសាបធ្វើឱ្យប៉ះពាល់ដល់បណ្តាខេត្តមួយចំនួននៅជុំវិញបឹងទន្លេសាប និងនៅប៉ែកខាងត្បូងនៃប្រទេស។

**ទីពីរ:** ទឹកជំនន់អាក្រក់ហួសហេតុជួបប្រទះនៅពេលមានទឹកភ្លៀងយ៉ាងខ្លាំងរួមគ្នាជាមួយការមកដល់នូវវិសម្ពាធ និងខ្យល់ព្យុះត្រូពិក

## ៤. ទឹកជំនន់រហ័ស

បណ្តាលមកពីការធ្លាក់ភ្លៀងយ៉ាងខ្លាំងច្រើនថ្ងៃនៅតំបន់ភ្នំ ហើយហូរចាក់មកស្ទឹង ទន្លេ ដោយស្របពេលនោះទឹកទន្លេឡើងខ្ពស់ធ្វើឱ្យទឹកស្ទឹងកើនឡើងលិច។ គ្រោះទឹកជំនន់មានរយៈពេល យូរបំផុតត្រឹមតែពីរ បីថ្ងៃប៉ុណ្ណោះ ប៉ុន្តែជារឿយៗបណ្តាលឱ្យមានការខូចខាតដល់ផលដំណាំ និងហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសតំបន់នៅតាមដងស្ទឹង ទន្លេ និងនៅតំបន់ជុំវិញបឹងទន្លេសាប។ ទឹកជំនន់ នេះធ្វើឱ្យប៉ះពាល់ដលល់ខេត្តមួយចំនួនដូចជា ខេត្តកណ្តាល កំពង់ស្ពឺ កំពត ពោធិសាត់ បាត់ដំបង កំពង់ឆ្នាំ រតនគីរី ព្រះវិហារ និងខេត្តឧត្តរមានជ័យ។

## ៥. រាំងស្ងួត

រាំងស្ងួតត្រូវបានពិចារណាទៅនឹងការពន្យារពេលនៃអាកាសធាតុហួតហែងខុសពីធម្មតាដែលមកពីមូលហេតុមានវិសមភាពនៃធារាសាស្ត្រក្នុងតំបន់។ ជាធម្មតាការធ្លាក់ភ្លៀងគឺចាប់ផ្តើមពីខែឧសភា ដល់ខែតុលា ហើយភ្លៀងធ្លាក់ច្រើនចាប់ពីខែសីហារហូតដល់ពាក់កណ្តាលខែតុលា ជាមួយនេះមានកូនរដូវប្រាំងក្នុងចន្លោះខែកក្កដា និងខែសីហា ចំនួនប្រហែលពី ២សប្តាហ៍ទៅ ៣សប្តាហ៍។ បើក្នុងមួយឆ្នាំរយៈពេលកូនរដូវប្រាំងនេះបានអូសបន្លាយពេលយូរគឺគ្រោះរាំងស្ងួតខាងកសិកម្មនឹងអាចកើតឡើងបន្ថែមទៅលើការធ្លាក់ភ្លៀងយឺតយ៉ាវ និងឆាប់បញ្ចប់រដូវវស្សា។ នៅក្នុងប្រទេសកម្ពុជា គ្រោះរាំងស្ងួតមាន ៤ប្រភេទ:

**ក.**មិនអាចទាយទុកជាមុនបានពីការធ្លាក់ភ្លៀងយឺតយ៉ាវ នៅដើមរដូវវស្សា

**ខ.**ភ្លៀងធ្លាក់មិនទៀងទាត់ ហើយបរិមាណទឹកភ្លៀង និងរយៈពេលនៃភ្លៀងធ្លាក់ខុសៗគ្នានៅតាមតំបន់

**គ.**រដូវភ្លៀងធ្លាក់រហ័សបញ្ចប់ក្នុងរដូវវស្សា

**ឃ.**ការកើតឡើងនៃកូនរដូវប្រាំងមានរយៈពេល៣សប្តាហ៍ឬច្រើនជាងក្នុងកំឡុងពេលរដូវវស្សាដែលអាចបណ្តាលឱ្យខូចខាតដល់ផលដំណាំផ្សេងៗដោយសារគ្មានប្រព័ន្ធស្រោចស្រព។ រាំងស្ងួតបានកំណត់កន្លែងជាក់ស្តែងនិងជាក់លាក់បំផុត ហើយម្យ៉ាងទៀតគឺនៅតំបន់ជាច្រើននៅក្នុងប្រទេសដែលរួមបញ្ចូលទាំងតំបន់ ដែលទទួលរងគ្រោះដោយសារគ្រោះទឹកជំនន់ផងដែរ។ គ្រោះរាំងស្ងួតបានប៉ះពាល់ដល់តំបន់មួយចំនួននៅក្នុងឆ្នាំ ២០០១ ២០០២ និង២០០៣។ ផលប៉ះពាល់ផ្ទាល់មានចំនួនច្រើនដោយសារតែបញ្ហាទឹកលើផលិតផលដំណាំកសិកម្ម ជាពិសេសផលិតផលស្រូវ និងបន្លែជាមួយដីកសិកម្ម ៨០% ដែលធ្វើឱ្យការដាំដុះលែងបានរយៈពេល ៦ខែ និងភ្ជាប់ជាមួយអត្រានៃការឆ្លងរោគ និងការស្លាប់ដោយសារជម្ងឺបណ្តាលមកពីទឹក។

## ៦. ការកើតមានជម្ងឺ និងរោគរាតត្បាត

ប្រទេសកម្ពុជាមានប្រវត្តិការកើតមានជម្ងឺ និងរោគរាតត្បាតមានដូចជា ជម្ងឺអាសន្នរោគ គ្រុនចាញ់ គ្រុនឈាម ហើយពេលថ្មីៗនេះមានវីរុសគ្រុនផ្តាសាយបក្សី (H5N1) ទៀតផង។ កង្វល់អំពីវីរុសគ្រុនផ្តាសាយបក្សី (H5N1) ដែលបានកើតយ៉ាងខ្លាំងកាលពីប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ ហើយបានគំរាមកំហែងយ៉ាងសាហាវនៅតាម ជនបទក្នុងខេត្តភាគខាងត្បូង នៃប្រទេសកម្ពុជា។ នៅឆ្នាំ២០០៥ ប្រទេសកម្ពុជាបានជួបប្រទះនូវការផ្ទុះនៃវីរុស គ្រុនផ្តាសាយបក្សី (H5N1)លើសត្វមាន់ ទាដែលធ្វើឱ្យប្រទេសកម្ពុជាជាប្រទេសមួយស្ថិតក្នុងចំណោមប្រទេសជាច្រើនក្នុងតំបន់ដែលជួបប្រទះនឹងការផ្ទុះឡើងនូវជម្ងឺបែបនេះដែរ។ ចាប់តាំងពីពេលនោះមកមាន ៧ករណី ដែលត្រូវបានគេអះអាងថាបានឆ្លងមកមនុស្សហើយបណ្តាលឱ្យស្លាប់មនុស្ស ៤នាក់ នៅឆ្នាំ២០០៥ នៅឆ្នាំ២០០៦ ស្លាប់ ២នាក់ និងឆ្នាំ២០០៧ ស្លាប់ ០១នាក់។ ការផ្ទុះឡើងនូវមេរោគនេះបាននឹងកំពុងបន្តដែលបាននាំឱ្យមានការអះអាងថាមានករណីឆ្លងទាំងបក្សីនិងមនុស្សនៅតាមបណ្តាប្រទេសជាច្រើនក្នុងតំបន់ក្នុងនោះក៏មានប្រទេស វៀតណាម ថៃ និងភូមាដែលជាប្រទេសជិតខាងកម្ពុជាផងដែរ។

## ៧. ខ្យល់ព្យុះ

ព្រឹត្តិការណ៍អាកាសធាតុដ៏ធ្ងន់ធ្ងរមានដូចជា ខ្យល់ព្យុះ ឬព្យុះសង្ឃរា មិនត្រូវបានចាត់ទុកថាជា បញ្ហាធំដុំសម្រាប់ប្រទេសកម្ពុជាឡើយពីព្រោះប្រទេសកម្ពុជាត្រូវបានហ៊ុំព័ទ្ធជុំវិញដោយជួរភ្នំ។ ប៉ុន្តែខ្យល់ព្យុះក៏កើតមានម្តងម្កាលនៅក្នុងប្រទេសហើយមួយចំនួននៃការខូចខាតដែលទាក់ទងនឹងខ្យល់ព្យុះបានបង្កឡើង ស្របពេលមានគ្រោះទឹកជំនន់ នៅក្នុងមូលដ្ឋានគួបផ្សំនឹង ទឹកភ្លៀងធ្លាក់យ៉ាងគំហុកផងដែរ។ ខ្យល់ព្យុះត្រូពិក ក៏អាចធ្វើអោយប៉ះពាល់ដល់កម្រិតកម្ពស់ទឹក ដែលបណ្តាលឱ្យមានជំនន់ទឹកទន្លេមេគង្គដូចដែលបានជួបប្រទះក្នុងបណ្តាឆ្នាំកន្លងមក។ ខ្យល់ព្យុះបានបោកបក់មកលើអាងទន្លេមេគង្គពីសមុទ្រចិនភាគខាងត្បូងឆ្ពោះទៅកាន់ទិសខាងកើត និងភាគអាគ្នេយ៍ឆ្លងកាត់ប្រទេសវៀតណាម និងចិនភាគខាងត្បូង។ ការខូចខាតធំបំផុតរមែងកើតមានឡើងក្នុងកំឡុងខែកញ្ញានិងខែតុលានៅពេលដែលលំហូរទឹកចេញពីអាងទន្លេមេគង្គមានកម្រិតខ្ពស់ស្រាប់ហើយគាប់ជួន និងកម្រិតទឹកភ្លៀងដ៏ខ្ពស់ជាលើកទី២ នៅក្នុងឆ្នាំក៏កើតឡើងផងដែរនោះគឺជាមូលហេតុនាំឱ្យមានទឹកជំនន់កើត ឡើង (MRC 2007) ។

## ៨. យុទ្ធសាស្ត្រជាតិគ្រប់គ្រងគ្រោះមហន្តរាយនិងការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

### ៨.១ ទស្សនវិស័យ

ឈានទៅកសាងសហគមន៍មានសមត្ថភាពទប់ទល់បានទៅនឹងគ្រោះមហន្តរាយដោយធម្មជាតិស្របតាមក្របខ័ណ្ឌការងារសកម្មភាពយូហ្គោ (HFA) ។

### ៨.២ ទិសដៅ

យុទ្ធសាស្ត្រជាតិនៃការគ្រប់គ្រងគ្រោះមហន្តរាយ និងការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយផ្សព្វផ្សាយស្របជាមួយនឹងផែនការជាតិ រួមស្ដីពីជម្ងឺផ្ដាសាយបក្សី និងជម្ងឺផ្ដាសាយបក្សីមនុស្ស (AHI) នៅខែកក្កដា ឆ្នាំ២០០៧។ យុទ្ធសាស្ត្រនេះមាន ៥ទិសដៅ:

**ក.** ពង្រឹងប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ

**ខ.** អភិវឌ្ឍន៍ធនធានមនុស្ស និងសមត្ថភាពស្ថាប័ន

**គ.** ពង្រឹងប្រព័ន្ធព័ត៌មានគ្រប់គ្រងគ្រោះមហន្តរាយ

**ឃ.** ពង្រឹងសមត្ថភាពត្រៀមរៀបចំ និងឆ្លើយតបគ្រោះមហន្តរាយ

**ង.** រួមបញ្ចូលគោលគំនិតការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការរបស់រាជរដ្ឋាភិបាលនៅគ្រប់ផ្នែកគ្រប់ថ្នាក់។

### ៨.៣ ផែនការសកម្មភាពសម្រាប់ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ គឺជាការទទួលខុសត្រូវរបស់ស្ថាប័នរាជរដ្ឋាភិបាលនៅគ្រប់ថ្នាក់ ហើយផែនការសកម្មភាពនេះមិនមែនជាផែនការ របស់ទីភ្នាក់ងារណាមួយររបស់រាជរដ្ឋាភិបាលនោះទេ។ ស្ថាប័នតែមួយរបស់រាជរដ្ឋាភិបាលក៏មិនមានលទ្ធភាព អនុវត្តរាល់ការផ្ដួចផ្ដើមការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយបានដែរ ពីព្រោះការកាត់បន្ថយគ្រោះភ័យនៃ គ្រោះមហន្តរាយជាបញ្ហាអន្តរវិស័យនៃការអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅកម្ពុជាអាចត្រូវបានអនុវត្តតាមរយៈអ្នកពាក់ព័ន្ធទាំងអស់ក្នុងប្រទេសដោយផែនការសកម្មភាពនេះដែលជាឯកសារគោលនឹងត្រូវបាន់យល់ព្រមទទួលយកពីភាគីពាក់ព័ន្ធចម្រុះដើម្បីអនុវត្តរួមគ្នា។

ផែនការសកម្មភាពត្រូវបានធ្វើបច្ចុប្បន្នភាពលើចំណុចសំខាន់ៗធ្វើការវិភាគលើចំណុចខ្វះខាតផ្សេងៗមួយចំនួនទៀតទៅលើគោលនយោបាយស្ដីពីការកាត់បន្ថយគ្រោះមហន្តរាយដែលមានស្រាប់ពីសំណាក់ក្រុមឬស្ថាប័ន ដៃគូពាក់ព័ន្ធដោយ

រួមមានទាំងមន្ត្រីគ្រប់គ្រងគ្រោះមហន្តរាយពីស្ថាប័នរាជរដ្ឋាភិបាលនៅមូលដ្ឋាន (កម្រិតខេត្ត ស្រុក និងឃុំ) អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ព្រមទាំងភ្នាក់ងារ និងស្ថាប័នម្ចាស់ជំនួយមួយ ចំនួនទៀត។

## ៨.៤ ក្របខ័ណ្ឌការងារនៃការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

ផែនការសកម្មភាពដែលបានលើកឡើងដោយផ្អែកលើក្របខ័ណ្ឌការងារសកម្មភាពយូហ្គោ (HFA) គឺបានរៀបចំក្នុងគម្រោងការគ្រប់ជ្រុងជ្រោយមួយដើម្បីចង្អុលណែនាំ អំពីការឆ្លើយតបរបស់អ្នកពាក់ព័ន្ធលើការ ដោះស្រាយផលប៉ះពាល់នៃគ្រោះមហន្តរាយ។ ប៉ុន្តែការសង្កត់ធ្ងន់ត្រូវបានតម្រង់ទៅរកការពង្រឹងសមត្ថភាពថ្នាក់ក្រោមជាតិ ជាពិសេសនៅថ្នាក់មូលដ្ឋានសហគមន៍ ដោយកំណត់ទិសដៅឱ្យបានច្បាស់លាស់សម្រាប់ការផ្តួចផ្តើម ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ និងដើម្បីគាំទ្រ ដល់ការសម្រេចឱ្យបាននូវគោលបំណង កាត់បន្ថយភាពក្រីក្ររបស់ប្រទេសដែលមាននៅក្នុងផែនការ និងគោលនយោបាយជាតិ(NSDP 2006-2010, NPRS. CMDG. NAPA 2006)។

## ៨.៥ ធានាឱ្យបាននូវការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយគឺជាអាទិភាពនៅថ្នាក់ជាតិ និងមូលដ្ឋាន

- រៀបចំដាក់លាក់គោលនយោបាយជាតិ និងនីតិកម្មក្នុងការគាំទ្រដល់ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ
- បង្កើត និងពង្រឹងយន្តការសម្របសម្រួលការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅថនាក់ជាតិ ឬកម្មវិធីជាតិស្តីពីការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ
- សមាហរណកម្មការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងផែនការ និងគោលនយោបាយអភិ-វឌ្ឍន៍ជាតិ
- ចាត់ចំណាយធនធានសមស្របសម្រាប់ការងារការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅថ្នាក់ជាតិ

## ៨.៦ ពង្រឹងការគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយនៅថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋានសហគមន៍

- វិមជ្ឈការការទទួលខុសត្រូវ និងធនធានសម្រាប់ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ
- លើកកម្ពស់ការអនុវត្តកម្មវិធីការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅមូលដ្ឋានសហគមន៍

## ៨.៧ កំណត់ប៉ាន់ប្រមាណ និងតាមដានត្រួតពិនិត្យមុខសញ្ញាគ្រោះថ្នាក់ និងលើកកម្ពស់ការផ្តល់ចំណឹងជាមុន

- ធ្វើការប៉ាន់ប្រមាណ ពីគ្រោះភ័យនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន

- បង្កើតប្រព័ន្ធព័ត៌មានគ្រប់គ្រងគ្រោះមហន្តរាយ
- កសាងប្រព័ន្ធផ្តល់ដំណឹងជាមុនពីពហុមុខសញ្ញាគ្រោះថ្នាក់
- សហការជាមួយអង្គការអន្តរជាតិ និងអង្គការថ្នាក់តំបន់លើកិច្ចខិតខំប្រឹងប្រែងការកាត់បន្ថយគ្រោះភ័យនៃគ្រោះ មហន្តរាយ

**៨.៨ ប្រើប្រាស់ចំណេះដឹង ការរកឃើញថ្មី និងការអប់រំដើម្បីកសាងវប្បធម៌សុវត្ថិភាព និងសមត្ថភាពទប់ទល់បាននៅគ្រប់ថ្នាក់**

- បង្កើតយន្តការសម្រាប់បណ្តាញការងារ និងការផ្លាស់ប្តូរព័ត៌មាន
- លើកកម្ពស់ការអប់រំ និងបណ្តុះបណ្តាលអំពីការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ
- លើកកម្ពស់ការបណ្តុះបណ្តាលយិនឌ័រ និងវប្បធម៌ភាពរហ័សរហួន ដែលជាសមាសភាគរួមរបស់ការកាត់បន្ថយ គ្រោះភ័យនៃគ្រោះមហន្តរាយ
- ដំណើរការស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ និងបច្ចេកទេសអំពីការគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយ
- បង្កើនការយល់ដឹងជាសាធារណៈ

**៨.៩ ការបញ្ជ្រាបការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងគោលនយោបាយ និងកម្មវិធីនានារបស់ក្រសួងពាក់ព័ន្ធ**

- រួមបញ្ចូលការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងការគ្រប់គ្រងធនធានធម្មជាតិនិងនិរន្តភាពបរិស្ថាន
- សមាហរណកម្មការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- បង្កើនសន្តិសុខស្បៀងដើម្បីបង្កើនសមត្ថភាពធន់ទ្រាំរបស់សហគមន៍
- សមាហរណកម្មការធ្វើផែនការការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងវិស័យសុខាភិបាល
- លើកកម្ពស់ការកាត់បន្ថយគ្រោះថ្នាក់តាមបែបរចនាសម្ព័ន្ធ និងមិនមែនរចនាសម្ព័ន្ធឱ្យបានសមស្រប
- រួមបញ្ចូលការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងការធ្វើផែនការប្រើប្រាស់ដី និងវិធានការបច្ចេកទេសផ្សេងៗទៀត
- បង្កើតទម្រង់បែបបទហិរញ្ញវត្ថុសម្រាប់ការដោះស្រាយគ្រោះភ័យនៃគ្រោះមហន្តរាយ ។

### ៨.១០ ពង្រឹងការត្រៀមរៀបចំសម្រាប់ឆ្លើយតបគ្រោះមហន្តរាយឱ្យមានប្រសិទ្ធភាពនៅគ្រប់ថ្នាក់

- ពង្រឹងសមត្ថភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសម្រាប់ការត្រៀមរៀបចំ និងឆ្លើយតប
- បង្កើននូវយន្តការប្រតិបត្តិការសម្របសម្រួលថ្នាក់តំបន់សម្រាប់ការងារសង្គ្រោះបន្ទាន់ដែលហួសពីសមត្ថភាពដោះស្រាយនៅថ្នាក់ជាតិ
- រៀបចំ និងធ្វើបច្ចុប្បន្នភាពតាមពេលវេលាលើការរៀបចំផែនការបម្រុងទុក និងការត្រៀមរៀបចំសម្រាប់គ្រោះមហន្តរាយ
- បង្កើតឱ្យមានមូលនិធិសង្គ្រោះបន្ទាន់

### ៨.១១ អាទិភាពនៃការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

ដោយសារតែខ្វះការយល់ដឹងពីការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ និង ការខ្វះខាតនូវធនធានមនុស្ស ធនធានហិរញ្ញវត្ថុបាន ធ្វើឱ្យការអនុវត្តនូវការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយអាចនឹងសម្រេច ជោគជ័យបានក្នុងរយៈពេលយូរ ដោយឆ្លងកាត់នូវដំណាក់កាលជាច្រើន។ សម្រាប់កិច្ចប្រឹងប្រែងរយៈពេលយូរនេះ ផែនការសកម្មភាពគឺធ្វើជាឧបករណ៍នៃកម្មវិធីដំបូង តាមរយៈការកំណត់នូវអាទិភាពយ៉ាងលម្អិតពីរាជរដ្ឋាភិបាល និងស្ថាប័នដៃគូអភិវឌ្ឍន៍ទាំងអស់ដែលអាចចាត់ចែង ដោយផ្ទាល់នូវថាមពលនិងធនធានរបស់ខ្លួនបាន។

គោលការណ៍ជ្រើសរើសសកម្មភាពអាទិភាពដែលអនុលោមតាមទិសដៅនិងគោលបំណងអភិវឌ្ឍន៍ថ្នាក់ជាតិជាពិសេសការកាត់បន្ថយភាពក្រីក្រនោះគឺបង្ហាញពីសមត្ថភាព និងបច្ចេកទេសស្ថាប័នដើម្បីអនុវត្តសកម្មភាពនិងគម្រោងកម្មវិធីព្រមទាំងការរំពឹងទុកថាមានធនធានមនុស្ស និងធនធានហិរញ្ញវត្ថុអាចចាត់ចែងប្រើបាន។ ផ្អែកលើលក្ខណៈវិនិច្ឆ័យនេះក្រុមការងារបច្ចេកទេសរបស់ SNAP បានចាត់ធ្វើសកម្មភាពតាមលំដាប់ថ្នាក់ និងកំណត់គម្រោងកម្មវិធីនៅក្នុងតារាងទៅតាមអាទិភាពកម្រិតទីមួយ ទីពីរ និងទីបី។

ការធ្វើអន្តរាគមន៍ដែលបានកំណត់គឺមានខ្លះត្រូវបានអនុវត្តរួចមកហើយ ដូច្នេះតម្រូវត្រឹមតែបន្ត ឬលើកតម្កើងថែមទៀតតែប៉ុណ្ណោះ។ បន្ថែមលើនេះ ការជ្រើសរើសទុកជាមុននូវអាទិភាពកម្រិតមធ្យម និងកម្រិតទាបដើម្បីកំណត់នូវសកម្មភាពនៃការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយមិនមែនមានន័យថា មិនអាចអនុវត្តបានភ្លាមៗនោះទេ ពីព្រោះការផ្តួចផ្តើមគំនិត ខ្លះមិនត្រូវការមូលនិធិនិងជំនួយបច្ចេកទេសទូលំទូលាយនោះឡើយ។ ទោះជាយ៉ាងណាក៏ដោយ ការរីកចំរើនលូតលាស់មានស្ថេរភាពឆ្ពោះទៅសម្រេចបាននូវគោលបំណងការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយរបស់ប្រទេសអាចនឹងត្រូវបរាជ័យ ប្រសិនបើគម្រោងអាទិភាពដែលបានកំណត់មកហើយមិនបានដោះស្រាយឱ្យបានមុននោះ។

## ៩. អាទិភាពសំខាន់ៗ

ក្នុងចំណោមវិធានការអាទិភាពខ្ពស់នៃការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយដែលបានកំណត់រួច ហើយត្រូវបានចំណាត់ថ្នាក់ជាការងារសំខាន់ឬបន្ទាន់។ វិធានការទាំងនេះមានជាអាទិ៍សមាសភាគទី១ ស្តីពីក្របខណ្ឌការងារ ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ដែលស្វែងរកនូវការធានាថា ទម្រង់នៃការកាត់បន្ថយ គ្រោះភ័យនៃគ្រោះមហន្តរាយគឺជាផ្នែករួមមួយនៃរបៀបវារៈអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល។ ការសម្រេចបាននូវគោលដៅកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយក្នុងរយៈពេលវែងអាស្រ័យលើការបង្កើតមូលដ្ឋានគ្រឹះរឹងមាំមួយដែលបានមកពីការផ្តួចផ្តើមគំនិត ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយផ្សេងទៀតដែលអាចដាក់ឱ្យប្រើប្រាស់បានកាន់តែមានប្រសិទ្ធភាព។

### *ក. អាទិភាពទី ១*

កិច្ចខិតខំប្រឹងប្រែងការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយក្នុងទ្រង់ទ្រាយទូលំទូលាយអាចកាន់តែមានប្រសិទ្ធភាព និងមានផលល្អថែមទៀតគ្រាន់តែទទួលរ៉ាប់រងបន្ទាប់ពីមានការកំណត់អាទិភាពពិត។ នៅពេលមានគោលនយោបាយ និងក្របខណ្ឌ័ការងារច្បាប់ ព្រមទាំងយន្តការសម្របសម្រួលការកាត់បន្ថយ គ្រោះភ័យនៃ គ្រោះមហន្តរាយរឹងមាំនៅក្នុងកន្លែងដែលមានជាអាទិភាពសំខាន់៧បីដែលគប្បីត្រូវបានដោះស្រាយ ពោលគឺ សមាហរណកម្មនៃការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ទៅក្នុងកម្មវិធីតាមវិស័យ និងដំណើរការរៀបចំផែនការរបស់ក្រសួងសំខាន់ៗ ការកាត់បន្ថយគ្រោះថ្នាក់ ការកាត់បន្ថយផលប៉ះ ពាល់ពីមុខសញ្ញាគ្រោះ ថ្នាក់ពី ធម្មជាតិ តាមរយៈការពង្រឹងសមត្ថភាពនៅតាមក៏រិតថ្នាក់ខេត្ត និងថ្នាក់ឃុំ និងការជួយរដ្ឋាភិបាល និងអាជ្ញាធរ មូលដ្ឋានដើម្បីរៀបចំ និងការឆ្លើយតបឱ្យប្រសើរឡើងទៅនឹងការជួបប្រទះមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ។ នៅពេលអនុវត្តនៃកិច្ចអន្តរាមន៍ទាំងនេះនឹងត្រូវបានធ្វើឡើងក្នុងរយៈពេលវែងផ្តល់នូវការ ការពារ ជាក់លាក់ និងផលប្រយោជន៍ច្រើនបំផុតដល់ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងតំបន់ដែលឆាប់ងាយទទួលមុខសញ្ញាគ្រោះថ្នាក់។

### *ខ. អាទិភាពទី២*

គម្រោងកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយមានបីប្រភេទមូលដ្ឋានដែលត្រូវបានចាត់ជាចំណាត់ថ្នាក់ជាអាទិភាពក៏រិតទី២។ ទីមួយគឺសកម្មភាព និងគម្រោងដែលបំពេញគ្នាទៅវិញទៅមកបន្ថែមទៀត និងលើកកម្ពស់ការអនុវត្តគម្រោងដោយឡែកការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៃអាទិភាព ក៏រិតទីមួយ សមាសភាគ ទី២ៈ ពង្រឹងសមត្ថភាពមូលដ្ឋានក្នុងការគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយ សមាសភាគ ទី៦ៈ ការត្រៀមរៀបចំគ្រោះមហន្តរាយសម្រាប់ការឆ្លើយតបឱ្យមានប្រសិទ្ធភាព។ ទីពីរគម្រោងការកាត់បន្ថយគ្រោះ ភ័យនៃគ្រោះមហន្តរាយដែលទាក់ទិននឹងសមាសភាគ ទី៣ៈ ការចាប់ផ្តើមធ្វើការប៉ាន់ប្រមាណលើគ្រោះភ័យ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន និងការប្រកាសឱ្យដឹងជាមុនតម្រូវឱ្យមានជំនួយ

បច្ចេកទេសច្រើនគួរសមថែមទៀត និងទិន្នន័យបញ្ចូល ពីព្រោះវាពាក់ព័ន្ធនឹងការអនុវត្តន៍ជំនាញថែមទៀត ដោយឡែក អ្វីដែលទាក់ទិននឹងការប្រើប្រាស់ឧបករណ៍ វិទ្យាសាស្ត្រ និងបច្ចេកទេសព្រមទាំងវិធីសាស្ត្រនានា។ ទីបី គម្រោងទាក់ទងសមាសភាគទី៤ ការប្រើចំណេះដឹងការគ្រប់គ្រងសម្រាប់ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយរួមបញ្ចូលគម្រោងការ និងការអនុវត្តយុទ្ធនាការការយល់ដឹងជាសាធារណៈអំពីការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយឱ្យបានទូលំទូលាយ។

***គ. អាទិភាពទី៣***

អាទិភាពទី៣គឺការអន្តរាគមន៍ដែលថ្លែងពីសកម្មភាពកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ និងមានសារៈសំខាន់សម្រាប់រយៈពេលវែងដោយមិនអាចធ្វើបានទៅនឹងការអនុវត្តក្នុងរយៈពេលដ៏ខ្លីនោះទេដោយឡែកការបង្កើតនិងការចាត់ចំណាយថវិកាពិសេសសម្រាប់ការត្រៀមរៀបចំ និងការកាត់បន្ថយគ្រោះថ្នាក់ការបង្កើន ក៏រិតមូលនិធិគ្រោះអាសន្នថ្មីៗ និងបទប្បញ្ញត្តិ ឯកសារផ្នែកហិរញ្ញវត្ថុសម្រាប់ការផ្ទេរគ្រោះភ័យនៃគ្រោះមហន្តរាយ (ឧ. គ្រោះមហន្តរាយ/ការធានារ៉ាប់រងលើដំណាំ)។ ការរួមបញ្ចូលផងដែរនៅក្នុងផ្នែកនេះគឺការបង្កើតភាពជាដៃគូ និងកិច្ចសហការជាមួយវិទ្យាស្ថានអប់រំ និងវិទ្យាសាស្ត្រជាតិ និងអន្តរជាតិដែលមិនលំបាកផ្តួចផ្តើមគំនិត ប៉ុន្តែការ ធ្វើបានយ៉ាងល្អបំផុតនោះ ក្រោយពីមានគម្រោងកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ដែលគេបានកំណត់ជាមូលដ្ឋានគ្រឹះថែមទៀតជាមួយក៏រិតចំណាត់អាទិភាព ដ៏ខ្ពស់ដែលត្រូវបានអនុវត្តមុនគេ។

## ១០. ការការពារគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត (ច្បាប់គ្រប់គ្រងធនធានទឹក)

នៅក្នុងច្បាប់ស្តីការគ្រប់គ្រងធនធានទឹកជំពូកទី៧បានលើកឡើងនូវវិធានការការពារគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត មាត្រាទី២៤សរសេរថា ក្នុងការការពារគ្រោះទឹកជំនន់ ក្រសួងធនធានទឹក និងឧតុនិយម ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានអាចប្រកាសកំណត់តំបន់ទំនាបជាតំបន់ស្រូបយកទឹកជំនន់។ នៅក្នុងតំបន់ការពារគ្រោះទឹកជំនន់ ក្រសួងធនធានទឹក និងឧតុនិយមរួមជាមួយស្ថាប័ននិងអាជ្ញាធរ មូលដ្ឋានពាក់ព័ន្ធត្រូវរៀបចំផែនការស្តីពីវិធានការទប់ស្កាត់ និងត្រួតពិនិត្យគ្រោះជំនន់ដើម្បីធានាសុវត្ថិភាពជីវិត មនុស្ស សត្វ និងទ្រព្យសម្បត្តិ។ ក្រសួងធនធានទឹក និងឧតុនិយមអាចហាមឃាត់ជាបណ្តោះអាសន្ននូវសកម្មភាពនានាដែលបង្កការខូចខាតដល់វិធានការការពារគ្រោះជំនន់ឬ ដែលរារាំងចរន្តទឹកហូរធម្មជាតិ។ ជាមួយគ្នានោះដែរ នៅត្រង់មាត្រាទី២៥បានបញ្ជាក់ថាក្នុងករណីដែលពិនិត្យឃើញថាសំណង់ការងារទឹកទាំងឡាយដែលមិនមានស្ថិរភាពគ្រប់គ្រាន់ ឬ អាចនឹងបង្កឱ្យមានមហន្តរាយប៉ះពាល់ដល់សង្គមជាតិ ក្រសួងធនធានទឹក និង ឧតុនិយមត្រូវពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានដើម្បីហាមឃាត់ជាបន្ទាន់តាមសមត្ថកិច្ចរៀងៗខ្លួន។ ចំណែកឯ នៅមាត្រាទី២៦វិញបានលើកឡើងថា នៅពេលមានគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ក្រសួងធនធានទឹក

និងឧត្តុនិយមជាសេនាធិការផ្ដល់ឱ្យរាជរដ្ឋាភិបាលក្នុងការចាត់ចែងការងារ ដោយរួមសហការជាមួយក្រសួងពាក់ព័ន្ធ និង អាជ្ញាធរមូលដ្ឋាន។

***ឯកសារសម្រាប់អានបន្ថែម:***

- *ច្បាប់ស្ដីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧*
- *យុទ្ធសាស្ត្រជាតិគ្រប់គ្រងគ្រោះមហន្តរាយ ២០០៨-២០១៣*
- *ពង្រាងច្បាប់គ្រប់គ្រងគ្រោះមហន្តរាយ ២០១២*
- *កម្រងឯកសារច្បាប់គ្រប់គ្រងគ្រោះមហន្តរាយ*

## ១. និយមន័យប្រភេទចំណាត់ថ្នាក់សំរាប់ទប់ទល់នឹងការកំពប់ប្រេង

ការទប់ទល់ប្រេងកំពប់ត្រូវបានគេចាត់ថ្នាក់ដោយយោងតាមទំហំប្រេងកំពប់ និងធនធានសំរាប់ទប់ទល់នឹងការកំពប់ប្រេង ដែលត្រូវការសំរាប់ចំណាត់ថ្នាក់នីមួយៗ:

**ចំណាត់ថ្នាក់ទី១:**ជាទូទៅកើតមានឡើងនូវព្រឹត្តិការណ៏តូចៗនៅក្នុងមូលដ្ឋាន ហើយចំពោះធនធានសំរាប់ទប់ទល់នឹងការកំពប់ប្រេង ត្រូវតែមាននៅក្នុងកន្លែងនោះផងដែរ។ ឧ. ប្រេងកំពប់ក្នុងចំណាត់ថ្នាក់ទី១ រួមមាន ការផ្ទេរប្រេងឥន្ទៈ ឬប្រេងខ្មៅនៅតាម**ចំណតផែប្រេង** ឬ ក៏ការកំពប់ប្រេងទ្រង់ទ្រាយតូចនៅតាម កំពង់ផែ។ ជាធម្មតា មិនត្រូវការសុំជំនួយពីខាងក្រៅទេសំរាប់ការទប់ទល់ការកំពប់ប្រេងចំណាត់ថ្នាក់ទី១។

**ចំណាត់ថ្នាក់ទី២:** គឺជាប្រេងកំពប់ទ្រង់ទ្រាយធំ ដែលនឹងអាចកើតមានឡើងនៅក្នុងតំបន់ជិតខាងនៃមជ្ឍមណ្ឌលទប់ទល់នឹងការកំពប់ប្រេង ឬ ការកំពប់ប្រេងទ្រង់ទ្រាយតូចនៅកន្លែងណាដែលឆ្ងាយ ហើយចំពោះ ធនធាន ពីប្រភពមួយចំនួនអាចនឹងត្រូវស្នើសុំជំនួយធនធានពីក្រុមហ៊ុនប្រេងឯកជន ក្រុមហ៊ុនផលិតប្រេង និងរដ្ឋាភិបាល។

**ចំណាត់ថ្នាក់ទី៣:** គឺជាទំហំសំរាប់ការកំពប់ប្រេងទ្រង់ទ្រាយធំ ដូចជាការគ្រោះថ្នាក់នាវាដឹកទំនិញធំៗ ដែលបណ្តាលឱ្យមានការលេចហៀរប្រេងខ្មៅ ឬការគ្រោះថ្នាក់នាវាដឹកប្រេងធំៗ ឬ ការផ្ទុះស្ថានីយ៏យកប្រេងនៅក្នុងសមុទ្រ។ ឧប្បត្តិហេតុក៏រិតទី៣ជាធម្មតានឹងត្រូវសុំជំនួយថ្នាក់ជាតិ និង អន្តរជាតិនូវធនធានសំរាប់ទប់ទល់នឹងការកំពប់ប្រេងទាំងស្រុង។

## ២. អនុសញ្ញាអន្តរជាតិពាក់ព័ន្ធការកំពប់ប្រេង

ផែនការនេះ អនុវត្តតាមតំរូវការអន្តរជាតិនានា ដែលមាននៅក្នុងអនុសញ្ញាដូចខាងក្រោម:

១. MARPOL 73/78

២. Civil Liability Convention 1992

៣. International Oil Pollution Compensation Fund Convention 1992

ចំពោះអនុសញ្ញាផ្សេងទៀត ដែលពាក់ព័ន្ធនឹងការទប់ទល់នឹងការកំពប់ប្រេងនឹងត្រូវអនុវត្តបន្ទាប់ពី ពេលដែលប្រទេសកម្ពុជាបានចុះហត្ថលេខារួច។

## ៣. ស្ថាប័ន និងការទទួលខុសត្រូវ

ក្រសួងសាធារណការ និងដឹកជញ្ជូន ជាស្ថាប័នដឹកនាំទទួលខុសត្រូវការបង្ការ ត្រួតពិនិត្យ និង ប្រយុទ្ធនឹងការបំពុល នៅក្នុងដែនសមុទ្រកម្ពុជា រួមទាំងតំបន់សេដ្ឋកិច្ចផ្តាច់មុខ។ ក្រសួងសាធារណការ និងដឹកជញ្ជូន អាចស្នើសុំជំនួយពីស្ថាប័ន និងភ្នាក់ងារពាក់ព័ន្ធនានារបស់រដ្ឋ និងផ្នែកឧស្សាហ៍កម្មឯកជន ព្រមទាំងធនធានស្ថាប័ន ឯកជនបរទេសផ្សេងទៀត។

## ៤. យុទ្ធសាស្ត្រសំរាប់ទប់ទល់នឹងការកំពប់ប្រេង

### ៤.១ អាទិភាពសំរាប់ការការពារ

" អាទិភាពសំរាប់ការការពារធនធានឆ្នេរសមុទ្រត្រូវផ្អែកលើការដឹងជាមុននៃធនធានដែលស្ថិតនៅក្នុងការចោទសួរ និង ទប់ទល់ត្រូវតែការពារបុគ្គលិកជាមុនដំបូងបង្អស់ "។ ផ្អែកតាមខ្លឹមសារខាងលើនេះយុទ្ធសាស្ត្រជាច្រើនត្រូវបានរៀបចំដើម្បី សំរេចនូវគោលបំណងដែលចង់បាន។

### *៤.២ វិធានការយុទ្ធសាស្ត្រទូទៅ*

- ប្រេង ត្រូវហ៊ុំព័ទ្ធ និង ប្រមូលយកតាមរបៀបណាដែលអាចប្រព្រឹត្តទៅបាន
- ប្រេង ត្រូវប្រមូលជាធម្មតាឱ្យគៀកទៅនឹងប្រភព បើសិនជាអាចប្រព្រឹត្តទៅបាន
- ការយកចិត្តទុកដាក់ ត្រូវបានបង្ការប្រេងមិនឱ្យទៅដល់ឆ្នេរសមុទ្រ
- សារធាតុគីមីបំបែកធាតុ ត្រូវបានគេពិចារណា បើសិនជាយន្តការការស្តារនីតិសម្បទារឡើងវិញ នោះមិនមាន ប្រសិទ្ធភាព ឬ មិនអាចប្រព្រឹត្តទៅបាន
- អាទិភាពសំរាប់ការការពារធនធានឆ្នេរសមុទ្រ ត្រូវពឹងផ្អែកលើការតំរូវរបស់ក្រសួងបរិស្ថាន។ *(ក្រសួង បរិស្ថានគួររៀបចំបញ្ជីនៃតំបន់ដែលតំរូវឱ្យមានកិច្ចការពារ) និង*
- ដំណើរការបំបែកធាតុដោយធម្មជាតិ ត្រូវប្រើប្រាស់លទ្ធភាពលាតសន្ធឹងយ៉ាងធំធេង។

### *៤.៣ យុទ្ធសាស្ត្រសំរាប់ការសំអាតនៅសមុទ្រ*

ត្រូវបានគេទទួលស្គាល់ថា ការប្រឹងប្រែង និង តម្លៃ ដែលបញ្ចូលគ្នាជាមួយនឹងការប្រមូលយកប្រេងនៅនឹងប្រភព មានតម្លៃមិនតិចជាងតំរូវការសំរាប់ការប្រមូលប្រេង និង ការសំអាតនៅលើឆ្នេរ។ ដូច្នេះអាទិភាពគឺកាត់បន្ថយ ឬ បញ្ចៀស មិនឱ្យប្រេងទៅប៉ះនឹងឆ្នេរសមុទ្រ។ យុទ្ធសាស្ត្រសំរាប់សំរេចការងារនេះ រួមមានៈ

- យន្តការហ៊ុំព័ទ្ធ និងប្រមូលយក

- សារធាតុគីមីបំបែកធាតុ
- ត្រៀមលក្ខណៈ
- យុទ្ធសាស្ត្រផ្សេងៗទៀត ដូចជាការដុតចោលនៅទីកន្លែង

### ៩.៤ យន្តការប្រព័ន្ធ និង ប្រមូលយក

យុទ្ធសាស្ត្រនេះអាចត្រូវបានប្រើប្រាស់នៅពេលដែលល័ក្ខខណ្ឌអាកាសធាតុ និង សមុទ្រ អំណោយផលដល់ឧបករណ៍ដែលមាន។ យុទ្ធសាស្ត្រពាក់ព័ន្ធនឹងការប្រើប្រាស់:

- ម៉ាស៊ីនបូមប្រេង
- ពោងគៀរប្រេង
- ទូក ឬនាវា
- អាងស្តុកប្រេងដែលបានប្រមូល

### ៩.៥ សារធាតុគីមីបំបែកធាតុ

វិធីសាស្ត្រនេះ ពាក់ព័ន្ធនឹងការប្រើប្រាស់សារធាតុគីមីដើម្បីជួយក្នុងការបំបែកធាតុ និង ការធ្វើឱ្យថយចុះនូវប្រេងអណ្តែត។ សារធាតុគីមីបំបែកអាចត្រូវបានគេបាញ់ទៅលើប្រេងអណ្តែតពីលើ:

- យន្តហោះ
- នាវាសមុទ្រ
- ឧទ្ធម្ភាគចក្រ

### ៩.៦ ការត្រៀមលក្ខណៈ

យុទ្ធសាស្ត្រត្រៀមលក្ខណៈអាចជាមធ្យោបាយដែលមានសុពលភាពធ្វើឱ្យប្រេងបំបែកធាតុ ដោយឯកឯង និង អាកាសធាតុ។ ជំរើសនេះត្រូវបានជ្រើសរើសនៅពេល:

- ទិសដៅប្រេងរសាត់ចាកចេញពីឆ្នេរសមុទ្រ និង ធនធានឯទៀត ដែលងាយធ្វើឱ្យរងគ្រោះ
- ប្រេងមានដង់ស៊ីតេ និង ភាពស្អិតទាប (ការរំហួត និង ការបំបែកធាតុដោយធម្មជាតិខ្ពស់)
- មានថាមពលរលកគ្រប់គ្រាន់ ដើម្បីកាត់បន្ថយបន្តិចម្តងៗនូវចំនួនប្រេងកំពប់លើផ្ទៃទឹកសមុទ្រ។

### ៩.៧ យុទ្ធសាស្ត្រសំរាប់ទប់ទល់តំបន់ឆ្នេរសមុទ្រ

តំបន់ឆ្នេរត្រូវបានគេឱ្យនិយមន័យនៅទីនេះដូចជាតំបន់ឆ្លងកាត់រវាងព្រំដែនខាងក្រៅនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខ និង

តំបន់ឆ្នេរសមុទ្រ ។ យុទ្ធសាស្ត្រសំខាន់ៗសំរាប់តំបន់ឆ្នេរគឺ:

- យន្តការហ៊ុំព័ទ្ធ និង ប្រមូលយក
- ការបំផ្លាតចេញពីធនធាន ដែលងាយទទួលរងគ្រោះ
- ការប្រើប្រាស់វត្ថុធាតុដែលស្រូបសំរាប់តំបន់ឆ្នេរ ដែលងាយទទួលរងគ្រោះ
- សារធាតុគីមីបំបែកធាតុសំរាប់តំបន់ដែលមិនងាយទទួលរងគ្រោះ

## ៩.៨ យុទ្ធសាស្ត្រសំរាប់ទប់ទល់ការកំពប់ប្រេងនៅតំបន់ឆ្នេរសមុទ្រ

បច្ចេកទេសផ្សេងៗ មានសំរាប់ការសំអាតប្រេងនៅតំបន់ឆ្នេរសមុទ្រ ដែលមានផលប៉ះពាល់ដោយការកំពប់ប្រេង ។ តំបន់ឆ្នេរសមុទ្រខ្លះត្រូវងាយទទួលរងគ្រោះណាស់ និង ការថែទាំពិសេសត្រូវបានអនុវត្តនៅក្នុងជំរើសបច្ចេកទេសសំរាប់តំបន់ទាំងអស់នេះ ។ វិធីសាស្ត្រសំរាប់ទប់ទល់នៅលើឆ្នេរសមុទ្រ រួមមាន:

- ការអនុវត្តស្រូបយកដោយដៃ
- ការអនុវត្តយកចេញនូវសំភារៈដែលប្រឡាក់ដោយប្រេង ( ដង ស្រោមដៃ រនាស់)
- ការសំអាតដោយដៃ និង យកចេញពីសារពើរុក្ខជាតិ
- ការបាញ់ទឹក ដែលមានសម្ពាធខ្សោយក្នុងសីតុណ្ហភាពធម្មតា
- រថយន្តបន្តុក ដែលមានម៉ាស៊ីនបូម
- ការលាងដោយទឹកក្តៅអ៊ុនៗ និង សម្ពាធខ្សោយ
- ការបាញ់ទឹក ដែលមានសម្ពាធខ្លាំង
- ការជុសចេញដោយដៃ
- ការលាងឆ្នេរខ្សាច់
- ត្រាក់ទ័រ និង រនាស់ ម៉ាស៊ីនឈូស ម៉ាស៊ីនកៀរ ការកើបដោយយោងឡើង ប្រដាប់ចូក
- ការបាញ់ខ្សាច់
- ការកែបំបាត់ជីវិត
- ការបំបែកធាតុ ( សារធាតុគីមីសំរាប់សំអាតឆ្នេរខ្សាច់)
- ការដុតនឹងទឹកន្លែង
- ការសំអាតដោយធម្មជាតិ

## ៩.៩ សុវត្ថិភាពបុគ្គលិក

គោលបំណងដែលត្រូវបង្កើតនៅដំណាក់កាលដំបូងនៃការទប់ទល់ និងត្រូវថែរទាំតាមរយៈដំណើការទាំងស្រុង គឺការការពារសុខភាព និង សុវត្ថិភាពបុគ្គលិកដែលទប់ទល់ប្រេងកំពប់ ។ ហានិភ័យដែលធ្វើឱ្យគ្រោះថ្នាក់ ចំពោះបុគ្គលិកអាចកើតពី:

- សុវត្ថិភាពយន្តហោះ និងនាវាសមុទ្រ
- បុគ្គលិកធ្វើការនៅសមុទ្រ
- ការធ្វើការនៅឆ្នេរ ដែលពោរពេញទៅដោយប្រេង
- ការធ្វើឱ្យគេដឹងពួពីសារធាតុគីមី និងឧទង្ការ (ប្រេងឆៅ)

## ៩.១០ ការទប់ទល់ពពួកសត្វប្រឡាក់ដោយប្រេង

សត្វស្លាប និង សត្វសមុទ្រទាំងអស់ ដែលរងប៉ះពាល់ដោយសារប្រេង មានវាសនានៅរស់ប្រសិនប្រសិនបើយុទ្ធសាស្ត្រនៃការសង្គ្រោះប្រកបដោយប្រសិទ្ធភាពការសំអាត និងការស្តារឡើងវិញត្រូវបានរៀបចំរួចជាស្រេចនោះ ។ ការទប់ទល់ត្រូវតំរូវឱ្យមានបុគ្គលិកដែលបានហ្វឹកហាត់ប្រកបដោយបទពិសោធន៏នៅក្នុងការព្យាបាលសត្វដែលរងប៉ះពាល់ដោយប្រេង ។

## ៩.១១ យុទ្ធសាស្ត្រសំរាប់ការស្តុក និង បោះចោលប្រេង និង កាកសំណល់

ប្រេង និង កាកសំណល់ដែលប្រឡាក់ប្រេងត្រូវបានបោះចោលនៅក្នុងវិធី ដែលគោរពទៅតាមលក្ខខណ្ឌរបស់ក្រសួងបរិស្ថាន ។

## ៩.១២ ឧបករណ៏សំរាប់ទប់ទល់នឹងការកំពប់ប្រេង

ឧបករណ៏សំរាប់ទប់ទល់នឹងការកំពប់ប្រេងអាចរកបានពីក្រុមហ៊ុនប្រេងឯកជននៅក្នុងប្រទេស ។

***ឯកសារសម្រាប់អានបន្ថែមៈ***

- *គោលនយោបាយជាតិវិស័យដឹកជញ្ជូន*
- *យុទ្ធសាស្ត្រជាតិវិស័យដឹកជញ្ជូន*
- *គោលការណ៍ណែនាំស្តីពីវិធានការឆ្លើយគ្រប់គ្រងការកំពុបប្រេង*
- *ពង្រាងច្បាប់ស្តីពីការដឹកជញ្ជូនផ្លូវទឹក*

  *ពង្រាងប្រកាសស្តីពីសំណល់គ្រប់គ្រងតាមកប៉ាល់ក្នុងការដឹកជញ្ជូនផ្លូវទឹក*
- *ពង្រាងច្បាប់ស្តីពីការដឹកជញ្ជូនតាមសមុទ្រ*
- *ពង្រាងច្បាប់ស្តីពីកំពង់ផែកម្ពុជា*
- *ពង្រាងផែនការយថាភាពដើម្បីឆ្លើយតបនឹងការកំពប់ប្រេង*
- *យុទ្ធសាស្ត្រឆ្លើតបនឹងការកំពប់ប្រេង*
- *សារាចរណែនាំស្តីពីផែនការកំពង់ផែសម្រាប់ការសាងសង់ និងប្រតិបត្តិការ*

## ជំពូកទី ៣: ករណីសិក្សាអំពីការបែងចែកចំណាត់ថ្នាក់តាមលក្ខណៈមុខងារនៃការប្រើប្រាស់តំបន់ឆ្នេរនៅខេត្តព្រះសីហនុ

តំបន់ឆ្នេរសមុទ្រ ក៏ត្រូវបានបែងចែក ដោយផ្អែកតាមលក្ខណៈមុខងារនៃការប្រើប្រាស់ឆ្នេរផងដែរ។ ទីកន្លែងសំរាប់អភិរក្ស និងការពារត្រូវបានចាត់ជា ***តំបន់អភិរក្ស តំបន់ការពារប្រភពទឹកស្អាត និងតំបន់ស្តារឡើងវិញ***។ តំបន់អភិវឌ្ឍន ត្រូវបានបែងចែកជាតំបន់ប្រើប្រាស់មានមុខងារបួនយ៉ាងគឺ ការនេសាទ វារីវប្បកម្ម ទេសចរណ៍ និងការគ្រប់គ្រងកំពង់ផែ ដែលជាតំបន់ប្រើប្រាស់ច្រើនយ៉ាង និងជាតំបន់អភិវឌ្ឍន៍ឧស្សាហកម្មតំបន់ឆ្នេរ។ ជាលទ្ធផលតំបន់ផ្សេងគ្នាទាំង ១២ត្រូវបានកំណត់នៅក្រោមសំណើគម្រោងតំបន់ប្រើប្រាស់ឆ្នេរក្រុងព្រះសីហនុដូចខាងក្រោមនេះ:

| **តំបន់ទី១: តំបន់ថែរក្សា និង អភិរក្ស** |
|---|
| **និយមន័យ**<br>• តំបន់ដី និងទឹក ដែលបានចាត់ទុកថាសំខាន់សំរាប់ការអភិរក្សទីជំរក និងការការពារ ថែរក្សាសត្វគ្រប់ប្រភេទ<br>• តំបន់តែមួយគត់ និងមានជំរកស្មុកស្មាញ និងមានជីវៈចំរុះច្រើនយ៉ាង<br>• ប្រព័ន្ធអេកូឡូស៊ី ដែលទ្រទ្រង់ពូជសត្វមានដោយកំរ និងជិតផុតពូជ<br>• ជាតំបន់មួយ ដែលសកម្មភាពកំសាន្តមួយចំនួនអាចត្រូវបានអនុញ្ញាត<br>• ជាតំបន់មួយ ដែលសកម្មភាពបន្ទាប់បន្សំខ្លះ អាចត្រូវបានអនុញ្ញាត ដល់ក្រុមអ្នកស្រុក ដែលរស់នៅក្នុងតំបន់ការពារនោះ |
| **គោលនយោបាយគ្រប់គ្រង:**<br>• ការពារ និងអភិរក្សទីជំរក ដែនដី-ដែនសមុទ្រ និង ប្រព័ន្ធអេកូឡូស៊ីអោយបានល្អ<br>• ការពារ និងអភិរក្ស មុខងារធម្មជាតិ នៃតំបន់ងាយរងគ្រោះ<br>• ការពារ ការបាត់បង់ទីជំរកតំបន់ឆ្នេររួមមាន ប្រភេទព្រៃលិចទឹក (ព្រៃកោងកាង) ផ្កាថ្ម ស្មៅសមុទ្រ ព្រៃឈើ និងប្រព័ន្ធមានជីវិត ដែលរស់នៅទីនោះ<br>• ការពារ និងថែរក្សាជីវៈចំរុះ<br>• ការពារ និងថែរក្សាប្រភេទសត្វ និងរុក្ខជាតិមានដោយកំរ និងជិតផុតពូជ<br>• ការពារ និងថែរក្សាតំបន់មានតម្លៃទេសភាពធម្មជាតិ<br>• ផ្តល់ការការពារ អោយតឹងរឹង ដល់ប្រព័ន្ធអេកូឡូស៊ី ដី និងសមុទ្រ ប៉ុន្តែអនុញ្ញាតអោយមានការចេញ-ចូលជាសាធារណៈសំរាប់ការកំសាន្តសប្បាយ |

- ផ្តល់ការការពារអោយតឹងរឹងដល់ប្រព័ន្ធអេកូឡូស៊ី ដី និងសមុទ្រ ប៉ុន្តែអនុញ្ញាតអោយមានការចេញ-ចូលសំរាប់តែអ្នករស់នៅក្នុងតំបន់ស្របតាមគោលបំណង នៃសកម្មភាពបន្ទាប់បន្សំជាប្រពៃណី
- ផ្តល់ការការពារអោយតឹងរឹងដល់ប្រព័ន្ធអេកូឡូស៊ី ដី និងសមុទ្រ ប៉ុន្តែអនុញ្ញាតអោយមានការចេញ-ចូលដល់ក្រុមអ្នកស្រាវជ្រាវក្នុងបំណងនៃដំណើរការ ស្រាវជ្រាវវិទ្យាសាស្ត្រ ដែលស្របជាមួយការអភិរក្ស

**ការប្រើប្រាស់ - សកម្មភាព ដែលបានអនុញ្ញាត**

- ការអភិរក្សទឹក ដី រុក្ខជាតិ និង សត្វ
- ការកំសាន្តខាងក្រៅដូច ជាការដើរ ការចែវទូក និងហែលទឹក ការមុជទៅក្នុងទឹក ដោយបំពាក់ឧបករណ៍
- សកម្មភាពគ្រប់គ្រងសត្វព្រៃ និង ការស្រាវជ្រាវវិទ្យាសាស្ត្រ
- ការកសាង និងថែរក្សាអគារមិនមែនជាលំនៅដ្ឋានពាណិជ្ជកម្ម ដែលជាគោលបំណងច្បាស់លាស់ ដូចជាមណ្ឌលពតិមាន រោងយាម ដែលមិនគួរអោយអាគារទាំងនេះ ស្ថិតនៅក្រៅតំបន់ការពារ
- ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដូចជាៈ ស្ពាន ផ្លូវ និងផ្លូវលំមានទីកន្លែងកំណត់ពិសេស
- ការកំណត់ការនេសាទជាលក្ខណៈគ្រួសារ និងការប្រមូលផលព្រៃឈើ អាចត្រូវបានពិចារណាក្នុងព្រឹត្តិការណ៍ដែលតំបន់នោះត្រូវបានតាំងទីលំនៅដោយក្រុមអ្នកស្រុក
- បង្កើតកសិកម្ម ដែលមានលក្ខណៈគ្រួសារ

**ការប្រើប្រាស់- សកម្មភាពហាមឃាត់**

- ការកាប់, ការរានព្រៃ និង ការប្រមាញ់សត្វ
- ការនេសាទហួសកំរិត និងការនេសាទខុសច្បាប់
- កសិកម្មខ្នាតធំ
- កប៉ាល់ដឹកទំនិញ និង ការចតកប៉ាល់ប្រេង
- ការចាក់ដីបំពេញ ការចាក់សំរាម ការចាក់សាប និងការជីកយកដី
- ការចាក់ចោលសារៈធាតុផ្សេងៗ
- ការទប់ទំនប់ រឺ ប្តូរទីតាំង
- ការសាងសង់ រឺ កែតម្រូវ
- ការសាងសង់ លំនៅដ្ឋានខុសច្បាប់ រឺ សំណង់អានាធិបតេយ្យ
- អាងស្តុក

- កន្លែងច្រោះទឹកសំអុយ, អាងប្រព្រឹត្តិកម្ម
- ការចាក់ចោល នូវសំណល់ចេញពីអាងប្រព្រឹត្តកម្ម, ទឹកសំអុយ
- ការបង្ហូរ រឺ ចាក់ចោលនូវជី និងសារៈធាតុគីមីមានគ្រោះថ្នាក់
- ដំណើរប្រព្រឹត្ត នៃឧស្សាហកម្ម និងរចនាសម្ព័ន្ធ
- ការរុករក និងទាញយករ៉ែ រួមទាំងខ្សាច់ និងគ្រួស

**តំបន់ទី២: តំបន់ការពារប្រភពទឹកស្អាត**

**និយមន័យ:**

- ទឹកសាបចេញពីដីតាមធម្មជាតិ និងដី ដែលនៅព័ទ្ធជុំវិញប្រភពទឹក។ ប្រភពទឹកចេញពីដីផ្តល់ដល់ប្រជាជន និង ឧស្សាហកម្ម នៃក្រុងព្រះសីហនុ នូវតំរូវការ ទឹកប្រើប្រាស់គ្រប់យ៉ាង ។

**គោលនយោបាយគ្រប់គ្រង:**

- ការពារ ការផ្គត់ផ្គង់ទឹក ប្រើប្រាស់ពីការរាំងស្ងួតប្រើហួសកំរិតការបំពុល រឺ ការគ្រប់គ្រងមិនបានល្អ
- ការពារ និងកាត់បន្ថយគ្រោះថ្នាក់ពីធម្មជាតិ ដល់សុខភាពសាធារណៈ សុវត្ថិភាព និង សុខមាលភាព ដោយការ ការពារ ភាពកខ្វក់ ដល់ប្រភពទឹកធម្មជាតិ

**ការប្រើប្រាស់- សកម្មភាព ដែលបានអនុញ្ញាត**

- ដាក់កំរិត អោយទាញយកទឹកប្រើប្រាស់ មិនអោយលើសពីលទ្ធភាពផ្តល់របស់វា
- ការត្រួតពិនិត្យការផ្គត់ផ្គង់ទឹក និងគុណភាពទឹក

**ការប្រើប្រាស់ - សកម្មភាព ហាមឃាត់:**

- ការឃ្វាលសត្វពាហនៈ នៅជុំវិញតំបន់ប្រភពទឹក
- ការហែលទឹកមុជទឹកធ្វើចរាចរទូក និងបណ្តាសកម្មភាពលំហែរផ្សេងៗ ទៀត
- ការចោលសំរាម រឺការធ្វើអោយកខ្វក់ដោយសារៈធាតុបំពុល
- ការដកចេញនូវរុក្ខជាតិព័ទ្ធជុំវិញ និងរបាំងធម្មជាតិការពារតំបន់នោះ
- ការអភិវឌ្ឍន៍ឧស្សាហកម្ម រឺ ទីលំនៅ
- ការកាប់រានព្រៃយកដី និងជីកដីចាក់លុប

**តំបន់ទី៣ : តំបន់ស្តារឡើងវិញ**

**និយមន័យ:**

- តំបន់ទាំងឡាយត្រូវបានគេកំណត់សំរាប់គោលបំណងជាក់លាក់នៃការធ្វើអោយប្រសើរ និងការធ្វើអោយដូចដើមវិញនូវប្រភពធនធានធម្មជាតិ ដែលបានរេចរិល ហើយនិងតំបន់ដែលមានសារៈសំខាន់ខាងផ្នែកប្រវត្តិសាស្ត្រ, វប្បធម៌ និង បុរាណវិទ្យា

***ឧទាហរណ៍:*** តំបន់ដីសើម, ព្រៃកោងកាង, ស្មៅសមុទ្រ, ផ្កាថ្ម, កេរ្តិ៍តំណែលវប្បធម៌ និង ប្រវត្តិសាស្ត្រ, វត្ថុបុរាណ និង តំបន់បុរាណវិទ្យា

**គោលនយោបាយគ្រប់គ្រង:**

- ស្តារឡើងវិញ នូវតម្លៃប្រវត្តិសាស្ត្រ និងធម្មជាតិ ដែលមានច្រើន នៅតំបន់ឆ្នេរ តាមរយៈសកម្មភាពធ្វើឱ្យប្រសើរឡើងវិញ និងការប្រើប្រាស់ បទបញ្ជា និង ច្បាប់
- ស្តារឡើងវិញនូវតម្លៃនៃសោភ័ណ្ឌភាព, គុណភាពទឹក និងតម្លៃជំរកធម្មជាតិ ដែលផ្តល់នូវការប្រើប្រាស់មានតម្លៃទាប ដែលមិនបង្វែរទិសដៅចេញពីតម្លៃធនធានទាំងនេះ

**ការប្រើប្រាស់ – សកម្មភាព ដែលបានអនុញ្ញាត**

- ការដាំឡើងវិញនូវៈ ព្រៃកោងកាង, ការដាំស្មៅសមុទ្រ និង ផ្កាថ្ម
- ការស្រាវជ្រាវខាងវិទ្យាសាស្ត្របរិស្ថាន
- សកម្មភាពស្តារឡើងវិញ នូវការខូចខាតវប្បធម៌ និងទីកន្លែងប្រវត្តិសាស្ត្រ

**ការប្រើប្រាស់ – សកម្មភាព ហាមឃាត់**

- គ្រប់សកម្មភាពនេសាទខុសច្បាប់
- ការធ្វើអាជីវកម្មផ្កាថ្ម ក្នុងតំបន់ផ្កាថ្ម និងក្នុងតំបន់ស្មៅសមុទ្រ
- ការកាប់, ការរានព្រៃកោងកាង
- ការបំផ្លាញ នូវរាល់ប្រភេទសត្វ និងរុក្ខជាតិ
- ហាមចតទូក និងធ្វើចរាចរ នៅតំបន់ផ្កាថ្ម និងសកម្មភាព ដែលបំផ្លាញស្មៅសមុទ្រ
- ការផ្លាស់ប្តូរតំបន់ដីសើម នៃប្រភេទណាមួយក្នុងតំបន់ ១, ២, រឺ ៣
- ការចាក់បំពេញ, ការលុបចោល,រឺការជីកកកាយយកផលលើកលែងតែមានគោលបំណងផ្លាស់ប្តូរសំខាន់ដែលត្រូវថែរក្សា រឺលើកកំពស់តំបន់ដីសើមជាតំបន់អភិរក្ស

**តំបន់៤ : តំបន់ប្រើប្រាស់តិចតួច សកម្មភាពទាប**

**និយមន័យ:**

| |
|---|
| តំបន់ប្រើប្រាស់ ដោយសកម្មភាពទាប រួមមានៈ តំបន់ទ្រនាប់ តំបន់បំរុងទុក និង Setback<br>• ***តំបន់ទ្រនាប់៖*** ជាតំបន់អោយប្រើប្រាស់មានកំរិតស្ថិតនៅក្បែរតំបន់ការពារ និងអភិរក្សធនធានធម្មជាតិ ដែលត្រូវបានគេកំណត់យកដើម្បីពង្រឹងការអភិរក្សធនធានជីវចំរុះអោយមានស្ថេរភាព។ តំបន់នេះអាចជាតំបន់ងាយទទួលរងគ្រោះថ្នាក់ ឬតំបន់សើម។ តំបន់នេះមានតួនាទីការពារតំបន់អភិរក្សធនធានធម្មជាតិ ពីផលប៉ះពាល់អវិជ្ជមាននានា ពីការអភិវឌ្ឍតំបន់នៅជុំវិញ។ តំបន់នេះរួមមានៈ តំបន់មានទេសភាពស្រស់ត្រកាល ដែលជួយទ្រទ្រង់ ដល់តំបន់ប្រើប្រាស់ សំរាប់កំសាន្ត និងសំរាប់ប្រជាជនក្នុងតំបន់ ដោយសកម្មភាពទាប ។ ឧ. កោះ និង តំបន់មាត់ពាមមួយចំនួន ។<br>• ***តំបន់បំរុងទុក :*** លក្ខណៈស្ថានភាពប្រពន្ធ័ និងទីជំរក នៅក្នុងតំបន់នេះ ងាយទទួលរងនូវការខូចខាតណាស់ ដូចជាៈ តំបន់ដីសើម ព្រៃលិចទឹក ផ្កាថ្ម និងកោះតូចៗ ជាដើម។ ល។ តំបន់ទាំងអស់នេះ ទាមទារអោយមានការគ្រប់គ្រងយ៉ាងត្រឹមត្រូវដើម្បីការពារថែរក្សា និងធ្វើអោយប្រសើរឡើងថែមទៀតនូវសុខភាព និង ស្ថានភាពប្រពន្ធ័របស់តំបន់នេះ ។<br>• ***តំបន់ Setback*** : តំបន់នេះ មានរយៈប្រវែងពី ៥០-២០០ម គិតចាប់ពីចំណុចដែលមានស្មៅដុះឡើងទៅ ។ ដោយផ្អែកទៅលើលក្ខណៈភូមិសាស្ត្រ និង ការប្រើប្រាស់ពីមុននៅក្នុងតំបន់នេះ ពុំអនុញ្ញាតអោយមានសកម្មភាពអភិវឌ្ឍន៏កើតឡើងទេក្នុងគោលបំណងការពារការហូរច្រោះ និងការបំផ្លាញតាមបណ្តោយឆ្នេរ ជំរកឆ្នេរ និងលក្ខណៈធម្មជាតិរបស់តំបន់ឆ្នេរ ។ |
| **ការប្រើប្រាស់ – សកម្មភាពអនុញ្ញាត**<br>• អភិរក្សធនធានធម្មជាតិដី-ទឹក រុក្ខជាតិ និងសត្វ<br>• បើកចំហអោយមានសកម្មភាពកំសាន្តដូចជា ការដើរកំសាន្តតាមភ្នំ ការហែលទឹក និងការជិះទូក<br>• សកម្មភាពគ្រប់គ្រងធនធានមច្ឆជាតិ និងសត្វព្រៃ<br>• ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងសេវាកម្មផ្សេងៗ ដូចជា មណ្ឌលពត៌មាន ស្ពាន ផ្លូវ ។ល។<br>• ការពារទំរង់ខ្សែទឹកតាមបណ្តោយឆ្នេរ គោលបំណងចំបង គឺដើម្បីលើកកំពស់កន្លែងនេះ សំរាប់ដាក់តំបន់អភិរក្ស និងតំបន់ទ្រនាប់ធម្មជាតិ សំរាប់ទប់ទល់ នឹងខ្យល់ព្យុះ<br>• តំបន់ប្រើប្រាស់ ដោយសកម្មភាពទាបផ្សេងៗទៀត ឧ. សកម្មភាពប្រកបរបចិញ្ចឹមជីវិត ជាលក្ខណៈប្រពៃណី |
| **ការប្រើប្រាស់ – សកម្មភាព ហាមឃាត់**<br>• ការប្រែប្រួលដីសើមតំបន់ឆ្នេរ |

- សកម្មភាព និងរចនាសម្ព័ន្ធឧស្សាហកម្ម
- សកម្មភាព រុករករ៉ែរួមមាន ការជីកយកខ្សាច់ និងគ្រួស
- ការជីកខួង ការបោះចោលកាកសំណល់ ពីការជីកខួង ការឈូស និងជីកកកាយ តាមបណ្តោយខ្សែទឹកសមុទ្រប្រសិនបើគ្មានសកម្មភាពណាមួយជួយការពារតំបន់នេះ ជាជំរកធម្មជាតិទេ។ ឧ. តំបន់ចំណីឆ្នេរ។
- ការបញ្ចេញចោល នូវសារៈធាតុ ដែលមិនធ្វើប្រព្រឹត្តិកម្មត្រឹមត្រូវ
- ការកាប់ព្រៃ ការបរបាញ់ ការធ្វើកសិកម្ម ឬ សាកវប្បកម្ម
- ការចាក់បំពេញដី ការចាក់សំរាម ការជីក រី ឈូសឆាយដី
- ការកសាងទំនប់ ឬការផ្លាស់ប្តូរទីលំនៅ
- ការស្តុកទុកអាងធំៗ ឬកុងទីន័រ
- ការបង្កើតអាងសំរាប់ធ្វើប្រព្រឹត្តិកម្មទឹកស្អុយ
- ការបញ្ចេញចោល កាកសំណល់មិនទាន់ធ្វើប្រព្រឹត្តិកម្ម ឬបញ្ចេញចោលទឹកស្អុយ
- ការបញ្ចេញចោល ឬការបោះចោលជីគីមី និងសារៈធាតុគីមី មានគ្រោះថ្នាក់
- ការធ្វើពាណិជ្ជកម្ម និងសង់លំនៅដ្ឋានក្នុងតំបន់ Setback " ដីចំណីសមុទ្រ "

**តំបន់៩: តំបន់ដំណាំកសិកម្ម**

**និយមន័យ:**

- តំបន់ ដែលចាត់ទុកជាកន្លែងសំខាន់ សំរាប់វិស័យផលិតផលដំណាំកសិកម្មនានា
- តំបន់នេះអាចត្រូវបែងចែក ជាតំបន់កសិកម្ម ដំណាំស្រូវ, ដំណាំរួមផ្សំនិងដំណាំហូបផ្លែនិងតំបន់កសិ-ឧស្សាហកម្ម

**គោលនយោបាយគ្រប់គ្រង:**

- ប្រើប្រាស់ដី អោយមានប្រសិទ្ធិភាព និងមាននិរន្តរភាពក្នុងវិស័យកសិកម្ម
- ការពារនូវការហូរច្រោះដីជីជាតិ និងការបាត់បង់ដីជាតិជីតាមរយៈសកម្មភាពផ្សេងៗ
- បង្កើតកម្មវិធី សំរាប់អភិវឌ្ឍន៍ដំណាំស្បៀង ក៏ដូចជា ដំណាំផ្សេងៗ
- បង្កើនផ្ទៃដីដាំដុះតាមរយៈការស្តារដី ដែលបោះបង់ចោល និងការផ្តល់នូវបច្ចេកទេសដល់កសិករ
- បង្កើនទិន្នផលដំណាំតាមរយៈការអនុវត្តន៍ នូវបច្ចេកទេសទំនើប

**ការប្រើប្រាស់-សកម្មភាព ដែលបានអនុញ្ញាត:**

- ការប្រើប្រាស់ដី សំរាប់ផលិតកម្ម ដំណាំដែលស្របច្បាប់

- ការប្រើប្រាស់ឧបករណ៍ និងបច្ចេកទេសសំរាប់ផលិតពូជដំណាំកសិកម្ម ជីនិងថ្នាំសំលាប់សត្វល្អិតដែលអនុញ្ញាតដោយច្បាប់
- ការបង្កើតសមាគម, សហគមន៍សំរាប់អភិវឌ្ឍន៏វិស័យកសិកម្ម

**ការប្រើប្រាស់-សកម្មភាព ហាមឃាត់ះ**

- ការប្រើប្រាស់ថ្នាំកំចាត់សត្វល្អិតខុសច្បាប់
- ការដាំដំណាំ ដែលហាមឃាត់

**តំបន់៦: តំបន់គ្រប់គ្រងការនេសាទ និងតំបន់កំពង់ផែនេសាទ**

**និយមន័យះ**

- តំបន់ដែលបានចាត់ទុកជាកន្លែងសំខាន់នូវគោលបំណងសំរាប់ការធ្វើអាជីវកម្មនេសាទនិងធ្វើ ការពិសោធន៏ សិក្សាស្រាវជ្រាវបច្ចេកទេសជលផលប្រកបដោយនិរន្តរភាព
- កំពង់ផែនេសាទគឺជាកន្លែង ដែលមានហេដ្ឋារចនាសម្ពន្ធ័នានាបំរើអោយសកម្មភាពនេសាទ, សហគមន៍នេសាទ, ប្រមូលផលនេសាទ, បែងចែកផលនេសាទ និងកែច្នៃផលនេសាទ

**គោលនយោបាយគ្រប់គ្រង**

- ការពារ ធនធានជលផលទឹកសាប, ទឹកប្រៃពីការធ្វើអាជីវកម្មនេសាទហួសកំរិត និងការពារជំរក
- កាត់បន្ថយជំលោះរវាងការនេសាទជាលក្ខណៈសិប្បកម្ម និងការនេសាទធុនតូច ជាលក្ខណៈគ្រួសារ ឬ ការនេសាទបន្ទាប់បន្សំដោយបែងចែកតំបន់នេសាទជាលក្ខណៈគ្រួសារ និង តំបន់នេសាទជាលក្ខណៈសិប្បកម្ម
- គ្រប់គ្រង នូវស្ថិតិផលិតផលនេសាទ និងចរាចរបែងចែកផលនេសាទ អោយបានសមស្របទៅតាមតម្រូវការក្នុងស្រុក និង ក្រៅស្រុក
- រក្សានូវសុវត្ថិភាព និងបំបាត់នូវភាពអានាធិបតេយ្យនៃទូកយន្តនេសាទ

**ការប្រើប្រាស់ សកម្មភាព ដែលបានអនុញ្ញាត**

- ការប្រើប្រាស់មធ្យោបាយនេសាទ និងឧបករណ៍នេសាទ សមស្រប រឺ អនុញ្ញាតតែប៉ុណ្ណោះនៅក្នុងតំបន់ ដែលបានកំណត់ ឬអនុញ្ញាត
- នេសាទក្នុងរដូវបើកនេសាទ
- មានតែមធ្យោបាយនេសាទធុនស្រាល រឺជាលក្ខណៈគ្រួសារ រឺសមស្របដែលនឹងត្រូវបានអនុញ្ញាតអោយនេសាទនៅកន្លែងទឹករាក់, តំបន់ព្រៃកោងកាង, ផ្កាថ្ម និង ស្មៅសមុទ្រ

| |
|---|
| • ស្រាវជ្រាវ ផលស្តុកធនធានជលផល និងការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រជលផល<br>• ការចតនាវាអាជីវកម្មនេសាទក្នុងកំពង់ផែនេសាទ រួមទាំងការចាក់ប្រេង, ការដាក់ទឹកសាប, ការដាក់ទឹកកក, ការផ្ទេរផលនេសាទ, ការជួសជុល និងការតំឡើងទូកនេសាទ<br>• ការកសាង និងថែទាំ សំភារៈកំពង់ផែនេសាទ<br>• ការអនុវត្តន៍នូវសេវាកម្ម និងសំភារៈគ្រប់គ្រងសំណល់សមស្របក្នុងកំពង់ផែនេសាទ<br>• ការកែច្នៃ និងបែងចែកផលនេសាទ |
| **ការប្រើប្រាស់ សកម្មភាពហាមឃាត់**<br>• ការធ្វើនេសាទដោយអួនអូស នឹងឈើបយន្តគ្រប់ប្រភេទនៅក្នុងតំបន់ទឹកហាមឃាត់<br>• ការចូលធ្វើនេសាទ របស់ជនបរទេសដែលគ្មានការអនុញ្ញាត<br>• ការប្រើប្រាសឧបករណ៏នេសាទទំនើប និង បច្ចេកទេសនេសាទ ដែលច្បាប់ហាមឃាត់<br>• ការនេសាទដែលមានការគំរាមកំហែងដល់ពូជត្រីក្នុងរដូវបន្តពូជ និងរដូវត្រីពង<br>• ការចាប់ត្រី ពពួកបង្គា និងសិប្បសត្វខុសទំហំ<br>• ការធ្វើនេសាទ ដោយប្រើគ្រឿងផ្ទុះ ថ្នាំបំពុល ថ្នាំសណ្តំគ្រប់ប្រភេទ<br>• ការចាប់រាល់ប្រភេទសត្វសមុទ្រជិតផុតពូជ និងកម្រ, ដូចជាៈជ្រូកទឹក, ផ្សោត, បាឡែន, អណ្តើក សមុទ្រ, ត្រីឆ្លាម, ភេសមុទ្រ, អណ្តើកសរសៃ, ការចរ និង បាឡាំងកាស, ក្រំយក្ស និង ត្រីសេះ |
| **តំបន់៧ : តំបន់វារីវប្បកម្ម កសិ-សមុទ្រ** |
| **និយមន័យៈ**<br>• កោះ ឆ្នេរ និង មាត់ពាម ដែលបានបែងចែក យ៉ាងសិរិតសំរាំង សំរាប់ប្រើប្រាស់តិចតួច លើការអភិវឌ្ឍន៍ វារីវប្បកម្ម កសិ-សមុទ្រ |
| **គោលនយោបាយគ្រប់គ្រងៈ**<br>• បង្កើនផលិតផល វារីវប្បកម្ម កសិ-សមុទ្រ នៅក្នុងតំបន់ឆ្នេរកោះ និងមាត់ពាម ដោយបែងចែកតំបន់ សិរិតសំរាំង សមស្របសំរាប់អភិវឌ្ឍន៍ប្រព័ន្ធវារីវប្បកម្មខ្នាតតូច និង ខ្នាតធំ |
| **ការប្រើប្រាស់ - សកម្មភាព ដែលបានអនុញ្ញាត**<br>• ការអភិវឌ្ឍន៍ ដោយនិរន្តភាព នូវវារីវប្បកម្ម, កសិ-សមុទ្រ ធុនតូច, មធ្យម, ធំ រួមមាន ការចិញ្ចឹមត្រី បង្គា គ្រំ និង ដាំសារាយសមុទ្រ .....។ល ។ |

**ការប្រើប្រាស់ – សកម្មភាព ហាមឃាត់**

- ការអភិវឌ្ឍន៍ នូវសកម្មភាព វារីវប្បកម្ម ដែលគ្មាននិរន្តរភាព ក្នុងការធ្វើអោយបំពុល ដល់តំបន់ទឹក នៅជុំវិញ
- ការប្រើប្រាស់ ជាតិគីមី ដែលមានសារៈធាតុពុល ក្នុងសកម្មភាព វារីវប្បកម្ម
- ការធ្វើ វារីវប្បកម្មសមុទ្រ គ្រប់ប្រភេទ ក្នុងតំបន់ព្រៃកោងកាង

**តំបន់៨ : តំបន់អភិវឌ្ឍន៍ ទេសចរណ៍**

**និយមន័យ:**

- តំបន់ ឬ ទីតាំង ទាំងឡាយណា ដែលមានអាទិភាព និងសក្តានុពលសំរាប់អភិវឌ្ឍន៏វិស័យទេសចរណ៍ ដូចជា ឆ្នេរខ្សាច់, កោះ, ភ្នំ, ទឹកជ្រោះ និងឧទ្យានជាតិ ព្រះសីហនុ " រាម "។ល។

**គោលនយោបាយគ្រប់គ្រង:**

**ឆ្នេរសមុទ្រ :**

- រក្សាគុណភាព និងសោភ័ណភាព នៃបរិស្ថានធម្មជាតិ ប្រកបដោយនិរន្តរភាព
- ថែរក្សា និងគ្រប់គ្រង ទីកន្លែងកំសាន្ត នៅតាមតំបន់ឆ្នេរខ្សាច់ សំរាប់បំរើអោយសាធារណៈជន និងភ្ញៀវទេសចរ
- ទប់ស្កាត់ សកម្មភាព ដែលប៉ះពាល់អវិជ្ជមានដល់បរិស្ថានតំបន់ឆ្នេរ និងសមុទ្រ
- ទប់ស្កាត់ការសាងសង់នៅក្នុងតំបន់ដែលងាយរងគ្រោះថ្នាក់
- ការពារតម្លៃ នៃប្រព័ន្ធអេកូឡូស៊ី តំបន់ឆ្នេរខ្សាច់ក្រុងព្រះសីហនុ

**ដែនកោះ:**

- ដើម្បីជំរុញការអភិវឌ្ឍន៍ អេកូ-ទេសចរណ៍ ដែនកោះ ដែលអាចផ្តល់នូវសម្បទា និងសេវាកម្មមួយចំនួន ដើម្បីបំពេញតំរូវការចាំបាច់ដល់ភ្ញៀវទេសចរ

***កំណត់ចំណាំ:*** អេកូ-ទេសចរណ៍ សំដៅលើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ បន្តិចបន្តួចមានផលប៉ះពាល់តិចតួចដល់ប្រព័ន្ធអេកូឡូស៊ីធម្មជាតិ និងការថែរក្សាបរិស្ថាន ធម្មជាតិ អោយស្ថិតក្នុងភាពដើមរបស់វា

- ដើម្បីជំរុញការលើកទឹកចិត្ត ដល់សកម្មភាពលំហែកាយការមើលទេសភាព ការចែវទូកកំសាន្ត ការហែលទឹក ការស្ទូចត្រី ការមុជទៅក្នុងទឹក ដោយប្រើឧបករណ៍ ដើម្បីមើលត្រី ផ្កាថ្ម និង ទេសភាពនៅបាតសមុទ្រ

**ទឹកធ្លាក់:**

- ការពារគុណភាព នៃបរិស្ថានធម្មជាតិ ទឹកធ្លាក់ក្បាលឆាយ និងអភិវឌ្ឍន៍តំបន់ក្បែរខាងអោយទៅជាតំបន់ទាក់ទាញអេកូ-ទេសចរណ៍ដែលអាចផ្តល់នូវសម្បទានិងសេវាកម្មទេសចរណ៍មួយចំនួនជាពិសេស គឺការគ្រប់គ្រងបរិស្ថានធម្មជាតិ និងកាកសំណល់អោយបានត្រឹមត្រូវ ។

| |
|---|
| **ឧទ្យានជាតិ :**<br>• ការប្រែតំបន់ខ្លះនៅក្នុងឧទ្យានជាតិសំរាប់អេកូ-ទេសចរណ៍, ទេសចរណ៍ផ្សងព្រេង ដែលផ្តល់នូវសកម្មភាពមួយចំនួនដូចជា ការដើរលំហែកំសាន្តការ មើលសត្វ ការចែវទូក ថតរូប ការសិក្សាស្រាវជ្រាវ ដើម្បីបង្កើនតម្លៃនៃឧទ្យានជាតិ ហើយចូលរួមចំណែកផ្ទាល់ ដល់វិធានការអភិរក្សដោយ និរន្តរភាព |
| **ការប្រើប្រាស់ - សកម្មភាព ដែលបានអនុញ្ញាត**<br>• សកម្មភាពលំហែកាយ និងកំសាន្តផ្សេងៗ ដែលមិនអន្តរាយដល់បរិស្ថាន<br>• ការអភិវឌ្ឍន៍សម្បទា និងសេវាកម្មទេសចរណ៍ ដែលមានការសិក្សា ប្លង់មេ ច្បាស់លាស់ និងមានច្បាប់ទំលាប់ត្រឹមត្រូវដើម្បីអាចបំពេញតំរូវការនៃការរីកសាយនៃឧស្សាហកម្មទេសចរណ៍ក៏ដូចជាតម្រូវការនៃវិស័យទេសចរណ៍ទាំងមូល ដោយឈរលើមូលដ្ឋានតុល្យភាព រវាងការអភិវឌ្ឍន៍ និងការអភិរក្សបរិស្ថានធម្មជាតិនៅក្នុងតំបន់ |
| **ការប្រើប្រាស់ - សកម្មភាព ហាមឃាត់**<br>**ជាទូទៅ:**<br>• ការប្រតិបត្តិ នៃរចនាសម្ព័ន្ធឧស្សាហកម្មផ្សេងៗ<br>• ការបរបាញ់សត្វ, ការកាប់បំផ្លាញព្រៃឈើ និងបំផ្លាញបរិស្ថានធម្មជាតិ<br>• ការធ្វើអាជីវកម្ម និងទាញយករ៉ែ គ្រប់ប្រភេទ<br>• ការចាក់កាកសំណល់ ផ្សេងៗ ដោយគ្មានការអនុញ្ញាត<br>• ការសាងសង់ សំណង់ អានាធិប្បតេយ្យ ដោយគ្មានផែនការច្បាស់លាស់ និងច្បាប់អនុញ្ញាត |
| **តំបន់ទី៩ : តំបន់គ្រប់គ្រងកំពង់ផែ និងគន្លងនាវាចរ** |
| **និយមន័យ:**<br>• តំបន់កំពង់ផែ ផែ និងទឹក ដែលផ្គត់ផ្គង់កំពង់ផែ និងផែ ការធ្វើនាវាចរ ការដឹកជញ្ជូន និងសកម្មភាពពាណិជ្ជកម្ម |
| **គោលនយោបាយគ្រប់គ្រង:**<br>• រក្សានូវតុល្យភាពរវាងសកម្មភាពដែលទាក់ទងនឹងកំពង់ផែ និងតំបន់កំពង់ផែចំរុះរួមទាំងការដឹកជញ្ជូនទំនិញអន្តរជាតិ និងក្នុងស្រុក និងទូកកំសាន្ត<br>• លើកកំពស់ការប្រើប្រាស់ឱ្យមានប្រសិទ្ធិភាពនៃគំលាតនិងការពារភាពស្រស់បំព្រង ដើម្បីបំរើឱ្យវិស័យទេសចរណ៍<br>• ជំរុញនូវការអភិវឌ្ឍន៍ និងទំនើបកម្មកំពង់ផែ ព្រមទាំងសកម្មភាពសេដ្ឋកិច្ច ឱ្យមានលក្ខណៈរីកចំរើននៅក្នុងឧស្សា |

ហកម្មសមុទ្រដោយរួមបញ្ចូលទៅក្នុង ផែនការរួម និងសកម្មភាពអភិវឌ្ឍន៍ ជាមួយស្ថាប័នផ្សេងទៀត ទាំងថ្នាក់ជាតិ និងអន្តរជាតិ

- បង្កើតនូវសេវាកម្ម និងសម្ភារៈសង្គ្រោះបន្ទាន់សមស្រប ពេលមានការកំពប់ប្រេងនិងគ្រោះថ្នាក់ផ្សេងៗ
- កំណត់នូវសូលុយស្យុងសំណល់សមស្រប ដែលអាចទទួលយកបាន ដើម្បីបំពេញតំរូវការសំរាប់ខួងក្នុងការធ្វើគន្លងនាវាចរ
- បែងចែកគន្លងនាវាចរដោយផ្អែកលើគោលបំណងធ្វើនាវាចរជាក់លាក់សំដៅកាត់បន្ថយទំនាស់ក្នុងការប្រើប្រាស់ផ្លូវទឹកនៅក្នុងកំពង់ផែ និងតំបន់ផែ

**ការប្រើប្រាស់- សកម្មភាព ដែលបានអនុញ្ញាត**

- ការចត ការចាក់ប្រេង ការលើកដាក់ឥវ៉ាន់ លើកប៉ាល់ សាឡាង កប៉ាល់កំសាន្ត និងការចូលចត នៃនាវានេសាទពាណិជ្ជកម្ម
- ការកសាង និងការថែរក្សាសម្ភារៈកំពង់ផែ ការធ្វើចរាចរ និងការចូលចត
- ការកសាង និងការថែរក្សាសម្ភារៈ ដែលចាំបាច់ សំរាប់ផ្គត់ផ្គង់ កំពង់ផែអន្តរជាតិ និងការធ្វើនាវាចរ ក៏ដូចជាកំពង់ផែនេសាទ
- ការអនុវត្តនូវសេវាកម្ម និងសម្ភារៈគ្រប់គ្រងសំណល់សមស្រប
- សកម្មភាព ដែលថែរក្សា និងជំរុញគុណភាពទឹក និងគុណភាព នៃទស្សនីយភាព រួមទាំងការថែរក្សានូវលក្ខណៈប្រវត្តិសាស្ត្រ

**ការប្រើប្រាស់,-សកម្មភាព ហាមឃាត់**

សកម្មភាព ដែលរំខានដល់ការប្រើប្រាស់អាទិភាព (ការធ្វើនាវា និងសកម្មភាពពាក់ព័ន្ធនឹងកំពង់ផែ) នៃតំបន់នេះមានដូចជា:

- ការបង្ហូរទឹកស្អុយ និងប្រេង ទៅក្នុងតំបន់ឆ្នេរសមុទ្រ
- ការនេសាទ និងវារីវប្បកម្ម
- តំបន់កំពង់ផែ និងគន្លងនាវាចរ
- ការអភិវឌ្ឍន៍លំនៅដ្ឋានឯកជន
- សេវាកម្មទិញ ឬ ដូរ ដែលផ្ទុយនឹងច្បាប់រដ្ឋ

**តំបន់ទី១០: តំបន់អភិវឌ្ឍន៍ អាកាសយានដ្ឋាន**

**និយមន័យ:**

- តំបន់ ដែលគេកំណត់ទុក ធ្វើជាអាកាសយានដ្ឋានជាតិ និងអន្តរជាតិ

**គោលនយោបាយគ្រប់គ្រង**

- អភិវឌ្ឍន៍ និងធានា សន្តិសុខ ដល់តំបន់នេះ សំរាប់បំរើអោយវិស័យអាកាសចរក្នុងស្រុក និងអន្តរជាតិ
- ជំរុញអោយមានការអភិវឌ្ឍន៍អាកាសយានដ្ឋាន ដើម្បីជួយសំរួលដល់វិស័យទេសចរណ៍ និង សកម្មភាពសេដ្ឋកិច្ច ផ្សេងៗ

**ការប្រើប្រាស់- សកម្មភាព ដែលបានអនុញ្ញាត**

- ការចុះចត និងផ្លាស់ប្តូរអ្នកដំណើរ, ទំនិញ ដែលស្របទៅតាម បទបញ្ញត្តិ និងច្បាប់

**ការប្រើប្រាស់- សកម្មភាព ហាមឃាត់**

- ការធ្វើកសិកម្ម និងការចិញ្ចឹមសត្វ
- សកម្មភាព ដែលមិនអនុញ្ញាត ដោយច្បាប់ និងបង្កអោយមានគ្រោះថ្នាក់ដល់អ្នកដំណើរ និងដល់ការផ្លាស់ប្តូរទំនិញ

**តំបន់ទី១១: តំបន់ប្រើប្រាស់ច្រើនយ៉ាង**

**និយមន័យ :**

- តំបន់នេះ រួមមានតំបន់ទឹក និងដី ដ៏ធំធេង ជុំវិញក្រុងព្រះសីហនុ ដែលផ្គត់ផ្គង់សកម្មភាពពាណិជ្ជកម្ម និងកំសាន្ត ជាច្រើន ព្រមទាំងផ្តល់នូវតម្លៃល្អ ដូចជា ត្រី និង ជំរកសត្វព្រៃ
- តំបន់ ដទៃទៀតទាំងអស់ មិនរាប់បញ្ចូលក្នុងតំបន់ ១១ ផ្សេងទៀតទេ

**គោលនយោបាយគ្រប់គ្រង**

- ការពារតំបន់ឆ្នេរ សំរាប់សកម្មភាពពាណិជ្ជកម្ម និងកំសាន្តជាច្រើន ស្របនឹងគោលដៅអភិវឌ្ឍន៍ ដោយនិរន្តរភាព រយៈពេលវែង
- រក្សានូវតុល្យភាព រវាងសកម្មភាពដែលមានក្នុងពេលជាមួយគ្នា។ លក្ខណៈប្រែប្រួលនៃសកម្មភាព ជាប្រពៃណី និងការអភិវឌ្ឍន៍ ដី-ទឹកតំបន់ឆ្នេរ បើអាច ធ្វើទៅបានតាមតំរូវការ នៃគោលដៅអភិវឌ្ឍន៍ ដោយនិរន្តរភាព រយៈពេលវែង និងតំរូវការក្នុងការថែរក្សាការពារ និងការស្តារឡើងវិញ ។
- តំបន់ឆ្នេរ ដ៏ធំធេង រួមមានតំបន់នេសាទសំខាន់ៗ និងជំរកត្រី ។ តំបន់ទាំងនេះ ត្រូវការពារពីការផ្លាស់ប្តូរ និងសកម្មភាព ដែលគំរាមកំហែង ដល់វិស័យ ជលផល ក្រុងព្រះសីហនុ ។
- គុណភាពទឹកស្អាត ត្រូវបានរក្សា នៅក្នុងទឹកសមុទ្រ និងទឹកតំបន់ឆ្នេរ ជុំវិញក្រុងព្រះសីហនុ ។

**ការប្រើប្រាស់- សកម្មភាព ដែលបានអនុញ្ញាត**

- គ្រប់សកម្មភាព និងការប្រើប្រាស់ ដែលស្របគ្នានឹងគោលដៅអភិវឌ្ឍន៍ ដោយនិរន្តរភាពរយៈពេលវែង

**ការប្រើប្រាស់- សកម្មភាព ហាមឃាត់**

- ការប្រើប្រាស់ ឬសកម្មភាពណា ដែលមិនស្របនឹងគោលដៅអភិវឌ្ឍន៍ ដោយនិរន្តរភាព រយៈពេលវែង

**តំបន់ទី១២: តំបន់ឧស្សាហកម្ម និង រុករករ៉ែ**

**និយមន័យ:**

- តំបន់ លាតសន្ធឹង ដែលបានកែប្រែ សំរាប់ផ្នែកពាណិជ្ជកម្ម និងឧស្សាសហកម្ម ពឹងផ្អែកលើទឹក និង សកម្មភាពកែច្នៃ ការប្រើប្រាស់ទឹក ឱ្យបានល្អប្រសើរ
- កន្លែងដែលបានបែងចែក និងគ្រប់គ្រង ការប្រើប្រាស់ដាច់ដោយឡែក សំរាប់ការអភិវឌ្ឍន៍ ឧស្សាហកម្ម និងសកម្មភាពសេដ្ឋកិច្ច
- កន្លែងសំរាប់ការរុករក និងទាញយកវត្ថុធាតុដើមដូចជាសារៈធាតុខនិជ, ខ្សាច់។ល។ សំរាប់គោលបំណងផ្គត់ផ្គង់លើការសាងសង់ និងសម្ភារៈសំណង់
- កន្លែង សំរាប់ការរុករកប្រភពថាមពល ដូចជា ប្រេង និងឧស្ម័ន

**គោលនយោបាយគ្រប់គ្រង**

- ជំរុញ និងទ្រទ្រង់ទំនើបកម្ម ឧស្សាហកម្ម និងធ្វើអោយរីកចំរើន នូវគ្រប់សកម្មភាពពាណិជ្ជកម្ម ។ សកម្មភាពពាណិជ្ជកម្ម ដែលជាប់ទាក់ទង និងនាវាចរ ឧស្សាហកម្មប្រេង និង សិប្បកម្ម ដែលកំពុងដំណើរការ។ល ។
- វាល់ការអភិវឌ្ឍន៍ ដែលប៉ះពាល់ លើបរិស្ថានធម្មជាតិ និងបរិស្ថាន ដែលនៅជុំវិញនោះ
- ដាក់កំរិតការរុករកនិងការទាញយករ៉ែនៅតំបន់ដែលរំពឹងថា ការបំផ្លាញនឹងអាចកើតមានចំពោះបរិស្ថាន ធម្មជាតិ ក្នុងដំណើការទាញយករ៉ែ
- ជុំរុញឱ្យមានការទាញយកនូវប្រភពថាមពល ដូចជាប្រេង និងឧស្ម័ន ដោយមានការធានានូវការបំផ្លាញកំរិតទាបបំផុតលើបរិស្ថានធម្មជាតិ

**ការប្រើប្រាស់ សកម្មភាព ដែលបានអនុញ្ញាត**

- សកម្មភាព រួមចំណែកធ្វើផែនការ និងរៀបចំអភិវឌ្ឍន៍ ឧស្សាហកម្ម
- ឧស្សាហកម្ម មានកំរិតបំពុលទាប/ការអនុវត្តដោយការអភិវឌ្ឍន៍បៃតង
- ការបង្កើត និងការអនុវត្តន៍កន្លែងប្រព្រឹត្តកម្មសំណល់សមស្រប
- ការសាងសាង់ផ្លូវ ក្នុងគោលបំណងដឹកជញ្ជូនផលិតផលឧស្សាហកម្ម និងរ៉ែ

**ការប្រើប្រាស់-សកម្មភាពហាមឃាត់**

- បញ្ចេញចោលសំណល់មិនទាន់សំអាត និងទឹកស្អុយចូលទៅក្នុងបឹង ខ្សែទឹកអូរ-ព្រែក ស្ទឹង និងទឹកនៅតាមតំបន់ឆ្នេរ
- គ្រប់សកម្មភាពតំបន់ឆ្នេរ ដែលមិនស៊ីចង្វាក់ជាមួយគម្រោងឧស្សាហកម្ម ដែលមានស្រាប់ និងសកម្មភាព រុករក និងទាញយករ៉ែ
- សកម្មភាពរុករករ៉ែ និងការទាញយករ៉ែ ដែលអាចត្រូវបានអនុវត្តដោយផលប៉ះពាល់ដល់ការបំផ្លិចបំផ្លាញរ៉ែ លើបរិស្ថានធម្មជាតិ

***ឯកសារសម្រាប់អានបន្ថែម:***

- *គម្រោងបែងចែកតំបន់ប្រើប្រាស់ដី-ទឹកតំបន់ឆ្នេរខេត្តព្រះសីហនុឆ្នាំ២០០៥*
- *ក្របខណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ ២០១០-២០១៩*
- *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រាប់សមុទ្រអាស៊ី-បូព៌ាឆ្នាំ២០១២-២០១៦*
- *ការសិក្សាអំពីយុទ្ធសាស្ត្រចម្រុះតំបន់ឆ្នេរថ្នាក់ជាតិ និង ផែនការមេខេត្តព្រះសីហនុសម្រាប់យុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់ប្រកបដោយនិរន្តភាពចម្រុះថ្នាក់ជាតិ*

## ជំពូកទី ៤: បច្ចេកស័ព្ទទាក់ទងនឹងគ្រោះមហន្តរាយ សមុទ្រ និងផែនការប្រើប្រាស់តំបន់ឆ្នេរសមុទ្រ

***ច្បាប់សាងសង់* (Building Codes) :** ជាបញ្ញត្តិ និងនិយ័តកម្មដើម្បីត្រួតពិនិត្យការធ្វើគម្រោងប្លង់ ការសាងសង់សម្ភារៈ ឬការស្ថាបនាទាំងឡាយដើម្បីធានាឱ្យបាននូវសុវត្ថិភាព និងសុខមាលភាពមនុស្ស។ **ច្បាប់សាងសង់**ត្រូវរួមបញ្ចូលទាំងស្តង់ដា បច្ចេកទេស និងដំណើរការមុខងារ។

***សមត្ថភាព* (Capacity) :**ការផ្សំនៃកម្លាំងសរុប និងធនធានដែលអាចរកបាននៅក្នុងសហគមន៍ សង្គម ឬអង្គការដែលអាចកាត់បន្ថយនូវកម្រិតគ្រោះភ័យ ឬឥទ្ធិពលនៃគ្រោះមហន្តរាយ។ **សមត្ថភាព**អាចរួមមានជារូបវ័ន្ត ស្ថាប័ន សង្គម ឬសេដ្ឋកិច្ច ក៏ដូចជាជំនាញផ្ទាល់ខ្លួន ឬសទ្ធតំថាជារបស់រួមដូចជាការដឹកនាំ និងការគ្រប់គ្រង។ សមត្ថភាពពិពណ៌នាផងដែរថាដូចកំលាំង សម្ភារៈ ឬស្មារតី(Capability) ។

***ការកសាងសមត្ថភាព* (Capacity-building):**ការខិតខំប្រឹងប្រែងដែលមានបំណងបង្កើនជំនាញរបស់មនុស្សឬហេដ្ឋារចនាសម្ព័ន្ធសង្គមនៅក្នុងសហគមន៍ ឬតម្រូវការអង្គការដើម្បីកាត់បន្ថយកម្រិតគ្រោះភ័យ។ **ការកសាងសមត្ថភាព**រួមបញ្ចូលផងដែរនូវការអភិវឌ្ឍផ្នែកស្ថាប័ន ហិរញ្ញវត្ថុ នយោបាយ និងធនធានផ្សេងៗដូចជាបច្ចេកវិទ្យានៅកម្រិតផ្សេងគ្នា និង វិស័យសង្គមមួយចំនួនទៀត។

***ការប៉ាន់ប្រមាណរួមរបស់ប្រទេស, ក្របខ័ណ្ឌការងារជំនួយអភិវឌ្ឍន៍អង្គការសហប្រជាជាតិ* (Common Country Assessment / United Nations Development Assistance Framework-CCA/UNDAF):** ដំណើរការ CCA/UNDAF គឺជាក្របខណ្ឌការងារយុទ្ធសាស្ត្ររួមសម្រាប់សកម្មភាពប្រតិបត្តិការនៃប្រព័ន្ធអង្គការសហប្រជាជាតិនៅថ្នាក់ជាតិ។ ប្រព័ន្ធនេះផ្តល់នូវការទំនាក់ទនងគ្នា និងសមាហរណកម្មឆ្លើយតបនៃប្រព័ន្ធអង្គការសហប្រជាជាតិទៅនឹងអាទិភាពជាតិ និងតម្រូវការនៃក្របខណ្ឌគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងការប្តេជ្ញាលើគោលដៅមុខព្រួញដទៃៗទៀតនៃសេចក្តីថ្លែងការណ៍សហស្សវត្សរ៍ និងកម្មវិធីសកម្មភាពដែលបានអនុម័តដោយសន្និសីទអន្តរជាតិ និងកិច្ចប្រជុំកំពូលដោយអនុលោមតាមអនុសញ្ញាសំខាន់ៗរបស់អង្គការសហប្រជាជាតិ។ CCA គឺជាឧបករណ៍វិនិច្ឆ័យដ៏សំខាន់បំផុតសម្រាប់ក្រុមប្រទេសជាសមាជិកអង្គការសហប្រជាជាតិ និងប្រទេសដៃគូរបស់ខ្លួនសម្រាប់ការប៉ាន់ប្រមាណ និងបង្កើនការយល់ដឹងរួមជាមូលដ្ឋានរបស់ប្រទេសដែលប្រឈមមុខក្នុងដំណើរការអភិវឌ្ឍន៍របស់ខ្លួន។ UNDAF កើតចេញពីការខិតខំប្រឹងប្រែងវិភាគ និង ការប៉ាន់ប្រមាណរបស់ប្រទេស និងជាមូលដ្ឋានគ្រឹះសម្រាប់កម្មវិធីសហប្រតិបត្តិការអង្គការសហប្រជាជាតិ (UN/ISDR and UNDP 2006) ។

***សមត្ថភាពទប់ទល់* (Coping Capacity) :** ជាប្រភពទុនដោយអ្នកណាមួយជាប្រជាជន ឬអង្គការប្រើប្រាស់ធនធាន ដែលអាចរកបាន និងបំណិនទៅនឹងផលវិបាកចំពោះមុខដែលមិនល្អ ហើយអាចនាំទៅមានគ្រោះមហន្តរាយ។ ជាទូទៅ សមត្ថភាពនេះជាប់ទាក់ទងការគ្រប់គ្រងធនធានក្នុងពេលវេលាធម្មតាពេលមានវិបត្តិ ឬស្ថានភាពមិនល្អ។ ការពង្រឹង ***សមត្ថភាពទប់ទល់*** គឺការកសាងប្រក្រតីភាពសមត្ថភាពទប់ទល់បានទៅនឹងការធន់នឹងឥទ្ធិពល និងមុខសញ្ញាគ្រោះថ្នាក់ដែលបង្កឡើងដោយមនុស្ស និងធម្មជាតិ។

***ដំណើរការរៀបចំផែនការអភិវឌ្ឍន៍* (Development Planning Processes):** ជាសកម្មភាពរស់រវើកដែលអនុញ្ញាតឱ្យរដ្ឋាភិបាលថ្នាក់ជាតិ តាមវិស័យ ថ្នាក់តំបន់ ឬរដ្ឋបាលមូលដ្ឋាន និងដៃគូអភិវឌ្ឍន៍គាំទ្រ និងចូលរួម ទាំងផ្នែកបច្ចេកទេស រូបវន្ត និងធនធានសេដ្ឋកិច្ចឆ្ពោះទៅរកការអភិវឌ្ឍគ្រប់ថ្នាក់ដែលជាសេចក្ដីប៉ងប្រាថ្នាសម្រាប់អនាគត។

***គ្រោះមហន្តរាយ* (Disaster):** គឺជាការកាត់ផ្ដាច់យ៉ាងធ្ងន់ធ្ងរនូវដំណើរការប្រព្រឹត្តិទៅរបស់សហគមន៍ ឬសង្គមមួយ បង្កឱ្យ មានការបាត់បង់ធំធេងនូវជីវិតមនុស្ស សម្ភារៈ សេដ្ឋកិច្ច-បរិស្ថាន ហើយដែលហួសពីសមត្ថភាពសហគមន៍ឬសមត្ថភាពក្នុងការលៃលកដោះស្រាយដោយប្រើប្រាស់នូវធនធានរបស់ខ្លួន។ គ្រោះមហន្តរាយគឺមានមុខងារនៃដំណើរការគ្រោះភ័យ។ លទ្ធផលរបស់វាមកពីការផ្សំគ្នានៃមុខសញ្ញាគ្រោះថ្នាក់ស្ថានភាពនៃភាពងាយរងគ្រោះ និងសមត្ថភាពឬវិធានការមិនគ្រប់គ្រាន់ដើម្បីកាត់បន្ថយផលវិបាកអវិជ្ជមានដែលអាចកើតមានពីគ្រោះភ័យនេះ។

***ការគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយ* (Disaster Risk Management):** ដំណើរការជាប្រព័ន្ធនៃការប្រើប្រាស់លើការសម្រេចចិត្តផ្នែករដ្ឋបាល អង្គភាពជំនាញ ប្រតិបត្តិការនិងសមត្ថភាពដើម្បីអនុវត្តនូវគោលនយោបាយ យុទ្ធសាស្ត្រ និងសមត្ថភាពលៃលករបស់សង្គម និងសហគមន៍ដើម្បីបន្ថយផលប៉ះពាល់ពីមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ និងពាក់ព័ន្ធគ្រោះមហន្តរាយនៃបច្ចេកវិទ្យា និងបរិស្ថាន។ ការងារនេះគឺមានគ្រប់ទ្រង់ទ្រាយនៃសកម្មភាពរួមមាន វិធានការជារចនាសម្ព័ន្ធ និងមិនមែនរចនាសម្ព័ន្ធដើម្បីចៀសវាង (ត្រៀមរៀបចំ) ឬដើម្បីកម្រិត (កាត់បន្ថយគ្រោះថ្នាក់ និងការត្រៀមរៀបចំ) ឥទ្ធិពលមិនល្អនៃមុខសញ្ញាគ្រោះថ្នាក់។

***ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ* (Disaster Risk Reduction):** គំនិតដំបូងនៃក្របខណ្ឌការងារដែលត្រូវបានលើកមកពិចារណាចំណុចសំខាន់ជាមួយលទ្ធភាពដើម្បីធ្វើឱ្យតិចឡើង នូវភាពងាយរងគ្រោះ និងគ្រោះភ័យនៃគ្រោះមហន្តរាយទាំងអស់នៅក្នុងសង្គមដើម្បីចៀសវាង (ការត្រៀមរៀបចំ) ឬដើម្បីកម្រិត (កាត់បន្ថយគ្រោះថ្នាក់ និងការត្រៀមរៀបចំ) ផលប៉ះពាល់មិនល្អនៃមុខសញ្ញាគ្រោះថ្នាក់ផ្នែកខាងក្នុងបរិបទធំទូលាយនៃការអភិវឌ្ឍប្រកបដោយចីរភាព។

***ផែនការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ*** **(Disaster Risk Reduction Plans)៖** ជាឯកសារដែលបានប្រកាសឱ្យដឹងអំពីការរៀបចំផែនការ គោលនយោបាយរបស់អាជ្ញាធរ និងសេចក្តីស្នើសម្រាប់កាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយដែលគប្បីបានធ្វើការពិចារណាក្នុងសកម្មភាពអភិវឌ្ឍន៍ និងផែនការអភិវឌ្ឍន៍រៀងៗខ្លួន។ ដោយហេតុ ទំហំភូមិសាស្ត្រប្លែកៗពីគ្នាដែលអាចអនុវត្តបាននៅកម្រិតខុសៗគ្នាផែនការកាត់បន្ថយគ្រោះភ័យ នៃគ្រោះមហន្តរាយជាក់លាក់ទៅនឹងថ្នាក់នីមួយៗរបស់រដ្ឋាភិបាល។

***ប្រព័ន្ធផ្តល់ដំណឹងជាមុន*** **(Early Warning System)៖** គឺការផ្តល់ព័ត៌មានពិស្តារប្រកបដោយប្រសិទ្ធភាពនិងកាលកំណត់តាមរយៈស្ថាប័នដែលបានថ្លែងពន្យល់នោះអនុញ្ញាតបង្ហាញឱ្យដឹងទៅនឹងមុខសញ្ញាគ្រោះថ្នាក់ដោយទទួលយកសកម្មភាពដើម្បីបញ្ចៀស ឬកាត់បន្ថយគ្រោះភ័យកន្លែងនោះនឹងត្រៀមសម្រាប់ការឆ្លើយតបឱ្យមានប្រសិទ្ធភាព។ ប្រព័ន្ធផ្តល់ដំណឹងជាមុនរួមមានការទាក់ទងពិសេសបន្តគ្នា ពោលគឺការយល់ដឹងនិងការធ្វើផែនទីមុខសញ្ញាគ្រោះថ្នាក់ការតាមដានត្រួតពិនិត្យ និងការព្យាករណ៍ព្រឹត្តិការណ៍ហៀបនឹងកើតឡើង ការដាក់ឱ្យដំណើរការ និងការចែកចាយព័ត៌មានដល់អាជ្ញាធរ អ្នកធ្វើនយោបាយនិងប្រជាពលរដ្ឋព្រមទាំងការទទួលធ្វើសមស្របនឹងកាលកំណត់សកម្មភាពក្នុងការឆ្លើយតបទៅនឹងការជូនដំណឹងនេះ។

***ប្រព័ន្ធអេកូស៊ីស្ទែម*** **(Ecosystem)៖** គឺជាការលាយផ្សំបញ្ចូលនៃភាពទំនាក់ទំនងបញ្ចូលគ្នានៃមុខងារសរីរាង្គមានជីវិត និងអន្តរកម្មជាមួយបរិស្ថានរូបវន្តទីនោះ។ ព្រំដែនប្រព័ន្ធអេកូស៊ីស្ទែមគឺគប្បីហៅថាអ្វីជាមូលដ្ឋានគ្រប់គ្រាន់ពឹងផ្អែកទៅលើការដែលគួរឱ្យចាប់អារម្មណ៍ ឬគួរឱ្យសិក្សា។ ហេតុដូច្នេះ វិសាលភាពនៃប្រព័ន្ធអេកូស៊ីស្ទែមប្រហែលជាមានប្រភេទច្រើនផ្សេងពីគ្នាចន្លោះពីទំហំនៃអវកាសតូចទៅនឹងភាពខ្ពស់បំផុតនៃផែនដីទាំងមូល។

***ការគ្រប់គ្រងគ្រោះអាសន្ន*** **(Emergency Management)៖** គឺជារបៀបរៀបចំ និងការគ្រប់គ្រងធនធាន និងការទទួលខុសត្រូវសម្រាប់ដោះស្រាយជាមួយរាល់ទិដ្ឋភាពគ្រោះអាសន្ន ការរួមបញ្ចូលនៅផ្នែកខាងក្នុងដោយឡែកដូចមានការត្រៀមរៀបចំការឆ្លើយតបការធ្វើឱ្យមានប្រក្រតីភាពឡើងវិញបន្ទាន់នៅក្នុងបរិបទការកាត់បន្ថយគ្រោះភ័យ។ ការគ្រប់គ្រងគ្រោះអាសន្នវាជាប់ទាក់ទងនឹងផែនការរចនាសម្ព័ន្ធរបស់ស្ថាប័ន និងការចាត់ចែងបង្កើតដើម្បីចាប់ផ្តើមការប្រឹងខ្នះខ្នែងពីរដ្ឋាភិបាលការស្ម័គ្រចិត្តពីភ្នាក់ងារឯកជនក្នុងភាពទូលំទូលាយ និងសម្របសម្រួលបែបផែនដើម្បីឆ្លើយតបទៅនឹងអ្នកទទួលវិសាលគមន៍ទាំងស្រុងនៃតម្រូវការគ្រោះអាសន្នហើយនេះក៏យល់ថាជាការគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយដែរ។

***ការធ្វើឱ្យខូចបរិស្ថាន* (Environmental Degradation):** គឺជាការកាត់បន្ថយនៃសមត្ថភាពរបស់បរិស្ថាន ដើម្បីគោលដៅ និងតម្រូវការសង្គម និងអេកូស៊ីស្ទែម។ សក្ដានុពលមានប្រសិទ្ធភាពជាការផ្សេងគ្នា និងការសូមឱ្យធ្វើវិភាគទាននឹងការកើនភាពងាយរងគ្រោះប្រេហ្វកង់ស៍ និងអាំងតង់ស៊ីតេនៃមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ។ ឧទាហរណ៍: ការធ្វើឱ្យខូចដី ការបំផ្លាញព្រៃឈើ ការធ្វើវាលរហោឋាន ភ្លើងឆេះព្រៃ ការបាត់បង់នៃជីវចម្រុះ ដី ទឹក និងខ្យល់អាកាសមានភាពខ្វក់ ការប្រែប្រួលអាកាសធាតុកម្រិតកម្ពស់ទឹកសមុទ្រកើនឡើង និងសឹករេចរឹលស្រទាប់អូហ្សូន។

***ការវាយតម្លៃផលប៉ះពាល់បរិស្ថាន* (Environmental Impact Assessment):** ការសិក្សាមួយត្រូវបានធ្វើឡើងក្នុងសេចក្ដីបង្គាប់ដើម្បីប៉ាន់ប្រមាណឥទ្ធិពលលើបរិស្ថានជាក់លាក់នៃការបង្ហាញឱ្យឃើញកត្តាថ្មីៗមួយចំនួនប្រហែលជាធ្វើឱ្យហិនហោចដល់តុល្យភាពនៃប្រព័ន្ធអេកូស៊ីស្ទែមបច្ចុប្បន្ន។ ការប៉ាន់ប្រមាណផលប៉ះពាល់នៃបរិស្ថាន (EIA) ជាឧបករណ៍ធ្វើគោលនយោបាយដើម្បីរក្សាឈានទៅផ្ដល់ភស្ដុតាង និងការវិភាគនៃផលប៉ះពាល់នៃបរិស្ថាន និងសកម្មភាពពីទស្សនទានឈានទៅការធ្វើសេចក្ដីសម្រេចចិត្ត។ នេះគឺការប្រើប្រាស់ដ៏ទូលំទូលាយក្នុងការរៀបចំកម្មវិធីជាតិ និងសម្រាប់គម្រោងជំនួយអភិវឌ្ឍន៍អន្តរជាតិ។ ការប៉ាន់ប្រមាណផលប៉ះពាល់នៃបរិស្ថានណាមួយដែលចាំបាច់រួមបញ្ចូលការប៉ាន់ប្រមាណលម្អិតគ្រោះភ័យ និងផ្ដល់នូវដំណោះស្រាយផ្លូវទៀត ឬអំណាចជ្រើសរើស។

***មុខសញ្ញាគ្រោះថ្នាក់* (Hazard):** ជាព្រឹត្តិការណ៍មួយ បាតុភូតមួយ ឬសកម្មភាពរបស់មនុស្សដែលសក្ដានុពលអាចធ្វើឱ្យខូចខាតជារូបវន្តខ្លាំងក្លារួមមានការបង្កឱ្យមានការបាត់បង់អាយុជីវិត ឬរបួសការខូចខាតទ្រព្យសម្បត្តិអាក់ដំណើរការសង្គម និងសេដ្ឋកិច្ច ឬការខូចនៃបរិស្ថាន។

***ការវិភាគអំពីមុខសញ្ញាគ្រោះថ្នាក់* (Hazard Analysis):** ការកំណត់អត្តសញ្ញាណ ការសិក្សា ការតាមដានត្រួតពិនិត្យលើរាល់មុខសញ្ញាគ្រោះថ្នាក់រួចធ្វើការកំណត់អំពីសក្ដានុពលប្រភពដើមលក្ខណៈ។

***ការរៀបចំផែនការប្រើប្រាស់ដីធ្លី* (Land-Use Planning):** ផ្នែកនៃការរៀបចំផែនការរូបវន្ត-សេដ្ឋកិច្ចសង្គមដែលកំណត់អំពីមធ្យោបាយ និងការប៉ាន់ប្រមាណលើតម្លៃ ឬកម្រិតនៃការជម្រើសនានាក្នុងទីតាំងដីណាមួយទៅនឹងការប្រើប្រាស់ជាមួយភាពត្រូវគ្នាមានឥទ្ធិពលលើចំណែកផ្សេងៗគ្នានៃចំនួនប្រជាជនទាំងអស់ ឬផលប្រយោជន៍ជាភស្ដុតាងសហគមន៍ទៅជាសេចក្ដីសម្រេចលទ្ធផល។ ការរៀបចំផែនការប្រើប្រាស់ដីធ្លីជាប់ទាក់ទងទៅនឹងការសិក្សា និងការកំណត់ផែនទី ការវិភាគអំពីទិន្នន័យមុខសញ្ញាគ្រោះថ្នាក់ និងបរិស្ថាន បទបញ្ញត្តិនៃផ្នែកច្បាប់ ការសម្រេចប្រើប្រាស់ដីធ្លី និងគម្រោងប្លង់នៃផែនការដែលទៅដល់រយៈពេលវែងនៃផែនការសម្រាប់ភូមិសាស្ត្រផ្សេងៗគ្នា និងដែនរដ្ឋបាល។

***ការកាត់បន្ថយគ្រោះថ្នាក់*** **(Mitigation)៖** វិធានការរចនាសម្ព័ន្ធ និងមិនមែនរចនាសម្ព័ន្ធដែលរាប់រងទៅនឹងកម្រិត នៃផលប៉ះពាល់មិនល្អពីមុខសញ្ញាគ្រោះធម្មជាតិ ការធ្វើឱ្យខូចខាតបរិស្ថាន និងមុខសញ្ញាគ្រោះដោយបច្ចេកវិទ្យា (ឧ.វិធានការរចនាសម្ព័ន្ធគឺការងារវិស្វកម្ម និងការសាងសង់ជាប់រឹងនឹងមុខសញ្ញាគ្រោះថ្នាក់ រីឯវិធានការមិនមែនរចនាសម្ព័ន្ធមានដូចជាការបង្កើនការយល់ដឹង ការអភិវឌ្ឍចំណេះដឹង គោលនយោបាយស្តីពីការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងធនធាន និងប្រតិបត្តិការជាក់ស្តែង។

***ការចូលរួមរបស់អ្នកពាក់ព័ន្ធ៖*** សារៈសំខាន់នៃការចូលរួមរបស់អ្នកពាក់ព័ន្ធត្រូវបានបង្ហាញជាប្រចាំក្នុងស្ថានភាពទាំងនោះកន្លែងដែលបានចាត់ទុកថាសំខាន់។ អត្ថន័យទូលំទូលាយនៃភាពជាម្ចាស់ការនៃដំណើរការធ្វើផែនការចាត់ទុកថាមានសារៈសំខាន់ក្នុងការប្តេជ្ញាចិត្តក្នុងការអនុវត្ត និងប្រតិបត្តិតាម។ សូម្បីក្នុងដំណើរការ ការចូលរួមរបស់ភាគីដែលមានផលប៉ះពាល់ជាច្រើនពង្រីកមូលដ្ឋាន ការបង្កើតគំនិត ការឱ្យនិយមន័យ និងកំណត់អាទិភាពនៃបញ្ហាដែលត្រូវដោះស្រាយ ការបង្កើតសេណារីយោអនាគត និង មូលដ្ឋានសម្រាប់ការវាយតម្លៃរបស់គេ។ ដោយមានទំនាក់ទំនងកាន់តែជិតជាមួយបញ្ហានៃការចូលរួមរបស់អ្នកពាក់ព័ន្ធបង្កឱ្យមានក្តីបារម្ភដល់សមភាពសង្គម ការកាត់បន្ថយភាពក្រីក្រ ការផ្តល់អំណាចឱ្យប្រជាជនស៊ីវិល និងសមភាពយេនឌ័រ។ កម្មវិធីរៀបចំឱ្យបានសមស្របសម្រាប់ការចូលរួមរបស់អ្នកពាក់ព័ន្ធនឹងធានាថាការព្រួយបារម្ភនេះនឹងត្រូវបានដោះស្រាយ។ ចំណែកឯ ឯកសារវិញចាត់ទុកថាការចូលរួមរបស់អ្នកពាក់ព័ន្ធមានសារៈសំខាន់ គេទទួលស្គាល់ថាមានប្រភេទ ឬកម្រិត និងទំហំផែនការផ្សេងៗតម្រូវឱ្យមានវិធីសាស្ត្រផ្សេងៗគ្នាដល់ការចូលរួមរបស់អ្នកពាក់ព័ន្ធ។ ពួកគេទទួលស្គាល់ថាដំណើរការនៃការចូលរួមត្រូវចំណាយថវិកា និងពេលវេលាអស់ជាច្រើន។ អាស្រ័យហេតុនេះ ចាំបាច់ត្រូវមានតុល្យភាពរវាងពេលវេលា និង ការចំណាយថវិកាជាមួយនឹងផលប្រយោជន៍នៃចូលរួម។

***ពហុអ្នកពាក់ព័ន្ធ*** **(Multi-Stakeholder)៖** ជាស័ព្ទដើម្បីរៀបរាប់អំពីក្រុមនៃបុគ្គល ឬអង្គការនានាដែលមានផលប្រយោជន៍ ឬ “ជាប់ពាក់ព័ន្ធ” ក្នុងបញ្ហាអ្វីមួយហើយជាអ្នកដែលសហប្រតិបត្តិការទទួលយកសកម្មភាពលើបញ្ហាអ្វីមួយក្នុងករណីដើម្បីកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ (សេចក្តីព្រាងអំពីនិយមន័យ គឺស្ថិតនៅក្រោមការពិភាក្សា)។

***កម្មវិធីជាតិសម្រាប់កាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ*** **(National Platform for Disaster Risk Reduction)៖** ម្ចាស់ការដឹកនាំដោយជាតិលើវេទិកា និងគណកម្មាធិការនៃអ្នកពាក់ព័ន្ធចម្រុះ។ កម្មវិធីនេះបម្រើការគាំទ្រនៃការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅគ្រប់កម្រិតផ្សេងគ្នា និងផ្តល់ការសម្របសម្រួលការវិភាគ និងផ្តល់យោបល់លើទីកន្លែងនៃសកម្មភាពសម្រុះសម្រួលទាមទារអាទិភាពតាមរយដំណើរការនៃការសម្របសម្រួល និងការចូលរួម។ កម្មវិធីជាតិសម្រាប់

កាត់បន្ថយ គ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងគោលនយោបាយជាតិអភិវឌ្ឍន៍ ការរៀបចំផែនការ និងកម្មវិធីនានាឱ្យស្រប ជាមួយការអនុវត្ត ក្របខណ្ឌការងារសកម្មភាពយូហ្គោ សកម្មភាព HFA ហើយក៏មានបំណងចូលរួមវិភាគទានដល់ការបង្កើត និងអភិវឌ្ឍន៍ទូលំទូលាយប្រព័ន្ធ កាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយថ្នាក់ជាតិ ហើយក៏ត្រូវសមស្របទៅនឹងប្រទេស នីមួយៗ) UN/ISDR គោលការណ៍ណែនាំ កម្មវិធីជាតិសម្រាប់ ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ) ។

***ក្របខណ្ឌការងារគោលនយោបាយជាតិ* (National Policy Framework)៖** ជាគោលនយោបាយដែលអនុម័តដោយអាជ្ញាធរជាតិដើម្បីកំណត់ និងលើកឡើងភាពស្មើគ្នានូវរាល់បញ្ហាជាពិសេសទាំងឡាយ និងឈានទៅដល់ការសម្រេចចិត្តខាងនយោបាយហើយមានជាប់ទាក់ទងទៅនឹងការប៉ាន់ប្រមាណ យុទ្ធសាស្ត្រគោលដៅ វិធីសាស្ត្រ បទបញ្ជា ផែនការសកម្មភាព ការកំណត់អាទិភាព ភ្នាក់ងារ និងការទទួលខុសត្រូវ។ ក្របខណ្ឌការងារ គោលនយោបាយកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយថ្នាក់ ជាតិអាចនាំផ្លូវដល់អ្នកពាក់ព័ន្ធ ភ្នាក់ងាររដ្ឋាភិបាលមូលដ្ឋាន និងផ្នែកដទៃទៀតផ្សេងទៀតក្នុងការអភិវឌ្ឍបំពេញឱ្យគ្នាទៅវិញទៅមក គោលនយោបាយកាត់បន្ថយគ្រោះភ័យក្នុងតំបន់នៃអាជ្ញាធរ (ការកំណត់ពង្រឹងស្ថិតក្រោមការពិភាក្សា) ។

***ការត្រៀមរៀបចំ* (Preparedness)៖** ជាសកម្មភាពមុនពេលមានគ្រោះមហន្តរាយដែលត្រូវទទួលរ៉ាប់រងក្នុងបរិបទនៃការគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយ និងជាមូលដ្ឋានលើសម្លេងវិភាគគ្រោះភ័យ។ សកម្មភាពនេះរួមមាន ការអភិវឌ្ឍលើកកម្ពស់ដល់យុទ្ធសាស្ត្រត្រៀមរៀបចំទាំងមូល គោលនយោបាយ រចនាសម្ព័ន្ធស្ថាប័ន ការផ្តល់ដំណឹង សមត្ថភាពនៃការព្យាករណ៍ និងផែនការដែលកំណត់នូវវិធានការនានាសំដៅជួយការពារសុវត្ថិភាពនូវគ្រោះភ័យមកលើសហគមន៍ការរស់នៅរបស់គេ ទ្រព្យសម្បត្តិដោយធ្វើការប្រកាសភាពប្រុងប្រយ័ត្នទៅនឹងមុខសញ្ញាគ្រោះថ្នាក់ និងការទទួលយកសកម្មភាពសមស្របក្នុងពេលដែលជិតកើតមានការគំរាមកំហែង ឬគ្រោះមហន្តរាយជាក់ស្តែង (ប្រភព OCHA ) ។

***ការត្រៀមបង្ការ*(Prevention)៖** សកម្មភាពដើម្បីផ្តល់ការបញ្ចៀសទាំងស្រុងពីផលប៉ះពាល់បណ្តាលមកពីមុខសញ្ញាគ្រោះថ្នាក់ និងជាមធ្យោបាយដើម្បីបន្ថយជាអតិប្បរិមាទាក់ទងនឹងគ្រោះមហន្តរាយនៃបរិស្ថានគ្រោះមហន្តរាយនៃបច្ចេកវិទ្យាគ្រោះមហន្តរាយនៃជីវសាស្ត្រ។ ការពឹងពាក់លើសង្គម និងបច្ចេកវិទ្យា និងការពិចារណាទៅលើតម្លៃនៃផលប្រយោជន៍ការវិនិយោគក្នុងវិធានការរៀបចំគឺបង្ហាញនូវភាពសមហេតុផលក្នុងតំបន់ប៉ះពាល់ញឹកញាប់ដោយគ្រោះមហន្តរាយ។ ក្នុងបរិបទនៃការយល់ដឹងជាសាធារណៈនិងអប់រំទាក់ទងទៅនឹងការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ការផ្លាស់ប្តូរអកប្បកិរិយានិងឥរិយាបថនាំមកនូវការរីកចំរើនឡើង។

***ការយល់ដឹងជាសាធារណៈ* (Public Awareness)៖** ជាដំណើរការនៃការផ្តល់ព័ត៌មានមានដល់ប្រជាជនទូទៅ បង្កើនការភ្ញាក់រឭកអំពីគ្រោះភ័យ និង ធ្វើយ៉ាងម៉េចឱ្យប្រជាជនអាចដើរតួទៅនឹងទង្វើរបស់គាត់ក្នុងការកាត់បន្ថយមុខសញ្ញាគ្រោះមហន្តរាយ។ ការយល់ដឹងនេះមានសារសំខាន់ណាស់ ជាពិសេសចំពោះមន្ត្រីសាធារណៈក្នុងការបំពេញការទទួលខុសត្រូវដើម្បីការពារជីវិត និងទ្រព្យសម្បត្តិក្នុងព្រឹត្តិការណ៍គ្រោះមហន្តរាយ។ ការយល់ដឹងជាសាធារណៈ ជាសកម្មភាពជម្រុញឱ្យចម្រើនឡើងការផ្លាស់ប្តូរក្នុងអាកប្បកិរិយានាំមុខគេឆ្ពោះទៅវប្បធម៌កាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ។ ការយល់ដឹងជាសាធារណៈជាប់ទាក់ទងព័ត៌មានសាធារណៈ ការចែកចាយ ការអប់រំ ការផ្សព្វផ្សាយ តាមវិទ្យុ និងទូរទស្សន៍ និង ការប្រើប្រាស់ការបោះពុម្ពប្រព័ន្ធឃោសនា ក៏ដូចជាការបង្កើតមជ្ឈមណ្ឌលព័ត៌មាន និងបណ្តាញការងាររួមទាំងសកម្មភាព និងការចូលរួមរបស់សហគមន៍។

***ការដោះស្រាយសម្រាលទុក្ខ/ការឆ្លើយតប* (Relief/ Response)៖** ជាការផ្តល់ទៅលើកិច្ចសង្គ្រោះ ឬអន្តរាគមន៍នៅក្នុងអំឡុងពេលមួយរំពេច ឬបន្ទាប់ពីពេលមានគ្រោះមហន្តរាយដើម្បីបំពេញឱ្យបានការការពារជីវិត និងសេចក្តីត្រូវការស្ថេរភាពជីវភាពជាមូលដ្ឋាននៃប្រជាជនដែលប៉ះពាល់នោះ។ ការដោះស្រាយសម្រាលទុក្ខ ការឆ្លើយតបវាអាចធ្វើភ្លាមៗរយៈពេលខ្លី ពន្យាថេរវេលា។

***ការកសាងភាពធន់* (Resilience)៖** ជាសមត្ថភាពនៃប្រព័ន្ធសហគមន៍ ឬសង្គមមានសក្តានុពលបានបង្ហាញឱ្យដឹងដើម្បីបន្សុាំទៅនឹងមុខសញ្ញាគ្រោះថ្នាក់ដោយការតស៊ូឬការផ្លាស់ប្តូរក្នុងសេចក្តីបង្គាប់ដើម្បីឈានទៅសម្រេចនិងកម្រិតថែទាំត្រូវទទួលបានទាំងមុខងារ និងរចនាសម្ព័ន្ធ។ សមត្ថភាពទប់ទល់បាននេះកំណត់ដោយកម្រិតថ្នាក់ប្រព័ន្ធសង្គមណាមួយមានលទ្ធភាពរៀបចំដោយខ្លួនឯងទៅនឹងការកើនសមត្ថភាព ដែលរៀនសូត្រពីគ្រោះមហន្តរាយកន្លងទៅហើយសម្រាប់ការការពារឱ្យប្រសើរជាងនៅអនាគត និងឈានទៅពង្រឹងវិធានការកាត់បន្ថយគ្រោះភ័យ។

***គ្រោះហានិភ័យ* (Risk)៖** ភាពអាចនឹងមានឡើងនៃផលវិបាកដែលធ្វើឱ្យខូចបង់ ឬការបាត់បង់ដែលយល់ថានឹងកើតមានឡើង (ការស្លាប់ របួស ទ្រព្យសម្បត្តិ ការរស់នៅ ការរំខានដល់សកម្មភាពសេដ្ឋកិច្ច ឬការខូចខាតដល់បរិស្ថាន) គឺលទ្ធផលមកពីអន្តរកម្មរវាងមុខសញ្ញាគ្រោះថ្នាក់បណ្តាលពីមនុស្ស ឬធម្មជាតិ និងស្ថានភាពនៃភាពងាយរងគ្រោះ។

**ការគ្រប់គ្រងគ្រោះហានិភ័យ:** គឺជាការកំណត់អត្តសញ្ញាណកម្ម ការវាយតម្លៃ និងការកំណត់អាទិភាព នៃហានិភ័យ (ផលប៉ះពាល់ នៃភាពមិនប្រាកដប្រាជានៃគោលបំណងថាតើវិជ្ជមាន ឬអវិជ្ជមាន) តាមរយៈការអនុវត្តធនធានតាមបែបសេដ្ឋកិច្ច និង

ការសម្របសម្រួលដើម្បីកាត់បន្ថយ តាមដាន និងត្រួតពិនិត្យនូវលទ្ធភាពនឹង/ឬ ផលប៉ះពាល់នៃព្រឹត្តិការណ៍ អកុសល្យ ឬ ដើម្បីបង្កើតឱ្យដល់កម្រិតអតិបរមានូវឱកាសជាក់លាក់។

***ការវាយតម្លៃ/ការវិភាគគ្រោះភ័យ* (Risk Assessment/ Analysis):** ជាវិធីសាស្ត្រដើម្បីកំណត់អំពីលក្ខណៈ និងវិសាលភាពគ្រោះភ័យដោយធ្វើការវិភាគទៅលើសក្តានុពលនៃមុខសញ្ញាគ្រោះថ្នាក់រួចធ្វើការវាយតម្លៃលើស្ថានភាពដែលមានស្រាប់នៃភាពងាយរងគ្រោះនេះអាចទំនងមានសក្តានុពលគំរាមកំហែង ឬមានគ្រោះថ្នាក់ទៅលើប្រជាជន ទ្រព្យសម្បត្តិ ការរស់នៅ និងបរិស្ថានលើអ្វីមួយដែលពួកគេពឹងពាក់។

***ការផ្ទេរគ្រោះភ័យ* (Risk Transfer):** ការធានារ៉ាប់រង និងការធានារ៉ាប់រងឡើងវិញទាំងពីរនេះគឺសម្រាប់ការឈប់អាជីវកម្ម និងការខូចខាតផ្នែករូបវន្ត ហើយការគាំពារដោយធានារ៉ាប់រងនេះ ដែលតែងតែផ្តល់នូវការទូទាត់បន្ថែមសាច់ប្រាក់ភ្លាម១បន្ទាប់ពីមានគ្រោះមហន្តរាយ។ ដើម្បីអាចសម្រេចបានទូលំទូលាយគឺត្រូវបង្កើនមូលនិធិរួមទូលាយនៃអ្នកទទួលបានការធានាដោយជៀសវាងបង់ប្រាក់បុព្វលាភខ្ពស់ និងនាំបង្ហាញខ្លួនអ្នកដែលត្រូវបានប្រគល់សិទ្ធិធានារ៉ាប់រងសម្រាប់ធុរកិច្ច នោះ និងស្ថាប័នសាធារណៈដែលមានទៅនឹងដំណើរការស្ថានភាពដែលប្រកបដោយមុខសញ្ញាគ្រោះថ្នាក់។

***ភាពងាយរងគ្រោះ*(Vulnerability):** ជាស្ថានភាពដែលកំណត់ដោយកត្តាឬដំណើរការជារូបវន្ត សង្គម សេដ្ឋកិច្ចនិងបរិស្ថាននៃសហគមន៍ណាមួយហើយដែលងាយកើនទៅនឹងផលប៉ះពាល់នៃមុខសញ្ញាគ្រោះថ្នាក់។

***ការគ្រប់គ្រងផ្អែកលើអេកូស៊ីស្ទែម* (Ecosystem-Based Management):** ជាវិធានការរួមសំរាប់ការគ្រប់គ្រងដែលគិតលើអេកូស៊ីស្ទែមទាំងមូលរួមបញ្ចូលទាំងមនុស្ស។ គោលដៅនៃការគ្រប់គ្រងផ្អែកលើអេកូស៊ីស្ទែមគឺដើម្បីរក្សាអេកូស៊ីស្ទែមឱ្យមានសុខភាពល្អប្រកបដោយផ្លែផ្កា និងធនដើម្បីឱ្យវាអាចផ្តល់នូវទំនិញ និងសេវាកម្មដែលមនុស្សត្រូវការ និងចង់បាន។ ការគ្រប់គ្រងផ្អែកលើអេកូស៊ីស្ទែមខុសពីវិធីសាស្ត្របច្ចុប្បន្នដែលតែងតែផ្តោតទៅលើប្រភេទតែមួយសកម្មភាពតែមួយផ្ទៃលតែមួយ រឺកង្វល់តែមួយ។ វាគិតទៅលើផលប៉ៈពាល់គ្រប់ផ្នែកទាំងអស់។

***ការគ្រប់គ្រងការប្រើប្រាស់សមុទ្រ***

មានលក្ខណៈស្រដៀងគ្នានឹងការគ្រប់គ្រងការប្រើប្រាស់ដីនៅក្នុងបរិស្ថានដែនដីដែរគឺៈ

១. កិច្ចការឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយនិរន្តរភាពមិនមែនជាការគ្រប់គ្រងដោយគ្រាន់តែផ្តោតលើការការពារបរិស្ថាន ឬការអភិរក្សហើយវារួមចំណែកច្រើនទៅលើគោលដៅផ្នែកសេដ្ឋកិច្ច និងសង្គម

២. ផ្តល់នូវក្របខណ្ឌប្រមើលមើលទៅអនាគតបែបសមាហរណកម្ម និង ជាយុទ្ធសាស្ត្រសំរាប់ការប្រើប្រាស់តំបន់សមុទ្រគ្រប់ប្រភេទដើម្បីជួយឱ្យសម្រេចបាននូវការអភិវឌ្ឍប្រកបដោយនិរន្តរភាពដោយគិតគូរអំពីបរិស្ថាន សង្គម និងសេដ្ឋកិច្ច។

៣. អនុវត្តវិធីសាស្ត្រផ្អែកលើអេកូស៊ីស្ទែមសំរាប់ការរៀបចំផែនការ និងការគ្រប់គ្រងការអភិវឌ្ឍ និងសកម្មភាពផ្សេងៗនៅតំបន់សមុទ្រដោយការពារនូវដំណើរការផ្អែកអេកូស៊ីស្ទែម និងការកសាងភាពធន់ដើម្បីធានាថាបរិស្ថានមានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្តល់ផលប្រយោជន៍ ផ្នែកសេដ្ឋកិច្ច និងសង្គម (រួមបញ្ចូលទាំងគុណប្រយោជន៍ទាំងអស់ដែលទាញចេញដោយផ្ទាល់ពីអេកូស៊ីស្ទែម)។

៤. កំណត់បង្ហាញ ការពារ ឬត្រង់ណាចាំបាច់ និងសមស្រប ស្តារឡើងវិញនូវសមាសធាតុសំខាន់ៗរបស់អេកូស៊ីស្ទែមសមុទ្រដោយរួមទាំងកេរ្តិ៍ដំណែលធម្មជាតិ និងការអភិរក្សធនធានធម្មជាតិ

៥. តាមរយៈផែនការប្រើប្រាស់តំបន់សមុទ្រ ចូរវិភាគ និងកំណត់ទីតាំងតាមរបៀបមួយដែលកាត់បន្ថយជម្លោះដែលកើតឡើងក្នុងចំណោមសកម្មភាពរបស់មនុស្សព្រមទាំងជម្លោះមនុស្សនិងធម្មជាតិ។

**ផែនការបែងចែកតំបន់:** ផែនការបែងចែកតំបន់គឺជាឧបករណ៍មួយសម្រាប់ការធ្វើផែនការប្រើប្រាស់ដី និងសមុទ្រដែលប្រើប្រាស់ទឹកដោយរដ្ឋាភិបាលមូលដ្ឋាននៃប្រទេសជាច្រើន។ ពាក្យនេះក្លាយមកពីការអនុវត្ត ការធ្វើគ្រោងប្លង់ប្រើប្រាស់ដែលត្រូវអនុញ្ញាតលើការប្រើប្រាស់ដី ឬសមុទ្រដោយផ្អែកលើការកំណត់តំបន់នៅលើផែនទីដែលខុសប្លែកពីការប្រើប្រាស់ដីនិងសមុទ្រពីកន្លែងមួយទៅកន្លែងមួយទៀត។ ការបែងចែកតំបន់ប្រហែលជាផ្អែកលើការប្រើប្រាស់ (កំណត់ការប្រើប្រាស់ថាតើដីឬសមុទ្រកន្លែងណាដែលត្រូវដាក់ក្នុងផែនការប្រើប្រាស់)ឬវាអាចកំណត់តាមរយៈកម្ពស់អាគារ ទំហំដីឡូ និងអត្តចរិកស្រដៀងគ្នាឬក៏ការរួមបញ្ចូលគ្នានូវគោលការណ៍ទាំងអស់នេះ។ វិធីសាស្ត្រកសាងផែនការនគរូបនីយ៍កម្មបានបង្ហាញនូវការប្រើប្រាស់តំបន់ផ្សេងៗគ្នាសម្រាប់គោលបំណងពិសេសនៅក្នុងទីក្រុងជាច្រើន។

**ការធ្វើផែនការបែងចែកតំបន់សមុទ្រ** ***(Marine Spatial Planning):***

គឺជាដំណើរការជាសាធារណៈនៃការវិភាគ និងការកំណត់ ការបែងចែកសកម្មភាពរបស់មនុស្សបណ្តោះអាសន្ននិងតាមផ្នែកនៅតំបន់សមុទ្រដើម្បីសម្រេចបានគោលដៅសេដ្ឋកិច្ច សង្គម និង អេកូស៊ីស្ទែមដែលជាទូទៅមានបញ្ជាក់ច្បាស់តាមរយៈដំណើរការផ្អែកនយោបាយ។ MSP គួរតែជាការគ្រប់គ្រងផ្អែកលើអេកូស៊ីស្ទែម និងជាសមាសធាតុមួយនៃការគ្រប់គ្រងការប្រើប្រាស់តំបន់សមុទ្រ។

**ការបែងចែកតំបន់មហាសមុទ្រ** ***(Ocean Zoning):***

គឺជាវិធានការនិយ័តកម្មមួយអនុវត្តនូវផែនការប្រើប្រាស់តំបន់សមុទ្រដ៏ស៊ីជម្រៅតាមរយៈការធ្វើផែនទីបែងចែកតំបន់ រឺការធ្វើផែនទី និងនិយ័តកម្មសម្រាប់តំបន់មួយចំនួន និង គ្រប់តំបន់ទាំងអស់ ការបែងចែកតំបន់សមុទ្រគឺជាវិធីសាស្ត្រមួយប្រកបដោយប្រសិទ្ធភាពក្នុងការអនុវត្ត MSP ។

**ច្រាំង/ចំណោតឆ្នេរ (Shoreline):** ជាច្រាំង ឬជាយដីដែលទប់នូវដែនទឹកដ៏ធំ ។ សម្រាប់ក្នុងន័យរូបវិទ្យាសាស្ត្រវិញ **shoreline** រឹកធំឡើងនូវជាយដីដែលបានកែប្រែដោយសារសកម្មភាពប្រែប្រួលរបស់ដែនទឹកនៅពេលអតីតកាលនិងបច្ចុប្បន្នកាល ។ **shoreline** អាចកំណត់នូវព្រំដែននៃទឹក ។

**តំបន់សេដ្ឋកិច្ចផ្តាច់មុខ Exclusive Economic Zone (EEZ):** តំបន់សេដ្ឋកិច្ចផ្តាច់មុខគឺជាទីតាំងសមុទ្រកំណត់ដោយអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនិតិសមុទ្រ (UNCLOS) ទៅគ្រប់រដ្ឋភាគីក្នុងការរុករកនិងប្រើប្រាស់ធនធានសមុទ្រជាពិសេសផលិតផលថាមពលពីទឹក និងខ្យល់ ។ តំបន់សេដ្ឋកិច្ចផ្តាច់មុខលាតសន្ធឹងពីឆ្នេរសមុទ្រ ២០០ម៉ៃល៍ ។

**តំបន់លំហសមុទ្រ ( ដែនសមុទ្រអន្តរជាតិ) (High Seas):** អនុវត្តចំពោះតំបន់នៅមហាសមុទ្រដែលមិនមែនជាតំបន់សេដ្ឋកិច្ចផ្តាច់មុខ ឬ សមុទ្រដែនដី ឬដែនទឹកផ្ទៃក្នុងរបស់រដ្ឋណាមួយ ។

**តំបន់ឆ្នេរ (Coastal Zone):** គឺជាទីតាំងតំបន់មានការធ្វើអន្តរកម្មរវាងសមុទ្រនិងដីដោយមិនបញ្ចូលទាំងដី ដែលនៅឆ្ងាយពីសមុទ្រ។ ដោយសារសកម្មភាពឌីណាមិចផ្តល់ឱ្យតំបន់នេះផលិតនូវប្រភេទនានានិងផលិតភាពអេកូស៊ីស្ទែមសម្រាប់កំណើននៃការតាំងទីលំនៅរបស់ប្រជាពលរដ្ឋ ។

**ផ្ទៃដីតំបន់ឆ្នេរ (Coastal Areas):** ជាទូទៅមានន័យថាជាការជួបប្រសព្វរវាងដី និងទឹកសមុទ្រដោយរាប់បញ្ចូលទាំងដីដែលនូវឆ្ងាយពីមាត់សមុទ្រ។ ភូមិសាស្ត្រឆ្នេរគឺមិនមានការទៀងទាត់នូវតួនាទីនិងទ្រង់ទ្រាយ ។ ការផ្លាស់ប្តូរជានិច្ច និងមិនផ្តល់ឱ្យ តំបន់នោះល្អដូច្នោះអាចកំណត់បានថាដោយសារតែលក្ខខណ្ឌលំហដីដ៏ដាច់ខាត ។

**ការគ្រប់គ្រងតំបន់ឆ្នេរសមុទ្រចម្រុះ (Integrated Coastal Management-ICM):** គឺជាសកម្មភាពគ្រប់គ្រងឆ្នេរដោយជំរុញចូលរួមពីគ្រប់ទិដ្ឋភាពទាំងអស់នៃតំបន់ឆ្នេររាប់បញ្ចូលទាំងភូមិសាស្ត្រ និង លក្ខខណ្ឌនយោបាយក្នុងការខិតខំប្រឹងប្រែងសម្រេចឱ្យបាននូវការចិញ្ចឹមជីវិតឱ្យមាននិរន្តរភាព ។

**ស្មៅសមុទ្រ** **(Sea grass):** គឺជាស្មៅដែលដូចជារុក្ខជាតិផ្កាដែលរស់ពាសពេញបាតសមុទ្រ និងមាត់សមុទ្រ

**ការគ្រប់គ្រងផ្អែកលើសហគមន៍** **(Community Based Management):** ពឹងផ្អែកទៅប្រជាជនមូលដ្ឋានក្នុងការទាញយកការស្រាវជ្រាវ រៀបចំ និងប្រតិបត្តិការនៃការគ្រប់គ្រង។ រចនាបទនៃការគ្រប់គ្រងនេះអាចប្រើសម្រាប់សង្គម និងបុព្វហេតុបរិស្ថាន។ CBM ប្រើប្រាស់វិធីសាស្ត្រច្នៃប្រឌិតដោយមានការចូលរួមពីប្រជាជនមូលដ្ឋាន និងការអនុវត្តការគ្រប់គ្រងដីធ្លី។

**ការបែងចែកការប្រើប្រាស់ដីតំបន់ឆ្នេរសមុទ្រ** **(Coastal Land Use Zoning):** គឺការបែងចែកតំបន់ប្រើប្រាស់ដីតំបន់ឆ្នេរសមុទ្រក្នុងវិស័យផ្សេងៗដូចជា កសិកម្ម ឧស្សាហកម្ម-ទេសចរណ៍ និងនេសាទហើយត្រូវអភិវឌ្ឍន៍ដោយនិរន្តរភាព។

**ខ្ពង់រាបបាតសមុទ្រ** **(Intercontinental Shelf):** ខ្ពង់រាបបាតសមុទ្ររបស់រដ្ឋឆ្នេរសមុទ្រផ្សំឡើងពីបាតសមុទ្រនិងដីក្រោមបាតសមុទ្រនៃតំបន់ក្រោមសមុទ្រដែលលាតសន្ធឹងហួសសមុទ្រដែនដីនៅពាសពេញការដុះបន្តនៃដែនដីគោករបស់ខ្លួនរហូតដល់គែមក្រៅរបស់ជាយទ្វីបឬរហូតដល់ចម្ងាយ ២០០ម៉ៃល៍សមុទ្រពីបន្ទាត់មូលដ្ឋានវាស់សមុទ្រដែនដីដែលគែមក្រៅរបស់ជាយទ្វីបមិនលាតសន្ធឹងដល់ចម្ងាយនោះ។

**ការអភិវឌ្ឍផ្អែកលើចក្ខុវិស័យ/ទ្រព្យសម្បត្តិ:** វិធីសាស្ត្របែបនេះចាប់ផ្តើមឡើងដោយផ្អែកលើទ្រព្យសម្បត្តិ, បង្កើតឡើងនូវចក្ខុវិស័យ និងគោលបំណងរយៈពេលវែង បន្ទាប់មកទៀត កំណត់លក្ខខណ្ឌទុកជាមុន ឧបសគ្គ និងការរារាំងដែលត្រូវតែដោះស្រាយ។ "**បញ្ហា**" បានកំណត់ថាទាក់ទងនឹងគោលបំណង និងចក្ខុវិស័យផ្ទុយទៅនឹងវិធីសាស្ត្របុរាណដែលដំបូងកំណត់ "**បញ្ហា**" និងកំណត់នូវគោលបំណងដើម្បីដោះស្រាយនូវបញ្ហាទាំងនោះ។

**ផែនការប្រើប្រាស់តំបន់ឆ្នេរ និងសមុទ្រ** (CMSP)**:ការរៀបចំផែនការប្រើប្រាស់តំបន់ឆ្នេរនិងសមុទ្រ** បានចាត់ថាជាឧបករណ៍ជម្រើសជុំវិញពិភពលោក ជាពិសេសក្នុងតំបន់ដែលប្រើប្រាស់សមុទ្រច្រើន។ **ការរៀបចំផែនការប្រើប្រាស់តំបន់ឆ្នេរនិងសមុទ្រ** ផ្តល់ឱ្យប្រទេសទាំងឡាយនូវក្របខណ្ឌអនុវត្តន៍ដើម្បីរក្សានូវតម្លៃជីវៈចម្រុះសមុទ្រដែលនៅពេលជាមួយគ្នាជម្រុញឱ្យមានការប្រើប្រាស់ប្រកបដោយចីរភាពនូវសក្តានុពលសេដ្ឋកិច្ចរបស់វា។

**ការរៀបចំផែនការប្រើប្រាស់តំបន់ឆ្នេរនិងសមុទ្រ:**គឺជាវិធីសាស្ត្រដែលអាចធ្វើឱ្យសមាសភាពសំខាន់ៗនៃការគ្រប់គ្រងតំបន់ឆ្នេរនិងសមុទ្រផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមក្លាយជាការពិត។

**មុខសញ្ញាគ្រោះថ្នាក់ ហានិភ័យ ភាពងាយរងគ្រោះ** នៅប្រទេសជាច្រើន ការគ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់ និង ហានិភ័យមានភាពខុសគ្នាពីការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរដោយមានអង្គការ និងអាជ្ញាធររបស់គេផ្ទាល់ ជាញឹកញាប់មានអាជ្ញាធរបែបហ្នឹងច្រើន។ ភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច/សង្គមជារើយៗមានការយកចិត្តទុកដាក់តិចតួចណាស់ពីសំណាក់អ្នកធ្វើផែនការ ឬអ្នកគ្រប់គ្រងហានិភ័យ។ ឯកសារនេះផ្តោតសំខាន់លើការផ្សាភ្ជាប់ទំនាក់ទំនងរវាងការគ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និងការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរ និងសមុទ្រ។

**ទស្សនៈទានរួម (Nesting) ផ្នែកប្រព័ន្ធអេកូស៊ីស្តែម រដ្ឋបាលគ្រប់គ្រងនិងផែនការប្រើប្រាស់តំបន់ឆ្នេរ:** ការរៀបចំផែនការប្រើប្រាស់តំបន់ឆ្នេរអនុវត្តតាមមាត្រដ្ឋានជាច្រើនពីផែនការជាលក្ខណៈបុគ្គលរហូតដល់តំបន់អន្តរជាតិ។ ដូចគ្នានេះផងដែរ អង្គភាពរដ្ឋបាល ជាទូទៅរៀបចំរចនាសម្ព័ន្ធតាមលក្ខណៈឋានានុក្រមដែលចាប់ផ្តើមពីតូចរហូតដល់ធំហើយ"**មូលដ្ឋាន**" ត្រូវបានដាក់ត្រួតគ្នាទៅក្នុងកម្រិតកាន់តែខ្ពស់ឡើងដែលនេះក៏តំណាងឱ្យប្រព័ន្ធគ្រប់គ្រងផងដែរ។ ទស្សនៈទានស្រដៀងគ្នានេះឃើញមាននៅក្នុងប្រព័ន្ធអេកូស៊ីស្តែមជាកន្លែងមានមីក្រូអេកូស៊ីស្តែមសំដៅលើតំបន់ដែលមានដើមឈើធំមួយក្នុងព្រៃក្រាស់តំបន់ទេសភាព ទីជម្រាល និងតំបន់ភូមិសាស្ត្រក្តៅ។ ទោះបីជាប្រភេទសត្វ រុក្ខជាតិនីមួយៗមានការរួមរស់ក្នុងលំហតូចចង្អៀតក៏ដោយ ក៏ប្រភេទផ្សេងដែលពួកគេមានអន្តរកម្មរវាងគ្នាអាចបង្កើនគម្លាតទូលាយជាង និង ដូចនេះវាទទួលរងផលប៉ះពាល់ជាច្រើនដែលបានយកចេញឆ្ងាយពីតំបន់សិក្សា។ អាស្រ័យហេតុនេះ ទស្សនៈទានរួមនេះមានទំនាក់ទំនងជិតស្និទ្ធនឹងគំនិតដែលនៅខាងក្រោយទស្សនៈទាន **(Ridge to Reef)**។ តាមទស្សនៈនេះបាតុភូតរួមបានបញ្ជាក់សម្រាប់ការកំណត់វិសាលភាពនៃធាតុចូល SCP ទោះជាខ្នាត ឬកម្រិតផែនការអ្វីក៏ដោយ។

<u>RIDGE-TO-REEF</u>: ផលវិបាករបស់ធម្មជាតិនៃការគ្រប់គ្រងផ្អែកតាមប្រព័ន្ធអេកូស៊ីស្តែមក្នុងតំបន់ឆ្នេរឪណាមិកគឺការទទួលស្គាល់នូវអ្វីកើតឡើងនៅក្នុងតំបន់មួយវានឹងមានផលប៉ះពាល់លើតំបន់មួយផ្សេងទៀត។ យន្តការទំនាក់ទំនងធម្មជាតិច្បាស់លាស់បំផុតគឺវដ្តជលសាស្ត្រដែលក្នុងចំណោមអ្វីៗផ្សេងទៀតនាំយកវត្ថុពីទីតាំងខ្ពស់មកទីតាំងទាប។ បើមានអ្វីកើតឡើងនៅតំបន់ខ្ពង់រាបឆ្ងាយពីតំបន់ឆ្នេរនឹងមានផលប៉ះពាល់ប្រព័ន្ធអេកូស៊ីស្តែមនៅតំបន់សមុទ្រទាំងមូល និងតំបន់នៅចន្លោះនោះជាច្រើនទៀត។ ឧទាហរណ៍ ការកាប់ព្រៃឈើនៅតំបន់ដីខ្ពង់រាបដែលមានសំណើមអាចនឹងនាំទៅរកការហូរច្រោះ និងនាំកករមកជាមួយកាន់តែច្រើនដែលអាចប៉ះពាល់ដល់ទន្លេនិងប្រព័ន្ធអេកូស៊ីស្តែមច្រាំងទន្លេ ព្រៃកោងកាង ស្មៅសមុទ្រ និងផ្កាថ្ម។ទាំងនេះគឺជាការបញ្ជាក់ដ៏សំខាន់សម្រាប់ការកំណត់ព្រំដែនតំបន់ CSP ដែលអាចមានការលំបាកក្នុងការដោះស្រាយ។

**គោលការណ៍ត្រៀមបម្រុង និងការកាត់បន្ថយហានិភ័យ:** គោលការណ៍នេះមានន័យថាក្នុងករណីមានការសង្ស័យ ឬទំនាស់ការយល់ច្រឡំត្រូវមានការប្រុងប្រយ័ត្នទុកជាមុន។ ក្នុងបរិបទចីរភាព គោលការណ៍នេះបានអំពាវនាវឱ្យមានការរក្សាទុកជម្រើសជាច្រើនបានឱ្យបានវែងតាមដែលអាចធ្វើទៅបានដើម្បីកុំឱ្យរារាំងលទ្ធភាពអ្នកជំនាន់ក្រោយធ្វើការជ្រើសរើស។

**ចីរភាព/និរន្តរភាព:** ការកសាងផែនការ គឺជាឧបករណ៍គ្រប់គ្រងដែលគោលបំណងសំខាន់របស់វា គឺ ការផ្តល់នូវ ការគ្រប់គ្រងនៅពេលអនាគតក្នុងបរិបទនៃភាពមិនប្រាកដប្រជា។ គោលបំណងគឺដើម្បីបង្កើតនូវអនាគតមួយដែលជាការកែលំអរនូវពេលបច្ចុប្បន្ន។ ការឆ្លើយតបទៅនឹងតម្រូវការបច្ចុប្បន្នមិនប៉ះពាល់តម្រូវការជំនាន់ក្រោយគឺជាចំណុចស្នូលនៃគោលការណ៍អភិវឌ្ឍដោយចីរភាព។ ផែនការប្រើប្រាស់តំបន់ឆ្នេរគឺជាឧបករណ៍គន្លឹះមួយដើម្បីឱ្យសម្រេចបានគោលដៅនេះដោយធានាថា ធនធានសំខាន់ៗត្រូវបានអភិរក្ស និងប្រើប្រាស់ដោយគតិបណ្ឌិត។

**តើអ្វីទៅជាការធ្វើផែនការបែងចែកការប្រើប្រាស់តំបន់សមុទ្រ?**

ការធ្វើផែនការបែងចែកការប្រើប្រាស់តំបន់សមុទ្រ (MSP) ជាវិធីសាស្ត្រជាក់លាក់ដើម្បីរៀបចំផែនការប្រើប្រាស់តំបន់សមុទ្រទំនាក់ទំនងនៃការប្រើប្រាស់ធ្វើឱ្យមានតុល្យភាពតំរូវការក្នុងការអភិវឌ្ឍ និង ភាពចាំបាច់ក្នុងការការពារប្រពន្ធ័អេកូស៊ីស្ទែមសមុទ្រនិងដើម្បីទទួលបាននូវគោលដៅផ្នែកសេដ្ឋកិច្ច និងសង្គម តាមវិធីសាស្ត្ររៀបចំផែនការដោយបើកចំហរ។ *ការធ្វើផែនការបែងចែកការប្រើប្រាស់តំបន់សមុទ្រ (MSP) ជាដំណើរការវិភាគ និងបែងចែកសកម្មភាពកើតឡើងដោយសារមនុស្សជាសារធារណៈនៅតំបន់សមុទ្រដើម្បីសម្រេចបានគោលដៅផ្នែកសង្គម សេដ្ឋកិច្ច និង អេកូស៊ីស្ទែមនៅក្នុងដំណើការរៀបចំគោលនយោបាយ។*

យើងត្រូវចងចាំថាយើងអាចរៀបចំផែនការនិងការគ្រប់គ្រងសកម្មភាពបង្កឡើងដោយសារមនុស្សនៅតំបន់សមុទ្របានតែយើងមិនអាចធ្វើទៅកើតលើប្រព័ន្ធអេកូស៊ីស្ទែមសមុទ្របានទេ។ យើងអាចបែងចែកសកម្មភាពកើតឡើងដោយសារមនុស្សតាមគោលបំណងនៅតំបន់សមុទ្រជាក់លាក់បាន ឧទាហរណ៍ដូចជាទៅតាមតំបន់អភិរក្ស ឬ តំបន់អភិវឌ្ឍន៏ ឬក៏ទៅតាមការប្រើប្រាស់ជាក់លាក់ ឧទាហរណ៍ដូចជាទៅតាមតំបន់ធ្វើកសិកម្ម តំបន់ឆ្នេរ តំបន់វាលខ្សាច់ និងតំបន់មានរ៉ែ។ MSP មិនមែនមានន័យថាជាការធ្វើផែនការតែម្តងចប់នោះទេ, វាជាដំណើរការបន្តបន្ទាប់ វិច្រាំដែលៗមួយដោយតម្រូវឱ្យរៀនសូត្រនិងបន្សាំតាមក្នុងរយៈពេលយូរ។ ការអភិវឌ្ឍ និងការអនុវត្ត MSP មានច្រើនជំហានដូចជា:

ក. ការកំណត់បង្ហាញនូវតម្រូវការ និងការបង្កើតអជ្ញាធរគ្រប់គ្រង

ខ. ការទទួលបាននូវការផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុ

គ. ការរៀបចំផែនការបឋម

ឃ. ការរៀបចំឱ្យមានការចូលរួមពីគ្រប់ស្ថាប័នពាក់ព័ន្ធ

ង. ការកំណត់ និងការវិភាគស្ថានភាពបច្ចុប្បន្ន

ច. ការកំណត់ និងការវិភាគស្ថានភាពអនាគត

ឆ. ការរៀបចំ និងការអនុម័តផែនការគ្រប់គ្រង

ជ. ការអនុវត្ត និងការពង្រឹងផែនការគ្រប់គ្រង

ឈ. ការតាមដាន និងការវាយតម្លៃការអនុវត្តផែនការ

ញ. ការបន្សាំ និងការអនុវត្តការគ្រប់គ្រងតំបន់សមុទ្រ

## ហេតុអ្វីបានជាចាំបាច់ត្រូវមានផែនការបែងចែកការប្រើប្រាស់តំបន់ឆ្នេរសមុទ្រ?

មានប្រទេសជាច្រើនបានធ្វើការបែងចែកការប្រើប្រាស់តំបន់សមុទ្រសំរាប់ការប្រើប្រាស់របស់មនុស្សដូចជា ការដឹកជញ្ជូនតាមសមុទ្រ ការអភិវឌ្ឍរុករកប្រេង និង ឧស្ម័ន ថាមពលកកើតឡើងវិញ ជលវប្បកម្មសមុទ្រ និងការបោះចោលកាកសំណល់។ ក៏ប៉ុន្តែបញ្ហានៅត្រង់ថាជាធម្មតាការបែងចែកតំបន់សមុទ្រនេះធ្វើឡើងតាមផ្នែកតាមករណីមួយៗដោយមិនបានគិតល្អិតល្អន់ពីផលប៉ះពាល់ទៅលើមនុស្ស និងបរិស្ថានសមុទ្រនោះទេ។ កត្តាទាំងនេះបណ្តាលឱ្យមានបញ្ហា២ប្រភេទធំៗ:

១. ជម្លោះកើតឡើងដោយសារការប្រើប្រាស់របស់មនុស្ស-ជម្លោះរវាងអ្នកប្រើប្រាស់ និងអ្នកប្រើប្រាស់

២. ជម្លោះរវាងការប្រើប្រាស់របស់មនុស្ស និង បរិស្ថានសមុទ្រ-ជម្លោះរវាងអ្នកប្រើប្រាស់ និងបរិស្ថាន

ជម្លោះទាំងនេះធ្វើឱ្យអន់ខ្សោយសមត្ថភាពរបស់សមុទ្រក្នុងការផ្តល់នូវអេកូស៊ីស្ទែមដែលជាទីពុំនាក់ដ៏សំខាន់របស់មនុស្ស និងជីវិតផ្សេងៗទៀតនៅលើផែនដី។ លើសពីនេះទៅទៀត អ្នកធ្វើការសំរេចចិត្តក្នុងស្ថានភាពនេះ ជាទូទៅអាចមានប្រតិកម្មតែចំពោះហេតុការណ៍ដែលកើតឡើងហួសពេលមិនមែនការមានជម្រើសធ្វើផែនការ និង រៀបចំសកម្មភាពសម្រាប់ដោះស្រាយបញ្ហាអនាគតតាមបំណងប្រាថ្នានៃបរិស្ថានសមុទ្រ។

## ហេតុអ្វីបានជាទីតាំង និងពេលវេលាមានសារៈសំខាន់?

តំបន់សមុទ្រមួយចំនួនមានសារៈសំខាន់ជាងតំបន់ផ្សេងៗទៀត ទាំងផ្នែកអេកូស៊ីស្ទែម និងផ្នែកសេដ្ឋកិច្ច។ ប្រភេទសត្វ និងរុក្ខជាតិផ្សេងៗ ជម្រក ចំនួនសត្វ និងរុក្ខជាតិ ប្រេងឆៅ ឧស្ម័ន ខ្សាច់ ថ្មតូចៗ និង ខ្យល់ធម្មជាតិមាននៅគ្រប់ទីកន្លែង និងទៅតាមពេលវេលាផ្សេងៗគ្នា។ ការគ្រប់គ្រងតំបន់សមុទ្រប្រកបដោយជោគជ័យគឺត្រូវការអ្នករៀបចំផែនការនិងអ្នកគ្រប់គ្រងដែលយល់ពីវិធីសាស្រធ្វើការជាមួយសមាសធាតុចម្រុះ និង ទំហំផ្ទៃសមុទ្រដ៏ធំធេង។ ការយល់ច្បាស់អំពីទំហំសមុទ្រ និងការវាយប៉ាយធនធានដែលមានក្នុងរយៈពេលកំណត់ព្រមទាំងធ្វើការបែងចែកតំបន់ប្រើប្រាស់ឱ្យបានច្បាស់លាស់ជាផ្នែកមួយសំខាន់

របស់ MSP ។ ម្យ៉ាងទៀតការគ្រប់គ្រងសកម្មភាពរបស់មនុស្សដើម្បីធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់រួមគ្នា ហើយកាត់បន្ថយជម្លោះ ដែលអាចកើតមានក្នុងចំណោមអ្នកប្រើប្រាស់ហើយកាត់បន្ថយជម្លោះរវាងសកម្មភាពកើតឡើងដោយមនុស្សនិងធម្មជាតិជាលទ្ធផលសំខាន់របស់ MSP ។ ការត្រួតពិនិត្យថាតើការបែងចែកនេះអាចមានការផ្លាស់ប្តូរដោយសារការប្រែប្រួលអាកាសធាតុ និងសំពាធរយៈពេលយូរផ្សេងៗទៀតដូចជាការនេសាទដោយមានដែនកំណត់លើប្រពន្ធ័ធនធានសមុទ្រជាជំហានមួយទៀតរបស់ MSP ។

## តើការរៀបចំផែនការប្រើប្រាស់តំបន់ឆ្នេរសមុទ្រមានផលប៉ះពាល់ចល់ប្រព័ន្ធអេកូស៊ីស្ទែមយ៉ាងដូចម្ដេចខ្លះ?

តំបន់សមុទ្រ ឬ ប្រពន្ធ័បរិស្ថានសមុទ្រទទួលរងផលប៉ះបាល់ដោយសារសកម្មភាពមនុស្សតម្រូវការប្រើប្រាស់ធនធានធម្មជាតិរបស់តំបន់នោះដើម្បីទទួលបាននូវផលិតផល និងសេវាកម្មតាមតម្រូវការរបស់ខ្លួនដូចជា ម្ហូបសមុទ្រ ការធ្វើដំណើរតាមសមុទ្រតម្រូវការថាមពលនិងតំបន់កំសាន្ត។ សេវាកម្មដោយប្រើអេកូស៊ីស្ទែមសមុទ្រដូចជាការការពារខ្យល់ព្យុះការកែច្នៃសំណល់ និងនិយ័តកម្មអាកាសធាតុក៏ទទួលការប៉ះពាល់ដោយសារសកម្មភាពរបស់មនុស្សដែរ ។

តម្រូវការផលិតផលនិងសេវាកម្មផ្គត់ផ្គង់ជីវិតពីតំបន់សមុទ្រជាធម្មតាវាហួសពីកំរិតសមត្ថភាពដែលសមុទ្រអាចផ្ដល់ឱ្យ។ ធនធានសមុទ្រ ឧទាហរណ៏ដូចជា ត្រី ផ្កាថ្ម ជានិច្ចកាលជាធនធានទ្រព្យសម្បត្តិរួមដែលអ្នកប្រើប្រាស់អាចទទួលយកបានដោយសេរី និងបើកទូលាយ។ ជានិច្ចកាលការចេញចូលដោយសេរី—ប៉ុន្តែមិនទូទៅនោះទេ-ធ្វើឱ្យមានការប្រើប្រាស់ហួសកំរិតដូចជានេសាទហួសកំណត់ ការសឹករេចរិល និងការបាត់បង់ធនធានទាំងនោះរួមទាំងការបំពុលសមុទ្រនិងការធ្វើឱ្យបាត់បង់ជម្រកសត្វ ។ដោយសារមិនមែនគ្រប់ផលិតផលនិងសេវាកម្មពីអេកូស៊ីស្ទែមសមុទ្រទាំងអស់អាចទូទាត់ជាថវិកាបានទេនោះ ដូចនេះទីផ្សារសេរីមិនអាចដើរតួជាអ្នកចែកចាយធនធានទាំងនោះបានទេ។ និតិវិធីសាធារណៈមួយចំនួនត្រូវតែប្រើប្រាស់ដើម្បីសំរេចថាតើការលាយចម្រុះនូវផលិតផល និងសេវាកម្មអ្វីខ្លះអាចផលិតចេញពីតំបន់សមុទ្រ។ និតិវិធីនោះគឺការធ្វើផែនការប្រើប្រាស់តំបន់សមុទ្រ។

## តើផលប្រយោជន៍នៃការរៀបចំផែនការប្រើប្រាស់តំបន់ឆ្នេរសមុទ្រមានអ្វីខ្លះ?

ការរៀបចំផែនការប្រើប្រាស់តំបន់សមុទ្រផ្តល់នូវផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច សង្គម និងបរិស្ថានដ៏សំខាន់នៅពេលដែលធ្វើការអភិវឌ្ឍតាមវិធានការសមស្រប។ ***សូមមើលតារាងខាងក្រោម៖***

| | |
|---|---|
| **ផលប្រយោជន៍ផ្នែកបរិស្ថាន ឬផ្នែកអេកូឡូស៊ី** | ការកំណត់អត្តសញ្ញាណរបស់តំបន់សំខាន់ផ្នែកជីវសាស្ត្រ និងអេកូស៊ីស្ទែម |
| | គោលបំណងផ្នែកជីវចម្រុះបញ្ជ្រាបទៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត |
| | ការកំណត់ និង ការកាត់បន្ថយជម្លោះរវាងការប្រើប្រាស់របស់មនុស្ស និងធម្មជាតិ |
| | ការបែងចែកតំបន់សំរាប់អភិរក្សជីវចម្រុះ និងធនធានធម្មជាតិ |
| | ការកំណត់ និងការកាត់បន្ថយផលប៉ះពាល់ពីសកម្មភាពមនុស្សលើប្រព័ន្ធបរិស្ថានសមុទ្រ |
| **ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច** | មានភាពជាក់លាក់កាន់តែខ្លាំងសំរាប់ការធ្វើវិនិយោគដែលមានរយៈពេលលើសពី ២០-៣០ឆ្នាំ |
| | កំណត់ច្បាស់លាស់នូវការប្រើប្រាស់រួមក្នុងតំបន់អភិវឌ្ឍន៍ដូចគ្នា |
| | កាត់បន្ថយជម្លោះការប្រើប្រាស់ដែលមិនមានលក្ខណៈស៊ីគ្នា |
| | ពង្រឹងសមត្ថភាពធ្វើផែនការសំរាប់សកម្មភាពថ្មីៗ និងមានការផ្លាស់ប្តូររួមមានបច្ចេកវិជ្ជាថ្មីៗដែលកើតឡើងព្រមទាំងផលប៉ះពាល់របស់វា |
| | កាន់តែមានសុវត្ថភាពក្នុងកំឡុងពេលធ្វើប្រត្តិបត្តិការសកម្មភាពផ្សេងៗ |
| | លើកកំពស់ការប្រើប្រាស់ធនធាន និងទីតាំងប្រកបដោយប្រសិទ្ធភាព |
| | ធ្វើការពិនិត្យពិច័យ និងតម្លាភាពក្នុងនិតិវិធីផ្តល់ការអនុញ្ញាត និងចេញប័នកម្មសិទ្ធិ |
| **ផលប្រយោជន៍ផ្នែកសង្គម** | ផ្តល់ឱកាសឱ្យមានការចូលរួមរបស់ប្រជាជន និងសហគមន៍ |
| | បង្ហាញផលប៉ះពាល់នៃការសំរេចចិត្តលើការបែងចែកតំបន់សមុទ្រ(ឧ.ការបិទតំបន់សំរាប់ការប្រើប្រាស់មួយចំនួន, តំបន់ការពារ) សំរាប់សហគមន៍ និងសកម្មភាពសេដ្ឋកិច្ចនៅតំបន់ដីគោក (ឧ. ការបម្រើការងារ និងការចែកចាយប្រាក់ចំណូល) |
| | ការធ្វើអត្តសញ្ញាណកម្ម និងការអភិរក្សកេរ្តិ៍ដំណែលធម្មជាតិ |
| | ការធ្វើអត្តសញ្ញាណកម្ម និងការថែរក្សានូវតម្លៃស្មារតី និង សង្គម ដែលទាក់ទងនឹងការប្រើប្រាស់មហាសមុទ្រ (ឧទាហរណ៍ មហាសមុទ្រគឺជាទីតាំងបើកចំហ) |

**តើលទ្ធផលទទួលបានពីការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរសមុទ្រមានអ្វីខ្លះ?**

លទ្ធផលសំខាន់ៗនៃ MSP គឺផែនការគ្រប់គ្រងដែលមានលក្ខណៈស៊ីជម្រៅសំរាប់តំបន់សមុទ្រ និងអេកូស៊ីស្ទែមរបស់វា។ យើងចាត់ទុកផែនការនេះថាជាចក្ខុវិស័យសម្រាប់អនាគតដែលផែនការនេះបានកំណត់នូវអាទិភាពសំរាប់តំបន់នីមួយៗនិងកំណត់ថាអាទិភាពទាំងនេះមានន័យដូចម្តេចដោយគិតពីពេលវេលា និងទីតាំង។ ជាធម្មតាផែនការគ្រប់គ្រងដែល

មានលក្ខណៈលំអិតផ្អែកលើលក្ខណៈធម្មជាតិមានរយៈពេល១០-២០ឆ្នាំនិងឆ្លុះបញ្ចាំងពីអាទិភាពផ្អែកនយោបាយសំរាប់តំបន់នោះ។

**តើ MSP ទាក់ទងនឹងវិធីសាស្រ្តធ្វើផែនការផ្សេងៗទៀតដូចម្តេចខ្លះ?**

MSP មិនអាចជំនួសដោយការធ្វើផែនការផ្អែកទោលនោះទេ ផ្ទុយទៅវិញ វាមានគោលបំណងផ្តល់នូវគោលការណ៍ណែនាំដល់អ្នកធ្វើការសំរេចចិត្តមួយចំនួនដែលទទួលខុសត្រូវជាក់លាក់ណាមួយ សកម្មភាព ឬ ក៏បញ្ហាជាក់លាក់ណាមួយដើម្បីឱ្យពួកគេមានមធ្យោបាយក្នុងការសំរេចចិត្តប្រកបដោយភាពជឿជាក់ក្នុងលក្ខណៈកាន់តែស៊ីជម្រៅសមាហរណកម្មនិងបំពេញបន្ថែម ***(សូមមើលតារាងខាងក្រោម)*** ។ តាមរបៀបមួយចំនួន MSP មានលក្ខណៈស្រដៀងនឹងការគ្រប់គ្រងតំបន់ឆ្នេរសមុទ្រចម្រុះ។ ឧទាហរណ៍ ផែនការទាំងពីរនេះគឺត្រូវបានធ្វើតាមបែបសមាហរណកម្មយុទ្ធសាស្រ្ត និងដោយមានការចូលរួម ហើយផែនការទាំងពីរនេះមានគោលបំណងធ្វើឱ្យស្របគ្នាកាន់តែខ្លាំងក្នុងចំណោមសកម្មភាពទាំងឡាយ និងដើម្បីកាត់បន្ថយជម្លោះទាំងក្នុងការប្រើប្រាស់របស់មនុស្ស និងរវាងការប្រើប្រាស់របស់មនុស្សនិងធម្មជាតិ។ MSP ផ្តោតទៅលើសកម្មភាពប្រើប្រាស់របស់មនុស្សនៅកន្លែង និងទីតាំងលំហសមុទ្រ។ នេះគឺជាបំណែកបាត់បង់ដែលអាចនាំទៅរកការរៀបចំផែនការចម្រុះសម្រាប់តំបន់ទីជម្រាលឆ្នេរហួតដល់តំបន់អេកូស៊ីស្ទែមសមុទ្រ។




*តារាងស្ដីពីការអនុមត៌វិធានការគ្រប់គ្រប់ដើម្បីសម្រេចគោលដៅជាក់លាក់*

### *ផែនការបែងចែកការប្រើប្រាស់តំបន់សមុទ្រ*

- ✓ ការដឹកជញ្ជូនតាមសមុទ្រ
- ✓ ថាមពលកកើតឡើងវិញ
- ✓ ការការពារ ឬអភិរក្សតំបន់សមុទ្រ
- ✓ ការជីកថ្ម និងខ្សាច់
- ✓ ជលផល
- ✓ ជលវប្បកម្មសមុទ្រ
- ✓ ការរុករកប្រេង និងឧស្ម័ន
- ✓ សព្វាវុធយោធា

***ឯកសារសម្រាប់អានបន្ថែម:***

- *ការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែម: វិធានការជាជំហានៗឆ្ពោះទៅរកការរៀបចំផែនការបែងចែកការប្រើប្រាស់សមុទ្រ (http://unesdoc.unesco.org/images/0018/001865/186559e.pdf)*
- *ឯកសារធនធានថ្នាក់តំបន់ស្តីពីការបញ្ជ្រាបបញ្ហាដែលកំពុងកើតឡើងនិងវិធីសាស្ត្រគ្រប់គ្រងថ្មីៗសម្រាប់ការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរ និងសមុទ្រ*
- *ការរៀបចំផែនការបែងចែកការប្រើប្រាស់សមុទ្រ: ជំហានមួយឆ្ពោះទៅរកការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមនៅតំបន់ការីប៊ីន http://www.ots.ac.cr/tropiweb/attachments/suppls/sup58-3_ALMC34___/05_Ogden_Marine_Spatial_Planning.pdf*

## ឧបសម្ព័ន្ធទី១: តារាងសង្ខេបអំពីគោលនយោបាយ យុទ្ធសាស្ត្រ និងបទដ្ឋានគតិយុត្តទាក់ទងនឹងការប្រើប្រាស់និងគ្រប់គ្រងតំបន់ឆ្នេរសមុទ្រប្រទេសកម្ពុជា

### ១. ថ្នាក់តំបន់ និងអន្តរជាតិ

| ចំណងជើង | ខ្លឹមសារ | កាលបរិច្ឆេទ |
|---|---|---|
| អនុសញ្ញាបាសែល ស្តីពីការត្រួតពិនិត្យការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ឆ្លងដែន និងការបោះបង់ចោល | គោលដើម្បីកាត់បន្ថយការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ឆ្លងដែន ការកាត់បន្ថយការបង្កើតសំណល់ហាមឃាត់ដឹកជញ្ជូនសំណល់គ្រោះថ្នាក់ទៅប្រទេសដែលខ្វះសមត្ថភាពក្នុងការបោះចោលដោយមិនធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន | ២០០១ |
| អនុសញ្ញាស្តីពីតំបន់ដីសើម | តំបន់ដីសើមគឺជាទីវាលទំនាបលិចទឹក ទំនាបភក់ ទីប្រកបដោយរុក្ខជាតិរលួយ ឬ ទឹកដែលកើតឡើងដោយធម្មជាតិ ឬ សប្បនិម្មិត មានទឹកជាអចិន្ត្រៃយ៍ ឬ អនាចិន្ត្រៃយ៍ ដែលមានទឹកនឹង ឬហូរ ទឹកសាប ភ្លាវ ឬប្រៃ រួមទាំងតំបន់សមុទ្រដែលមានជំរៅទឹកមិនលើសពី ៦ម នៅពេលនាច ។ | ទី២២ ខែតុលា ១៩៩៦ |
| អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ | ដើម្បីអនុវត្តអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុតាមរយៈ ការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងស្ថាប័នជាតិ | ទី១៣ ខែធ្នូ ឆ្នាំ១៩៩៥ |
| អនុសញ្ញា ស្តីពីជីវៈចម្រុះនៅទីក្រុង Rio de Janeiro, ឆ្នាំ១៩៩២ | ដើម្បីអនុវត្តអនុសញ្ញាស្តីពីជីវៈចម្រុះតាមរយៈ ការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការនិងស្ថាប័នជាតិគ្រប់គ្រងជីវចម្រុះ | ១៩៩៣ |
| វិធីសារ**កាតាហ្គាណា** ស្តីពីជីវៈសុវត្ថិភាព | ដើម្បីអនុវត្តពិធីសារស្តីពីស្តីពីជីវៈសុវត្ថិភាពតាមរយៈការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ ស្ថាប័នជាតិ និងបទដ្ឋានគតិយុត្តិ | ទី១៦ ខែធ្នូ ឆ្នាំ២០០៣ |
| អនុសញ្ញាអន្តរជាតិ ស្តីពីនិតិសមុទ្រ (UNCLOS) | ដើម្បីឱ្យកម្ពុជាមានសិទ្ធិអធិបតេយ្យសមុទ្រដែនដីចម្ងាយ១២ម៉ៃល៍ និងតំបន់សេដ្ឋកិច្ចផ្តាច់មុខចម្ងាយ ២០០ម៉ៃល៍ | ទី១០ ខែធ្នូ ឆ្នាំ១៩៨២ |
| អនុសញ្ញាការពាររុក្ខជាតិអន្តរជាតិ(IPPC) | គោលបំណងដើម្បីធានានូវសកម្មភាពរួម និងមានប្រសិទ្ធភាពដើម្បីការពារការរីករាលដាល | ១៩៥២ |

| | | |
|---|---|---|
| | និងការប្រើប្រាស់ថ្នាំសំលាប់រុក្ខជាតិ និងផ្សព្វផ្សាយវិធានការដើម្បីត្រួតពិនិត្យ | |
| កិច្ចព្រមព្រៀងហៃគួចុះហត្ថលេខាដោយប្រទេសទាំង១១ នៅក្រោមអង្គការ PEMSEA | គោលបំណងដើម្បីរៀបចំនិងអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រប្រកបដោយនិរន្តរភាព SDS-SEA ដែលតម្រូវឱ្យប្រទេសជាសមាជិករៀបចំយុទ្ធសាស្ត្រជាតិនេះឡើង | ទី១៥ ធ្នូ ឆ្នាំ២០០៦ |
| សេចក្តីប្រកាសនៃកិច្ចសហការតំបន់**ពុត្រាចាយ៉ា** (Putrajaya) សម្រាប់ការអភិវឌ្ឍដោយចីរភាពនៃសមុទ្រ អាស៊ីបូព៌ា | ជាការតម្រង់ទិស និងជាវិធានដ៏មានសារៈសំខាន់ទាំងនៅកម្រិតជាតិតំបន់ និងពិភពលោក ដែលអាចឱ្យអាជ្ញាធរនិង អ្នកពាក់ព័ន្ធនានាចាត់វិធានការនិងដោះស្រាយបញ្ហាបរិស្ថាន និងធនធានធម្មជាតិនៅក្នុងមូលដ្ឋាន | ទី១២ ខែធ្នូ ឆ្នាំ ២០០៣ |
| ផែនការសហប្រតិបត្តិការ ASEAN ស្តីពីការបំពុលឆ្លងដែនមានប្រភពចេញពីកប៉ាល់និងការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ | គ្របដណ្តប់លើការបំពុលបរិយាកាសនិងប្រភពចេញពីកប៉ាល់និងការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ | ខែមិថុនា ឆ្នាំ១៩៩៥ |
| ចូលរួមជាសមាជិកភាពរបស់អង្គភាពសម្របសម្រួលតំបន់សមុទ្រអាស៊ីបូព៌ា (COBSEA) | ក្នុងមុខងារនេះ ប្រទេសកម្ពុជាមានឱកាសទទួល និងអនុវត្តគម្រោងអភិវឌ្ឍន៍តំបន់ឆ្នេរឈ្មោះថា *"ការស្តារឡើងវិញនូវដំណើរការខូចខាតបរិស្ថានសមុទ្រចិនភាគខាងត្បូង និងឈូងសមុទ្រថៃ"* ដែលមានគោលបំណងឆ្លុះបញ្ចាំងការដោះស្រាយបញ្ហាបរិស្ថានតំបន់ឆ្នេរ ៣ចំណុចសំខាន់ៗ គឺ:១-ការបាត់បង់ និងភាពសឹករេចរិលដែនជម្រកតំបន់ឆ្នេរ ២-ការធ្វើអាជីវកម្មនៃសាទត្រីហួសកំណត់ និង ៣-ការបំពុលពីដំបន់ដីគោក ជាងនេះទៅទៀតប្រទេសកម្ពុជានឹងទទួលបានជំនួយពីប្រភពនានាដើម្បីអនុវត្តគម្រោងការប្រើប្រាស់ និងគ្រប់គ្រងតំបន់ឆ្នេរសមុទ្រ | ១៩៩៤ |

## ២. ថ្នាក់ជាតិ

| ចំណងជើង | ខ្លឹមសារ | កាលបរិច្ឆេទ |
|---|---|---|
| | **ផ្នែកបរិស្ថាន** | |
| www.moe.gov.kh and www.camclimate.org.kh | | |
| ព្រះរាជក្រឹត្យ ស្តីពីការបង្កើតនិងកំណត់តំបន់ការពារចំនួន២៣ កន្លែងគ្របដណ្តប់លើផ្ទៃដីចំនួន ៣.៣ លានហិចតាស្មើនឹង ១៨.២៣ភាគរយនៃផ្ទៃដីសរុប | គោលបំណងនៃព្រះរាជក្រឹត្យនេះដើម្បីដោះស្រាយនូវដំណើរការគ្រប់គ្រងធនធានធម្មជាតិ ដោយស្របគ្នាទៅនឹងបញ្ជីឈ្មោះរបស់អង្គការសហប្រជាជាតិស្តីពី ឧទ្យានជាតិ និងតំបន់ការពារ ។ | ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ |
| ច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ | ច្បាប់នេះមានគោលដៅ:<br>- ការពារ លើកកំពស់គុណភាពបរិស្ថាន និង សុខភាពពលរដ្ឋដោយធ្វើការ ទប់ស្កាត់ការកាត់បន្ថយ និង ការត្រួតពិនិត្យការបំពុល<br>- វាយតំលៃហេតុប៉ះពាល់បរិស្ថានមុននឹងចេញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលចំពោះរាល់គំរោងដែលបានស្នើឡើង<br>- ធានាឱ្យមានការអភិរក្ស ការអភិវឌ្ឍ ការគ្រប់គ្រងនិងការប្រើប្រាស់ដោយសមហេតុផលនិងប្រកបដោយនិរន្តភាពនូវធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា<br>- លើកទឹកចិត្តនិងផ្តល់លទ្ធភាពឱ្យសាធារណជនចូលរួមក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ<br>- បង្រ្កាបអំពើទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន | ថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៦ |
| ច្បាប់ ស្តីពីតំបន់ការពារ | ច្បាប់នេះបង្កើតឡើងដើម្បី :<br>- គ្រប់គ្រង និងអនុវត្តឱ្យមានប្រសិទ្ធភាពក្នុងការអភិរក្សធនធានជីវៈចម្រុះនិងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាពក្នុងតំបន់ការពារ | ខែមករា ឆ្នាំ២០០៨ |

| | | |
|---|---|---|
| | - កំណត់អំណាច និងទំនួលខុសត្រូវរបស់រដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថាននៅក្នុងការគ្រប់គ្រងតំបន់ការពារ<br>- ការកំណត់ស្តង់ដា និងវិធីសាស្ត្រសំរាប់គ្រប់គ្រងតំបន់ការពារ<br>- ការកំណត់ទំនួលខុសត្រូវនិងការចូលរួមនៃសហគមន៍មូលដ្ឋាន និង<br>- អនុវត្តអនុសញ្ញា វិធីសារ និងកិច្ចព្រមព្រៀងថ្នាក់តំបន់ និងអន្តរជាតិ ស្តីពីកិច្ចការពារប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះ ។ | |
| ច្បាប់ ស្តីពីជីវៈសុវត្ថភាព | ច្បាប់នេះមានគោលបំណងដើម្បីៈ<br>- ទប់ស្កាត់ផលបះពាល់អវិជ្ជមានលើអភិរក្សជីវៈចម្រុះនិងធនធានធម្មជាតិក្នុងព្រះរាជាណាចក្រកម្ពុជាបណ្តាលមកពីការដឹកជញ្ជូនឆ្លងដែន ការលើកដាក់ ការផ្ទេរ ការរក្សាទុក និងបោះបង់ចោលសរីរាង្គកែច្នៃរស់បានមកពីបច្ចេកវិទ្យាជីវសាស្ត្រទំនើប<br>- ធានានូវប្រសិទ្ធភាពអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានជីវៈចម្រុះប្រកបដោយចិរភាពដោយគិតគូរពីហានិភ័យលើសុខភាពមនុស្ស<br>- ផ្តល់ដំណើរការប្រកបដោយតម្លាភាពមួយសម្រាប់បង្កើតនិងពិនិត្យមើលសេចក្តីសំរេចស្តីពី សរីរាង្គកែច្នៃរស់ សកម្មភាពនិងដំណើរការទាក់ទងគ្នា<br>- អភិវឌ្ឍការអប់រំជីវៈបច្ចេកទេសនៅពេលដែលធ្វើការទប់ស្កាត់ហានិភ័យសុខភាពនិងបរិស្ថានរួមជាមួយនឹងការប្រើប្រាស់ និងការបញ្ចេញសរីរាង្គកែច្នៃរស់ | ខែកុម្ភះ ឆ្នាំ២០០៨ |
| អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងប្រែប្រួលអាកាស | គោលបំណងដើម្បីរៀបចំ សម្របសម្រួល និងបង្ហាញនូវការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ ច្បាប់ ផែនការ និងកម្មវិធីរាជរដ្ឋាភិបាលដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុទាក់ទងនឹងបញ្ហាក្នុងប្រទេសដូច្នេះការចែករំលែកទៅនឹងកិច្ចការពារនៃបរិស្ថាន និងធនធានធម្មជាតិ និង ការមើលទុកមុននិងការទប់ស្កាត់ពីមនុស្សជាតិប្រែប្រួល | ទី២៤ ខែមេសា ឆ្នាំ២០០៦ |

| | | |
|---|---|---|
| | អាកាសធាតុដែលអាចប៉ះពាល់នឹងលើការប្រព្រឹត្តរបស់មនុស្ស | |
| អនុក្រឹត្យស្តីពីការគ្រប់គ្រងសារធាតុបំផ្លាញស្រទាប់អូហ្សូន | អនុក្រឹត្យនេះបង្កើតឡើងដើម្បីបញ្ឈប់ការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់ អូហ្សូននិងគ្រប់គ្រងរាល់សកម្មភាពជំនួញ និងការប្រើប្រាស់សារធាតុទាំងនេះដោយអនុលោមតាមអនុសញ្ញាវីយ៉េនណា និងពិធីសារម៉ុងរ៉េអាល់ | ទី២៩ ខែមីនា ឆ្នាំ២០០៥ |
| អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់និងរំខានដោយសំលេង | អនុក្រឹត្យនេះកំណត់ការត្រួតពិនិត្យការបំពុលខ្យល់ និង ការរំខានដោយសំលេងដើម្បីទប់ស្កាត់ និងកាត់បន្ថយសារធាតុដែលបំពុលខ្យល់និងសំលេងក្នុងបរិយាកាសសំដៅការពារគុណភាពបរិស្ថាន និងសុខភាពសាធារណៈ ។ | ទី៩ ខែមិថុនា ឆ្នាំ២០០០ |
| អនុក្រឹត្យ ស្តីពីការបំពុលទឹក | អនុក្រឹត្យនេះមានគោលដៅកំណត់ការត្រួតពិនិត្យការបំពុលទឹកដើម្បីទប់ស្កាត់ និង កាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈសំដៅធានាបានការការពារសុខភាពមនុស្ស និងការអភិរក្សជីវចម្រុះ ។ | ទី១២ ខែមិនា ឆ្នាំ១៩៩៩ |
| អនុក្រឹត្យ ស្តីពីការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន (EIA) | មានគោលបំណង :<br>- កំណត់ការវាយតំលៃហេតុប៉ះពាល់បរិស្ថានលើរាល់គំរោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈហើយត្រូវពិនិត្យ និងវាយតំលៃដោយក្រសួងបរិស្ថានមុនដាក់ជូនរាជរដ្ឋាភិបាលសំរេច<br>- កំណត់ប្រភេទ និងទំហំគម្រោង សកម្មភាពដែលស្នើឡើងព្រមទាំងសកម្មភាពដែលមានស្រាប់និងកំពុង ដំណើរការទាំងឯកជន ទាំងសាធារណៈ ដែលត្រូវវាយតំលៃហេតុប៉ះពាល់បរិស្ថាន<br>- បំផុសឱ្យមានការចូលរួមពីសាធារណៈជនក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថានព្រមទាំង ទទួលយកមតិយោបល់មកធ្វើការពិចារណា ក្នុងកិច្ចដំណើរការអនុម័តគម្រោង ។ | ទី២៣ ខែកញ្ញា ឆ្នាំ១៩៩៩ |
| អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំណល់រឹង | អនុក្រឹត្យនេះមានគោលដៅកំណត់ការគ្រប់គ្រងសំណល់រឹងប្រកបដោយលក្ខណៈបច្ចេក | ទី២ ខែមេសា ឆ្នាំ១៩៩៩ |

| | | |
|---|---|---|
| | ទេសសមស្របនិងប្រកបដោយសុវត្ថិភាពសំដៅធានាបាននូវការការពារសុខភាពសាធារណៈ គុណភាពបរិស្ថាន និងការអភិរក្សជីវៈចម្រុះ | |
| ផែនការយុទ្ធសាស្ត្រជាតិពីបរិស្ថាន (២០០១-២០០៣), (២០០៤-២០០៨), និង(២០០៩-២០១៣) | ផែនការយុទ្ធសាស្ត្រពីបរិស្ថានគឺចេញផ្សាយដោយក្រសួងបរិស្ថានក្នុងឆ្នាំនីមួយៗ ២០០១-២០០៤ និង២០០៩។ ផែនការយុទ្ធសាស្ត្រទាំងនេះត្រូវបានរៀបសារឡើងវិញនូវរាល់បទបញ្ញតិមានស្រាប់កំណត់បញ្ហាសំខាន់ និង ភាគីពាក់ព័ន្ធព្រមទាំងការរៀបរាប់លំអិតកម្មវិធីផ្សេងគ្នានៃសកម្មភាពពាក់ព័ន្ធគ្នាសំរាប់កំឡុងឆ្នាំ (២០០១-២០០៣), (២០០៤-២០០៨), (២០០៩-២០១៣) ដើម្បីធានាការអនុវត្ត និងគ្រប់គ្រងបរិស្ថានជាចីរភាពរាប់ការពារសុខភាព និងបរិស្ថានសង្គម | ២០០១/២០០៤ និង ២០០៩ |
| ផែនការសកម្មភាពជាតិពីបរិស្ថាន (១៩៩៨-២០០២), (២០០៣-២០០៨) និង (សេចក្តីព្រាងនៅ ឆ្នាំ២០១២-២០១៦) | ផែនការសកម្មភាពពីបរិស្ថានគឺជាឯកសារសំខាន់ក្នុងការកំណត់បញ្ហាសំខាន់ និងសកម្មភាពពាក់ព័ន្ធជិវិញ៦ ប្រភេទៈ ព្រៃឈើ, នេសាទ និងកសិកម្មតំបន់លិចទឹកក្នុងតំបន់ទន្លេសាប, ជលផលតំបន់ឆ្នេរ, តំបន់ការពារ និងជីវៈចំរុះ, ការអភិវឌ្ឍថាមពល និងគ្រប់គ្រងសំណល់ជាយក្រុង (នគរូបនីយកម្ម) | ១៩៩៨/២០០៣ និង ២០១២ |
| យុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចម្រុះជាតិ | យុទ្ធសាស្ត្រនិងផែនការសកម្មភាពជីវៈចម្រុះជាតិ（NBSAP）ត្រូវបានចេញផ្សាយអោយប្រើប្រាស់ដើម្បីពង្រឹង ការពារ និងគ្រប់គ្រងជីវៈចម្រុះជាតិដើម្បីធានាថាប្រទេសកំពុងរអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ខ្លួនដោយមិនព្រងើយកន្តើយនូវទស្សនៈការអភិវឌ្ឍប្រកបដោយចីរភាពនោះទេ។ | ២០០២ |
| ការវាយតំលៃលើសក្តានុពលភាពសំរាប់វិស័យអេកូទេសចរណ៍ក្នុងតំបន់ដែនជំរកសត្វព្រៃពាមក្រសោបខេត្តកោះកុង | គម្រោងគ្រប់គ្រងបរិស្ថានតំបន់ឆ្នេរប្រទេសកម្ពុជាមានគោលបំណងកែលំអជីវភាពរស់នៅរបស់ប្រជាជន ក្នុងតំបន់ឆ្នេរប្រទេសកម្ពុជាតាមរយៈការប្រើប្រាស់ និងការអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រដោយនិរន្តរភាព។ អ្នកទទួលផលប្រយោជន៍សំខាន់នៃគំរោងនេះគឺសហគមន៍ក្រីក្រក្នុងតំបន់ឆ្នេរសមុទ្ររដ្ឋាភិបាលមូលដ្ឋានដែលអនុវត្តការគ្រប់គ្រងបរិស្ថាន និងបុគ្គលិកសមភាគីនៅថ្នាក់ជាតិ។ ការកាត់បន្ថយភាពក្រីក្រនឹងសំរេចបានតាមរយៈការផ្តល់ជំរើស | ២០០៥ |

| | | |
|---|---|---|
| | ប្រកបរបរចិញ្ចឹមជីវិតថ្មីនៅថ្នាក់មូលដ្ឋាននិងការប្រើប្រាស់ធនធានតំបន់ឆ្នេរឱ្យបាន ត្រឹមត្រូវរបាយការណ៍នេះ គឺផ្អែកទៅលើការវិភាគព័ត៌មានមានស្រាប់ពីតំបន់ការពារដែន ជំរកសត្វព្រៃពាមក្រសោប ។ | |
| ក្របខ័ណ្ឌការងារសំរាប់អភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិនៅសហគមន៍គ្រប់គ្រងធនធានតំបន់ឆ្នេរ | គម្រោងគ្រប់គ្រងបរិស្ថានតំបន់ឆ្នេរប្រទេសកម្ពុជាមានគោលបំណងកែលំអជីវភាពរស់នៅ របស់ប្រជាជនក្នុងតំបន់ឆ្នេរប្រទេសកម្ពុជាតាមរយៈការប្រើប្រាស់ និងការអភិវឌ្ឍន៍តំបន់ ឆ្នេរសមុទ្រដោយនិរន្តរភាព ។ អ្នកទទួលផលប្រយោជន៍សំខាន់នៃគំរោងនេះគឺសហគមន៍ ក្រីក្រក្នុងតំបន់ឆ្នេរ រដ្ឋាភិបាលមូលដ្ឋានដែលអនុវត្តការគ្រប់គ្រងបរិស្ថាន និងបុគ្គលិក សមភាគីនៅថ្នាក់ជាតិ ។ ការកាត់បន្ថយភាពក្រីក្រនឹងសំរេចបានតាមរយៈការផ្តល់ជំរើស ប្រកបរបរចិញ្ចឹមជីវិតថ្មីនៅថ្នាក់មូលដ្ឋាននិងការប្រើប្រាស់ធនធានតំបន់ឆ្នេរឱ្យបាន ត្រឹមត្រូវ ។ | ធ្នូ ២០០៤ |
| យុទ្ធសាស្ត្រអភិវឌ្ឍន៍អេកូទេសចរណ៍នៅក្នុងក្រុងកែប | គម្រោងគ្រប់គ្រងបរិស្ថានតំបន់ឆ្នេរសមុទ្រកម្ពុជាមានគោលបំណងកែលំអរជីវភាពរស់នៅ របស់ប្រជាជនក្នុងតំបន់ឆ្នេរប្រទេសកម្ពុជាតាមរយៈការប្រើប្រាស់ និងការអភិវឌ្ឍន៍តំបន់ ឆ្នេរប្រកបដោយនិរន្តរភាព ។ អ្នកទទួលផលប្រយោជន៍សំខាន់នៃគំរោងនេះគឺសហគមន៍ ក្រីក្រក្នុងតំបន់ឆ្នេរ រដ្ឋាភិបាលមូលដ្ឋានដែលអនុវត្តការគ្រប់គ្រងបរិស្ថាន និងបុគ្គលិក សមភាពភាគីនៅថ្នាក់ជាតិ ។ ការកាត់បន្ថយភាពក្រីក្រនឹងសំរេចបានតាមរយៈការផ្តល់ ជំរើសប្រកបរបរចិញ្ចឹមជីវិតថ្មីនៅថ្នាក់មូលដ្ឋាន និងការប្រើប្រាស់ធនធានតំបន់ឆ្នេរឱ្យបាន ត្រឹមត្រូវ ។ របាយការណ៍នេះត្រូវបានរៀបចំឡើងដោយផ្អែកទៅលើការវិភាគព័ត៌មាន បច្ចុប្បន្នទាក់ទងនឹងទេសចរណ៍ក្នុងក្រុងកែប ។ | ២០០៦ |
| យុទ្ធសាស្ត្រគ្រប់គ្រងឆ្នេរសមុទ្រកម្ពុជា **(shoreline)** (២០០៦) http://www.czmcam.org/content/documents/Shoreline%20management%20EN.pdf | គោលបំណងនៃយុទ្ធសាស្ត្រគ្រប់គ្រងឆ្នេរសមុទ្រ (SMS) គឺដើម្បីលើកកម្ពស់ការយល់ដឹង ដល់ប្រជាជនកម្ពុជា មន្ត្រីគ្រប់ជាន់ថ្នាក់ និស្សិត សាស្ត្រាចារ្យ គ្រូបង្រៀន ភ្នាក់ងារជាតិ និងអន្តរជាតិលើបញ្ហាទាំងឡាយវិធានការច្បាប់ និង បទបញ្ញត្តិពាក់ព័ន្ធលើការគ្រប់គ្រង | ទី០៧ ខែមករា ឆ្នាំ២០០៦ |

| | | |
|---|---|---|
| | តំបន់ឆ្នេរនៅកម្ពុជានិងការផ្តល់អនុសាសន៍ក្នុងការគ្រប់គ្រងឆ្នេរសមុទ្រអោយបានល្អ ធានាចីរភាពនៃធនធានធម្មជាតិ និងបរិស្ថានតំបន់ឆ្នេរព្រះរាជាណាចក្រកម្ពុជា | |
| ពង្រាងផែនការអនុវត្តន៍យុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៃសមុទ្រអាស៊ីបូព៌ា (SDS-SEA) សម្រាប់ប្រទេសកម្ពុជាដើម្បីការពារបរិស្ថានតំបន់ឆ្នេរ (២០១២-២០១៦) | ផែនការយុទ្ធសាស្ត្រនេះមានបំណងដើម្បីអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាពលើការគ្រប់គ្រងបរិស្ថានដើម្បីលើកម្ពស់សុខភាពសាធារណៈ ការពារ ការហូរច្រោះ ធានាប្រសិទ្ធភាពគ្រប់គ្រងធនធាន ធម្មជាតិ ការពារគ្រោះមហន្តរាយ និងការប្រែប្រួលអាសកាសធាតុ ការកាត់បន្ថយ និងបំបាត់ចោលការបំពុលបរិស្ថានតំបន់ឆ្នេរសមុទ្រ | ខែតុលា ឆ្នាំ២០១២ |
| ផែនការសកម្មភាពគ្រប់គ្រងបរិស្ថានតំបន់ឆ្នេរ(២០០៧-២០១១) | ផែនការនេះរៀបចំឡើងដើម្បីបង្ហាញពីទស្សនៈនៃដំណើរការគ្រប់គ្រងចម្រុះតំបន់ឆ្នេរក្នុងការរៀបចំផែនការ និង សេចក្តីសំរេចរួមលើសកម្មភាពពហុវិន័យជាពិសេសក្នុងវិស័យព្រៃឈើ ជលផល សំណល់រឹង និងរាវព្រមទាំង ផែនការប្រើប្រាស់ដីតំបន់ឆ្នេរ | ២០០៧ |
| គណៈកម្មាធិការត្រួតពិនិត្យនិងវាយតម្លៃសម្រាប់បង្រ្កាបការរុករានដីទៅក្នុងតំបន់ព្រៃកោងកាងនិងការចាប់យកដីតំបន់ឆ្នេរ | រាជរដ្ឋាភិបាលកម្ពុជាជាមួយនឹងសេចក្តីសម្រេចលេខ ២៨ ស.ស.រ\២០០៥ បានបង្កើតគណៈកម្មាធិការស្តីពី ***ការត្រួតពិនិត្យ និងវាយតម្លៃក្នុងការបង្រ្កាបរុករានដីទៅក្នុងតំបន់ព្រៃកោងកាង និងការចាប់យកដីតំបន់ឆ្នេរ*** ដើម្បីបញ្ឈប់ការរុករាន ស្តារឡើងវិញនូវដីដែលបានរុករាន និងចាប់យក និងបញ្ចាឱ្យដាំព្រៃឡើងវិញនៅតំបន់ព្រៃកោងកាងដែលបាត់បង់រឺត្រូវបានបំផ្លាញ | ២០០៥ |
| **ដែនដី នគរូបនីយកម្ម និងសំណង់** | | |
| www.mlmupc.gov.kh | | |
| ច្បាប់ភូមិបាល | ដីធ្លីនៃរដ្ឋកម្ពុជា ជាសម្បត្តិរបស់រដ្ឋ ហើយត្រូវបានរដ្ឋគ្រប់គ្រងដោយឯកភាព ទូទាំងប្រទេស ។ រដ្ឋមិនទទួលស្គាល់ដាច់ខាតរបបកម្មសិទ្ធិចាស់លើដីធ្លីមុនឆ្នាំ១៩៧៩។ កម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀតលើដីធ្លីត្រូវស្ថិតនៅក្រោមអំណាចនៃច្បាប់នេះ។ ច្បាប់នេះមានគោលបំណងដើម្បីកំណត់នូវម្ចាស់កម្មសិទ្ធិអចលនវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីធានា | ទី៦ ខែកុម្ភៈ ឆ្នាំ២០០២ |

| | | |
|---|---|---|
| | នូវសិទ្ធិកាន់កាប់និងភាពជាម្ចាស់នៃអចលនវត្ថុទាំងនោះដោយអនុលោមតាមរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ | |
| ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ | ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់មានកម្មវត្ថុជំរុញអោយមានការរៀបចំកែលំអទីក្រុងនិងតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធានាកិច្ចអភិវឌ្ឍន៍សុខដុមនៃប្រទេស ក្នុងស្មារតីៈ - គោរពប្រយោជន៍ និង ប្រយោជន៍បុគ្គលផងគោរពសិទ្ធិឯកជនផងគោរពបទបញ្ញត្តិច្បាប់ផងនិងត្រួតពិនិត្យការសាងសង់ផង។ ធានាការអភិវឌ្ឍន៍សំដៅរកលំនឹងរវាងទីក្រុងនិងតំបន់ជនបទ ផ្អែកទៅលើភូមិសាស្ត្រនិងលក្ខណះពិសេសនៃជនបទនីមួយៗ។ ធានាលើតំលៃសម្បត្តិធម្មជាតិ សម្បត្តិវប្បធម៌ និងធានាការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចវិស័យទេសចរណ៍ និងរក្សាបាននូវគុណភាពបរិស្ថាន ។ | ទី២៤ ខែឧសភា ឆ្នាំ១៩៩៤ |
| អនុក្រឹត្យស្តីពីការរៀបចំ និង តួនាទីនៃគណៈកម្មាធិការសុរិយោដីសម្រាប់ដំណោះស្រាយទំនាស់ដីធ្លីក្រៅប្រព័ន្ធតុលាការ | គោលបំណងដើម្បីជួយសម្រួលក្នុងការដោះស្រាយទំនាស់ដីធ្លីក្រៅប្រព័ន្ធតុលាការ | ទី៣១ ខែឧសភា ឆ្នាំ២០០២ |
| អនុក្រឹត្យលេខ១១៨អនក្រ.បកស្តីពី “ ការគ្រប់គ្រងដីរដ្ឋ” នៅក្នុងអនុក្រឹត្យនេះកបានចែងផង ដែរអំពីការកំណត់ប្រភេទដីរដ្ឋ | អនុក្រឹត្យនេះមានគោលដៅកំណត់គោលការណ៍ នីតិវិធីនិងការរៀបចំផ្នែកស្ថាប័នសម្រាប់ការគ្រប់គ្រងដីរដ្ឋ លើៈ ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ ការចុះបញ្ជី និងការធ្វើចំណាត់ ថ្នាក់ដីរដ្ឋ ការបង្កើត និងការថែរក្សាប្រព័ន្ធ ទិន្នន័យដីរដ្ឋ ការបែងចែកនិការគ្រប់គ្រងដីរដ្ឋ និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ | ទី៧ ខែតុលា ឆ្នាំ២០០៥ |
| គណៈកម្មាធិការជាតិ សំរាប់គ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ (១៩៩៧) | គណៈកម្មាធិការនេះមានតួនាទី និងភារៈកិច្ចដើម្បីរៀបចំផែនការប្រើប្រាស់ដីធ្លី ការចូលរួម នគរូបណីយកម្ម កិច្ចការពារបេតិកភ័ណ្ឌ បរិស្ថាន ការអភិវឌ្ឍសេដ្ឋកិច្ច និងធនធានធម្មជាតិ ត្រួតពិនិត្យការងារសាងសង់ និងដាក់ទីតាំងរោងចក្រ លើសក៏វិតកិច្ចការប្រឡាប់បញ្ឈប់ការងារ និងរឹបអូសឧបករណ៏សាងសង់ពាក់ព័ន្ធជាមួយក៏វិតប្រព្រឹត្តល្មើស | ១៩៩៧ |
| សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលស្តីពីគោលនយោបាយដីធ្លី | **ចក្ខុវិស័យ**នៃគោលនយោបាយដីធ្លីនៅកម្ពុជាគឺគ្រប់គ្រងរៀបចំប្រើប្រាស់និងបែងចែកដី | |

| | | |
|---|---|---|
| | ប្រកបដោយសមធម៌ តម្លាភាពប្រសិទ្ធភាពនិងចីរភាពដើម្បីរួមចំណែកធ្វើឱ្យសម្រេច គោលដៅជាតិនៃការកាត់បន្ថយភាពក្រីក្រ ការធានាសន្តិសុខស្បៀងការការពារបរិស្ថាន និងធនធានធម្មជាតិកិច្ចការពារជាតិនិងអភិវឌ្ឍសេដ្ឋកិច្ចសង្គមក្នុងបរិបទសេដ្ឋកិច្ចទីផ្សារ ។ អនុវិស័យដីធ្លីមានពាគឺ: **អនុវិស័យរដ្ឋបាលដីធ្លី អនុវិស័យរៀបចំដែនដីនិង អនុវិស័យរដ្ឋបាលដីធ្លី។** | |
| គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា | ចក្ខុវិស័យនៃគោលនយោបាយជាតិរៀបចំដែនដីសំដៅធានាថាការគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍតាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដី និង ការធ្វើឱ្យរលូននូវវិធាន និងឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្ត្រនីមួយៗ | |
| យុទ្ធសាស្ត្រអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ | យុទ្ធសាស្ត្រនិងផែនការសកម្មភាពដើម្បីផ្តល់នូវបណ្តាញផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធដែលទាក់ទងនឹងខេត្តនីមួយៗ គឺមានរៀបរាប់ដូចខាងក្រោម:<br>- ការកែលម្អនូវលក្ខខណ្ឌផ្ទៃកំរាលផ្លូវនៅផ្លូវជាតិលេខ ៤៨ និងមធ្យោបាយឆ្លងកាត់ព្រំដែននៅព្រំដែនរបស់ប្រទេសថៃ<br>- ការផ្តល់ជូនទាំងផ្លូវឧស្សាហកម្ម និងផ្លូវទេសចរណ៍ និងការកែលម្អផ្លូវជាតិលេខ ៤ និងផ្លូវ ជាតិលេខ៣ | |
| យុទ្ធសាស្ត្រអភិវឌ្ឍន៍ផែនការរៀបចំដែនដី | ដំណើរការនគរូបនីយកម្មត្រូវបានកើតឡើងដោយសារអ្នកចំណាកស្រុកពីជនបទមកទីក្រុង ហើយការចំណាកស្រុកនេះកើតឡើងដោយសារមានសម្ពាធសង្គម២យ៉ាងគឺឥទ្ធិពលរុញច្រាននិង ឥទ្ធិពលអូសទាញ។ ពេលដែលទីក្រុងអាចផ្តល់កាលានុវត្តភាព ការងារបានច្រើនទៅតាម តម្រូវការអ្នកចំណាកស្រុកបញ្ហាសង្គមនឹងត្រូវបានកាត់បន្ថយ ។ ដូច្នេះការគ្រប់គ្រងកំណើននគរូបនីយកម្មដែលប្រកបដោយប្រសិទ្ធភាពគួរតែត្រូវបានបង្កើតឡើងដោយមាន ការប្រុងប្រយ័ត្នដើម្បីពិនិត្យមើលលើសមត្ថភាពផ្ទុករបស់តំបន់ទីក្រុងនិងជនបទ | |

| | | |
|---|---|---|
| របាយការចុងក្រោយ( សៀវភៅទី១និង២) យុទ្ធសាស្ត្រជាតិសមាហរណកម្មតំបន់ឆ្នេរនិងប្លង់គោលក្រុងព្រះសីហនុ និង យុទ្ធសាស្ត្រអភិវឌ្ឍខេត្តកំពតសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព | តំបន់ឆ្នេរសមុទ្រគឺជាប៉ូលសេដ្ឋកិច្ចដ៏សំខាន់មួយក្នុងចំណោមប៉ូលសេដ្ឋកិច្ចសំខាន់ៗទាំង៣របស់កម្ពុជា និង ជាមុខព្រួញដ៏សំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមតាមរយៈវិស័យទេសចរដឹកជញ្ជូនឧស្សាហកម្ម ពាណិជ្ជកម្ម និងសេវាកម្ម។ ចំណុចសំខាន់របស់ឆ្នេរសមុទ្រកម្ពុជាគឺជាអ័ក្សអភិវឌ្ឍដ៏សំខាន់របស់កម្ពុជា និងអាស៊ានដែលក្នុងនោះអ័ក្សនៃតំបន់ឆ្នេរតភ្ជាប់ពីខេត្ត កោះកុង មកខេត្តព្រះសីហនុខេត្តកំពតនិងខេត្តកែបឆ្ពោះទៅប្រទេសថៃ និងវៀតណាមព្រមជាមួយផ្លូវអាស៊ានហាយវ៉េលេខ១២៣និងភ្ជាប់មករាជធានីភ្នំពេញតាមរយៈអ័ក្សអភិវឌ្ឍភ្នំពេញ-ព្រះសីហនុជាមួយផ្លូវអាស៊ានហាយវេលេខ១១និង តភ្ជាប់ទៅអន្តរជាតិ តាមផ្លូវទឹកសមុទ្រជ្រៅបំផុតរបស់កម្ពុជា | |
| សារាចរណែនាំលេខ០១សរណនស្តីពី ការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា | ដើម្បីគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរឱ្យត្រឹមត្រូវមានប្រសិទ្ធភាពនិងមានចីរភាពរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវសារាចរស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជានេះឡើងដើម្បីណែនាំដល់ក្រសួងស្ថាប័នពាក់ព័ន្ធនិងរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យអនុវត្តនូវគោលការណ៍គ្រប់គ្រងប្រើប្រាស់ ថែរក្សាការពារ និងអភិវឌ្ឍតំបន់ឆ្នេរកម្ពុជាដែលរួមមានដែនគោកកោះ និងដែនទឹកដោយមានផែនការគ្រប់គ្រង និង អភិវឌ្ឍន៍តំបន់ឆ្នេរឱ្យបានត្រឹមត្រូវមានប្រសិទ្ធិភាពនិងចីរភាពដើម្បីចៀសវាង និង ទប់ស្កាត់ផលប៉ះពាល់ដល់ការអភិវឌ្ឍទេសចរណ៍សេដ្ឋកិច្ច-សង្គមបរិស្ថានវប្បធម៌និងប្រពៃណីក្នុងតំបន់ឆ្នេរសមុទ្រដែលចាំបាច់សម្រាប់អាជ្ញាធរដែលមានសមត្ថកិច្ចពាក់ព័ន្ធនឹងតំបន់ឆ្នេរសមុទ្រត្រូវរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី និងផែនការអភិវឌ្ឍតំបន់ឆ្នេរសមុទ្ររាល់ទីតាំងដែលពុំទាន់មានប្លង់គោលនិងផែនការប្រើប្រាស់ដី | ទី០៣ ខែកុម្ភះ ឆ្នាំ២០១២ |
| ព្រះរាជក្រឹត្យនស.រកត.០៤១២.២៨១ស្តីពី "ការតែងតាំងសមាសភាពអគ្គលេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា | ដើម្បីធានាដល់ដំណើរការការងារគ្រប់គ្រងនិងអភិវឌ្ឍអនុវត្តទៅបានដោយរលូនសមាសភាពជាក់ស្តែងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិគ្រប់គ្រង និង អភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជាត្រូវបានបង្កើតឡើង។ អគ្គលេខាធិការដ្ឋាននៃ**គអឆក**មានសមាស | ទី០៦ ខែមេសា ឆ្នាំ២០១២ |

| | | |
|---|---|---|
| | ភាពចម្រុះ ចំនួន០៩រូបមកពីស្ថាប័នពាក់ព័ន្ធ | |
| ព្រះរាជក្រឹត្យនស.រកត.០២១២.០៧៩ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ( គអឆក) | **គអឆក**ត្រូវបានបង្កើតឡើងដើម្បីធ្វើជាសេនាធិការផ្ទាល់របស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ឆ្នេរ សមុទ្រកម្ពុជាប្រកបដោយនិរន្តរភាពនិងការទទួលខុសត្រូវខ្ពស់ដែលមានវិសាលភាពអនុវត្តការងាររបស់ខ្លួនលើឆ្នេរសមុទ្រ ដីចំណីឆ្នេរសមុទ្រ តំបន់រណបកោះដៃសមុទ្រស្ទឹងព្រែកផ្លូវទឹកដែលតភ្ជាប់ទៅនឹងសមុទ្រ និង ផ្ទៃទឹកដែលជាប់នឹងឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជាដែលមានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ | ទី០៦ ខែកុម្ភៈ ឆ្នាំ២០១២ |
| សេចក្តីណែនាំលេខ០១៧សណនកគដស្តីពីការអនុវត្តបទបញ្ជាលេខ០១បប របស់ រាជរដ្ឋាភិបាលស្តីពី ការពង្រឹងនិងការបង្កើនប្រសិទ្ធិភាពនៃការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ចពាក់ព័ន្ធនឹងផ្លូវថ្នល់ផ្លូវដែក ផ្លូវលំ បឹង ទន្លេ ឆ្នេរនិងទីតាំងសាធារណៈ | ដើម្បីធានាបាននូវបទដ្ឋាន រៀបចំដែនដីនិងនគរូបនីយកម្ម និងរក្សានូវហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តសង្គមនិងបរិស្ថានក្នុងការធ្វើអត្តសញ្ញាណកម្ម និងចុះវាស់វែងដីជូនប្រជាពលរដ្ឋដីផ្លូវ សាធារណៈ ព្រៃសហគមន៍ ដីសហគមន៍ បឹងឆ្នេរសមុទ្រច្រាំងទន្លេប្រឡាយ និងផ្លូវទឹកនានាដូចជាព្រែកអូរស្ទឹងជាដីសាធារណៈរបស់រដ្ឋដោយយកកំណត់ព្រំប្រទល់តាមការអនុវត្តកន្លងមកត្រូវរក្សាទុកជាដីសាធារណៈរបស់រដ្ឋ | ទី០៧ ខែឧសភា ឆ្នាំ២០១២ |
| បទបញ្ជាលេខ០១បបរបស់រាជរដ្ឋាភិបាលស្តីពីការពង្រឹងនិងការបង្កើនប្រសិទ្ធភាព នៃការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច | ក្នុងគោលដៅធានាដល់ការប្រើប្រាស់ដីក្នុងគោលដៅសម្បទានដីសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាព និងចីរភាពដែលធានាដល់សមធម៌ ដោយពង្រឹងនិងបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងការផ្តល់ជូននូវសម្បទានដីសេដ្ឋកិច្ច រាជរដ្ឋាភិបាលបានដាក់ចេញនូវបទបញ្ជាឱ្យក្រសួងស្ថាប័ននិងអាជ្ញាធរពាក់ព័ន្ធ | ទី០៧ ខែឧសភា ឆ្នាំ២០១២ |
| **វិស័យកសិកម្ម** | | |
| ច្បាប់ ស្តីពីព្រៃឈើ http://www.forestry.gov.kh/Documents/Forestry%20Law_Eng.pdf | ច្បាប់នេះមានគោលបំណងដើម្បីធានាការគ្រប់គ្រងធនធានព្រៃឈើទាំងនេះប្រកបដោយនិរន្តរភាពដើម្បីផលប្រយោជន៍បរិស្ថាន សេដ្ឋកិច្ច និងសង្គម ដោយរួមទាំងការអភិរក្សជីវចម្រុះ និងកេរ្តិ៍ដំណែលវប្បធម៌ | ទី៣០ ខែកក្កដា ឆ្នាំ២០០២ |
| ច្បាប់ ស្តីពីជលផល | ច្បាប់នេះមានគោលបំណងដើម្បីបង្កើតនូវក្របខណ្ឌមួយសម្រាប់ការគ្រប់គ្រង ការពារ | ២០០៦ |

| | | |
|---|---|---|
| | អភិរក្ស ប្រើប្រាស់ ធ្វើអាជីវកម្ម ការស្តារព្រៃលិចទឹក និងការអភិវឌ្ឍវិស័យជលផល ដើម្បីធានានូវនិរន្តរភាពធនធានជលផលដើម្បីបម្រើឱ្យផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថានដោយយោងតាមគោលនយោបាយជលផលជាតិ | |
| ក្របខណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងជលផល (២០១០-២០១៩) | ក្របខណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលត្រូវបានរៀបចំដើម្បីដាក់ចេញនូវចក្ខុវិស័យរដ្ឋាភិបាលលើអនាគតនៃការគ្រប់គ្រងវិស័យជលផលនិងរៀបរាប់នូវទិសដៅដែលគួរតែសម្រេចបានដើម្បីធានាកំណើនត្រីនៅក្នុងដែនទឹកប្រទេសកម្ពុជាទាំងទឹកប្រៃ និងទឹកសាប និងប្រព័ន្ធអេកូឡូស៊ីទាំងមូល។ យុទ្ធសាស្ត្រនេះមានគោលបំណងផងដែរ ក្នុងការគាំទ្រការសំរេចឱ្យបាននូវគោលដៅអភិវឌ្ឍ សហស្សវត្សកម្ពុជា ផែនការយុទ្ធសាស្ត្រជាតិ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងការគោរពតាមច្បាប់ជលផល | ២០១០ |
| **វិស័យសាធារណការ និងដឹកជញ្ជូន** | | |
| www.mpwt.gov.kh | | |
| ច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោកប្រទេសកម្ពុជា | គោលបំណងដើម្បី:<br>-រក្សាសណ្តាប់ធ្នាប់សុវត្ថិភាពក្នុងការធ្វើចរាចរណ៍នៅលើផ្លូវថ្នល់ដែលបើកឱ្យធ្វើចរាចរណ៍ជាសាធារណៈទូទាំង ព្រះរាជាណាចក្រកម្ពុជា<br>-ការពារអាយុជីវិតមនុស្ស សត្វ និងការពារបរិស្ថាន<br>-ទប់ស្កាត់ការប៉ះពាល់សុខភាពមនុស្ស និងការខូចខាត ទ្រព្យសម្បត្តិរដ្ឋ និង ឯកជន<br>-ទប់ស្កាត់ការប្រព្រឹត្តបទល្មើសដែលបណ្តាលមកពីការប្រើប្រាស់ផ្លូវថ្នល់។ | ទី២០ ខែធ្នូ ឆ្នាំ២០០៦ |
| គោលការណ៍ណែនាំ និងគោនយោបាយជាតិ ស្តីពីការប្រើប្រាស់សសារធាតុសំអាតប្រេងកំពប់នៅកម្ពុជា | ប្រទេសកម្ពុជាបង្កើតគោលនយោបាយ និងគោលការណ៍ណែនាំជាតិស្តីពីការប្រើប្រាស់សារធាតុសំអាតប្រេងកំពប់ដើម្បីផ្តល់នូវការគាំទ្រផ្នែកបច្ចេកទេសអនុវត្ត ផែនការយថាភាពក្នុងការឆ្លើយតបទៅនឹងប្រេងកំពប់។ ម្យ៉ាងទៀត គោលការណ៍ណែនាំនេះគឺរៀបចំឡើងដើម្បីសម្រួល និងណែនាំការសំរេចចិត្តភ្លាមៗលើការប្រើប្រាស់សារធាតុសំអាតប្រេង | ២០០៨ |

| | | |
|---|---|---|
| | កំពប់នៅពេលមានឧបទ្ទវត្តហេតុកំពប់ប្រេងកើតមានឡើង | |
| គណៈកម្មាធិការជាតិគ្រប់គ្រងសន្តិសុខលំហរសមុទ្រ | គោលបំណងជួយរដ្ឋាភិបាលដឹកនាំ និង អនុវត្តនូវកិច្ចការពារដែនដីរបស់ប្រទេសកម្ពុជា និងប្រទេសជិតខាងកុំឱ្យមានការគំរាមកំហែងដែលអាចកើតឡើង និងកេងផលចំណេញពីវិស័យសមុទ្រ, គណៈកម្មាធិការនេះនឹងជួយរដ្ឋាភិបាលក្នុងការដឹកនាំ គ្រប់គ្រងនិងសម្របសម្រួលការអនុវត្តច្បាប់ដើម្បីការពារ និងទប់ស្កាត់ប្រកបដោយប្រសិទ្ធភាពនូវរាល់ការគំរាមកំហែង ព្រមទាំងធានានូវសុវត្ថភាព និង សន្តិសុខការអភិវឌ្ឍសេដ្ឋកិច្ច និងកិច្ចសហការជាមួយប្រទេសជិតខាងទាំងកិច្ចព្រមព្រៀងទ្វេភាគីនិងពហុភាគី ។ គណៈកម្មាធិការនេះទទួលខុសត្រូវផងដែរក្នុងការរៀបចំ និងបង្កើត ***គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពរយៈ ពេលវែង មធ្យម និងខ្លី*** ដើម្បី ពង្រឹងសន្តិសុខ និងសុវត្ថភាពជាតិនៅលំហសមុទ្រព្រមទាំងជាមួយប្រទេសជិតខាង | ទី២៣ ខែធ្នូ ឆ្នាំ២០០៩ |
| គណៈកម្មាធិការសម្របសម្រួលកងនាវាចរណ៍ **(NCC)** | គោលបំណងសំខាន់នៃគណៈកម្មាធិការនេះគឺដើម្បីអនុវត្តផែនការមេសម្រាប់ការដឹកជញ្ជូនតាមទឹកនៅប្រព័ន្ធដងទន្លេមេគង្គនៅកម្ពុជា, រៀបចំនិងសម្របសម្រួលសកម្មភាពដែលបានលើកឡើងនៅក្នុងផែនការមេស្តីពីការរៀបចំរចនាសម្ព័ន្ធ ស្ថាប័នឡើងវិញ ការធ្វើវិសោធន៍កម្មច្បាប់ សុវត្ថភាព សន្តិសុខ អភិវឌ្ឍកំពុងផែ និងរៀបចំតំបន់ទន្លេ ការកសាងសមត្ថភាពផ្នែកបរិស្ថាន,ដើម្បីរៀបចំគោលនយោបាយជាតិស្តីពីការប្រើប្រាស់ប្រភេទនៃការដឹកជញ្ជូន, និងជម្រុញគោការណ៍ពហុប្រភេទព្រមទាំងដើរតួជាអ្នកសម្របសម្រួលរវាងវិស័យឯកជនសមាគមន៍អ្នកជំនាញការ ភ្នាក់ងារផ្តល់ជំនួយក្រសួងសាធារណៈការ និងដឹកជញ្ជូន និងអាជ្ញាធរ និងក្រសួងពាក់ព័ន្ធឯទៀត។ | មេសា ២០០៧ |
| **គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ** | | |
| www.ncdm.gov.kh | | |
| គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) | បង្កើតនៅឆ្នាំ១៩៩៥ ដឹកនាំដោយនាយករដ្ឋមន្ត្រីដែលមានក្រសួងនិងភ្នាក់ងារចំនួន ២២ | ១៩៩៥ |

| | | |
|---|---|---|
| | ហើយដើរតួជាភ្នាក់ងារសម្របសម្រួលដោយអនុក្រឹត្យលេខ ៣៥ អនក្រ-បកហត្ថលេខា យល់ព្រមដោយនាយករដ្ឋមន្ត្រី។ បន្ទាប់ពីបានបង្កើត NCDM មានគោលនយោបាយ និងយុទ្ធសាស្ត្រគ្រប់គ្រងគ្រោះមហន្តរាយជាតិជាច្រើនត្រូវបានបង្កើតផងដែរ ហើយប្រទេសកម្ពុជាថ្មីៗនេះ ស្ថិតក្នុងដំណាក់កាលអនុវត្តនៃច្បាប់គ្រប់គ្រងគ្រោះមហន្តរាយ | |
| ផែនការយុទ្ធសាស្ត្រជាតិគ្រប់គ្រងគ្រោះមហន្តរាយ ២០០៨-២០១៣ (SNAP-DRR) http://unisdr-apps.net/confluence/display/bib/Strategic+National+Action+Plan+(SNAP)+for+Disaster+Risk+Reduction | ផែនការយុទ្ធសាស្ត្រជាតិគ្រប់គ្រងគ្រោះមហន្តរាយបានកំណត់នូវធាតុសំខាន់ចំនួន៦ ក្នុងការអនុវត្តតាមគ្រោងការសកម្មភាព ***ហាយូហ្គោ*** (HFA) រួមមាន (១)-ធានាថា DRR គឺជាចំណុចអាទិភាពថ្នាក់តំបន់និងជាតិ (២)-ពង្រឹងសហគមន៍និងថ្នាក់ក្រោមជាតិដោយផ្អែកលើការគ្រប់គ្រងហានិភ័យគ្រោះថ្នាក់ (៣)-កំណត់លើការវាយតំលៃ និងត្រួតពិនិត្យហានិភ័យគ្រោះថ្នាក់ និងលើកកម្ពស់ប្រព័ន្ធផ្សព្វផ្សាយពីភាពអាសន្ន (៤)-ប្រើនូវចំណេះ និងការអប់រំដើម្បីធានានូវសុវត្ថភាព និងភាពប្រសើរឡើងវិញ (៥)-បញ្ជ្រាប DRR ទៅក្នុងកម្មវិធី និងគោលនយោបាយនៃក្រសួងពាក់ព័ន្ធនិង(៦)- ពង្រឹងការទប់ស្កាត់គ្រោះហានិភ័យប្រកបដោយប្រសិទ្ធភាព។ | ២០០៨ |

## ជំពូកទី៥: ឯកសារបណ្តុះបណ្តាលថ្នាក់ជាតិ

### ១. សេចក្តីផ្តើម

ការធ្វើផែនការប្រើប្រាស់ដីតំបន់ឆ្នេរសមុទ្របានក្លាយទៅជាចំណុចគួរឱ្យចាប់អារម្មណ៍ខ្លាំងនៅក្នុងពិភពលោក ជាពិសេសនៅតាមតំបន់សមុទ្រដែលបានប្រើប្រាស់ខ្លាំងចាប់តាំងពីឆ្នាំ ២០០៦ នៅពេលដែលអង្គការ អង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំសហប្រជាជាតិ (*UNESCO*) បានរៀបចំសិក្ខាសាលាអន្តរជាតិស្តីអំពី ***ការធ្វើផែនការប្រើប្រាស់តំបន់សមុទ្រ*** (Marine Spatial Planning)។ ការធ្វើផែនការប្រើប្រាស់ដីតាមតំបន់សមុទ្របានរៀបចំនូវក្របខណ្ឌប្រតិបត្តិសំរាប់បណ្តាប្រទេសនានាដើម្បីរក្សាតម្លៃនៃជីវៈចម្រុះតំបន់សមុទ្រហើយក៏អនុញ្ញាតិឱ្យមានការប្រើប្រាស់ដោយនិរន្តភាពនូវសក្តានុពលសេដ្ឋកិច្ចនៃមហាសមុទ្រផងដែរ។

ដោយស្វែងយល់ដឹងពីតម្រូវការជាបន្ទាន់ការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរសមុទ្រត្រូវបានចាប់ផ្តើមអនុវត្តយ៉ាងទូលំទូលាយនៅតំបន់សមុទ្រអាស៊ីបូព៌ា (EAS)។ ទោះជាយ៉ាងណាក៏ដោយ ដូចបណ្តាប្រទេសនានាដែរ ប្រទេសកម្ពុជាបានកំណត់នូវចំណុចខ្វះខាត និងឧបសគ្គមួយចំនួននៅក្នុងដែន និង ការអនុវត្តរបស់កម្មវិធីខ្លួន។ ជាពិសេស វាមានសារៈសំខាន់ណាស់នៅពេលដែលមានការកើនឡើងនូវការគម្រាមកំហែងដែលបង្ករឡើងដោយសារមនុស្សនិង ធម្មជាតិនូវតំបន់ឆ្នេរ និង សេចក្តីរំពឹងទុកដែលចេះតែកើនឡើងសំរាប់អាជ្ញាធរដែលមានមុខងារ និងតួនាទីបញ្ជ្រាបវិធីសាស្ត្រគ្រប់គ្រងផ្អែកលើប្រពន្ធ័អេកូស៊ី-ស្ទែមទៅក្នុងប្រពន្ធ័ផែនការ និង ធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតឡើងមួយចំនួន ដូចជា ***ការកាត់បន្ថយ និង ការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ និង ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ***។

ឆ្នេរសមុទ្រប្រទេសកម្ពុជាលាតសន្ធឹងប្រវែង ៤៣៥គីឡូម៉ែត្រ តាមបណ្តោយឈូងសមុទ្រថៃ។ ព្រំប្រទល់ដែនសមុទ្រត្រូវបានកំណត់រហូតដល់តំបន់សេដ្ឋកិច្ចផ្តាច់មុខដែលមានផ្ទៃក្រឡាទំហំ ៥៥,៦០០គីឡូម៉ែត្រការ៉េ។ តំបន់ឆ្នេរស្ថិតនៅតាមបណ្តោយខេត្ត**កោះកុង កំពត ព្រះសីហនុ និងកែប**។ នាពេលថ្មីៗនេះ តំបន់ឆ្នេររបស់ប្រទេសកម្ពុជាកំពុងជួបប្រទះនូវបញ្ហាមួយចំនួន ដូចជាការកាប់បំផ្លាញព្រៃកោងកាង ការបំផ្លាញផ្កាថ្ម/ស្មៅសមុទ្រ ការសឹករេចរិលតំបន់ឆ្នេរ ការប្រែប្រួលអាកាសធាតុ ការកើនឡើងកម្ពស់ទឹកសមុទ្រ និងបញ្ហាមួយចំនួនទៀត។ វាមិនមែនជារឿងដែលគួរឱ្យភ្ញាក់ផ្អើលនោះទេដែលថាតម្រូវការប្រើប្រាស់របស់សង្គម និង ឱកាសថ្មីៗសំរាប់ការប្រើប្រាស់ធនធានតំបន់ឆ្នេរសមុទ្រគឺជាប្រភពនៃជម្លោះដែលចេះតែរីករាលដាលឡើងៗនោះ។

ដើម្បីបង្កើននូវចំណេះដឹង ជំនាញ អាកប្បកិរិយា និង សមត្ថភាពដែលត្រូវការជាចាំបាច់កម្មវិធីបណ្តុះបណ្តាលស្តីពី " ***ការធ្វើផែនការប្រើប្រាស់ដីនៅតាម តំបន់ឆ្នេរសមុទ្រកម្ពុជា*** " បានរៀបចំឡើងដែលធ្វើឱ្យរាជរដ្ឋាភិបាល និង អ្នកពាក់ពន្ធ័នានាបញ្ជ្រាបនូវបញ្ហាដែលកើតឡើង និងវិធីសាស្ត្រគ្រប់គ្រងថ្មីៗទៅក្នុងការអនុវត្តជាក់ស្តែង និងប្រពន្ធ័ផែនការប្រើប្រាស់ដី

នៅតាមមូលដ្ឋានទាំងថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ។ ឯកសារសង្ខេបនេះ ផ្តល់នូវជម្រើសសម្រាប់ពង្រឹងសមត្ថភាពដែលអាចធ្វើទៅបាន និង វិធីសាស្ត្រនានាដែលជាមូលដ្ឋានគ្រឹះសំរាប់ការចូលរួមសិក្ខាសាលាបណ្តុះបណ្តាលស្តីអំពីការធ្វើផែនការប្រើប្រាស់ដីតំបន់ឆ្នេរសមុទ្រក្នុងប្រទេសកម្ពុជា។

## ២. តើហេតុអ្វីយើងត្រូវការការធ្វើផែនការប្រើប្រាស់តំបន់សមុទ្រ និងត្រូវធ្វើយ៉ាងដូចម្តេច?

ការធ្វើផែនការប្រើប្រាស់តំបន់សមុទ្រ (MSP) គឺជាមធ្យោបាយមួយដើម្បីបង្កើត និងរៀបចំឡើងនូវរបៀបប្រើប្រាស់លំហសមុទ្រ និងអន្តរកម្មទៅវិញទៅមករវាងការប្រើប្រាស់ទាំងអស់នេះ ដើម្បីធ្វើឱ្យមានតុល្យភាពរវាងតម្រូវការសំរាប់ការអភិវឌ្ឍជាមួយនឹងតម្រូវការការពារប្រព័ន្ធអេកូស៊ីស្ទែមសមុទ្រ និង ដើម្បីសំរេចឱ្យបាននូវគោលដៅសេដ្ឋកិច្ចសង្គមតាមរបៀបបើកចំហរ និងមានផែនការច្បាស់លាស់[២]។ ម្យ៉ាងវិញទៀត វាគឺជាដំណើរការជាសាធារណៈមួយនៃការវិភាគ និងកំណត់នូវការបែងចែកសកម្មភាពមនុស្សនៅតាមតំបន់ឆ្នេរ និង តំបន់សមុទ្រដើម្បីសម្រេចឱ្យបាននូវគោលដៅ **សេដ្ឋកិច្ចសង្គម និងបរិស្ថាន** ដែលជាធម្មតាត្រូវបានកំណត់តាមរយៈដំណើរការនយោបាយ។ ការធ្វើផែនការប្រើប្រាស់តំបន់សមុទ្រមិនមែនជាផែនការធ្វើតែម្តងនោះទេវាគឺជាដំណើរការបន្តបន្ទាប់ និងមានទំនាក់ទំនងគ្នាទៅវិញទៅមកដែលត្រូវធ្វើការសិក្សា និងត្រូវការពេលវេលាសមស្របដើម្បីអនុវត្តតាមជំហានទាំង១០ដូចខាងក្រោម៖

---

១ នាយកដ្ឋានកិច្ចការជនបទ ស្បៀង និងបរិស្ថាន ចក្រភពអង់គ្លេស (២០០៨)

**រូបភាពទី១៖ ដំណើរការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរ សមុទ្រ**




ជំហានទាំង១០នេះមិនមែនជាដំណើរការងាយស្រួលទេពីជំហានមួយទៅជំហានមួយទៀតនោះ។ ការតភ្ជាប់គ្នាពីចំណុចមួយទៅចំណុចមួយទៀតគួរដាក់បញ្ចូលទៅក្នុងដំណើរការទាំងនេះ។ ឧទាហរណ៍ គោលដៅនិងគោលបំណងដែលបានកំណត់នៅក្នុងដំណាក់កាលដំបូងនៃការធ្វើផែនការនេះគឺទំនងជាកែប្រែទៅជា ថ្លៃដើម និងផលចំណេញនៃវិធានការគ្រប់គ្រងផ្សេងៗគ្នាដែលបានកំណត់នៅក្នុងដំណាក់កាលបន្ទាប់។ ការវិភាគលក្ខខណ្ឌដែលមានស្រាប់និងនៅថ្ងៃអនាគតនឹងត្រូវផ្លាស់ប្តូរទៅជាព័ត៌មានថ្មីៗដែលបានកំណត់និងដាក់បញ្ចូលនៅក្នុងដំណើរការនេះ។ ការចូលរួមរបស់អ្នកពាក់ព័ន្ធនឹងផ្លាស់ប្តូរដំណើរការធ្វើផែនការនៅពេលដែលវាវិវត្តន៍ទៅមុខ។ ការធ្វើផែនការគឺជាដំណើរការដ៏សំខាន់ហើយអ្នកធ្វើផែនការត្រូវមានចិត្តបើកទូលាយដើម្បីទទួលនូវការផ្លាស់ប្តូរនៅពេលដែលដំណើរការបានវិវត្តន៍ទៅមុខ។

អស់រយៈពេលជាច្រើនឆ្នាំកន្លងទៅហើយគេបានចាត់ទុកការធ្វើផែនការប្រើប្រាស់តំបន់សមុទ្រ (MSP) ថាជាវិធីសាស្ត្រជាក់ស្តែងមួយដើម្បីគ្រប់គ្រងទាំងជម្លោះនិងការប្រកួតប្រជែងដែលប្រឈមទៅនឹងការអភិវឌ្ឍនិងការអភិរក្សធម្មជាតិដែលចេះតែកើនឡើង។ គម្រោង " ***ការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរ ការការពារគ្រោះមហន្តរាយ និង ការអភិវឌ្ឍប្រកបដោយនិរន្តរភាព*** " ត្រូវបានរៀបចំឡើងដោយអង្គភាពសម្របសម្រួលសម្រាប់សមុទ្រអាស៊ីបូព៌ា (COBSEA) ដែលជាគម្រោងបង្កើតឡើងក្នុងកំឡុងឆ្នាំ២០០៦ ក្រោយពីបាតុភូតរលកយក្ស**សូណាមិ** និងបានដាក់ជូនទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសស៊ុយអែត (SIDA)។ នៅដើមឆ្នាំ២០០៩ សំណើនេះបានអនុម័តផ្តល់ថវិកាគាំទ្រដោយ SIDA។ គោលបំណងរួម

របស់គម្រោងនេះគឺដើម្បីកាត់បន្ថយ និងបង្កផលប៉ះពាល់នៃគ្រោះមហន្តរាយ ការប្រែប្រួលអាកាសធាតុ ការកើនឡើងកម្ពស់ទឹកសមុទ្រ និង ជម្រុញការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃតំបន់ឆ្នេរសមុទ្រនៃបណ្តាប្រទេសជាសមាជិករបស់ COBSEA តាមរយៈការអនុវត្តការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរសមុទ្រ ដើម្បីធានាការអនុវត្តគម្រោងការគ្រប់គ្រងតំបន់ឆ្នេរសមុទ្រចម្រុះ (ICZM) និងការគ្រប់គ្រងដោយផ្អែកលើប្រពន្ធ័អេកូស៊ីស្តែម (EBM)។

## ៣. ប្រទេសកម្ពុជាបានបោះជំហានចូលក្នុងដំណើរការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរសមុទ្រ

នាពេលថ្មីៗនេះ កម្រងឯកសារថ្នាក់តំបន់បានរៀបចំឡើងដែលមានចំណងជើងថា ***ការធ្វើផែនការប្រើប្រាស់តាមតំបន់ឆ្នេរនៃតំបន់សមុទ្រអាស៊ីបូព៌ា: ការបញ្ហាបបញ្ហាដែលកំពុងកើតឡើង និងវិធីសាស្រ្តគ្រប់គ្រងថ្មីៗ*** និង ជំហាននានាត្រូវបានអនុវត្តដើម្បីកំណត់នូវតម្រូវការវគ្គបណ្តុះបណ្តាល និង/ឬ ការពង្រឹងសមត្ថភាពដល់បណ្តាប្រទេសដែលបានចូលរួម និង ការរៀបចំនូវកម្មវិធី ឬក៏វិធីសាស្រ្តបណ្តុះបណ្តាលនានាឆ្លើយតបទៅនឹងតម្រូវការដែលបានកំណត់តាមបណ្តាប្រទេសនីមួយៗ។ កាលពីថ្ងៃទី១៤-១៨ ខែឧសភា ឆ្នាំ២០១២ COBSEA បានរៀបចំនូវវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីអំពីការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរ និងសមុទ្រនៃតំបន់សមុទ្រអាស៊ីបូព៌ា នៅខេត្តភូកេត ប្រទេសថៃដែលមានក្រុមការងារបច្ចេកទេសចំនួន៦នាក់ពីប្រទេសកម្ពុជាចូលរួមយ៉ាងសកម្ម និងបានចាប់ផ្តើមអនុវត្តការងារនេះចាប់តាំងពីពេលនោះមក។

**ក្រុមការងារបច្ចេកទេសកម្ពុជាដែលបានចូលរួមវគ្គបណ្តុះបណ្តាលរួមមាន:**

១. ឯ.ឧ បណ្ឌិត **ម៉េង បុណ្ណារិទ្ធ** ប្រធាននាយកដ្ឋានគ្រប់គ្រងដែនដី ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ និងជាអគ្គលេខាធិការរង នៃអគ្គលេខា ធិការដ្ឋានគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា

២. លោក **ស៊ុយ ធា** ប្រធានមន្ទីរបរិស្ថានខេត្តកំពត

៣. លោក **ហាក់ ម៉ៅ** មន្រ្តីជំនាញតំបន់ឆ្នេរថ្នាក់ជាតិ ជាប្រធានការិយាល័យវាយតម្លៃភាពងាយរងគ្រោះ និង បន្សាំនឹងការប្រែប្រួលអាកាសធាតុ ក្រសួងបរិស្ថាន

៣. លោក **ប្រាក់ វិសាល** នាយករងសាលាខេត្តព្រះសីហនុ

៤. លោក **ឈុន សីហា** អនុប្រធានការិយាល័យវាយតម្លៃភាពងាយរងគ្រោះ និង បន្សាំនឹងការប្រែប្រួលអាកាសធាតុ ក្រសួងបរិស្ថាន

៥. លោក **លី រតនា** សាស្រ្តាចារ្យសាកលវិទ្យាល័យស្វាយរៀង

លោក **កុច សុវ៉ាទ** អគ្គនាយករងបច្ចេកទេសនៃក្រសួងបរិស្ថាន, ជនបង្គោល និងជាអ្នកសម្របសម្រួលថ្នាក់ជាតិនៃគម្រោងនេះ។ ក្រុមការងារបានកំណត់នូវតម្រូវការឧបសគ្គ និងវិធីសាស្រ្តនានាដើម្បីរៀបចំឯកសារបណ្តុះបណ្តាលនេះ។

## ៤. តម្រូវការចំបងៗរបស់ប្រទេសកម្ពុជា

ប្រទេសកម្ពុជាត្រូវការវគ្គបណ្តុះបណ្តាលមួយចំនួនចាប់ពីជំនាញគ្រប់គ្រងទូទៅរហូតដល់ចំណេះដឹងជំនាញ និងព័ត៌មាន និងវិទ្យាសាស្ត្រជាក់លាក់។ តម្រូវការជាបន្ទាន់សំរាប់ពង្រឹងសមត្ថភាពមន្ត្រីរាជរដ្ឋាភិបាល (ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) អង្គការសង្គមស៊ីវិល វិទ្យាស្ថានស្រាវជ្រាវ វិទ្យាស្ថានសិក្សា និង សហគមន៍មូលដ្ឋាននៅតាមតំបន់ឆ្នេរសមុទ្រ មានដូចជា:

ក) ការចែករំលែកចំណេះដឹង និងបទពិសោធន៍ ស្តីពីការធ្វើផែនការតំបន់ឆ្នេរដល់អ្នកពាក់ពន្ធ័នានា

ខ) ការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពដែលមានស្រាប់របស់អាជ្ញាធរមូលដ្ឋាន និង សហគមន៍តំបន់ឆ្នេរក្នុងការគ្រប់គ្រងតំបន់ឆ្នេរ និង

គ) ការបញ្ជ្រាបការអនុវត្តល្អនៃការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរ និង ការគ្រប់គ្រងតំបន់ឆ្នេរចម្រុះពីបណ្តាប្រទេសនានាឱ្យសមស្របតាមស្ថានភាព ប្រទេសកម្ពុជា។

## ៥. ឧបសគ្គចំបងៗ ក្នុងការធ្វើផែនការគ្រប់គ្រងតំបន់ឆ្នេរ

តាមការអនុវត្តជាក់ស្តែងមានឧបសគ្គមួយចំនួនសំរាប់ការអភិរក្ស ការគ្រប់គ្រង និងការអភិវឌ្ឍតំបន់ឆ្នេរនៅក្នុងប្រទេសកម្ពុជា។ ខាងក្រោមនេះគឺជាឧបសគ្គចំបងៗមួយចំនួនក្នុងការគ្រប់គ្រងតំបន់ឆ្នេរសមុទ្រ:

ក) **ការគ្រប់គ្រង និងការគាំទ្រហិរញ្ញវត្ថុមិនគ្រប់គ្រាន់:** ការគាំទ្រផ្នែកហិរញ្ញវត្ថុសំរាប់ការអនុវត្ត និងការគ្រប់គ្រងតំបន់ឆ្នេរសមុទ្របានទទួលពីប្រភពម្ចាស់ជំនួយផ្សេងៗគ្នាជាច្រើន។ គម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាពឹងផ្អែកទាំងស្រុងលើការគាំទ្រហិរញ្ញវត្ថុពីប្រភពខាងក្រៅតាមរយៈដៃគូអភិវឌ្ឍន៍ បណ្តាប្រទេសម្ចាស់ជំនួយ និងអង្គការអន្តរជាតិ ។ល។

ខ) **ពុំមានក្របខណ្ឌគតិយុត្តិជាក់លាក់:** ប្រទេសកម្ពុជាជួបនូវកង្វះខាតឯកសារ បទបញ្ញត្តិ និង បុគ្គលិកជំនាញដើម្បីត្រួតពិនិត្យ និងតាមដាននូវសកម្មភាពការអភិវឌ្ឍដោយនិរន្តភាពនៃតំបន់ឆ្នេរសមុទ្រ។ មានច្បាប់និងបទបញ្ញត្តិព្រះរាជក្រឹត្យ និងអនុក្រិត្យមួយចំនួនបានរៀបចំ និងអនុមត័ប៉ុន្តែមិនមានក្របខណ្ឌគតិយុត្តិជាក់លាក់ ស្តីពីការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃតំបន់ឆ្នេរសមុទ្រត្រូវបានរៀបចំឡើងនោះទេ។

គ) **បញ្ហាស្ថាប័ន និងសមត្ថភាពបុគ្គលិក:** ចំនួនមន្ត្រីរាជការដែលមានសមត្ថភាពនៅមានកម្រិត និង ឆន្ទៈអនុវត្តន៍ការងារនៅមានកំរិតទាបនៅឡើយ ដែលនេះគឺជាឧបសគ្គចំពោះការអភិវឌ្ឍ និងអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ជាទូទៅ បុគ្គលិកមន្ទីរតាមខេត្តនានាមានសមត្ថភាព និងចំណេះដឹងនៅមានកម្រិតទាំងទិដ្ឋភាពច្បាប់ និង បច្ចេកទេសអនុវត្តកម្មវិធីគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិតំបន់ឆ្នេរសមុទ្រ។

ឃ) **ការចូលរួម និងផ្សព្វផ្សាយជាសាធារណៈនៅមានកម្រិត:** បញ្ហាជាច្រើនទាក់ទងទៅនឹងការចូលរួម និងការផ្សព្វផ្សាយជាសាធារណៈគួរត្រូវបានដោះស្រាយ និង សកម្មភាពនានាដើម្បីពង្រឹងច្បាប់គឺតម្រូវឱ្យមានការផ្សព្វផ្សាយជាសាធារណៈ និងឱ្យមានការចូលរួមជាសាធារណៈរួមបញ្ចូលទាំងការត្រួតពិនិត្យ និងស្រាវជ្រាវផងដែរ។

## ៦. គោលបំណងនៃវគ្គបណ្តុះបណ្តាល

មានគោលបំណងមួយចំនួនទាក់ទងនឹងការពង្រឹងសមត្ថភាព និង ការបណ្តុះបណ្តាលដែលត្រូវធ្វើជាបន្តបន្ទាប់។ ទាំងនេះរួមមានចាប់ពីការពង្រឹងសមត្ថភាពផ្សព្វផ្សាយសាមញ្ញៗ ជាពិសេសព័ត៌មានមូលដ្ឋានទាក់ទងទៅនឹងការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរគួរត្រូវបានផ្សព្វផ្សាយរហូតដល់អាជ្ញាធរថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ និង អ្នកពាក់ព័ន្ធនានាដើម្បីធ្វើឱ្យពួកគេអាចបញ្ជ្រាបប្រកបដោយប្រសិទ្ធភាពនូវបញ្ហាប្រឈមនានាដូចជា ការប្រែប្រួលអាកាសធាតុការកើនឡើងនូវកម្ពស់ទឹកសមុទ្រ និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយព្រមទាំងគោលការណ៍នាពេលបច្ចុប្បន្ន ដូចជាការបញ្ជ្រាបវិធីសាស្ត្រគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែមទៅក្នុងក្របខណ្ឌគ្រប់គ្រង និងគោលនយោបាយដែលមានស្រាប់។ នៅទីបញ្ចប់ ប្រហែលជានឹងមានតម្រូវការសំរាប់ការកសាងនូវមូលដ្ឋានចំណេះដឹងដ៏រឹងមាំមួយនៃដំណើរការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរ ការបង្កើតជំនាញប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) ឬបច្ចេកទេសធ្វើផែនទីផ្សេងៗទៀតការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់អ្នកប្រតិបត្តិការផ្លាស់ប្តូរអកប្បកិរិយាអនុវត្តការងារទាក់ទងទៅនឹងរបៀបធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរ។ សូមមើលរូបភាពដែលបានគូសបញ្ជាក់ដូចខាងក្រោម:

**រូបភាពទី២: គោលបំណងក្នុងការពង្រឹងសមត្ថភាព និងការរៀបចំវគ្គបណ្តុះបណ្តាលវ**




សរុបមកគោលបំណងចំបងៗនៃបណ្តុះបណ្តាលរួមមាន:

១) ណែនាំអំពីទស្សនទានជាមូលដ្ឋាន និងពាក្យបច្ចេកទេស នៃការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរ និង សមុទ្របញ្ហាកើតឡើងទាក់ទងនឹងតំបន់ឆ្នេរសមុទ្រ ការប្រែប្រួលអាកាសធាតុ និង ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយទៅដល់មន្ត្រីរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធសំខាន់ៗ

២) ណែនាំ និង ចែករំលែកនូវចំណេះដឹងអំពីវិធីសាស្ត្រគ្រប់គ្រងសំរាប់ការធ្វើផែនការប្រើប្រាស់ដីតំបន់ឆ្នេរ និង សមុទ្រដើម្បីដោះស្រាយបញ្ហាដែលកំពុងកើតឡើង

៣) ណែនាំ និងពង្រឹងសមត្ថភាពអំពីវិធីសាស្ត្រថ្មីៗសម្រាប់ការគ្រប់គ្រងការធ្វើផែនការប្រើប្រាស់ដីតំបន់ឆ្នេរសមុទ្រដល់អ្នកពាក់ពន្ធ័នានា ជាពិសេសអ្នកអនុវត្តការងារ និងមន្ត្រីជាន់ខ្ពស់

៤) ណែនាំនូវវិធីសាស្ត្រគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រកម្ពុជាតាមរយៈការផ្តល់នូវការអនុវត្តល្អៗពីបណ្តាប្រទេសនានាជាពិសេសប្រទេសដែលមានស្ថានភាពអភិវឌ្ឍន៍សេដ្ឋកិច្ចនិងភូមិសាស្ត្រប្រហាក់ប្រហែល នឹងប្រទេសកម្ពុជា និង

៥) ធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួល កិច្ចសហប្រតិបត្តិការ និងការពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាល សង្គមស៊ីវិល វិទ្យាស្ថានសិក្សា ស្រាវជ្រាវ សហគមន៍មូលដ្ឋានដើម្បីធានានូវការអភិរក្ស និងគ្រប់គ្រងតំបន់ឆ្នេរសមុទ្រប្រកបដោយនិរន្តភាព។

## ៧. វិធីសាស្ត្របណ្តុះបណ្តាល

វិធីសាស្ត្រកសាងសមត្ថភាព/បណ្តុះបណ្តាលណាមួយគួរតែមានលក្ខណៈផ្តោតជាសំខាន់ទៅលើអ្នកប្រតិបត្តិ ជាជាងរបៀបបង្រៀនបែបបុរាណក្នុងថ្នាក់រៀន ដែលគ្រូជាអ្នកនិយាយ។ ហើយជាជាងផ្តោតសំខាន់តែទៅលើមាតិកា និង របៀបបណ្តុះបណ្តាលដែលមានជាធម្មតាទៅហើយនៅក្នុងវគ្គបណ្តុះបណ្តាល និង កសាងសមត្ថភាពគ្រូជាអ្នកហៅឱ្យសរសេរ ដូច្នេះជាការចាំបាច់នោះគឺត្រូវផ្តល់ឱកាសឱ្យសិក្ខាកាមរៀបចំរបៀបបង្រៀននិងមាតិកាបណ្តុះបណ្តាលដោយខ្លួនឯង។ ទាំងនេះគឺជាការផ្លាស់ប្តូរពីអ្នកជំនាញដឹកនាំបង្រៀនមកជាការរៀបចំវគ្គបណ្តុះបណ្តាលដែលមានសិក្ខាកាមជាអ្នកដឹកនាំ។ ចំណុចសំខាន់គឺនៅត្រង់ថាក៏រិតនៃការយល់ដឹងពីស្ថានភាពវប្បធម៌ (ឧទាហរណ៍៖លទ្ធភាពដើម្បីស្វែងយល់និងប្រតិបត្តិការឱ្យមានប្រសិទ្ធភាពនៅក្នុងបរិបទវប្បធម៌ផ្សេងៗគ្នា) គឺជារឿងចាំបាច់ដើម្បីធានាថាវិធីសាស្ត្របណ្តុះបណ្តាលកសាងសមត្ថភាពដែលស្នើឡើងគឺសមស្របនិងឆ្លើយតបទៅនឹងស្ថានភាពស្ថាប័ននយោបាយ និងបរិបទនៅក្នុងប្រទេសកម្ពុជា។

វិធីសាស្ត្រកសាងសមត្ថភាព/បណ្តុះបណ្តាលរយៈពេលខ្លីនិងមធ្យមគួរយកមកអនុវត្តជាលក្ខណៈបុគ្គលឬក៏នៅពេលខ្លះគួរធ្វើរួមគ្នាដើម្បីសំរេចឱ្យបាននូវតម្រូវការសិក្សារៀនសូត្រដោយគោរពទៅតាមរបៀបរៀនសូត្រដែលមានពីមុនមកនៅក្នុងប្រទេសកម្ពុជា និងតម្រូវការនាពេលបច្ចុប្បន្នរបស់សិក្ខាកាមនៅក្នុងវគ្គបណ្តុះបណ្តាលៈ

- ការបង្រៀន (ទោះបីជាមានការបញ្ជាក់តិចឡើងៗ)
- ការងារជាក្រុមៈ រៀនពីគ្នាទៅវិញទៅមក-រៀន និងស្វែងយល់ពីគ្នា
- លំហាត់អនុវត្ត (Role playing)
- ការស្រាវជ្រាវជាក្រុម/ជាបុគ្គល (ករណីសិក្សា)

- ទស្សនៈកិច្ចទៅកាន់ទីតាំងនានា ដែលបានអនុវត្តការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរប្រកបដោយប្រសិទ្ធភាព
- ធ្វើការផ្លាស់ប្តូរយោបល់ក្នុងចំណោមអ្នកមានបទពិសោធន៍ និងអ្នកមិនមានបទពិសោធន៍។

## ៧.១ លទ្ធផលរំពឹងទុក

វគ្គបណ្តុះបណ្តាលនេះនឹងផ្តល់នូវលទ្ធផលសំខាន់ៗមួយចំនួនដូចខាងក្រោមៈ

ក) សិក្ខាកាមបានយល់ដឹងពីពាក្យបច្ចេកទេស និងទស្សនទានអំពីការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរសមុទ្រ

ខ) យល់ដឹងបានទូលំទូលាយអំពីវិធីសាស្ត្រគ្រប់គ្រងការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរសមុទ្រ និងអាចអនុវត្តតាមខេត្តរៀងៗខ្លួន

គ) កែលំអរ និងពង្រឹងយន្តការសម្របសម្រួលក្នុងចំណោមសិក្ខាកាម សំរាប់កិច្ចសហការនៅពេលអនាគត

ឃ) បង្កើននូវជំនឿទុកចិត្តឱ្យកាន់តែរឹងមាំថែមទៀតក្នុងការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងវិធីសាស្ត្រគ្រប់គ្រងការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរសមុទ្រ ដើម្បីដោះស្រាយនូវក្តីបារម្ភ និងបញ្ហាដែលកំពុងកើតឡើង។

## ៧.២ ប្រភេទនៃវគ្គបណ្តុះបណ្តាល

ដើម្បីឆ្លើយតបទៅនឹងគោលបំណងទាំងអស់នេះ ប្រភេទមួយចំនួននៃការកសាងសមត្ថភាពត្រូវបានរៀបចំឡើង។ ប្រភេទទាំងនេះ រួមមាន ១) កិច្ចខិតខំប្រឹង ប្រែងផ្សព្វផ្សាយឱ្យមានការយល់ដឹងជាសាធារណៈ ២) ការអប់រំក្នុងប្រព័ន្ធ (ផ្លូវការ) ៣) វគ្គបណ្តុះបណ្តាល ៤) ការអភិវឌ្ឍវិជ្ជាជីវៈ និង ៥) ការបង្រៀន/ ការណែនាំ។

ក) ការអភិវឌ្ឍធនធានមនុស្ស និងការផ្សព្វផ្សាយ

ខ) ការពង្រឹងសមត្ថភាពស្ថាប័ន

គ) ការកៀរគរធនធាន និងវិធីសាស្ត្រគ្រប់គ្រង និង

ឃ) ក្របខណ្ឌបទដ្ឋានគតិយុត្តិ និងគោលនយោបាយ (គោលនយោបាយផែនការប្រើប្រាស់តំបន់ឆ្នេរដែលមានស្រាប់ សារាចរណែនាំស្តីអំពីការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរ និង ការគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ឆ្នេរចម្រុះព្រមទាំងណែនាំនូវវិធីសាស្ត្រគ្រប់គ្រងថ្មីៗ) និងការកែលំអរបច្ចេកទេស។

## ៧.៣ សិក្ខាកាមចូលរួមវគ្គបណ្តុះបណ្តាល

សិក្ខាកាម រួមមានមន្ត្រី និងអាជ្ញាធរទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេសមកពីបណ្តាខេត្តតាមតំបន់ឆ្នេរសមុទ្រ។ លើសពីនេះទៅទៀត វគ្គបណ្តុះបណ្តាលនេះនឹងផ្តល់ឱកាសឱ្យអ្នកពាក់ពន្ធ័ផ្សេងៗទៀតដែលធ្វើការលើវិស័យនេះបានមកជួបជុំគ្នា។ ខាងក្រោមនេះគឺជាស្ថាប័នពាក់ពន្ធ័ដែលនឹងត្រូវបានអញ្ជើញឱ្យចូលរួមនៅក្នុងវគ្គនេះ :

១) ក្រសួងបរិស្ថាន

២) ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់

៣) ក្រសួងមហាផ្ទៃ

៤) ក្រសួងសាធារណការ និងដឹកជញ្ជូន

៥) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៦) ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

៧) ក្រសួងអប់រំ យុវជន និងកីឡា

៨) ក្រសួងទេសចរណ៍

៩) ក្រសួងសុខាភិបាល

១០) ក្រសួងកិច្ចការនារី

១១) បណ្តាខេត្តតំបន់ឆ្នេរសមុទ្រទាំង៤ : ខេត្តកំពត ខេត្តកោះកុង ខេត្តព្រះសីហនុ និង ខេត្តកែប (អាជ្ញាធរខេត្ត និង មន្ទីរនានា)

១២) សហគមន៍តំបន់ឆ្នេរ (ប្រធានសហគមន៍មកពីបណ្តាខេត្តនីមួយៗ)

១៣) អង្គការក្រៅរដ្ឋាភិបាល (IUCN)

១៤) សាកលវិទ្យាល័យ (សកលវិទ្យាល័យភូមិន្ទកសិកម្ម និងសកលវិទ្យាល័យភូមិន្ទភ្នំពេញ)

១៥) គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

## ៧.៤ ឯកសារបណ្តុះបណ្តាល

ឯកសារពាក់ពន្ធ័មួយចំនួនបានកំណត់រួចរាល់ហើយសម្រាប់វគ្គបណ្តុះបណ្តាលនេះ ប៉ុន្តែឯកសារជាក់ស្តែងប្រហែលជាមានចំនួនច្រើន ជាងនេះទៀតអាស្រ័យលើការចូលរួមរបស់បុគ្គលសំខាន់ៗ។ ឯកសារបណ្តុះបណ្តាលរួមមានៈ

១) កម្រងឯកសារថ្នាក់ជាតិ និងថ្នាក់តំបន់ស្តីពីការគ្រប់គ្រងតំបន់ឆ្នេរ

២) ការគ្រប់គ្រង និងអភិរក្សតំបន់ឆ្នេរថ្នាក់ជាតិ

៣) យុទ្ធសាស្ត្រគ្រប់គ្រងឆ្នេរសមុទ្រថ្នាក់ជាតិ

៤) ស្ថានភាពតំបន់ឆ្នេរនៃប្រទេសកម្ពុជា

៥) ពង្រាងយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ឆ្នេរថ្នាក់ជាតិ (រួមទាំងៈ ការគ្រប់គ្រងដោយផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែម)

៦) ច្បាប់ និងគោលនយោបាយដីធ្លី

៧) សារាចរណែនាំ និងគោលនយោបាយផែនការប្រើប្រាស់តំបន់ឆ្នេរថ្នាក់ជាតិ

៨) យុទ្ធសាស្ត្រសមាហរណកម្មតំបន់ឆ្នេរ និងប្លង់គោលខេត្តព្រះសីហនុសម្រាប់ការអភិវឌ្ឍ

៩) ការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរទូទៅ (ប្រភពមកពីវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់)

១០) ការកំណត់ការប្រើប្រាស់ដីតំបន់ឆ្នេរ (ខេត្តព្រះសីហនុ)

១១) យុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសំរាប់ប្រទេសកម្ពុជា

១២) ផែនការយុទ្ធសាស្ត្រ និងគោលនយោបាយការប្រែប្រួលអាកាសធាតុថ្នាក់ជាតិដែលពាក់ព័ន្ធ និង

១៣) ការវាយតម្លៃភាពងាយរងគ្រោះ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅតាមបណ្តាខេត្តតំបន់ឆ្នេរក្នុងប្រទេសកម្ពុជា

## ៧.៥ ឯកសារដែលត្រូវបកប្រែមកជាខេមរភាសា

១) ការបញ្ហាបបញ្ហាដែលកំពុងកើតឡើង និងវិធីសាស្ត្រគ្រប់គ្រងថ្មីៗសម្រាប់ការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរសមុទ្រនៅក្នុងប្រទេសកម្ពុជា

២) ឯកសារវគ្គបណ្តុះបណ្តាល និង

៣) ឯកសារពាក់ព័ន្ធផ្សេងៗទៀត សំរាប់រៀបចំកម្រងឯកសារថ្នាក់ជាតិ

## ៧.៦ ទីកន្លែងរៀបចំវគ្គបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលនេះរៀបចំនៅមន្ទីរបរិស្ថានក្នុងខេត្តកំពត។ សំភារៈ/ឧបករណ៍សំរាប់វគ្គបណ្តុះបណ្តាលនេះជួលយកមកប្រើប្រាស់។

## ៧.៧ ខ្លឹមសារនៃវគ្គបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលរយៈពេល២ថ្ងៃកន្លះរំពឹងថានឹងគ្របដណ្តប់លើប្រធានបទមួយចំនួនដូចខាងក្រោមនេះ ដោយមានការចូលរួមយ៉ាងសកម្មពីអាជ្ញាធរមូលដ្ឋាន និងមន្ត្រីថ្នាក់ជាតិ និងអ្នកពាក់ព័ន្ធនានា:

១) ការណែនាំអំពីគោលបំណងនៃវគ្គបណ្តុះបណ្តាល និងលទ្ធផលរំពឹងទុក

២) ការស្វែងយល់អំពីទស្សនទានតំបន់ឆ្នេរសមុទ្រៈ ឆ្នេរសមុទ្រ ខ្ពង់រាបបាតសមុទ្រ តំបន់សេដ្ឋកិច្ចផ្តាច់មុខ និងដែនសមុទ្រអន្តរជាតិ ។ល។

៣) ពាក្យបច្ចេកទេសនានាទាក់ទងនឹងការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរ-តំបន់ឆ្នេរផ្ទៃដីតំបន់ឆ្នេរស្មៅសមុទ្រ ការគ្រប់គ្រងតំបន់ឆ្នេរចម្រុះការធ្វើផែនការប្រើប្រាស់ដី ការកំណត់ការប្រើប្រាស់ដីតំបន់ឆ្នេរ ការគ្រប់គ្រងដោយផ្អែកលើសហគមន៍/ប្រព័ន្ធអេកូស៊ីស្ទែម គ្រោះមហន្តរាយ ហានិភ័យ និងភាពងាយរងគ្រោះ ។ល។

៤) ការស្រាវជ្រាវថ្នាក់ជាតិ ស្តីអំពីផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ និងការកើនឡើងកម្ពស់ទឹកសមុទ្រនៅតាមតំបន់ឆ្នេរ

៥) ព័ត៌មានទូទៅស្តីពីការគ្រប់គ្រង និងផលប៉ះពាល់បណ្តាលមកពីហានិភ័យគ្រោះមហន្តរាយ

៦) ការគ្រប់គ្រងការដឹកជញ្ជូនតាមសមុទ្រ (ការកំពប់ប្រេង ការចោលកាកសំណល់ ការនេសាទខុសច្បាប់ ការគ្រប់គ្រងទំនិញ អំពើប្លន់តាមសមុទ្រ) / ការគ្រប់គ្រងកំពង់ផែ

៧) ការវាយតម្លៃភាពងាយរងគ្រោះមហន្តរាយតំបន់ឆ្នេរសមុទ្រ/ការស្វែងយល់អំពីហានិភ័យនៅតាមតំបន់ឆ្នេរសមុទ្រ (IUCN)

៨) ការគ្រប់គ្រងជីវៈចម្រុះតំបន់ឆ្នេរសមុទ្រ

៩) ស្ថានភាពស្មៅសមុទ្រ និងផ្កាថ្មនៅកម្ពុជា

១០) ការគ្រប់គ្រងព្រៃកោងកាងដោយមានការចូលរួម

១១) ស្ថានភាពនៃការគ្រប់គ្រង និងយុទ្ធសាស្ត្រអភិវឌ្ឍន៍អេកូទេសចរណ៍តំបន់ឆ្នេរសមុទ្រនៅកម្ពុជា

១២) បញ្ហាការគ្រប់គ្រង និងផលប៉ះពាល់នៃសំណល់

១៣) យុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៅតាមតំបន់ឆ្នេរសមុទ្រអាស៊ីបូព៌ាសម្រាប់កម្ពុជា

១៤) ការវាយតម្លៃផលប៉ះពាល់បរិស្ថានសំរាប់ការអភិវឌ្ឍតំបន់ឆ្នេរ (ទស្សនទានអំពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន)

១៥) សារាចរណែនាំ/គោលនយោបាយនៃការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរនៅក្នុងប្រទេសកម្ពុជា ព័ត៌មានទូទៅពីវគ្គបណ្តុះបណ្តាលនៅភូកេត (ទស្សនទាននៃការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរ)

១៦) ការកំណត់ផែនការប្រើប្រាស់តំបន់ឆ្នេរសមុទ្រខេត្តព្រះសីហនុ

១៧) ការគ្រប់គ្រងការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរ និង ឧបសគ្គ/ជម្លោះ (ការរៀបចំស្ថាប័ន ដូចជាគណៈកម្មាធិការជាតិគ្រប់គ្រងតំបន់ឆ្នេរសមុទ្រ និងគណៈកម្មាធិការជាតិដោះស្រាយទំនាស់ដីធ្លី ។ល។)

១៨) យុទ្ធសាស្ត្រសមាហរណកម្មតំបន់ឆ្នេរ និងប្លង់គោលខេត្តព្រះសីហនុសម្រាប់ការអភិវឌ្ឍ

## ៧.៨ របៀបវារៈនៃវគ្គបណ្តុះបណ្តាល [៣]

របៀបវារៈនៃវគ្គបណ្តុះបណ្តាលមានដូចខាងក្រោម៖

២ របៀបវារៈចុងក្រោយ នឹងរៀបចំឱ្យបានរួលរាល់សំរាប់សិក្ខាកាម មុនពេលវគ្គបណ្តុះបណ្តាល

| ពេលវេលា | ប្រធានបទ | អ្នកធ្វើបទបង្ហាញ | អ្នកសម្របសម្រួល |
|---|---|---|---|
| ថ្ងៃទី ៣០-០៩-១២ | ចេញដំណើរពីទីក្រុងភ្នំពេញទៅកាន់ខេត្តកំពត | | |
| **ថ្ងៃទី ០១-១០-១២** | **បញ្ហាទាក់ទងទៅនឹងផ្នែកបច្ចេកទេស និង ការងារគ្រប់គ្រងតំបន់ឆ្នេរ** | | |
| ៨.៣០-៩.០០ | ពិធីបើកកិច្ចប្រជុំ<br>- ចំណាប់អារម្មណ៍ដោយតំណាងខេត្តកំពត<br>- ថ្លែងកន្ទរកថាបើកដោយឯកឧត្តមរដ្ឋលេខាធិការ | ឯ.ឧ. **សូត យា**, អភិបាលរងខេត្តកំពត<br>**Mr. Reynaldo F. Molina**, ទីប្រឹក្សា គម្រោង COBSEA<br>ឯ.ឧ. **ខុង សំនួន**, រដ្ឋលេខាធិការ, ក្រសួង បរិស្ថាន | M/C |
| | ***ថតរូបរួមគ្នា*** | | |
| ៩.០០-៩.១៥ | សេចក្ដីណែនាំអំពីវគ្គបណ្ដុះបណ្ដាល | លោក ហាក់ ម៉ៅ | |
| **៩.១៥-៩.៣០** | **សម្រាកអាហារសម្រន់** | | |
| ៩.៣០-១០.៤៥ | បច្ចេកស័ព្ទទាក់ទងនឹងគ្រោះមហន្តរាយសមុទ្រ និង ផែនការប្រើប្រាស់សមុទ្រ (កិច្ចពិភាក្សា) | លោក ឈុន សីហា<br>លោក លី រតនា | លោក កុច សុវ៉ាទ |
| ១០.៤៥-១១.៣០ | គោលនយោបាយរៀបចំដែនដី<br>(សំនួរ និង ចំលើយ) | បណ្ឌិត ម៉េង ប៊ុណ្ណារិទ្ធ | |
| **១១.៣០-១៣.០០** | **សម្រាកអាហារថ្ងៃត្រង់** | | |

| | | | |
|---|---|---|---|
| ១៣.00-១៤.00 | សារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា (សំនួរ និង ចំលើយ) | បណ្ឌិត ម៉េង ប៊ុណ្ណារិទ្ធ | លោក កុច សុវ៉ាទ[4] |
| ១៤.00-១៥.00 | ទស្សនទានអំពីការគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា (សំនួរ និង ចំលើយ) | លោក សុទ្ធ គីមកុលមុនី | |
| **១៥.00-១៥.១៥** | **សម្រាកអាហារសម្រន់** | | |
| ១៥.១៥-១៦.00 | ការដឹកជញ្ជូនផ្លូវសមុទ្រ (សំនួរ និង ចំលើយ) | លោក ម៉ក់ ស៊ីដែត | លោក កុច សុវ៉ាទ |
| ១៦.00-១៦.៤៥ | ការវាយតម្លៃភាពងាយរងគ្រោះ និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅតំបន់ឆ្នេរសមុទ្រ (សំនួរ និង ចំលើយ) | លោក ហាក់ ម៉ៅ | |
| ១៦.៤៥-១៧.00 | សង្ខេបថ្ងៃទីមួយ | លោក កុច សុវ៉ាទ | |
| **ថ្ងៃទី0២-១០-១២** | **សេចក្តីណែនាំអំពីលទ្ធផលនៃការស្រាវជ្រាវ និងការគ្រប់គ្រងតំបន់ឆ្នេរ** | | |
| ៨.00-៩.00 | ប្រព័ន្ធកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់ បរិស្ថាននៅប្រទេសកម្ពុជា (EIA System in Cambodia) | លោក ឌួង សំគាត | លោក កុច សុវ៉ាទ |

[4] លោក **កុច សុវ៉ាទ** អគ្គនាយករងក្រសួងបរិស្ថាន, ជនង្គោល និងជាអ្នកសម្របសម្រួលគម្រោង

| | | | |
|---|---|---|---|
| | (សំនួរ និង ចំលើយ) | | |
| ៩.00-៩.៤៥ | កសាងភាពធន់ទ្រាំនៅនឹងផលប៉ះពាល់ពីការប្រែប្រួលអាកសធាតុក្នុងតំបន់ឆ្នេរសមុទ្រ ប្រទេសកម្ពុជា វៀតណាម និងថៃ<br>(Building Coastal Resilience to Climate Change Impacts – Southeast Asia) (BCR)<br>(សំនួរ និង ចំលើយ) | លោក គង់ គីមស្រេង | |
| **៩.៤៥-១0.00** | **សម្រាកអាហារសម្រន់** | | |
| ១0.00-១១.១៥ | បទពិសោធន៏ការគ្រប់គ្រងប្រព័ន្ធអេកូស៊ីស្ទែមព្រៃកោងកាងនៅតំបន់ឆ្នេរសមុទ្រកម្ពុជា<br>(Adaptive Co-Management Experience on Mangrove Eco-System Management in Coastal Cambodia)<br>(សំនួរ និង ចំលើយ) | លោក គីម ណុង | លោក ហាក់ ម៉ៅ |
| ១១.១៥-១២.00 | ការអភិវឌ្ឍន៏ និងរៀបចំផែនការបែងចែកតំបន់ប្រើប្រាស់ដី-ទឹកតំបន់ឆ្នេរខេត្តព្រះសីហនុដំណើរការការប្រឈម និង អត្ថប្រយោជន៏<br>(សំនួរ និង ចំលើយ) | លោក ប្រាក់ វិសាល | |

| | | | |
|---|---|---|---|
| **១២.០០-១៣.៣០** | **ទទួលទានអាហារថ្ងៃត្រង់** | | |
| ១៣.៣០-១៤.៣០ | យុទ្ធសាស្ត្រជាតិសមាហរណកម្មតំបន់ឆ្នេរ និង ប្លង់គោល ខេត្តព្រះសីហនុសម្រាប់ការអភិវឌ្ឍប្រកបដោយចិរភាព (សំនួរ និង ចំលើយ) | លោក លី ចាន់ភក្តី | លោក ហាក់ ម៉ៅ |
| ១៤.៣០-១៥.៣០ | ការគ្រប់គ្រងសំណល់រឹងប្រកបដោយសុវត្ថភាពបរិស្ថាន (សំនួរ និង ចំលើយ) | លោក ង៉ែត បុល | |
| **១៥.៣០-១៥.៤៥** | **សម្រាកអាហារសម្រន់** | | |
| ១៥.៤៥-១៦.៤៥ | យុទ្ធសាស្ត្រអភិវឌ្ឍប្រកបដោយនិរន្តរភាពសម្រាប់សមុទ្រអាស៊ីបូព៌ាសម្រាប់ប្រទេសកម្ពុជា (សំនួរ និង ចំលើយ) | លោក ហាក់ ម៉ៅ | |
| ១៦.៤៥-១៧.០០ | សង្ខេបថ្ងៃទី២ | លោក កុច សុវ៉ាទ | |
| **ថ្ងៃទី០៣-១០-១២** | **ទស្សនៈទានពីការគ្រប់គ្រង និងដំណោះស្រាយ ⁄ បទដ្ឋានច្បាប់ គោលនយោបាយ និងយុទ្ធសាស្ត្រជាតិ គ្រប់គ្រង តំបន់ឆ្នេរ និងវិធានការដោះស្រាយជម្លោះនៅក្នុងតំបន់ឆ្នេរសមុទ្រ** | | |
| ៨.០០-០៩.០០ | ការគ្រប់គ្រងចម្រុះតំបន់ឆ្នេរសមុទ្រកម្ពុជា និង យុទ្ធសាស្ត្រនៃការរៀបចំអេកូទេសចរណ៍ | លោក មាស រិទ្ធី | លោក កុច សុវ៉ាទ |

| | | | |
|---|---|---|---|
| | (សំនួរ និង ចំលើយ) | | |
| **០៩.០០-០៩.១៥** | **សម្រាកអាហារសម្រន់** | | |
| ០៩.១៥-១០.០០ | ស្ថានភាពធនធានផ្កាថ្មនិងស្មៅសមុទ្រនៅកម្ពុជា (សំនួរ និង ចំលើយ) | លោក ស៊ុយ ធា | លោក កុច សុវ៉ាទ |
| ១០.០០-១១.០០ | ព័ត៌មានទាក់ទងនឹងផលប៉ះពាល់ និងវិធានការឆ្លើយតប នឹងការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកម្ពុជា (សំនួរ និង ចំលើយ) | លោក ហាក់ ម៉ៅ | |
| ១១.០០-១២.០០ | ការវាយតម្លៃវគ្គបណ្តុះបណ្តាល និងបិទវគ្គ | លោក កុច សុវ៉ាទ | |
| **១២.០០-១៣.៣០** | **ទទួលទានអាហារថ្ងៃត្រង់ និងធ្វើដំណើរត្រលប់មកភ្នំពេញវិញ** | | |

***ព័ត៌មានអំពីអ្នកធ្វើបទបង្ហាញ:***

1. បណ្ឌិត **ម៉េង ប៊ុណ្ណារិទ្ធ** អគ្គលេខាធិការរង នៃអគ្គលេខាធិកាដ្ឋានគ្រប់គ្រងតំបន់ឆ្នេរ និងជាប្រធាននាយកដ្ឋាន រៀបចំដែនដី, ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់
2. លោក **គីម ណុង**, អគ្គនាយករង, ក្រសួងបរិស្ថាន
3. លោក **ម៉ក់ ស៊ីវែត,** ប្រធាននាយកដ្ឋានជំនួញនាវាសមុទ្រ នៃក្រសួងសាធារណការ និងដឹកជញ្ជូន
4. លោក **សួត គីមកុលមុន្នី,** អនុប្រធាននាយកដ្ឋាន បរិវត្តភាព និងបណ្តុះបណ្តាលនៃគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយ
5. លោក **ខួង សំគាត**, អនុប្រធាននាយកដ្ឋានវាយតម្លៃផលប៉ះពាល់បរិស្ថាន, ក្រសួងបរិស្ថាន
6. លោក **ស៊ុយ ធា**,ប្រធានមន្ទីរបរិស្ថានខេត្តកំពត
7. លោក **ហាក់ ម៉ៅ**, ជំនាញការជាតិតំបន់ឆ្នេរ, ប្រធានការិយាល័យវាយតម្លៃភាពងាយរងគ្រោះ និងបន្សុាំនឹងការប្រែប្រួលអាកាសធាតុ,ក្រសួងបរិស្ថាន
8. លោក **ប្រាក់ វិសាល**, អនុការិយាល័យសាលាខេត្តព្រះសីហនុ
9. លោក **ង៉ែត បុល,** អនុការិយាល័យគ្រប់គ្រងការបំពុលនៃក្រសួងបរិស្ថាន
10. លោក **ឈុន សីហា**, អនុប្រធានការិយាល័យវាយតម្លៃភាពងាយរងគ្រោះ និងបន្សុាំនឹងការប្រែប្រួលអាកាសធាតុ, ក្រសួងបរិស្ថាន
11. លោក **មាស រិទ្ធី**, អនុប្រធានការិយាល័យអង្គការជាតិ និងអន្តរជាតិ នៃនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងកិច្ចការអាស៊ាន
12. លោក **លី រតនា**, សាស្ត្រាចារ្យនៃសាកលវិទ្យាល័យស្វាយរៀង
13. លោក **គង់ គីមស្រេង** មន្ត្រីគម្រោង IUNC និង
14. លោក **លី ចាន់ភក្តី** មន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ៧.៩ ឯកសារបណ្តុះបណ្តាល (Resource Materials)

ក) កម្រងឯកសារវគ្គបណ្តុះបណ្តាលសម្រាប់ការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរនៅក្នុងតំបន់សមុទ្រអាស៊ីបូព៌ា (ភាសាខ្មែរ និងអង់គ្លេស)

ខ) កម្មវិធីថ្នាក់តំបន់សំរាប់ការគ្រប់គ្រងការហូរច្រោះតំបន់ឆ្នេរផ្អែកលើអេកូស៊ីស្ទែមនិងប្រកបដោយនិរន្តរភាពនៅក្នុងតំបន់សមុទ្រអាស៊ីបូព៌ា (ភាសាអង់គ្លេស)

គ) ការបញ្ហាបបញ្ហាដែលកំពុងកើតឡើងនិងវិធីសាស្ត្រគ្រប់គ្រងថ្មីៗសម្រាប់ការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរសមុទ្រនៅក្នុងប្រទេសកម្ពុជា (ភាសាខ្មែរនិងអង់គ្លេស)

ឃ) ការធ្វើផែនការប្រើប្រាស់តំបន់សមុទ្រៈ វិធីសាស្ត្រជំហានៗឆ្ពោះទៅរកការរៀបចំការគ្រប់គ្រងដោយផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែម (EBM) (ភាសាអង់គ្លេស)

ង) ឯកសារបណ្តុះបណ្តាលថ្នាក់តំបន់ស្តីអំពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយសំរាប់អ្នកគ្រប់គ្រងតំបន់ឆ្នេរសមុទ្រ (ភាសាអង់គ្លេស)

ច) ការគ្រប់គ្រង និងអភិរក្សតំបន់ឆ្នេរសមុទ្រថ្នាក់ជាតិ (ភាសាខ្មែរ និងអង់គ្លេស)

ឆ) យុទ្ធសាស្ត្រគ្រប់គ្រងឆ្នេរសមុទ្រថ្នាក់ជាតិ (ភាសាខ្មែរ និងអង់គ្លេស)

ជ) ស្ថានភាពនៃការគ្រប់គ្រងតំបន់ឆ្នេរសមុទ្រនៅក្នុងប្រទេសកម្ពុជា (ភាសាខ្មែរ និងអង់គ្លេស)

ឈ) ពង្រាងយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ឆ្នេរសមុទ្រថ្នាក់ជាតិ (ភាសាខ្មែរ និងអង់គ្លេស)

ញ) ច្បាប់ និងគោលនយោបាយដីធ្លី (ភាសាអង់គ្លេស)

ដ) សារាចរណែនាំ និងគោលនយោបាយផែនការប្រើប្រាស់ដីថ្នាក់ជាតិ (ភាសាខ្មែរ និងអង់គ្លេស)

ឋ) យុទ្ធសាស្ត្រជាតិសមាហរណកម្មតំបន់ឆ្នេរ និង ប្លង់គោលខេត្តព្រះសីហនុសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព

ឌ) ការកំណត់ការប្រើប្រាស់ដីតំបន់ឆ្នេរសមុទ្រខេត្តព្រះសីហនុ (ភាសាខ្មែរ និងអង់គ្លេស)

ឍ) យុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសំរាប់ប្រទេសកម្ពុជា (ភាសាខ្មែរ និងអង់គ្លេស) និង

ណ) ការកសាងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុតំបន់ឆ្នេរសមុទ្រអាស៊ីអាគ្នេយ៍

## ៧.១០ ពេលវេលា និងផែនការ

វាពិតជាមានសារៈសំខាន់ខ្លាំងណាស់ដើម្បីអនុវត្តបន្តនូវលទ្ធផលទទួលបានពីវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់។ ការរៀបចំនូវតារាងពេលវេលាច្បាស់លាស់និងដោយមានការទទួលខុសត្រូវជាមួយអ្នកពាក់ព័ន្ធដែលបានកំណត់អាចធានាបាននូវភាពជោគជ័យ ។ ខាងក្រោមនេះគឺជាតារាងពេលវេលា និងអ្នកទទួលខុសត្រូវលើការងារនេះតាមដំណាក់កាលនានាដូចជាៈ

| ការងារ | កាលបរិច្ឆេទ | អ្នកទទួលខុសត្រូវ |
|---|---|---|
| ក) បញ្ចប់ឯកសារបណ្តុះបណ្តាល និង ស្នើសុំឱ្យមានការឯកភាព | ០៣ សីហា ២០១២ | ជនបង្គោលថ្នាក់ជាតិ និង មន្ត្រីជំនាញថ្នាក់ជាតិ |
| ខ) រៀបចំកម្មវិធីបណ្តុះបណ្តាលផ្លូវការ | ៣១ សីហា | មន្ត្រីជំនាញថ្នាក់ជាតិ |

| | | |
|---|---|---|
| | ២០១២ | |
| គ) កំណត់ និងអញ្ជើញគ្រូបណ្តុះបណ្តាល/ វាគ្មិន/ ប្រធានកិច្ចប្រជុំ | មិថុនា-កញ្ញា ២០១២ | អ្នកសម្របសម្រួល ថ្នាក់ជាតិ និងមន្ត្រីជំនាញថ្នាក់ជាតិ |
| ឃ) កំណត់កាលបរិច្ឆេទរៀបចំវគ្គបណ្តុះបណ្តាល | ១៦ កក្កដា ២០១២ | អ្នកសម្របសម្រួលថ្នាក់ជាតិ/ជនបង្គោលថ្នាក់ជាតិ/ មន្ត្រីជំនាញ ថ្នាក់ជាតិ |
| ង) ការរៀបចំឯកសារ | ០១សីហា-កញ្ញា ២០១២ | អ្នកសម្របសម្រួលថ្នាក់ជាតិ និង មន្ត្រីជំនាញថ្នាក់ជាតិ |
| ច) អញ្ជើញសិក្ខាកាម | សីហា-កញ្ញា ២០១២ | អ្នកសម្របសម្រួលថ្នាក់ជាតិ និង មន្ត្រីជំនាញថ្នាក់ជាតិ |
| ឆ) រៀបចំវគ្គបណ្តុះបណ្តាល | ១-៣ តុលា ២០១២ | អ្នកសម្របសម្រួលថ្នាក់ជាតិ/ ជនបង្គោលថ្នាក់ជាតិ/ មន្ត្រីជំនាញ ថ្នាក់ជាតិ |
| ជ) បញ្ចប់ និងដាក់ជូននូវរបាយការណ៍ វគ្គបណ្តុះបណ្តាល | ០១ ធ្នូ ២០១២ | អ្នកសម្របសម្រួលថ្នាក់ជាតិ/ ជនបង្គោលថ្នាក់ជាតិ/ មន្ត្រីជំនាញ ថ្នាក់ជាតិ |

## ៨. ត្រួតពិនិត្យ និងវាយតម្លៃវគ្គបណ្តុះបណ្តាល

ប្រពន្ធ័ត្រួតពិនិត្យ និងវាយតម្លៃនឹងត្រូវដាក់បញ្ចូល និងសម្របទៅតាមគោលបំណងនៃការរៀបចំព័ត៌មានស្តីពីផែនការប្រើប្រាស់តំបន់ឆ្នេរដែលបានកំណត់ទុកពីដំបូងព្រោះវាជាសមាសភាពដ៏សំខាន់សំរាប់ការគ្រប់គ្រង។ សូមមើលក្របខណ្ឌគ្រប់គ្រងនៃដំណើរការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរសមុទ្រដូចមានក្នុងតារាងខាងក្រោម:

### រូបភាពទី៣ៈ ក្របខណ្ឌគ្រប់គ្រង និងការធ្វើផែនការ [៥]




ការត្រួតពិនិត្យ និងវាយតម្លៃនឹងផ្សារភ្ជាប់រវាងអ្នកធ្វើផែនការ និងអ្នកគ្រប់គ្រងឱ្យរៀនសូត្រពីបទពិសោធន៍ និងជួយរដ្ឋាភិបាលកម្ពុជា និងភ្នាក់ងារផ្តល់ជំនួយរបស់ខ្លួននៅគ្រប់កំរិតទាំងអស់ដើម្បីត្រួតពិនិត្យនូវប្រសិទ្ធភាពនៃវគ្គបណ្តុះបណ្តាលការធ្វើផែនការប្រើប្រាស់តំបន់សមុទ្រ និងការអនុវត្តការគ្រប់គ្រង។ កម្មវិធីបណ្តុះបណ្តាលនេះនឹងត្រូវបានត្រួតពិនិត្យយ៉ាងហ្មត់ចត់ និងធ្វើការវាយតម្លៃភ្លាមៗតាមប្រព័ន្ធផ្លូវការមួយ។ ការរកឃើញនានាពីការវាយតម្លៃវគ្គបណ្តុះបណ្តាលនេះនឹងត្រូវបានរាយការណ៍ជូនដល់អ្នកពាក់ព័ន្ធនានាដើម្បីឱ្យបានយល់ដឹងបន្ថែមទៀតអំពីសមិទ្ធផលនានា និងចំនុចខ្វះខាតដើម្បីកែលំអរឱ្យបានល្អប្រសើរជាងនេះទៅទៀតនៅពេលអនាគត។ គេរំពឹងថាការទំនាក់ទំនងគ្នាប្រកបដោយអត្ថន័យនេះជាមួយនឹងការចូលរួមជាសាធារណៈ និងពីបណ្តាអ្នកធ្វើសេចក្តីសំរេចចិត្តក្នុងការរៀបចំប្រព័ន្ធត្រួតពិនិត្យនឹងនាំមកនូវភាពជោគជ័យ។

## ៩. កិច្ចការបន្តនិងការផ្តល់អនុសាសន៍សម្រាប់អនុវត្តបន្ទាប់ពីវគ្គបណ្តុះបណ្តាល

ទស្សនៈទាននៃវិធីសាស្ត្របណ្តុះបណ្តាលនេះអាចបញ្ជ្រាបទៅថ្នាក់ក្រោមជាតិ។ ដើម្បីធានាឱ្យបាននូវលទ្ធផលល្អខេត្តតាមតំបន់គោលដៅត្រូវបានលើកទឹកចិត្តឱ្យរៀបចំនូវវគ្គបណ្តុះដូចគ្នានេះដែរ។ តែទោះជាយ៉ាងណាក៏ដោយដើម្បីរៀបចំវគ្គបណ្តុះបណ្តាលបែបនេះ ការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុគឺជាការចាំបាច់ខ្លាំងណាស់។ ថ្នាក់ជាតិនឹងផ្តល់ការគាំទ្របច្ចេកទេស

[៥] សិក្ខាសាលារបស់អង្គការ UNESCO ស្តីអំពីការធ្វើផែនការប្រើប្រាស់តំបន់សមុទ្រ និងការគ្រប់គ្រងការប្រើប្រាស់តំបន់សមុទ្រដោយផ្អែកលើប្រព័ន្ធអេកូស៊ីស្ទែម (ឆ្នាំ២០០៦)

ចំណែកឯជំនួយហិរញ្ញវត្ថុអាចធ្វើការស្នើសុំទៅម្ចាស់ជំនួយ ឬក៏ត្រូវរៀបចំគម្រោងសំណើដាក់ទៅអង្គការក្រៅរដ្ឋាភិបាលនានាដែលកំពុងអនុវត្តគម្រោងនៅតាមបណ្តាខេត្ត តំបន់ឆ្នេរឧទាហរណ៍ អង្គការ IUCN កំពុងធ្វើការអនុវត្តគម្រោងលើការកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុនៅតំបន់អាស៊ីអាគ្នេយ៍នៅក្នុងខេត្តកោះកុង។ ជាងនេះទៅទៀត គម្រោងភាពជាដៃគូក្នុងការគ្រប់គ្រងបរិស្ថានសមុទ្រនៃតំបន់អាស៊ីបូព៌ា (PEMSEA) គឺកំពុងអនុវត្តនៅក្នុងខេត្តព្រះសីហនុ ដូចច្នេះហើយគេអាចពិចារណាដើម្បីបង្កើនវិសាលភាពការងារសំរាប់ខេត្តតាមតំបន់ឆ្នេរ ដើម្បីកសាងសមត្ថភាព និងផ្សព្វផ្សាយឱ្យមានការយល់ដឹងដើម្បីបន្សុាំនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយដែលចេះតែកើនឡើងនេះ។ វគ្គបណ្តុះបណ្តាលបន្តបន្ទាប់ទៀតផ្តោតសំខាន់នៅថ្នាក់ក្រោមជាតិរួមមាន សហគមន៍ និងអាជ្ញាធរមូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងតាមបណ្តាសាលារៀននានា។ មន្ទីរបរិស្ថានខេត្ត និងមន្ទីរពាក់ពន្ធ័នឹងដឹកនាំការងារនេះ។

## ១០. សេចក្តីសន្និដ្ឋាន

កម្រងឯកសារបណ្តុះបណ្តាលនេះបានចាត់ទុកការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរថាជាបរិស្ថាន សង្គម ច្បាប់ និងកម្មវិធីរូបវន្តនៅក្នុងប្រទេសកម្ពុជា។ លិខិត អនុញ្ញាត ក្បួនច្បាប់ និង បទបញ្ញត្តិនានានៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់តំបន់ត្រូវបានត្រួតដើម្បីធានា ការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរសមុទ្រប្រកបដោយជោគជ័យដោយសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការបង្កើតទំនាក់ទំនងល្អនិងការទទួលយកបានដោយអ្នកពាក់ពន្ធ័ទាំងអស់។ ការយកចិត្តទុកដាក់លើបរិស្ថាន និង ការលើកទឹកចិត្តឱ្យមានការវិនិយោគចាំបាច់ត្រូវវាយតម្លៃទៅលើផលប៉ះពាល់សំខាន់ៗនៅក្នុងការធ្វើផែនការ និងការប្រតិបត្តិតាមពេលវេលា។ វគ្គបណ្តុះបន្តបន្ទាប់ទៀតនឹងផ្តោតសំខាន់ទៅលើថ្នាក់ក្រោមជាតិរួមមានៈប្រធានសហគមន៍ និងអាជ្ញាធរមូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាល អង្គការជាតិ និងតាមបណ្តាសាលារៀននានា។ មន្ទីរបរិស្ថានខេត្ត និងមន្ទីរពាក់ពន្ធ័នឹងដឹកនាំការងារនេះ។

## ឧបសម្ព័ន្ធ១: បញ្ជីរសំនួរវាយតម្លៃវគ្គបណ្តុះបណ្តាល

**តារាងត្រួតពិនិត្យ និងវាយតម្លៃវគ្គបណ្តុះបណ្តាលអំពីការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរដើម្បីដោះស្រាយទៅនឹងបញ្ហា កំពុងកើតមានឡើង**

កំឡុងពេលៈ.........................     ទីតាំងបណ្តុះបណ្តាលៈ..................................................

ចំណេះដឹង/កម្មវត្ថុ/គោលបំណងនៃវគ្គ (សូមសរសេរដោយផ្ទាល់/តាមការយល់)ៈ

| សំនួរវាយតម្លៃ | សូមឱ្យពិន្ទុពី ១-៥<br>(សូមគូសរង្វង់ចំពោះលេខមួយណាដែលអ្នកយល់ថាសមស្រប) | |
|---|---|---|
| ១) តើអ្នកមានអារម្មណ៍ថា វគ្គបណ្តុះ បណ្តាលនេះ ឆ្លើយតបទៅនឹងគោលបំណងរៀនសូត្ររបស់អ្នកដែរឬទេ? | ១. មិនឆ្លើយតប | ១ |
| | ២. | ២ |
| | ៣. | ៣ |
| | ៤. | ៤ |
| | ៥. ឆ្លើយតបពេញលេញ | ៥ |
| ២. តើរយៈពេលបណ្តុះបណ្តាលនេះដូចម្តេច ដែរ? | ១. ខ្លីពេក មិនអាចរៀនបានគ្រប់គ្រាន់នៅក្នុងរយៈពេលខ្លី | ១ |
| | | ២ |

| សំនួរវាយតម្លៃ | សូមឱ្យពិន្ទុពី ១-៥<br>(សូមគូសរង្វង់ចំពោះលេខមួយណាដែលអ្នកយល់ថាសមស្រប) | |
|---|---|---|
| | ២. ដូចជារាងខ្លីបន្តិច<br>៣. ល្មម<br>៤. ដូចជារាងយូរបន្តិច<br>៥. យូរណាស់ ទស្សនៈទានទាំងនេះអាចរៀនបានក្នុងរយៈពេលតិចជាងនេះ។ | ៣<br>៤<br>៥ |
| ៣. តើសំភារៈសំរាប់វគ្គបណ្តុះបណ្តាលនេះ មានសារៈសំខាន់ដែរឬទេ? សូមរាយនាមឯកសារសំខាន់ៗដែលអ្នកបាន ទទួល? | ១. មិនសំខាន់។ វាមានលក្ខណៈពិបាកយល់<br>២.<br>៣.<br>៤.<br>៥. មានសារៈសំខាន់ មានភាពងាយស្រួលយល់ | ១<br>២<br>៣<br>៤<br>៥ |
| ៤. តើការពន្យល់ផ្ទាល់មាត់របស់គ្រូ បង្រៀន/អ្នកបណ្តុះបណ្តាល/អ្នកសម្របសម្រួល ពិតជាមានអត្ថន័យបន្ថែមលើសំភារៈ ដែលលោកអ្នកបានទទួលដែរ ឬទេ? | ១. មិនបានបន្ថែមអត្ថន័យ/តម្លៃ ចំពោះសំភារៈបណ្តុះបណ្តាលទេ។<br>២.<br>៣.<br>៤.<br>៥. បាទ ការពន្យល់បន្ថែមផ្ទាល់មាត់ពិតជាមានអត្ថន័យ និង សារៈសំខាន់ខ្លាំងណាស់ | ១<br>២<br>៣<br>៤<br>៥ |

| សំនួរវាយតម្លៃ | សូមឱ្យពិន្ទុពី ១-៥<br>(សូមគូសរង្វង់ចំពោះលេខមួយណាដែលអ្នកយល់ថាសមស្រប) | |
|---|---|---|
| ៥. តើគ្រូបង្រៀន/គ្រូបណ្ដុះបណ្ដាល/ អ្នកសម្របសម្រួលបានពន្យល់ ឬឆ្លើយសំនួររបស់អ្នកចូលរួមយ៉ាងដូចម្ដេចដែរ? | ១. ការពន្យល់ ឬឆ្លើយសំនួរ នៅមានកម្រិតខ្លាំង។ មិនបានព្យាយាមពន្យល់សំនួរ ឬមិនព្យាយាមផ្ដល់ចំលើយដែលមានសារៈសំខាន់នោះទេ។<br>២.<br>៣.<br>៤.<br>៥. ឆ្លើយសំនួរបានយ៉ាងល្អ | ១<br>២<br>៣<br>៤<br>៥ |
| ៦. តើគ្រូបង្រៀន/អ្នកបណ្ដុះបណ្ដាល/ អ្នកសម្របសម្រួលបានជួយដល់ការធ្វើការជាក្រុម/បុគ្គលដែរឬទេ (ប្រសិនបើមាន) | ១. ទេ មិនមានពេលគ្រប់គ្រាន់ និងមិនសូវបានជួយដល់ការងារជាក្រុម/បុគ្គលនោះទេ។<br>២.<br>៣.<br>៤.<br>៥. បាទពិតជាបានជួយដល់ការធ្វើការជាក្រុម/បុគ្គល | ១<br>២<br>៣<br>៤<br>៥ |
| ៧. តើការធ្វើការងារជាក្រុម/បុគ្គល មានលក្ខណៈពិបាកយ៉ាងដូចម្ដេចទៅ? (ប្រសិនបើមាន) | ១. ពិបាកខ្លាំងណាស់។ មិនបានជួយ ឬក៏មិនបានលើកទឹកចិត្តឱ្យអ្នកអនុវត្តដំបូងនោះបាន ដឹងច្បាស់អំពីឧបករណ៍ និងទស្សនទាននោះទេ។<br>២. រាងពិបាកបន្តិច។ វាអាចប្រសើរជាងនេះប្រសិនបើ | ១<br>២<br>៣<br>៤ |

| សំនួរវាយតម្លៃ | សូមឱ្យពិន្ទុពី ១-៥<br>( សូមគូសរង្វង់ចំពោះលេខមួយណាដែលអ្នកយល់ថាសមស្រប) | |
|---|---|---|
| | មានការពន្យល់ និងរៀបរាប់ឱ្យបានលំអិតជាងនេះ<br>៣. ល្មមជួយឱ្យខ្ញុំអាចស្វែងរកចំលើយ ប្រើប្រាស់នូវបទពិសោធន៏ និងស្វែងរកចំលើយដោយខ្លួនឯងផ្ទាល់<br>៤. មានភាពងាយស្រួលសំរាប់ក៏រិតបច្ចេកទេសផ្ទាល់ខ្លួនខ្ញុំ<br>៥. មានភាពងាយស្រួលសំរាប់សិក្ខាកាមគ្រប់គ្នា។ គួរតែ ជួយឱ្យសិក្ខកាមទាំងអស់បានអនុវត្តជាក់ស្តែងគ្រប់ៗគ្នា | ៥ |
| ៨. តើមានពេលវេលាគ្រប់គ្រាន់ដែរឬទេ សម្រាប់ការធ្វើការងារជាក្រុម/បុគ្គល? | ១. មិនគ្រប់គ្រាន់ទេ ត្រូវការពេលវេលាបន្ថែមសំរាប់អនុវត្ត ការងារជាក្រុម/បុគ្គល<br>២. ត្រូវការពេលវេលាបន្តិចទៀត<br>៣. ល្មម<br>៤. បើបន្ថយពេលបន្តិចក៏គ្រប់គ្រាន់ដែរ<br>៥. មិនចាំបាច់ចំណាយពេលវេលាច្រើនសំរាប់ធ្វើការងារ ជាក្រុមនោះទេ។ អនុវត្តនៅកន្លែងធ្វើការពិតជាចាំបាច់។ | ១<br>២<br>៣<br>៤<br>៥ |
| ៩. តើអ្នកធ្វើចំណាត់ថ្នាក់យ៉ាងដូចម្តេចដែរ ចំពោះបរិយាកាសសិក្ខាសាលា/វគ្គបណ្តុះ | ១. អន់ | ១ |

| សំនួរវាយតម្លៃ | សូមឱ្យពិន្ទុពី ១-៥<br>(សូមគូសរង្វង់ចំពោះលេខមួយណាដែលអ្នកយល់ថាសមស្រប) | |
|---|---|---|
| បណ្តាល (ទំហំ បន្ទប់ ឧបករណ៍ប្រើប្រាស់ បរិយាកាសនៅក្នុងពេលបណ្តុះបណ្តាល? | ២.<br>៣.<br>៤.<br>៥. ពិតជាល្អណាស់ | ២<br>៣<br>៤<br>៥ |
| ១០. តើវគ្គនីមួយៗរៀបចំយ៉ាងដូចម្តេចដែរ? (ការចុះឈ្មោះពេលវេលាការសំរាក ការរៀបចំអាហារសម្រន់)? | ១. មិនបានល្អ<br>២.<br>៣.<br>៤.<br>៥. ពិតជាល្អណាស់ | ១<br>២<br>៣<br>៤<br>៥ |
| ១១. តើវគ្គនេះមានសារៈសំខាន់បែបណា ដែរចំពោះការងារប្រចាំថ្ងៃរបស់លោកអ្នក? | ១. មិនសូវមានសារៈសំខាន់<br>២.<br>៣.<br>៤.<br>៥. ពិតជាមានសារៈសំខាន់ណាស់ ។ វានឹងធ្វើការ អនុវត្ត ការងាររបស់ខ្ញុំកាន់តែងាយស្រួល និងបានទទួលលទ្ធផលច្រើន ។ | ១<br>២<br>៣<br>៤<br>៥ |

<table>
<tr><th>សំនួរវាយតម្លៃ</th><th colspan="2">សូមឱ្យពិន្ទុពី ១-៥<br>(សូមគូសរង្វង់ចំពោះលេខមួយណាដែលអ្នកយល់ថាសមស្រប)</th></tr>
<tr><td rowspan="5">១២. ការធ្វើចំណាត់ថ្នាក់ជារួមអំពីវគ្គនេះ (យោងតាមការយល់ឃើញផ្ទាល់ខ្លួន)</td><td>១. មិនពេញចិត្ត</td><td>១</td></tr>
<tr><td>២. ជិតល្អ</td><td>២</td></tr>
<tr><td>៣. ល្អ</td><td>៣</td></tr>
<tr><td>៤. ល្អប្រសើរ</td><td>៤</td></tr>
<tr><td>៥. ល្អណាស់</td><td>៥</td></tr>
<tr><td colspan="3">មតិកែលំអ (ប្រសិនបើមាន)</td></tr>
</table>

| | |
|---|---|
| ហត្ថលេខា | |
| ឈ្មោះ | |
| តួនាទី/នាយកដ្ឋាន | |
| អង្គការ/ស្ថាប័ន | |

## ១១. លទ្ធផល និងបទពិសោធន៍ទទួលបានពីវគ្គបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលថ្នាក់ជាតិស្តី **ការធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរដើម្បីដោះស្រាយទៅនឹងបញ្ហាកំពុងកើតមានឡើង** ត្រូវបានរៀបចំឡើងក្រោមអធិបតី ភាពឯកឧត្តម **ខុង សំនួន** រដ្ឋលេខាធិការក្រសួងបរិស្ថាន, ឯកឧត្តម **សូត យ៉ា** អភិបាលរងខេត្តកំពត និងតំណាងមកពីអង្គភាព COBSEA រយៈពេលបីថ្ងៃចាប់ពីថ្ងៃទី០១-០៣ ខែតុលា ឆ្នាំ២០១២ នៅមន្ទីរបរិស្ថានខេត្តកំពត ។ វគ្គបណ្តុះបណ្តាលនេះមានសារសំខាន់ណាស់ទាំងសម្រាប់មន្ត្រីរាជការថ្នាក់ជាតិ និង ថ្នាក់មូលដ្ឋាន ជាពិសេសប្រជាជនសហគមន៍ដែលជាអ្នកទទួលផលប៉ះពាល់ដោយផ្ទាល់ពីការប្រែប្រួលអាកាសធាតុនិងបញ្ហាគ្រោះមហន្តរាយកំពុងកើតឡើងនូវតំបន់ឆ្នេរសមុទ្រ ។ អ្នកចូលរួមទាំងអស់បានបង្ហាញនូវការគាំទ្រ និងកិច្ចសហប្រតិបត្តិការក្នុងការអនុវត្តផែនការបែងចែកការប្រើប្រាស់ដីតំបន់ឆ្នេរសមុទ្រ ។ ជាមួយគ្នានោះដែរ យើងឃើញថាមានការចូលរួមយ៉ាងសកម្មពីថ្នាក់ដឹកនាំក៏ដូចជាមន្ត្រីក្រោមឱវាទថ្នាក់ខេត្តក្នុងការផ្តល់ទីតាំងនិងរៀបចំវគ្គបណ្តុះបណ្តាលរហូតទទួលបានជោគជ័យជាទីមោទនៈ ។

វគ្គបណ្តុះបណ្តាលនេះ មានវាគ្មិនចំនួនជាងដប់នាក់មកពីស្ថានប័នពាក់ព័ន្ធត្រូវបានអញ្ជើញដើម្បីធ្វើបទបង្ហាញចែករំលែកនូវទ្រឹស្តី និងបទពិសោធន៍ជាក់ស្តែងដែលបានអនុវត្តកន្លងមក ។ វគ្គបណ្តុះបណ្តាលនេះ មានសិក្ខាកាមចូលរួមចំនួន៥០នាក់មកពីបណ្តាក្រសួងពាក់ព័ន្ធ តំណាងមន្ទីរពាក់ព័ន្ធនៃបណ្តាខេត្តតំបន់ឆ្នេរទាំងអស់អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នសិក្សា ។ និតិវិធីនៃវគ្គបណ្តុះបណ្តាលនេះចាប់ផ្តើមឡើងដោយមានវាគ្មិនធ្វើបទបង្ហាញបន្ទាប់មកទុកពេល ពី១៥-២០នាទី សម្រាប់សមាជិក សមាជិកាចូលរួមទាំងអស់លើកជាសំនួរ រឺផ្តល់នូវអនុសាសន៍សម្រាប់កែលំអរ ។ តាមការកត់សម្គាល់ឃើញថា សមាជិក សមាជិកាទាំងអស់មានការចូលរួមយ៉ាងសស្រាក់សស្រាំដោយបានលើកជាសំនួរ និងផ្តល់អនុសាសន៍បន្ថែមសំខាន់ៗមួយចំនួនដល់វាគ្មិនទាំងនោះ ។

ដូចដែលបានរៀបរាប់ខាងលើវគ្គបណ្តុះបណ្តានេះមិនអាចទទួលបានជោគជ័យទេប្រសិនបើគ្មានការសហការ និងគាំទ្រពីប្រធានដឹកនាំ វាគ្មិន និងការចូលរួមយ៉ាងសកម្មពីសិក្ខាកាមទាំងអស់នោះ ។ ការរៀបចំប្រកបដោយជោគជ័យនេះបានផ្តល់នូវបទពិសោធន៍សម្រាប់ការអនុវត្តនៅពេលខាងមុខប្រសិនបើមានការរៀបចំវគ្គបណ្តុះបណ្តាលស្រដៀងគ្នានេះ ។ ម្យ៉ាងវិញ ការរៀបចំវគ្គបណ្តុះបណ្តាលនេះទទួលបានជោគជ័យដោយសារការដឹកនាំ និងចាត់ចែងដ៏ល្អរបស់ប្រធានគម្រោង និងការចូលរួមយ៉ាងសកម្មពីសំណាក់មន្ត្រីគម្រោងទាំងអស់ ។ ជាការពិត ការសម្របសម្រួលដើរតួនាទីយ៉ាងសំខាន់ដើម្បីទទួលបានការចូលរួមពីស្ថាប័នពាក់ព័ន្ធទាំងអស់ជាមួយគ្នានោះដែរ យើងត្រូវតែរៀបចំផែនការគម្រោងឱ្យបានជាក់លាក់ដើម្បីអនុវត្តដោយរលូន និងជោគជ័យ ។

## ជំពូកទី ៦ លទ្ធផល និងបទពិសោធន៍ទទួលបានពីការអនុវត្តគម្រោង

គម្រោង "***ការធ្វើផែនការបែងចែកការប្រើប្រាស់តំបន់ឆ្នេរ-ការការពារគ្រោះមហន្តរាយ និងការអភិវឌ្ឍប្រកបដោយចីរភាព***" បានអនុវត្តក្នុងឆ្នាំ២០១០។ តាំងពីការចាប់ផ្តើមអនុវត្តគម្រោង ប្រទេសកម្ពុជាទទួលបាននូវឱកាសជាច្រើនដើម្បីចូលរួមជាមួយប្រទេសជាសមាជិករបស់អង្គភាព COBSEA និងទីប្រឹក្សាអន្តរជាតិតាមរយៈកម្មវិធីសិក្ខាសាលាថ្នាក់តំបន់ដើម្បីពិភាក្សា និងចែករំលែកបទពិសោធន៍ក្នុងការរៀបចំកម្រងឯកសារធនធានថ្នាក់តំបន់ដែលជាឯកសារមូលដ្ឋានសម្រាប់អនុវត្តន៍នៅតាមបណ្តាទេសនីមួយៗ។ ជាងនេះទៅទៀត គម្រោងនេះក៏បានផ្តល់ឱកាសឱ្យមន្ត្រីរាជការពីបណ្តាក្រសួងពាក់ព័ន្ធមួយចំនួននៅក្នុងប្រទេសកម្ពុជាបានចូលរួមក្នុង **កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ** ដោយមានការចូលរួមពីតំណាង COBSEA នៅទីក្រុងបាងកក ប្រទេសថៃផងដែរ ដើម្បីពិភាក្សា និងផ្តល់យោបល់លើតម្រូវការកសាងសមត្ថភាពជាតិ។ តាមរយៈកិច្ចប្រជុំពិគ្រោះយោបល់នេះធ្វើឱ្យប្រទេសកម្ពុជាអាចកំណត់នូវតម្រូវការ ភាពខ្វះចន្លោះ និងឱកាសសម្រាប់ការអនុវត្តផែនការ និងសកម្មភាពជាក់ស្តែង។

ជាមួយគ្នានោះដែរ យើងកត់សម្គាល់ឃើញថា បន្ទាប់ពីការចុះហត្ថលេខារវាងក្រសួងបរិស្ថាន និងកម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP) ដែលតំណាងដោយលេខាធិការដ្ឋានអង្គភាព COBSEA នៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១២ មកក្រុមការងារគម្រោងបានចូលរួមក្នុងសកម្មភាពផ្សេងៗយ៉ាងសកម្មដើម្បីអនុវត្តគម្រោង ជាក់ស្តែងក្រុមការងារបានចូលរួមក្នុង**វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់**នៅខេត្តភូកេត ប្រទេសថៃ ហើយតាមរយៈវគ្គបណ្តុះបណ្តាលនេះ ក្រុមការងារកម្ពុជាទទួលបាននូវចំណេះដឹង និងសមិទ្ធផលសំខាន់ៗដូចខាងក្រោមៈ

- ចំណេះដឹង និងបទពិសោធន៍ស្តីពីការរៀបចំផែនការបែងចែកការប្រើប្រាស់តំបន់ឆ្នេរសមុទ្រថ្មីៗ
- កែលំអ និងពង្រឹងនូវចំណេះដឹងដែលមានស្រាប់ផ្នែកការរៀបចំផែនការបែងចែកការប្រើប្រាស់តំបន់ឆ្នេរសមុទ្រ
- កែលំអ និងពង្រឹងសមត្ថភាពលើការសម្របសម្រួលជាមួយភាគីពាក់ព័ន្ធសម្រាប់ការងារគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រ
- អាចបញ្ច្រាបនូវការអនុវត្តល្អៗលើការងាររៀបចំផែនការបែងចែកការប្រើប្រាស់ និង ការគ្រប់គ្រងតំបន់ឆ្នេរសមុទ្រចម្រុះពីប្រទេសផ្សេងៗទៅក្នុងប្រទេសកម្ពុជា
- ទទួលបាននូវទស្សនទានជាមូលដ្ឋាន និងពាក្យបច្ចេកទេសទាក់ទងនឹងផែនការបែងចែកការប្រើប្រាស់តំបន់ឆ្នេរសមុទ្រ បញ្ហាកំពុងកើតឡើងនៅតំបន់ឆ្នេរសមុទ្រ ការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានីភ័យគ្រោះមហន្តរាយ និងអាចចែករំលែកនូវចំណេះដឹងនិងបទពិសោធន៍ដល់ភាគីពាក់ព័ន្ធ និង
- យល់ដឹងនូវអភិក្រមថ្មីៗនិងគ្រប់ជ្រុងជ្រោយលើការងារគ្រប់គ្រងនិងធ្វើផែនការប្រើប្រាស់តំបន់ឆ្នេរសមុទ្រ

ជាក់ស្តែង ក្រោយពីបានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់ ក្រុមការងារគម្រោងប្រទេសកម្ពុជាអាចអនុវត្ត គម្រោងជំហានទី៣ប្រកបដោយជោគជ័យ និងទាន់ពេលវេលា។ ជាក់ស្តែងក្រុមការងារគម្រោងបានសម្រេចនូវសមិទ្ធិផល ជាច្រើនរួមមាន:

- ការបកប្រែកម្រងឯកសារថ្នាក់តំបន់ស្តីពី ***"ការរៀបចំផែនការបែងចែកការប្រើប្រាស់តំបន់ឆ្នេរនៅអាស៊ីបូព៌ា: ការបញ្ច្រាបបញ្ហាកំពុងកើតឡើងនិងវិធីសាស្ត្រគ្រប់គ្រងថ្មីៗ "*** ជាភាសាជាតិដែលការបកប្រែនេះជួយសម្រួលដល់មន្ត្រីក៏ដូចជាភាគីពាក់អាចអាននិងយល់បាននូវអត្ថន័យ និងខ្លឹមសារបានស្រួលដោយសារតែមន្ត្រីនិងអ្នកពាក់ព័ន្ធភាគច្រើនមានការយល់ដឹងភាសាអង់គ្លេសតិចតួច។
- ការចងក្រងកម្រងឯកសារជាតិ ដោយរួមបញ្ចូលទាំងឯកសារធនធានថ្នាក់តំបន់ដែលឯកសារនេះជាកម្រងឯកសារដំបូងសម្រាប់ប្រទេសកម្ពុជា ស្តីពីការរៀបចំផែនការបែងចែកការប្រើប្រាស់តំបន់ឆ្នេរដើម្បីដោះស្រាយគ្រោះមហន្តរាយកំពុងកើតឡើង និងការប្រែប្រួលអាកាសធាតុ។ តាមរយៈឯកសារនេះធ្វើឱ្យអ្នកពាក់ព័ន្ធភាគច្រើនអាចយកធ្វើជាឯកសារយោង រឺអាចបង្កើតគំនិតថ្មីៗដើម្បីដោះស្រាយទៅនឹងបញ្ហាកំពុងកើតឡើងនៅតំបន់ឆ្នេរសមុទ្រ។
- ការរៀបចំកម្រងឯកសារបណ្តុះបណ្តាលដែលបានប្រើប្រាស់សម្រាប់វគ្គបណ្តុះបណ្តាលថ្នាក់ជាតិ
- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិដើម្បីអនុម័តលើកម្រងឯកសារធនធាន និង កម្រងឯកសារបណ្តុះបណ្តាល
- រៀបចំវគ្គបណ្តុះបណ្តាល**គ្រូបង្គោលថ្នាក់ជាតិ**ដោយជ្រើសរើសវាគ្មិនភាគច្រើន ដែលបានចូលរួមវគ្គបណ្តុះបណ្តាលថ្នាក់តំបន់។ ក្រៅពីនេះគម្រោងបានអញ្ជើញវាគ្មិនដែលមានចំណេះដឹង និងបទពិសោធន៍លើផ្នែកនេះមួយចំនួនទៀតមកពីស្ថានប័នពាក់ព័ន្ធដើម្បីចែករំលែកចំណេះ និងបទពិសោធន៍របស់ពួកគេដល់សិក្ខាកាមទាំងអស់ ហើយសង្ឃឹមថាពួកគេអាចមានសមត្ថភាពរៀបចំវគ្គបណ្តុះបណ្តាលស្រដៀងគ្នានៅតាមស្ថាប័ននីមួយៗនូវពេលដែលពួកគេមានថវិការៀបចំ។

ដូចដែលបានរៀបរាប់ខាងលើគម្រោងនេះបានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់ប្រទេសកម្ពុជាទាំងទ្រឹស្តីនិងការអនុវត្តជាក់ស្តែង ប្រសិនបើគ្មានគម្រោងនេះទេ សកម្មភាពដែលបានរៀបរាប់ខាងលើក៏មិនអាចទទួលបានដែរ។ អាស្រ័យហេតុក្នុងនាមជាជនបង្គោលជាតិនៃអង្គភាព COBSEA និងជាប្រទេសទទួលជំនួយពីអង្គការ SIDA ខ្ញុំសូមឆ្លៀតឱកាសនេះថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងសូមស្នើឱ្យអង្គការ SIDA បន្តផ្តល់ជំនួយដើម្បីអនុវត្តគម្រោង ជាក់ស្តែងនៅតាមបណ្តាខេត្តតំបន់ឆ្នេរដើម្បីឱ្យពួកគេអាចដោះស្រាយទៅនឹងគ្រោះមហន្តរាយ និង មានលទ្ធភាពកសាងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុនៅតំបន់ឆ្នេរសមុទ្រ។ កម្ពុជាពិតជាត្រូវការជំនួយជាចាំបាច់ទាំងផ្នែកបច្ចេកទេសនិងថវិកាដើម្បីអភិវឌ្ឍន៍ប្រទេស **ប្រកបដោយចីរភាពដែលជារួមបញ្ចូលនូវសេដ្ឋកិច្ចបៃតង និងសេដ្ឋកិច្ចពណ៌ខៀវ**។